00661492

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: D427/1/30

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី:** សរ ច័ន្ទរ៉ាត
Entela JOSIFI

**កាលបរិច្ឆេទ:** ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១

---

## សាធារណៈ:
## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH
សេង ប៊ុនឃាង

**<u>ជនជាប់ចោទ</u>**
អៀង សារី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 04 / 2011
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

00661493

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANNONE
Elisabeth RABESANDRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUNDZINSKY
Annie DELAHIE
Fabienne TRUSSES-NAPROUS
ស៊ិន សុវ៉ន
Patrick BAUDOIN
Marie GUIRAUD
Lyma Thuy NGUYEN
ពេជ អង្គ
ជេត វណ្ណលី
Laure DESFORGES
Isabelle DURAND
Francoise GAUTRY
Christinne MARTINEAU
Pascal AUBOIN
Ferdinand DJAMMEN-NZEPA
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
វ៉េន ពៅ

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង
Siegfried BLUNK

E.C.C.C ✶ C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

I. **ប្រវត្តិនីតិវិធី៖** ......................................................................................................... ៤

II. **បទបញ្ញត្តិ៖** ......................................................................................................... ១០

III. **សំអាងហេតុសម្រាប់ធ្វើសេចក្តីសម្រេច៖** ........................................................................ ១២

**ក. សេចក្តីសង្ខេបបណ្តឹងឧទ្ធរណ៍៖** ........................................................................ ១២

**ខ. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍៖** ........................................................ ២០

១. ភាពអាចទទួលយកបានជាផ្លូវការ៖ ........................................................................ ២០

២. ភាពអាចទទួលយកបានក្រោមវិធានផ្ទៃក្នុង៖ ........................................................ ២១

i) សេចក្តីសន្និដ្ឋានរបស់ភាគីនានាលើលក្ខខណ្ឌកំណត់អំពីភាពអាចទទួលយកបាន៖ ................. ២១

ii) ការពិចារណាជាទូទៅរបស់អង្គបុរេជំនុំជម្រះអំពីលក្ខខណ្ឌកំណត់
អំពីភាពអាចទទួលយកបាន៖ ........................................................................ ២៧

(ក) ភាពអាចទទួលយកបានស្របតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង៖ ................................ ២៧

(ខ) ភាពអាចទទួលយកបានតាមវិធាន ២១ នៃវិធានផ្ទៃក្នុង៖ ........................................ ៣១

(គ) បញ្ហាថាតើបណ្តឹងជំទាស់ផ្នែកយុត្តាធិការនៅក្នុងបណ្តឹងឧទ្ធរណ៍ត្រូវបានរារាំងដោយ
ពេលវេលាដែរឬទេ៖ ........................................................................ ៣៧

iii) ការពិនិត្យរបស់អង្គបុរេជំនុំជម្រះអំពីភាពអាចទទួលយកបានសម្រាប់មូលដ្ឋាននីមួយៗ នៃ
បណ្តឹងឧទ្ធរណ៍៖ ........................................................................ ៤០

(ក) មូលដ្ឋានទីមួយ (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) ៖ ........ ៤០

(ខ) មូលដ្ឋានទីពីរ (លើកលែងទោស និងអនុគ្រោះទោស) ៖ ........................................ ៤៣

(គ) មូលដ្ឋានទីបី (គោលការណ៍នីត្យានុកូលភាព) ៖ ........................................ ៤៥

(ឃ) មូលដ្ឋានទីបួន (យុត្តាធិការលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ) ៖ ... ៤៦

(ង) មូលដ្ឋានទីប្រាំ ((យុត្តាធិការលើបទល្មើសជាតិ) ៖ ........................................ ៤៨

(ច) មូលដ្ឋានទីប្រាំមួយ (ការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) ៖ ........................ ៤៩

(ឆ) មូលដ្ឋានទីប្រាំពីរ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ៖ ........................................ ៥០

(ជ) មូលដ្ឋានទីប្រាំបី (ការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ) ៖ ....... ៥៨

(ឈ) មូលដ្ឋានទីប្រាំបួន (ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម) ៖ ........................................ ៦០

(ញ) មូលដ្ឋានទីដប់ (ការអនុវត្តទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ) ៖ ................................ ៦១

(ដ) មូលដ្ឋានទីដប់មួយ (យុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើ) ៖ .................... ៦២

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

**គ. បទដ្ឋាននៃការពិនិត្យឡើងវិញ ៖ ..........................................................៦៥**

**ឃ. ការពិចារណាទៅលើអង្គសេចក្តី៖.................... .......................................៦៩**

១. មូលដ្ឋានទី១៖ (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ)៖.......... .......៦៩

២. មូលដ្ឋានទីពីរ៖ (ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស) ៖ ......................១០៧

៣. មូលដ្ឋានទីបី៖ (គោលការណ៍នីត្យានុកូលភាព) ៖ ..............................................១២៥

៤. មូលដ្ឋានទីប្រាំ៖ (បទល្មើសជាតិ) ៖ ............................................................១៦៤

៥. មូលដ្ឋានទីប្រាំពីរ៖(ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ៖ ........................................១៨៧

i) មូលដ្ឋានរងទី៣ (ចំណងទាក់ទង) ៖ ...............................................១៨៧

ii) មូលដ្ឋានរងទី១០ (ការដាក់ក្នុងមន្ទីរឃុំឃាំង) ៖ ..................................១៩៨

iii) មូលដ្ឋានរងទី១១ (ទណ្ឌកម្ម) ៖ ..................................................២១០

iv) មូលដ្ឋានរងទី១៤ (ការរំលោភលើផ្លូវភេទ) ៖ .....................................២២៣

v) មូលដ្ឋានរងទី១៥ (អំពើអមនុស្សធម៌ដទៃទៀត), មូលដ្ឋានរងទី១៦(ការរៀបការដោយបង្ខំ)
មូលដ្ឋានរងទី១៧ (អំពើហឹង្សាផ្លូវភេទ) និងមូលដ្ឋានរងទី១៩ (ការបាត់ខ្លួនដោយបង្ខំ) ៖ ......២៣៦

៦. មូលដ្ឋានទីដប់មួយ៖(ការទទួលខុសត្រូវរបស់ថ្នាក់លើ) ៖ ...................................២៥២

**ខ. សំអាងហេតុសម្រាប់ការឃុំខ្លួន៖ .........................................................២៩១**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ [របស់សហចៅក្រមស៊ើបអង្កេត]" ("បណ្តឹងឧទ្ធរណ៍ អៀង សារី")[១] ដែលដាក់នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។

# I. **ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ និងបានជូនដំណឹងភាគីនានាថា សហចៅក្រមស៊ើបអង្កេតបានពិចារណាអំពីការបញ្ចប់កិច្ចស៊ើបសួរ នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២")[២]។ សំណុំរឿង ០០២ ត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[៣]។

២. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន អនុលោមតាមវិធាន៦៦[៤] ដែលត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០។

៣. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ("ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា")[៥]។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីជូនដំណឹងអំពីការដាក់ឯកសារមានលក្ខណៈមិនគ្រប់គ្រាន់ ទាក់ទងនឹងការដាក់ចម្លើយតបរបស់សហមេធាវី

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, ឯកសារ D427/1/6 ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")។

[២] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០, ឯកសារ D317។

[៣] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤ ), ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ (វិធានផ្ទៃក្នុង) វិធាន៦៦នៃវិធានផ្ទៃក្នុង។

[៤] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០, ឯកសារ D390។

[៥] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D390/1/2/1.3។

ការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពរ[៦]។ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០ សហ មេធាវីការពារក្តី អៀង សារី បានដាក់ "បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី" ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០[៧]។ នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ចម្លើយតបរបស់សហមេធាវីការពារក្តី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ត្រូវដាក់នៅក្នុងសំណុំរឿង[៨]។

៤. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាដំណោះស្រាយ[៩] ដោយចោទប្រកាន់ជនជាប់ចោទ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[១០]។ ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃដដែល។

---

[៦] សេចក្តីជូនដំណឹងរបស់ក្រឡាបញ្ជីអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់ ការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃ ទី២ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2។

[៧] បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និង សេចក្តីអង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី, ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D390/1/2/1។

[៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីអង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/3។ សំអាងហេតុដែលមាននៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីអង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D390/1/2/4។

[៩] ដីកាដំណោះស្រាយ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427 (ដីកាដំណោះស្រាយ)។

[១០] ដីកាដំណោះស្រាយ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427, កថាខណ្ឌ ១៦១៣។

៥. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[១១]។ ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ត្រូវបានជូនដំណឹងនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។ នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានអនុញ្ញាតតាមសំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ ដែលមានចំនួនសរុប ១៨០ ទំព័រជាភាសាអង់គ្លេស[១២]។ ដោយសារតែស្ថានភាពវិសាមញ្ញ ដែលបង្កឱ្យមានទឹកលិចជុំវិញបរិវេណអគារ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យពន្យារពេលកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០។ សហមេធាវីការពារក្តី អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងទៅភាគីនានាជាភាសាអង់គ្លេសនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០ និងជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ ២០១០។

៦. នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ “សំណើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់”[១៣]។ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

---

[១១] ការចុះបញ្ជីបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០១០ D427/1។

[១២] សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលបានលើកនៅក្នុងដីកាដំណោះស្រាយ, ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/3។

[១៣] សំណើរបស់សហព្រះរាអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/5 ។

៧. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួមសួរថាតើខ្លួននឹងត្រូវបានអនុញ្ញាតឱ្យដាក់ចម្លើយតប ឬសេចក្តីអង្កេតលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែរឬយ៉ាងណា[១៤]។

៨. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញដីកាអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ទាំងនោះចុងក្រោយបំផុតជាភាសាអង់គ្លេស និងជាភាសាខ្មែរ[១៥]។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថាបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន បានលើកឡើងនូវមូលដ្ឋានដាច់ដោយឡែកពីគ្នានៃបណ្តឹងឧទ្ធរណ៍ និងយល់ឃើញថា វាមានលក្ខណៈសមរម្យសម្រាប់សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា[១៦]។ អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់ផងដែរអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្តីសង្កេត ដើម្បីគាំទ្រដល់ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃដាក់ចម្លើយតបរបស់សហព្រះរាជ អាជ្ញា[១៧]។

៩. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[១៨] និងនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ ចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងដល់ភាគីនានាជាភាសាខ្មែរ និងជាភាសាអង់គ្លេស។

---

[១៤] អ៊ីមែលចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ ពីមន្ត្រីកាន់សំណុំរឿងនៃអង្គភាពដើមបណ្តឹងរដ្ឋប្បវេណី ផ្ញើជូនក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ។

[១៥] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/8 (សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា), ទំព័រ៦។

[១៦] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[១៧] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ទំព័រ ៦។

[១៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២ ០១០, ឯកសារ D427/1/17 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

១០. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់សំណើសុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រកំណត់ ដើម្បីឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ("សំណើរបស់អៀង សារី")[១៩]។ សំណើរបស់ អៀង សារី បានជូនដំណឹងដល់ភាគីនានាជាភាសាខ្មែរ និងភាសាអង់គ្លេសនៅថ្ងៃដដែល។ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញការណែនាំដោយអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីទាំងអស់ ដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេល១០ថ្ងៃ ចាប់តាំងពីថ្ងៃជូនដំណឹង និងអនុញ្ញាតឲ្យ អៀង សារី ដាក់ការឆ្លើយតបចំនួន៧៥ទំព័រ។

១១. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីអង្កេតរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ("សេចក្តីអង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ជាភាសាខ្មែរ និងជាភាសាបារាំងប៉ុណ្ណោះ។ សេចក្តីអង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ជាភាសាខ្មែរ និងជាភាសាបារាំង។ សេចក្តីអង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់ និងត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១០[២០]។

១២. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទីពីរ បានដាក់សេចក្តីអង្កេតរបស់ខ្លួន ("សេចក្តីអង្កេត II របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ជាភាសាខ្មែរ និងជាភាសាបារាំងប៉ុណ្ណោះ[២១]។ សេចក្តីអង្កេត II របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាភាសា

---

[១៩] សំណើបន្ទាន់របស់លោក អៀង សារី សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រកំណត់ដើម្បីឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ បើសិនជាគ្មានសវនាការផ្ទាល់មាត់ដោយផ្ទាល់មាត់, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/16។

[២០] សារណារួមរបស់ *Advocats Sans Frontieres* France តំណាងដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ដែលជំទាស់នឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/18 ("សេចក្តីសង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១")។

[២១] សេចក្តីសង្កេតរួម ចំពោះបណ្តឹងឧទ្ធរណ៍ដាក់ដោយ លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/19 ("សេចក្តីសង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២")។

ខ្មែរ និងជាភាសាបារាំងប៉ុណ្ណោះ។ សេចក្តីអង្កេត II របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់ និងត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០។

១៣. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី បានដាក់សេចក្តីអង្កេតរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ("សេចក្តីអង្កេត III របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ជាភាសាខ្មែរប៉ុណ្ណោះ[២២]។ សេចក្តីអង្កេត III របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាភាសាខ្មែរ។ សំណៅជាភាសាអង់គ្លេសត្រូវបានជូនដំណឹង នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០។

១៤. នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ "សំណើជាបន្ទាន់សុំពន្យារថេរវេលាដើម្បីដាក់អត្ថបទបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលត្រូវបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ[២៣]។

១៥. នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ("សារណាឆ្លើយតប អៀង សារី")[២៤] ជាភាសាអង់គ្លេសប៉ុណ្ណោះ ដែលសារណាឆ្លើយតបនេះត្រូវបានជូនដំណឹងទៅភាគីនានា នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០។ ការបកប្រែសារណាឆ្លើយតប អៀង សារី ជាភាសាខ្មែរ ត្រូវបានដាក់ និងបានជូនដំណឹង នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០។

---

[២២] សេចក្តីសង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ជំទាស់នឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/20។ ("សេចក្តីសង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣")។

[២៣] សំណើជាបន្ទាន់សុំពន្យារថិរវេលាដើម្បីដាក់អត្ថបទបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារ D427/1/21។

[២៤] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០១០, ឯកសារ D427/1/23 ("សារណាឆ្លើយតបរបស់ អៀង សារី")។

១៦. នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ចម្លើយតបទៅនឹងសេចក្តីអង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[២៥] និងនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ សហមេធាវីការពារក្តី អៀង សារី បានដាក់ចម្លើយតបទៅនឹងសេចក្តីអង្កេត II របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[២៦]។ សហមេធាវីការពារក្តីរបស់ អៀង សារី មិនបានដាក់ចម្លើយតបទៅនឹងសេចក្តីអង្កេត III របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ។

១៧. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសជាលាយលក្ខណ៍អក្សរ **កំណត់អំពីសេចក្តីសម្រេចស្តាពរលើបណ្តឹងឧទ្ធរណ៍**ដោយបញ្ជាក់ថា "សំអាងហេតុសម្រាប់សាលដីកានេះនឹងចេញតាមពេលវេលាកំណត់"។

## II. **បទបញ្ញត្តិ**

**តាមរយៈនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីប្រាំ ទីប្រាំពីរ (មួយផ្នែក) និងទីដប់មួយ អាចទទួលយកបាន។ មូលដ្ឋានដែលនៅសល់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ។

៣. មូលដ្ឋានទីមួយ មិនត្រូវបានអនុញ្ញាត ហេតុដូច្នេះ ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរ មិនត្រូវបានអនុញ្ញាត ហេតុដូច្នេះ ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបី មិនត្រូវបានអនុញ្ញាត ហេតុដូច្នេះ ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីប្រាំ មិនត្រូវបានអនុញ្ញាត ហេតុដូច្នេះ ត្រូវបានបដិសេធ។

---

[២៥] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី *Advocats Sans Frontieres* France ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា, ជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារ D427/1/24 ("ចម្លើតតបរបស់ អៀង សារី ទៅនឹងសេចក្តីសង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១")។

[២៦] ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីសង្កេតរួមទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/1/25 ("ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីសង្កេតរបស់សហមេធាវីក្រុម២")។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. C.E.T.C. PRÉLIMINAIRE

៧. មូលដ្ឋានទីប្រាំពីរ ត្រូវបានអនុញ្ញាតចំពោះផ្នែកខ្លះដូចខាងក្រោម រីឯផ្នែកផ្សេងពីនេះ ត្រូវបានបដិសេធ។

១. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានពុំបានធ្វើការពិចារណាថា ក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឱ្យមានចំណងពាក់ព័ន្ធ រវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវបានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងជំពូក IV(ក) នៃដីកាដំណោះស្រាយ។

២. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

៨. មូលដ្ឋានទីដប់មួយ មិនត្រូវបានអនុញ្ញាត ហេតុដូច្នេះ ត្រូវបានបដិសេធ។

៩. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១០. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឱ្យបញ្ជូនខ្លួនឱ្យចូលរួមសវនាការដូចដែលបានចែងនៅក្នុងដីកាដំណោះស្រាយដែលត្រូវអានដំណាលគ្នាជាមួយនឹងសាលដីកានេះ។

១៧. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ត្រូវបានបង្គាប់/មិនត្រូវបានបង្គាប់ឱ្យបន្តចិរវេលា ផ្អែកតាមហេតុផលដែលបានគូសបញ្ជាក់នៅក្នុងសាលដីកានេះ រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំខ្លួនបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[២៧]។

១៨. នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសំអាងហេតុនានាសម្រាប់ការសម្រេចនៅក្នុងចំណុច ១១ នៃការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍[២៨]។

១៩. អង្គបុរេជំនុំជម្រះផ្តល់នូវសំអាងហេតុពេញលេញ សម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ។

## III. សំអាងហេតុសម្រាប់ធ្វើសេចក្តីសម្រេច ÷

## ក. សេចក្តីសង្ខេបសារណានានា ÷

<u>សំណើនៅក្នុងបណ្តឹងឧទ្ធរណ៍៖</u>

"មេធាវីការពារក្តីស្នើដោយក្តីគោរពសុំឱ្យអង្គបុរេជំនុំជម្រះមេត្តា ៖

ក. ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានតាមវិធាន ៧៤(៣)(ក) និងវិធាន២១។

ខ. សម្រេចថា អង្គជំនុំជម្រះមិនមានយុត្តាធិការចោទប្រកាន់បញ្ជូន លោក អៀង សារី ទៅជំនុំជម្រះដោយផ្អែកលើគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[២៩]។

---

[២៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26។

[២៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយសំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/1/27 ("សំអាងហេតុសម្រាប់បន្តការឃុំខ្លួន")។

[២៩] គោលការណ៍ *មិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ចែងថាតុលាការមិនត្រូវបង្កើតដំណើរការនីតិវិធីប្រឆាំងនឹងបុគ្គលម្នាក់ចំពោះឧក្រិដ្ឋកម្មមួយដែលជាកម្មវត្ថុនៃនីតិវិធីព្រហ្មទណ្ឌរួចហើយនោះទេ ហើយដែលជននោះត្រូវបានផ្តន្ទាទោស ឬត្រូវបានកាត់ឱ្យរួចទោសដោយសារបទល្មើសនោះរួចហើយនោះទេ។ គោលការណ៍នេះត្រូវបានគេស្គាល់ដោយឈ្មោះជាច្រើននៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗគ្នា ដោយរួមមាន វិធាន*អាជ្ញាអស់ជំនុំ* វិធាននៃ*ការលើកលែងការចោទប្រកាន់/ផ្តន្ទាទោស* និងការពារ

គ. សម្រេចថា អង្គជំនុំជម្រះមិនមានយុត្តាធិការចោទប្រកាន់បញ្ជូន លោក អៀង សារី ទៅជំនុំជម្រះ ដោយសារតែព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស នៅជាធរមាន និងនៅមានសុពលភាព ឬជម្រើសផ្សេងពីនេះ៖

ឃ. សម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឬបទល្មើសជាតិ ឬជម្រើសផ្សេងពីនេះ សម្រេចថា បទល្មើសទាំងនេះមិនអាចយកមកអនុវត្តទៅលើនឹងលោក អៀង សារី ដោយសារ ក.ស.ច.ស ខកខានក្នុងការកំណត់និយមន័យ និងអនុវត្តនូវបទល្មើសទាំងនេះ ទៅលើលោក អៀង សារី និង/ឬ កង្វះខាតនូវភាពជាក់លាក់នៃដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះរបស់ ក.ស.ច.ស។

ង. សម្រេចថា [សហឧក្រិដ្ឋកម្មរួម] (JCE) ដែលសន្និដ្ឋានដោយអង្គបុរេជំនុំជម្រះថាអាចអនុវត្តបាននោះ មិនអាចយកមកអនុវត្តចំពោះលោក អៀង សារី ទេ និង

ច. ដកចេញការធ្វើផែនការរួម ការញុះញង់ ការជួយនិងជំរុញ និងការបញ្ជាចេញពីដីកាដំណោះស្រាយចំពោះការយកមកអនុវត្តមកលើ លោក អៀង សារី និង

ឆ. សម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការទៅលើការទទួលខុសត្រូវរបស់ថ្នាក់លើ ឬជម្រើសផ្សេងពីនេះ ដកចេញការទទួលខុសត្រូវរបស់ថ្នាក់លើទាក់ទងនឹង លោក អៀង សារី ចេញពីដីកាដំណោះស្រាយ ឬជម្រើសផ្សេងពីនេះ សម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើទៅតាមការកំណត់ចរិតលក្ខណៈដោយមេធាវីការពារក្តី អាចយកមកអនុវត្តនៅ អ.វ.ត.ក បាន[៣០]។

## <u>បញ្ហាបឋមដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍៖</u>

២០. បញ្ហាទាំងអស់នេះរួមមាន: ១) បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន[៣១]។ ២) សំណើសុំបើកសវនា

---

ប្រឆាំងនឹងការកាត់ទោសទ្វេរដងលើបទល្មើសតែមួយ។ អត្ថបទស្រាវជ្រាវរបស់ Christine Van den Wyngaert និង Tom Ongena មានចំណងជើងថា៖ “Ne bis in idem Principle, Including the Issue of Amnesty”, នៅក្នុង Antonio Cassese *និងអ្នកផ្សេងទៀត.* (ប្រែសម្រួល), ព្រឹត្តិប័ត្រស្រាវជ្រាវ៖*The Rome Statute of the International Criminal Court: a Commentary*, ភាគ ១, បោះពុម្ពដោយ Oxford, Oxford University Press, ឆ្នាំ២00២, (“លក្ខន្តិកៈទីក្រុងរ៉ូម”) ទំព័រ ៧0៥ ត្រង់ ៧0៦ (អង់គ្លេស)។

[៣០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, ទំព័រ ១៩៤។

[៣១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ១-២។ កត់សម្គាល់ថា ទឡ្ហីករណ៍ទាំងនេះ ត្រូវបានបកស្រាយយ៉ាងពេញលេញនៅក្នុងផ្នែកស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ខាងក្រោមនៅក្នុងសាលដីកានេះ។



PRE-TRIAL ... E.C.C.C. ... PRÉLIMINAIRE

ការផ្តាល់មាត់ជាសាធារណៈលើបណ្តឹងឧទ្ធរណ៍[៣២]។ ៣) សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការសម្រេចលើបញ្ហាមួយចំនួន[៣៣]។ ៤) សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ចម្លើយសារភាព និងភស្តុតាងដែលកំពុងជាប់បណ្តឹងឧទ្ធរណ៍សុំមោឃភាព[៣៤]។ និង ៥) អ.វ.ត.ក គឺជាតុលាការជាតិកម្ពុជា[៣៥]។

២១. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ដោយផ្អែកលើមូលដ្ឋាននានាដូចខាងក្រោម:

<u>មូលដ្ឋានទីមួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននោះទេ[៣៦]។

<u>មូលដ្ឋានទីពីរ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស លោក អៀង សារី មិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននោះទេ[៣៧]។

<u>មូលដ្ឋានទីបី</u>៖ ក.ស.ច.ស មានកំហុសតាមផ្លូវច្បាប់ ព្រោះយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តលើបទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ

---

[៣២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៤ និង ១០ នៅក្នុងសាលដីកាខាងលើ។

[៣៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៥។ កត់សម្គាល់ថា ទឡ្ហីករណ៍ទាំងនេះ ត្រូវបានបកស្រាយយ៉ាងពេញលេញនៅក្នុងផ្នែកដែលពិភាក្សាអំពីអង្គសេចក្តីនៃមូលដ្ឋានទីមួយ នៃបណ្តឹងឧទ្ធរណ៍ខាងក្រោមនៅក្នុងសាលដីកានេះ។

[៣៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ៦-៧។ ទឡ្ហីករណ៍ទាំងនេះបច្ចុប្បន្នត្រូវបានជជែកដេញដោល ពីព្រោះទឡ្ហីករណ៍ទាំងនេះត្រូវបានលើកឡើងនៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ (អ.ប.ជ ៧២)។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់ សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរដែលធ្វើឡើង ឬដោយមានជំនួយពីលោក David Boyle និងលោក Stephen Heder និងលើសំណើរបស់លោក អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងដីកាបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D402/1/4។

[៣៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៨-២០។ កត់សម្គាល់ថា ទឡ្ហីករណ៍ទាំងនេះ ត្រូវបានបកស្រាយយ៉ាងពេញលេញនៅក្នុងផ្នែកដែលពិភាក្សាអំពីអង្គសេចក្តីនៃមូលដ្ឋានទីបី នៃបណ្តឹងឧទ្ធរណ៍ខាងក្រោមនៅក្នុងសាលដីកានេះ។

[៣៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២១-៤១។

[៣៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ៤២-១០២។

ដោយហេតុថា ការធ្វើដូច្នេះនឹងជាការរំលោភបំពានទៅលើ *គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege) (គោលការណ៍នីត្យានុកូលភាព)*[៣៨]។

<u>មូលដ្ឋានទីបួន</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្វីបើមានអាជ្ញាយុកាលនៃបទល្មើសក៏ដោយ[៣៩]។

<u>មូលដ្ឋានទីប្រាំ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការដើម្បីអនុវត្តមាត្រា ៣ថ្មី (បទល្មើសជាតិ)[៤០]។

<u>មូលដ្ឋានទីប្រាំមួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បើសិនជាយល់ឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៤១]។

<u>មូលដ្ឋានទីប្រាំពីរ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បើសិនជាយល់ឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៤២]។

<u>មូលដ្ឋានទីប្រាំបី</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ចំពោះការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បើសិនជាយល់ឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៤៣]។

<u>មូលដ្ឋានទីប្រាំបួន</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម[៤៤]។

<u>មូលដ្ឋានទីដប់</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ចំពោះការអនុវត្តការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ[៤៥]។

---

[៣៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ១០៣-១៣៥។ គោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ក៏ត្រូវបានស្គាល់ផងដែរថាជាគោលការណ៍នីត្យានុកូលភាព។ ចំពោះការពន្យល់លម្អិតស្តីពីអត្ថន័យនៃពាក្យនេះសូមមើលផ្នែកពិភាក្សាពីអង្គសេចក្តីនៃមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ខាងក្រោមនៅក្នុងសាលដីកានេះ។

[៣៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៣៦-១៣៧។

[៤០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៣៨-១៧៩។

[៤១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ១៨០-១៨៣។

[៤២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ១៨៤-២៣១។

[៤៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ២៣២-២៤៨។

[៤៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ២៤៩-២៧២។

[៤៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ២៧៣-២៨២។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

00661508



<u>មូលដ្ឋានទីដប់មួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការអនុវត្តនូវការទទួលខុសត្រូវរបស់ថ្នាក់លើ បើសិនជាយល់ឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៤៦]។

***សេចក្ដីសង្ខេបអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា និងការអង្កេតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ៖***

២២. សហព្រះរាជអាជ្ញាលើកឡើងនៅក្នុងចម្លើយតបថា បណ្ដឹងឧទ្ធរណ៍គឺ ១) មិនអាចទទួលយកបានដោយបានបញ្ជាក់អំពីការទទួលយកការដាក់បណ្ដឹងឧទ្ធរណ៍។ ២) "មិនមានអង្គសេចក្ដីគ្រប់គ្រាន់" និង ៣) មិនចាំបាច់មានសវនាការផ្ទាល់មាត់ជាសាធារណៈទេ[៤៧]។ សហព្រះរាជអាជ្ញាលើកឡើងនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នីមួយៗរបស់ជនជាប់ចោទថា ៖

១. មូលដ្ឋានទីមួយ: គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*មិនបានរារាំងមិនឱ្យចោទប្រកាន់ជនជាប់ចោទទេ[៤៨] និងបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទដោយផ្អែកលើមូលដ្ឋាននេះត្រូវបានហាមឃាត់ដោយ*អាជ្ញាអស់ជំនុំ*[៤៩]។

២. មូលដ្ឋានទីពីរ: ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសចំពោះជនជាប់ចោទមិនបានរារាំងមិនឱ្យ អ.វ.ត.ក ធ្វើការចោទប្រកាន់រូបគាត់នោះឡើយ[៥០]។

៣. មូលដ្ឋានទីបី: អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ[៥១]។

៤. មូលដ្ឋានទីបួន: អ.វ.ត.ក មានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការវិនិច្ឆ័យទោសចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានរារាំងដោយពេលវេលានោះទេ[៥២]។

៥. មូលដ្ឋានទីប្រាំ: អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មជាតិ[៥៣]។

---

[៤៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ២៨៣-៣២៤។

[៤៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២-៧។

[៤៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៦៨-៨២

[៤៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៤៥-៤៩។

[៥០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៦១-៦៧។

[៥១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៣១-១៦៧។

[៥២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០០-២០៥។

[៥៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៨៣-១២៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

៦. មូលដ្ឋានទីប្រាំមួយ: អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[៥៤]។

៧. មូលដ្ឋានទីប្រាំពីរ: អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥៥]។

៨. មូលដ្ឋានទីប្រាំបី: ទឡ្ហីករណ៍ដែលថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរ មិនអាចទទួលយកបានទេ[៥៦]។

៩. មូលដ្ឋានទីប្រាំបួន: មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមគឺជាអាជ្ញាអស់ជំនុំ និងមិនអាចទទួលយកបានទេ[៥៧]។

១០. មូលដ្ឋានទីដប់: មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជំរុញ មិនអាចទទួលយកបានទេ ពីព្រោះជនជាប់ចោទមិនអាចប្តឹងឧទ្ធរណ៍អំពីកំហុសនៅក្នុងទម្រង់នៃការចោទប្រកាន់ ឬអំពីធាតុផ្សំផ្សេងៗនៃទម្រង់នៃការទទួលខុសត្រូវបានទេ[៥៨]។

១១. មូលដ្ឋានទីដប់មួយ: អ.វ.ត.ក មានយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើ និងដីកាដំណោះស្រាយដែលលើកឡើងយ៉ាងច្បាស់អំពីលិទ្ធិនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[៥៩]។

២៣. នៅក្នុងសេចក្តីសង្ខេប I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីលើកឡើងថា គោលការណ៍នីត្យានុកូលភាព ត្រូវបានបំពេញពាក់ព័ន្ធនឹងការកាត់សេចក្តីជនជាប់ចោទពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[៦០]។ សហមេធាវីការពារក្តីលើកឡើងថា ការកាត់សេចក្តីពីបទឧក្រិដ្ឋថ្នាក់ជាតិមិនត្រូវបានរារាំងដោយពេលវេលានោះទេ[៦១] និងថា សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃការទទួលខុសត្រូវដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[៦២]។ សហមេធាវីការពារក្តីលើកឡើងថា គ្មានការលើកលែងទោសណាមួយ ក៏ដូចជាគ្មានគោលការណ៍គ្មានការកាត់ទោស

---

[៥៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៦៨-៧១។

[៥៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៧២-១៩៩។

[៥៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០០-២០១។

[៥៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៤៥-៥២។

[៥៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២៧-៣០។

[៥៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០៥-២៥៧។

[៦០] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទី១, កថាខណ្ឌ៨-៣៦។

[៦១] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទី១, កថាខណ្ឌ៣៧-៤២។

[៦២] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទី១, កថាខណ្ឌ៤៣-៥៩។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ពីរដងចំពោះបទល្មើសតែមួយ រារាំងដល់ការកាត់សេចក្ដីជនជាប់ចោទនោះទេ[៦៣]។

២៤. នៅក្នុងសេចក្ដីសង្កេត II របស់ដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីលើកឡើងថា ឧក្រិដ្ឋកម្មអន្តរជាតិ នានាអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[៦៤] និងថា ការកាត់សេចក្ដីជនជាប់ចោទមិនរំលោភលើគោលការណ៍នីត្យានុកូលភាពនោះទេ[៦៥] ព្រមទាំងថា ជនជាប់ចោទបានដឹងអំពីបទឧក្រិដ្ឋទាំងឡាយ ដែលខ្លួនត្រូវបានចោទប្រកាន់ហើយ[៦៦]។

២៥. នៅក្នុងការអង្កេត III របស់ដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីលើកឡើងថា សេចក្ដីសន្និដ្ឋានរបស់ជនជាប់ចោទគឺ "មិនអាចទទួលយកបាននោះទេ"[៦៧] និងតែត្រូវសម្រេចបដិសេធចោល[៦៨]។

**សេចក្ដីសង្ខេបចម្លើយតបរបស់សហមេធាវីការពារក្ដី:**

២៦. សហមេធាវីការពារក្ដីជនជាប់ចោទលើកឡើង នៅក្នុងចម្លើយតបទៅនឹងសហព្រះរាជអាជ្ញាថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន: វាគឺជាបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបញ្ហាផ្នែកយុត្តាធិការដែលរួមបញ្ចូលនូវបញ្ហាអង្គហេតុ និងអង្គច្បាប់[៦៩] និងដែលអាចមានការទាក់ទិនទៅនឹងនិយមន័យនៃធាតុផ្សំនៃបទឧក្រិដ្ឋនានា ឬទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ[៧០]។ បណ្ដឹងឧទ្ធរណ៍អំពីកំហុសនៅក្នុងទម្រង់នៃការចោទប្រកាន់ក៏អាចទទួលយកបានផងដែរ[៧១]។ បណ្ដឹងឧទ្ធរណ៍មិនត្រូវបានរារាំងដោយពេលវេលា[៧២] និងមិនត្រូវបានហាមឃាត់ដោយ*អាជ្ញាអស់ជំនុំ* នោះទេ[៧៣]។ សហមេធាវីការពារក្ដី

[៦៣] សេចក្ដីអង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី១, កថាខណ្ឌ៦៣-៦។

[៦៤] សេចក្ដីសង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី២, កថាខណ្ឌ៧-២១។

[៦៥] សេចក្ដីសង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី២, កថាខណ្ឌ២២-២៨។

[៦៦] សេចក្ដីសង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី២, កថាខណ្ឌ២៩-៣៨។

[៦៧] សេចក្ដីសង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី៣, កថាខណ្ឌ៨។

[៦៨] សេចក្ដីសង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទី៣, កថាខណ្ឌ១១។

[៦៩] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២-៩។

[៧០] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១០។

[៧១] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១៥-១៨។

[៧២] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២០-២៣។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

ជនជាប់ចោទក៏បានលើកឡើងថែមទៀតថា អ.វ.ត.ក ការខ្វះយុត្តាធិការផ្ទាល់ខ្លួនទៅលើជនជាប់ចោទ ផ្អែកតាមព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[៧៤] និងគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[៧៥]។ សហមេធាវីការពារក្តីលើកឡើងថា អ.វ.ត.ក ខ្វះយុត្តាធិការទៅលើបទឧក្រិដ្ឋថ្នាក់ជាតិ[៧៦] ក៏ដូចជាបទឧក្រិដ្ឋអន្តរជាតិផងដែរ[៧៧] ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ[៧៨] ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[៧៩] និងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ[៨០]។

២៧. នៅក្នុងចម្លើយតបរបស់ខ្លួន[៨១] ទៅនឹងការអង្កេត I របស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តីជនជាប់ចោទលើកឡើងថា ដីកាដំណោះស្រាយរំលោភលើគោលការណ៍នីត្យានុកូលភាព[៨២] និងថាការកាត់សេចក្តីអំពីបទឧក្រិដ្ឋជាតិត្រូវបានរាំងដោយពេលវេលា[៨៣] និងថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានយកចិត្តទុកដាក់អំពីសេចក្តីសន្និដ្ឋានស្តីពីសហឧក្រិដ្ឋកម្មរួមនោះទេ[៨៤] និងថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[៨៥] និងថា ការកាត់សេចក្តីជនជាប់ចោទត្រូវបានហាមឃាត់ដោយការលើកលែងទោស និងដោយ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[៨៦]។

---

[៧៣] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២៥។

[៧៤] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២៦-៣២។

[៧៥] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៣៣-៤០។

[៧៦] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៤១-៦៣។

[៧៧] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៦៤-៨៥។

[៧៨] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៨៦-១០៥។

[៧៩] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១០៦-១១១។

[៨០] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១១២-១៣៤។

[៨១] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I។

[៨២] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I, កថាខណ្ឌ២-១៣។

[៨៣] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I,កថាខណ្ឌ១៤-១៧។

[៨៤] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I,កថាខណ្ឌ១៨-១៩។

[៨៥] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I,កថាខណ្ឌ២០-២៥។

[៨៦] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី I,កថាខណ្ឌ២៦-២៩។

២៨. នៅក្នុងចម្លើយតបរបស់ខ្លួន[៨៧] ទៅនឹងការអង្កេត II របស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តីជនជាប់ចោទលើកឡើងថា អនុសញ្ញាអន្តរជាតិមិនអាចយកមកអនុវត្តផ្ទាល់នៅ អ.វ.ត.ក បានទេ[៨៨] ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏មិនអាចយកមកអនុវត្តផ្ទាល់បានដែរ[៨៩]។ សហមេធាវីការពារក្តីបន្ថែមថា គោលការណ៍នីត្យានុកូលភាពរាំងដល់ការផ្តន្ទាទោសជនជាប់ចោទ ចំពោះបទឧក្រិដ្ឋអន្តរជាតិ[៩០] និងថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានកំហុស នៅក្នុងការវិភាគអំពីការប្រមើលមើលឃើញជាមុន និងការផ្សព្វផ្សាយដែលអាចស្វែងរកបាន[៩១]។

## ខ. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

### ១. ភាពអាចទទួលយកបានជាផ្លូវការ៖

២៩. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយដែលត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០។ នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ផ្អែកតាមកាលៈទេសៈវិសាមញ្ញដែលបង្កឡើងដោយសារការលិចទឹកជុំវិញអគារ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យមានការពន្យារពេលសម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០ អនុលោមតាមវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ត្រូវបានដាក់នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ហេតុដូច្នេះហើយស្ថិតនៅក្នុងរយៈពេលកំណត់ដែលត្រូវបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ យោងតាមវិធានផ្ទៃក្នុង។

[៨៧] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី II។

[៨៨] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី II, កថាខណ្ឌ៤-៩។

[៨៩] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី II, កថាខណ្ឌ១០-១២។

[៩០] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី II, កថាខណ្ឌ១៣-១៦។

[៩១] ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី II, កថាខណ្ឌ១៨-២០។

## ២. ភាពអាចទទួលយកបានក្រោមវិធានផ្ទៃក្នុង៖

### i) សេចក្តីសន្និដ្ឋានរបស់ភាគីនានាលើលក្ខខណ្ឌកំណត់អំពីភាពអាចទទួលយកបាន៖

៣០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ស្របតាមវិធាន ៧៤(៣) និង ២១ នៃវិធានផ្ទៃក្នុង។ ពាក់ព័ន្ធនឹងបញ្ហានេះ ភាគីនានាលើកឡើងដូចខាងក្រោម ៖

សហមេធាវីការពារក្តីជនជាប់ចោទ៖

៣១. សហមេធាវីការពារក្តីលើកឡើងថា វិធាន ៧៤(៣)(ក) បានចែងយ៉ាងច្បាស់ថា ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ សហមេធាវីការពារក្តីគិតថា ដីកាដំណោះស្រាយគឺពិតជាដីកាដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចនេះហើយអាចអនុវត្តបានស្របតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

៣២. សហមេធាវីការពារក្តីថែមទាំងលើកឡើងទៀតថា បណ្តឹងឧទ្ធរណ៍ក៏អាចទទួលយកបានផងដែរ អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង។ សហមេធាវីការពារក្តីកត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីមុនថា ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ខ្លួន "វិធាន ២១ តម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារ (...)"[៥២] និងលើកឡើងថា ដូចនេះវិធាន២១ ប្រគល់នូវយុត្តាធិការផ្ទាល់ខ្លួនឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចលើសំណើសុំដែលពាក់ព័ន្ធទៅនឹងសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ។ សហមេធាវីការពារក្តីលើកឡើងថា វិធាន២១ តម្រូវឱ្យ

---

[៥២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D390/1/2/4, កថាខណ្ឌ១៣, ដកស្រង់ពីបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២។

អង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះ ពីព្រោះ៖ ក) តុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយមិនត្រូវបានរក្សាឡើយ ប្រសិនបើ ក.ស.ព ត្រូវបានអនុញ្ញាតឱ្យធ្វើបណ្តឹងឧទ្ធរណ៍លើបញ្ហាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ខណៈពេលដែលមេធាវីការពារក្តីត្រូវបានហាមឃាត់មិនឱ្យធ្វើបណ្តឹងឧទ្ធរណ៍នោះ។ ខ) សិទ្ធិជាមូលដ្ឋានក្នុងការមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួនរបស់លោក អៀង សារី នឹងត្រូវបានរំលោភបំពាន ប្រសិនបើដីកាដំណោះស្រាយខ្វះភាពជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងដល់រូបគាត់ឱ្យបានពិស្តារអំពីប្រភេទនៃការចោទប្រកាន់ដែលគាត់ត្រូវប្រឈមមុខ។ និង គ) វានឹងមិនមែនជាផលប្រយោជន៍នៃភាពយុត្តិធម៌នោះទេ ចំពោះការពន្យារការសម្រេចសេចក្តីលើបញ្ហាយុត្តាធិការទាំងនេះ ឬបង្រួញវិសាលភាពរបស់វានោះឡើយ[៥៣]។

<u>សហព្រះរាជអាជ្ញាលើកឡើងដូចខាងក្រោម៖</u>[៥៤]

៣៣. សហព្រះរាជអាជ្ញាលើកឡើងថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ។ សហព្រះរាជអាជ្ញាលើកឡើងថា មូលដ្ឋានទីមួយ ទីបួន ទីប្រាំមួយ ទីប្រាំពីរ ទីប្រាំបី ទីប្រាំបួន ទីដប់ និងទីដប់មួយ នៃបណ្តឹងឧទ្ធរណ៍មិនអាចកំណត់បានថាជាការជំទាស់ផ្នែកយុត្តាធិការនោះទេ។ ដោយយល់ឃើញថា វិធានផ្ទៃក្នុងមិនបានកំណត់អត្ថន័យនៃពាក្យយុត្តាធិការទេនោះ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គបុរេជំនុំជម្រះស្វែងរកគោលការណ៍ណែនាំពីបទដ្ឋាននានា ដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិដែលកំណត់អំពីការជំទាស់ផ្នែកយុត្តាធិការតែមួយគត់ថា ជាសំណើដែលតតាំងអំពីការចោទប្រកាន់ ដោយហេតុថា វាមិនទាក់ទិនទៅនឹងយុត្តាធិការផ្ទាល់ខ្លួន យុត្តាធិការតាមដែនដី យុត្តាធិការតាមពេលវេលា ឬយុត្តាធិការតាមកម្មវត្ថុរបស់តុលាការ។ សហព្រះរាជអាជ្ញាលើកឡើងថា វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ផ្នែកយុត្តាធិការដែលត្រូវបានអនុញ្ញាតដល់អង្គបុរេជំនុំជម្រះ ត្រូវធ្វើការបកស្រាយក្នុងលក្ខណៈមួយដែលទូលំទូលាយជាងការចែងនៅក្នុងវិធាន ៧២(ឃ) របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) នោះទេ និងផ្តល់ឧទាហរណ៍អំពីបញ្ហាមួយចំនួនដែលត្រូវបានលើកឡើងថាជាលក្ខណៈយុត្តាធិការនៅក្នុង ICTY។

---

[៥៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២-៣។

[៥៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៨-៥២។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

៣៤. សហព្រះរាជអាជ្ញាបន្ថែមថា ការជំទាស់ផ្នែកយុត្តាធិការប្រកបដោយសុពលភាពមិនត្រូវបានបន្ថែមដើម្បីរួមបញ្ចូលនូវបញ្ហានៃអង្គហេតុនានា ការជំទាស់ចំពោះការកំណត់ធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវក្រោមយុត្តាធិការរបស់តុលាការមួយ កំហុសនៅក្នុងទម្រង់នៃការចោទប្រកាន់ ឬចំពោះកំហុសផ្នែកនីតិវិធីដែលត្រូវបានគិតដោយវិធាន ៧៦ នៃវិធានផ្ទៃក្នុងនោះទេ។ ពេលនោះ សហព្រះរាជអាជ្ញាផ្តល់ឧទាហរណ៍នានាដែលការជំទាស់ផ្នែកយុត្តាធិការដែលត្រូវបានអះអាងត្រូវបានបដិសេធដោយហេតុថា ការជំទាស់ទាំងនោះជាប់ទាក់ទិននឹងបញ្ហាអង្គហេតុដែលអាចត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅពេលសវនាការ។

៣៥. សហព្រះរាជអាជ្ញាលើកឡើងជាជម្រើសម្យ៉ាងទៀតថា ចំពោះវិសាលភាពនៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ណាមួយដែលត្រូវបានកំណត់ថាមានលក្ខណៈយុត្តាធិការមូលដ្ឋានទាំងនោះ ត្រូវតែបដិសេធចោល ពីព្រោះជនជាប់ចោទត្រូវបានហាមឃាត់ដោយពេលវេលាមិនឱ្យធ្វើការប្តឹងឧទ្ធរណ៍ អំពីដីកាដំបូងៗរបស់តុលាការនេះដែលសម្រេចលើបញ្ហាដដែលៗនោះទេ។ សហព្រះរាជអាជ្ញាលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទនៅក្នុងដីកាសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ដែលបានចេញនៅចន្លោះថ្ងៃទី ១៩ ខែ កញ្ញា និងថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ សហព្រះរាជអាជ្ញានិយាយថា តាមរយៈការខកខានមិនបានប្តឹងឧទ្ធរណ៍អំពីដីកាសម្រេចទាំងអស់នោះនៅក្នុងរយៈពេលកំណត់ ១០ថ្ងៃ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ជនជាប់ចោទបាត់បង់សិទ្ធិក្នុងការតតាំងអំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងកិច្ចដំណើរការនីតិវិធីបុរេជំនុំជម្រះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនជាប់ចោទមិនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ លើបញ្ហាទាំងអស់នោះបានទេ ពីព្រោះគ្មានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលបញ្ជាក់ឡើងវិញអំពីយុត្តាធិការរបស់ អ.វ.ត.ក ណាមួយត្រូវបានអនុញ្ញាតនោះទេ។

៣៦. សហព្រះរាជអាជ្ញាបន្ថែមថា ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏ត្រូវបានហាមឃាត់មិនឱ្យលើកឡើងអំពីភាពអាចអនុវត្តបាននៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវនៅអង្គជំនុំជម្រះវិសាមញ្ញ ពីព្រោះអង្គបុរេជំនុំជម្រះបានឮ និងបានកំណត់អំពីទឡ្ហីករណ៍ទាំងអស់នេះរួចទៅហើយ។ ផ្អែកលើមូលដ្ឋាននៃអាជ្ញាអស់ជំនុំ ហេតុដូច្នេះមូលដ្ឋានទីពីរ និងទីប្រាំបួនត្រូវតែបដិសោធចោល។



អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER E.C.C.C. * C.E.T.C. CHAMBRE PRÉLIMINAIRE

៣៧. សហព្រះរាជអាជ្ញាក៏បានលើកឡើងថែមទៀតថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេក្រោម វិធាន ២១។ ពាក់ព័ន្ធទៅនឹងការទាមទាររបស់ អៀង សារី ដែលថា វិធាន ២១ តែឯកឯងក៏អាចបង្កើតបានជាសិទ្ធិនៃការប្តឹងឧទ្ធរណ៍នោះ សហព្រះរាជអាជ្ញាលើកឡើងថា នេះជាការបកស្រាយខុសអំពីវិធានផ្ទៃក្នុង និងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ សហព្រះរាជអាជ្ញាលើកឡើងថា វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តំណាងឱ្យសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ និងថា វិធាន ២១ មិនបង្កើតមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ថ្មី ដាច់ដោយឡែកសម្រាប់ជនជាប់ចោទនោះទេ។ សហព្រះរាជអាជ្ញាបកស្រាយពាក្យពេចន៍របស់អង្គបុរេជំនុំជម្រះ[៩៥] ថា វិធាន ២១ តម្រូវថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ត្រូវបានគាំពារ។ សហព្រះរាជអាជ្ញាបន្ថែមថា វាសំខាន់ណាស់ដែលថា នៅក្នុងសេចក្តីសម្រេចដដែល អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ជនត្រូវចោទ"អាចប្តឹងឧទ្ធរណ៍អំពីទស្សនៈយល់ឃើញមួយចំនួនរបស់ដីកាដំណោះស្រាយ" និងថា "សហមេធាវីការពារក្តីត្រូវបានកំណត់នៅក្នុងបញ្ហានានាដែលខ្លួនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" យោងតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ ដូចនេះ សហព្រះរាជអាជ្ញាជជែកថា នៅពេលដែលវិធាន ២១ អនុញ្ញាតឱ្យមានការអានវិធាន ៧៤ បន្ថែមទៀត លក្ខខណ្ឌកំណត់ដែលមានចែងនៅក្នុងវិធាន ៧៤ នៅតែមាន"។

៣៨. លើសពីនេះទៀត សហព្រះរាជអាជ្ញាលើកឡើងថា ការបកស្រាយវិធាន ២១ របស់ អៀង សារី ចាត់ទុកថាជាសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង។ ឯកសារមូលដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាឯកសារមូលដ្ឋានរបស់តុលាការអន្តរជាតិផ្សេងទៀត មិនបានលើកទឹកចិត្តឱ្យមានការវិសោធនកម្មតាមអំពើចិត្ត និងជាឯកតោភាគីរបស់អង្គជំនុំជម្រះលើវិធាននីតិវិធីរបស់តុលាការនោះទេ។ តួនាទីនៃការធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនេះ ត្រូវបានទុកឱ្យកិច្ចប្រជុំពេញអង្គរបស់ចៅក្រមជាអ្នកសម្រេច។ វិធានផ្ទៃក្នុងចែងអំពីដំណើរការធ្វើវិសោធនកម្មដែល

---

[៩៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៨, ជើងទំព័រ៥១ និង៥២ យោងលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, D390/1/2/4, កថាខណ្ឌ១៣ និង ១៨ និងយោងលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ទាក់ទងនឹងការបកប្រែ កថាខណ្ឌ៣៦។



PRE-TRIAL CH... E.C.C.C • C.E.T.C ...LIMINAIRE

ធ្វើដោយផ្នែកណាមួយរបស់អង្គជំនុំជម្រះវិសាមញ្ញរួមទាំងផ្នែកគាំពារការការពារក្តី អាចដាក់សំណើជូនទៅគណៈកម្មាធិការវិធានផ្ទៃក្នុង និងនីតិវិធី ដើម្បីធ្វើការពិចារណា។ សហព្រះរាជអាជ្ញានិយាយថា ជនជាប់ចោទអាចធ្វើសំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ដើម្បីពង្រីកសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ទោះបីជាចំណុចនេះមិនធ្លាប់ត្រូវបានធ្វើវិសោធនកម្មកាលពីមុនក៏ដោយ។

៣៩. សហព្រះរាជអាជ្ញាបានលើកឡើងថែមទៀតថា ការពង្រីកវិសាលភាពនៃសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទអនុលោមតាមវិធានផ្ទៃក្នុង មិនត្រឹមត្រូវនោះទេ នៅដំណាក់កាលនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ប្រការដែលថា សហព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ចំណែកឯជនជាប់ចោទមិនមានសិទ្ធិប្តឹងឧទ្ធរណ៍គ្រប់ដីកាសម្រេចទាំងអស់នោះ មិនផ្ទុយទៅនឹងគោលការណ៍សមភាពតទល់ក្នុងរឿងក្តីនោះទេ។ សមភាពតទល់ក្នុងរឿងក្តីមិនកំណត់ថា ភាគីនានាមានសិទ្ធិស្មើគ្នានៅគ្រប់ដំណើរការនីតិវិធីនោះទេ ជាពិសេសនៅដំណាក់កាលបុរេជំនុំជម្រះ នៅពេលដែលសហព្រះរាជអាជ្ញាមានតួនាទីពិសេសតែមួយគត់នោះ។ ជាការពិត សិទ្ធិក្នុងការឆ្លើយបំភ្លឺរបស់ជនជាប់ចោទ ត្រូវបានការពារដោយវិធានផ្ទៃក្នុងលើសពីគ្រប់គ្រាន់ទៅទៀត។ ជនជាប់ចោទមានឱកាសក្នុងការឆ្លើយបំភ្លឺនៅដំណាក់កាលស៊ើបសួរទាំងអស់ ហើយនឹងមានឱកាសលើកឡើងអំពីបញ្ហាដែលអង្គបុរេជំនុំជម្រះចាត់ទុកថា នៅក្រៅវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នេះ នៅដំណាក់កាលសវនាការទៀតផង។

៤០. យោងតាមមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបន្ថែមថា ជនជាប់ចោទមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហានានា ដែលមិនត្រូវបានសម្រេចសេចក្តី ដោយដីកាដំណោះស្រាយនោះទេ ពីព្រោះមូលដ្ឋាននេះមិនតំណាងឱ្យការបញ្ជាក់អំពីយុត្តាធិការនោះទេ។

<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងដូចខាងក្រោម៖</u>

៤១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា បណ្តឹងឧទ្ធរណ៍ "ត្រូវបានដាក់នៅក្នុងកាលៈទេសៈមិនសមស្រប និងមិនអាចទទួលយកបានទេ"[៥៦] ហេតុនេះហើយអង្គបុរេជំនុំជម្រះត្រូវ

[៥៦] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទី III, កថាខណ្ឌ១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

តែប្រកាសថាមិនអាចទទួលយកបាន[៩៧]។

<u>សហមេធាវីការពារក្តីជនជាប់ចោទលើកឡើងនៅក្នុងចម្លើយតបដូចខាងក្រោម៖</u>

៤២. សហមេធាវីការពារក្តីជនជាប់ចោទលើកឡើង នៅក្នុងចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាថា បណ្តឹងឧទ្ធរណ៍គឺជាបណ្តឹងប្រឆាំងនឹងដីកា ឬសេចក្តីសម្រេច "ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" ដូចនេះហើយអាចទទួលយកបាន ស្របតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[៩៨]។ សហមេធាវីការពារក្តីលើកឡើងថា មូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍ដែលបានតវ៉ាដោយសហព្រះរាជអាជ្ញាមិនមែនជាបញ្ហាយុត្តាធិការ "ប៉ុន្តែយ៉ាងហោចណាស់ មានការពាក់ព័ន្ធទៅនឹងការវាយតម្លៃសមត្ថភាពផ្លូវច្បាប់របស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើរឿងក្តី" ជនជាប់ចោទ[៩៩]។ សហមេធាវីការពារក្តីលើកឡើងថា មូលដ្ឋានទី២ ដែលជា*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលជាឧបសគ្គយុត្តាធិការ "គឺជាបញ្ហាយុត្តាធិការច្បាស់ណាស់"[១០០] ខណៈពេលដែលមូលដ្ឋានទី៥, ទី៦, ទី៧, ទី៨, ទី៩ និងទី១០ លើកឡើងពីបញ្ហានានាដែលត្រូវបានតុលាការ ICTY ចាត់ទុកថាជាបញ្ហាយុត្តាធិការ[១០១]។ សហមេធាវីការពារក្តីលើកឡើងថា បញ្ហាយុត្តាធិការរួមបញ្ចូលនូវបញ្ហាចម្រុះនៃអង្គហេតុ និងអង្គច្បាប់ ដែលមិនតម្រូវឱ្យមានការវាយតម្លៃភស្តុតាងនោះទេ ប៉ុន្តែគ្រាន់តែ "តម្រូវឱ្យមានការវាយតម្លៃលើអង្គច្បាប់ ដោយផ្អែកលើអង្គហេតុដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ"ប៉ុណ្ណោះ[១០២]។ សហមេធាវីការពារក្តីលើកឡើងថា បញ្ហាយុត្តាធិការរួមបញ្ចូលនូវនិយមន័យនៃធាតុផ្សំ ដែលបង្កើតបានជាឧក្រិដ្ឋកម្ម ឬបង្កើតបានជាទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ[១០៣]។

៤៣. សហមេធាវីការពារក្តីលោក អៀង សារី លើកឡើងថែមទៀតថា វិធាន ២១ នៃវិធានផ្ទៃក្នុង បង្កើត

[៩៧] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទី III, កថាខណ្ឌ១១។

[៩៨] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២។

[៩៩] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៤។

[១០០] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៥។

[១០១] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៦។

[១០២] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៩។

[១០៣] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១០។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

“នូវសិទ្ធិប្តឹងឧទ្ធរណ៍ដោយឯករាជ្យ” ដែលស្របតាមវិធាននោះ បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន[១០៤]។ បណ្តឹងឧទ្ធរណ៍លើវិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែពិចារណានៅដំណាក់កាលសវនាការ[១០៥]។ ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចលើបញ្ហានៃ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅតែជាសេចក្តីសម្រេចផ្នែកយុត្តាធិការ ប្រសិនបើសហចៅក្រមស៊ើបអង្កេត “បានពិចារណាឃើញថា អ.វ.ត.ក មិនមានយុត្តាធិការ ក.ស.ច.ស នឹងមិនទុកបញ្ហានេះជូនទៅអង្គជំនុំជម្រះសាលាដំបូងនោះទេ”[១០៦]។ សហមេធាវីការពារក្តីលើកឡើងថា បណ្តឹងឧទ្ធរណ៍មិនត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលានោះទេ “ពីព្រោះថា ក.ស.ច.ស ទើបតែបានបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញតែប៉ុណ្ណោះ”[១០៧]។ ពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាថាជា*អាជ្ញាអស់ជំនុំ* សហមេធាវីការពារក្តីលើកឡើងថា បញ្ហានៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ត្រូវបានសម្រេចតែនៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នប៉ុណ្ណោះ។ ហើយជនជាប់ចោទ ត្រូវបានចោទប្រកាន់បន្ថែម ដែល “ការអនុវត្ត RPA ... មិនត្រូវបានពិចារណា និងសម្រេចដោយអង្គបុរេជំនុំជម្រះឱ្យបានពេញលេញទេ”[១០៨]។ បន្ថែមពីលើនេះទៀត សហមេធាវីការពារក្តីលើកឡើងថា ខ្លួនលើកឡើង “អំពីបញ្ហាផ្សេងទៀតទាក់ទិននឹង JCE ដែលមិនទាន់បានសម្រេចជាស្ថាពរដោយអង្គបុរេជំនុំជម្រះនោះទេ”[១០៩]។

**ii) ការពិចារណាជាទូទៅរបស់អង្គបុរេជំនុំជម្រះអំពីលក្ខខណ្ឌកំណត់អំពីភាពអាចទទួលយកបាន៖**

***(ក) ភាពអាចទទួលយកបានស្របតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង៖***

៤៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អនុលោមតាមវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ដីកាដំណោះ

[១០៤] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១១។

[១០៥] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១៥-១៨។

[១០៦] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១៩។

[១០៧] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២១។

[១០៨] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២៤។

[១០៩] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២៤ យោងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ ២៦៤-២៧២។

00661520



ស្រាយបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងនៅក្នុងវិធាន ៧៤[១១០]។ វិធាន ៧៤ ចែងអំពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលអាចត្រូវបានលើកឡើងដោយភាគីនានានៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយពាក់ព័ន្ធ ទៅនឹងបណ្តឹងឧទ្ធរណ៍នេះ វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ចែងថា "ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត [...] ដោយបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[១១១] ។

៤៥. នៅក្នុងការបកស្រាយវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីមុនថា មានតែបណ្តឹងជំទាស់យុត្តាធិការប៉ុណ្ណោះដែលអាចលើកឡើងបានក្រោមវិធាននោះ[១១២]។ នៅក្នុងការសម្រេចថាអ្វីខ្លះដែលបង្កើតបានជាបណ្តឹងជំទាស់យុត្តាធិការត្រឹមត្រូវមួយ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា អង្គជំនុំជម្រះវិសាមញ្ញ "មានស្ថានភាពអាចប្រៀបធៀបបានទៅនឹងតុលាការ *មិនអចិន្ត្រៃយ៍*នានា" ដែលមានលក្ខណៈផ្ទុយទៅនឹងប្រព័ន្ធច្បាប់ស៊ីវិលជាតិ នៅពេលដែលលក្ខខណ្ឌនៃច្បាប់លក្ខន្តិកៈទាក់ទងទៅនឹងបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលអាចត្រូវបានចោទប្រកាន់ មានលក្ខណៈទូលំទូលាយ នៅពេលដែលច្បាប់ជាធរមានមិនមានការកំណត់ និងនៅពេលដែល "គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យតុលាការអនុវត្តច្បាប់ជាធរមាន ចំពោះអំពើដែលចោទប្រកាន់ជនជាប់ចោទនៅពេលនោះ [...] [និង] តម្រូវឱ្យវិធានច្បាប់ត្រូវតែអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១១៣]។ ជាលទ្ធផល អង្គបុរេជំនុំជម្រះបានអនុម័តវិធីសាស្ត្រដែលប្តឹងឧទ្ធរណ៍ថា៖ ១) "បណ្តឹងជំទាស់ [...] អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬការទទួលស្គាល់ទម្រង់នោះតាមច្បាប់ [...] នៅពេលដែលចោទប្រកាន់"។ ឬ ២) តវ៉ាថា ទម្រង់នៃការទទួលខុសត្រូវ "មិនអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាក់លាក់ណាមួយ" នៅពេលដែលចោទប្រកាន់នោះទេ។ និង ៣) បង្ហាញថា "ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនឹងរំលោភលើគោលការណ៍នីត្យានុកូលភាព" លើកឡើងនូវបណ្តឹងជំទាស់យុត្តាធិការជាកម្មវត្ថុអាចទទួលយកបានដែលអាចធ្វើឡើង

---

[១១០] វិធានផ្ទៃក្នុង ៦៧(៥)។

[១១១] វិធានផ្ទៃក្នុង ៧៤(៣)(ក)។

[១១២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ("សាលដីកាលើសហឧក្រិដ្ឋកម្មរួម"), ឯកសារ D97/14/15, កថាខណ្ឌ២១។

[១១៣] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២៣, ២៤ (ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Milutinović *និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-05-98, សាលដីកាលើសំណើសុំរបស់ Dragoljub Ojdanić ជំទាស់ទៅនឹងយុត្តាធិការ—សហឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ១០)។

នៅក្នុងដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[១១៤]។ ទោះបីជាយ៉ាងណាក៏ដោយ"បណ្តឹងជំទាស់ទាក់ទងនឹងបញ្ហាជាក់លាក់មួយចំនួននៃ [...] ទម្រង់នៃការទទួលខុសត្រូវ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ"[១១៥]។

៤៦. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រដែលអនុវត្តទាក់ទិនទៅនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នៅដំណាក់កាលបុរេជំនុំជម្រះដោយជជែកអំពីបទល្មើសសំខាន់ៗ ដែលត្រូវបានចោទប្រកាន់តាមមាត្រា ៣ (ថ្មី) - មាត្រា ៨ នៃច្បាប់ អ.វ.ត.ក[១១៦]។ បណ្តឹងឧទ្ធរណ៍ទាំងនេះគ្រាន់តែលើកឡើងអំពីបណ្តឹងជំទាស់ដែលមានកម្មវត្ថុយុត្តាធិការដែលអាចទទួលយកបានប៉ុណ្ណោះ នៅពេលដែលមានបណ្តឹងជំទាស់ទៅនឹងអត្ថិភាពនៅក្នុងអង្គច្បាប់នៃបទល្មើស និងធាតុផ្សំនៃបទល្មើសនោះនៅពេលដែលចោទប្រកាន់ ដែលនឹងនាំឱ្យមានការរំលោភលើគោលការណ៍នីត្យានុកូលភាព ប្រសិនបើត្រូវបានអនុវត្ត[១១៧]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា "បណ្តឹងជំទាស់ទាក់ទងនឹងបញ្ហាជាក់លាក់មួយចំនួន [...] គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ"[១១៨]។ ជាឧទាហរណ៍ បណ្តឹងជំទាស់

[១១៤] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២៣-២៤។

[១១៥] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២៣ (សម្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić*, សំណុំរឿងលេខ IT-95-14-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ៣២-៤២ (ការបង្ហាញការពិតអំពីដំណើរការធាតុផ្សំអត្តនោម័តនៃ "ការបញ្ជា" ស្របតាមមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-05-87-PT, សាលដីកាលើសំណើសុំរបស់ Ojdanić ជំទាស់ទៅនឹងយុត្តាធិការ - ការរួមប្រព្រឹត្តបទល្មើសដោយប្រយោល, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY, ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ២៣។

[១១៦] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ជាមួយនឹងវិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦), ("ច្បាប់ អ.វ.ត.ក")។

[១១៧] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ante Gotovina អ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-06-90-AR72.1, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Ante Gotovina ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំជាច្រើនជំទាស់ទៅនឹងយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៧ ("*Gotovina និងអ្នកផ្សេងទៀត*. សាលដីកាលើយុត្តាធិការ"), កថាខណ្ឌ ១៥, ១៨។

[១១៨] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២៣ (ទាញហេតុសំអាង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-96-21-AR72.5, សាលដីកាលើពាក្យសុំតម្កល់បណ្តឹងឧទ្ធរណ៍ដាក់ដោយ Hazim Delić (កំហុសនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ), អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ៦ ខែធ្នូ ឆ្នាំ១៩៩៦, កថាខណ្ឌ ២៧ (លើកឡើងថាជម្លោះណាមួយទាក់ទងទៅនឹងធាតុផ្សំឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រា ២, ៣, ៤, និង ៥ នៃច្បាប់

00661522



ទៅនឹងនិយមន័យជាក់លាក់ និងការអនុវត្តធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ មិនអាចទទួលយកបានទេ នៅដំណាក់កាលបុរេជំនុំជម្រះ[១១៩]។ លើសពីនេះទៀត បណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ហាថាតើធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ពិតជាមានជាក់ស្តែង ដែលផ្ទុយទៅនឹងផ្លូវច្បាប់នៅពេលដែលការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានចោទប្រកាន់មិនអាចទទួលយកបានដែរឬទេ[១២០]។ នេះដោយសារតែបណ្តឹងជំទាស់ទាំងនេះទាក់ទិនទៅនឹងបញ្ហាពិតប្រាកដ ឬបញ្ហាចម្រុះរវាងការសម្រេចលើអង្គច្បាប់ និងអង្គហេតុដែលត្រូវធ្វើឡើង នៅពេលសវនាការផ្អែកតាមការសួរដេញដោល និងការវិនិច្ឆ័យលើភស្តុតាងដែលពាក់ព័ន្ធ។

---

លក្ខន្តិកៈ: "គឺជាបញ្ហាសម្រាប់បើកសវនាការ មិនមែនសម្រាប់ការជំទាស់នៅអង្គបុរេទេ")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Furundžija,* សំណុំរឿងលេខ IT-05-17/1-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៧២-១៨៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-96-23-T & IT-96-23/1-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY, ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១, កថាខណ្ឌ៤៣៦-៤៦០ (សាលក្រមសាលាដំបូងបង្ហាញការពិតពីការរំលោភលើផ្លូវភេទ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមមាត្រា ៥(ឆ) នៃច្បាប់លក្ខន្តិកៈ)។

[១១៩] *Gotovina និងអ្នកផ្សេងទៀត* សាលដីកាលើយុត្តាធិការ, កថាខណ្ឌ១៥, ១៨ (ការរកឃើញមូលដ្ឋានដែលមិនអាចទទួលយកបានរបស់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងនិយមន័យនៃធាតុផ្សំជាក់លាក់នៃការនិរទេស និងការជម្លៀសដោយបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជាការរំលោភទៅនឹងមាត្រា៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងជជែកតវ៉ាថា ធាតុផ្សំទាំងនោះគួរត្រូវបានបកស្រាយយ៉ាងតឹងរឹង)។

[១២០] *Gotovina និងអ្នកផ្សេងទៀត* សាលដីកាលើយុត្តាធិការ, កថាខណ្ឌ២១ (បដិសេធថាជាការមិនអាចទទួលយកបាននូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលជំទាស់បញ្ហាថាតើប្រទេស ដែលមានជម្លោះប្រដាប់អាវុធពិតជាបានកើតឡើងពាក់ព័ន្ធទៅនឹងការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិដែលបានលើកឡើង ដូចដែលត្រូវបានចោទប្រកាន់ដែរឬទេ)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ljube Boškoski និង Johan Tarčulovski,* សំណុំរឿងលេខ IT-04-82-AR72.1, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពីយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥, កថាខណ្ឌ១១-១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rasim Delić,* សំណុំរឿងលេខ IT-04-83-AR72, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់នឹងយុត្តាធិការរបស់តុលាការ, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥, កថាខណ្ឌ១១ (លើកឡើងថា "ក្នុងករណីដែលទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទាក់ទងនឹងភាពគ្រប់គ្រាន់នៃការចោទប្រកាន់នោះទេ តែទាក់ទងនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដាក់បន្ទុក អង្គជំនុំជម្រះតុលាការកំពូលឯកភាពជាមួយអង្គជំនុំជម្រះសាលាដំបូងថា នេះជាបញ្ហាត្រូវដោះស្រាយនៅពេលសវនាការ")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Vojislav Šešelj,* សំណុំរឿងលេខ IT-03-67-AR72.1, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទាក់ទងនឹងយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ កថាខណ្ឌ១៤ (លើកឡើងថា ថាតើការកាត់សេចក្តីអាចបង្កើតឲ្យមានទំនាក់ ទំនងរវាងឧក្រិដ្ឋកម្មដែលបានចោទដូចមានចែងនៅក្នុងមាត្រា៥ ក្នុង Vojvodina និងជម្លោះប្រដាប់អាវុធនៅក្នុង Croatia និង/ឬ Bosnia ដែរឬទេ រឺង Herzegovina គឺជាបញ្ហាអង្គហេតុដែលត្រូវសម្រេចនៅពេលសវនាការ)។

៤៧. ជាចុងក្រោយ ពាក់ព័ន្ធទៅនឹងបណ្តឹងជំទាស់ដែលបានលើកឡើងពីកំហុសនានា នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងជំទាស់ទាំងនោះប្រាកដណាស់ថាគ្មានលក្ខណៈជាបណ្តឹងជំទាស់យុត្តាធិការនោះទេ ហេតុដូច្នេះហើយមិនអាចទទួលយកបានទេនៅដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ដោយគិតដល់អត្ថន័យទាំងមូលនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង និងជំពូក II នៃច្បាប់ អ.វ.ត.ក ដែលគូសបញ្ជាក់អំពីយុត្តាធិការផ្ទាល់ខ្លួន យុត្តាធិការតាមពេលវេលា និងយុត្តាធិការជាកម្មវត្ថុរបស់ អ.វ.ត.ក[១២១]។ ពុំមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុងលើកឡើងថា កំហុសនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿង ទៅជំនុំជម្រះដែលបានលើកឡើងបង្ហាញពីបញ្ហាយុត្តាធិការនានានោះទេ។ ដូចនេះទឡ្ហីករណ៍ទាំងអស់នេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាលើអង្គសេចក្តីនៅពេលសវនាការ ហើយចំណុចនេះមិនបង្ហាញពីកង្វះយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ។

### (ខ) ភាពអាចទទួលយកបានតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ៖

៤៨. ដូចដែលបានកត់សម្គាល់ខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា អនុលោមតាមវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងនៅក្នុងវិធាន ៧៤។ គ្មានវិធានផ្ទៃក្នុងផ្សេងទៀតត្រូវបានរៀបរាប់នៅក្នុងវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែលចែងអំពីមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនោះទេ។ ជាងនេះទៅទៀត ខុសពីវិធាន ៧៤ វិធាន ២១ មិនបានលាតត្រដាងច្បាស់លាស់អំពីមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍ មុនពេលជំនុំជម្រះនោះទេ។ ផ្ទុយទៅវិញ វិធាននេះកំណត់អំពីគោលការណ៍គ្រឹះដែលគ្រប់គ្រងអំពីកិច្ចដំណើរការនីតិវិធីនៅ

---

[១២១] *Gotovina និងអ្នកផ្សេងទៀត*។ សាលដីកាលើយុត្តាធិការ កថាខណ្ឌ២១, ២៤ (ដោយយល់ឃើញថា ទឡ្ហីករណ៍ដែលចោទថា រដ្ឋអាជ្ញាខកខានមិនបានទាញហេតុសំអាងធាតុផ្សំទម្រង់នៃការទទួលខុសត្រូវឲ្យបានត្រឹមត្រូវថា បទប្បញ្ញត្តិនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមមានភាពមិនស៊ីសង្វាក់គ្នា និងថា រដ្ឋអាជ្ញាខកខានមិនបានអះអាងអំពីអង្គហេតុនានាដើម្បីគាំទ្រដល់អត្ថិភាពនៃធាតុផ្សំនៃបទល្មើសដែលថាមិនអាចទទួលយកបានទូវការចោទប្រកាន់ អំពីកំហុសនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំ ជម្រះ) *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Jadranko Prlić *និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-04-74-AR72.1, សាលដីកាលើ បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Petković ប្រឆាំងនឹងសាលដីការបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីយុត្តាធិការ, អង្គជំនុំជម្រះ តុលាការកំពូល នៃតុលាការ ICTY, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ១៣។



PRE-TRIAL ... E.C.C.C ... PRELIMINAIRE

ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ហេតុនេះ ស្របតាមលក្ខខណ្ឌច្បាស់លាស់នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយណាមួយ អាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ។ នៅពេលដែលបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង លើកឡើងអំពីបញ្ហាដែលមិនអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែតម្រូវបាន និងមិនអនុញ្ញាតឱ្យមានលទ្ធភាពប្ដឹងឧទ្ធរណ៍នៅដំណាក់កាលនេះបាន នឹងបង្កការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ វិធាន ២១ នៃវិធាន ផ្ទៃក្នុងធានាការអនុវត្តដើម្បីពង្រីកវិសាលភាពនៃវិធាន ៧៤ នៃវិធានផ្ទៃក្នុង មួយករណីម្ដងៗ។ បើមិនដូច្នេះទេ វិធាននេះនឹងមិនត្រូវបានអនុវត្តទេ។

៤៩. អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីលើកមុនថា ស្របជាមួយនឹងមាត្រា ៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ការជំនុំជម្រះក្ដីត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ" និង "ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ" និងស្របជាមួយនឹងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[១២២] ដែល "អាចអនុវត្តបាននៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ [...] ការពិចារណាសំខាន់ជាងគេ នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺជាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង"[១២៣]។ ហេតុដូច្នេះ នៅពេលដែលអង្គហេតុ និងកាលៈទេសៈនានានៃបណ្ដឹងឧទ្ធរណ៍តម្រូវឱ្យមានការពិចារណាសំខាន់ជាងគេ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ខ្លួនមានសមត្ថកិច្ចធ្វើការពិចារណាអំពីមូលដ្ឋាននានាដែលបានលើកឡើងដោយម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ ស្របតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តាមរយៈការបកស្រាយដែលមានគំនិតច្រើនអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការប្ដឹងឧទ្ធរណ៍ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះ

---

[១២២] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានអនុម័ត និងចាប់ផ្ដើមចុះហត្ថលេខា ឲ្យសច្ចាប័ននិងព្រមព្រៀងដោយសេចក្ដីសម្រេចរបស់មហាសន្និបាតអគ្គលេខា អ.ស.ប លេខ 2200A(XXI) នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, ត្រូវបានចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ("ICCPR")។

[១២៣] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរ ដោយមូលហេតុវិលោភនីតិវិធី (D426/1), ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ("សាលដីកាស្ដីពីការវិលោភនីតិវិធី"), កថាខណ្ឌ១៣-១៤។

បានយល់ឃើញថា ខ្លួនមានសមត្ថកិច្ចក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ អៀង ធីរិទ្ធ សុំផ្អាកកិច្ចដំណើរការនីតិវិធីដោយសារការបំពានលើនីតិវិធី ពីព្រោះបណ្តឹងឧទ្ធរណ៍ "លើកឡើងនូវបញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌"[១២៤]។ ស្រដៀងគ្នានេះដែរ នៅក្នុងសេចក្តីសម្រេចស្តីពី JCE អង្គបុរេជំនុំជម្រះបានយល់ឃើញថា ខ្លួនមានសមត្ថកិច្ចធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងពីបញ្ហាថាតើជនត្រូវចោទបានទទួលសេចក្តីជូនដំណឹងគ្រប់គ្រាន់ អំពីការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវ ស្របតាមការចែងនៅក្នុងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន [...]" និងអង្គហេតុដែលថា "ទាំងបទដ្ឋានអន្តរជាតិ ទាំងមាត្រា ៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក តម្រូវឱ្យមានភាពច្បាស់លាស់នៅក្នុងការចោទប្រកាន់"ដែរឬទេ[១២៥]។ បញ្ហានោះត្រូវបាននិយាយថា អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា នៅក្នុងសេចក្តីសម្រេចទាំងពីរ អង្គបុរេជំនុំជម្រះមិនបានលើកឡើងថា ជាវិធានទូទៅ អង្គបុរេជំនុំជម្រះនឹងមានសមត្ថកិច្ចជាស្វ័យប្រវត្តិស្របតាមវិធាន ៧៤(៣) ឬវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីធ្វើការពិចារណាអំពីមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍ ដែលក្នុងនោះម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងអំពីបញ្ហានានា ដែលជាក់ទាក់ទងនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនោះទេ។ ផ្ទុយទៅវិញ ក្នុងការពិចារណាគ្រប់រឿងទាំងអស់ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាយ៉ាងយកចិត្តទុកដាក់មួយករណីម្តងៗ លើបញ្ហាថាតើ "អង្គហេតុ និងកាលៈទេសៈនានា" នៃបណ្តឹងឧទ្ធរណ៍បានតម្រូវឱ្យមានការបកស្រាយទូលំទូលាយជាងអំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ដែរឬទេ[១២៦]។ ជាឧទាហរណ៍ នៅក្នុងសេចក្តីសម្រេចលើការរំលោភបំពាននីតិវិធី អង្គបុរេជំនុំជម្រះបានពិចារណាលើបញ្ហាថាតើភាពធ្ងន់ធ្ងរ និងភាពខុសប្រក្រតីនៃបញ្ហានៃភាពយុត្តិធម៌នានា ដែលបានលើកឡើងក្រោមទ្រឹស្តីនៃការរំលោភបំពាននីតិវិធី និងផលប៉ះពាល់របស់បញ្ហាទាំងនោះទៅលើកិច្ចដំណើរការនីតិវិធីដែលត្រូវបានធានាឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍[១២៧]។ ស្រដៀងគ្នានេះដែរ នៅក្នុងសេចក្តីសម្រេចអំពី JCE ក្នុងការពិចារណាគ្រប់រឿងទាំងអស់ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើបញ្ហាថាតើ

---

[១២៤] សាលដីកាស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៥។

[១២៥] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣០-៣៤។

[១២៦] សាលដីកាស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៤។ សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣០។

[១២៧] សាលដីកាស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៤។

“ផលប្រយោជន៍នៅក្នុងការរក្សាធនធានតុលាការ និងការពន្លឿនដំណើរការច្បាប់ និងដំណើរការនីតិវិធី” មានតម្លៃជាងផលប្រយោជន៍នៃភាពយុត្តិធម៌ដែលនឹងត្រូវបានបំពេញតាមរយៈការប្រកាសថាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ដែលទាក់ទងនឹងសិទ្ធិក្នុងការបញ្ជាក់ឱ្យច្បាស់លាស់ នៅក្នុងដីកាចោទប្រកាន់ទាំងអស់នោះអាចទទួលយកបានដែរឬទេ[១២៨]។ នៅក្នុងសេចក្ដីសម្រេចផ្សេងទៀត អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើបញ្ហាថាតើសេចក្ដីត្រូវការឱ្យធ្វើការធានាថា “កិច្ចដំណើរការនីតិវិធីនៅក្នុងពេលស៊ើបសួរមានភាពត្រឹមត្រូវ និងថា តុល្យភាពត្រូវបានរក្សាទុករវាងសិទ្ធិរបស់ភាគីនានា” នឹងធានាឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្ដឹងឧទ្ធរណ៍ដែលត្រូវបានដាក់ប្រឆាំងនឹងដីកាសម្រេចលើសិទ្ធិទទួលបានការបកប្រែភាសារបស់ជនត្រូវចោទដែរឬទេ ដែលវាជាប្រភេទដីកាដែលគ្មានការចែងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះនៅក្នុងវិធានផ្ទៃក្នុងនោះ[១២៩]។ នៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍លើសំណើសុំលើកទីដប់មួយ អង្គបុរេជំនុំជម្រះត្រូវធ្វើការពិនិត្យលើបញ្ហាថាតើភារកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការធានាថា “ផលប្រយោជន៍របស់ជនត្រូវចោទ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព និងភាពយុត្តិធម៌” នឹងធានាឱ្យមានការទទួលយកបណ្ដឹងឧទ្ធរណ៍នានា ដែលបានដាក់ដោយផ្អែកលើមូលដ្ឋានខុសប្រក្រតីដែរឬទេ[១៣០]។ នៅក្នុងសេចក្ដីសម្រេចលើពាក្យបណ្ដឹងជិតចិត្តបុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើបញ្ហាថាតើបណ្ដឹងដែលបានដាក់ដោយផ្អែកលើមូលដ្ឋានខុសប្រក្រតីនេះ ត្រូវទទួលបានការអនុញ្ញាត ដើម្បី“ធានាដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅក្នុងពេលស៊ើបសួរ”ដែរឬទេ[១៣១]។ នៅក្នុងសាលដីកាលើ “បណ្ដឹងឧទ្ធរណ៍ស្ដីពីការធ្វើ

---

[១២៨] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៤, ៣៥។

[១២៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារA190/I/20, (“បណ្ដឹងឧទ្ធរណ៍លើសិទ្ធិនៃការបកប្រែលើកទី១”) កថាខណ្ឌ៣២-៥០។ សូមមើលផងដែរ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារA190/II/9, (“បណ្ដឹងឧទ្ធរណ៍លើសិទ្ធិនៃការបកប្រែលើកទី២ II”), កថាខណ្ឌ២៧-៤៤។

[១៣០] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D158/1/15, (“សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងសំណើទីដប់មួយ”) កថាខណ្ឌ៣០-៥១។

[១៣១] សាលដីកាលើបណ្ដឹងជិតចិត្តរបស់ជនត្រូវចោទ (អៀង សារី) ទៅលើលោកបណ្ឌិត Stephen Heder និងលោកបណ្ឌិត ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ៣, អបជ ឯកសារគ្មានលេខ, 00378097-00378103, កថាខណ្ឌ១៦-២២។

ទារុណកម្ម” អង្គបុរេជំនុំជម្រះត្រូវធ្វើការពិនិត្យថាតើភារកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការធានាថា “កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងឆាប់រហ័ស” បានធានាឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានដាក់នៅក្នុងដំណាក់កាលស៊ើបសួរនៃកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងបញ្ហានានានៃភាពអាចទទួលយកបាននៃភស្តុតាងដែរឬទេ[១៣២]។ នៅក្នុងសេចក្តី សម្រេចផ្សេងទៀត អង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណាថាតើភារកិច្ចរបស់អង្គបុរេជំនុំជម្រះ ក្នុងការធានាអំពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី នឹងធ្វើឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាទទួលយកបណ្តឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងសំណើសុំ ដែលតាមលក្ខណៈនៃសំណើសុំទាំងនោះ មិនចាត់ទុកថាជាសំណើសុំបំពេញកិច្ចស៊ើបសួរដែលត្រូវបានអនុញ្ញាតតាមវិធានផ្ទៃក្នុងដែរឬទេ[១៣៣]។

៥០. នៅក្នុងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា អង្គហេតុ និងកាលៈទេសៈនានាតម្រូវឱ្យអង្គបុរេជំនុំជម្រះត្រូវយល់ឃើញថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានស្របតាមការបកស្រាយដ៏ទូលំទូលាយនៃវិធាន ៧៤(៣)(ក) ឬតាមវិធាន ២១ នៃវិធានផ្ទៃក្នុង នោះឡើយ។ អង្គបុរេជំនុំជម្រះរំលឹកថា មាត្រា ៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងថា “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ *និងឆាប់រហ័ស* [...]”[១៣៤]។ លើសពីនេះទៀត វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា គោលការណ៍គ្រឹះដែលត្រូវបានអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញ គឺថា “ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប”[១៣៥]។ ស្រដៀងគ្នានេះដែរ មាត្រា ១៤(៣) នៃ ICCPR ដែលត្រូវបានបង្ហាញនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[១៣៦] ចែងថា “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានា

[១៣២] សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D130/9/21, (“សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងទារុណកម្ម”) កថាខណ្ឌ២៤-៣១។

[១៣៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ នួន ជា លើកទី១៦ (D253) និងទី១៧ (D265), ឯកសារ D253/3/5, កថាខណ្ឌ១១។

[១៣៤] ច្បាប់របស់ អ.វ.ត.ក, មាត្រា៣៣ (ថ្មី) (គូសបញ្ជាក់បន្ថែម)។

[១៣៥] វិធាន២១(៤) នៃវិធានផ្ទៃក្នុង។

[១៣៦] សាលដីកាស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៣។

ជាអប្បបរិមា[...]ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស"[១៣៧]។ បទបញ្ញត្តិទាំងអស់នេះគូសបញ្ជាក់ថា សិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងឡាយដែលម្ចាស់បណ្តឹងឧទ្ធរណ៍មាន គឺសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីឆាប់រហ័ស។ ដូចនេះ "ភារកិច្ចក្នុងការធានាអំពីភាពយុត្តិធម៌ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីសវនាការ តម្រូវឱ្យមានជាចាំបាច់នូវតុល្យភាពដ៏ធំនៃផលប្រយោជន៍"[១៣៨]។

៥១. សហាមេធាវីការពារក្តីលើកឡើងពីបញ្ហានានា ដែលជាប់ទាក់ទងនឹងកំហុសនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានលើកឡើង[១៣៩] ដែលស្រដៀងទៅនឹងបញ្ហានានាដែលត្រូវបានពិចារណានៅក្នុងសាលដីកា JCE ដែលត្រូវបានចេញ ជាការឆ្លើយតបទៅនឹងភាពខ្វះចន្លោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលបានដាក់ដោយសហព្រះរាជអាជ្ញា[១៤០]។ នៅដំណាក់កាលនោះ កិច្ចស៊ើបសួរនានាកំពុងបន្តធ្វើ រីឯដីកាចោទប្រកាន់មិនទាន់ត្រូវបានចេញនៅឡើយទេ។ ស្របជាមួយនឹងសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជូនដំណឹងឆាប់រហ័ស អំពីបទចោទប្រកាន់លើខ្លួន ប្រសិនបើម្ចាស់បណ្តឹងឧទ្ធរណ៍បានជជែកតវ៉ាដោយជោគជ័យថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានកំហុសនោះ អង្គជំនុំជម្រះនឹងមានតួនាទីតម្រូវឱ្យមានសេចក្តីពិស្តារថែមទៀតអំពីការចោទប្រកាន់ដែលបានបញ្ជូនដោយសហព្រះរាជអាជ្ញា ដែលគូសបញ្ជាក់ពីដំណើរការនៃកិច្ចស៊ើបសួរ។ នៅដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានអំពីកិច្ចស៊ើបសួរបន្ថែមដែលបានធ្វើឡើងអស់រយៈពេលបីឆ្នាំ បានចេញដីកាដំណោះស្រាយ ដែលបានចោទប្រកាន់លើជនជាប់ចោទ និងបានបញ្ជូនរឿងក្តីប្រឆាំងនឹងជនជាប់ចោទ ដូចដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង។ ដូចនេះ "ផលប្រយោជន៍នៅក្នុងការបង្កើនល្បឿននៃដំណើរការនីតិវិធី និងច្បាប់"[១៤១] មានផលប្រយោជន៍ធំជាង និងមានតម្លៃជាងផល

---

[១៣៧] ICCPR, មាត្រា១៤(៣)។

[១៣៨] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Pauline Nyiramasuhuko និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ ICTR-98-42-AR73, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ II ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ទាក់ទងនឹងការច្រានចោលពាក្យសុំផ្លាស់ប្តូរបញ្ជីឈ្មោះសាក្សីរបស់គាត់, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTR, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ២៤ (គូសបញ្ជាក់បន្ថែម)។

[១៣៩] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣១-៣៣។

[១៤០] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៦, ៣១។

[១៤១] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៥។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ប្រយោជន៍ដែលនឹងត្រូវទទួលបាន តាមរយៈការពិចារណាលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ នៅដំណាក់កាលនេះ ពីព្រោះការចោទប្រកាន់អំពីកំហុសនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាច ត្រូវបានលើកឡើងដោយ អៀង សារី នៅពេលសវនាការ។

**(គ) បញ្ហាថាតើបណ្តឹងជំទាស់ផ្នែកយុត្តាធិការនៅក្នុងបណ្តឹងឧទ្ធរណ៍ត្រូវបានរារាំងដោយពេលវេលា ដែរឬទេ ៖**

៥២. អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនហាក់ដូចជាមិនជឿជាក់ទាល់តែសោះចំពោះទឡ្ហីករណ៍របស់ សហព្រះរាជអាជ្ញាដែលថា ដីកាដំណោះស្រាយគឺបញ្ជាក់ឡើងវិញអំពីយុត្តាធិការរបស់អង្គជំនុំ ជម្រះវិសាមញ្ញ ហេតុដូច្នេះម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកឡើងពីការជំទាស់ផ្នែកយុត្តាធិការ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះបានទេ។ អង្គបុរេជំនុំជម្រះសម្គាល់ឃើញថា អង្គបុរេ ជំនុំជម្រះមិនច្បាស់លាស់ថាតើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នសម្រាប់ជនជាប់ចោទ តំណាង ឲ្យដីកាដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ទាក់ទិនទៅនឹងបទឧក្រិដ្ឋនានាដែល ត្រូវបានចោទប្រកាន់ដែរឬទេនោះទេ។ គោលបំណងដំបូងនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺដើម្បី "បញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់ ដែលនាំឲ្យមានការឃុំខ្លួន"[១៤២]។ ដូចនេះ ដីកាសម្រេច ឃុំខ្លួនបណ្តោះអាសន្នដែលជាបញ្ហាចោទ បានសម្គាល់អំពីបទល្មើស និងការចោទប្រកាន់អំពីអង្គ ហេតុនានាដែលបានលើកឡើង សហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបាន សម្រេចថា មានមូលហេតុសមស្របដែលនាំឲ្យជឿបានថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានប្រព្រឹត្តបទ ល្មើសដែលបានចោទប្រកាន់ និងយល់ឃើញថា ការឃុំខ្លួននឹងមានភាពចាំបាច់នៅក្នុងដំណើរការ ស៊ើបសួរដោយមូលហេតុផ្សេងៗជាច្រើន[១៤៣]។ នៅពេលដែលអាចមានការតវ៉ាថា នៅក្នុងការធ្វើ បែបនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ដោយមិនច្បាស់លាស់អំពីយុត្តាធិការ ជាកម្មវត្ថុ របស់អង្គជំនុំជម្រះវិសាមញ្ញ ពាក់ព័ន្ធទៅនឹងបទល្មើសនានាដែលត្រូវបានចោទប្រកាន់ថាបាន ប្រព្រឹត្ត និងបទល្មើសនានាដែលត្រូវបានជំទាស់លើមូលដ្ឋានយុត្តាធិការនៅក្នុងបណ្តឹងឧទ្ធរណ៍ ទឡ្ហីករណ៍នេះមិនគួរឲ្យជឿជាក់ និងមិនអាចធ្វើការសម្រេចបានទេ។

---

[១៤២] វិធានផ្ទៃក្នុង៦៣(២)(ក)។

[១៤៣] ដីកាឃុំខ្លួន អៀង សារី បណ្តោះអាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, ឯកសារ C22 ("ដីកាឃុំខ្លួនបណ្តោះអាសន្ន")។

៥៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្រោមវិធាន ៦៧ នៃវិធានផ្ទៃក្នុង នៅពេលបញ្ចប់កិច្ចស៊ើបសួរ និងចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានធ្វើការសម្រេចចុងក្រោយពាក់ព័ន្ធទៅនឹងការកំណត់តាមផ្លូវច្បាប់ចំពោះអំពើនានា ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងសម្រេចថាតើអំពើទាំងនោះចាត់ទុកថាជាបទល្មើស ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញដែរឬទេ[១៤៤]។ ក្នុងការធ្វើដូច្នេះ "ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ" នៅក្នុងដំណើរការស៊ើបសួរ[១៤៥]។ ដូចនេះ វាមានភាពមិនច្បាស់លាស់ នៅពេលចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នថា បទល្មើសដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញាគឺជាបទល្មើសដែលម្ចាស់បណ្ដឹងឧទ្ធរណ៍នឹងត្រូវបានចោទប្រកាន់ នៅពេលបន្ទាប់ពីពេលបញ្ចប់កិច្ចស៊ើបសួរឬយ៉ាងណា។ ក្រោមលក្ខខណ្ឌនៃវិធាន ៦៧ នៃវិធានផ្ទៃក្នុង វានឹងជាការសមស្រប សម្រាប់ម្ចាស់បណ្ដឹងឧទ្ធរណ៍ធ្វើការសន្មតថា ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នមិនបញ្ជាក់ពីយុត្តាធិការនោះទេ និងថា វានឹងជាការត្រឹមត្រូវក្នុងការលើកឡើងអំពីការជំទាស់យុត្តាធិការជាកម្មវត្ថុ បន្ទាប់ពីមានសេចក្ដីសន្និដ្ឋានស្ថាពរស្ដីពីយុត្តាធិការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ។

៥៤. បន្ថែមពីលើនេះ ដូចដែលបានលើកឡើងនៅក្នុងចម្លើយតប ម្ចាស់បណ្ដឹងឧទ្ធរណ៍មានបំណង "លើកឡើងពីការតវ៉ានឹងបញ្ហាយុត្តាធិការជាច្រើន ក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការ និង ក.ស.ច.ស បានជូនដំណឹងម្ដងហើយម្ដងទៀតថា ខ្លួននឹង "ធ្វើការពិនិត្យលើ" អំពីការតវ៉ានៅពេលចេញដីកាដំណោះស្រាយ"[១៤៦]។

៥៥. ក្នុងករណីដែលអង្គបុរេជំនុំជម្រះបានជឿជាក់ថា សហចៅក្រមស៊ើបអង្កេតពិតជាបានបញ្ជាក់អំពីយុត្តាធិការជាកម្មវត្ថុរបស់អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដែលស្ថិតនៅក្នុងអត្ថន័យនៃវិធាន ៧៤(៣)(ក) អង្គបុរេជំនុំជម្រះរំលឹកថា តាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ ឬតាមសំណើផ្ទាល់ខ្លួន អង្គបុរេជំនុំជម្រះអាច "ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើ ក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុត

---

[១៤៤] វិធានផ្ទៃក្នុង ៦៧ (១)-(៣)។

[១៤៥] វិធានផ្ទៃក្នុង ៦៧(១)។

[១៤៦] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ២១, ជើងទំព័រ៨២។

រលត់ ប្រសិនបើ[ខ្លួន]យល់ឃើញថាត្រឹមត្រូវសមហេតុផល”[១៤៧]។ នៅក្នុងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍ពេលនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ចំពោះមូលហេតុដូចខាងក្រោម វានឹងជាផលប្រយោជន៍នៃភាពយុត្តិធម៌ ក្នុងការអនុញ្ញាតឲ្យមានការជំទាស់ផ្នែកយុត្តាធិការរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ប្រសិនបើមាន ទោះបីជាម្ចាស់បណ្តឹងអាចតវ៉ាថាខ្លួនត្រូវប្តឹងឧទ្ធរណ៍អំពីដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋានទាំងអស់នេះ “ក្នុងអំឡុងពេល ១០(ដប់) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬដីកា”[១៤៨]។

៥៦. ដូចដែលបានកត់សម្គាល់ខាងលើ វាអាចមានភាពច្បាស់លាស់ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ថា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបានបញ្ជាក់ពីយុត្តាធិការ ដែលស្ថិតនៅក្រោមលក្ខខណ្ឌនៃវិធាន ៦៣ និង៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ បន្ថែមពីលើនេះ វិធានផ្ទៃក្នុង ឬច្បាប់ជាធរមានផ្សេងទៀតនៅអង្គជំនុំជម្រះវិសាមញ្ញក៏គ្មានភាពច្បាស់លាស់ផងដែរថា ប្រយោគ “បញ្ជាក់ពីយុត្តាធិការ” នៅក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ច្រានចោលការប្តឹងឧទ្ធរណ៍អំពីដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត “ដែលបញ្ជាក់ឡើងវិញ” អំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា។ លើសពីនេះទៀត ដូចដែលបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា ការជំទាស់ទៅនឹងយុត្តាធិការគឺជាមូលដ្ឋានដ៏សំខាន់ដែលត្រូវធ្វើឲ្យបានឆាប់រហ័ស[១៤៩]។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអង្គហេតុដែលថា ខុសពីបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ បណ្តឹងផ្នែកយុត្តាធិការត្រូវបានលើកយកមកយ៉ាងច្បាស់លាស់ ធ្វើជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍មានកំណត់ដែលសមស្រប ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងកិច្ចដំណើរការនីតិវិធីបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះឯកភាពថា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវធ្វើឡើងឲ្យបានឆាប់រហ័ស និងថាបញ្ហាជាមូលដ្ឋានដូចជាយុត្តាធិការនេះ ត្រូវធ្វើការដោះស្រាយឲ្យបានឆាប់នៅក្នុងកិច្ចដំណើរការនីតិវិធីតាមដែលអាចធ្វើទៅបាន។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពិចារណាអំពីការជំទាស់ផ្នែកយុត្តាធិការរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅពេលបិទកិច្ចស៊ើបសួរ និង

[១៤៧] វិធានផ្ទៃក្នុង ៣៩(៤)(ខ)។

[១៤៨] វិធានផ្ទៃក្នុង ៧៥(១)។

[១៤៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៣៧។



PRE-TRIAL CHAMBER E.C.C.C C.E.T.C. CHAMBRE PRÉLIMINAIRE

00661532



មុនពេលចាប់ផ្តើមសវនាការ នឹងមិនប៉ះពាល់ដល់ភាពឆាប់រហ័សនោះទេ។ ផ្ទុយទៅវិញ ការពិចារណានៅពេលនេះ គាំទ្រដល់ការប្រព្រឹត្តទៅយ៉ាងឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីតាមរយៈការផ្តល់ការការពារប្រឆាំងនឹងលទ្ធផលដែលក្នុងនោះ "បញ្ហាជាមូលដ្ឋាននេះ ដែលជា [...] យុត្តាធិការ [...] ត្រូវបានរក្សាទុកសម្រាប់ធ្វើសេចក្តីសម្រេចនៅចុងបញ្ចប់នៃការជំនុំជម្រះក្តី ដែលអាចអូសបន្លាយរយៈពេលវែងដែលអាចគួរឱ្យរំភើបចិត្ត និងដែលអាចមានការចំណាយច្រើន"[១៥០]។

៥៧. ជាចុងក្រោយ ស្របជាមួយនឹងកង្វះនៃបទបញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុង ស្តីពីប្រសិទ្ធភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬពាក់ព័ន្ធទៅនឹងការបញ្ជាក់ឡើងវិញ លក្ខណៈនៃការជំទាស់ផ្នែកយុត្តាធិការ និងដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការពិចារណាអំពីខ្លឹមសារនៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងថា ការជំទាស់ផ្នែកយុត្តាធិការប្រឆាំងនឹងដីកាដំណោះស្រាយអាចទទួលយកបាននៅពេលនេះ។

## iii) ការពិនិត្យរបស់អង្គបុរេជំនុំជម្រះអំពីភាពអាចទទួលយកបានសម្រាប់មូលដ្ឋាននីមួយៗ នៃបណ្តឹងឧទ្ធរណ៍៖

### (ក) មូលដ្ឋានទីមួយ៖

៥៨. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការផ្តន្ទាទោស អៀង សារី ចំពោះអំពើនានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយត្រូវបានរាំងដោយគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ពីព្រោះរូបគាត់ត្រូវបានជំនុំជម្រះក្តី និងត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ ចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍បន្ថែមពីលើបទល្មើសមួយចំនួនផ្សេងទៀត ដោយតុលាការបដិវត្តន៍ប្រជាជន ឆ្នាំ១៩៧៩ ("សវនាការ

---

[១៥០] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dusko Tadić*, សំណុំរឿងលេខ IT-94-AR72, សាលដីកាលើញត្តិរបស់មេធាវីការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំលើយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICYT, ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ៦។

00661533



ឆ្នាំ១៩៧៩")[១៥១]។ សហមេធាវីការពារក្ដីតវ៉ាថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជូន អៀង សារី ទៅជំនុំជម្រះ ដោយមិនសម្រេចជាដំបូងពីបញ្ហា *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* រំលោភលើសិទ្ធិជាមូលដ្ឋានរបស់ អៀង សារី ក្នុងការទទួលបានការសន្មតជាមុនថាគ្មានទោស[១៥២] និងចាត់ទុកថាជាដីកាដែលបញ្ជាក់ពីយុត្តាធិការ ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនបំពេញតួនាទីតាមផ្លូវតុលាការក៏ដោយ[១៥៣]។

៥៩. សហព្រះរាជអាជ្ញាតវ៉ាថា មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ដោយហេតុថាបណ្ដឹងឧទ្ធរណ៍មិនពាក់ព័ន្ធទៅនឹងដីកាដែលបញ្ជាក់អំពីយុត្តាធិការនោះទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតមិនបានសម្រេចលើបញ្ហានោះទេ ដោយខ្លួនគ្រាន់តែបានបញ្ជូនបញ្ហាទៅឱ្យអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ[១៥៤]។

៦០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត "យល់ឃើញថា បញ្ហាដែលចោទឡើងថាតើសាលក្រមនាឆ្នាំ ១៩៧៩ នៅតែមានសុពលភាព និងអាចលើកយកមកធ្វើជាសំអាងនៅក្នុងការជំទាស់ទៅនឹងដំណើរការក្ដីថ្មី ទាក់ទងនឹងបទប្រល័យពូជសាសន៍ចំពោះ អៀង សារី ឬទេនោះ គឺជាយុត្តិកម្មមួយដែលនាំទៅរកការពិភាក្សាដេញដោលជាសាធារណៈ និងចំពោះមុខនៅអង្គជំនុំជម្រះសាលាដំបូង"[១៥៥]។ ទោះបីជាមិនបានប្រកាន់នូវជំហរច្បាស់លាស់លើបញ្ហា *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ក៏ដោយសហចៅក្រមស៊ើបអង្កេតបានសម្រេចថា "អៀង សារី នឹងត្រូវបានបញ្ជូនទៅកាត់ក្ដីលើអង្គហេតុទាំងមូលដែលត្រូវបានធ្វើឡើងចំពោះរូបគាត់នាពេលបច្ចុប្បន្ននេះ"[១៥៦]។

៦១. អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីមុនថា "គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទ*

[១៥១] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣។

[១៥២] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៤១។

[១៥៣] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ១៩។

[១៥៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៣៣។

[១៥៥] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៣៣ (គូសបញ្ជាក់បន្ថែម)។

[១៥៦] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៣៤ និង ១៦១៣។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*ល្មើសតែមួយ* ចែងថា តុលាការមិនអាចផ្តួចផ្តើមនីតិវិធីចោទប្រកាន់បុគ្គលណាមួយ ចំពោះឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃដំណើរការក្តីព្រហ្មទណ្ឌម្តងរួចមកហើយ និងចំពោះឧក្រិដ្ឋកម្មដែលតុលាការបានយកមកកាត់ទោស ឬកាត់ឱ្យរួចទោសរួចហើយ" និងថា "គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានគេបកស្រាយថា ជនជាប់ចោទ "មិនត្រូវបានគេយកមកកាត់ទោសពីរដងចំពោះបទចោទតែមួយ"[១៥៧]។ ដូចនេះ និងនៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានពិចារណាកាលពីលើកមុនអំពីគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ថាជាបញ្ហាផ្នែកយុត្តាធិការ[១៥៨]។

៦២. សេចក្តីសន្និដ្ឋាននេះគ្រាន់តែត្រូវបានពង្រឹង នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះប៉ុណ្ណោះ នៅពេលដែលជនជាប់ចោទកំពុងត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះបញ្ជាក់ថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការរំលត់មូលហេតុនៃបណ្តឹងអាជ្ញាផ្អែកតាម *អាជ្ញាអស់ជំនុំ* ដែលទស្សនាទានដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[១៥៩] ជាធម្មតាត្រូវនាំឱ្យចេញនូវដីកាសម្រេចបដិសេធដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត[១៦០]។ តាមរយៈការបញ្ជូន អៀង សារី ទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតបានធ្វើការបដិសេធដោយមិនច្បាស់លាស់លើសំណើសុំបង្ហាញអំពីការរំលត់បណ្តឹងអាជ្ញាប្រឆាំងនឹងរូបគាត់[១៦១] ដូចនេះ បានបញ្ជាក់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការកាត់ទោសគាត់។ ការសន្និដ្ឋានអ្វីផ្សេងពីនេះនឹងមិនឱ្យ អៀង សារី

[១៥៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, ឯកសារC22/I/73, កថាខណ្ឌ៥១ (ទាញហេតុសំអាង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, ផ្នែក X, per Judge Nieto-Navia) (គូសបញ្ជាក់បន្ថែម)។

[១៥៨] សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីក្នុងការស្នើសុំពន្យារពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងយុត្តាធិការ, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៩, ឯកសារC22/I/15។

[១៥៩] សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ៤៧។

[១៦០] Christian Guéry, *Instruction préparatoire*, Rép. pén. Dalloz, janvier 2008, no. 747 (និយាយថាប្រសិនបើចៅក្រមស៊ើបអង្កេតយល់ឃើញថាបណ្តឹងអាជ្ញាត្រូវបានរលត់, ចៅក្រមត្រូវចេញដីកាលើកលែងការចោទប្រកាន់)។ មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា (CPC) ផ្តល់នូវវិធីសាស្ត្រស្រដៀងគ្នានេះ ដោយចែងថា៖ "នៅពេលបណ្តឹងអាជ្ញាត្រូវបានរំលត់ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មិនអាចត្រូវបានបន្តទៀត ឬត្រូវបញ្ចប់តែម្តង" (គូសបញ្ជាក់បន្ថែម)។

[១៦១] François-Louis Coste, *Chambre de l'instruction*, Rép. pén. Dalloz, ខែ ធ្នូ ឆ្នាំ ២០០៦, កថាខណ្ឌ៤៥៥។

អនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ប៉ុន្តែវាជាបញ្ហាយុត្តាធិការដែលចៅក្រមខ្លួនឯងមិនបានធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការនោះទេ។

៦៣. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ គឺជា "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"និង ស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

**(ខ) មូលដ្ឋានទីពីរ ៖**

៦៤. សហមេធាវីការពារក្តី អៀង សារី អះអាងថា សហចៅក្រមស៊ើបអង្កេត "បានសម្រេចថា អ.វ.ត.ក មានយុត្តាធិការលើលោក អៀង សារី ទោះបីជាមានព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស" ដែលបានចេញដោយព្រះមហាក្សត្រនៅឆ្នាំ ១៩៩៦ ក៏ដោយ ដែលតាមការយល់ឃើញរបស់សហមេធាវី ជាការរារាំងដល់យុត្តាធិការរបស់ អ.វ.ត.ក លើលោក អៀង សារី[១៦២]។ ជាពិសេស សហមេធាវីការពារក្តីតវ៉ាថា ការអនុគ្រោះទោសការពារលោក អៀង សារី មិនឲ្យមានការផ្តន្ទាទោស នៅអង្គជំនុំជម្រះវិសាមញ្ញ និងការលើកលែងទោសធានាថា អៀង សារី មិនអាចទទួលទោសណាមួយពីការផ្តន្ទាទោស ដែលផ្អែកលើអំពើនានាដែលបានលើកឡើងនៅក្នុងសវនាការឆ្នាំ១៩៧៩ នោះទេ[១៦៣]។ សហមេធាវីការពារក្តីលើកឡើងថែមទៀតថា ភាពអាចអនុវត្តបាន និងវិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនត្រូវបានសម្រេចយ៉ាងពេញលេញដោយអង្គបុរេជំនុំជម្រះនោះទេ និងថា ពេលនេះបញ្ហានេះត្រូវបានគេលើកយកមកដោះស្រាយ[១៦៤]។

៦៥. សហមេធាវីការពារក្តីតវ៉ាថា សហព្រះរាជអាជ្ញាឆ្លើយតបថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ដោយផ្អែកលើគោលការណ៍*អាជ្ញាអស់ជំនុំ* ពីព្រោះអង្គបុរេជំនុំជម្រះបានធ្វើការសម្រេចចុងក្រោយ អំពីបញ្ហានៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះ

---

[១៦២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៥០។

[១៦៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៥៨។

[១៦៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៥៣-៥៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អាសន្ន[១៦៥]។

៦៦. ដូចដែលបានអះអាងដោយសហមេធាវីការពារក្តី អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការលើកលែងទោសត្រូវបានដឹងថាជា "ឧបសគ្គចំពោះការផ្តន្ទាទោស" ដែលអាចមាន[១៦៦] ដែលទាក់ទងគ្នាទៅនឹងបញ្ហានៃ *គោលការណ៍គ្មានការកាត់ទោសពីរដងទៅលើបទល្មើសតែមួយ*[១៦៧]។ ការអនុគ្រោះទោសអាចមានប្រសិទ្ធភាពស្រដៀងគ្នា។ ដូចដែលអង្គបុរេជំនុំជម្រះបានធ្វើការពិចារណារួចកាលពីមុន[១៦៨] ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាទាំងអស់នេះគឺជាបញ្ហាយុត្តាធិការ។ ដោយបានសម្រេចថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសមិនមានផលប៉ះពាល់ទៅលើកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ[១៦៩] និងបានបញ្ជូនជនជាប់ចោទ អៀង សារី ទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះក្នុងការជំនុំជម្រះក្តី អៀង សារី។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ស្ថិតនៅក្នុងវង្វង់នៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

៦៧. ដូចដែលបានចង្អុលបង្ហាញដោយសហព្រះរាជអាជ្ញារួចហើយថា កាលពីមុន អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យបន្តិចបន្តួចប៉ុណ្ណោះ លើបញ្ហានៃការលើកលែងទោស និងអនុគ្រោះទោស នៅពេល

---

[១៦៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៤៥-៤៩។

[១៦៦] មាត្រា១០ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន("SCSL")។ មាត្រា៦ នៃលក្ខន្តិកៈនៃតុលាការពិសេសសម្រាប់លីបង់("STL")។ ស្រដៀងគ្នាដែរ គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម ("ICRC") នៅក្នុងការផ្តល់យោបល់លើមាត្រា ៦ នៃពិធីសារបន្ថែម II បានចាត់ទុកការលើកលែងទោសថាជាអំពើមួយ "ដែលលុបបំបាត់ផលវិបាកនៃបទល្មើសដែលអាចផ្តន្ទាទោសបានមួយចំនួន បញ្ឈប់ការចោទប្រកាន់ និងលើកលែងការផ្តន្ទាទោស"។ ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធមិនមានលក្ខណៈអន្តរជាតិ (ពិធីសារ II) ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ការផ្តល់យោបល់ ផ្នែក II៖ ការប្រព្រឹត្តរបស់មនុស្ស មាត្រា ៦ ការចោទប្រកាន់បទព្រហ្មទណ្ឌ កថាខណ្ឌ ៤៦១៧។

[១៦៧] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[១៦៨] សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីក្នុងការស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងយុត្តាធិការ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨, ឯកសារC22/I/15។ សូមមើលផងដែរ៖ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kallon,* SCSL-2004-15-AR75E, "សាលដីកាលើការជំទាស់នឹងយុត្តាធិការ៖ Amnesty Lomé Agreement", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ (ប្រសិនបើបញ្ហានោះត្រូវបានចាត់ទុកថាជាការជំទាស់ទៅនឹងយុត្តាធិការ)។

[១៦៩] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៣១។

ដែលខ្លួនបានទទួលបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។ ដោយគិតអំពីសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ ក្នុងការមិនត្រូវបានឃុំឃាំងតាមអំពើចិត្ត ដែលត្រូវបានធានាតាមរយៈមាត្រា ៩ នៃ ICCPR អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា "អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រសិនបើយើងអាចមើលឃើញកាលៈទេសៈដែលបានផ្តល់ភស្តុតាងយ៉ាងច្បាស់ថាជាការរារាំងដល់ការកាត់ទោសដោយអង្គជំនុំជម្រះសាលាដំបូង ការចេញដីកាឱ្យនាំខ្លួន ឬដីកាឃុំខ្លួន គឺធ្វើឡើងដោយខុសនឹងច្បាប់"[១៧០]។ ដូចនេះ អង្គបុរេជំនុំជម្រះបានធ្វើការសម្រេចបឋមលើបញ្ហាទាំងអស់នេះ ដើម្បីសម្រេចអំពីនីត្យានុកូលភាពនៃដីកាចាប់ខ្លួន ដោយមានព័ត៌មាន មានកំណត់ដែលសមស្របនៅពេលនោះ ដោយផ្អែកលើការចោទប្រកាន់ដំបូង និងតាមរយៈការប្រើប្រាស់បទដ្ឋាននៃការពិនិត្យមើលខ្ពស់ជាងនេះ ជាសំខាន់ពោលគឺ "កាលៈទេសៈដែលនឹងរារាំងការផ្តន្ទាទោសយ៉ាងពិតប្រាកដ និងយ៉ាងជាក់ស្តែង"។ បន្ថែមពីលើនេះ ដោយបានពិចារណាលើអង្គហេតុ ដែលថាកិច្ចពិភាក្សាលើបញ្ហាទាំងអស់នេះត្រូវបានធ្វើឡើងនៅពេលខ្លះដោយសហព្រះរាជអាជ្ញា និងថា អៀង សារី ចង់ឱ្យមានការលើកឡើងអំពីបញ្ហាទាំងអស់នេះនៅដំណាក់កាលបន្ទាប់ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ថា អៀង សារី នឹងមិនត្រូវបានរារាំងមិនឱ្យលើកឡើងអំពីបញ្ហាទាំងអស់នេះនៅដំណាក់កលបន្ទាប់នៃកិច្ចដំណើរការនីតិវិធីនោះទេ[១៧១]។ នៅក្នុងកាលៈទេសៈទាំងអស់នេះ ដូចដែលបានតវ៉ាដោយសហព្រះរាជអាជ្ញា គេមិនអាចធ្វើការពិចារណាថាការសម្រេចចុងក្រោយពាក់ព័ន្ធនឹងបញ្ហាថាតើព្រះរាជក្រិត្យនឹងរារាំងដល់ការផ្តន្ទាទោស អៀង សារី នៅចំពោះមុខ អ.វ.ត.ក ដែរឬទេនោះ ត្រូវបានធ្វើឡើងកាលពីលើកមុនដោយអង្គបុរេជំនុំជម្រះនោះទេ។ ដោយសារតែបញ្ហាមិនទាន់អាចឈានដល់ទីបញ្ចប់ អៀង សារី មិនត្រូវបានរារាំងដោយ *គោលការណ៍អាជ្ញាអស់ជំនុំ* មិនឱ្យលើកឡើងនូវបញ្ហានានាស្តីពីការលើកលែងទោស និងការអនុគ្រោះទោស នៅចំពោះមុខអង្គបុរេជំនុំជម្រះនោះឡើយ។

### *(គ) មូលដ្ឋានទីបី ៖*

---

[១៧០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, ឯកសារC22/I/73, កថាខណ្ឌ ១៦ (សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្ន")។

[១៧១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ២០ ("អង្គបុរេជំនុំជម្រះសង្កេតឃើញពាក់ព័ន្ធនឹងបញ្ហានេះថាការលើកឡើងដែលបាន ធ្វើនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងឧទ្ធរណ៍នាពេលបច្ចុប្បន្ន ក្នុងការលើកឡើងអំពីសិទ្ធិក្នុងការលើកទឡ្ហីករណ៍នៅដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៧៤(៣)(ក) និងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង")។

៦៨. សហមេធាវីការពារក្តី អៀង សារី លើកឡើងនៅក្នុងមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្លូវច្បាប់ដោយបានលើកឡើងថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលការធ្វើបែបនេះជាការរំលោភលើគោលការណ៍នីត្យានុកូលភាព[១៧២]។

៦៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កថាខណ្ឌនានានៃដីកាដំណោះស្រាយដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍បានយោង ទាក់ទិនជាមួយនឹងលក្ខខណ្ឌកំណត់របស់គោលការណ៍នីត្យានុកូលភាព និងផលប៉ះពាល់របស់លក្ខខណ្ឌនេះ ទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវនានាដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា "ទាំងបទល្មើស ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលកំណត់នៅក្នុងផ្នែកនេះនៃដីកាដំណោះស្រាយ ស្របទៅនឹងគោលការណ៍នីត្យានុកូលភាព"[១៧៣]។ដែលអនុលោមតាមគោលការណ៍នីត្យានុកូលភាព គឺជាបុរេលក្ខខណ្ឌដើម្បីបង្កើតយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ឃើញថា កាយល់ឃើញទាំងនោះដោយអានភ្ជាប់គ្នាជាមួយនឹងកថាខណ្ឌ ១៦១៣ នៃដីកាដំណោះស្រាយ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតនេះចាត់ទុកថាជាការបញ្ជាក់អំពីយុត្តាធិការ ជាមួយនឹងការជំទាស់របស់សហមេធាវីការពារក្តីត្រូវបានយល់ឃើញថាអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ គោលការណ៍នីត្យានុកូលភាពត្រូវតែជាគោលការណ៍មួយដែលបានបង្កើតឡើងពីពេលមុន នឹងមានភាពសមហេតុសមផលសមស្របអាចទទួលយកបានថាបទល្មើសជាក់ស្តែងមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវ បានកើតឡើងនៅពេលដែលបទល្មើសត្រូវលើកឡើងថាបានប្រព្រឹត្ត។ ហេតុដូច្នេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទាំងនោះ ដែលបានលើកឡើងពីការភ័ន្តច្រឡំពាក់ព័ន្ធទៅនឹងបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបានអនុវត្តទាំងអស់នោះ ចាត់ទុកថាជាបណ្តឹងជំទាស់ផ្នែកយុត្តាធិការ។

---

[១៧២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១០៣-១៣៥។

[១៧៣] ដីកាដំណោះស្រាយ, កថាខណ្ឌ១២៩៩។

(ឃ) មូលដ្ឋានទីបួន៖

៧០. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តទៅលើការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ ("ការរំលោភបំពានធ្ងន់ធ្ងរ") ថ្វីបើមានការលើកឡើងរបស់សហមេធាវីការពារក្តីអំពីលក្ខខណ្ឌដែលបានកំណត់អំពីអាជ្ញាយុកាលនៃបទល្មើសក៏ដោយ[១៧៤]។ សហមេធាវីការពារក្តីបានលើកឡើងថា ការដែលគ្មានបទប្បញ្ញត្តិសម្រាប់កង្វះខាតអាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរ នៅក្នុងមាត្រា ៦ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញចង្អុលបង្ហាញថា អាជ្ញាយុកាលអាចអនុវត្តបាន ចំពោះការរំលោភបំពានធ្ងន់ធ្ងរ និងលើកឡើងថា រយៈពេលអាជ្ញាយុកាល ១០ឆ្នាំ ដែលគេបានដឹងជាមុនតាមរយៈបទប្បញ្ញត្តិជាតិ ត្រូវតែអនុវត្តនិងថាអាជ្ញាយុកាលនោះបានកន្លងផុតទៅហើយ។

៧១. សហព្រះរាជអាជ្ញាលើកឡើងថា អាជ្ញាយុកាលមិនអាចអនុវត្តបានចំពោះការរំលោភបំពានធ្ងន់ធ្ងរនោះទេ[១៧៥]។ សហព្រះរាជអាជ្ញាលើកឡើងថា ការមិនមានប្រើពាក្យថា "ដែលមិនមានអាជ្ញាយុកាល" នៅក្នុងបទប្បញ្ញត្តិស្តីពីការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ អ.វ.ត.ក ពុំមែនជាសំអាងហេតុគ្រប់គ្រាន់ក្នុងការអនុវត្តរយៈពេលអាជ្ញាយុកាលថ្នាក់ជាតិ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ[១៧៦]។ សហព្រះរាជអាជ្ញាលើកឡើងថា ប្រសិនបើតុលាការពិចារណាឃើញថា អាជ្ញាយុកាល និងកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជាមានទំនាស់គ្នា តុលាការត្រូវបដិសេធចោលអាជ្ញាយុកាល ដើម្បីជាប្រយោជន៍ដល់ការប្រកាន់ខ្ជាប់កាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជា[១៧៧]។

៧២. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តីតវ៉ាថា បញ្ហានោះគឺជាបញ្ហាយុត្តាធិការមួយ និងអាចត្រូវបានប្តឹងឧទ្ធរណ៍ ពីព្រោះ "អាជ្ញាយុកាលដែលអាច

---

[១៧៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៣៦-១៣៧។

[១៧៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០២។

[១៧៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០២។

[១៧៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២០៥។

00661540



អនុវត្តបាន គឺជាឧបសគ្គចំពោះការកាត់ទោស"[១៧៨]។

៧៣. ដំបូងឡើយ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតបានធ្វើការចោទប្រកាន់លើជនត្រូវចោទពីបទរំលោភបំពានធ្ងន់ធ្ងរ[១៧៩] ជាកាឆ្លើយតប អង្គជំនុំជម្រះវិសាមញ្ញឥន្ទានុសិទ្ធិ ក្នុងការជំនុំជម្រះទោសជនដែលត្រូវចោទចំពោះបទល្មើសទាំងនេះ។ ការជំទាស់របស់សហមេធាវីការពារក្ដី ទៅលើការបញ្ជាក់អំពីយុត្តាធិការត្រូវបានផ្អែកលើការអះអាងថា រយៈពេលអាជ្ញាយុកាលតាមច្បាប់ជាតិក៏អនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិផងដែរ។ អនុសញ្ញាទីក្រុងហ្សឺណែវដែលជាច្បាប់អាចអនុវត្តបានក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ចែងថា ឧក្រិដ្ឋកម្មសង្គ្រាមពុំមានអាជ្ញាយុកាលនោះទេដែលបង្ហាញថា ពុំមានអាជ្ញាយុកាលដែលអាចអនុវត្តបានទេ។ ការលើកឡើងផ្ទុយពីនេះពុំទុកជាបានការឡើយ។ ដោយសារតែម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំបានធ្វើការជំទាស់ផ្អែកយុត្តាធិការ មូលដ្ឋាននេះពុំអាចទទួលយកបានទេ។

(ង) មូលដ្ឋានទីប្រាំ៖

៧៤. សហមេធាវីការពារក្ដី អៀង សារី លើកឡើងនៅក្នុងមូលដ្ឋានទីប្រាំនៃបណ្ដឹងឧទ្ធរណ៍ថា "សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការ ដើម្បីអនុវត្តមាត្រា ៣ថ្មី (បទល្មើសជាតិ)[១៨០] និងស្នើសុំឱ្យអង្គបុរេជំនុំជម្រះលើកឡើងថា អង្គជំនុំជម្រះវិសាមញ្ញពុំមានយុត្តាធិការទៅលើបទល្មើសទាំងអស់នេះទេ[១៨១]។

៧៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងកថាខណ្ឌ ១៥៧៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតនិយាយថា សហចៅក្រមស៊ើបអង្កេត "សម្រេចបញ្ជូនជនត្រូវចោទ ទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនាដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្ដន្ទាទោសដោយក្រមព្រហ្មទណ្ឌ

[១៧៨] សារណាឆ្លើយតបរបស់ អៀង សារី, កថាខណ្ឌ៨។

[១៧៩] ដីកាដំណោះស្រាយ, កថាខណ្ឌ១៦១៣។

[១៨០] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៣៨-១៧៩។

[១៨១] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី សំណូមពរ។

ឆ្នាំ ១៩៥៦"។ តាមរយៈការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើបទឧក្រិដ្ឋជាតិ។

៧៦. ផ្អែកលើសេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយសហមេធាវីការពារក្តី អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះស្ថិតនៅក្រោមលក្ខខណ្ឌកំណត់នៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលហេតុនេះ ជនជាប់ចោទមានសិទ្ធិធ្វើការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ បញ្ហានៃលទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋជាតិ ដែលមានអាជ្ញាយុកាលគឺជាបញ្ហាយុត្តាធិការ។ ដីកាដំណោះស្រាយបញ្ជាក់អំពីយុត្តាធិការជាកម្មវត្ថុរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋថ្នាក់ជាតិ។ ដូចនេះ បញ្ហាណាដែលពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋថ្នាក់ជាតិ គប្បីត្រូវបាន ដោះស្រាយនៅដំណាក់កាលនេះ។

**(ច) មូលដ្ឋានទីប្រាំមួយ៖**

៧៧. យោងតាមកថាខណ្ឌ ១៣១២ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តី អៀង សារី តវ៉ានៅក្នុងមូលដ្ឋានទីប្រាំមួយ នៃបណ្តឹងឧទ្ធរណ៍ថា ទោះបីជាសហចៅក្រមស៊ើបអង្កេតបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រឹមត្រូវក៏ដោយ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយអនុវត្តនិយមន័យនេះមិនត្រឹមត្រូវ រហូតឈានទៅធ្វើឱ្យសហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានខុសថា អ.វ.ត.ក មានយុត្តាធិការក្នុងការចោទប្រកាន់ អៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[១៨២]។

៧៨. លើសពីនេះទៀត យោងតាមកថាខណ្ឌ ១៣២០ ដល់ ១៣២៦, ១៣៤០, ១៣៤១, ១៣៤៧ និង ១៣៤៨ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីតវ៉ាថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយយល់ឃើញថា ចេតនានៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គ្រាន់តែត្រូវបានសន្និដ្ឋានតែប៉ុណ្ណោះ ដោយមិនបានរកឱ្យឃើញថា វាជាការសន្និដ្ឋានប្រកបដោយហេតុផល ដោយសំអាងទៅ

[១៨២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨០។

00661542



លើភស្តុតាងដែលមាននោះទេ។ សហមេធាវីការពារក្តីតវ៉ាថា ពុំមានករណីដែលគួរឱ្យជឿ*តាមការមើលជាបឋម* ដើម្បីអនុវត្តបទចោទពីអំពើប្រល័យពូជសាសន៍ប្រឆាំងមកលើលោក អៀង សារី បានទេ ហើយបទចោទនេះ ត្រូវតែដកចេញពីដីកាដំណោះស្រាយ[១៨៣]។

៧៩. ជាចុងក្រោយ យោងតាមកថាខណ្ឌ ១៥២៧ នៃដីកាដំណោះស្រាយ ម្ចាស់បណ្តឹងឧទ្ធរណ៍តវ៉ាថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយការខកខានមិនបានកំណត់ពីអំពើប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលអាចផ្តន្ទាទោសបានដែលបានចោទប្រកាន់លើលោក អៀង សារី និងបានស្នើសុំ “ឱ្យមានការធ្វើកែប្រែដីកាដំណោះស្រាយដើម្បីឱ្យច្បាស់លាស់ថា អៀង សារី មិនត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍”[១៨៤]នោះទេ។

៨០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីមិនបានជំទាស់អំពីយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ សហមេធាវីការពារក្តីមិនបានលើកឡើងអំពីអត្ថិភាពនៃបទឧក្រិដ្ឋតាមផ្លូវច្បាប់ នៅចំពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ ផ្ទុយទៅវិញសហមេធាវីការពារក្តីតវ៉ាថា និយមន័យនៃបទល្មើសដែលបានលើកឡើងថា ការភ័ន្តច្រឡំអាចធ្វើឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការសន្និដ្ឋានអំពីយុត្តាធិការខុស។ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងតវ៉ាទាំងអស់នេះគឺជាទឡ្ហីករណ៍ដែលពាក់ព័ន្ធទៅនឹងការអនុវត្តការអះអាង និងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមិនតំណាងឱ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការដែលអាចទទួលយកបាននោះទេ[១៨៥]។

**(ឆ) មូលដ្ឋានទីប្រាំពីរ៖**

៨១. នៅក្នុងសេចក្តីផ្តើមនៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តី អៀង សារី លើកឡើង

---

[១៨៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨០-១៨២។

[១៨៤] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៤០-១៣៤១។

[១៨៥] សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ante Gotovina និងអ្នកផ្សេងទៀត*, សាលដីកាលើយុត្តាធិការ, កថាខណ្ឌ១៥ *និង ព្រៀបធៀប Prlić និងអ្នកផ្សេងទៀត* សាលដីកា [បន្ទាន់បន្ថែ] ស្តីពីយុត្តាធិការ កថាខណ្ឌ១៣។

ថា ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានរកឃើញថាអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៨៦]។ សហមេធាវីការពារក្តីយោងលើកថាខណ្ឌ ៤៣ នៃសាលដីកា JCE របស់អង្គបុរេជំនុំជម្រះ ដែលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានកំណត់បុរេលក្ខខណ្ឌចំនួនបួន រាល់ការទទួលខុសត្រូវណាមួយ ត្រូវតែបំពេញដើម្បីឱ្យស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ។ គោលបំណងសង្ខេបរបស់ដំណើរការនីតិវិធី អ.វ.ត.ក មានដូចខាងក្រោម៖ ក) បុរេលក្ខខណ្ឌត្រូវតែមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ដោយផ្ទាល់ ឬដោយប្រយោល ខ) បុរេលក្ខខណ្ឌត្រូវតែមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលពាក់ព័ន្ធ គ) ច្បាប់ដែលមានចែងចំពោះទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចដឹងឱ្យបានគ្រប់គ្រាន់នៅពេលពាក់ព័ន្ធចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើនោះ ឃ) ជននោះត្រូវតែអាចប្រមើលដឹងថា គាត់អាចត្រូវសម្រេចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់គាត់ ប្រសិនបើគាត់ត្រូវបានចាប់ខ្លួន។

៨២. ជាក់ស្តែង សហមេធាវីការពារក្តីនិយាយថា លក្ខខណ្ឌតម្រូវទាំងអស់នេះ ត្រូវអនុវត្តយ៉ាងស្មើភាពគ្នាចំពោះបទល្មើសអន្តរជាតិ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ សហមេធាវីការពារក្តីសន្និដ្ឋានថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់និយមន័យនៃពាក្យថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងដីកាដំណោះស្រាយ ដែលពុំសមស្របទៅនឹងលក្ខខណ្ឌតម្រូវទាំងនោះ ក.ស.ច.ស បានប្រើប្រាស់យុត្តាធិការ ដោយផ្អែកទៅតាមការវិភាគច្បាប់ជាធរមាន ពុំបានត្រឹមត្រូវ។ ដូច្នេះសហមេធាវីការពារក្តីបានលើកឡើងអំពីពាក្យសុំរបស់សហចៅក្រមស៊ើបទៅលើកំហុសឆ្គងក្នុងការប្រើប្រាស់និយមន័យនៃពាក្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាកម្មវត្ថុក្នុងការប្តឹងឧទ្ធរណ៍ជំទាស់ ក.ស.ច.ស អនុលោមតាមវិធាន ៧៤(៣)(ក)[១៨៧]។

៨៣. សហមេធាវីការពារក្តីបង្កើតនូវទឡ្ហីករណ៍នៅក្នុងមូលដ្ឋានរងនានាដូចខាងក្រោម ៖

១. និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែពិចារណា អនុលោមតាមគោលការណ៍

[១៨៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, ឆ (ចំណងជើងមូលដ្ឋានទី៧)។

[១៨៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨៤។

*អនុវត្តច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយ* (*lex mitior*)[១៨៨] ហេតុដូច្នេះ និយមន័យនាពេលតំណាលគ្នានេះ ហើយដែលមិននៅក្រោមច្បាប់ប្រពៃណីអន្តរជាតិ អំឡុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ គួរត្រូវយកមកអនុវត្ត[១៨៩]។

២. សហចៅក្រមស៊ើបអង្កេតកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយរៀបរាប់ថា រំលោភការហាមឃាត់មិនឱ្យមានការប្រើប្រាស់សទិសភាព ហេតុដូច្នេះ ក.ស.ច.ស បានប្រើប្រាស់យុត្តាធិការ ដោយផ្អែកតាមការវិភាគវាយតម្លៃពុំបានត្រឹមត្រូវនូវច្បាប់ជាធរមាន[១៩០]។

៣. សហចៅក្រមស៊ើបអង្កេតខកខានពុំបានធ្វើការពន្យល់ថា *ចំណងពាក់ព័ន្ធ*[១៩១] ឬការទាក់ទង រវាងអំពើនានាដែលបានគូសបញ្ជាក់ និងជម្លោះប្រដាប់អាវុធអន្តរជាតិគឺជាលក្ខខណ្ឌកំណត់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក។ ចាប់ពីទសវត្សរ៍ឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៧៩ មានភស្តុតាងតិចតួចស្តួចស្តើងណាស់ ដែលបញ្ជាក់អំពីទម្លាប់អនុវត្តទូទៅរបស់រដ្ឋ និងទស្សនៈនៃច្បាប់ ដែលថាចំណង*ពាក់ព័ន្ធ* នេះលែងជាធាតុផ្សំមួយចាំបាច់ទៀតហើយ[១៩២]។

៤. សហចៅក្រមស៊ើបអង្កេតខកខានពុំបានរាប់បញ្ចូលអត្ថិភាព នៃគោលនយោបាយចាត់តាំង ឬគោលនយោបាយរដ្ឋថាជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅ អ.វ.ត.ក ហេតុដូច្នេះ ក.ស.ច.ស បានប្រើប្រាស់យុត្តាធិការដោយផ្អែកតាមការវិភាគវាយតម្លៃពុំបានត្រឹមត្រូវនូវច្បាប់ជាធរមាន[១៩៣]។

៥. សហចៅក្រមស៊ើបអង្កេតពុំបានកំណត់ត្រឹមត្រូវតាមលក្ខណៈច្បាប់នូវអង្គហេតុនានា

---

[១៨៨] គោលការណ៍អនុវត្តច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយ ប្រសិនបើមានការចោទប្រកាន់នៅក្នុងច្បាប់នោះ ត្រូវបានស្គាល់ជាឃ្លាជាភាសាឡាតាំងថា "*lex mitior*"។

[១៨៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨៥។

[១៩០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨៦-១៨៧ យោងកថាខណ្ឌ១៤៧០ និងជើងទំព័រ៥២៧៦ នៃដីកាដំណោះស្រាយ។

[១៩១] ពាក្យឡាតាំង '*nexus*' មានន័យថា 'ការជាប់ពាក់ព័ន្ធ ឬទំនាក់ទំនង ជារឿយៗជាទំនាក់ទំនងធម្មតា'៖ វចនានុក្រម Black's Law។

[១៩២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨៨-១៨៩។

[១៩៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៩០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ដែលគេជឿថាបានបញ្ជាក់អំពីអត្ថិភាពនៃ"ការវាយប្រហារ"[១៩៤] ដែលបង្ហាញពី "ការវាយប្រហារដែលរីករាលដាលគ្រប់ទីកន្លែង និងជាលក្ខណៈប្រព័ន្ធ"[១៩៥] និងបានប្រើប្រាស់យុត្តាធិការដោយផ្អែកតាមការវិភាគវាយតម្លៃពុំបានត្រឹមត្រូវនូវច្បាប់ជាធរមាន។

៦. ដើម្បីបង្កើតបានជាភស្តុតាងនៃការវាយប្រហារសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ក.ស.ច.ស បានបំពានសិទ្ធិអំណាចរបស់ខ្លួន ដោយធ្វើការពិចារណាទៅលើអំពើ ដែលពុំស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[១៩៦]។

៧. ដើម្បីបង្កើតបានជាភស្តុតាង នៃការវាយប្រហារតាមមូលហេតុរើសអើង ក.ស. ច.ស បានបំពានសិទ្ធិអំណាចរបស់ខ្លួន ដោយធ្វើការពិចារណាទៅលើអំពើដែលពុំស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[១៩៧]។

៨. សហចៅក្រមស៊ើបអង្កេតបានកំណត់ពុំបានត្រឹមត្រូវនូវអង្គហេតុនានា ដែលគេជឿថាបានបញ្ជាក់ឱ្យឃើញនូវធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហេតុដូច្នេះបានប្រើប្រាស់យុត្តាធិការពុំបានត្រឹមត្រូវ[១៩៨]។

៩. សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ដោយសំអាងលើការប្រើប្រាស់នូវនិយមន័យមិនត្រឹមត្រូវ ដែលបានលើកឡើងនៃធាតុផ្សំជាច្រើននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៩៩]។

១០. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយបានយល់ឃើញ ការដាក់ក្នុងមន្ទីរឃុំឃាំង ថាជាអំពើដែលបានរៀបរាប់បង្កឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការដាក់ក្នុងមន្ទីរឃុំឃាំងមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០០]។

---

[១៩៤] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៩១ យោងកថាខណ្ឌ១៣៥១ នៃដីកាដំណោះស្រាយ។

[១៩៥] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៩២-១៩៤ យោងកថាខណ្ឌ១៣៥២, ១៣៥៣, ១៣៥៥, ១៣៥៧ និង១៣៥៨ នៃដីកាដំណោះស្រាយ។

[១៩៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៩៥-១៩៧ យោងកថាខណ្ឌ១៣៦៣, ១៣៦៤ នៃដីកាដំណោះស្រាយ។

[១៩៧] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៩៧-១៩៩ យោងកថាខណ្ឌ១៣៦៥ មើលភ្ជាប់ជាមួយកថាខណ្ឌ ១៣៧១, ១៣៦៦, ១៣៦៧, ១៣៦៨ និង ១៣៩៦ នៃដីកាដំណោះស្រាយ។

[១៩៨] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០០។

[១៩៩] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០១-២០៤ និង២១០។

[២០០] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០៥-២០៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00661546



១១. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយបានយល់ឃើញ ការធ្វើទារុណកម្មថាជាអំពើដែលបានរៀបរាប់បង្កឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការធ្វើទារុណកម្មមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០១]។

១២. សហចៅក្រមស៊ើបអង្កេតខកខានមិនបានបញ្ជាក់ពីភស្តុតាងអង្គហេតុអំពើឧក្រិដ្ឋដែលរងការចោទប្រកាន់[២០២]។

១៣. ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតមិនមានភាពជាក់លាក់គ្រប់គ្រាន់នោះឡើយ[២០៣]។

១៤. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយបានយល់ឃើញ ការរំលោភផ្លូវភេទថាជាអំពើដែលបានរៀបរាប់បង្កឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០៤]។

១៥. សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំដោយយល់ឃើញថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាបទល្មើសមូលដ្ឋានបង្កឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ។ សហចៅក្រមស៊ើបអង្កេតបន្ថែមថា ដោយតុលាការជាតិកម្ពុជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលជាមូលដ្ឋាននោះ អ.វ.ត.ក មានយុត្តាធិការទៅលើតែឧក្រិដ្ឋកម្មទាំងឡាយណាដែលច្បាប់បានចែងយ៉ាងច្បាស់ប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអះអាងថា សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានវិនិច្ឆ័យដោយផ្អែកលើគោលការណ៍រំលោភបំពានភាពជាក់លាក់និងមួយវិញទៀតដើម្បីបង្កើតជាទម្រង់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[២០៥]។

១៦. សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំ ដោយបានយល់ឃើញថា ការរៀបការដោយបង្ខំបណ្តាលឱ្យមាន "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលអាចយកមកអនុវត្តបាន។ ការរៀបការដោយបង្ខំ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានរៀបរាប់នៅក្នុងច្បាប់

---

[២០១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០៨-២០៩។

[២០២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២១១-២១៣។

[២០៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២១៤-២១៧។

[២០៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២១៨-២១៩។

[២០៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២០។

00661547



ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០៦]។

១៧. សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំ ដោយបានយល់ឃើញថា អំពើហិង្សាផ្លូវភេទបណ្តាលឲ្យមាន "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ អំពើហឹង្សាផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានរៀបរាប់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០៧]។

១៨. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយបានយល់ឃើញថា ការជម្លៀសប្រជាជនដោយបង្ខំគឺជាអំពើដែលបណ្តាលឲ្យមាន "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ មាត្រា ៤ នៃអ.វ.ត.ក ចែងអំពីការជម្លៀសប្រជាជនដោយបង្ខំ ថាជាអំពើប្រល័យពូជសាសន៍ តែមិនមែនជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ហេតុដូច្នេះ អ.វ.ត.ក មានយុត្តាធិការតែលើឧក្រិដ្ឋកម្មទាំងឡាយណា ដែលត្រូវបានច្បាប់ចែងយ៉ាងច្បាស់លាស់ប៉ុណ្ណោះ "ការជម្លៀសប្រជាជនដោយបង្ខំ" មិនគួរចោទប្រកាន់ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះទេ[២០៨]។

១៩. សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំ ដោយបានយល់ឃើញថា ការបាត់ខ្លួនដោយបង្ខំបណ្តាលឲ្យមាន "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ការបាត់ខ្លួនដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានរៀបរាប់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[២០៩]។

៨៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងអនុមូលដ្ឋានមួយចំនួននៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ដែលត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើរួមមាន ៖ កថាខណ្ឌរង ៣ ("ទទ្ធីករណ៍ស្តីពីចំណងពាក់ព័ន្ធ")[២១០]។ កថាខណ្ឌរង ១០ ("ទទ្ធីករណ៍ស្តីពីការដាក់នៅក្នុងមន្ទីរឃុំឃាំង")[២១១]។

---

[២០៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៣។

[២០៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៥។

[២០៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៦។

[២០៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣០។

[២១០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ១៨៨-១៨៩។

[២១១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០៥-២០៧។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00661548



កថាខណ្ឌរង ១១ (“ទឡ្ហីករណ៍ស្តីពីការធ្វើទារុណកម្ម”)[២១២]។ កថាខណ្ឌរង ១៤ (“ទឡ្ហីករណ៍ស្តីពីការរំលោភផ្លូវភេទ”)[២១៣]។ កថាខណ្ឌរង ១៥ (“ទឡ្ហីករណ៍ស្តីពីអំពើអមនុស្សធម៌ផ្សេងទៀត”)[២១៤]។ កថាខណ្ឌរង ១៦ (“ទឡ្ហីករណ៍ស្តីពីការរៀបការដោយបង្ខំ”)[២១៥]។ កថាខណ្ឌរង ១៧ (“ទឡ្ហីករណ៍ស្តីពីអំពើហិង្សាផ្លូវភេទ”[២១៦] និងកថាខណ្ឌរង ១៩ (“ទឡ្ហីករណ៍ស្តីពីការបាត់ខ្លួនដោយបង្ខំ”)[២១៧] សហមេធាវីការពារក្តីលើកឡើងអំពីអត្ថិភាពផ្លូវច្បាប់ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៃប្រភេទមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលតំណាងឲ្យទឡ្ហីករណ៍ដែលជាខ្លឹមសារនៃការវិនិច្ឆ័យស្របតាមគោលការណ៍នីត្យានុកូលភាព ដូចនេះហើយតំណាងឲ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការដែលអាចទទួលយកបាន។

៨៥. នៅក្នុងអនុកថាខណ្ឌ ១, ២ និង ៩ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានកំណត់និយមន័យដោយភ័ន្តច្រឡំអំពីបទល្មើស ឬធាតុផ្សំនៃបទល្មើស។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ទាំងអស់ទាក់ទងទៅនឹងការអនុវត្តការអះអាង និងមិនតំណាងឲ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការនោះឡើយ។

៨៦. នៅក្នុងមូលដ្ឋានរងទីបួន ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីមានការពាក់ព័ន្ធទៅនឹងទម្រង់នៃធាតុផ្សំនៃបទល្មើស ហេតុដូច្នេះហើយទាក់ទងទៅនឹងការអនុវត្តការអះអាង និងមិនតំណាងឲ្យបណ្តឹងផ្នែកយុត្តាធិការនោះទេ។

៨៧. នៅក្នុងមូលដ្ឋានរងទីប្រាំ និងទីប្រាំបី ការលើកឡើងរបស់សហមេធាវីការពារក្តីដែលថា សហចៅក្រមស៊ើបអង្កេតបានធ្វើការកំណត់មិនត្រឹមត្រូវ អំពីអង្គហេតុនានាដែលបានលើកឡើងថាបង្ហាញពី

---

[២១២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២០៨-២០៩។
[២១៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២១៨-២១៩។
[២១៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២០។
[២១៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៣។
[២១៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៥។
[២១៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣០។

ធាតុផ្សំនៃបទល្មើសនោះ មិនតំណាងឱ្យបណ្តឹងផ្នែកយុត្តាធិការនោះទេ។ ទឡ្ហីករណ៍ទាំងអស់នេះ មានការទាក់ទងទៅនឹងបញ្ហាអង្គច្បាប់ និងអង្គហេតុ ព្រមទាំងការអនុវត្តការអះអាងទាក់ទងទៅនឹង បញ្ហាដែលត្រូវមានការពាក់ព័ន្ធនៅពេលសវនាការ។

៨៨. នៅក្នុងមូលដ្ឋានរងទីប្រាំមួយ និងទីប្រាំពីរ សហមេធាវីការពារក្តីតវ៉ាអំពីការពិចារណាសហចៅក្រម ស៊ើបអង្កេតទៅលើអំពើដែលពុំស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែលតំណាងឱ្យ ទឡ្ហីករណ៍ដែលមានការទាក់ទងទៅនឹងបញ្ហាអង្គហេតុ និងអង្គច្បាប់ ដែលត្រូវលើកឡើងនៅពេល សវនាការល្អជាង។ បន្ទាប់ពីបានធ្វើការអង្កេត អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កិច្ចពិភាក្សា អំពីបញ្ហាដែលមិនស្ថិតនៅក្នុងពេលវេលា នៃការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះអាចមានការពាក់ ព័ន្ធទៅនឹងបរិបទ និងការបន្តការប្រព្រឹត្ត[២១៨]។

៨៩. មូលដ្ឋានរងទីដប់ពីរ និងទីដប់បី ជាមូលដ្ឋានដែលសហមេធាវីការពារក្តីតវ៉ាថា ការអះអាងរបស់ សហចៅក្រមស៊ើបអង្កេតខ្វះភាពជាក់លាក់ឱ្យបានគ្រប់គ្រាន់ មិនមែនជាមូលដ្ឋានសម្រាប់បណ្តឹង ជំទាស់ផ្នែកយុត្តាធិការនោះទេ ពីព្រោះមូលដ្ឋានរងទាំងនោះមានការទាក់ទងទៅនឹងបញ្ហាអង្គហេតុ និងអង្គច្បាប់។

៩០. ពាក់ព័ន្ធទៅនឹងមូលដ្ឋានរងទីដប់បួន ("ទឡ្ហីករណ៍ស្តីពីការរំលោភផ្លូវភេទ") អង្គបុរេជំនុំជម្រះនឹង មិនពិនិត្យ ឬសម្រេចលើទឡ្ហីករណ៍របស់សហមេធាវីការពារក្តីនៅក្នុងកថាខណ្ឌ ២១៩ នៃបណ្តឹង ឧទ្ធរណ៍នោះទេ ពីព្រោះទឡ្ហីករណ៍ទាំងអស់នេះពាក់ព័ន្ធជាពិសេសទៅនឹងវិធីដែលសហចៅក្រម ស៊ើបអង្កេតបានកំណត់និយមន័យការរំលោភផ្លូវភេទ ក្រៅពីអត្ថិភាពនៃការរំលោភផ្លូវភេទដែល កើតមាននៅក្នុងច្បាប់ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

[២១៨] សូមមើល សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការ បញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D365/2/17, កថាខណ្ឌ៩១។

៩១. នៅក្នុងមូលដ្ឋានរងទីដប់ប្រាំបី ("ទស្សីករណ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ")[២១៩] សហមេធាវីការពារក្តីមិនជំទាស់ផ្លូវច្បាប់អំពីអត្ថិភាពនៃ "ការជម្លៀសប្រជាជនដោយបង្ខំ" នោះទេ ផ្ទុយទៅវិញ សហមេធាវីការពារក្តីជំទាស់នឹងចំណាត់ថ្នាក់មិនត្រឹមត្រូវ របស់សហចៅក្រមស៊ើបអង្កេតដែលថា ការជម្លៀសប្រជាជនដោយបង្ខំគឺជាធាតុផ្សំមួយនៃបទល្មើសមួយ ឬមួយទៀត ដែលជាទស្សីករណ៍ ដែលជាការអនុវត្តការអះអាង ហេតុដូច្នេះហើយមិនតំណាងឲ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការដែលអាចទទួលយកបានឡើយ។

*(ជ) មូលដ្ឋានទីប្រាំបី៖*

៩២. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា ការភ័ន្តច្រឡំអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតទៅលើភាពសំនុំរឿងរបស់ពួកគេស្តីអំពីការរំលោភបំពានធ្ងន់ធ្ងរទាំងនោះ គួរតែត្រូវបានយល់ឃើញថាអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញ។ ដោយយោងតាមកថាខណ្ឌ ១៣១៧ និងជើងទំព័រលេខ ៥២០២ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយខកខានមិនបានកំណត់អំពីលក្ខខណ្ឌកំណត់សម្រាប់ជម្លោះប្រដាប់អាវុធអន្តរជាតិ[២២០]។ យោងតាមកថាខណ្ឌ ១៤៨២ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយខកខានមិនបានកំណត់និយមន័យនៃពាក្យជនដែលត្រូវការពារឲ្យបានច្បាស់លាស់ និងដោយសារតែយុត្តាធិការតាមពេលវេលា និយមន័យនៃពាក្យ "ជនដែលត្រូវការពារ" នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញរាប់បញ្ចូលតែជនដែលត្រូវបានការពារផ្អែកតាមសញ្ជាតិរបស់ខ្លួន[២២១]។ យោងតាមកថាខណ្ឌ ១៤៨៣ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយខកខាន មិនបានកំណត់ឲ្យបានច្បាស់លាស់អំពីភាពចាំបាច់នៃ*ការជាប់ទាក់ទងគ្នា* រវាងជម្លោះប្រដាប់អាវុធអន្តរជាតិ និងបទល្មើសនានា និងថា ការខកខាននេះបានធ្វើឲ្យសហចៅក្រមស៊ើបអង្កេតប្រើប្រាស់យុត្តាធិការ "ដោយមិនបានរកឃើញថា ធាតុផ្សំទាំងអស់នៃការរំលោភបំពានធ្ងន់

[២១៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២២៦។

[២២០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣៥, ជើងទំព័រ៣៧១ ទាញហេតុសំអាង អនុសញ្ញាក្រុងហ្សឺណែវមាត្រា២។

[២២១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣៦-២៣៧។

ធ្ងរ ត្រូវបានបំពេញ”[២២២]។ យោងតាមកថាខណ្ឌ ១៤៩៣ និង ១៤៩២ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការអនុវត្ត *ធាតុផ្សំអត្តនោម័ត*[២២៣] មិនត្រឹមត្រូវ ចំពោះអំពើមនុស្សឃាតដោយចេតនា។ សហមេធាវីការពារក្តីលើកឡើងថា “ការយល់ដឹងសមហេតុផលតែឯកឯង ទំនងជាមានការស្លាប់ ដោយអវត្តមាននូវចេតនាសម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ មិនបង្កើតបានជាអំពើមនុស្សឃាតដោយចេតនាឡើយ”[២២៤]។ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយមិនបានកំណត់អំពីលក្ខខណ្ឌតម្រូវនៃការធ្វើទារុណកម្ម[២២៥]។ យោងតាមកថាខណ្ឌ ១៥០១ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយខកខានមិនបានលើកឡើងឱ្យបានពេញលេញ អំពីលក្ខខណ្ឌនៃការធ្វើបាបដោយអមនុស្សធម៌[២២៦]។ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយប្រើប្រាស់មិនត្រឹមត្រូវនូវធាតុផ្សំអត្តនោម័តនៃការបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសស្នាមធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព[២២៧]។ យោងតាមកថាខណ្ឌ ១៥០៩, ១៥១៣ និង ១៥១០ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយខកខានមិនបានលើកឡើងឱ្យបានពេញលេញ អំពីលក្ខខណ្ឌនៃការដកហូតសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងទៀងទាត់[២២៨]។

៩៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការលើកឡើងរបស់សហមេធាវីការពារក្តីទាំងអស់នេះ មិនជំទាស់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះទៅលើការរំលោភបំពានធ្ងន់ធ្ងរនោះទេ។ ផ្ទុយទៅវិញ ការលើកឡើងជំទាស់ទៅនឹងវិធីដែលសហចៅក្រមស៊ើបអង្កេតធ្វើការកំណត់អនុវត្ត ឬ លើកឡើងអំពី

---

[២២២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣៨។

[២២៣] ពាក្យឡាតាំង *mens rea* មានន័យក្នុងភាសាអង់គ្លេសថា “ចេតនាឧក្រិដ្ឋ” ឬ “សភាពនៃចិត្តដែលការប្រព្រឹត្តនោះ ត្រូវតែបង្ហាញថាជនជាប់ចោទមានចេតនានោះនៅពេលដែលប្រព្រឹត្តបទឧក្រិដ្ឋ ដើម្បីធានាដល់ការផ្តន្ទាទោស; ចេតនាឧក្រិដ្ឋ ឬការធ្វេសប្រហែស”។ វចនានុក្រម Black’s Law ។

[២២៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៣៩-២៤០។

[២២៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៤១។

[២២៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៤២-២៤៣។

[២២៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៤៤-២៤៦។

[២២៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៤៧-២៤៨។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C.

លក្ខខណ្ឌតម្រូវសម្រាប់បទល្មើស ឬធាតុផ្សំនៃបទល្មើសច្រើន។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទាំងអស់នេះជាការជំទាស់ដែលទាក់ទងទៅនឹងកំហុសនានា ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬការអនុវត្តការអះអាងដែលអាចត្រូវបានធ្វើឱ្យកើនឡើងយ៉ាងត្រឹមត្រូវ និងត្រូវបានជជែកតវ៉ានៅក្នុងពេលដំណើរការសវនាការ។

*(ឈ) មូលដ្ឋានទីប្រាំបួន៖*

៩៤. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់នៅក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួម[២២៩]។ នៅក្នុងកថាខណ្ឌ ២៥៩ ដល់ ២៦៣ នៃបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីមិនបានយោងលើចំណុចណាមួយនៃដីកាដំណោះស្រាយនោះទេ ផ្ទុយទៅវិញ សហមេធាវីការពារក្តីយោងលើសាលដីកា JCE របស់អង្គបុរេជំនុំជម្រះដែលបានលើកឡើងថា សហមេធាវីការពារក្តីមិនស្នើសុំឱ្យមានការពិចារណាឡើងវិញអំពីសេចក្តីសម្រេចនោះទេ ប៉ុន្តែស្នើសុំរក្សាសិទ្ធិធ្វើការលើកឡើងនូវបញ្ហានេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ អង្គបុរេជំនុំជម្រះមិនបានចាត់ទុកចំណុចនេះថាជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នោះទេ ប៉ុន្តែវាគ្រាន់តែជាសេចក្តីជូនដំណឹងអំពីយុទ្ធសាស្ត្រការពារក្តីតែប៉ុណ្ណោះ។

៩៥. ចាប់ពីកថាខណ្ឌ ២៦៤ តទៅ នៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដោយបានឃើញសេចក្តីសន្និដ្ឋានកាលពីលើកមុនរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹង JCE I ម្ចាស់បណ្តឹងឧទ្ធរណ៍តវ៉ាថា ទោះបីជាសហឧក្រិដ្ឋកម្មរួមត្រូវបានរកឃើញថាអាចអនុវត្តបាន ជាពិសេសនៅក្នុងរឿងក្តីរបស់ អៀង សារី ក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញពុំមានយុត្តាធិការក្នុងការអនុវត្ត JCE I នោះទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តដោយប្រើប្រាស់ *ធាតុផ្សំអត្តនោម័ត*[២៣០] មិនត្រឹមត្រូវ ពាក់ព័ន្ធនឹងការចូលរួមរបស់ អៀង សារី នៅក្នុងផែនការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួម និងនៅក្នុងការយល់ឃើញថា ផែនការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួមត្រូវបានពន្លាតដល់ការប្រព្រឹត្ត

---

[២២៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៥៩-២៧២។

[២៣០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៦៥-២៦៩ យោងកថាខណ្ឌ១៥២៤-១៥២៥, ១៥៣៤ នៃដីកាដំណោះស្រាយ។

អំពើប្រល័យពូជសាសន៍ ដោយពុំមានការបង្ហាញអំពីចេតនាជាក់លាក់នោះទេ[២៣១]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងមូលដ្ឋានរងនៃមូលដ្ឋានទីប្រាំបួននៃបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីចោទប្រកាន់អំពីការភ័ន្តច្រឡំលើបញ្ហាចម្រុះនៃអង្គហេតុ និងអង្គច្បាប់ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ សហមេធាវីការពារក្តីពុំបានជំទាស់ទៅនឹងការបញ្ជាក់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះលើបញ្ហា JCE I នោះទេ ផ្ទុយទៅវិញសហមេធាវីការពារក្តីជំទាស់អំពីវិធីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋាននេះមិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះទេ។

*(ញ) មូលដ្ឋានទីដប់៖*

៩៦. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការកំហុសអង្គច្បាប់នៅក្នុងការអនុវត្តការធ្វើផែនការ ការញុះញង់ ការបង្គាប់បញ្ជារ ការជួយនិងជំរុញ[២៣២]។ ដោយបានដកស្រង់កថាខណ្ឌ ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់នៅក្នុងការអនុវត្តទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ៖

១. ដោយខកខានមិនបានកំណត់ប្រភេទបទល្មើសទៅតាមអង្គហេតុទាំងឡាយឱ្យបានគ្រប់គ្រាន់ (មូលដ្ឋានរងទីមួយ)[២៣៣]។

២. ដោយបានលើកឡើង និងប្រើប្រាស់ធាតុផ្សំអត្តនោម័តមិនបានត្រឹមត្រូវ (មូលដ្ឋានរងទីពីរ)[២៣៤]។

៣. ដោយលើកឡើងថា ទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះអាចយកមកអនុវត្ត ដោយការបន្ថែម ឬដោយការជំនួស ចំពោះសហឧក្រិដ្ឋកម្មរួម (មូលដ្ឋានរងទីបី)[២៣៥]។

៤. ដោយមិនបានលើកឡើងថា ការរៀបចំផែនការ "ត្រូវតែជាកត្តាចូលរួមយ៉ាងសំខាន់" និង

---

[២៣១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៧០-២៧២ យោងកថាខណ្ឌ១៥២៧ នៃដីកាដំណោះស្រាយ។

[២៣២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៧៣-២៨២។

[២៣៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៧៣-២៧៤។

[២៣៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៧៥-២៨០។

[២៣៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨១។

ក្នុងការប្រើប្រាស់បទដ្ឋានខុសសម្រាប់ការជួយនិងជំរុញ (ដែលតម្រូវឲ្យមាន"ឥទ្ធិពលច្បាស់លាស់" ដែលមិនត្រឹមត្រូវ ជាជាងគ្រាន់តែ "មានឥទ្ធិពលសំខាន់")។ (មូលដ្ឋានរងទីបួន)[២៣៦]។

៩៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការលើកឡើងរបស់សហមេធាវីការពារក្តីក្រោមមូលដ្ឋានទីដប់មិនមែនជាការជំទាស់ទៅនឹងអត្ថិភាពនៃទម្រង់ណាមួយ ក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវនោះទេ ឬការទទួលស្គាល់ទម្រង់ទាំងនោះក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលពាក់ព័ន្ធនោះទេ។ ផ្ទុយទៅវិញ សហមេធាវីការពារក្តីតវ៉ាថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះចំពោះអង្គហេតុនានាដែលត្រូវបានកំណត់ នៅក្នុងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ឬថា ធាតុផ្សំនានានៃទម្រង់នៃការទទួលខុសត្រូវ ត្រូវបានកំណត់និយមន័យមិនត្រឹមត្រូវ។ ទាំងអស់នេះមិនចាត់ទុកថា ជាការជំទាស់ផ្នែកយុត្តាធិការនោះទេ ផ្ទុយទៅវិញជាការចោទប្រកាន់អំពីកំហុសនានា នៅក្នុងការអះអាងក្នុងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ។ ពុំមានការជំទាស់ទៅនឹងការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះស្របតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដែលទាមទារឲ្យធ្វើមោឃភាពដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសារកំហុសនីតិវិធី (សម្រាប់ការខកខានមិនបានកំណត់អំពីការពណ៌នាអំពីអង្គហេតុសត្យានុម័ត និងការកំណត់លក្ខណៈផ្លូវច្បាប់អំពីអង្គហេតុទាំងនោះ) អាចត្រូវបានរៀបចំឡើងនៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ។ វិធាន ៨០ ស្ទួន និង ៨៩ នៃវិធានផ្ទៃក្នុងបានចែងអំពីនីតិវិធីសម្រាប់ការជំទាស់នេះ។ ទាំងអស់នេះគឺជាបញ្ហាតែមួយគត់នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។

### *(ង) មូលដ្ឋានទីដប់មួយ៖*

៩៨. សហមេធាវីការពារក្តី អៀង សារី លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការអនុវត្តនៅ អ.វ.ត.ក នូវការទទួលខុសត្រូវរបស់ថ្នាក់លើ ប្រសិនបើយល់ឃើញថាអាចអនុវត្ត

[២៣៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨២។

បាននៅ អ.វ.ត.ក[២៣៧] ។ សហមេធាវីការពារក្តីលើកឡើងនូវទឡ្ហីករណ៍នៅក្នុងមូលដ្ឋានរង ដូចខាងក្រោម៖

១) ការទទួលខុសត្រូវរបស់ថ្នាក់លើពុំមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩[២៣៨] នោះទេ ពីព្រោះ៖

ក. រឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរ ពុំកំណត់ច្បាស់លាស់អំពីធាតុផ្សំនានា[២៣៩] ។

ខ. ទម្លាប់អនុវត្តរបស់រដ្ឋមិនបង្ហាញអំពីទំនៀមទម្លាប់ដែលមានមុនឆ្នាំ ១៩៧៥ នោះទេ[២៤០] ។

គ. ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ I មិនចងក្រងជាច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ[២៤១] ។

២) ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានការភ័ន្តច្រឡំ ទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើ និងលែងមានសុពលភាពចំពោះកង្វះការបញ្ជាក់ឱ្យបានច្បាស់លាស់[២៤២] ។

៣) សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ពីព្រោះ៖

ក. សហចៅក្រមស៊ើបអង្កេតត្រូវកម្រិតការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រឹមតែស្ថានភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ[២៤៣] ។

ខ. សហចៅក្រមស៊ើបអង្កេតត្រូវយល់ឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចត្រឹមតែយកមកអនុវត្តចំពោះមេបញ្ជាការយោធាតែប៉ុណ្ណោះ។ ពុំមានការអនុវត្តរបស់រដ្ឋស៊ីសង្វាក់គ្នា ក្នុងការដាក់បន្ទុកនូវការទទួលខុសត្រូវលើថ្នាក់លើដែលមិនមែនជាយោធា ចំពោះអំពើដែលប្រព្រឹត្តដោយអ្នកក្រោមឱវាទរបស់ខ្លួន

[២៣៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨៣-៣២៤។

[២៣៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨៣-២៨៤។

[២៣៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨៥-២៩២។

[២៤០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៩៣-២៩៧។

[២៤១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៩៨-៣០២។

[២៤២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣០៣-៣០៦។

[២៤៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣០៧-៣១៣។

00661556



ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[២៤៤] នោះទេ។

គ. សហចៅក្រមស៊ើបអង្កេតត្រូវយល់ឃើញថា ត្រូវមានទំនាក់ទំនងហេតុផល និងរវាងអំពើរបស់ថ្នាក់លើ និងបទល្មើសដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន និងនៅពេលដែលថ្នាក់លើជាជនស៊ីវិលមានកាតព្វកិច្ចជាមុនតាមផ្លូវច្បាប់ ដើម្បីទប់ស្កាត់ និងដាក់ទណ្ឌកម្ម[២៤៥]។

ឃ. សហចៅក្រមស៊ើបអង្កេតត្រូវយល់ឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចអនុវត្តចំពោះបទល្មើសដែលមានចេតនាពិសេស ដូចជា អំពើប្រល័យពូជសាសន៍ បានទេ[២៤៦]។

៩៩. សហមេធាវីការពារក្តីបានយោងយ៉ាងច្បាស់លាស់លើកថាខណ្ឌ ១៣១៩ និង ១៥៥៨ នៃដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ផ្នែកផ្សេងៗទៀតនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ទាំងអស់នេះ តែសហមេធាវីការពារក្តីមិនបានយកធ្វើជាសំអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ គឺកថាខណ្ឌ ១៣០៧, ១៣១៨, ១៥៥៧, ១៥៥៩, ១៥៦០ និង ១៦១៣។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទ "ដោយសារតែការទទួលខុសត្រូវរបស់ថ្នាក់លើ"[២៤៧] ចំពោះអំពើប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហេតុដូច្នេះ ដីកាដំណោះស្រាយគឺជាដីកា ឬសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ សម្រាប់ទម្រង់នៃការទទួលខុសត្រូវនេះ។

១០០. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានរងទីមួយ នៃមូលដ្ឋានទីដប់មួយដែលបានជំទាស់ទៅនឹងអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅពេលដែលទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលប្រព្រឹត្តបទល្មើសដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយតំណាងឱ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការ។

---

[២៤៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣១៤-៣១៥។

[២៤៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣១៦-៣២២។

[២៤៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣២៣-៣២៤។

[២៤៧] ដីកាដំណោះស្រាយ, កថាខណ្ឌ១៦១៣។



* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

១០១. មូលដ្ឋានរងទីពីរ នៃមូលដ្ឋានទីដប់មួយ ដែលលើកឡើងពីកង្វះការបញ្ជាក់ច្បាស់លាស់ នៅក្នុងការចោទប្រកាន់មិនបានលើកឡើងពីការជំទាស់ផ្នែកយុត្តាធិការស្របតាមវិធាន ៧៤(៣)(ក) នោះទេ។

១០២. មូលដ្ឋានរងទីបី នៃមូលដ្ឋានទីដប់មួយ ត្រង់ផ្នែកទាក់ទងទៅនឹងទឡ្ហីករណ៍ដែលថា ពុំមានការអនុវត្តរបស់រដ្ឋស៊ីសង្វាក់គ្នាក្នុងការដាក់បន្ទុកនូវការទទួលខុសត្រូវជល់ថ្នាក់លើ ដែលមិនមែនជាយោធា ចំពោះអំពើដែលប្រព្រឹត្តដោយអ្នកក្រោមឱវាទរបស់ខ្លួន ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺជាការជំទាស់ផ្នែកយុត្តាធិការដែលអាចទទួលយកបាន។ ផ្នែកដែលនៅសល់នៃមូលដ្ឋានរងនេះបង្ហាញពីបញ្ហាចម្រុះនៃអង្គហេតុ និងអង្គច្បាប់ ហើយបញ្ហានៃដំណើរនៃទម្រង់នៃការទទួលខុសត្រូវទាំងនេះ ដែលផ្ទុយទៅនឹងអត្ថិភាពនៃបញ្ហាទាំងអស់នេះ មិនមែនជាការជំទាស់ផ្នែកយុត្តាធិការនោះទេ[២៤៨]។

<u>ការសន្និដ្ឋានអំពីភាពអាចទទួលយកបាន ៖</u>

១០៣. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទីបួន ទីប្រាំមួយ ទីប្រាំពីរ(ផ្នែកខ្លះ) ទីប្រាំបី ទីប្រាំបួន ទីដប់ និងទីដប់មួយ(ផ្នែកខ្លះ) មិនអាចទទួលយកបានទេ។ ផ្នែកដែលនៅសល់នៃមូលដ្ឋាននានា អាចទទួលយកបាន ហើយនឹងត្រូវបានពិភាក្សាលើអង្គសេចក្តី នៅក្នុងកថាខណ្ឌជាបន្តបន្ទាប់ដូចខាងក្រោម។

## <u>គ. មូលដ្ឋាននៃការពិនិត្យឡើងវិញ</u>

<u>វិសាលភាពនៃការពិនិត្យសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ៖</u>

១០៤. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងលេខ ០០១ ក្នុងការកត់សម្គាល់ទូទៅពាក់ព័ន្ធទៅនឹងវិសាលភាពនៃការពិនិត្យសម្រាប់ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" អង្គបុរេជំនុំជម្រះយល់ឃើញថា ៖

> "ដោយបានពិចារណាលើវិធានផ្ទៃក្នុងពាក់ព័ន្ធជាមួយនឹងតួនាទីរបស់អង្គបុរេជំនុំជម្រះ ថាជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងពិសេសជាងនេះទៀត ពេលវេលាបានកំណត់ អង្គបុរេជំនុំ

[២៤៨] *Gotovina* *និងអ្នកផ្សេងទៀត។ សាលដីកាលើយុត្តាធិការ កថាខណ្ឌ២៣-២៤។*

ជម្រះសាលាដំបូងយល់ឃើញថា វិសាលភាពនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ត្រូវបានកម្រិតចំពោះតែបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ”[២៤៩]។

## បទដ្ឋាននៃការពិនិត្យឡើងវិញ៖

១០៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះត្រូវបានដាក់ដោយជនជាប់ចោទ ដែលច្បាប់បានដឹងជាមុនអំពីសិទ្ធិមានកំណត់ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលជាករណីបណ្តឹងជំទាស់ទៅនឹងការបញ្ជាក់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ដូចមានចែងជាពិសេសនៅក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

១០៦. ជនជាប់ចោទស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការកែប្រែដីកាដំណោះស្រាយ ដោយលើកឡើងថា អង្គជំនុំជម្រះវិសាមញ្ញពុំមានយុត្តាធិការលើបទល្មើសមួយចំនួន និងលើទម្រង់នៃការទទួលខុសត្រូវនោះទេ ហេតុដូច្នេះ គឺត្រូវតែមានការកាត់បន្ថយចំនួនបទចោទប្រកាន់លើជនត្រូវចោទ[២៥០]។ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងលេខ ០០១ អង្គបុរេជំនុំជម្រះយល់ឃើញថា ៖

---

[២៤៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/1/26 កថាខណ្ឌ២៩។

[២៥០] បណ្តឹងឧទ្ធរណ៍ អៀង សារី ផ្នែក IV។ (ដោយលើកឡើងថា អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការបញ្ជូន អៀង សារី ទៅជំនុំជម្រះនោះទេ ផ្អែកតាមគោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ។ លើកឡើងថា អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការបញ្ជូន អៀង សារី ទៅជំនុំជម្រះនោះទេ ផ្អែកតាមព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស។ ជាជម្រើសម្យ៉ាងទៀត លើកឡើងថា អ.វ.ត.ក ពុំមានយុត្តាធិការលើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរ ឬបទល្មើសថ្នាក់ជាតិនោះទេ ឬជាជម្រើសមួយវិញទៀត យល់ឃើញថា បទល្មើសទាំងអស់នេះមិនអាចអនុវត្តបានចំពោះ អៀង សារី នោះទេ ផ្អែកតាមការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់និយមន័យ និងអនុវត្តបទល្មើសទាំងអស់នេះ និង/ឬកង្វះភាពច្បាស់លាស់នៃបទល្មើសទាំងអស់នេះ។ យល់ឃើញថា JCE ដូចដែល អបជ បានយល់ឃើញថាអាចអនុវត្តបាន មិនអាចអនុវត្តលើ អៀង សារី បានទេ។ ជំទាស់នឹងការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងការបញ្ជានៅក្នុងដីកាដំណោះស្រាយនៅពេលអនុវត្តចំពោះ អៀង សារី លើកឡើងថា អ.វ.ត.ក ពុំមានយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ។ ជាជម្រើសម្យ៉ាងទៀត ជំទាស់នឹងការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងដីកាដំណោះស្រាយនៅពេលអនុវត្តចំពោះ អៀង សារី។ ជាជម្រើសម្យ៉ាងទៀត យល់ឃើញថាការកំណត់របស់មេធាវីការពារក្តី អំពីការទទួលខុសត្រូវរបស់ថ្នាក់លើអាចទទួលយកបាន។

វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងលើកឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកា ដំណោះស្រាយថ្មី ឬដីកាដំណោះស្រាយដែលបានកែសម្រួល ដែលនឹងធ្វើជាមូលដ្ឋានសម្រាប់សវនាការ: "អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះពីសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ"។ នៅក្នុងសន្ទានុក្រមរបស់វិធានផ្ទៃក្នុង ពាក្យថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ត្រូវបានឲ្យនិយមន័យថា "សំដៅទៅលើដីកាដំណោះស្រាយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ"[២៥១]។

១០៧. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង ចែង ៖

> ដីកាដំណោះស្រាយអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត។

១០៨. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងករណីដែលអង្គបុរេជំនុំជម្រះអនុញ្ញាតតាមបណ្តឹងជំទាស់ផ្នែកយុត្តាធិការ ជាលទ្ធផលអង្គបុរេជំនុំជម្រះកាត់បន្ថយចំនួនបទចោទប្រកាន់លើជនត្រូវចោទ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ នៅពេលដែលអង្គបុរេជំនុំជម្រះគ្រាន់តែត្រូវធ្វើបែបនេះ។ ករណីចាំបាច់ អង្គបុរេជំនុំជម្រះអាចបន្ថែមសំអាងហេតុទៅលើសំអាងហេតុទាំងឡាយ ដែលផ្តល់ឲ្យដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ។

១០៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានចែងអំពីបញ្ញត្តិណាមួយដែលនឹងជួយឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថាអ្វីខ្លះជាអំណាចរបស់ខ្លួន នៅពេលធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដូចជាបណ្តឹងឧទ្ធរណ៍ណាមួយដែលធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ នេះដោយសារតែសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាដំណោះស្រាយនេះ មិនត្រូវបានផ្តល់ឲ្យសម្រាប់ជាទម្លាប់អនុវត្តធម្មតានៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ដោយមេធាវីការពារក្តីប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមូលដ្ឋានមិនប្រក្រតីនៃបណ្តឹងជំទាស់ផ្នែកយុត្តាធិការ។ កាលៈទេសៈនេះអាចឲ្យយល់បាន ដោយហេតុថា អ.វ.ត.ក ត្រូវបានផ្តល់ឲ្យនូវអំណាចដែលមានលក្ខណៈវិសាមញ្ញ បើប្រៀបធៀបជាមួយនឹងតុលាការកម្ពុជាទូទៅផ្សេងទៀត។

---

[២៥១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" , ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ៤០។

១១០. ដរាបណាប្រភេទនៃកំហុសដែលអង្គបុរេជំនុំជម្រះត្រូវធ្វើការពិនិត្យ សម្រាប់គោលបំណងនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានយល់ឃើញកាលពីលើកមុន នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ស្តីពីមូលដ្ឋានស្រដៀងគ្នាថា ៖

> អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងវិសាលភាពដែលដីកាដែលត្រូវបានជំទាស់ លើកឡើងអំពីបញ្ហាយុត្តាធិការនានា អង្គបុរេជំនុំជម្រះពុំពាក់ព័ន្ធនឹងឆន្ទានុសិទ្ធិណាមួយសម្រាប់ [សហចៅក្រមស៊ើបអង្កេតនោះទេ][២៥២]។

១១១. អង្គបុរេជំនុំជម្រះសង្កេតឃើញថែមទៀតថា នៅក្នុងបណ្តឹងឧទ្ធរណ៍ដែលដាក់ជូនអង្គបុរេជំនុំជម្រះ នៅពេលដែលបណ្តឹងជំទាស់យុត្តាធិការត្រូវបានផ្អែកលើមូលដ្ឋាន ដែលលើកឡើងពីការរំលោភគោលការណ៍នីត្យានុកូលភាព អង្គបុរេជំនុំជម្រះក៏ត្រូវបានតម្រូវផងដែរឱ្យធ្វើការពិនិត្យលើការភ័ន្តច្រឡំអង្គហេតុ ដរាបណាចំណុចនេះពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យសត្យានុម័ត ទៅលើបញ្ហាភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងជាមុនថាមានច្បាប់ចែង ឬទម្រង់នៃការទទួលខុសត្រូវដោយជនជាប់ចោទ។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ភាពច្បាស់លាស់ ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងជាមុនថាមានច្បាប់ចែង គឺជាធាតុផ្សំនៃគោលការណ៍នីត្យានុកូលភាព និងថា អាចមានទស្សនៈជាច្រើននៃបណ្តឹងឧទ្ធរណ៍ ដែលអាចធ្វើឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាលើបញ្ហាទាំងឡាយ ដែលហួសពីបញ្ហាដែលពាក់ព័ន្ធតែទៅនឹងយុត្តាធិការ។ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះអាចធ្វើការពិនិត្យមើលដីកាដំណោះស្រាយចំពោះការភ័ន្តច្រឡំអង្គហេតុពិសេសណាមួយ តែចំពោះវិសាលភាពនោះប៉ុណ្ណោះ។ នៅពេលដែលសហមេធាវីការពារក្តីស្នើសុំឱ្យមារបស់សហមេធាវីការពារក្តី នឹងតម្រូវឱ្យមានការសម្រេចផ្នែកអង្គហេតុដែលមិនមានការពិចារណាលើការដឹងរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងរដ្ឋជាសមាជិកនៃច្បាប់អន្តរជាតិ សំណើសុំស្ថិតនៅក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ។ ការសម្រេចផ្នែកអង្គហេតុទាំងនេះគឺស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង បញ្ហាបែបនេះអាចត្រូវបានជំទាស់នៅពេលជំនុំជម្រះក្តី។

១១២. អង្គបុរេជំនុំជម្រះយល់ឃើញថា បទដ្ឋាននៃការពិនិត្យមើលនេះ ស្របគ្នាជាមួយនឹងការអនុវត្តដែល

[២៥២] សាលដីកាលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ត្រូវបានធ្វើតាមនៅកម្រិតអន្តរជាតិ។ ជាឧទាហរណ៍ នៅក្នុងតុលាការ ICTY នៅក្នុងសាលដីការឿងក្តី Gotovina ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៧ ដោយបានយោងលើច្បាប់យុត្តិសាស្ត្រកាលពីមុន អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានធ្វើការសង្ខេបអំពីបទដ្ឋាននៃការពិនិត្យឡើងវិញ សម្រាប់បណ្តឹងជំទាស់យុត្តាធិការដូចខាងក្រោម ៖

> នៅពេលពិនិត្យមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តាធិការ តាមវិធាន ៧២(ខ)(i) នៃវិធាននានា អង្គជំនុំជម្រះតុលាការកំពូលនឹងបដិសេធសាលដីកានោះ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តទៅដោយការភ័ន្តច្រឡំអង្គហេតុ និងអង្គច្បាប់ជាក់លាក់ ដោយប្រកាសសាលដីកាទុកជាឥតបានការ ឬថ្លឹងថ្លែងអំពីការពិចារណាដែលពាក់ព័ន្ធ ឬការពិចារណាដែលមិនពាក់ព័ន្ធនៅក្នុងលក្ខណៈមួយដែលមិនសមហេតុសមផល"[២៥៣]។

១១៣. អង្គបុរេជំនុំជម្រះយល់ឃើញថា គេបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិថា ចំពោះបណ្តឹងឧទ្ធរណ៍ ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ និងការភ័ន្តច្រឡំ អង្គហេតុត្រូវបានពិនិត្យមើល ស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បីសម្រេចថា តើពុំមានអ្នកវិនិច្ឆ័យសេចក្តីអង្គហេតុដែលសមស្របបានធ្វើសំអាងផ្អែកអង្គហេតុដែលបានលើកឡើង ដែរឬ ទេ[២៥៤]។

## ឃ. ការពិចារណានៅលើអង្គសេចក្តី

### ១. មូលដ្ឋានទី១ ៖ <u>*(គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ)*</u>

<u>សារណារបស់ភាគីនានា</u>

[២៥៣] *Gotovina និងអ្នកផ្សេងទៀត*។ សាលដីកាលើយុត្តាធិការ កថាខណ្ឌ៧ ដកស្រង់ផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jadranko Prli} និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-04-74-AR72.1, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទីរបស់ Petkovi} ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តាធិការ, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ("*Prli} និងអ្នកផ្សេងទៀត*។ បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទីលើយុត្តាធិការ"), កថាខណ្ឌ១១ ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Slobodan Milo{evi}*, សំណុំរឿងលេខ IT-02-54-AR73.7, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទីនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងក្រុមមេធាវីការពារក្តី, ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ១០។

[២៥៤] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ramush Hardinaj និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-04-84-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ១១, ១២។



PRE-TRIAL CHAMBER E.C.C.C. CHAMBRE PRÉLIMINAIRE

00661562



១១៤. សហមេធាវីការពារក្តីរបស់ អៀង សារី លើកឡើងថា យុត្តាធិការរបស់ អ.វ.ក.ត ដើម្បីកាត់ទោស អៀង សារី ចំពោះអំពើដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ ត្រូវបានហាមឃាត់ដោយគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយហេតុថា អៀង សារី ត្រូវបានជំនុំជម្រះ និងផ្តន្ទាទោស*កំបាំងមុខ* ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ បន្ថែមទៅលើបទល្មើសមួយចំនួនទៀត ដោយតុលាការប្រជាជនបដិវត្តន៍ ("PRT") ក្នុងឆ្នាំ ១៩៧៩ (សវនាការឆ្នាំ ១៩៧៩[២៥៥] រួចទៅហើយ។ យោងតាមមាត្រា ៧ និងមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា (CPC) ដែលសហមេធាវីការពារក្តីលើកឡើងថា ផ្តល់ការការពារដល់ អៀង សារី ប្រសើរជាងមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ទៅទៀតនោះ សហមេធាវីការពារក្តីលើកឡើងថា អៀង សារី មិនអាចត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសតែមួយបានទេ[២៥៦]។ សហមេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា CPC មិនបានចែងអំពីករណីលើកលែងទៅលើគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះទេ។ សហធាវីការពារក្តីជំទាស់តវ៉ាថា ទោះជាក្នុងករណីណាក៏ដោយ មិនមានករណីលើកលែងណាមួយក្នុងចំណោមករណីលើកលែងទាំងពីរ ដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ខ្លួនថា[២៥៧] ដំណើរការនីតិវិធីពីមុន៖ i) គឺមានគោលបំណងការពារជនពាក់ព័ន្ធឱ្យរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ ii) មិនបានដំណើរការដោយឯករាជ្យ ឬអនាគតិ ដោយគោរពតាមបទដ្ឋាននីតិវិធី និងបានដំណើរការក្នុងលក្ខណៈមួយមិនស្របនឹងគោលបំណង ដើម្បីនាំខ្លួនជនដែលពាក់ព័ន្ធនោះមកធ្វើការកាត់ទោស អាចអនុវត្តចំពោះករណីរបស់ អៀង សារី បានទេ ដោយហេតុថា គាត់ត្រូវបានផ្តន្ទាទោសប្រហារជីវិត ហើយទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ត្រូវបានសម្រេចរឹបអូស[២៥៨]រួចរាល់អស់ហើយ។

១១៥. សហព្រះរាជអាជ្ញាលើកឡើងនៅក្នុងចម្លើយតបថា ការចោទប្រកាន់ និងការផ្តន្ទាទោស អៀង សារី ក្នុងឆ្នាំ ១៩៧៩ មិនរារាំងដល់ការចោទប្រកាន់ជាថ្មីទៀត នៅចំពោះមុខ អ.វ.ត.ក នោះទេ ដោយសារ i) CPC កម្រិតការអនុវត្ត*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*

---

[២៥៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៣។

[២៥៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៩ ដល់ ៣១។

[២៥៧] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៨។

[២៥៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៤ ដល់ ៣៧។

ចំពោះករណីដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ និង ii) មាត្រា ១៤(៧) នៃ ICCPR មិនត្រូវបានយកមកជាសំអាងនោះទេ ដោយសារសាលក្រមឆ្នាំ ១៩៧៩ ដែលបានសម្រេចដោយ*កំបាំងមុខ* នោះ[២៥៩] មិនបានចូលជាស្ថាពរ ឬស្របទៅនឹងនីតិវិធី និងច្បាប់កម្ពុជានោះឡើយ។ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា ទោះក្នុងករណីណាក៏ដោយ ច្បាប់អន្តរជាតិចែងថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបានទេ នៅពេលដែលតុលាការអន្តរជាតិធ្វើការចោទប្រកាន់ជាលើកទីពីរ ក្រោយពីការផ្តន្ទាទោសលើកទីមួយដោយតុលាការជាតិ បានប្រព្រឹត្តទៅមិនស្របទៅនឹងការធានាជាលក្ខណៈអន្តរជាតិ ដែលតម្រូវឱ្យមានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដូចជាករណីសវនាការឆ្នាំ ១៩៧៩ នេះជាដើម[២៦០]។ សហព្រះរាជអាជ្ញាលើកឡើងថា វាមិនចាំបាច់ដើម្បីធ្វើការប្រៀបធៀបពីអំពើ និងឧក្រិដ្ឋកម្មដែលត្រូវបានផ្តន្ទាទោសក្នុងឆ្នាំ ១៩៧៩ ជាមួយនឹងអំពើដែលត្រូវបានចោទប្រកាន់ចំពោះ អៀង សារី នាពេលបច្ចុប្បន្នដែលជា "ការចោទប្រកាន់លើកទីពីររបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មខុសគ្នា ផ្អែកលើអំពើព្រហ្មទណ្ឌដូចគ្នា មិនជាការរំលោភ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយនោះទេ* ដរាបណា ភាពមិនត្រឹមត្រូវកើតចេញពីការកាត់ទោសពីរដង ត្រូវបានគេគិតគូរសម្រាប់ការកាត់ទោស"[២៦១]។

១១៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមមេធាវីគ្មានព្រំដែនប្រទេសបារាំង "Group ASF France") លើកឡើងថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបានទេ ប្រសិនបើ i) ការកាត់ទោសនោះធ្វើឡើងមិនស្របនឹងគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ii) ការកាត់សេចក្តីនោះធ្វើឡើងក្នុងគោលបំណងការពារជនណាម្នាក់ឱ្យរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ iii) ការជំនុំជម្រះក្តីនោះមិនឆ្លើយតបនឹងបទដ្ឋានអន្តរជាតិ[២៦២]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតមិនបានបង្ហាញនូវការកត់សម្គាល់ជាក់លាក់ទាក់ទងទៅនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះទេ។

---

២៥៩ ពាក្យឡាតាំងថា (*ដោយកំបាំងមុខ "in absentia"*) មានន័យជាភាសាអង់គ្លេសថា (ដោយអវត្តមាន "in the absence of")។

២៦០ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦០។

២៦១ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨១។

២៦២ សេចក្តីសង្កេតរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី I កថាខណ្ឌ ៦៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១១៧. សហមេធាវីការពារក្ដីរបស់ អៀង សារី ឆ្លើយតបថា មាត្រា ១២ នៃ CPC តម្រូវឱ្យមានការបកស្រាយដោយគ្រប់ដណ្ដប់ទៅលើជនណាម្នាក់ដែលត្រូវបានផ្ដន្ទាទោស ដូចក្នុង*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*ក្នុងច្បាប់អន្តរជាតិ ដែលមានបំណងការពារឱ្យជននោះឱ្យរួចផុតពី "ការផ្ដន្ទាទោស" ពីរដង[២៦៣]។ ពួកគាត់បានលើកឡើងថា សាលក្រមឆ្នាំ ១៩៧៩ ត្រូវតែយកមកពិចារណាថាជាសាលក្រមស្ថាពរ ដោយហេតុថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនត្រូវបានយកមកអនុវត្តក្នុងការកាត់ទោសឆ្នាំ ១៩៧៩ នោះទេ មិនមានតុលាការកំពូលទេនាពេលនោះ ហើយ អៀង សារី មិនមានលទ្ធភាពទទួលបានកាត់សេចក្ដីឡើងវិញ ដោយតុលាការប្រជាជនបដិវត្តន៍នោះទេ។ ពួកគាត់លើកឡើងម្ដងហើយម្ដងទៀតថា ករណីលើកលែងដែលសហព្រះរាជអាជ្ញាបានលើកមកសំអាងថា ការជំនុំជម្រះក្ដីដោយតុលាការជាតិមិនបានធ្វើឡើងស្របនឹងការធានាជាអន្តរជាតិ ដែលឱ្យមានការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះ គឺមិនបានចែងឱ្យបានច្បាស់នៅក្នុងច្បាប់អន្តរជាតិដូចដែលបានបង្ហាញយ៉ាងច្បាស់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("លក្ខន្តិកៈទីក្រុងរ៉ូម") ដែលដកចេញពីបទប្បញ្ញត្តិនៃ*តុលាការមិនអចិន្ត្រៃយ៍* នានា។ ជាមួយនេះផងដែរ ពួកគាត់បានលើកឡើងថា "សិទ្ធិនានាដែលមានចែងក្នុងមាត្រា ១៤ នៃ ICCPR សំដៅដល់ការការពារសិទ្ធិរបស់ជនជាប់ចោទ និងមិនតម្រូវឱ្យយកជន នោះទៅជំនុំជម្រះសាជាថ្មីឡើយ ប្រសិនបើគាត់មិនបានស្វែងរកឱ្យមានសវនាការថ្មី"[២៦៤]។ មេធាវីការពារក្ដីអះអាងជាចុងក្រោយឡើងវិញថា បញ្ហានៃការផ្ដន្ទាទោសត្រួតគ្នា ដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ មិនអាចអនុវត្តនៅទីនេះបានទេ ដោយសារដំណើរការនីតិវិធីទាំងពីរត្រូវបានបានញែកដាច់ពីគ្នាដោយសាររយៈពេល ៣០ ឆ្នាំ[២៦៥]។

## ការពិភាក្សា

១១៨. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា កិច្ចព្រមព្រៀង[២៦៦] និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក

[២៦៣] សារណាតបរបស់ អៀង សារី, កថាខណ្ឌ ៣៣។

[២៦៤] សារណាតបរបស់ អៀង សារី, កថាខណ្ឌ ៣៧។

[២៦៥] សារណាតបរបស់ អៀង សារី កថាខណ្ឌ ៤០។

[២៦៦] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ (ហៅថា "កិច្ចព្រមព្រៀង")។

និងវិធានផ្ទៃក្នុង មិនមានចែងអំពីការហាមឃាត់ចំពោះការកាត់ទោសពីរដង និងមិនបាននិយាយអំពីអានុភាពនៃការផ្តន្ទាទោសពីមុន ទៅលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះទេ។ អនុលោមតាម មាត្រា ១២ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក អង្គបុរេជំនុំជម្រះនឹងពិនិត្យមើល CPC ដែលសហមេធាវីការពារក្តីមានការយល់ឃើញថា មានបទប្បញ្ញត្តិអាចដោះស្រាយបញ្ហានៅចំពោះមុខនេះបាន។

**<u>ក្រមនីតិវិធីព្រហ្មទណ្ឌ (CPC)</u>**

១១៩. មាត្រា ៧ នៃ CPC ដែលបានអនុម័តនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ចែងថា៖

> មាត្រា ៧៖ ការរលត់នៃបណ្តឹងអាជ្ញាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖
> (...)
> *៥. អាជ្ញាអស់ជំនុំ (Res judicata)*
> កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។

១២០. មាត្រា ១២ ចែងបន្ថែមទៀតថា៖

> **មាត្រា ១២** *អាជ្ញាអស់ជំនុំ*
> ដោយអនុវត្តតាមគោលការណ៍*អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ចំពោះអំពើដដែល ទោះបីជាស្ថិតនៅក្រោមការកំណត់ឈ្មោះបទល្មើសផ្សេងក៏ដោយ។

១២១. សហមេធាវីការពារក្តីលើកឡើងថា មាត្រា ១២ ត្រូវតែបកស្រាយ ដោយមិនមែនគ្របដណ្តប់តែទៅលើជនដែលត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះទេ តែក៏ត្រូវបកស្រាយដោយគ្របដណ្តប់ទាំងជនដែលត្រូវបានផ្តន្ទាទោសផងដែរ។

១២២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ១២ នៃ CPC អនុវត្តចំពោះជនណាដែលត្រូវបានតុលាការ "សម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ"។ អនុលោមតាមគោលការណ៍នៃការបកស្រាយដែលគេបានទទួលស្គាល់ "នៅក្នុងការបកស្រាយច្បាប់លក្ខន្តិកៈ និងលិខិតុបករណ៍ជាលាយលក្ខណ៍អក្សរទាំងអស់ត្រូវប្រកាន់ខ្ជាប់អត្ថន័យនៃពាក្យតាមវេយ្យាករណ៍ និងតាមន័យធម្មតា លើកលែងតែថាវាអាចនាំឱ្យមានភាពមិនសមហេតុសមផល ឬភាពមិនស៊ីសង្វាក់គ្នាជាមួយលិខិតុបករណ៍នោះ ដែលក្នុងករណីនេះ អត្ថន័យតាមវេយ្យាករណ៍ និងតាមន័យធម្មតា អាចត្រូវបានកែប្រែដើម្បីជៀសវាងភាពមិនសមហេតុផល ឬភាពមិនស៊ីសង្វាក់គ្នា ប៉ុន្តែមិនត្រូវឱ្យហួសពីនេះទេ[២៦៧]។

១២៣. អង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីការពារក្ដីមិនបានបង្ហាញឱ្យឃើញថា អត្ថន័យធម្មតានៃមាត្រា១២ មិនស្របគ្នានឹង CPC ដោយរបៀបណាមួយនោះទេ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការពង្រីកវិសាលភាពនៃមាត្រា ១២ ដើម្បីរួមបញ្ចូលទាំងទណ្ឌិត ដូចដែលសហមេធាវីការពារក្ដីបានលើកឡើង អាចផ្ទុយគ្នាទៅនឹងបញ្ញត្តិដទៃទៀតនៃ CPC ដែលអនុញ្ញាតឱ្យបើកដំណើរការនីតិវិធីឡើងវិញ នៅក្នុងករណីដែលមានការផ្ដន្ទាទោសរួចហើយនោះ។ ជាពិសេស CPC ផ្ដល់លទ្ធភាពឱ្យ i) ពិនិត្យដំណើរការនីតិវិធីឡើងវិញ ក្នុងករណីមានការផ្ដន្ទាទោសរួចហើយ[២៦៨] និង ii) ចំពោះជនណាដែលត្រូវបានកាត់ទោស*កំបាំងមុខ* ដើម្បីប្ដឹងជំទាស់នឹងសាលក្រម និងកាត់សេចក្ដីជាថ្មីឡើងវិញ[២៦៩]។ ការអនុវត្តមាត្រា ១២ ចំពោះទណ្ឌិតអាចនឹងនាំឱ្យមានការច្រានចោលលទ្ធភាពពីរនៃការបើកឱ្យមានដំណើរការនីតិវិធីឡើងវិញដោយសារថា អនុ

---

[២៦៧] រឿងក្ដីរវាង *Grey* តទល់នឹង *Pearson* (1857) 10ER 1216, 1234។ សូមមើលផងដែរ រឿងក្ដីរវាង *Becke* តទល់នឹង *Smith* (1836) 2 M&W 195។ រឿងក្ដីរវាង *Caminetti* តទល់នឹង សហរដ្ឋអាមេរិក, 242 U.S. 470 (1917) ត្រង់ទំព័រ ៤៨៥ (អង់គ្លេស) ("វាសំខាន់ណាស់ថា នៅក្នុងករណីទីមួយ អត្ថន័យនៃច្បាប់ត្រូវតែបកស្រាយនៅក្នុងភាសាដែលគ្របដណ្ដប់ទៅលើអំពើមួយ ហើយប្រសិនបើវាមានន័យច្បាស់លាស់ហើយ [...] នោះមុខងារតែមួយគត់របស់តុលាការ គឺអនុវត្តច្បាប់នោះទៅតាមពាក្យពេចន៍របស់វា"។ ហើយប្រសិនបើភាសារបស់ច្បាប់មួយវាងាយយល់ និងច្បាស់លាស់ហើយនោះតុលាការត្រូវបានក្រើនរំលឹកបន្ថែមទៀតថា "កាតព្វកិច្ចនៃការបកស្រាយមិនកើតមាននោះទេ ហើយវិធានដែលជួយសម្រួលដល់អត្ថន័យមិនច្បាស់លាស់នេះ មិនត្រូវការពិភាក្សានោះទេ")។ មាត្រា ៣១ និងមាត្រា ៣៣ នៃអនុសញ្ញាទីក្រុងវីយែនរបស់អង្គការសហប្រជាជាតិ ស្ដីពីច្បាប់នៃសន្ធិសញ្ញា ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ អង្គការសហប្រជាជាតិ កម្រងសន្ធិសញ្ញា វ៉ុលលេខ ១១៥៥ ទំព័រ ៣៣១ ("សន្ធិសញ្ញាក្រុងវីយែន")។

[២៦៨] មាត្រា ៤៤៣ ដល់ មាត្រា ៤៤៥ នៃ CPC ។

[២៦៩] មាត្រា ៣៦៥ មាត្រា ៣៧០ និងមាត្រា ៣៧១ នៃ CPC ។

លោមតាមមាត្រា ១៥ នៃ CPC ការចោទប្រកាន់ពីបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬត្រូវតែបញ្ឈប់។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា ទណ្ឌិតមិនអាចត្រូវបានទុកចោលដោយមិនមានការការពារនោះទេ ដោយសារពួកគេទទួលបានអត្ថប្រយោជន៍ពីសិទ្ធិដែលមានចែងនៅក្នុងមាត្រា ១៤(៧) នៃ ICCPR ដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២ ដែលនឹងយកមកពិភាក្សាខាងក្រោមនេះ។

១២៤. ការមិនមានហេតុផល ឬភាពស៊ីសង្វាក់គ្នាជាមួយនឹង CPC នោះ អង្គបុរេជំនុំជម្រះត្រូវប្រកាន់យកអត្ថន័យធម្មតានៃមាត្រា ១២ ដោយការយល់ឃើញថា មាត្រានេះមិនអនុវត្តចំពោះទណ្ឌិតនោះទេ។

១២៥. ដោយយល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យមានសេចក្ដីសម្រេចដោះស្រាយបញ្ហានៅចំពោះមុខបាន អង្គបុរេជំនុំជម្រះសូមយោងទៅមាត្រា ១២ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ដែលចែងក្នុងកថាខណ្ឌទី១ ថា គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ និងចែងក្នុងកថាខណ្ឌទី២ ថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជាភាគីហត្ថលេខីដែរនោះ"។

១២៦. នៅក្នុងរឿងក្ដីនេះ ដំបូងអង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលមាត្រា ១៤(៧) នៃ ICCPR ជាមុនសិន ហើយបន្ទាប់មកនឹងយោងទៅបទដ្ឋាននីតិវិធីដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ ប្រសិនបើបញ្ហានៅតែមិនទាន់បានដោះស្រាយនៅឡើយនោះ។

**កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)**

១២៧. គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានចែងជាសិទ្ធិសារវ័ន្តនៅក្នុងមាត្រា១៤(៧) នៃ ICCPR ដែលចែងថា៖

គ្មានជនណាម្នាក់ ត្រូវបានយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និង នីតិវិធីព្រហ្មទណ្ឌ របស់រដ្ឋនីមួយៗរួចហើយនោះទេ។

១២៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ការការពារដែលបានផ្តល់ដោយមាត្រា ១៤(៧) ICCPR មានអានុភាពត្រឹមតែកម្រិតជាតិប៉ុណ្ណោះ។ គណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងស្របគ្នាថា មាត្រា ១៤(៧) "មិនធានាចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ទាក់ទងនឹងយុត្តាធិការជាតិរបស់រដ្ឋពីរ ឬច្រើននោះទេ។ បទប្បញ្ញត្តិនេះហាមឃាត់ចំពោះតែការកាត់ទោសពីរដង ទាក់ទងនឹងបទល្មើសដែលបានវិនិច្ឆ័យនៅក្នុងរដ្ឋណាមួយតែប៉ុណ្ណោះ"[២៧០]។ នៅក្នុងរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* Tadić អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានសន្និដ្ឋានផងដែរថា មាត្រា ១៤(៧) មិនមានការទទួលស្គាល់ទូលំទូលាយថា ជាបទដ្ឋានដាច់ខាត (mandatory norm) នៃការអនុវត្តជាអន្តរប្រទេសនោះទេ[២៧១]។ បទប្បញ្ញត្តិនេះត្រូវបានទទួលស្គាល់យ៉ាងជាក់លាក់ដោយបណ្តាប្រទេសអឺរ៉ុប ដែលភាគច្រើនគឺជារដ្ឋភាគីនៃ ICCPR ដែលបានអនុម័តយកបទប្បញ្ញត្តិក្នុងមាត្រា៤ នៃពិធីសារលេខ៧ ដាក់ទៅក្នុងកតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR")[២៧២] ដែលចែងយ៉ាងច្បាស់ថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អនុវត្តចំពោះតែដំណើរការនីតិវិធីនៅក្នុងរង្វង់ច្បាប់ជាតិតែប៉ុណ្ណោះ[២៧៣]។

---

[២៧០] គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តីរវាង *A.R.J. តទល់នឹង ប្រទេសអូស្ត្រាលី*, CCPR/C/60/D/692/1996, ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦.៤, *សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ មាត្រា ១៤ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និង សាលាជម្រះក្តី និងចំពោះការជំនុំជម្រះក្តីដោយយុត្តិធម៌* ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ CCPR/C/GC/32 កថាខណ្ឌ ៥៧។ *សូមមើលផងដែរ* រឿងក្តីរវាង *A.P និងអ្នកផ្សេងទៀត តទល់នឹង ប្រទេស អ៊ីតាលី*, លិខិតឆ្លើយឆ្លងលេខ ២០៤/១៩៨៦ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ កថាខណ្ឌ ៧.៣ ("បទប្បញ្ញត្តិនេះហាមឃាត់មិនឲ្យមានការកាត់ទោសពីរដងចំពោះតែបទល្មើសដែលបានសម្រេចសេចក្តីនៅក្នុងរដ្ឋណាមួយតែប៉ុណ្ណោះ។

[២៧១] រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* Tadić, IT-94-1-T "សេចក្តីសម្រេចទៅលើសារណារបស់មេធាវីការពារស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៩។

[២៧២] អនុសញ្ញាទ្វីបអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ETS 5; 213 UNTS 221 ដែលបានចូលជាធរមាននៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៥៣ (ECHR)។

[២៧៣] ពិធីសារលេខ ៧ បន្ថែមលើអនុសញ្ញាសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៤ ("ពិធីសារលេខ ៧ បន្ថែមទៅលើ ECHR")។ មាត្រា ៤(១) ចែងថា៖ "គ្មានជនណាម្នាក់ ត្រូវប្រឈមមុខនឹងការចោទប្រកាន់ ឬផ្តន្ទាទោសនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលស្ថិតនៅក្រោម

១២៩. ការកម្រិតការការពារ ដែលផ្តល់ដោយមាត្រា ១៤(៧) ត្រូវបានពន្យល់យ៉ាងច្បាស់ថា រដ្ឋមួយមិនមានកាតព្វកិច្ចទទួលស្គាល់សាលក្រមបរទេសបានទេ លើកលែងតែរដ្ឋនោះបានយល់ព្រមទទួលស្គាល់តាមរយៈអនុសញ្ញាអន្តរជាតិ ដែលមានភាពជាក់លាក់ចំពោះអានុភាពនេះ[២៧៤]។ អវត្តមានកាតព្វកិច្ចបែបនេះនៅក្រោមច្បាប់អន្តរជាតិ ត្រូវបានឆ្លុះបញ្ចាំងដោយប្រព័ន្ធដ៏ស្មុគស្មាញបំផុតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅក្នុងបញ្ហាព្រហ្មទណ្ឌ ដែលបានលេចឡើងតាមរយៈការអនុម័តអនុសញ្ញាទ្វេភាគី និងពហុភាគី។ ដោយការទទួលស្គាល់ការកម្រិតនៃមាត្រា១៤(៧) គណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងទាក់ទងនៅក្នុងបញ្ហានេះថា បញ្ហានេះមិនគួរ "ធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ ដើម្បីទប់ស្កាត់កុំឱ្យមានការកាត់-ទោសឡើងវិញ ចំពោះបទល្មើសដដែលតាមរយៈអនុសញ្ញាអន្តរជាតិនោះទេ"[២៧៥]។

១៣០. ដោយសារតែមូលហេតុនេះ មាត្រា ១៤(៧) មិនអនុវត្តនៅចំពោះមុខតុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") នោះទេ ហើយតាមរយៈនេះ ការការពារជាអន្តរជាតិ *មិនឱ្យមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលត្រូវបានយកមកពិចារណាចំពោះលក្ខណៈពិសេសៗនៃអន្តរកម្មរវាងដំណើរការនីតិវិធីនៅកម្រិតជាតិ និងកម្រិតអន្តរជាតិសម្រាប់ការផ្តន្ទាទោសចំពោះបទល្មើសអន្តរជាតិនោះ ត្រូវបានបង្ហាញឡើង ដូចដែលត្រូវបានយកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។ ក្នុងន័យនេះមាន ការកត់សម្គាល់បន្ថែមទៀតថា វិសាលភាពនៃមាត្រា១៤(៧) ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុត ដោយសារមាត្រានេះអនុវត្តចំពោះ "បទល្មើស" ដដែល មានន័យថា ចរិតលក្ខណៈគតិយុត្តិដូចគ្នានៃអំពើទាំងនោះ ចំណែកឯការការពារជាអន្តរជាតិផ្តោតទៅលើ "ទង្វើ" របស់ជនជាប់ចោទ។ ដូច្នេះ ដោយការពិចារណាទៅលើការអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះការណ៍ដែលថា ដំណើរការនីតិវិធីអន្តរជាតិអាចមានចរិតលក្ខណៈគតិយុត្តិខុសពីដំណើរការនីតិវិធីនៅកម្រិតជាតិ។

---

យុត្តាធិការរបស់រដ្ឋដដែល ចំពោះបទល្មើសដែលជននោះត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយ ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនោះបានឡើយ"។

[២៧៤] Stefan Trechsel *សិទ្ធិមនុស្សនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ* បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០៥ ទំព័រ ៣៨៦ សាស្ត្រាចារ្យ Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០៣ ("Cassese ២០០៣") ទំព័រ ៣១៩ ដល់ ៣២០ (អង់គ្លេស)។

[២៧៥] សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ ទំព័រ ១៦ ដល់ ១៧ (អង់គ្លេស)។

១៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានការការពារជាអន្តរជាតិមិនឱ្យមាន*ការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* នៅក្នុង ICCPR នោះទេ។ ដោយពិចារណាទៅលើការយល់ឃើញមុនៗ របស់ខ្លួនថា អ.វ.ត.ក គឺជាតុលាការមួយដែលមានចរិតអន្តរជាតិ ដំណើរការខុសពីរចនាសម្ព័ន្ធ តុលាការកម្ពុជា[២៧៦] នោះអង្គបុរេជំនុំជម្រះយល់ឃើញថា "គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ*"[២៧៧] ដូចមានចែងក្នុងមាត្រា ១៤(៧) នៃ ICCPR មិនអនុវត្តចំពោះដំណើរ ការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះទេ។ ក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះនឹងស្វែង រកការណែនាំនៅក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិដើម្បីពិចារណាថាតើការ ផ្តន្ទាទោសលើកមុនចំពោះ អៀង សារី ដោយតុលាការកម្ពុជានឹងរារាំង អ.វ.ត.ក មិនឱ្យអនុវត្តយុត្តា ធិការទៅលើរូបគាត់ ចំពោះបទល្មើសដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែរឬយ៉ាង ណានោះ។

**<u>បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ</u>**

១៣២. ការលើកឡើងដ៏ច្បាស់លាស់លើកទីមួយ នៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើស តែមួយ* នៅក្នុងឯកសារដ៏សំខាន់របស់តុលាការអន្តរជាតិ ត្រូវបានរកឃើញនៅក្នុងមាត្រា ១០ នៃ លក្ខន្តិកៈសម្រាប់តុលាការ ICTY[២៧៨] ដែលចែងថា៖

មាត្រា ១០៖

*មិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*Non-bis-in-idem*)

---

[២៧៦] *សូមមើល*ផ្នែកស្តីពីការពិភាក្សាទៅលើអង្គសេចក្តីនៃមូលដ្ឋានទីបី នៃបណ្តឹងឧទ្ធរណ៍ នៅក្នុងផ្នែកខាងក្រោមនេះ។

[២៧៧] Cassese ២០០៣ ទំព័រ ៣១៩ (អង់គ្លេស)។

[២៧៨] ធម្មនុញ្ញទីក្រុងឡុង សម្រាប់បង្កើតតុលាការ Nuremberg មានចែងចំពោះតែ (អានុភាពពីខ្ពស់ទៅទាប) នៃគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មានន័យថា នីតិវិធីដែលធ្វើឡើងដោយតុលាការជាតិ ក្រោយពីសេចក្តីសម្រេច មួយត្រូវបានប្រកាសដោយតុលាការអន្តរជាតិ។ *ធម្មនុញ្ញតុលាការសឹកអន្តរជាតិ ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងឡុង* ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥, 82 U.N.T.S. 280, (តុលាការយោធាអន្តរជាតិ "IMT") មាត្រា១១ ចែងថា៖ "ជនណាដែល ត្រូវបានតុលាការផ្តន្ទាទោសរួចហើយ អាចត្រូវបានចោទប្រកាន់នៅចំពោះតុលាការជាតិ តុលាការសឹក ឬតុលាការរបស់ភាគី ត្រួតត្រា (occupation court) ដោយអនុលោមតាមមាត្រា ១០ នៃធម្មនុញ្ញនេះ ចំពោះបទល្មើសមួយ ជាជាងសមាជិកភាពនៅក្នុង ក្រុម ឬអង្គការឧក្រិដ្ឋ ហើយបន្ទាប់ពីផ្តន្ទាទោសជននោះរួចហើយ តុលាការទាំងនេះអាចផ្តន្ទាទោសជននោះដោយឯករាជ្យ បន្ថែមទៅលើទណ្ឌកម្ម ដែលបានសម្រេចដោយតុលាការសឹកអន្តរជាតិ ពីបទចូលរួមក្នុងសកម្មភាពឧក្រិដ្ឋជាមួយក្រុម ឬអង្គការ នោះ"។

១. គ្មានជនណាម្នាក់ ត្រូវបានផ្តន្ទាទោសនៅចំពោះមុខតុលាការជាតិចំពោះអំពើទាំងឡាយដែលបង្កបាន ជាការរំលោភធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលស្ថិតនៅក្រោមលក្ខន្តិកៈបច្ចុប្បន្ន ដែលជននោះត្រូវបានជំនុំជម្រះក្តីដោយតុលាការអន្តរជាតិរួចហើយនោះទេ។

២. ជនណាដែលត្រូវបានផ្តន្ទាទោសដោយតុលាការជាតិ ចំពោះអំពើទាំងឡាយដែលបង្កបានជាការរំលោភធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ អាចត្រូវបានជំនុំជម្រះទោសឡើងវិញ តែក្នុងករណី ដែល៖

(ក) ជននោះត្រូវបានផ្តន្ទាទោសចំពោះអំពើ ដែលត្រូវបានកំណត់ចរិតលក្ខណៈជាបទល្មើសធម្មតា ឬ

(ខ) ដំណើរការនីតិវិធីដោយតុលាការជាតិមិនមានអនាគតិ ឬឯករាជ្យ ដែលត្រូវបានរៀបចំឡើងដើម្បីការពារជនជាប់ចោទឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ ឬ រឿងក្តីនោះមិនត្រូវបានចោទប្រកាន់ប្រកបដោយវីរិយភាពតែប៉ុណ្ណោះ។

៣. ក្នុងការពិចារណាអំពីទណ្ឌកម្ម ដែលត្រូវសម្រេចទៅលើជនណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសនៅក្រោមលក្ខន្តិកៈបច្ចុប្បន្នរួចហើយ នោះតុលាការអន្តរជាតិត្រូវពិចារណាពីទណ្ឌកម្មដែលបានសម្រេចដោយតុលាការជាតិទៅលើមនុស្សតែមួយ ចំពោះបទល្មើសតែមួយដែលត្រូវយកមកផ្តន្ទាទោសរួចហើយ។

១៣៣. ខ្លឹមសារនៃបទប្បញ្ញត្តិនេះត្រូវបានបង្កើតឡើងវិញនៅក្នុងពាក្យពេចន៍ស្រដៀងគ្នា ក្នុងមាត្រា ៩ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") មាត្រា ៩ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") និងមាត្រា ៥ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសឡេបាណន់ ("STL")[២៧៩]។

១៣៤. លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់បង្កើតតុលាការ ICC ក៏មានបញ្ចូលបទប្បញ្ញត្តិ ស្តីពី*ការមិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ទៅក្នុងមាត្រា ២០ នៃលក្ខន្តិកៈនេះ ផងដែរ៖

មាត្រា ២០៖

*ការមិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*

[២៧៩] ក្រៅពីមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងពាក្យពេចន៍ មានភាពខុសគ្នាតែមួយគត់ គឺមាត្រា ១០(២)(ក) នៃលក្ខន្តិកៈតុលាការ ICTY មិនត្រូវបានយកទៅចែងឡើងវិញនៅក្នុងនៅក្នុងលក្ខន្តិកៈតុលាការ STL ដែលត្រូវបានពន្យល់យ៉ាងងាយថា តុលាការ STL មានយុត្តាធិការតែទៅលើបទល្មើសជាតិរបស់ប្រទេសលីបង់តែប៉ុណ្ណោះ។

១. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសនៅចំពោះមុខតុលាការនេះ ទាក់ទងនឹងអំពើដែលបង្កើតបានជាមូលដ្ឋាននៃបទល្មើស ដែលតុលាការនេះបានសម្រេចផ្តន្ទាទោស ឬសម្រេចឱ្យរួចផុតពីការចោទប្រកាន់ហើយនោះទេ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីលក្ខន្តិកៈនេះ។

២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសដោយតុលាការមួយផ្សេង ចំពោះបទល្មើសដូចដែលបានយោងក្នុងមាត្រា ៥ ដែលតុលាការនេះបានសម្រេចផ្តន្ទាទោស ឬសម្រេចឱ្យរួចផុតពីការចោទប្រកាន់ហើយនោះទេ។

៣. គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជម្រះក្តីដោយតុលាការមួយផ្សេងទៀត ចំពោះអំពើដែលមានចែងក្នុងមាត្រា ៦ មាត្រា ៧ ឬមាត្រា ៨ផងដែរនោះ ត្រូវបានផ្តន្ទាទោសដោយតុលាការនេះទាក់ទងនឹងបទល្មើសតែមួយនោះទេ លើកលែងតែដំណើរការនីតិវិធីនៅក្នុងតុលាការផ្សេងនោះ៖

(ក) បានប្រព្រឹត្តទៅដោយមានបំណងធ្វើឱ្យជនដែលពាក់ព័ន្ធនោះ រួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ ឬ

(ខ) មិនបានដំណើរការដោយឯករាជ្យ ឬអនាគតិ ស្របតាមបទដ្ឋាននីតិវិធីដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ និងបានដំណើរការក្នុងលក្ខណៈមួយមិនស្របនឹងគោលបំណងដើម្បីនាំខ្លួនជនពាក់ព័ន្ធនោះមកផ្តន្ទាទោស នៅក្នុងកាលៈទេសៈបែបនេះនោះទេ[២៨០]។

១៣៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បទដ្ឋានទាំងនេះបញ្ជាក់ឱ្យឃើញថា តុលាការអន្តរជាតិនានាអាចជៀសវាងពីការអនុវត្តយុត្តាធិការប្រឆាំងនឹងជនណាម្នាក់ ដែលត្រូវបានតុលាការជាតិមួយជំនុំជម្រះទោសរួចហើយ ដោយយោងទៅលើមូលដ្ឋាននៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ក្នុងករណីដែលដំណើរការនីតិវិធីដោយតុលាការជាតិនេះ បានបំពេញលក្ខខណ្ឌជាក់លាក់ហើយនោះ។ ប៉ុន្តែ ម្យ៉ាង ការលើកលែងចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានកំណត់ឡើងដោយមានការប្រើប្រាស់ពាក្យពេចន៍ផ្សេងគ្នានៅក្នុងលក្ខន្តិកៈសម្រាប់តុលាការ *មិនអចិន្ត្រៃយ៍* និងម្យ៉ាងវិញទៀតគឺលក្ខន្តិកៈទីក្រុងរ៉ូមនេះឯង។

១៣៦. ទីមួយ លក្ខន្តិកៈសម្រាប់តុលាការ *មិនអចិន្ត្រៃយ៍* មានការលើកលែងមួយដែលមិនត្រូវបានយកមកចែងឡើងវិញនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមគឺ "ការលើកលែងចំពោះបទល្មើសធម្មតា" ដែលមានចែងក្នុងកថាខណ្ឌ ២(ក) នៃលក្ខន្តិកៈសម្រាប់តុលាការ ICTY, ICTR និង SCSL ដែលអនុញ្ញាតឱ្យតុលាការ *មិនអចិន្ត្រៃយ៍* ធ្វើការជំនុំជម្រះសាជាថ្មីចំពោះអំពើតែមួយ ប្រសិនបើអំពើដែលត្រូវបាន

[២៨០] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២០។

យកមកផ្តន្ទាទោសចំពោះជននោះ មិនត្រូវបានកំណត់ចរិតលក្ខណៈតាមផ្លូវច្បាប់ថា ជាបទល្មើសអន្តរជាតិ នៅក្នុងដំណើរការនីតិវិធីដោយតុលាការជាតិនោះទេ។

១៣៧. ចំពោះការលើកលែងទីពីរ ដែលឆ្លើយតបទៅនឹងបទដ្ឋានដែលដំណើរការនីតិវិធីដោយតុលាការជាតិត្រូវធានាការពារមិនឲ្យមានការចោទប្រកាន់ជាថ្មីទៀតនៅចំពោះមុខតុលាការអន្តរជាតិនានានោះ អង្គបុរេជំនុំ-ជម្រះកត់សម្គាល់ឃើញថា ភាសាដែលបានប្រើប្រាស់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមខុសគ្នាដោយផ្នែកខ្លះពីភាសាដែលបានប្រើប្រាស់នៅក្នុងលក្ខន្តិកៈតុលាការ *មិនអចិន្ត្រៃយ៍* ដែលត្រូវបានអនុម័តទាំងមុន និងទាំងក្រោយលក្ខន្តិកៈទីក្រុងរ៉ូម។

១៣៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ទាំងលក្ខន្តិកៈតុលាការ *មិនអចិន្ត្រៃយ៍* និងទាំងលក្ខន្តិកៈទីក្រុងរ៉ូម មានការលើកលែងមួយចំនួនចំពោះគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ចំពោះដំណើរការនីតិវិធី៖

១) ដែលបានដំណើរការដោយមានបំណងធ្វើឲ្យជនពាក់ព័ន្ធនោះ រួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការតុលាការអន្តរជាតិ (មាត្រា ១០(២)(ខ) នៃលក្ខន្តិកៈតុលាការ ICTY និងមាត្រា ២០(៣)(ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម)។

២) ដែលមិនបានដំណើរការដោយឯករាជ្យ ឬអនាគតិ ស្របតាមបទដ្ឋាននីតិវិធីដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ (មាត្រា ១០(២)(ខ) នៃលក្ខន្តិកៈតុលាការ ICTY និងមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម)។ ក្នុងករណីនៃតុលាការ ICC មាត្រា ២០(៣)(ខ) ចែងបន្ថែមថា "និងត្រូវបានដំណើរការនីតិវិធី ក្នុងលក្ខណៈមួយមិនស្របនឹងគោលបំណងដើម្បីនាំខ្លួនជនដែលពាក់ព័ន្ធនោះមកផ្តន្ទាទោស នៅក្នុងកាលៈទេសៈបែបនេះនោះទេ"។

១៣៩. សហមេធាវីការពារក្តីរបស់ អៀង សារី លើកឡើងថា ផ្នែកចុងក្រោយនៃមាត្រា ២០(៣)(ខ) ចែងថា តុលាការ ICC អាចផ្តន្ទាទោសតែចំពោះជនណាដែលត្រូវបានកាត់ទោសរួចហើយ ចំពោះអំពើដដែល ក្នុងករណីដែលដំណើរការនីតិវិធីដោយតុលាការជាតិ បានប្រព្រឹត្តទៅដោយមានបំណងធ្វើឲ្យជននោះរួចផុតពីការផ្តន្ទាទោសតែប៉ុណ្ណោះ[២៨១]។ សហមេធាវីការពារក្តីលើកឡើងថា "ភាពខុសគ្នា

[២៨១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៧។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00661574



ទៅនឹងលក្ខន្តិកៈតុលាការ ICC បង្ហាញថា ករណីលើកលែងចំពោះគោលការណ៍នេះមិនបានបំភ្លឺនៅក្នុងច្បាប់អន្តរជាតិ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងផងទេ”[២៨២]។

១៤០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការមិនមានចែងអំពីការការពារជាអន្តរជាតិណាមួយចំពោះ *ការកាត់ទោសពីរដងទៅលើបទល្មើសតែមួយ* នៅក្នុងមាត្រា១៤(៧) នោះកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះគឺមិនមែនដើម្បីពិចារណា ថាតើការលើកលែងចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងទៅលើបទល្មើសតែមួយ* ត្រូវបានបំភ្លឺនៅក្នុងច្បាប់អន្តរជាតិដែរឬអត់នោះទេ ប៉ុន្តែថាតើបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ មានភាពស្របគ្នាគ្រប់គ្រាន់ដើម្បីឱ្យអង្គបុរេជំនុំជម្រះស្វែងរកការណែនាំនៅក្នុងបទដ្ឋានទាំងនោះ សម្រាប់យកមកដោះស្រាយបញ្ហានៅក្នុងដៃបានដែរឬយ៉ាងណា នោះមានន័យថាតើ អ.វ.ត.ក អាចអនុវត្តយុត្តាធិការដើម្បីកាត់ទោស អៀង សារី ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែរ ឬអត់នោះ។

១៤១. គិតមកទល់នឹងថ្ងៃចេញសេចក្តីសម្រេចនេះ អង្គបុរេជំនុំជម្រះមិនបានរកឃើញច្បាប់យុត្តិសាស្ត្រណាមួយពីតុលាការ ICC ដែលបានបកស្រាយមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ ហើយសហមេធាវីការពារក្តីក៏មិនបានរកឃើញករណីណាមួយ ដើម្បីគាំទ្រដល់ការបកស្រាយរបស់ខ្លួនចំពោះបទប្បញ្ញត្តិនេះដែរ។ ក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលហេតុផលសំខាន់ៗ ដែលស្ថិតនៅពីខាងក្រោយការអនុម័តលក្ខន្តិកៈសម្រាប់តុលាការ *មិនអចិន្ត្រៃយ៍*នានា *ឯកសារព្រាង* លក្ខន្តិកៈទីក្រុងរ៉ូម និងសេចក្តីអត្ថាធិប្បាយរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់[២៨៣] ដើម្បីពិចារណា ថាតើលក្ខន្តិកៈទីក្រុងរ៉ូមអាចនាំឱ្យមានការងាកចេញពីបទដ្ឋានសម្រាប់តុលាការ *មិនអចិន្ត្រៃយ៍* ដែលនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា ដែលអង្គបុរេជំនុំជម្រះនឹងត្រូវយកមកពិចារណាដើម្បីស្វែងរកការណែនាំនៅក្នុងបទដ្ឋានទាំងនេះដែរ ឬយ៉ាងណានោះ។

១៤២. មូលហេតុសំខាន់ៗ សម្រាប់ការអនុម័តបទប្បញ្ញត្តិជាក់លាក់មួយចំពោះ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅក្នុងលក្ខន្តិកៈសម្រាប់តុលាការ*មិនអចិន្ត្រៃយ៍* កើតចេញពីការណ៍ដែលថា ការបង្កើតតុលាការអន្តរជាតិ ឬតុលាការដែលមានចរិតលក្ខណៈអន្តរជាតិ នាំឱ្យបង្កើនហានិភ័យនៃការដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការកាត់ទោសពីរដង ដោយហេតុថា

---

[២៨២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៧។

[២៨៣] មាត្រា ៣២ នៃអនុសញ្ញាទីក្រុងវីយែន និងមាត្រា ៣៨(១)(ឃ) នៃ*លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ* (ICC)។

តាមនិយមន័យ តុលាការទាំងនេះមានយុត្តាធិការទៅលើបទល្មើសអន្តរជាតិ ដែលជាកម្មវត្ថុនៃយុត្តាធិការសកល។ ហេតុដូច្នេះ អវត្តមានការការពារជាអន្តរជាតិចំពោះ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះតម្រូវឱ្យមានការទទួលស្គាល់គោលការណ៍ទាំងនេះ ដែលត្រូវបានទទួលស្គាល់នៅក្រោមទម្រង់ផ្សេងៗក្នុងប្រព័ន្ធច្បាប់ខុសៗគ្នា[២៨៤] និងប្រើប្រាស់ជាទម្លាប់សម្រាប់គោលបំណងពីរ គឺដើម្បីការពារជនទាំងឡាយមិនឱ្យមានការយាយីពីសំណាក់រដ្ឋ និងជាការធានាដ៏សំខាន់មួយសម្រាប់សច្ចភាពតតិយុត្តិ។ ជាពិសេសតាមទស្សនវិស័យសិទ្ធិមនុស្ស គំនិតដែលបានលើកឡើងអំពីការហាមឃាត់មិនឱ្យមានការកាត់ទោសពីរដងគឺថា "ដោយខ្លួនមានមធ្យោបាយ និងអំណាចទាំងអស់នោះ រដ្ឋមិនគួរត្រូវបានអនុញ្ញាតឱ្យមានចេតនាម្តងហើយម្តងទៀត ដើម្បីផ្តន្ទាទោសជនណាម្នាក់ចំពោះបទល្មើសណាមួយ ដែលតាមរយៈនេះបណ្តាលឱ្យជននោះប្រឈមមុខការយាយី ការចំណាយ ការឈឺចាប់ និងបង្ខំឱ្យជននោះរស់នៅដោយមានអារម្មណ៍ខ្វល់ខ្វាយ និងអសន្តិសុខ ក៏ដូចជាការបង្កើនឱ្យមានលទ្ធភាពដែលថា ទោះបីជាជននោះគ្មានពិរុទ្ធភាពក៏ដោយ ក៏ជននោះអាចត្រូវបានគេសម្រេចថាមានទោសបានដែរ" ដូចដែលតុលាការកំពូលសហរដ្ឋអាមេរិកបានលើកឡើងនៅក្នុងរឿងក្តីរវាង Green *តទល់នឹង សហរដ្ឋអាមេរិក*[២៨៥]។ តាមរយៈទស្សនវិស័យនៃសច្ចភាពតតិយុត្តិ ទ្រឹស្តីនេះបានដើរតួនាទីនៅក្នុងការលើកស្ទួយឱ្យមានជំនឿទុកចិត្តពីសាធារណជន ចំពោះប្រព័ន្ធយុត្តិធម៌ និងការគោរពដល់ដំណើរការនីតិវិធីតុលាការ។ ទ្រឹស្តីនេះក៏ជួយពង្រឹងឱ្យមានការផ្តន្ទាទោសដោយប្រុងប្រយ័ត្នផងដែរ[២៨៦]។

---

[២៨៤] Christine Van den Wyngaert និង Tom Ongena "*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយរួមទាំងការលើកលែងទោស*" នៅក្នុងសេចក្តីអត្ថាធិប្បាយរបស់ Antonio Cassese, Paola Gaeta និង John R.W.D Jones។ លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីអត្ថាធិប្បាយ វ៉ុលលេខ ១ បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០២ ទំព័រ ៧០៥ (អង់គ្លេស) កថាខណ្ឌ ៧០៦ ("គោលការណ៍នេះត្រូវបានគេស្គាល់នៅក្រោមឈ្មោះខុសៗគ្នា ក្នុងប្រព័ន្ធច្បាប់ផ្សេងៗគ្នា រួមទាំងបទដ្ឋានស្តីពីអាជ្ញាអស់ជំនុំ (*res judicata*) *បទដ្ឋានស្តីពីការសម្រេចឱ្យរួចផុតពីការចោទប្រកាន់/ការសម្រេចផ្តន្ទាទោស* (the rule of *autrefois acquit/autrefois convict*) និងការការពារមិនឱ្យមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ")។

[២៨៥] រឿងក្តីរវាង *Green តទល់នឹង សហរដ្ឋអាមេរិក*, 355 U.S. 184 (1957), កថាខណ្ឌ ១៨៧ ដល់ ១៨៨។

[២៨៦] Stefan Trechsel, *សិទ្ធិមនុស្សនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ*, បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០៥ ទំព័រ ៣៨៣ ដល់ ៣៨៤ (អង់គ្លេស)។ Lorraine Finlay "តើតុលាការព្រហ្មទណ្ឌអន្តរជាតិការពារមិនឱ្យមានការកាត់ទោសពីរដងដែរឬយ៉ាងណានោះ៖ ការវិភាគទៅលើមាត្រា ២០ នៃលក្ខន្តិកៈទីក្រុងរ៉ូម", 15 *U.C. Davis Int'l L & Pol'y* 221 ត្រង់កថាខណ្ឌ ២២៤។

១៤៣. ទោះជាយ៉ាងណាក៏ដោយ ផលប្រយោជន៍ទាំងនេះត្រូវបានថ្លឹងថ្លែងឱ្យមានតុល្យភាពជាមួយគ្នានឹងផលប្រយោជន៍របស់សហគមន៍អន្តរជាតិ និងជនរងគ្រោះ ដើម្បីធានាថា អ្នកដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសអន្តរជាតិ ត្រូវបានផ្តន្ទាទោសយ៉ាងត្រឹមត្រូវ[២៨៧]។

១៤៤. ហេតុដូច្នេះ ដំណោះស្រាយប្រកបដោយការយោគយល់មួយត្រូវបានរកឃើញ ដូចដែលលោក Cassese ពន្យល់ថា៖

> "[បទល្មើសអន្តរជាតិ] រំលោភទៅលើតម្លៃដែលលើសលប់លើបណ្តារដ្ឋ និងសហគមន៍របស់រដ្ឋទាំងនោះ។ វាធ្វើឱ្យប៉ះពាល់ និងពាក់ព័ន្ធដល់រដ្ឋទាំងអស់នោះ។ ហេតុដូច្នេះ រដ្ឋណាក៏ដោយក៏មានសិទ្ធិធ្វើការចោទប្រកាន់ និងផ្តន្ទាទោសចំពោះបទល្មើសទាំងនោះបានដែរ ឱ្យតែតុលាការរបស់រដ្ឋដែលកាត់សេចក្តីចំពោះបទល្មើសទាំងនោះ ធ្វើឡើងស្របទៅនឹងគោលការណ៍មូលដ្ឋានខ្លះៗ ស្តីពីការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងប្រព្រឹត្តទៅដោយឯករាជ្យ អនាគតិ និងដោយប្រុងប្រយ័ត្ននោះ រដ្ឋដទៃ និងរដ្ឋដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តឡើង រួមទាំងតុលាការអន្តរជាតិនានាផងដែរ ត្រូវតែដកខ្លួនចេញពីការជំនុំជម្រះក្តីចំពោះបទល្មើសតែមួយនេះ"[២៨៨]។

១៤៥. អាស្រ័យហេតុនេះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានលើកឡើងនៅក្នុងរបាយការណ៍របស់គាត់ដាក់ជូនក្រុមប្រឹក្សាសន្តិសុខស្តីពីការអនុម័តលក្ខន្តិកៈតុលាការ ICTY ថា៖

> អនុលោមតាមគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បុគ្គលម្នាក់មិនត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសតែមួយបានទេ។ នៅក្នុងបរិបទបច្ចុប្បន្ន ដោយសារតែបឋមភាពរបស់តុលាការអន្តរជាតិ នោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អាចហ្រានចោលមិនឱ្យមានការកាត់ទោសជាបន្តបន្ទាប់នៅចំពោះមុខតុលាការជាតិ។ ប៉ុន្តែ គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនគួរហ្រានចោលមិនឱ្យមានការកាត់ទោសជាបន្តបន្ទាប់ នៅចំពោះមុខតុលាការអន្តរជាតិនោះទេ នៅក្រោមកាលៈទេសៈពីរដូចខាងក្រោមនេះ៖

---

[២៨៧] Yasmin Q. Naqvi, *ឧបសគ្គចំពោះការអនុវត្តយុត្តាធិការទៅលើបទល្មើសអន្តរជាតិ*, ទីក្រុងឡាអេ បោះពុម្ពផ្សាយដោយ TMC Asser ឆ្នាំ ២០១០ ទំព័រ ២៨៨ (អង់គ្លេស)។ Lorraine Finlay "តើតុលាការព្រហ្មទណ្ឌអន្តរជាតិការពារមិនឱ្យមានការកាត់ទោសពីរដងដែរឬយ៉ាងណានោះ៖ ការវិភាគទៅលើមាត្រា ២០ នៃលក្ខន្តិកៈទីក្រុងរ៉ូម, 15 *U.C. Davis Int'l L & Pol'y* 221 ត្រង់កថាខណ្ឌ ២២៤។

[២៨៨] Cassese ឆ្នាំ ២០០៣ ទំព័រ ៣២០ (អង់គ្លេស)។

(ក) ការកំណត់បទចោទ ដោយតុលាការជាតិ មិនឆ្លើយតបទៅនឹងការកំណត់បទចោទទៅតាមលក្ខន្តិកៈនេះទេ ឬ

(ខ) លក្ខខណ្ឌនៃអនាគតិ ឯករាជ្យភាព ឬមធ្យោបាយប្រកបដោយប្រសិទ្ធភាពនៃការវិនិច្ឆ័យសេចក្តី មិនត្រូវបានធានានៅក្នុងដំណើរការនីតិវិធី នៅចំពោះមុខតុលាការជាតិនោះទេ[២៨៩]។

១៩៦. ក្នុងរឿងក្តីរវាង*រដ្ឋអាជ្ញា តទល់នឹង Tadić* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានលើកឡើងផងដែរថា "ខ្លួនមានទស្សនៈយល់ឃើញទៅលើកាលៈទេសៈពិសេស ដែលមានចែងនៅក្នុងមាត្រា ១០(២) នៃលក្ខន្តិកៈនេះថា ជាការលើកលែងមួយមានកម្រិត ចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*"[២៩០]។

១៩៧. នៅក្នុងករណីនៃការផ្តន្ទាទោសលើកមុន គេបានកត់សម្គាល់ឃើញថា ភាពត្រឹមត្រូវចំពោះជនជាប់ចោទត្រូវបានរក្សាទុកដោយការអនុវត្ត "គោលការណ៍កាត់បន្ថយការផ្តន្ទាទោស" ដែលមានន័យថា ពេលវេលាទទួលទោសជាប់ពន្ធនាគារ នឹងត្រូវបានកាត់បន្ថយពីការផ្តន្ទាទោសបន្តបន្ទាប់មកទៀតទាក់ទងទៅនឹងអំពើតែមួយ[២៩១]។

១៩៨. នៅក្នុងសេចក្តីព្រាងលក្ខន្តិកៈសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("សេចក្តីព្រាងលក្ខន្តិកៈរបស់ ILC") គណៈកម្មាធិការច្បាប់អន្តរជាតិបានស្នើសុំឱ្យមានបទប្បញ្ញត្តិមួយស្តីពី*ការមិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយបានសង្កត់ធ្ងន់ទៅលើមាត្រា១០ នៃលក្ខន្តិកៈ ICTY[២៩២]

---

[២៨៩] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ៨០៨ (១៩៩៣) ឯកសារ អ.ស.ប លេខ S/25704, ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៦៦(ខ)។

[២៩០] រឿងក្តីរវាង*រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-T, "សេចក្តីសម្រេចទៅលើសារណារបស់មេធាវីការពារក្តី អំពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៣។

[២៩១] មាត្រា ១០(៣) នៃលក្ខន្តិកៈតុលាការ ICTY មាត្រា ៩(៣) នៃលក្ខន្តិកៈតុលាការ ICTR មាត្រា ៩(៣) នៃលក្ខន្តិកៈតុលាការ SCSL និង មាត្រា ៥(៣) នៃលក្ខន្តិកៈតុលាការ STL។ *សូមមើលផងដែរ* Christine Van den Wyngaert និង Tom Ongena ទំព័រ ៧២០ (អង់គ្លេស)។

[២៩២] របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិអំពីកិច្ចការរបស់ខ្លួន ក្នុងសម័យប្រជុំលើកទី ៤៦ ពីថ្ងៃទី ២ ខែ ឧសភា ដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៤ ឯកសារលេខ A/49/10 សៀវភៅកំណត់ហេតុប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ១៩៩៤ វ៉ុល II ផ្នែកទី ២ ទំព័រ ៥៧ (អង់គ្លេស) កថាខណ្ឌ ២។

00661578



ដូចដែលខ្លួនបានស្នើសុំកាលពីលើកមុន សម្រាប់សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ។ ការលើកលែងនៅក្នុងមាត្រា ៤២(២)(ខ) នៃសេចក្តីព្រាងលក្ខន្តិកៈ របស់ ILC គឺដូចគ្នាយ៉ាងច្រើន ទៅនឹងមាត្រា ១០(២)(ខ) នៃលក្ខន្តិកៈតុលាការ ICTY[២៩៣]។ យោង តាមគណៈកម្មាធិការច្បាប់អន្តរជាតិ មាត្រា ៤២(២)((ខ) ត្រូវបានយកមកអនុវត្ត "ករណីសវនា ការបំភាន់ភ្នែក មានន័យថា មានចេតនាការពារជនជាប់ចោទឱ្យរួចផុតពីការទទួលខុសត្រូវផ្នែក ព្រហ្មទណ្ឌអន្តរជាតិ"[២៩៤]។ សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ដែលនៅ សេសសល់ចំពោះមាត្រា ៤២(២)(ខ) នោះគឺមានដូចខាងក្រោមនេះ៖

> កថាខណ្ឌ ២(ខ) ឆ្លុះបញ្ចាំងពីទស្សនៈដែលយល់ឃើញថា តុលាការនេះគួរតែជំនុំជម្រះលើ ជនជាប់ចោទ ប្រសិនបើដំណើរការនីតិវិធីព្រហ្មទណ្ឌលើកមុនសម្រាប់បទល្មើសដដែល ពិតជាដំណើរការនីតិវិធីគ្រាន់តែ"បំភាន់ភ្នែក" ដែលប្រហែលជាធ្វើឡើងដើម្បីការពារជន ជាប់ចោទឱ្យរួចផុតពីការផ្តន្ទាទោសរបស់តុលាការតែប៉ុណ្ណោះ។ គណៈកម្មាធិការនេះបាន សម្រេចប្រើពាក្យ "រឿងក្តីនោះមិនត្រូវបានជំនុំជម្រះឱ្យបានហ្មត់ចត់" ដោយយោងទៅលើការ យល់ឃើញថា ពួកគាត់មិនមានចេតនាអនុវត្តចំពោះតែភាពចន្លោះប្រហោង ឬកំហុសឆ្គងនៃ ការផ្តន្ទាទោសលើកមុនប៉ុណ្ណោះទេ ប៉ុន្តែ ចំពោះការខ្វះការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ ក្នុងកម្រិតមួយដែលត្រូវបានគេគិតថា ដើម្បីការពារជនជាប់ចោទពីការទទួលខុសត្រូវពិតៗ ចំពោះអំពើដែលចោទជាបញ្ហានេះ។ កថាខណ្ឌ ២(ខ) ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយ ក្នុងករណីលើកលែងតែប៉ុណ្ណោះ[២៩៥]។

---

[២៩៣] មាត្រា ៤២(២)(ខ) បានចែងថា៖ "ដំណើរការនីតិវិធីនៅក្នុងតុលាការផ្សេងទៀត គឺមិនមានអនាគតិ និងឯករាជ្យ ឬត្រូវបានធ្វើ ឡើងដើម្បីការពារជនជាប់ចោទឱ្យរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអន្តរជាតិ ឬរឿងក្តីនោះមិនត្រូវបានផ្តន្ទាទោសប្រកប ដោយវីរិយនោះទេ"។

[២៩៤] របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិអំពីកិច្ចការរបស់ខ្លួន ក្នុងសម័យប្រជុំលើកទី ៤៦ ពីថ្ងៃទី ២ ខែ ឧសភា ដល់ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ១៩៩៤ សៀវភៅកំណត់ហេតុប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ១៩៩៤ វ៉ុល II ផ្នែកទី ២ ទំព័រ ៥៨ កថាខណ្ឌ ៥។

[២៩៥] របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិអំពីកិច្ចការរបស់ខ្លួន ក្នុងសម័យប្រជុំលើកទី ៤៦ ពីថ្ងៃទី ២ ខែ ឧសភា ដល់ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៤ សៀវភៅកំណត់ហេតុប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ១៩៩៤ វ៉ុល II ផ្នែកទី ២ ទំព័រ ៥៩ កថាខណ្ឌ ៧។



PRE-TRIAL CHAMBER * E.C.C.C. * E.T.C. PRÉLIMINAIRE

00661579



១៤៩. នៅក្នុងសេចក្ដីអត្ថាធិប្បាយរបស់ខ្លួនទៅលើមាត្រា ១២(២)(ក)(ii) នៃសេចក្ដីព្រាងរបស់ខ្លួនទៅលើក្រមស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ គណៈកម្មាធិការច្បាប់អន្តរជាតិក៏បានលើកឡើងផងដែរថា៖

> ក្នុងករណីបែបនេះ ជនដែលមិនត្រូវបានជំនុំជម្រះ ឬផ្ដន្ទាទោសចំពោះអំពើដែល ឬបទល្មើសតែមួយ ដោយសារតែការរំលោភអំណាច ឬការចាត់ចែងដំណើរការយុត្តិធម៌ មិនបានត្រឹមត្រូវដោយអាជ្ញាធរជាតិ នៅក្នុងការជំនុំជម្រះរឿងក្ដី ឬនៅក្នុងការបំពេញដំណើរការនីតិវិធី។ សហគមន៍អន្តរជាតិ មិនត្រូវបានតម្រូវឲ្យទទួលស្គាល់សេចក្ដីសម្រេចមួយ ដែលជាលទ្ធផលនៃការបំពានធ្ងន់ធ្ងរទៅលើដំណើរយុត្តិធម៌ព្រហ្មទណ្ឌនោះទេ[២៩៦]។

១៥០. ទស្សនៈយល់ឃើញមួយ ត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ *មិនអចិន្ត្រៃយ៍* ដែលត្រូវបានធ្វើឡើងដើម្បីពិភាក្សាទៅលើសេចក្ដីព្រាងលក្ខន្តិកៈទីក្រុងរ៉ូមដែលថា មាត្រា៤២ នៃសេចក្ដីព្រាងលក្ខន្តិកៈតុលាការ ILC "បានឈានចូលទៅកៀកនឹងការធ្វើឲ្យអន្តរាយដល់គោលការណ៍នៃ "ការបំពេញបន្ថែម" ដែលមានចែងក្នុងមាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងកាត់សេចក្ដីតែករណីទាំងឡាយ ដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់ខ្លួនតែប៉ុណ្ណោះ ប្រសិនបើរដ្ឋទាំងឡាយមិនមានចេតនា ឬមិនអាចកាត់សេចក្ដីចំពោះករណីទាំងនោះដោយខ្លួនឯងបានទេ[២៩៧]។ យោងតាមរបាយការណ៍របស់គណៈ កម្មាធិការ *មិនអចិន្ត្រៃយ៍* "ភាពសមស្របនៃការផ្ដល់អំណាចទៅឲ្យតុលាការ ដើម្បីចេញសេចក្ដីសម្រេចអំពីអនាគតិ ឬឯករាជ្យភាពរបស់តុលាការជាតិ ត្រូវបានចោទជាបញ្ហាយ៉ាងធ្ងន់ធ្ងរ" ហើយ "កថាខណ្ឌរង (ខ) នៃមាត្រា ៤២(២) នៃសេចក្ដីព្រាងលក្ខន្តិកៈតុលាការ ILC ត្រូវបានប្រតិភូខ្លះពិចារណាថា បានរៀបចំឡើងដោយមានភាពស្រពិចស្រពិលយ៉ាងខ្លាំង និងពាក់ព័ន្ធទៅនឹងការវាយតម្លៃជាអត្តនោម័ត"[២៩៨]។

---

[២៩៦] របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិអំពីកិច្ចការរបស់ខ្លួន ក្នុងសម័យប្រជុំលើកទី ៤៨ ពីថ្ងៃទី ៦ ខែ ឧសភា ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ សៀវភៅកំណត់ហេតុប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ វ៉ុល II ផ្នែកទី ២ ទំព័រ ៣៨ កថាខណ្ឌ ១១។

[២៩៧] មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[២៩៨] របាយការណ៍របស់គណៈកម្មាធិការមិនអចិន្ត្រៃយ៍ ស្ដីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារ អ.ស.ប A/50/22 កំណត់ហេតុផ្លូវការរបស់មហាសន្និបាត សម័យប្រជុំលើកទី ៥០ ឯកសារបំពេញបន្ថែមលេខ ២២ កថាខណ្ឌ ១៧៧ និង ១៨០។ *សូមមើលផងដែរ* កថាខណ្ឌ ៤៣ កថាខណ្ឌ ៩២ និងកថាខណ្ឌ ១០៩។

១៥១. នៅឯកិច្ចប្រជុំរបស់គណៈកម្មាធិការរៀបចំសេចក្តីព្រាង ក្នុងឆ្នាំ ១៩៩៦៖

[ប្រតិភូជាច្រើនបានសម្តែងការព្រួយបារម្ភរបស់ខ្លួនអំពីភាពមិនច្បាស់លាស់ និងភាពសក្បានុម័តនៃលក្ខណៈវិនិច្ឆ័យក្នុងមាត្រា ៤២(២)(ខ) នៃសេចក្តីព្រាងលក្ខន្តិកៈតុលាការ ILC]។ គេបានចង្អុលបង្ហាញថា បទល្មើសសំខាន់ៗមួយចំនួនមិនអាចជំនុំជម្រះប្រកបដោយប្រសិទ្ធភាព ដោយតុលាការជាតិបានទេ ដោយសារចរិតលក្ខណៈ និងកាលៈទេសៈខុសៗគ្នានៃការប្រព្រឹត្តបទល្មើសទាំងនោះ។ ប្រតិភូមួយចំនួនបានយល់ថា ពាក្យពេចន៍នេះអាចអនុញ្ញាតឱ្យតុលាការមានសិទ្ធិមួយលើសលប់ ត្រួតត្រាទៅលើយុត្តាធិការជាតិ និងអាចធ្វើឱ្យអន្តរាយដល់គោលការណ៍នៃការបំពេញបន្ថែម។ យោងតាមទស្សនៈយល់ឃើញនេះ តុលាការនេះមិនគួរត្រូវបានពិចារណាថាជាតុលាការជាន់ខ្ពស់នោះទេ។ ប៉ុន្តែ ប្រតិភូខ្លះទៀតបានពិចារណាទៅលើមាត្រា ដែលបានព្រាងដោយគណៈកម្មាធិការច្បាប់អន្តរជាតិថា មានភាពច្បាស់លាស់គ្រប់គ្រាន់ និងងាយយល់[២៩៩]។

១៥២. នាសម័យប្រជុំលើកចុងក្រោយរបស់ខ្លួនក្នុងឆ្នាំ ១៩៩៨ គណៈកម្មាធិការរៀបចំសេចក្តីព្រាងបានអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ១៨(៣)(ខ) ដែលមានពាក្យពេចន៍ស្ទើរតែដូចគ្នានឹងពាក្យពេចន៍ក្នុងមាត្រា២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម[៣០០]។ សេចក្តីព្រាងមាត្រា១៨(៣) ត្រូវបានប្រតិភូតំណាងរដ្ឋភាគីពិភាក្សាគ្នានៅឯសន្និបាតក្នុងទីក្រុងរ៉ូម ការផ្តល់មតិយោបល់ត្រូវបានលើកឡើង ដោយបានឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញថា បណ្តារដ្ឋទាំងឡាយបានយល់ឃើញថា បទប្បញ្ញត្តិនេះអនុញ្ញាតឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិទទួលបាននូវ

---

[២៩៩] របាយការណ៍របស់គណៈកម្មាធិការរៀបចំ ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ វ៉ុល I (ដំណើរការនីតិវិធីរបស់គណៈកម្មា-ធិការរៀបចំសេចក្តីព្រាង នៅក្នុងអំឡុងខែ មីនា មេសា និង សីហា ឆ្នាំ ១៩៩៦) ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ ឯកសារ អ.ស.ប លេខ A/51/22 កថាខណ្ឌ ១៧២។ *សូមមើលផងដែរ* សេចក្តីព្រាងលក្ខន្តិកៈ របាយការណ៍របស់គណៈកម្មាធិការរៀបចំសេចក្តីព្រាង ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារបំពេញបន្ថែម អ.ស.ប A/CONF.183/2/Add.1 (ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៩៨) ទំព័រ ៤១ (អង់គ្លេស) លេខយោងជើងទំព័រ ៤២ និងរបាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិទៅលើកិច្ចការក្នុងសម័យប្រជុំលើកទី ៤៦ ពីថ្ងៃទី ២ ខែ ឧសភា ដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៩៤ ឯកសារ អ.ស.ប A/49/10 ទំព័រ ២៥ កថាខណ្ឌ ៧២។

[៣០០] សេចក្តីព្រាងលក្ខន្តិកៈ របាយការណ៍របស់គណៈកម្មាធិការរៀបចំសេចក្តីព្រាង ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារបំពេញបន្ថែម អ.ស.ប A/CONF.183/2/Add.1 (ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៩៨) ទំព័រ ៤៥ ដល់ ៤៦។ នៅឯសន្និបាតក្នុងទីក្រុងរ៉ូម មានតែពាក្យថា "ស្របតាមបទដ្ឋាននីតិវិធីដែលបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ" ត្រូវបានបន្ថែមទៅលើអ្វីដែលបានក្លាយជាមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម [Committee of the Whole, Bureau Discussion Paper, ឯកសារ អ.ស.ប លេខ A/CONF.183/C.1/L.53 ចុះថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ទំព័រ ១៨ មាត្រា ១៨(៣)(ខ)]។

ការធានាអំពីឯករាជ្យភាព និងភាពអនាគតិ ដែលបានផ្តល់ដោយយុត្តាធិការជាតិ នៅពេលធ្វើការសម្រេចទៅលើភាពអាចទទួលយកបាននៃរឿងក្តី ដែលត្រូវបានជំនុំជម្រះដោយយុត្តាធិការជាតិ។ ការបកស្រាយនេះបាននាំឱ្យរដ្ឋខ្លះសង្កត់ធ្ងន់ថាគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវតែយល់ឃើញដោយយោងទៅលើស្មារតីនៃគោលការណ៍បំពេញបន្ថែម ឯរដ្ឋខ្លះទៀត បង្ហាញនូវការព្រួយបារម្ភអំពីការណ៍ដែលថា បទប្បញ្ញត្តិ*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលបានស្នើសុំនេះ អាចធ្វើឱ្យអន្តរាយដល់គោលការណ៍បំពេញបន្ថែមនេះ[៣០១]។ រដ្ឋជាភាគីដទៃទៀតដូចជា ប្រទេសបែលហ្ស៊ិក ប្រទេសបូស្នៀ និងហឺហ្ស៊ីហ្គូវីណា និងប្រទេសហ្វាំងឡង់ បានបញ្ចេញសំឡេងគាំទ្រដល់ការលើកលែងដែលបានស្នើសុំនេះ និងបានបង្ហាញទស្សនៈយល់ឃើញថា *ការមិនមានការកាត់ទោសពីរដង* "មិនគួរត្រូវយកមកបានប្រើប្រាស់ដើម្បីលាក់បាំងស្ថានភាពនានា ឬរារាំងមិនឱ្យតុលាការអនុវត្តយុត្តាធិការរបស់ខ្លួន នៅក្នុងរឿងក្តីដែលជនជាប់ចោទគឺជាកម្មវត្ថុនៃសវនាការសិប្បនិម្មិត នៅកម្រិតជាតិនោះទេ"[៣០២]។ ចុងបញ្ចប់ នៅឯសន្និបាតទីក្រុងរ៉ូម មានតែពាក្យថា "ដោយអនុលោមតាមបទដ្ឋាននីតិវិធី ទទួលស្គាល់ដោយច្បាប់អន្តរជាតិ" ត្រូវបានបន្ថែមទៅលើអ្វីដែលបានក្លាយជាមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ដោយមិនមានការបញ្ជាក់ឱ្យបានច្បាស់ថា ការព្រួយបារម្ភដែលបានលើកឡើងដោយរដ្ឋខ្លះទាក់ទងទៅនឹងគោលការណ៍នៃការបំពេញបន្ថែម បានឈានទៅដល់ការអនុម័តបទប្បញ្ញត្តិមួយ ដែលមានខ្លឹមសារងាកចេញពីបទប្បញ្ញត្តិមួយ ដែលមានចែងក្នុងលក្ខន្តិកៈ*តុលាការមិនអចិន្ត្រៃយ៍*។ តាមពិតទៅ ពាក្យពេចន៍ចុងក្រោយនៃបទប្បញ្ញត្តិ ដែលតម្រូវឱ្យតុលាការអនុវត្តយុត្តាធិការរបស់ខ្លួន ប្រសិនបើដំណើរការ

---

[៣០១] *ឧទាហរណ៍* សន្និបាតពេញអង្គ៖ សន្និបាតការទូតអង្គការសហប្រជាជាតិនៃតំណាងការទូតវិសាមញ្ញ និងពេញសមត្ថភាពអំពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី ១៥ ខែ មិថុនា ដល់ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ កំណត់ហេតុផ្លូវការ វ៉ុល II ឯកសារ អ.ស.ប លេខ A/CONF.183/SR.3 កថាខណ្ឌ ១៣ (ប្រទេសឥណ្ឌូណេស៊ី)។ កិច្ចប្រជុំរបស់គណៈកម្មាធិការ Whole, កំណត់ហេតុផ្លូវការ វ៉ុល II ឯកសារ អ .ស.ប លេខ A/CONF.183/C.1/SR.9, កថាខណ្ឌ ៣៧ (ប្រទេសឥណ្ឌូណេស៊ី) ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.11, កថាខណ្ឌ ២២ (ប្រទេសកាណាដា ជាអ្នកសម្របសម្រួល) កថាខណ្ឌ ៣២ (ប្រទេសអែលសាល់វ៉ាឌ័រ) កថាខណ្ឌ ៣៧ (ប្រទេសទួគី) កថាខណ្ឌ ៨ (ប្រទេសប៉ាគីស្ថាន) ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.30, កថាខណ្ឌ ៦៣ (ប្រទេសកូឌីវ័រ) ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.31, កថាខណ្ឌ ២២ (ប្រទេសអ៊ីរ៉ាក់) ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.35, កថាខណ្ឌ ៣៤ (ប្រទេសឥណ្ឌូណេស៊ី) កថាខណ្ឌ ៦៣ (ប្រទេសអេត្យូពី) កថាខណ្ឌ ៦៥ (ប្រទេសអ៊ីរ៉ាក់) និង ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.36 កថាខណ្ឌ ៤៣ (ប្រទេសកាមេរូន)។

[៣០២] ឯកសារ អ.ស.ប លេខ A/CONF.183/C.1/SR.11, កថាខណ្ឌ ២៨ (ប្រទេសបែលហ្ស៊ិក)។ *សូមមើលផងដែរ* មតិដែលផ្តល់ដោយប្រទេសហ្វាំងឡង់ ប្រទេសបូស្នៀ និងហឺហ្ស៊ីហ្គូវីណា ដែលបានត្រូវបានរាយការណ៍នៅក្នុងកថាខណ្ឌ ៤០ និង ៤៤។

នីតិវិធីដោយតុលាការជាតិ នៅក្នុងកាលៈទេសៈបែបនេះ "បានប្រព្រឹត្តទៅក្នុងលក្ខណៈមួយដែលមិនស្របនឹងគោលបំណង ដើម្បីនាំខ្លួនជនពាក់ព័ន្ធមកជំនុំជម្រះទោសនោះ" មិនបានលើកឡើងថា តម្រូវឱ្យមានគោលបំណងពីរផ្ទួ ដើម្បីធ្វើឱ្យកាន់តែលំបាកដល់ការផ្តន្ទាទោសជនជាប់ចោទនោះទេ។ លក្ខខណ្ឌតម្រូវនៃការរារាំងមិនឱ្យជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺបាននិយាយរួចមកហើយក្នុងមាត្រា ២០(៣)(ក)។ ហេតុដូច្នេះ ការបកស្រាយ កថាខណ្ឌ ២០(៣)(ខ) ដើម្បីដាក់បញ្ចូលលក្ខខណ្ឌនេះផងដែរនោះ គឺពិតជាធ្វើឱ្យបទប្បញ្ញត្តិនេះមានភាពលក្ខណៈជាន់គ្នា និងគ្មានសារប្រយោជន៍នោះឡើយ។

១៩៣. សេចក្តីអត្ថាធិប្បាយរបស់អ្នកសិក្សាស្រាវជ្រាវភាគច្រើន មិនបានញែកចេញពីគ្នារវាងបទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូម និងបទប្បញ្ញត្តិនៃតុលាការចំពោះកិច្ចនោះទេ នៅពេលនិយាយអំពីករណីលើកលែងជាក់លាក់ណាមួយនោះ ដោយពួកគាត់បានលើកឡើងថា *តុលាការមិនអចិន្ត្រៃយ៍* ពិតជាអនុវត្តយុត្តាធិការ នៅពេលដែលតុលាការ *មិនអចិន្ត្រៃយ៍*យល់ឃើញដំណើរការនីតិវិធីមុនៗដោយតុលាការជាតិ មិនបានប្រព្រឹត្តទៅដោយឯករាជ្យ និងអនាគតិស្របតាមបទដ្ឋាននីតិវិធីនោះទេ[៣០៣]។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង ("IACtHR") ក៏បានយោងទៅលក្ខន្តិកៈសម្រាប់តុលាការ *មិនអចិន្ត្រៃយ៍* និងលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីសន្និដ្ឋានថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចអនុវត្តនៅក្នុងកាលៈទេសៈបែបនេះបានទេ[៣០៤]។ ទោះបីជាអ្នកធ្វើអត្ថាធិប្បាយមួយចំនួនតូចយល់ឃើញថា បញ្ហានេះគឺជាបញ្ហាដែលអាចពិភាក្សាបាន[៣០៥] ហើយអ្នកធ្វើ

---

[៣០៣] ឧទាហរណ៍ សាស្ត្រាចារ្យ Cassese, ឆ្នាំ ២០០៣ ទំព័រ ៣២០(អង់គ្លេស) សាស្ត្រាចារ្យ Naqvi ទំព័រ ៣១៥ ដល់ ៣១៨ (អង់គ្លេស)។

[៣០៤] រឿងក្តីរវាង *Carpio-Nicolle និងអ្នកផ្សេងទៀត តទល់នឹង Guatemala* សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣១។ នៅក្នុងជើងទំព័រយោងលេខ ១៣៧ តុលាការ IACtHR ចង្អុលបង្ហាញប្រភពច្បាប់ដូចតទៅ៖ "លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារ អ.ស.ប A/CONF.183/9 (១៩៩៨) មាត្រា ២០។ លក្ខន្តិកៈតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ឯកសារ អ.ស.ប S/Res/955 (១៩៩៤) មាត្រា ៩ និងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឯកសារ អ.ស.ប S/Res/827 (១៩៩៣) មាត្រា ១០"។

[៣០៥] Van den Wyngaert និង Ongena ទំព័រ ៧២៥ (អង់គ្លេស) "តើមាត្រា ២០(៣)(ខ) មានន័យថា តុលាការនេះក៏អាចធ្វើអន្តរាគមន៍បានផងដែរឬយ៉ាងណា នៅក្នុងស្ថានភាពដែលជនជាប់ចោទ គឺជាជនរងគ្រោះនៃយុត្តិធម៌ប្រកាន់បក្សពួក?" Immi Tallgren និង Astrid Reisinger Coracini, *"មាត្រា ២០ គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ"* នៅក្នុងសៀវភៅ Otto Triffterer (ed.) *សេចក្តីអត្ថាធិប្បាយទៅលើលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ កំណត់សម្គាល់របស់*

អត្ថាធិប្បាយម្នាក់លើកឡើងថា មាត្រា ២០(៣) អនុវត្តតែក្នុងករណីមិនមានឯករាជ្យភាព ឬអនាគតិ នៅក្នុងដំណើរការនីតិវិធីដោយតុលាការជាតិ បានបង្កឱ្យកាន់តែលំបាកឡើងដល់ការផ្តន្ទាទោសចុងចោទ[៣០៦]ក៏ដោយ នោះជំហរចុងក្រោយនេះហាក់ដូចជាគ្រាន់តែជាបញ្ហាបន្ទាប់បន្សំតែប៉ុណ្ណោះ។

១៥៤. ការបកស្រាយមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម រួមជាមួយនឹងបទប្បញ្ញត្តិនៃលក្ខន្តិកៈ *តុលាការមិនអចិន្ត្រៃយ៍* គឺស្របគ្នានឹងគោលបំណងបង្កើតតុលាការ ICC រួមទាំង "ដើម្បីធានាឱ្យមានការគោរពជារៀងរហូត និងការពង្រឹងដល់យុត្តិធម៌អន្តរជាតិ"[៣០៧]។ វាស្របជាមួយនឹងទស្សនៈយល់ឃើញដែលបានលើកឡើងដោយស្ថាប័នសិទ្ធិមនុស្ស ជាពិសេស តុលាការ IACtHR ដែលថា ការលើកលែងចំពោះ*ការមិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[៣០៨] នៅក្នុងករណីដែលដំណើរការនីតិវិធីមុនៗ មិនបានប្រព្រឹត្តទៅដោយអនាគតិ និងឯករាជ្យ ដែលជាការចាំបាច់ដើម្បីធានាថា រដ្ឋទាំងឡាយត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដើម្បីផ្តល់សំណងប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ។

---

*អ្នកសង្កេតការណ៍ មួយមាត្រាម្តងៗ* បោះពុម្ពផ្សាយលើកទីពីរ ឆ្នាំ ២០០៨ ទំព័រ ៦៩៥ជើងទំព័រយោងលេខ ១៤៨ ("លទ្ធផលដូចគ្នាអាចសម្រេចបានដោយការបកស្រាយលក្ខន្តិកៈនេះ ដោយតុលាការ ICC")។

[៣០៦] Kevin Jon Heller (ស្រមោលនៃការបំពេញបន្ថែម "The Shadow Side of Complementarity")៖ អានុភាពនៃមាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមទៅលើបទដ្ឋាននីតិវិធីជាតិ"17 *Crim. L. F.* 255 (២០០៦) ត្រង់ទំព័រ ២៦១ ដល់ ២៦២ និង ២៦៣ (អង់គ្លេស)ជើងទំព័រយោងលេខ ២៦ (ហេតុដូច្នេះ ឃ្លាថា "នាំខ្លួនជនពាក់ព័ន្ធមកផ្តន្ទាទោស" ក្នុងមាត្រា ១៧(២)(គ) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងឃ្លាដូចគ្នាក្នុងមាត្រា ១៧(២)(ខ) "គឺមានន័យដូចគ្នានឹងគោលបំណងទទួលបានការផ្តន្ទាទោស") និងទំព័រ ២៦៨ ដល់ ២៦៩ (អង់គ្លេស) ("ការបកស្រាយប្រកបដោយហេតុផលនៃមាត្រា ២០ គឺវាមានមុខងារឆ្ពោះទៅរកទិសដៅតែមួយ។ តុលាការអាចជំនុំជម្រះសាជាថ្មីចំពោះចុងចោទដែលត្រូវបានផ្តន្ទាទោស ឬដោះលែងឱ្យរួចផុតពីការចោទប្រកាន់រួចទៅហើយ នៅក្នុងដំណើរការនីតិវិធីដោយតុលាការជាតិបាន តែក្នុងករណីដែលដំណើរការនីតិវិធីនោះ មិនមានឯករាជ្យ ឬអនាគតិ *ហើយ*កង្វះឯករាជ្យភាព ឬអនាគតិនេះ បានធ្វើឱ្យកាន់តែលំបាកឡើងដល់ការផ្តន្ទាទោសចុងចោទ"។

[៣០៧] លក្ខន្តិកៈទីក្រុងរ៉ូម បុព្វកថា កថាខណ្ឌ ១១។

[៣០៨] គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានចែងនៅក្នុងមាត្រា ៨(៤) នៃអនុសញ្ញាសិទ្ធិមនុស្សអាមេរិកាំងដែលចែងថា៖ "ជនជាប់ចោទដែលត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ដោយសាលក្រមបិទផ្លូវប្តឹងតវ៉ា មិនត្រូវប្រឈមមុខនឹងការកាត់សេចក្តីជាថ្មី ចំពោះអំពើដែលនោះទេ"។

១៥៥. ជាពិសេស តុលាការ IACtHR បានប្រើប្រាស់ពាក្យ [*អាជ្ញាអស់ជំនុំ* "ពិតប្រាកដ" ឬ "ក្លែងក្លាយ"[៣០៩] គឺសំដៅទៅលើសាលក្រមទាំងឡាយណាដែលត្រូវបានចេញ ក្នុងករណី "១) មានអន្តរាគមន៍របស់តុលាការដែលបានជំនុំជម្រះរឿងក្តីនេះ និងបានសម្រេចបដិសេធរឿងក្តី ឬដោះលែងជនដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស ឬច្បាប់អន្តរជាតិឱ្យរួចផុតពីការចោទប្រកាន់ ក្នុងបំណងការពារជនជាប់ចោទពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ២) ដំណើរការនីតិវិធីមិនបានប្រព្រឹត្តទៅដោយឯករាជ្យ ឬអនាគតិ ស្របតាមការធានានៃបទដ្ឋាននីតិវិធី ឬ ៣) មិនមានចេតនាពិតប្រាកដដើម្បីនាំអ្នកដែលទទួលខុសត្រូវនោះមកផ្តន្ទាទោស"[៣១០]]។ តាមការយល់ឃើញរបស់តុលាការនេះ "រដ្ឋមិនអាចសំអាងទៅលើសាលក្រមដែលបានសម្រេចនៅក្នុងដំណើរនីតិវិធីដែលមិនស្របនឹងបទដ្ឋានអនុសញ្ញាអាមេរិកាំង ដើម្បីឱ្យរួចផុតពីកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសបាននោះទេ។ វិធានជាមូលដ្ឋានស្តីពីការបកស្រាយ ដែលមានចែងនៅក្នុងមាត្រា ២៩ នៃអនុសញ្ញានេះ បានបំបាត់ចោលនូវការមន្ទិលសង្ស័យទាំងឡាយទាក់ទងនឹងបញ្ហានេះ"[៣១១]។ ក្នុងកាលៈទេសៈបែបនេះ "សម្រេកនៃយុត្តិធម៌ សិទ្ធិរបស់ជនរងគ្រោះ ស្មារតី និងពាក្យពេចន៍នៃអនុសញ្ញាអាមេរិកាំង ត្រូវយកមកជំនួសការការពារគោលការណ៍ *គ្មានការកាត់ទោស*

---

[៣០៩] តុលាការ IACtHR, *រឿងក្តីរវាង Almonacid-Arellano និងអ្នកផ្សេងទៀត តទល់នឹង ប្រទេសឈីលី* សាលក្រម (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦ ("សាលក្រម *Amonacid-Arellano*") កថាខណ្ឌ ១៥៤។ *សូមមើលផងដែរ រឿងក្តីរវាង La Cantuta តទល់នឹង ប្រទេសប៉េរូ* សាលក្រម (អង្គសេចក្តី សំណង និងតម្លៃ) ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៥៣។ ("សាលក្រមដែលបានចេញនៅក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ គ្រាន់តែផ្តល់សំអាងហេតុតាមបែបសន្មត ឬសំអាងហេតុក្លែងក្លាយចំពោះការកាត់ទោសពីរដង")។ *សាលក្រម* Carpio-Nicolle កថាខណ្ឌ ១៣១ (ដែលតុលាការ IACtHR បានបង្កើតពាក្យថា "*អាជ្ញាអស់ជំនុំក្លែងក្លាយ*" (fraudulent *res judicata*) ដែលជាលទ្ធផលបានមកពីសវនាការមិនគោរពបទដ្ឋាននីតិវិធី ឬនៅពេលដែលចៅក្រមមិនបានបំពេញតួនាទីដោយឯករាជ្យ និងអនាគតិនោះ")។

[៣១០] តុលាការ IACtHR, សាលក្រម *Almonacid-Arellano* កថាខណ្ឌ ១៥៤។

[៣១១] តុលាការ IACtHR សាលក្រម *Carpio-Nicolle* កថាខណ្ឌ ១៣២។ *សូមមើលផងដែរ* រឿងក្តីរវាង *Gutiérrez-Soler តទល់នឹង ប្រទេសកូឡុំប៊ី,* សាលក្រម (អង្គសេចក្តី សំណង និងតម្លៃ) ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ៩៨។ តាមរយៈតុលាការ IACtHR *សូមមើល៖ Santos Mendivelso Coconubo* IACHR របាយការណ៍លេខ 62/99 សំណុំសរឿងលេខ 11.540 ប្រទេសកូឡុំប៊ី ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤ ដល់ ៥៥ និង *Jose Alexis* Fuentes Guerrero និងអ្នកផ្សេងទៀត IACHR របាយការណ៍លេខ 61/99 សំណុំសរឿងលេខ 11.519 ប្រទេសកូឡុំប៊ី ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦២ ដល់ ៦៣ "ដោយសារគោលការណ៍នីត្យានុកូលភាព ត្រូវបានចែងក្នុងអនុសញ្ញាអាមេរិកាំង នោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ មិនគួរត្រូវបានយកមកសំអាងដើម្បីគ្របដណ្តប់ទៅលើការទទួលបាន ឬការអនុវត្តសិទ្ធិដទៃទៀតនោះទេ ដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញាអាមេរិកាំង [មាត្រា ២៩(ក)] ក្នុងករណីនេះ គឺសិទ្ធិទទួលបានយុត្តិធម៌"។

*ពីរដងចំពោះបទល្មើសតែមួយ*"[៣១២] និងត្រូវបានពិចារណាថា សាលក្រមលើកដំបូងមិនមានអានុភាពគតិយុត្តិ សម្រាប់គោលបំណងនៃការអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះទេ។ ទាក់ទងនឹងចំណុចនេះ ក្នុងរឿងក្តី *Gutiérrez-Soler តទល់នឹង ប្រទេសកូឡុំប៊ី*[៣១៣] ចៅក្រម Sergio Garcia-Ramirez បានផ្តល់នូវការបកស្រាយដូចខាងក្រោម នូវឃ្លាថា (ការកាត់ទោសពីរដងដោយគ្រាន់តែបំភាន់ភ្នែក "sham double jeopardy") ដែលជាឃ្លាមួយត្រូវបានតុលាការ IACtHR យកមកប្រើប្រាស់ និងអានុភាពរបស់វា៖

> ឃ្លានេះសង្កត់ធ្ងន់ទៅលើពាក្យ "ការក្លែងបន្លំ" ថាបានចាក់ឫសនៅក្នុងសាលក្រមខ្លះ ដែលជាលទ្ធផលនៃឧបាយកលទុច្ចរិតរបស់អាជ្ញាធរដែលស៊ើបអង្កេតទៅលើអង្គហេតុ ការចោទប្រកាន់ និងការចេញសាលក្រម ទោះជាលទ្ធផលនៃការកាត់សេចក្តីនោះ ជាការដោះលែងឱ្យរួចផុតពីការចោទប្រកាន់ *ឬផ្តន្ទាទោស*យ៉ាងណាក្តី។ ដំណើរការក្តីនេះ គឺជាដំណើរ "ទំនងដូចជា" ដំណើរការមែនទែន ហើយសាលក្រមនោះ គឺពិតជាបម្រើការរៀបចំជាក់លាក់ណាមួយ ជាជាងបម្រើផលប្រយោជន៍យុត្តិធម៌ទៅវិញទេ។
>
> (...)
>
> ដំណើរការនីតិវិធីដែលមានវិការៈបែបនេះ មិនមែនជាដំណើរការនីតិវិធីពិតប្រាកដនោះទេ ហើយសាលក្រមដែលបានចេញបែបនេះ ក៏មិនមែនជាសាលក្រមពិតប្រាកដនោះដែរ។ ប្រសិនបើសាលក្រមបែបនេះមិនត្រូវបានទទួលយកទេ នោះសវនាការបន្ទាប់ទៅលើអង្គហេតុតែមួយ និងប្រឆាំងចំពោះមនុស្សដដែល មិនត្រូវចាត់ទុកថា ជាសវនាការលើកទីពីរនោះទេ ហើយក៏មិនត្រូវចាត់ទុកថា មិនគោរពគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះដែរ[៣១៤]។

---

[៣១២] តុលាការ IACtHR, រឿងក្តី *Almonacid-Arellano* កថាខណ្ឌ ១៥៤។

[៣១៣] តុលាការ IACtHR, រឿងក្តីរវាង *Gutiérrez-Soler* តទល់នឹង ប្រទេសកូឡុំប៊ី សាលក្រម (អង្គសេចក្តី សំណង និងតម្លៃ) ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥ (សាលក្រម *Gutiérrez-Soler*)។

[៣១៤] តុលាការ IACtHR, សាលក្រម *Gutiérrez-Soler* កថាខណ្ឌ ១៧ និងកថាខណ្ឌ ២១ (ត្រូវបានបញ្ជាក់បន្ថែម)។ *សូមមើល*ផងដែរ តុលាការ IACtHR, រឿងក្តីរវាង *La Cantuta* តទល់នឹង ប្រទេសប៉េរូ (អង្គសេចក្តី សំណង និងតម្លៃ) ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣០(១) និងកថាខណ្ឌ ១៥៣ (លក្ខខណ្ឌតម្រូវនៃការដោះលែងឱ្យរួចផុតពីការចោទប្រកាន់លើកមុនមិនត្រូវបានបំពេញនោះទេ ដោយសារសាលក្រមនោះមិនមានអានុភាពគតិយុត្តិ ដើម្បីតទល់នឹងការជំទាស់ជាចំហទៅនឹងកាតព្វកិច្ចអន្តរជាតិបានទេ" ហើយយោបល់ដាច់ដោយឡែករបស់ចៅក្រម Sergio Garcia-Ramirez កថាខណ្ឌ ១១ "ដោយការមិនគោរពតាមបទដ្ឋាននីតិវិធី នោះមិនមានសាលក្រមពិតប្រាកដ *មិនមានអាជ្ញាអស់ជំនុំទេ* ហើយក៏មិនមានឱកាសអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះដែរ"។

១៥៦. នៅក្នុងបរិបទនៃអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បទប្បញ្ញត្តិជាក់លាក់មួយត្រូវបានអនុម័តដើម្បីកំណត់ថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* "មិនត្រូវរារាំងដល់ការបើកសំណុំរឿងឡើងវិញ ដោយអនុលោមតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋពាក់ព័ន្ធនោះទេ (...) ប្រសិនបើមានកំហុសជាសារវ័ន្តនៅក្នុងដំណើរការនីតិវិធីកាលពីលើកមុន ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃរឿងក្តីនោះ"[៣១៥]។ របាយការណ៍បកស្រាយអំពីពិធីសារលេខ ៧ ពន្យល់ថា "ករណីមានកំហុសជាសារវ័ន្ត នៅក្នុងដំណើរការនីតិវិធី ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃរឿងក្តីនោះ ទោះជាផ្តល់ប្រយោជន៍ដល់បុគ្គលនោះ ឬធ្វើឱ្យខូចប្រយោជន៍បុគ្គលនោះក្តី។ (មានបញ្ជាក់បន្ថែម)"[៣១៦]។

១៥៧. អង្គបុរេជំនុំជម្រះយល់ឃើញថា បទដ្ឋាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិផ្តល់ការណែនាំសំខាន់ៗថា តុលាការអន្តរជាតិ ឬតុលាការដែលមានចរិតអន្តរជាតិ មិនត្រូវអនុវត្តយុត្តាធិការពាក់ព័ន្ធទៅនឹងបុគ្គលដែលត្រូវបានកាត់សេចក្តីរួចហើយ ចំពោះអំពើដដែល ដោយអាជ្ញាធរជាតិនោះទេ លើកលែងតែត្រូវបានរកឃើញថា ដំណើរការនីតិវិធីដោយតុលាការជាតិមិនត្រូវបានដំណើរការដោយឯករាជ្យ ឬអនាគតិ ស្របតាមបទដ្ឋាននីតិវិធីទេនោះ។ អ.វ.ត.ក កំពុងស្ថិតនៅក្នុងជំហរដូចគ្នានឹងតុលាការទាំងនេះដែរ ហើយដោយពិចារណាឃើញថា សំអាងហេតុដែលចង្អុលបង្ហាញគោលការណ៍ដូចបានលើកឡើងខាងលើ ក៏ពាក់ព័ន្ធនឹងបរិបទនៃដំណើរការនីតិវិធីរបស់ខ្លួននោះ អ.វ.ត.ក នឹងអនុវត្តបទដ្ឋានដូចគ្នានេះដែរ ដើម្បីពិចារណាទៅលើបញ្ហានៅចំពោះមុខនេះ។

១៥៨. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា លើកលែងតែមានកំហុសជាសារវ័ន្តនៅក្នុងដំណើរការនីតិវិធីដោយតុលាការជាតិ នោះទើប អ.វ.ត.ក អាចអនុវត្តយុត្តាធិការនេះបាន។

១៥៩. នៅក្នុងរបាយការណ៍របស់គាត់ផ្ញើជូនក្រុមប្រឹក្សាសន្តិសុខ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានលើកឡើងថា មាត្រា ១០(២)(ខ) នៃលក្ខន្តិកៈតុលាការ ICTY អាចយកមកអនុវត្តបាននៅពេលដែល "អនាគតិភាព ឯករាជ្យភាព ឬមធ្យោបាយប្រកបដោយប្រសិទ្ធភាពនៃការជំនុំ

---

[៣១៥] ពិធីសារលេខ ៧ ចំពោះកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស កថាខណ្ឌ ៤(២)។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានឧបម្រុង សេចក្តីប្រកាស ឬការជាប់ពាក់ព័ន្ធផងទៃទៀត ទៅនឹងមាត្រា ៤(២) នៃពិធីសារលេខ ៧ នោះទេ។

[៣១៦] របាយការណ៍ពន្យល់អំពីពិធីសារលេខ ៧ ចំពោះ ECHR កថាខណ្ឌ ៣០ (មានបញ្ជាក់បន្ថែម)។

ជម្រះសេចក្តីមិនត្រូវបានធានានៅក្នុងដំណើរការនីតិវិធី នៅចំពោះមុខតុលាការជាតិនោះទេ[៣១៧]។ រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Tadic* ចៅក្រម Nieto-Navia បានសង្ខេបបទប្បញ្ញត្តិនេះថា "នីតិវិធីតុលាការជាតិ មិនស្របទៅនឹងគោលការណ៍ជាសារវ័ន្តនៃច្បាប់ព្រហ្មទណ្ឌនោះទេ"[៣១៨]។ លោក Cassese ក៏បានពិចារណាផងដែរថា ការលើកលែងនេះអនុវត្តនៅពេលដែល "តុលាការមិនបានអនុវត្តឱ្យស្របទាំងស្រុងទៅនឹងការធានាជាសារវ័ន្ត នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ឬមិនបានបំពេញមុខងារដោយឯករាជ្យ ឬដោយអនាគតិ"[៣១៩]។

១៦០. តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ពិចារណាថា នៅក្នុងបរិបទនៃមាត្រា ៤ នៃពិធីសារទី ៧ កំហុសជាសារវ័ន្តនៅក្នុងដំណើរការនីតិវិធី គឺជាប់ទាក់ទងទៅនឹង "កំហុសលើយុត្តាធិការ ឬការរំលោភធ្ងន់ធ្ងរទៅលើនីតិវិធីតុលាការ ការបំពានអំណាច និងកំហុសជាក់ស្តែងនៅក្នុងការអនុវត្តច្បាប់សារធាតុ ឬមូលហេតុសំខាន់ៗ ដែលកើតចេញពីផលប្រយោជន៍នៃយុត្តិធម៌"។ តាមការយល់ឃើញរបស់តុលាការ "ការគ្រាន់តែពិចារណាថា ការស៊ើបអង្កេតទៅលើរឿងក្តីរបស់ដើមបណ្តឹងគឺ "មិនបានធ្វើឡើងឱ្យបានគ្រប់ជ្រុងជ្រោយ និងធ្វើឡើងតែទៅលើភាគីម្ខាង" ឬនាំឱ្យមានការ "សម្រេចរួចផុតពីការចោទប្រកាន់ "ទាំងខុស" គឺមិនគ្រប់គ្រាន់នោះឡើយ[៣២០]។

---

[៣១៧] របាយការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣) ឯកសារ អ.ស.ប លេខ S/25704 (ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣) កថាខណ្ឌ ៦៦(ខ)។ ក្រោយមក ក្រុមប្រឹក្សាសន្តិសុខបានសម្រេចតាមរបាយការណ៍របស់លោកអគ្គលេខាធិការ និងបានអនុម័តសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការ ICTY៖ សេចក្តីសម្រេចលេខ ៨២៧ (១៩៩៣) ឯកសារ អ.ស.ប លេខ S/Res/827(1993) (ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣)។

[៣១៨] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Tadic* សំណុំរឿងលេខ IT-94-1-A សាលដីកា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ សេចក្តីប្រកាសរបស់ចៅក្រម Nieto-Navia កថាខណ្ឌ ២។

[៣១៩] សាស្ត្រាចារ្យ Cassese ឆ្នាំ ២០០៣ កថាខណ្ឌ ៣២១។

[៣២០] តុលាការ ECtHR រឿងក្តីរវាង *Radchikov តទល់នឹង ប្រទេសរុស្ស៊ី* សំណុំរឿងលេខ ៦៥៥៨២/០១ សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៨។ ស្រដៀងគ្នានេះដែរ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានលើកឡើងនៅក្នុងរឿងក្តីរវាង *Chistyakov តទល់នឹងប្រទេសរុស្ស៊ី* ថា "ការដែលគ្រាន់តែមានការពិចារណាថា សាលាដំបូង ឬសាលាឧទ្ធរណ៍មិនបានគោរពទៅតាមសេចក្តីណែនាំពាក់ព័ន្ធទាំងអស់ ដោយមិនមានកំហុសលើយុត្តាធិការ ឬការរំលោភធ្ងន់ធ្ងរទៅលើនីតិវិធីតុលាការ ការបំពានអំណាច ឬមូលហេតុសំខាន់ៗដទៃទៀត ដែលកើតចេញពីផលប្រយោជន៍នៃយុត្តិធម៌ទេ មិនអាចបញ្ជាក់ថាមានកំហុសជាសារវ័ន្តនៅក្នុងដំណើរការនីតិវិធីលើកមុនបានទេ (រឿងក្តីរវាង *Radchikov តទល់នឹងប្រទេសរុស្ស៊ី* សំណុំរឿងលេខ ១៥៣៣៦/០២ សេចក្តីសម្រេច ចុះថ្ងៃទី ៩ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ២៦)។

<u>**ការជំនុំជម្រះក្តីឆ្នាំ ១៩៧៩**</u>

១៦១. ទាក់ទងនឹងបទដ្ឋាននីតិវិធី អង្គបុរេជំនុំជម្រះពិនិត្យមើលថាតើការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ បានប្រព្រឹត្តទៅដោយឯករាជ្យ និងអនាគតិដែរ ឬយ៉ាងណានោះ។

១៦២. កាលប្បវត្តិនៃព្រឹត្តិការណ៍ជុំវិញសវនាការឆ្នាំ ១៩៧៩ *ដោយកំបាំងមុខ* អៀង សារី អាចត្រូវបានសង្ខេបដូចខាងក្រោមនេះ៖

ក. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៩ លោក ហេង សំរិនត្រូវបានតែងតាំងជាប្រធានរដ្ឋនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាថ្មី (PRK)[៣២១]។

ខ. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩ ក្រឹត្យច្បាប់លេខ ១ ដែលមានឈ្មោះថា "ការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះបន ប៉ុល ពត និង អៀង សារី ចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ត្រូវបានចុះហត្ថលេខាដោយលោក ហេង សំរិន ប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា[៣២២]។

គ. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩ លោក កែវ ចិន្តា (រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងព័ត៌មាន) ត្រូវបានចាត់តាំងជាប្រធានតុលាការ ហើយលោក ឈឹម ចាន់តារា ជាប្រធានតុលាការបម្រុង[៣២៣]។

ឃ. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩ តំណាងប្រជាជនចំនួន ១០ រូប និងតំណាងបម្រុងចំនួន ៤ រូប ត្រូវបានតែងតាំងជាសមាជិកនៃតុលាការប្រជាជនបដិវត្តន៍[៣២៤]។

---

[៣២១] Evan Gottesman *ប្រទេសកម្ពុជាក្រោយពីរបបខ្មែរក្រហម នៅខាងក្នុងនយោបាយកសាងជាតិ* ទីក្រុងបាងកក សៀវភៅរបស់ Silkworm ២០០៤ ("Gottesman") ទំព័រ ១១ (អង់គ្លេស)។

[៣២២] ក្រឹត្យច្បាប់លេខ ១ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះពួក ប៉ុល ពត និង អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅ Howard J. De Nike, John Quigley និង Kenneth J. Robinson *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ឯកសារបានមកពីការជំនុំជម្រះ ប៉ុល ពត និង អៀង សារី* បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Pennsylvania ឆ្នាំ ២០០០ ទំព័រ ៤៥ (អង់គ្លេស)។ ("*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា*")។

[៣២៣] ក្រឹត្យច្បាប់លេខ ៤ ស្តីពីការតែងតាំងប្រធានតុលាការ និងប្រធានតុលាការបម្រុង ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៤៩ (អង់គ្លេស)។

ង. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៧៩ លោក ម៉ាត់ លី ដែលជារដ្ឋអាជ្ញាបានបើកការស៊ើបអង្កេតប្រឆាំងទៅលើពួក ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍[៣២៥]។

ច. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៧៩ រដ្ឋអាជ្ញាបានចេញដីកាបង្គាប់ឲ្យស្វែងរកចាប់ខ្លួន ប៉ុល ពត និង អៀង សារី[៣២៦]។

ឆ. នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៩ រដ្ឋអាជ្ញាបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍[៣២៧]។

ជ. នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៩ នីតិវិធីជំនុំជម្រះត្រូវបានបង្កើតឡើងដោយប្រធានតុលាការ[៣២៨]។

ឈ. នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៧៩ ប្រធានអង្គជំនុំជម្រះបានចេញដីកាបង្គាប់ឲ្យបើកសវនាការ[៣២៩]។

---

[៣២៤] ក្រឹត្យច្បាប់លេខ ២៥ ស្ដីពីការតែងតាំងសមាជិកតុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥០ ដល់ ៥១ (អង់គ្លេស)។

[៣២៥] សេចក្ដីសម្រេចលេខ ២ រដ្ឋអាជ្ញាអមតុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ។ សេចក្ដីសម្រេចបើកការស៊ើបអង្កេត។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥១ ដល់ ៥២ (អង់គ្លេស)។

[៣២៦] សេចក្ដីសម្រេចលេខ ៣៖ រដ្ឋអាជ្ញាអមតុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ។ ដីកាបង្គាប់ឲ្យស្វែងរកចាប់ខ្លួន ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥២ (អង់គ្លេស)។

[៣២៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយរដ្ឋអាជ្ញាអមតុលាការប្រជាជនបដិវត្តន៍ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៤៦៣ ដល់ ៤៨៨(អង់គ្លេស)។

[៣២៨] សេចក្ដីសម្រេចអំពីនីតិវិធីជំនុំជម្រះ នៅក្នុងសម័យប្រជុំអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់បន ប៉ុល ពត អៀង សារី ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅ Howard J. De Nike, John Quigley និង Kenneth J. Robinson *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* Pennsylvania បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Pennsylvania ឆ្នាំ ២000 ទំព័រ ៥៣ ដល់ ៥៦ (អង់គ្លេស)។

[៣២៩] ដីកាបង្គាប់លេខ ១៖ ប្រធានតុលាការ ដីកាបង្គាប់ឲ្យបើកសវនាការ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នា ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅត្រង់ផ្នែក *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥៩ (អង់គ្លេស)។

00661590



ញ. នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៧៩ លោក ឌិត មន្ទីរ និងលោក យស ប៉ោ ត្រូវបានប្រធានតុលាការប្រជាជនបដិវត្តន៍ចាត់តាំងជាមេធាវីការពារក្តី[៣៣០]។ ដីកាបង្គាប់ឱ្យ ប៉ុល ពត និង អៀង សារី ចូលខ្លួនមកចំពោះមុខសវនាការ ក៏ត្រូវបានចេញដែរ[៣៣១]។

ដ. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៩ បញ្ជីឈ្មោះសាក្សីចំនួន ៥៤ នាក់ (មកពីបណ្តាខេត្តចំនួនបួន) ដែលត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ ក៏ត្រូវបានរៀបចំឡើងផងដែរ[៣៣២]។

ឋ. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៧៩ ដីកាបង្គាប់ឱ្យ ប៉ុល ពត និង អៀង សារី ចូលខ្លួនមកចំពោះមុខសវនាការក៏ត្រូវបានចាប់ផ្តើមផ្សព្វផ្សាយក្នុងរយៈពេលប្រាំមួយថ្ងៃ នៅតាមវិទ្យុជាតិ កម្ពុជា[៣៣៣]។

ឌ. ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ ដំណើរការនីតិវិធីជំនុំជម្រះបានចាប់ផ្តើមពីម៉ោង ៧.៣០ នាទីព្រឹក ដល់ ១១.៣០ នាទីព្រឹក និងពីម៉ោង ២.០០ រសៀល ដល់ម៉ោង ៥.៣០ នាទីល្ងាច[៣៣៤]។ កម្មវិធីជំនុំជម្រះត្រូវបានត្រៀមរៀបចំសម្រាប់រយៈពេលប្រាំថ្ងៃ រួមទាំងការប្រកាសសាលក្រមនៅរសៀលនៃថ្ងៃចុងក្រោយ ក្រោយពីការបញ្ចប់សេចក្តីសន្និដ្ឋានសួរដេញដោលភ្លាមៗ ដែលបានធ្វើឡើងនៅពេលព្រឹកនៃថ្ងៃចុងក្រោយនេះ។ កំណត់ហេតុ

---

[៣៣០] សេចក្តីសម្រេចលេខ ២៥៖ ប្រធានតុលាការ ការចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅត្រង់ផ្នែក*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥៩ ដល់ ៦០ (អង់គ្លេស)។

[៣៣១] សេចក្តីសម្រេចលេខ ៣៖ ប្រធានតុលាការ ដីកាបង្គាប់ឱ្យ (អៀង សារី) ចូលខ្លួនមកចំពោះមុខសវនាការ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅត្រង់ផ្នែក*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៦៥ (អង់គ្លេស)។

[៣៣២] បញ្ជីរាយនាមសាក្សីដែលត្រូវចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅត្រង់ផ្នែក*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៦៣ ដល់ ៦៤ (អង់គ្លេស)។

[៣៣៣] អាជ្ញាសាលា កំណត់ហេតុនៃការជូនដំណឹងអំពីដីកាបង្គាប់ឱ្យជនសង្ស័យឈ្មោះ អៀង សារី ដែលរត់គេចខ្លួន ចូលខ្លួនមកក្នុងសវនាការ ដែលចុះហត្ថលេខាដោយ ហ៊ុល សំអុល។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញក្នុងសៀវភៅ *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៦៣ ដល់ ៦៦ (អង់គ្លេស)។

[៣៣៤] កម្មវិធីជំនុំជម្រះរបស់តុលាការប្រជាជនបដិវត្តន៍ នៅក្នុងដំណាក់កាលជំនុំជម្រះនាពេលបច្ចុប្បន្នរបស់ខ្លួន។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញក្នុងសៀវភៅ*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៦៧ ដល់ ៦៨ (អង់គ្លេស) ("កម្មវិធីសវនាការ")។

ស្តាប់ចម្លើយសាក្សី និងការអានរបាយការណ៍ស៊ើបអង្កេត គឺជាផ្នែកមួយនៃ កម្មវិធីជំនុំជម្រះ រួមទាំងសេចក្តីសន្និដ្ឋានបិទរបស់តំណាងភាគីនីមួយៗ។ ការទទួលបដិសណ្ឋារកិច្ច ពិធីជប់លៀងសម្រាប់ភ្ញៀវបរទេស និងដំណើរទស្សនៈកិច្ចទៅកាន់ខេត្តសៀមរាប ក៏ត្រូវដាក់បញ្ចូលក្នុងកម្មវិធីជំនុំជម្រះនេះផងដែរ។

**<u>តុលាការឯករាជ្យ និងអនាគតិ</u>**

១៦៣. ការធានាពីតុលាការមួយដែលឯករាជ្យតម្រូវថា ចៅក្រមទាំងអស់មិនត្រូវទទួលរងការគាបសង្កត់ និងការជ្រៀតជ្រែកពីខាងក្រៅឡើយ[៣៣៥]។ ជាពិសេស ការធានានេះត្រូវបានគេយល់ជាទូទៅថា មានលក្ខខណ្ឌតម្រូវដូចខាងក្រោម ដូចដែលបានបង្ហាញដោយគណៈកម្មាធិការសិទ្ធិមនុស្សនៅក្នុងការកត់សម្គាល់លេខ ៣២ របស់ខ្លួន ដែលមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖

> ជាពិសេស លក្ខខណ្ឌតម្រូវនៃឯករាជ្យភាពនេះ គឺសំដៅទៅលើនីតិវិធី និងលក្ខណៈសម្បត្តិសម្រាប់ការតែងតាំងចៅក្រម ព្រមទាំងការធានាទាំងឡាយទាក់ទងនឹងសន្តិសុខនៃការកាន់កាប់មុខតំណែងរបស់ពួកគាត់ រហូតឈានដល់អាយុចូលនិវត្តន៍ជាកំណត់ ឬរហូតដល់ផុតអាណត្តិកាន់មុខតំណែងរបស់ពួកគាត់ រួមទាំងលក្ខខណ្ឌនានាដែលគ្របដណ្តប់ទៅលើការដំឡើងតួនាទី ការផ្ទេរ ការព្យួរ និងការបញ្ឈប់ពួកគាត់ពីមុខងារ និង*ឯករាជ្យភាពពិតៗរបស់តុលាការចេញពីការជ្រៀតជ្រែកខាងនយោបាយដោយស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ*។ [...] *ក្នុងករណីដែលមុខងារ និងសមត្ថកិច្ចរបស់ស្ថាប័នតុលាការ និងស្ថាប័ននីតិប្រតិបត្តិមិនបានចែងច្បាស់លាស់ទេ ឬក្នុងករណីដែលស្ថាប័ននីតិប្រតិបត្តិមិនអាចគ្រប់គ្រង ឬដឹកនាំបានទេ នោះស្ថាប័នតុលាការមានវិសមតិភាពជាមួយនឹងសញ្ញាណ នៃតុលាការមួយដែលឯករាជ្យហើយ*[៣៣៦]។

---

[៣៣៥] *សូមមើល*រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Kanyabashi* សំណុំរឿងលេខ ICTR-96-15-A "សេចក្តីសម្រេចទៅលើសារណារបស់មេធាវីការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង I" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ១៩៩៩ យោបល់រួម និងយោបល់ដាច់ដោយឡែករបស់ចៅក្រម MacDonald និងចៅក្រម Vohrah កថាខណ្ឌ ៣៥។ រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Barayagwiza* សំណុំរឿងលេខ ICTR-97-19-AR72 "សេចក្តីសម្រេចទៅលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យមានការពិនិត្យ និងពិចារណាឡើងវិញ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២000 សេចក្តីប្រកាសរបស់ចៅក្រម Rafael Nieto-Navia កថាខណ្ឌ ៩ កថាខណ្ឌ ១០ រហូតដល់កថាខណ្ឌ ១៤ ។

[៣៣៦] សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ កថាខណ្ឌ ១៩ (មានបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តីរវាង *Oló Bahamonde* តទល់នឹង *Equatorial Guinea* លិខិតឆ្លើយឆ្លងលេខ ៤៦៨/១៩៩១ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ

១៦៤. ទាក់ទងទៅនឹងការធានាអំពីភាពអនាគតិ យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងតុលាការអន្តរជាតិនានា បានលើកឡើងស្របគ្នាថា លក្ខខណ្ឌនៃភាពអនាគតិត្រូវបានរំលោភ ប្រសិនចៅក្រមពិតជាលម្អៀង ឬទំនងជាមានការបង្ហាញឲ្យឃើញថា មានភាពលម្អៀងមែននោះ។ ការទំនងជាមានការបង្ហាញឲ្យឃើញថាមានភាពលម្អៀង អាចត្រូវបានរកឃើញ ប្រសិនបើ "(ក) ចៅក្រមណាម្នាក់ជាភាគីមួយនៃរឿងក្តីនោះ ឬមានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬខាងទ្រព្យសម្បត្តិ ដែលបានមកពីលទ្ធផលនៃរឿងក្តីនោះ ឬប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រមណាម្នាក់ នឹងនាំឲ្យមានការគាំទ្រដល់មូលហេតុណាមួយ ដែលចៅក្រមរូបនោះមានការពាក់ព័ន្ធ ឬ(ខ) កាលៈទេសៈនានាដែលអាចនាំអ្នកសង្កេតការណ៍ប្រកបដោយហេតុផល ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ ជឿជាក់ប្រកបដោយហេតុផលថា មានភាពលម្អៀងពិតប្រាកដមែន"។ នៅក្នុងលក្ខណៈវិនិច្ឆ័យនេះ អ្នកសង្កេតការណ៍ប្រកបដោយហេតុផល "ត្រូវតែជាបុគ្គលម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ និងមានការយល់ដឹងនូវគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ដែលបង្កើតបានជាផ្នែកមួយនៃប្រវត្តិសាវតា ហើយក៏បានជួយវាយតម្លៃដល់ការណ៍ដែលថា ភាពអនាគតិ

---

១៩៩៣ កថាខណ្ឌ ៩.៤ (ករណីដែលមុខងារ និងសមត្ថកិច្ចរបស់តុលាការ និងស្ថាប័ននីតិប្រតិបត្តិ មិនត្រូវបានញែកចេញពីគ្នាឲ្យបានច្បាស់លាស់ ឬក្នុងករណីដែលស្ថាប័ននីតិប្រតិបត្តិមិនអាចមានលទ្ធភាពគ្រប់គ្រងបាន នោះស្ថាប័នតុលាការមានវិសមិតភាពជាមួយនឹងគោលការណ៍នៃតុលាការឯករាជ្យហើយ)។ *គោលការណ៍ជាមូលដ្ឋាននៃឯករាជ្យភាពតុលាការ* ដែលបានអនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទីប្រាំពីរ (៧) ស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តចំពោះជនល្មើស ដែលបានប្រារព្ធធ្វើនៅឯទីក្រុង Milan ពីថ្ងៃទី ២៦ ខែ សីហា ដល់ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៨៥ និងបានយល់ព្រមដោយសេចក្តីសម្រេចមហាសន្និបាត អ.ស.ប លេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៨៥។ រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Delalic* សំណុំរឿងលេខ IT-96-21-A "សាលក្រម" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៦៨៩ "*ការបែងចែកអំណាចដាច់ពីគ្នា* [...] សារៈសំខាន់ជាសារវ័ន្តនៃឯករាជ្យភាពរបស់តុលាការត្រូវបានលើកយកមកបញ្ជាក់នៅក្នុងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នេះ។ យុត្តិសាស្ត្រនេះក៏បានទទួលស្គាល់ផងដែរថា ជាទូទៅ គោលការណ៍ស្តីពីឯករាជ្យភាពតុលាការនៅក្នុងប្រព័ន្ធច្បាប់ជាតិ និងប្រព័ន្ធច្បាប់អន្តរជាតិ តម្រូវថា បុគ្គល ឬស្ថាប័នទាំងឡាយដែលអនុវត្តអំណាចតុលាការ មិនត្រូវអនុវត្តអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិ ឬនីតិបញ្ញត្តិផងដែរនោះទេ"។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស រឿងក្តីរវាង *Incal* តទល់នឹងប្រទេសទួគី (៤១/១៩៩៧/៨២៥/១០៣១) សាលក្រម ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៥ "យោងតាមគោលបំណងនៃមាត្រា ៦.១ តុលាការបានលើកឡើងសាជាថ្មីថា ដើម្បីអាចឲ្យពិចារណាបានថាតើតុលាការមួយមាន "ឯករាជ្យភាព" ដែរឬយ៉ាងអត់ *នោះនៅក្នុងចំណោមបញ្ហាជាច្រើនទៀត* គេត្រូវពិចារណាទៅលើរបៀបតែងតាំងសមាជិករបស់តុលាការនោះ និងអាណត្តិការងាររបស់ពួកគេ អត្ថិភាពនៃការធានាមិនឲ្យមានការគាបសង្កត់ពីខាងក្រៅ និងបញ្ហាថាតើតុលាការនោះបង្ហាញឲ្យឃើញថាមានឯករាជ្យដែរឬអត់នោះ"។

គឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចជាច្រើន ដែលចៅក្រមគ្រប់រូបសច្ចាប្រកាន់ឱ្យបានខ្ជាប់ខ្ជួន"[៣៣៧]។

១៦៥. តុលាការប្រជាជនបដិវត្តន៍ ត្រូវបានបង្កើតឡើងដោយស្ថាប័ននីតិប្រតិបត្តិ គឺទីប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា[៣៣៨] មិនមែនបង្កើតឡើងដោយច្បាប់ដែលបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិរបស់រដ្ឋាភិបាលនេះទេ។ បើដូច្នេះ ក្រឹត្យច្បាប់មានតម្លៃត្រឹមតែជាបទបញ្ញាមួយ គឺលិខិតគតិយុត្តិដែលតាមធម្មតា ប្រកាសពីការចូលជាធរមាននៃច្បាប់ណាមួយ បន្ទាប់ពីបានអនុម័តដោយអង្គនីតិបញ្ញត្តិរួចមក។ យោងតាមគោលការណ៍ច្បាប់ដែលត្រូវបានគេទទួលស្គាល់ជាទូទៅ ដោយសារបទបញ្ញាមិនមែនច្បាប់ និងដោយពិចារណាឃើញថា តុលាការមួយត្រូវតែបង្កើតឡើងដោយច្បាប់[៣៣៩] ដែលត្រូវបានគេទទួលស្គាល់ជាទូទៅ នោះមូលដ្ឋានចម្បងនៃការបង្កើតតុលាការប្រជាជនបដិវត្តន៍ គឺជាចំណោទបញ្ហាហើយនៅក្នុងគោលការណ៍ច្បាប់ដែលត្រូវបានគេទទួលយកជាទូទៅរួចហើយ។

១៦៦. ក្រឹត្យច្បាប់នេះផ្ទាល់បង្ហាញពីទស្សនៈយល់ឃើញរបស់អង្គនីតិប្រតិបត្តិនៃរដ្ឋាភិបាលនោះ ចំពោះពិរុទ្ធភាពរបស់បុគ្គលតែពីរនាក់ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការប្រជាជនបដិវត្តន៍ ដែលបុព្វកថារបស់ក្រឹត្យច្បាប់នេះចែងគួរឱ្យកត់សម្គាល់ថា ជនជាប់ចោទ "បានសម្លាប់ប្រជាជនស្លូតត្រង់រាប់លាននាក់យ៉ាងរង្គាលព្រៃផ្សៃបំផុត" ហើយតុលាការនេះ ត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះអំពើប្រល័យពូជសាសន៍ "ដែលប្រព្រឹត្ត" ដោយបន ប៉ុល ពត - អៀង សារី[៣៤០]។

---

[៣៣៧] សេចក្តីសម្រេចជាសាធារណៈ ស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីការពារក្តី ចំពោះចៅក្រម ន័យ ថុល ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ C11/29 កថាខណ្ឌ ២០ ដល់ ២១ ក្រោយពីមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងរឿងក្តីរបស់ នួន ជា ដោយយោងទៅរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង *Furundzija* សំណុំរឿងលេខ IT-95-17/1-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ ១៨៩ ដល់ ១៩០។

[៣៣៨] ក្រឹត្យច្បាប់លេខ ១ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះបន ប៉ុល ពត និង អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៧៩ "ក្រឹត្យច្បាប់លេខ ១"។ ការបកប្រែជាភាសាអង់គ្លេសត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៤៥ ដល់ ៤៧។

[៣៣៩] មាត្រា ១៤(១) នៃកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៨ នៃអនុសញ្ញាអាមេរិកាំង ស្តីពីសិទ្ធិមនុស្ស និង មាត្រា ៦(១) នៃអនុសញ្ញាទ្វីបអឺរ៉ុប ស្តីពីសិទ្ធិមនុស្ស។

[៣៤០] ក្រឹត្យច្បាប់លេខ ១ មាត្រា ១។

១៦៧. សមាជិកទាំងឡាយរបស់តុលាការប្រជាជនបដិវត្តន៍ ដែលត្រូវបានតែងតាំងឡើងដើម្បីសម្រេចទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ ជាចៅក្រម ឬទីប្រឹក្សាប្រជាជន សុទ្ធតែជាប់ពាក់ព័ន្ធទៅនឹងអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាលនេះ។ ជាពិសេស លោក កែវ ចិន្តា ដែលជាប្រធានតុលាការនោះ ក៏ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ឃោសនាការ និងវប្បធម៌ ដែលពិតជាសមាជិករបស់រដ្ឋាភិបាលនេះ។ ទីប្រឹក្សាប្រជាជនពីររូបក្នុងចំណោមទីប្រឹក្សាទាំងអស់ ក៏ជាសមាជិករបស់រដ្ឋាភិបាលផងដែរ[៣៤១]។

១៦៨. ដោយពិចារណាឃើញថា តុលាការប្រជាជនបដិវត្តន៍ត្រូវបានបង្កើតឡើងដោយអង្គនីតិប្រតិបត្តិដោយបាន៖ (១) តែងតាំងសមាជិក ឬនិយោជិតរបស់រដ្ឋាភិបាលឱ្យកាន់មុខតំណែងជាចៅក្រម (២) ប្រកាសពិរុទ្ធភាពរបស់ជនជាប់ចោទតែពីរនាក់ ដែលត្រូវជំនុំជម្រះទោសនៅក្នុងក្រឹត្យច្បាប់បង្កើតតុលាការនេះ នោះអង្គបុរេជំនុំជម្រះយល់ឃើញថា តុលាការប្រជាជនបដិវត្តន៍មិនបានធានាឱ្យបានគ្រប់គ្រាន់នូវការបែងចែកអំណាចឱ្យដាច់ពីគ្នា ដើម្បីធានាថា ចៅក្រមទាំងអស់មិនទទួលរងការគាបសង្កត់ និងការជ្រៀតជ្រែកពីខាងក្រៅឡើយ។ ពិតហើយថា កាលៈទេសៈនៃការបង្កើតតុលាការប្រជាជនបដិវត្តន៍ និងការតែងតាំងសមាជិករបស់តុលាការនេះ បញ្ជាក់ឱ្យឃើញថា មិនមានការបែងចែកអំណាចរវាងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៩ គឺនៅចុងបញ្ចប់នៃសម័យខ្មែរក្រហម ដែលនាំឱ្យឈានដល់ការបង្កើតតុលាការមួយ ដែលមិនបានឆ្លើយតបទៅនឹងការធានាឱ្យមានឯករាជ្យភាពនោះឡើយ។

១៦៩. ដោយការពិនិត្យទៅលើភាពអនាគតិនៃសមាជិកតុលាការប្រជាជនបដិវត្តន៍ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា លោក កែវ ចិន្តា ដែលជាប្រធានតុលាការនេះបានប្រកាសនៅក្នុងសន្និសីទសារព័ត៌មាន កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧៩ ថាបន ប៉ុល ពត - អៀង សារី មានពិរុទ្ធភាពនៅចំពោះមុខតុលាការនេះ ដោយបានមានប្រសាសន៍ថា៖

> "វាច្បាស់ហើយថា បន ប៉ុល ពត - អៀង សារី បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ [...]
> [...] ប៉ុល ពត និង អៀង សារី គឺជាមេដឹកនាំ និងបានប្រព្រឹត្តសកម្មភាពឧក្រិដ្ឋជាច្រើន។
> ដូច្នេះ ពួកគេត្រូវបានកាត់សេចក្ដី។ [...]

---

[៣៤១] សមាសភាពរបស់តុលាការប្រជាជនបដិវត្តន៍តាំងនៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះបន ប៉ុល ពត និង អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្ដីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៥៦ ដល់ ៥៧ (អង់គ្លេស)។

បន ប៉ុល ពត - អៀង សារី បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើប្រជាជនទាំងមូល"[៣៨២]។

១៧០. យោងតាមមាត្រា ៣ នៃក្រឹត្យច្បាប់នេះ នៅក្នុងចំណោមទីប្រឹក្សាប្រជាជនទាំងអស់ យ៉ាងហោចណាស់ក៏មានទីប្រឹក្សាប្រជាជនចំនួនពីរនាក់ ដែលមានអំណាចស្មើគ្នានឹងប្រធានតុលាការ មានផលប្រយោជន៍ពិសេសនៅក្នុងរឿងក្តីនេះ គឺម្នាក់បានផ្តល់ភស្តុតាងដាក់បន្ទុកក្នុងដំណាក់កាលមុនសវនាការក្នុងនាមជាជនរងគ្រោះ[៣៨៣] និងម្នាក់ទៀតបានដាក់ជូនរបាយការណ៍អ្នកជំនាញ[៣៨៤]។

១៧១. មេធាវីការពារក្តី ដែលបានតែងតាំងដោយប្រធានតុលាការដើម្បីតំណាងឱ្យជនជាប់ចោទនៅក្នុង *សវនាការកំបាំងមុខនេះ* ក៏បានបង្ហាញនូវភាពលម្អៀង និងបានបំពេញតួនាទីខុសធម្មតា ប្រឆាំងនឹងកូនក្តីរបស់ខ្លួនឯង ដោយមានភស្តុតាងបង្ហាញដូចខាងក្រោមនេះ៖

ក. លោក ឌិត មន្ទី ដែលត្រូវបានចាត់តាំងឱ្យធ្វើជាមេធាវីការពារក្តី[៣៨៥] ក៏ជាជនរងគ្រោះនៃរបបខ្មែរក្រហម "ដែលបានបាត់បង់សមាជិកគ្រួសារចំនួន ៣៨ នាក់" បានផ្តល់ចម្លើយសាក្សីដើម្បីធ្វើការដាក់បន្ទុក នៅក្នុងអំឡុងពេលស៊ើបអង្កេត[៣៨៦]។

---

[៣៨២] សន្និសីទសារព័ត៌មានរបស់លោក កែវ ចិន្តា កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៤៧ ត្រង់កថាខណ្ឌ ៤៨ ដល់ ៤៩ (អង់គ្លេស)។

[៣៨៣] ចម្លើយសាក្សីរបស់លោក ប៉ែន ណាវុធ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៧៩ និងក្រឹត្យច្បាប់លេខ ២៥ ស្តីពីការតែងតាំងសមាជិកតុលាការ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យ ពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៩៥ ដល់ ៩៦ និងទំព័រ ៤៩ ដល់ ៥០ (អង់គ្លេស)។

[៣៨៤] ការអភិវឌ្ឍផ្នែករាងកាយ និងប្រាជ្ញាស្មារតីនាពេលអនាគតរបស់កុមារក្រុងភ្នំពេញ បន្ទាប់ពីការជម្លៀសចេញពីក្រុងកម្ពុជាក្នុងឆ្នាំ ១៩៧៥ ដូចដែលបានយល់ឃើញដោយវេជ្ជបណ្ឌិតដែលមានឯកទេសខាងជំងឺកុមារ។ វេជ្ជបណ្ឌិត នុត សាវឿន របាយការណ៍ និងការតែងតាំងសមាជិកនៃតុលាការ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៣៣៥ ដល់ ៣៣៧ និងទំព័រ ៥០ ដល់ ៥១ (អង់គ្លេស)។

[៣៨៥] សេចក្តីសម្រេចលេខ ២៥៖ ប្រធានតុលាការ ការចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៧៩ ។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ៥៩ ដល់ ៦០ (អង់គ្លេស)។

[៣៨៦] កំណត់ហេតុផ្តល់ចម្លើយសាក្សីរបស់លោក ឌិត មន្ទី ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៧៩ ។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ១៣៤ ដល់ ១៣៨ (អង់គ្លេស)។ *សូមមើលផងដែរ* Suzannah Linton "Putting Cambodia's Extraordinary Chambers into Context"



PRE-TRIAL CHAMBER

00661596



ខ. មិនមានការសួរតទល់សាក្សីបដិបក្ខទេ បើទោះបីជាសិទ្ធិនេះត្រូវបានចែងយ៉ាងច្បាស់យ៉ាងណាក្តី[៣៤៧]។

គ. មេធាវីការពារក្តីរបស់ ប៉ុល ពត និង អៀង សារី មិនបានផ្តល់ភស្តុតាងអ្វីនោះទេ[៣៤៨]។ នៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទការសួរដេញដោល មេធាវីការពារក្តីមិនបានបង្ហាញទឡ្ហីករណ៍ប្រកបដោយអត្ថន័យណាមួយនោះទេ។ ផ្ទុយទៅវិញ ពួកគាត់បានទទួលស្គាល់យ៉ាងច្បាស់ថា ជនជាប់ចោទពិតជាមានចេតនាជាក់លាក់ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍មែន[៣៤៩] និងបានធ្វើសេចក្តីថ្លែងផ្សេងៗទៀតដែលជាការធ្វើឱ្យខូចប្រយោជន៍ដល់ជនជាប់ចោទ។ ឧទាហរណ៍៖

១. លោក Hope Stevens ដែលបានធ្វើសារណាតំណាងឱ្យជនជាប់ចោទ បាននិយាយនៅក្នុងសេចក្តីសន្និដ្ឋានបិទការសួរដេញដោលរបស់ខ្លួនថា ប៉ុល ពត និង អៀង សារី គឺជា "ឧក្រិដ្ឋជនដ៏ឆ្កួតលីលាខុសគេ ដែលបានសម្រេចនូវកម្មវិធីមួយ ដែលបង្កើតឡើងជាពិសេសសម្រាប់តែពួកវា"[៣៥០]។

២. លោក យស់ ប៉ោ ដែលត្រូវបានចាត់តាំងឱ្យធ្វើជាមេធាវីការពារក្តី បានប្រកាសនៅក្នុងអំឡុងពេលសវនាការថា "ប៉ុល ពត - អៀង សារី នៅមានកម្លាំងខ្មៅងងឹតលាក់នៅខាងក្រោយខ្នង ដើម្បីនឹងញុះញង់ លើកទឹកចិត្ត ប្រើកម្លាំងគាបសង្កត់ និងជួយបិទបាំងឱ្យពួកវាមានដំណើរការនូវបទឧក្រិដ្ឋទាំងនេះ។ បណ្តាកម្លាំងដ៏ខ្មៅងងឹតនោះ ទោះបីខំលាក់ខ្លួនបំពួនអាត្មាយ៉ាងណាក៏ដោយ ក៏ត្រូវលេចឡើងនូវរូបខាងដើមរបស់វានិង

---

(ការពិនិត្យមើលអង្គជំនុំជម្រះវិសាមញ្ញក្នុង បរិបទកម្ពុជា) ឆ្នាំ ២០០៧ ទំព័រ XI (អង់គ្លេស) *សៀវភៅប្រចាំឆ្នាំរបស់ប្រទេសសិង្ហបុរី ស្តីពីច្បាប់អន្តរជាតិ* ២១១ ("Linton")។

[៣៤៧] សៀវភៅដែលមានចំណងជើងថា *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ១៦ (អង់គ្លេស)។ *សូមមើលផងដែរ* William Schabas "សៀវភៅស្តីពីការពិនិត្យឡើងវិញ ប្រទេសកម្ពុជា៖ តើវាពិតជាអំពើប្រល័យពូជសាសន៍មែនទេ? ២៣ (២០០១) សិទ្ធិមនុស្សប្រចាំត្រីមាស ទំព័រទី ៤៧៥ ដល់ ៤៧៦ (អង់គ្លេស)។

[៣៤៨] សៀវភៅសរសេរដោយលោក David Chandler ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បោះពុម្ពលើកទី ៤ Silkworm Books ឆ្នាំ ២០០៨ ទំព័រទី ២៨០ (អង់គ្លេស)។

[៣៤៩] សាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើង វិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ៥២៣ (អង់គ្លេស) ត្រង់កថាខណ្ឌ ៥៤២។

[៣៥០] សេចក្តីសន្និដ្ឋានបិទការសួរដេញដោលរបស់មេធាវីការពារក្តី Hope R. Stevens ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើង វិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ៥០៤ (អង់គ្លេស)។

បញ្ចេញនូវមុខមាត់ដ៏ខ្ពើមរអើមរបស់វានៅលើទីលានដ្ឋានបទឧក្រិដ្ឋដ៏មហាសម្បើម គឺនៅលើទឹកដី និងប្រជាជនកម្ពុជា"[៣៥១]។ មេធាវីរូបនេះក៏បានលើកឡើងផងដែរថា "ដោយមកពីឥទ្ធិពលយ៉ាងខ្លាំងក្លាពីលទ្ធិម៉ៅ ដោយមកពីតាមលទ្ធិម៉ៅយ៉ាងល្ងិតល្ងង់ ហើយអាចនិយាយថាឆ្កួតលីលាក៏បាន ទើបអាចធ្វើនូវកិច្ចការអ្វីដែលអ្នកមានសតិសម្បជញ្ញៈ និងស្មារតីធម្មតាពុំដែលជួបប្រទះសោះ"[៣៥២]។

១៧២. កំណត់ហេតុផ្តល់ចម្លើយរបស់សាក្សី ដែលបានយកមកធ្វើជាសំអាងនៅក្នុងសវនាការនាពេលនោះ អាចត្រូវបានគេរិះគន់ ដោយសារមូលហេតុដូចខាងក្រោម៖

ក. ការចោទប្រកាន់ចំពោះ "ការចាត់ចែង" ទៅលើសាក្សី[៣៥៣]។

ខ. កំណត់ហេតុផ្តល់ចម្លើយរបស់សាក្សីបានប្រើប្រាស់ពាក្យពេចន៍ និងភាសាស្រដៀងៗគ្នា ជាពិសេសសំដៅទៅលើបន ប៉ុល ពត - អៀង សារី និងការកំណត់ថា អ្នកទាំងពីរនេះគឺជា "ជនក្បត់ជាតិ"[៣៥៤]។

គ. សាក្សីបានលើកឡើងថា "ប៉ុល ពត" ឬ "អៀង សារី" បានប្រព្រឹត្តអំពើ x y ឬ z ដោយប្រៀបធៀបអំពើទាំងនេះជាមួយនឹងចលនាផ្ទាល់របស់វា ឬប្រៀបធៀបបុគ្គលទាំងឡាយស្ថិតនៅក្នុងចលនានេះ" តែតាមពិតទៅ សាក្សីទាំងនោះមិនធ្លាប់បានជួបជាមួយជនជាប់ចោទទេ[៣៥៥]។

ឃ. ចម្លើយសាក្សីត្រូវបានសរសេរឡើងដោយការប្រើប្រាស់សព្វនាម/នាមជាបុរសទី៣[៣៥៦]។

---

[៣៥១] សេចក្តីសន្និដ្ឋានបិទការសួរដេញដោលរបស់មេធាវី យស់ ប៉ោ តំណាងឱ្យ ប៉ុល ពត និង អៀង សារី។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ៥០៨ (អង់គ្លេស) ត្រង់កថាខណ្ឌ ៥១០។

[៣៥២] ទឡ្ហីករណ៍ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទរបស់មេធាវី យស់ ប៉ោ តំណាងឱ្យ ប៉ុល ពត និង អៀង សារី ដែលជាប់ចោទពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រទី ៥០៨ (អង់គ្លេស) ត្រង់កថាខណ្ឌ ៥១០។

[៣៥៣] សៀវភៅនិពន្ធដោយ Linton ទំព័រ ២០៩ ដល់ ២១០ (អង់គ្លេស)។

[៣៥៤] កំណត់ហេតុផ្តល់ចម្លើយរបស់សាក្សីរបស់លោក អ៊ុង ពេជ្រ, ពេជ្រ ទុំក្រវិល, អ៊ុង សំអួន និង សូ សំអុល។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី *អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ៧៥ ១០២ ១០៣ ១២០ ១២២ និងទំព័រ ១២៧។

[៣៥៥] Linton ទំព័រ ២០៩ ដល់ ២១០ (អង់គ្លេស)។ សូមមើលផងដែរ ចម្លើយសាក្សីដែលបានដកស្រង់ខាងលើ នៅក្នុងលេខយោងជើងទំព័រមុន។ *សូមមើលផងដែរ* កំណត់ហេតុចម្លើយសាក្សីដែលបានដកស្រង់ខាងលើ ក្នុងជើងទំព័រមុន។

ង. ចម្លើយជនរងគ្រោះ និងចម្លើយសាក្សី បានសម្តែងពីសេចក្តីពេញចិត្ត និងភក្តីភាពចំពោះរដ្ឋាភិបាលថ្មីនេះ[៣៥៧]។

១៧៣. ផ្អែកលើរយៈពេលនៃដំណើរការនីតិវិធី (រយៈពេល ២០ ថ្ងៃគិតពីពេលបើកកិច្ចស៊ើបសួររហូតដល់ការចាប់ផ្តើម*សវនាការកំបាំងមុខ* ដោយមាន៥ ថ្ងៃសម្រាប់ការជំនុំជម្រះ និងការចេញសាលក្រមនៅថ្ងៃបិទការសួរដេញដោល និងតារាងពេលវេលាការងារ គេអាចសន្និដ្ឋានថា ជនជាប់ចោទត្រូវបានគេពិចារណាថាមានពិរុទ្ធភាពជាមុនរួចទៅហើយ។ តារាងពេលវេលាសវនាការដែលបានកំណត់ជាមុនថា តុលាការប្រជាជនបដិវត្តន៍នឹងចេញសាលក្រមរបស់ខ្លួន នៅពេលដំណាលគ្នានឹងថ្ងៃបិទការសួរដេញដោល បញ្ជាក់ឱ្យឃើញថា តុលាការនេះមិនមានចេតនាធ្វើការពិភាក្សាឱ្យបានហ្មត់ចត់នោះទេ។ តាមពិតទៅ សាលក្រមដែលមានចំនួន ៣១ ទំព័រ (ជាភាសាអង់គ្លេស) ត្រូវបានប្រកាសតែក្នុងរយៈពេលពីរបីម៉ោង ក្រោយពីការបញ្ចប់សេចក្តីសន្និដ្ឋានសួរដេញដោលរួចមក។

១៧៤. យោងទៅលើអង្គហេតុទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សមាជិកមួយចំនួននៃតុលាការប្រជាជនបដិវត្តន៍មិនមានអនាគតិទេ។ តាមរយៈសេចក្តីថ្លែងរបស់ខ្លួន ទាំងនៅក្រៅតុលាការ និងទាំងការបង្ហាញភស្តុតាងប្រឆាំងនឹងជនជាប់ចោទ សមាជិកមួយចំនួននៃតុលាការប្រជាជនបដិវត្តន៍បានបង្ហាញនូវភាពលម្អៀងយ៉ាងពិតប្រាកដ។ លើសពីនេះទៅទៀត របៀបដែលសមាជិកតុលាការប្រជាជនបដិវត្តន៍បំពេញដំណើរការនីតិវិធី ដោយការអនុញ្ញាតទទួលយកចម្លើយសាក្សីដូចដែលបានលើកឡើងខាងលើ ដោយមិនមានការសួរដេញដោលសាក្សីបដិបក្ខ ការអនុញ្ញាតឱ្យបន្តដំណើរការនីតិវិធីដោយ*កំបាំងមុខ* ដែលមេធាវីការពារក្តីមិនត្រឹមតែមិនបានធ្វើជាតំណាងឱ្យជនជាប់ចោទប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែ បែរជាធ្វើសកម្មភាពប្រឆាំងនឹងជនជាប់ចោទទៅវិញ និងការប្រកាសពីពិរុទ្ធភាពរបស់ជនជាប់ចោទចំពោះបទល្មើសដ៏ធំធេងបែបនេះ បន្ទាប់ពីសវនាការរយៈពេលប្រាំ(៥) ថ្ងៃរួចមក និងបន្ទាប់ពីការពិភាក្សាសម្រេច ក្នុងរយៈពេលតែពីរបីម៉ោង បង្ហាញឱ្យឃើញថា តុលាការនេះខកខានមិនបានរក្សាឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងពីរទេ។

---

[៣៥៦] William Schabas "សៀវភៅស្តីពីការពិនិត្យឡើងវិញ ប្រទេសកម្ពុជា៖ តើវាពិតជាអំពើប្រល័យពូជសាសន៍មែនឬ? ២៣ (២០០១) សិទ្ធិមនុស្សប្រចាំត្រីមាស ៤៧០ កថាខណ្ឌ ៤៧៥ ដល់ ៤៧៦។

[៣៥៧] សៀវភៅដែលមានចំណងជើងថា អំពើប្រល័យពូជសាសន៍នៅកម្ពុជា ទំព័រ ១៥ (អង់គ្លេស) ចម្លើយសាក្សីឈ្មោះ ជា ពន្លក, អ៊ុំ ប៉ាភ័នី, ចៀន ផាន់ណា, យី ធុន។ ការបកប្រែជាភាសាអង់គ្លេស ត្រូវបានធ្វើឡើងវិញនៅក្នុងសៀវភៅស្តីពី*អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា* ទំព័រ ១១២, ១២៣, ១១៤, ១២០, ១៣២ (អង់គ្លេស)។

00661599



នៅក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ការខកខានរបស់សមាជិកតុលាការប្រជាជនបដិវត្តន៍ ដោយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាឲ្យដំណើរការនីតិវិធីត្រូវបានប្រព្រឹត្តទៅដោយត្រឹមត្រូវ និងមិនបានគោរពដល់សិទ្ធិរបស់ភាគីទាំងឡាយនោះ[៣៥៨] បង្ហាញឲ្យឃើញនូវកង្វះអនាគតិពិតប្រាកដមែន។

១៧៥. យោងតាមមូលដ្ឋានអង្គហេតុខាងលើ នៃ*ការជំនុំជម្រះក្ដីដោយកំបាំងមុខ* ក្នុងឆ្នាំ ១៩៧៩ ប្រឆាំងនឹង អៀង សារី នោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការកាត់សេចក្ដីឆ្នាំ ១៩៧៩ មិនបានប្រព្រឹត្តទៅដោយឯករាជ្យ និងអនាគតិ ស្របតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋាននីតិវិធីនោះទេ បើទោះបីជាអាចមានភាពតានតឹងក្នុងការចោទប្រកាន់ ការជំនុំជម្រះ និងការផ្ដន្ទាទោសចំពោះ អៀង សារី ក៏ដោយ។ ជាផលវិបាក ការចោទប្រកាន់ ការជំនុំជម្រះ និងការផ្ដន្ទាទោស អៀង សារី ក្នុងឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍ មិនបានរារាំងដល់ការអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក ទៅលើ អៀង សារី ឬទៅលើបទចោទណាមួយ នៅក្នុងដីកាដំណោះស្រាយនោះទេ។

១៧៦. អាស្រ័យហេតុនេះ មូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ត្រូវបានបដិសេធចោល។

## ២. មូលដ្ឋានទីពីរ (ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស)

### សារណារបស់ភាគីនានា

១៧៧. សហមេធាវីការពារក្ដីលោកអៀង សារី បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[៣៥៩] ("ព្រះរាជក្រឹត្យលើកលែងទោស") ដែលព្រះមហាក្សត្របានប្រទានជូនលោកអៀង សារី សម្រាប់លើកលែងការ

---

[៣៥៨] *គោលការណ៍ជាមូលដ្ឋាន ស្ដីពីឯករាជ្យភាពនៃតុលាការ* ឆ្នាំ ១៩៨៥ ដែលអនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទីប្រាំពីរ អំពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជនល្មើស ដែលបានប្រារព្ធធ្វើនៅក្នុងទីក្រុង មីឡាន (Milan) ពីថ្ងៃ ២៦ សីហា ដល់ថ្ងៃ ៦ កញ្ញា ១៩៨៥ និងបានយល់ព្រមដោយសេចក្ដីសម្រេចរបស់មហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃ ២៩ វិច្ឆិកា ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃ ១៣ ធ្នូ ១៩៨៥ ឯកសារ អ.ស.ប លេខ A/CONF.121/22/Rev.1 ត្រង់កថាខណ្ឌ ៥៩ គោលការណ៍ទី ៦។

[៣៥៩] ព្រះរាជក្រឹត្យ នស/រកត/១៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ("ព្រះរាជក្រឹត្យ")។

ផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ កាលពីឆ្នាំ ១៩៧៩ ព្រមទាំងការលើកលែងការចោទប្រកាន់ដែលបានកំណត់ដោយច្បាប់ស្តីពីការដាក់ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ឱ្យនៅក្រៅច្បាប់[៣៦០] ("ច្បាប់ឆ្នាំ ១៩៩៤") មិនអាចរារាំងការចោទប្រកាន់លើលោកអៀង សារី ក្នុងពេលបច្ចុប្បន្ននេះបានឡើយ[៣៦១]។

១៧៨. នៅចំណុចដំបូង សហមេធាវីការពារក្តីបានសន្និដ្ឋានថា ព្រះរាជក្រឹត្យលើកលែងទោសនៅតែមានសុពលភាពតាមផ្លូវច្បាប់ក្នុងប្រទេសកម្ពុជា ព្រោះព្រះរាជក្រឹត្យនេះត្រូវបានព្រះរាជទានដោយព្រះមហាក្សត្រ ស្របតាមមាត្រា២៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[៣៦២]។ សហមេធាវីការពារក្តីបានលើកឡើងថា ព្រះរាជក្រឹត្យលើកលែងទោសមានសុពលភាពសម្រាប់ អ.វ.ត.ក ព្រោះថាអង្គជំនុំជម្រះមួយនេះជាតុលាការជាតិ ដែលត្រូវគោរព និងអនុវត្តតាមច្បាប់កម្ពុជាដែលនៅជាធរមាន និងមានសុពលភាព។ ក្នុងចំណុចនេះ សហមេធាវីការពារក្តីបានលើកឡើងថា ការអនុគ្រោះទោសក្នុងស្រុក មានសុពលភាពចំពោះបទឧក្រិដ្ឋ*អាជ្ញាបញ្ញា*ផងដែរ (*jus cogens*)[៣៦៣] ដូចបានបញ្ជាក់ជាឧទាហរណ៍មួយថា នៅពេលដែលរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ផ្តល់នូវការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋ*អាជ្ញាបញ្ញា* ការផ្តល់នេះត្រូវបានសហគមន៍អន្តរជាតិទទួលយក[៣៦៤]។ បើទោះបីជា អ.វ.ត.ក ត្រូវគិតពិចារណាពីបទដ្ឋានយុត្តិធម៌អន្តរជាតិក៏ដោយ ក៏សហមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា គ្មានបទដ្ឋានណាមួយ ដែលរារាំងនូវការអនុវត្តការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋ*អាជ្ញាបញ្ញា*ឡើយ[៣៦៥]។ តាមទស្សនៈរបស់សហមេធាវីការពារក្តី ការដែលតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") មិនបានគាំទ្រការអនុគ្រោះទោសដែលបានធ្វើ

---

[៣៦០] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឱ្យនៅក្រៅច្បាប់ ព្រះរាជក្រមលេខ ១ នស៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ "ច្បាប់ឆ្នាំ១៩៩៤"។

[៣៦១] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៥០។

[៣៦២] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៦៣

[៣៦៣] ពាក្យជាភាសាឡាតាំង *"jus cogens"* សំដៅទៅលើវិធានដាច់ខាតមួយ នៃច្បាប់អន្តរជាតិ ដូចជាវិធានដែលបានទទួលយក និងទទួលស្គាល់ជារួមដោយសហគមន៍នៃរដ្ឋជាអន្តរជាតិ ថាជាវិធានដែលមិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរផ្ទុយ លើកលែងតែមានវិធាននៃច្បាប់អន្តរជាតិទូទៅ ហើយដែលមានលក្ខណៈដូចគ្នា ទើបអាចកែប្រែលើវិធាននេះបាន។ អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា មាត្រា៥៣។

[៣៦៤] បណ្តឹងឧទ្ធរណ៍ អៀងសារី កថាខណ្ឌ ៧០។

[៣៦៥] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៧៤។

ឡើងដោយរដ្ឋាភិបាលសៀរ៉ាឡេអូន នៅក្នុងកិច្ចព្រមព្រៀង Lomé សម្រាប់បទឧក្រិដ្ឋ*អាជ្ញាបញ្ញា* គឺ មិនអាចរារាំង អ.វ.ត.ក មិនឱ្យគាំទ្រការអនុគ្រោះទោសឡើយ ព្រោះអង្គជំនុំជម្រះនេះមិនអនុវត្ត យុត្តាធិការសកលឡើយ[៣៦៦]។

១៧៩. សហមេធាវីការពារក្តីបានលើកឡើងថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស គ្រប ដណ្តប់ទៅលើបទល្មើសនានាដែល អៀង សារី ត្រូវបានចោទប្រកាន់ នៅចំពោះមុខ អ.វ.ត.ក ហេតុដូច្នេះវានឹងរារាំងដល់ការចោទប្រកាន់ចំពោះ អៀង សារី។ សហមេធាវីបានលើកឡើងជា បឋមទាក់ទិនទៅនឹងបញ្ហានេះថា ការអនុគ្រោះទោសចំពោះ អៀង សារី សម្រាប់រាល់ការចោទ ប្រកាន់តាមច្បាប់ឆ្នាំ ១៩៩៤ គ្របដណ្តប់ទៅលើបទ ឧក្រិដ្ឋដែលចោទប្រកាន់នៅក្នុងដីកាដំណោះ ស្រាយ ព្រោះថា ច្បាប់ឆ្នាំ ១៩៩៤ មានន័យថាបានគ្រប់ដណ្តប់ទៅលើរាល់ឧក្រិដ្ឋកម្មទាំងអស់ ដែលសមាជិកក្រុមកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្ត ដែលច្បាប់ឆ្នាំ ១៩៩៤ នេះ បានក្លាយជា ច្បាប់ពិសេស (*lex specialis*)[៣៦៧] សម្រាប់វិនិច្ឆ័យទោសបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តដោយពួក ខ្មែរក្រហម។ សហមេធាវីការពារក្តីបានលើកឡើងថា បុព្វកថា ព្រមទាំងមាត្រា១ ដល់មាត្រា៤ នៃ ព្រះរាជក្រឹត្យ ព្រមទាំងយុត្តាធិការនៃតុលាការកម្ពុជា បានគាំទ្រដល់ការបកស្រាយបែបនេះ[៣៦៨]។ សហមេធាវីការពារក្តីបានសន្និដ្ឋានថា ទាក់ទិនទៅនឹងព្រះរាជទានលើកលែងចំពោះការផ្តន្ទាទោស កាលពីឆ្នាំ ១៩៧៩ ដោយសារតែទោសប្រហារជីវិតត្រូវបានលុបបំបាត់តាំងពីមុនពេលដែលព្រះ មហាក្សត្រ បានព្រះរាជទានលើកលែងទោសលោក អៀង សារី ទើបក្នុងការប្រទានលើកលែង ទោសនេះ ព្រះមហាក្សត្រមានព្រះរាជបំណងចង់ធានាថា អៀង សារី មិនត្រូវទទួលការផ្តន្ទាទោស ណាមួយ ទាក់ទិនទៅនឹងអំពើដែលគាត់បានប្រព្រឹត្ត ហើយត្រូវបានជំនុំជម្រះកាលពីឆ្នាំ ១៩៧៩ ឡើយ ប្រសិនបើមិនដូច្នោះទេ ព្រះរាជក្រឹត្យនេះនឹងក្លាយជាអសារឥតការ[៣៦៩]។ ជាចុងបញ្ចប់ សហ មេធាវីការពារក្តីបានថ្លែងថា អ.វ.ត.ក មិនមានយុត្តាធិការសម្រេច ថាតើព្រះរាជក្រឹត្យលើកលែង

---

[៣៦៦] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៧៥។

[៣៦៧] ពាក្យជាភាសាឡាតាំង *"lex specialis"* សំដៅទៅលើលិទ្ធិមួយ ដែលទាក់ទិននឹងការបកស្រាយច្បាប់ ដែលច្បាប់គ្រប់គ្រង លើបញ្ហាជាក់លាក់មួយ *"lex specialis"* អាចមានអានុភាពលើច្បាប់ដែលគ្រប់គ្រងលើបញ្ហាជាទូទៅ *"lex generalis"*។

[៣៦៨] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៨៤ ដល់៨៥។

[៣៦៩] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ៨៦។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ទោស និងអនុគ្រោះទោសនេះ មានសុពលភាព ឬគ្មាននោះទេ តែ អ.វ.ត.ក អាចសម្រេចបានត្រឹមតែវិសាលភាពរបស់វាតែប៉ុណ្ណោះ[៣៧០]។

១៨០. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការលើកលែងទោស និងអនុគ្រោះទោស អៀង សារី នៅក្នុងឆ្នាំ ១៩៩៦ មិនអាចរារាំងការចោទប្រកាន់បន្ថែមនៅ អ.វ.ត.ក បានឡើយ។ ជាបឋម សហព្រះរាជអាជ្ញាបានជំទាស់ថា ច្បាប់ឆ្នាំ ១៩៩៤ មិនបានរួមបញ្ចូលនូវបទល្មើសដែលត្រូវបានចោទប្រកាន់ប្រឆាំង អៀង សារី ក្នុងដីកាដំណោះស្រាយនោះទេ ព្រោះច្បាប់នេះ "មានវិសាលភាពទៅអនាគតសម្រាប់តែកំណត់ជាបទល្មើសដល់សមាជិករបស់ពួកខ្មែរក្រហម ចាប់ពីប្រាំមួយខែ ក្រោយពីច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤"[៣៧១]។ ទីពីរ សហព្រះរាជអាជ្ញាបានលើកឡើងថា វិសាលភាពនៃការលើកលែងទោសគឺកម្រិតត្រឹមគ្រាន់តែឲ្យរួចខ្លួនពីការផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិរបស់គាត់ទាំងអស់តែប៉ុណ្ណោះ[៣៧២]។ ទីបី សហព្រះរាជអាជ្ញាបានយល់ស្របថា ការលើកលែងទោស និងការអនុគ្រោះទោស មិនត្រូវបានអនុញ្ញាត ចំពោះបទឧក្រិដ្ឋ*អាជ្ញាបញ្ញា*នោះឡើយ[៣៧៣] ហើយការផ្តល់ការលើកលែងទោសណាមួយ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាការរំលោភបំពានទៅលើកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា នៅក្រោមអនុសញ្ញាស្តីពីការប្រល័យពូជសាសន៍ ហេតុដូចនេះការលើកលែងទោសបែបនេះគឺមិនមានសុពលភាពនោះទេ[៣៧៤]។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានជំទាស់ថា ការលើកលែងទោសតាមច្បាប់ក្នុងស្រុក មិនអាចយកមកអនុវត្តបាន នៅក្នុងការជំនុំជម្រះលើបទឧក្រិដ្ឋ*អាជ្ញាបញ្ញា* អន្តរជាតិនៅចំពោះមុខ អ.វ.ត.ក ដែលត្រូវបានចាត់ទុកថាជា "តុលាការពិសេសមានចរិកជាអន្តរជាតិមួយ ដែលត្រូវអនុវត្តតាមច្បាប់អន្តរជាតិ" នោះឡើយ[៣៧៥]។

១៨១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមមេធាវីគ្មានព្រំដែនប្រទេសបារាំង) បានផ្តល់ចម្លើយតបថា បទល្មើសដែលបានចាត់ជាបទឧក្រិដ្ឋក្រោមច្បាប់ឆ្នាំ ១៩៩៤ គឺមិនដូចគ្នានឹងអ្វីដែល

---

[៣៧០] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ១០០។

[៣៧១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦១។

[៣៧២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២។

[៣៧៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៤។

[៣៧៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៥។

[៣៧៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។

បានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយឡើយ។ ដូច្នេះ ការអនុគ្រោះទោសមិនអាចអនុវត្តបានចំពោះដំណើរការនីតិវិធីក្នុងពេលបច្ចុប្បន្ននេះឡើយ[៣៧៦]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានបន្ថែមទៀតថា វិសាលភាពនៃការលើកលែងទោស គឺកម្រិតត្រឹមតែទោសដែលត្រូវបានប្រកាសកាលពីឆ្នាំ ១៩៧៩ តែប៉ុណ្ណោះ[៣៧៧]។

១៨២. សហមេធាវីការពារក្តី អៀង សារី បានចេញសារណាតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាថា ការអនុគ្រោះទោសត្រូវអនុវត្តចំពោះគ្រប់បទឧក្រិដ្ឋដែលសមាជិក "ក្រុមកម្ពុជាប្រជាធិបតេយ្យ" បានប្រព្រឹត្ត ព្រោះការបកស្រាយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា មានលក្ខណៈជាការបកស្រាយមិនច្បាស់លាស់ (blank cheque) ដែលថាប្រព្រឹត្តបទល្មើសក្នុងរយៈពេល៦ខែ[៣៧៨]។ សហមេធាវីការពារក្តីបានជំទាស់ថា ការអនុគ្រោះទោសគួរត្រូវបកស្រាយឲ្យបានទូលំទូលាយ ដោយស្របតាមមាត្រា៦(៥) នៃ*ពិធីសារបន្ថែមទី២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ព្រមទាំងទាក់ទិនដល់ការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារទី២) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧* ("ពិធីសារបន្ថែមទី២")[៣៧៩] ដែលឆ្លុះបញ្ចាំងពីចេតនារបស់រាជរដ្ឋាភិបាល ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា[៣៨០]។ បន្ថែមពីលើនេះទៀត សហមេធាវីការពារក្តីបានលើកឡើងសាជាថ្មីថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ពិតជាអាចអនុវត្តបានចំពោះបទឧក្រិដ្ឋ*អាជ្ញាបញ្ញា* ហើយពួកគាត់បានបន្ថែមថា "ការផ្តន្ទាទោស" ទៅលើបទឧក្រិដ្ឋទាំងនោះ មិនអាចចាត់ទុកថាជា *អាជ្ញាបញ្ញា*បានទេ[៣៨១]។

---

[៣៧៦] សេចក្តីសង្កេតផ្នែកទី១ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៦។

[៣៧៧] សេចក្តីសង្កេតផ្នែកទី១ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៦។

[៣៧៨] សារណាតបរបស់ អៀង សារី កថាខណ្ឌ ២៦។

[៣៧៩] សារណាតបរបស់ អៀង សារី កថាខណ្ឌ ២៨។

[៣៨០] សារណាតបរបស់អៀង សារី កថាខណ្ឌ២៨ ដល់២៩។

[៣៨១] សារណាតបរបស់អៀង សារី កថាខណ្ឌ ៣០។

១៨៣. សហមេធាវីការពារក្ដី អៀង សារី បានផ្ដល់សារណាតបថា ការសង្កេតរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គ្មានលក្ខណៈយុត្តិកម្មឡើយ[៣៨២]។

## ការពិភាក្សា

១៨៤. នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៩៤ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័ត"ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់"("ច្បាប់ឆ្នាំ ១៩៩៤")។ ច្បាប់ឆ្នាំ ១៩៩៤ នេះ បានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធដូចតទៅ៖

*រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា*

> ដោយយល់ឃើញថា កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ស្ដីពីដំណោះស្រាយ នយោបាយរួមមួយ នៃជម្លោះនៅកម្ពុជា ដែលក្រុម "កម្ពុជាប្រជាធិបតេយ្យ" បានចុះហត្ថលេខាជាមួយហត្ថលេខីខ្មែរបីទៀត តម្រូវឱ្យក្រុម "កម្ពុជាប្រជាធិបតេយ្យ" ក៏ដូចជាហត្ថលេខីបីទៀត អនុវត្តបទប្ប ញ្ញត្តិទាំងប៉ុន្មានសម្រាប់នាំមកនូវសន្តិភាព និងការផ្សះផ្សាជាតិ។
>
> ដោយជាក់ស្ដែង ក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនព្រមអនុវត្តបទប្បបញ្ញត្តិសំខាន់ៗ នៃកិច្ចព្រមព្រៀងខាងលើ ហើយជាពិសេសរំលោភលើមាត្រាដែលទាមទារឱ្យគោរពបទឈប់បាញ់, ឱ្យអនុញ្ញាតឱ្យមន្ត្រី និងបុគ្គលិកនៃអង្គការសហប្រជាជាតិ (អ.ស.ប) ចូលទៅតំបន់ដែលខ្លួនកាន់កាប់, ឱ្យអនុវត្តការប្រមូលផ្ដុំ កម្លាំងប្រដាប់អាវុធរបស់ខ្លួន ដកអាវុធ និងរំសាយកម្លាំងទ័ព, ឱ្យគោរពសិទ្ធិមនុស្សនៅកម្ពុជា។
>
> ដោយលើសពីការមិនគោរពបទប្បញ្ញត្តិសំខាន់ៗទាំងឡាយខាងលើដែលខ្លួនជាហត្ថលេខី ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឈ្លានពានដោយប្រដាប់អាវុធទៅលើមន្ត្រី និងបុគ្គលិករបស់អាជ្ញាធរបណ្ដោះនៃ អ.ស.ប ទៅលើមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងទៅលើអាយុជីវិតរបស់ប្រជារាស្ត្រកម្ពុជា ដោយមិនរើសមុខ។
>
> [...]

---

[៣៨២] សារណាតបរបស់ អៀង សារី ចំពោះសេចក្ដីសង្កេតផ្នែកទី១ របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ២៨ ដល់២៩។

ដោយតាំងពីការបោះឆ្នោតនាឆ្នាំ១៩៩៣រៀងរហូតមក ក្រុមកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តជាបន្តបន្ទាប់នូវ ឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួនតាំងពីក្រុមខ្លួនដណ្តើមយកអំណាចកាន់កាប់នៅខែ មេសា ឆ្នាំ ១៩៧៥ [...]

ដោយ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" បានរំលោភលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសលើ [...]

ដោយយល់ឃើញថាមេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាចយកកិច្ចព្រមព្រៀងនាទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយរួមមួយ នៃជម្លោះនៅកម្ពុជា ធ្វើជាខែលខាងច្បាប់សម្រាប់លាក់បំបាំងយករួចខ្លួន ពីការទទួលខុសត្រូវរបស់ពួកខ្លួន ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ចាប់តាំងពីពេលរបបប៉ុល ពត ដណ្តើមអំណាចនៅឆ្នាំ ១៩៧៥-១៩៧៨។ បទឧក្រិដ្ឋប្រល័យពូជសាសន៍ គ្មានអាជ្ញាយុកាលឡើយ។

*ហេតុនេះរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តច្បាប់ដែលមានបញ្ញត្តិដូចតទៅ៖*

មាត្រា១៖ ដាក់ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" និងកម្លាំងយោធារបស់ខ្លួន ឱ្យនៅក្រៅច្បាប់។

មាត្រា២៖ ចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ជនទាំងឡាយណាដែលជាសមាជិកអង្គការនយោបាយ និងជាកម្លាំងយោធារបស់ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ត្រូវចាត់ទុកជាជនល្មើសនឹងរដ្ឋធម្មនុញ្ញ និងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣៖ សមាជិកអង្គការនយោបាយ និងកម្លាំងយោធារបស់ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ធ្វើមនុស្សឃាតដោយចេតនា ចាប់បង្ខំនារីសេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងឯកជន ។ល។ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

មាត្រា៤៖ សមាជិកអង្គការនយោបាយ និងកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តអំពើ៖

. ធ្វើសកម្មភាពអបគមន៍ [sic]

. បំផ្លាញរាជរដ្ឋាភិបាល

. បំផ្លាញអង្គការនៃអំណាចសាធារណៈ

. ញុះញង់ ឬបង្ខំពលរដ្ឋឱ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ ត្រូវចាត់ទុកជាជនឧក្រិដ្ឋ ប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់គុកពី២០ឆ្នាំ ទៅ៣០ឆ្នាំ ឬអស់មួយជីវិត។

មាត្រា៥៖ ច្បាប់នេះអនុគ្រោះទុកពេល៦ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធា នៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" វិលត្រឡប់មករួមរស់ក្រោមការ

គ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើស ដែលខ្លួនបានប្រព្រឹត្ត។

មាត្រា៦៖ ចំពោះមេដឹកនាំនៃ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ។

មាត្រា៧៖ ព្រះមហាក្សត្រ ទ្រង់អាចបន្ធូរបន្ថយទោស ឬលើកលែងទោស តាមព្រះរាជសិទ្ធិ ដែលមានចែងក្នុងមាត្រា២៧ នៃរដ្ឋធម្មនុញ្ញ។

មាត្រា៨៖ ក្រោយពីច្បាប់នេះចូលជាធរមានភ្លាម ទ្រព្យសម្បត្តិទាំងឡាយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬរបស់ជនល្មើសផ្សេងទៀត ហើយដែលបានមកពីការ បំបែក កាន់កាប់ទឹកដីមួយផ្នែក នៃព្រះរាជាណាចក្រកម្ពុជា ដោយរំលោភច្បាប់ និងយកធនធានធម្មជាតិ របស់ប្រជាជាតិ ទៅធ្វើអាជីវកម្ម ទ្រព្យសម្បត្តិទាំងឡាយនោះនឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ទោះបីជាស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬស្ថិតនៅក្រៅប្រទេស។

មាត្រា៩៖ ជនណាមួយដែលយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋ ដោយធ្វើការគំរាមកំហែង ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម ឬរំលោភលើលំនៅដ្ឋាន នឹងត្រូវផ្តន្ទាទោសដាក់គុកពី ពីរឆ្នាំទៅប្រាំឆ្នាំ។

អ្នកផ្តល់ព័ត៌មានមិនពិត អ្នកធ្វើសាក្សីភូតកុហក អ្នកក្លែងបង្កើតភស្តុតាង ដើម្បីបម្រើផលប្រយោជន៍ នៃការយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋ ត្រូវផ្តន្ទាទោសដាក់គុកពី ពីរឆ្នាំ ទៅប្រាំឆ្នាំ។

ប្រជាពលរដ្ឋរងគ្រោះដោយអយុត្តិធម៌ មានសិទ្ធិប្តឹងតវ៉ា ទារសំណង ដើម្បីជួសជុលការខូចខាតដែលបង្កើតឡើងពីការរំលោភសិទ្ធិខាងលើ។

១៨៥. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យដែលបានត្រាស់បង្គាប់ បានចែងថា៖

"យើង ព្រះបាទសម្តេចព្រះ នរោត្តមសីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី

[...]

ត្រាស់បង្គាប់

មាត្រា១៖ ត្រូវបានលើកលែងទោសឱ្យលោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស ក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និងចំពោះទោសដែលបានកំណត់ដោយ

ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ចុះថ្ងៃទី[១៥] ខែ កក្កដា ឆ្នាំ ១៩៩៤។

មាត្រា២៖ ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខនេះតទៅ។

មាត្រា៣៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេចជាស្ថាពរ"[៣៨៣]។

១៨៦. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង") ដែលមានចែងនូវបទប្បញ្ញត្តិដូចតទៅទាក់ទិននឹងសំណើ "លើកលែងទោស" នៅចំពោះមុខ អ.វ.ត.ក៖

<u>មាត្រា១១៖</u>

<u>ការលើកលែងទោស</u>

១. រាជរដ្ឋាភិបាលកម្ពុជា នឹងមិនស្នើសុំឱ្យមានការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោស អំពីឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ។

២. ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះ មានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ ១៩៧៩ ពីបទប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសម្រេចដោយ អង្គជំនុំជម្រះវិសាមញ្ញ[៣៨៤]។

---

[៣៨៣] ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ជាភាសាអង់គ្លេស ដែលបកប្រែពីឯកសារដើមជាភាសាខ្មែរដោយអង្គបុរេជំនុំជម្រះ ដោយមានជំនួយពីអ្នកបកប្រែដែលបានចាត់តាំងនៅអង្គជំនុំជម្រះ។ ការបកប្រែនេះដែលត្រូវបានប្រើប្រាស់ដោយអង្គបុរេជំនុំជម្រះ ក្នុងសាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន គឺមានលក្ខណៈខុសគ្នាពីឯកសារជាភាសាអង់គ្លេស ដែលមានក្នុងសំណុំរឿង ហើយដែលសហមេធាវីការពារក្តី អៀង សារី បានយោងនៅក្នុងបណ្តឹងឧទ្ធរណ៍។

[៣៨៤] កិច្ចព្រមព្រៀង មាត្រា១១(២)។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. PRÉLIMINAIRE

១៨៧. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ក៏មានចែងនៅក្នុងមាត្រា៤០ ថ្មី ផងដែរថា៖ "វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្តល់ឱ្យមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"[៣៨៥]។

១៨៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារ អៀង សារី ផ្អែកទៅលើក្រឹត្យច្បាប់ដែលបកប្រែជាភាសាអង់គ្លេស ដែលខុសពីឯកសារដែលប្រើប្រាស់ដោយអង្គបុរេជំនុំជម្រះ នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ដែលចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨[៣៨៦] និងបានបង្កើតឡើងវិញនៅខាងលើ។ ឯកសារបកប្រែប្រើប្រាស់ដោយ អៀង សារី ដែលជាការបកប្រែក្រៅផ្លូវការចេញផ្សាយតាមគេហទំព័រ អ.វ.ត.ក ប្រើពាក្យពេចន៍ "ការអនុគ្រោះទោស" នៅក្នុងប្រយោគទីមួយជំនួសឱ្យពាក្យ "ការលើកលែងទោស"។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ជាសាធារណៈរួចហើយ នៅក្នុងសាលដីការបស់ខ្លួនមួយថា នៅក្នុងឯកសារដើមជាភាសាខ្មែរ ពាក្យ "ការលើកលែងទោស" ត្រូវបានប្រើប្រាស់នៅក្នុងប្រយោគទីមួយផង និងនៅក្នុងផ្នែកទីពីរនៃក្រឹត្យច្បាប់នោះផងដែរ ដែលការប្រើប្រាស់បែបនេះ បាននាំឱ្យអង្គបុរេជំនុំជម្រះអនុម័តយកការបកប្រែតាមពាក្យ ដូចបង្ហាញពីខាងលើនេះ[៣៨៧]។ ចំពោះអត្ថន័យនៃពាក្យ "ការលើកលែងទោស" អង្គបុរេជំនុំជម្រះបានយល់ឃើញថា៖

> "អត្ថន័យនៃពាក្យ "លើកលែងទោស" មិនអាចកំណត់បានឡើយ ប្រសិនបើបកស្រាយដោយផ្អែកតាមវេយ្យាករណ៍។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការប្រើប្រាស់ពាក្យខ្មែរសម្រាប់ពាក្យ "លើកទោស" ត្រូវបានប្រើប្រាស់ផ្ទុយគ្នា។ ពាក្យថា "លើកលែងទោស" នៅក្នុងប្រយោគទី១ នៃមាត្រា១ គឺសរសេរថា "ការលើកលែងទោស" ប៉ុន្តែនៅក្នុងប្រយោគទី២ ពាក្យនេះសរសេរថា "លើកលែងទោសពីការចោទប្រកាន់"។ "ការលើកលែងទោស" និង "ការលើកលែងទោស

[៣៨៥] ច្បាប់ អ.វ.ត.ក មាត្រា៤០ ថ្មី។

[៣៨៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្នចំពោះ អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/73។

[៣៨៧] សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៥៧។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ពីការចោទប្រកាន់" ទាំងពីរនេះ ដែលបានចែងនៅក្នុងព្រះរាជក្រឹត្យ មានភាពផ្ទុយគ្នានឹងបទប្បញ្ញត្តិ ស្តីពីការលើកលែងទោសតាមមាត្រា២៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣[៣៨៨]។

១៨៩. សហមេធាវីការពារក្តី មិនបានដាក់សារណាស្នើណាមួយជាយុត្តិកម្មសម្រាប់អង្គបុរេជំនុំជម្រះពិនិត្យការបកប្រែភាសានៃព្រះរាជក្រឹត្យ និងការបកស្រាយចំពោះពាក្យពេចន៍ប្រើប្រាស់នៅក្នុងនោះទេ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងដោះស្រាយមូលដ្ឋានមួយនេះនៃបណ្តឹងឧទ្ធរណ៍ ដោយផ្អែកតាមការយល់ឃើញរបស់ខ្លួនពីមុន ដូចបង្ហាញពីខាងលើនេះ។

១៩០. សហមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា ការលើកលែងទោសទាំងពីរនេះរួមគ្នាបង្កើតបានជាឧបសគ្គដល់ការកាត់សេចក្តី អៀង សារី ដោយ អ.វ.ត.ក ពាក់ព័ន្ធនឹងបទចោទដែលមានចែងនៅក្នុងដីកាដំណោះស្រាយ។ ជាបឋម អង្គបុរេជំនុំជម្រះនឹងពិនិត្យលើការលើកលែងទោសឱ្យរួចពីការផ្តន្ទាទោសឆ្នាំ១៩៧៩។ បន្ទាប់មក អង្គបុរេជំនុំជម្រះនឹងវិភាគលើការលើកលែងទោសពីការចោទប្រកាន់ អនុលោមតាមច្បាប់ឆ្នាំ ១៩៩៤។

## ការលើកលែងទោសឱ្យរួចពីការផ្តន្ទាទោសឆ្នាំ ១៩៧៩

១៩១. បើទោះជាអត្ថន័យជាក់លាក់នៃពាក្យ "លើកលែងទោស" មិនមានភាពច្បាស់លាស់នៅក្នុងច្បាប់កម្ពុជាក៏ដោយ ក៏អត្ថបទនៃព្រះរាជក្រឹត្យបង្ហាញឱ្យឃើញថា ការលើកលែងទោសដែលត្រូវបានផ្តល់ឱ្យទៅ អៀង សារី (ដោយសន្មតថាការលើកលែងទោសនេះមានសុពលភាពត្រឹមត្រូវតាមច្បាប់) ធ្វើឡើងចំពោះការកាត់ទោសប្រហារជីវិត អៀង សារី និងរឹបអូសទ្រព្យសម្បត្តិរបស់គាត់ ដែលប្រកាសដោយតុលាការប្រជាជនបដិវត្តន៍ នៅក្នុងឆ្នាំ ១៩៧៩។ ផ្ទុយពីការលើកឡើងរបស់សហមេធាវីការពារក្តី មិនមានការបង្ហាញណាមួយដែលថា ការលើកលែងទោសគ្របដណ្តប់ "ការផ្តន្ទាទោសណាមួយ ដែលផ្អែកលើអំពើនានាដែលបានលើកឡើងនៅក្នុងសវនាការកាលពីឆ្នាំ ១៩៧៩"[៣៨៩] នោះទេ។

---

[៣៨៨] សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៥៧។

[៣៨៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ៩០។

១៩២. អង្គហេតុដែលថាទោសប្រហារជីវិតត្រូវបានលុបបំបាត់ចោល[៣៩០] នាពេលព្រះរាជទានព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះ មិនគាំទ្រដល់ការបកស្រាយនេះទេ។ ជាការពិត សហមេធាវីការពារក្ដី អៀង សារី មិនបានបង្ហាញ ឬក៏ពន្យល់ ថាតើមូលហេតុអ្វីទើបការលុបបំបាត់ទោសប្រហារជីវិត នាំឱ្យបុគ្គលដែលត្រូវទទួលការផ្ដន្ទាទោសប្រហារជីវិត អាចដើរហើរដោយសេរី ដោយមិនបាច់ទទួលទោសជាប់ពន្ធនាគារនោះ។ ការពិតបានបង្ហាញយ៉ាងច្បាស់ថា ទោសប្រហារជីវិតប្រាកដជាត្រូវបានប្រែមកជាទោសជាប់ពន្ធនាគារវិញហើយ ប្រសិនបើមិនដូច្នោះទេ បុគ្គលទាំងឡាយណាដែលត្រូវបានផ្ដន្ទាទោសប្រហារជីវិតពីបទប្រព្រឹត្តអំពើឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរនោះ ប្រាកដជាអាចរួចខ្លួនដោយសេរីភ្លាមៗមិនខាន។ សហមេធាវីការពារក្ដីក៏មើលរំលងផងដែរលើអង្គហេតុដែលថា ការកាត់ទោសឱ្យរឹបអូសទ្រព្យសម្បត្តិរបស់ អៀង សារី នៅមានអានុភាពនៅឡើយ ដែលការអះអាងបែបនេះ មានលក្ខណៈបញ្ច្រាសគ្នាជាមួយនឹងការអះអាងរបស់សហមេធាវីការពារក្ដីដែលថាការលើកលែងទោស នឹងមានលក្ខណៈ "មិនសំខាន់ទៀតទេ" ប្រសិនបើការលើកលែងទោសនោះ អនុវត្តតែចំពោះការកាត់ទោសដែលសម្រេចដោយតុលាការប្រជាជនបដិវត្តន៍។ ពិតហើយ ការបកស្រាយដែលធ្វើឡើងដោយសហមេធាវីការពារក្ដីចាត់ទុកការប្រកាសការលើកលែងទោស ចំពោះការកាត់ទោសឆ្នាំ ១៩៧៩ ថាជាការលើកលែងទោសលើការចោទប្រកាន់ចំពោះអំពើនានាដែលត្រូវបានជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩។ អត្ថន័យបែបនេះមិនមែនជាអត្ថន័យរបស់ព្រះរាជក្រឹត្យនោះទេ នៅពេលដែលយើងសំដៅទៅលើការលើកលែងទោសពីការចោទប្រកាន់នាពេលអនាគត ព្រោះអត្ថន័យនេះមានលក្ខណៈច្បាស់លាស់ថា វាគឺជាការលើកលែងទោសពីការចោទប្រកាន់ក្រោមច្បាប់ឆ្នាំ ១៩៩៤។

១៩៣. ដោយមិនបានឃើញពីភាពមិនស្របគ្នា ឬលទ្ធផលមិនប្រក្រតីណាមួយត្រូវបានបង្ហាញនោះ អង្គបុរេជំនុំជម្រះនឹងប្រើប្រាស់អត្ថន័យនៃពាក្យទាំងនេះទៅតាមន័យវេយ្យាករណ៍ និងន័យសាមញ្ញដែលប្រើនៅក្នុងព្រះរាជក្រឹត្យ ដោយសន្និដ្ឋានថា ការលើកលែងទោសឱ្យ អៀង សារី ត្រូវបានកម្រិតត្រឹមការកាត់ទោសជាក់លាក់ដែលត្រូវបានប្រកាសកាលពីឆ្នាំ១៩៧៩។ នៅក្នុងបរិបទដែលពាក់ព័ន្ធនឹងការកាត់ទោស អានុភាពតែមួយគត់នៃការលើកលែងទោសគឺ "លុបបំបាត់ចោល" និង

[៣៩០] របាយការណ៍របស់លោក អគ្គលេខាធិការ ផ្ញើជូនក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម, "ទោសប្រហារជីវិត និងការអនុវត្តនូវវិធានការការពារ ដែលធានានូវការការពារសិទ្ធិបុគ្គលទាំងឡាយណា ដែលត្រូវប្រឈមនឹងទោសប្រហារជីវិត" ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៩៥, UN doc. E/1995/78 ត្រង់កថាខណ្ឌ ៣៣៖ កម្ពុជាបានលុបបំបាត់ទោសប្រហារជីវិត ក្នុងឆ្នាំ ១៩៨៩។

"បំភ្លេចចោល" នូវការកាត់ទោសឆ្នាំ១៩៧៩ [៣៩១] ដើម្បីធានាឱ្យបានថា ការកាត់ឱ្យមានទោសនេះនឹងមិនមានអានុភាពនោះទេ។ ការលើកលែងទោស នេះមិនមានអានុភាពចំពោះលទ្ធភាពនៃការចាប់ផ្ដើមការចោទប្រកាន់ក្រោយៗទៀតទេ ដោយហេតុថាការលើកលែងទោសនោះ មិនពាក់ព័ន្ធទៅនឹង "អំពើនានា" ដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តឡើយ។

១៩៤. អង្គបុរេជំនុំជម្រះបានរកឃើញរួចមកហើយថា សវនាការនៅឆ្នាំ ១៩៧៩ និងការផ្ដន្ទាទោសដែលជាលទ្ធផលនៃដាក់ទោស និងប្រកាសទោសនោះ មិនរាំងខ្ទប់ដល់ដំណើរកិច្ចនីតិវិធីនាពេលបច្ចុប្បន្នដែលប្រឆាំងនឹង អៀង សារី ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ។ ដោយពិចារណាថា ការលើកលែងទោសត្រូវបានភ្ជាប់ជាមួយនឹងការកាត់ទោសដោយគ្មានសុពលភាពនៅក្នុង ឆ្នាំ១៩៧៩ ការលើកលែងទោសនេះមិនមានអានុភាពលើយុត្តាធិការរបស់ អ.វ.ត.ក ដើម្បីជំនុំជម្រះក្ដីលើ អៀង សារី ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ។

## <u>ការលើកលែងទោសពីការចោទប្រកាន់ក្រោមច្បាប់ឆ្នាំ ១៩៩៤</u>

១៩៥. នៅក្នុងសាលដីការបស់ខ្លួនមួយ ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន អង្គបុរេជំនុំជម្រះបានសម្រេចរួចមកហើយថា ការលើកលែងទោសទីពីរ "អាចត្រូវបានបកស្រាយថាមានន័យថា ជនជាប់ចោទ 'នឹងមិនត្រូវចោទប្រកាន់' ពាក់ព័ន្ធនឹងការកាត់ទោសដែលសម្រេចហើយនោះ ឬការរំលោភបំពានលើ [ច្បាប់ឆ្នាំ ១៩៩៤] ឡើយ"។ ដោយផ្អែកលើមូលដ្ឋានបឋមមួយ អង្គបុរេជំនុំជម្រះក៏បានសម្រេចផងដែរថា "បទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ មិនស្ថិតនៅក្រោម

---

[៣៩១] ដើម្បីសម្រេចលើអានុភាពនៃការលើកលែងទោសលើការកាត់ឱ្យមានទោស អង្គបុរេជំនុំជម្រះស្វែងរកការណែនាំពីសេចក្ដីសម្រេចនៅតុលាការពិសេសសម្រាប់ប្រទេស សៀរ៉ាឡេអូន ក្នុងសំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង កាឡុន (Kallon)* ដែលក្នុងសំណុំរឿងនេះអង្គជំនុំជម្រះតុលាការជាន់ខ្ពស់ពិចារណាថា ការលើកលែងទោសគឺជា "*អំពើអធិបតេយ្យនៃការបំភ្លេចចោល*នូវអំពើពីអតីតកាល ដែលត្រូវបានផ្ដល់ដោយរដ្ឋាភិបាលណាមួយ ឱ្យទៅជនទាំងឡាយណា (ឬបុគ្គលជាក់លាក់មួយចំនួន) ដែលមានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋ ឬបទល្មើស" ហើយ "<u>ការលើកលែងទោសគឺជាការបំភ្លេចចោល និងភាពភ្លេចភ្លាំងអំពីបទល្មើស</u>" (*សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង កាឡុន(Kallon)* លេខ SCSL-04-15-AR72 (E) និង *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង កាម៉ារ៉ា (Kamara)* លេខ SCSL-04-16-AR72 (E) សាលដីកាលើការជំទាស់លើយុត្តាធិការ៖ កិច្ចព្រមព្រៀងលើកលែងទោសឱ្យ ឡូមេ (Lomé) របស់អង្គជំនុំជម្រះតុលាការជាន់ខ្ពស់ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ៦៦ (បញ្ជាក់បន្ថែម))។

សមត្ថកិច្ចរបស់ អ.វ.ត.ក ឡើយ"[៣៩២]។ សម្រាប់សំអាងហេតុដូចមានចែងខាងក្រោមនេះ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ជាថ្មីម្តងទៀតលើសេចក្តីសន្និដ្ឋានបឋមរបស់ខ្លួន។

១៩៦. ច្បាប់ឆ្នាំ ១៩៩៤ ត្រូវបានអនុម័តក្រោយពីក្រុម "កម្ពុជាប្រជាធិបតេយ្យ" ត្រូវបានចោទប្រកាន់ថាមិនគោរពទៅតាមកិច្ចព្រមព្រៀងនានា ស្តីពីដំណោះស្រាយនយោបាយពេញលេញនៃជម្លោះកម្ពុជា ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ដែលគេស្គាល់ថាជា "កិច្ចព្រមព្រៀងទីក្រុងបារីស" ហើយដែលត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីសន្តិភាព និងការផ្សះផ្សាជាតិនៅក្នុងបរិបទសង្គ្រាមស៊ីវិលដែលបានបន្តកើតឡើង បន្ទាប់ពីការផ្តួលរំលំរបបខ្មែរក្រហមដោយកងកម្លាំងវៀតណាម[៣៩៣]។ ច្បាប់នេះប្រកាសដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" និងកងកម្លាំងប្រដាប់អាវុធរបស់ក្រុមនេះឱ្យនៅ "ក្រៅច្បាប់"[៣៩៤] ហើយបញ្ជាឱ្យរឹបអូស រាល់ទ្រព្យសម្បត្តិរបស់ក្រុមនេះទាំងអស់ដែលត្រូវបានទទួលក្នុងកាលៈទេសៈជាក់លាក់មួយចំនួន[៣៩៥]។ តាមការសន្មតថាក្រុមកម្ពុជាប្រជាធិបតេយ្យបានរំលោភបំពានលើរដ្ឋធម្មនុញ្ញ[៣៩៦] ច្បាប់ឆ្នាំ១៩៩៤ កំណត់ការផ្តន្ទាទោសចំពោះបទល្មើសមួយជំពូកជាក់លាក់ដែលមានដូចជា បទល្មើសប្រឆាំងនឹងសន្តិសុខផ្ទៃក្នុងប្រទេសដែលត្រូវបានកំណត់ថាជា "បទល្មើសអបគមន៍", ការបំផ្លាញរាជរដ្ឋាភិបាល, ការបំផ្លាញអង្គការនៃអំណាចសាធារណៈ ឬការញុះញង់ ឬបង្ខិតបង្ខំពលរដ្ឋឱ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ។ អំពើទាំងនេះត្រូវទទួលការផ្តន្ទាទោសជាក់លាក់មួយចំនួន[៣៩៧]។

១៩៧. បើទោះជាមិនមានភាពច្បាស់លាស់ទាំងស្រុង ថាតើបទល្មើសជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" អាចកំណត់ជាបទល្មើសនៅក្រោមច្បាប់ឆ្នាំ១៩៩៤ (មាត្រា១ និង២) បានដែរឬអត់នោះ ក៏មិនមានការបង្ហាញណាមួយដែលថា ការចោទប្រកាន់ទៅ

---

[៣៩២] សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៦១។

[៣៩៣] ច្បាប់ឆ្នាំ ១៩៩៤ អារម្ភកថា។

[៣៩៤] ច្បាប់ឆ្នាំ ១៩៩៤ មាត្រា១ និងមាត្រា២ ក៏បានចែងថា សមាជិកទាំងឡាយរបស់ក្រុមកម្ពុជាប្រជាធិបតេយ្យ ត្រូវចាត់ទុកជាជនល្មើស នឹងរដ្ឋធម្មនុញ្ញ និងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

[៣៩៥] ច្បាប់ឆ្នាំ ១៩៩៤ មាត្រា៨។

[៣៩៦] ច្បាប់ឆ្នាំ ១៩៩៤ អារម្ភកថា, កថាខណ្ឌ៦។

[៣៩៧] ច្បាប់ឆ្នាំ ១៩៩៤ មាត្រា៤។

លើបទឧក្រិដ្ឋដទៃទៀត នឹងត្រូវបញ្ឈប់មិនឲ្យមានការចោទប្រកាន់ តាមក្រមព្រហ្មទណ្ឌដែលចូលជាធរមានរួចមកហើយនោះដែរ។ ម្យ៉ាងវិញទៀត ច្បាប់ឆ្នាំ ១៩៩៤ បានបង្កើតនូវបទល្មើសថ្មីៗ ព្រមទាំងការផ្តន្ទាទោសនានា ដែលត្រូវពិចារណាលើបរិបទជាក់ស្តែង ដូចដែលបានបង្ហាញពីខាងលើរួចមកហើយ ប៉ុន្តែច្បាប់នេះមិនបានបង្កើតនូវរបបក្រមព្រហ្មទណ្ឌស្វយ័តមួយ ដើម្បីចោទប្រកាន់ទៅលើក្រុមកម្ពុជាប្រជាធិបតេយ្យ ចំពោះបទឧក្រិដ្ឋណាមួយដែលស្ថិតក្រោមក្រមព្រហ្មទណ្ឌដែលនៅជាធរមាននោះទេ។ ការចោទប្រកាន់ទៅលើបទល្មើសដែលមិនអាចកំណត់ថាជាបទល្មើសតាមច្បាប់ឆ្នាំ១៩៩៤ ទោះបីជាអំពើនោះត្រូវបានធ្វើឡើង ដោយក្រុមកម្ពុជាប្រជាធិបតេយ្យ ឬក៏មិនមែនក៏ដោយ ក៏ការចោទប្រកាន់នោះនៅតែអាស្រ័យទៅលើច្បាប់ដែលនៅជាធរមាន។

១៩៨. សាលក្រមរបស់សាលាឧទ្ធរណ៍កម្ពុជា នៅក្នុងសំណុំរឿង ឈូក រិន មិនបានគាំទ្រដល់ការបកស្រាយផ្សេង ដូចអ្វីដែលសហមេធាវីការពារក្តីបានលើកជាទឡ្ហីករណ៍នោះឡើយ។ ផ្ទុយពីការលើកឡើងរបស់សហមេធាវីការពារក្តី សាលាឧទ្ធរណ៍មិនបានសម្រេចថា ច្បាប់ឆ្នាំ ១៩៩៤ អនុវត្តបានទាំងស្រុងចំពោះរាល់បទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តដោយសមាជិកក្រុមកម្ពុជាប្រជាធិបតេយ្យ ដោយមិនគិតពីប្រភពនោះឡើយ ហើយក៏មិនបានសម្រេចថា អាចអនុវត្តចំពោះតែបទឧក្រិដ្ឋដែលបានប្រព្រឹត្តមុនពេលអនុម័តច្បាប់នោះដែរ។ អ្វីដែលសាលាឧទ្ធរណ៍បានសម្រេចគឺថា បទប្បញ្ញត្តិទាក់ទិនការលើកលែងទោស គឺមាត្រា៥ នៃច្បាប់នោះ មិនអាចអនុវត្តបានចំពោះសំណុំរឿងដែលកំពុងស្ថិតនៅក្នុងដៃសាលាឧទ្ធរណ៍បានឡើយ ព្រោះបញ្ញត្តិនេះគ្របដណ្តប់តែលើបទល្មើសដែលបានប្រព្រឹត្តមុនច្បាប់នេះចូលជាធរមានប៉ុណ្ណោះ[៣៩៨]។

១៩៩. បទល្មើសដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្លូវសាសនា ដែលជាបទល្មើសជាតិ មិនអាចកំណត់ជាបទល្មើសតាមច្បាប់ឆ្នាំ ១៩៩៤ បានឡើយ ដូច្នេះឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ដែលនៅជាធរមាន ទាំងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ បើទោះបីជាអំពើទាំងនោះត្រូវបានប្រព្រឹត្តដោយសមាជិកនៃក្រុមកម្ពុជាប្រជាធិបតេយ្យដែលរងការចោទប្រកាន់ក៏ដោយ។

[៣៩៨] សាលាឧទ្ធរណ៍ក្រុងភ្នំពេញ, រឿងក្តីព្រហ្មទណ្ឌលេខ ៤៦៣/១៧.១០.២០០០ “សាលក្រមរបស់តុលាការសាលាឧទ្ធរណ៍” ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ ទំព័រ២៣។



អង្គជំនុំជម្រះសាលាដំបូង
PRE-TRIAL CHAMBER
E.C.C.C.
PRÉLIMINAIRE

២០០. តាមរយៈការអានយ៉ាងសាមញ្ញលើព្រះរាជក្រឹត្យ ព្រមគ្នាជាមួយនឹងច្បាប់ឆ្នាំ ១៩៩៤ អង្គបុរេជំនុំជម្រះអាចទាញនូវការសន្និដ្ឋានបានថា ការលើកលែងទោស ក្នុងករណី អៀង សារី អាចរារាំងមិនឱ្យមានការជំនុំជម្រះគាត់តែទៅលើបទល្មើសប្រឆាំងសន្តិសុខរដ្ឋ ដូចមានចែងក្នុងមាត្រា៤ ហើយប្រហែលជាអាចរារាំងទៅលើបទល្មើស នៃសមាជិកភាពក្នុងក្រុមកម្ពុជាប្រជាធិបតេយ្យ ដោយសន្មតថា បទល្មើសទាំងនោះអាចផ្តន្ទាទោសបានតាមរយៈមាត្រា១ និងមាត្រា២។ មិនមានចំណុចណាមួយដែលបង្ហាញថាព្រះរាជក្រឹត្យនេះត្រូវគ្របដណ្តប់ទៅលើបទល្មើសនានាដែល អៀង សារី បានប្រព្រឹត្ត ដោយមិនគិតអំពីប្រភពរបស់អំពើនោះឡើយ។ ហើយក៏មិនមានចំណុចណាមួយបង្ហាញថា ព្រះរាជក្រឹត្យនេះមានចេតនាគ្របដណ្តប់ទៅលើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។

២០១. ការបកស្រាយទៅលើព្រះរាជក្រឹត្យដែលធ្វើឡើងដោយសហមេធាវីការពារក្តី អៀង សារី ដែលថាបានផ្តល់ការលើកលែងទោសចំពោះ អៀង សារី លើគ្រប់បទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ដោយរួមទាំងឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ មិនត្រឹមតែងាកចេញពីអត្ថបទនៃព្រះរាជក្រឹត្យ ព្រមទាំងច្បាប់ឆ្នាំ ១៩៩៤ ប៉ុណ្ណោះទេ តែការបកស្រាយបែបនេះគឺខុសទាំងស្រុងពីកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជា។ ក្នុងករណីដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ការផ្តល់នូវការលើកលែងទោស ដោយមិនបានធ្វើការជំនុំជម្រះ និងផ្តន្ទាទោសនោះ នឹងនាំដល់ការមិនគោរពតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះសន្ធិសញ្ញា ក្នុងការជំនុំជម្រះ និងផ្តន្ទាទោសចំពោះអ្នករៀបចំបង្កើតបទល្មើសទាំងនោះ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ[៣៩៩] អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម[៤០០] និងអនុសញ្ញាទី៤ ទីក្រុងហ្សឺណែវ[៤០១]។

---

[៣៩៩] អនុសញ្ញាស្តីពីការរារាំង និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា១ និង ៥ (កម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ ១៩៥០)។

[៤០០] អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬប្រព្រឹត្តិដោយសាហាវព្រៃផ្សៃ អមនុស្សធម៌ និងបន្ទាបបន្ថោក, ឯកសារ លេខ 1465 U.N.T.S. 85 (បើកចំហរឱ្យចុះហត្ថលេខា នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ និងចូលជាធរមាន នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧) ("សន្ធិសញ្ញាប្រឆាំងការធ្វើទារុណកម្ម") មាត្រា៤ និង៥ (កម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៩២)។

[៤០២] ប្រទេសកម្ពុជាដែលបានផ្តល់សច្ចាប័នទៅលើ ICCPR ក៏មានកាតព្វកិច្ចធានាថាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យគឺសំដៅដល់ការបង្កនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ត្រូវទទួលបាននូវការជួសជុលប្រកបដោយប្រសិទ្ធភាព[៤០៣]។ ជាទូទៅកាតព្វកិច្ចទាំងនេះតម្រូវឲ្យរដ្ឋធ្វើការជំនុំជម្រះ និងផ្តន្ទាទោសលើអ្នករៀបចំបង្កើតបទឧក្រិដ្ឋនេះ[៤០៤]។ ការផ្តល់នូវការលើកលែងទោស ដែលមានន័យថាជាការលុបបំបាត់ និងបំភ្លេចចោលនូវ

---

[៤០១] អនុសញ្ញាទី៣ ទាក់ទងនឹងការប្រព្រឹត្តិចំពោះឈ្លើយសឹក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៩, ឯកសារលេខ 75 U.N.T.S. 135 (បើកចំហរឲ្យចុះហត្ថលេខា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងចូលជាធរមាន នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៥១) (កម្ពុជាបានផ្តល់ សច្ចាបន នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨) ("អនុញ្ញាទីក្រុងហ្សឺណែវទី៣") មាត្រា១២៩។ អនុសញ្ញាទី៤ ទាក់ទិននឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៩, ឯកសារលេខ 75 U.N.T.S. 287 (បើកចំហរឲ្យចុះហត្ថលេខា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងចូលជាធរមាន នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៥១) (កម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨) ("អនុសញ្ញាទីក្រុងហ្សឺណែវទី៤") មាត្រា១៤៦ ។ សូមមើលផងដែរ៖ Jean Pictet (និងអ្នកឯទៀត) វិចារណកថា អនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែ សីហា ឆ្នាំ ១៩៤៩, អនុសញ្ញាទី៤ ទីក្រុងហ្សឺណែវ ទាក់ទិននឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម។ គណៈកម្មការអន្តរជាតិកាក-បាទក្រហម ឆ្នាំ១៩៥៨ ទំព័រ១៦០ (កាតព្វកិច្ចក្នុងការផ្តន្ទាទោសលើអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលមានន័យ "ប្រាកដ" ថារដ្ឋជាភាគី ទោះជាក្នុងកាលៈទេសៈណាក៏ដោយ មិនអាចគេចវេសពីការបំពេញកាតព្វកិច្ចបែបនេះ ដោយការផ្តល់នូវអភ័យឯកសិទ្ធិតាមរយៈមធ្យោ-បាយច្បាប់អនុគ្រោះទោស)។

[៤០២] សូមមើលឧទាហរណ៍ រដ្ឋអាជ្ញា តទល់និង Kallon, SCSL-04-15-AR72 (E) និង Kamara, SCSL-04-16-AR72 (E) "សេចក្តីសម្រេចលើការជំទាស់លើយុត្តាធិការ៖ កិច្ចព្រមព្រៀងអនុគ្រោះទោស Lomé, អង្គជំនុំជម្រះតុលាការជាន់ខ្ពស់ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ៧៣ ("មិនមានភាពលំបាកក្នុងការឯកភាពជាមួយនឹងសារណា ដែលបានដាក់ដោយអ្នកមិនមែនជាភាគីនៃរឿងក្តី គឺសាស្ត្រាចារ្យ Orentlicher ហើយកែតម្រូវថា ដោយផ្អែកលើកាតព្វកិច្ចនៃសន្ធិសញ្ញា ក្នុងការជំនុំជម្រះ ឬធ្វើបត្យាប័នជនល្មើសនោះ ការផ្តល់នូវការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋដូចមានចែងក្នុងមាត្រា២ ដល់មាត្រា៤ នៃលក្ខន្តិកៈតុលាការមិនគ្រាន់តែមិនសមស្របប៉ុណ្ណោះទេ តែវាក៏ជាការរំលោភទៅលើកាតព្វកិច្ចរបស់រដ្ឋចំពោះសហគមន៍អន្តរជាតិទាំងមូលតែម្តង។")។

[៤០៣] មាត្រា២(៣) នៃ ICCPR បានចែងថា "រដ្ឋជាភាគីនីមួយៗនៃកតិកាសញ្ញាដែលនៅជាធរមានត្រូវ៖ (ក) ធានាថា បុគ្គលទាំងឡាយដែលសិទ្ធិ និងសេរីភាពរបស់ខ្លួនត្រូវបានទទួលស្គាល់នៅទីនេះ តែសិទ្ធិនិងសេរីភាពទាំងនោះត្រូវបានគេរំលោភបំពាន ត្រូវទទួលបាននូវ*ការជួសជុលដ៏មានប្រសិទ្ធភាព* ដោយមិនគិតដល់ការដែលជនរំលោភបំពាននោះបានប្រព្រឹត្តក្នុងតួនាទីផ្លូវការនោះឡើយ" (គូសបញ្ជាក់បន្ថែម)។

[៤០៤] IACtHr, *រឿងក្តី Velázquez Rodriguez* "សេចក្តីសម្រេច និងសាលក្រម" ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ កថាខណ្ឌ ១៧៦ ("រដ្ឋមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតទៅលើគ្រប់ស្ថានការណ៍ទាំងអស់ ដែលពាក់ព័ន្ធនឹងការរំលោភបំពានលើសិទ្ធិដែលបានការពារដោយអនុសញ្ញា។ ករណីដែលក្បាលម៉ាស៊ីនរដ្ឋបានប្រព្រឹត្តនូវការរំលោភបំពាន ហើយបានរួចផុតពីការផ្តន្ទាទោស ឯជនរងគ្រោះមិនទទួលបាននូវការជួសជុល ព្រមទាំងផ្តល់នូវសិទ្ធិពេញលេញនោះទេ មានន័យថារដ្ឋមិនបានគោរពតាមតួនាទីរបស់ខ្លួនក្នុងការធានាដល់ការប្រើប្រាស់ដោយសេរី និងពេញលេញនូវសិទ្ធិរបស់ប្រជាជនដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន។

បទល្មើស[៤០៥] ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងមិនគោរពតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ចំពោះ ICCPR ដែលត្រូវជំនុំជម្រះ និងផ្តន្ទាទោស ចំពោះអ្នករៀបចំបង្កើតអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ឬក៏ការផ្តល់នូវការជួសជុលប្រកបដោយប្រសិទ្ធភាពចំពោះជនរងគ្រោះផងដែរ[៤០៦]។ ដោយសារតែមិនមានចំណុចណាមួយដែលបង្ហាញថា ព្រះមហាក្សត្រ (និងបុគ្គលនានាដែលបានពាក់ព័ន្ធ) មានព្រះរាជបំណង/បំណង មិនគោរពតាមកាតព្វកិច្ចជាអន្តរជាតិរបស់

---

លក្ខណៈដូចគ្នានេះនឹងកើតឡើង ប្រសិនបើរដ្ឋអនុញ្ញាតឱ្យបុគ្គល ឬក្រុមឯកជនណាមួយ អនុវត្តដោយសេរី ដោយមានអភ័យឯកសិទ្ធិ ដែលអំពើរបស់ពួកគេធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដែលបានទទួលស្គាល់ដោយអនុសញ្ញា។" (គូសបញ្ជាក់បន្ថែម) សៀវភៅរបស់ Diane Orentlicher ដែលមានចំណងជើងថា "Settling Accounts: The Duty to Presecute Human Right Violation of a Prior Regime," 100 *Yale L.J.* 2537 (1990-1991) ត្រង់២៥៦៨ ដល់២៥៨២។ សូមមើលផងដែរនូវឯកសារយោង ដែលបានដកស្រង់ក្នុងជើងទំព័របន្តបន្ទាប់ទៀត។

[៤០៥] រដ្ឋអាជ្ញា តទល់និង Kallon, SCSL-04-15-AR72 (E) និង Kamara, SCSL-04-16-AR72 (E) "សេចក្តីសម្រេចលើការជំទាស់លើយុត្តាធិការ៖ កិច្ចព្រមព្រៀងអនុគ្រោះទោស Lomé, អង្គជំនុះជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ៦៦។ ម្តងទៀត៖ ការដកស្រង់ចេញពី Blacks Law Dictionary.

[៤០៦] រដ្ឋអាជ្ញា តទល់ Furundzija IT-95-17/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៥៥ (អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY សម្រេចថា ការដែលរដ្ឋបានផ្តល់នូវការអនុគ្រោះទោស ចំពោះបទល្មើសធ្វើទារុណកម្ម ដែលជាបទល្មើស *អាជ្ញាបញ្ញា* នឹងរំលោភបំពានទៅលើកាតព្វកិច្ចជាអន្តរជាតិរបស់រដ្ឋនោះ)។ គណៈកម្មាការសិទ្ធិមនុស្ស យោបល់ទូទៅ លេខ២០៖ ជំនួសដល់យោបល់ទូទៅ លេខ៧ ទាក់ទិននឹងការហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មសាហាវព្រៃផ្សៃ *(មាត្រា៧)* ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ កថាខណ្ឌ១៥ ("គណៈកម្មាការបានកត់សម្គាល់ថា រដ្ឋមួយចំនួនបានផ្តល់នូវការអនុគ្រោះទោសចំពោះអំពើធ្វើទារុណកម្ម។ *ជាទូទៅ ការអនុគ្រោះទោសគឺប្រឆាំងទៅនឹងតួនាទីរបស់រដ្ឋក្នុងការស៊ើបអង្កេតលើអំពើបែបនោះ ធ្វើដូច្នេះដើម្បីធានាថាមិនមានអំពើបែបនេះនៅក្នុងយុត្តាធិការរបស់ខ្លួន និងធានាថាអំពើបែបនេះនឹងមិនកើតមានឡើងក្នុងពេលអនាគត។ រដ្ឋមិនអាចដកហូតសិទ្ធិទទួលបាននូវការជួសជុលប្រកបដោយប្រសិទ្ធភាពពីបុគ្គលនានាបានឡើយ* ដែលការជួសជុលនោះរួមបញ្ចូលការទូទាត់សង ព្រមទាំងការស្តារនីតិសម្បទាទាំងស្រុងឡើងវិញ តាមដែលអាចធ្វើទៅបាន។ (គូសបញ្ជាក់បន្ថែម); IACtHR រឿងក្តី*Barrios Altos* "សាលក្រម" ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៤១ ដល់៤៤ (ករណីដែល IACtHR បានរកឃើញថាការអនុគ្រោះទោស ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនោះ គឺផ្ទុយទៅនឹងអនុសញ្ញា) ECtHR *Ould Dah c. France* សំណើសុំលេខ១៣១១៣/០៣ "សាលក្រម" ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ១៦ ដល់១៧ (ករណីដែល ECtHR បានរកឃើញថា ការអនុគ្រោះទោស ជាទូទៅប្រឆាំងនឹងតួនាទីរបស់រដ្ឋក្នុងការស៊ើបអង្កេតលើអំពើធ្វើទារុណកម្ម); សាស្ត្រាចារ្យ Antonio Cassese, សៀវភៅក្រោមចំណងជើងថា *International Criminal Law,* Oxford University Press ឆ្នាំ២០០៣ ទំព័រ៣១៣ (ជំទាស់ថា កាតព្វកិច្ចជាទូទៅរបស់រដ្ឋគឺត្រូវធានាថា ការប្រើប្រាស់នូវសិទ្ធិជាមូលដ្ឋាន គឺប្រឆាំងនឹងអំពើនិទ្ទណ្ឌភាព ឬការបិទបាំងលើការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ។

ប្រទេសកម្ពុជាក្នុងពេលចេញព្រះរាជក្រឹត្យនោះ ទើបការបកស្រាយរបស់សហមេធាវីការពារក្តីចំពោះឯកសារមួយនេះ ជាការបកស្រាយដោយគ្មានមូលដ្ឋាន។

២០២. មូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធចោល។

### ៣. មូលដ្ឋានទីបី៖ (គោលការណ៍នីត្យានុកូលភាព)
### សេចក្តីសង្ខេបសារណារបស់សហមេធាវីការពារក្តីអៀង សារី

២០៣. សហមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយលើកឡើងថា អ.វ.ត.ក អាចអនុវត្តនូវបទល្មើសព្រហ្មទណ្ឌ និងទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិបាន ព្រោះច្បាប់ អ.វ.ត.ក បានចែងពីការអនុវត្តលើចំណុចទាំងនេះ ហើយការសម្រេចលើឋានៈរបស់ អ.វ.ត.ក ថាជាតុលាការជាតិ ឬតុលាការអន្តរជាតិនោះ គឺមិនពាក់ព័ន្ធនឹងបញ្ហានេះទេ។ សហមេធាវីការពារក្តីបានថ្លែងថា ច្បាប់ អ.វ.ត.ក បានរំលោភលើគោលការណ៍នីត្យានុកូលភាព[៤០៧] ដោយការធ្វើកំណត់ជាប្រតិសកម្មថាអំពើណាមួយគឺជាបទល្មើស ដែលអំពើនោះមិនមែនជាបទល្មើសនៅក្នុងប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[៤០៨]។

២០៤. សហមេធាវីការពារក្តីបានលើកឡើងថា ឋានៈនៃ អ.វ.ត.ក ជាតុលាការជាតិ ឬតុលាការអន្តរជាតិគឺជាបញ្ហាទាក់ទិនមួយ ព្រោះបទដ្ឋានសម្រាប់គោលការណ៍នីត្យានុកូលភាព ត្រូវបានអនុវត្តខុសៗគ្នា[៤០៩]។ សហមេធាវីការពារក្តីបានបង្ហាញថា ដោយសារតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋ-កម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងទម្រង់នៃការទទួលខុសត្រូវដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺមិនមានក្នុងច្បាប់កម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ "វាមានភាពចាំបាច់ដើម្បីធ្វើការសម្រេចថាតើអនុសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់ ជាច្បាប់កម្ពុជានៅក្នុងអំឡុង

---

[៤០៧] សូមកត់សម្គាល់ថា ពាក្យ "Principle of legality" (គោលការណ៍នីត្យានុកូលភាព) អាចហៅម្យ៉ាងទៀតថាជា "*nullum crimen sine lege.*" (គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង)។

[៤០៨] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១០៣។

[៤០៩] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១០៦ និង១០៩។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានដែរឬទេ”[៦១០]។ សហមេធាវីការពារក្តីបានជំទាស់បន្ថែមទៀតថា ច្បាប់អន្តរជាតិមិនអាចយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជានោះទេ ពីព្រោះប្រទេសកម្ពុជាគោរពតាមប្រព័ន្ធទ្វិកនិយម (dualist) ដែលផ្ទុយពីប្រព័ន្ធឯកនិយម (monist) ក្នុងយន្តការរបស់ខ្លួន ដើម្បីអនុវត្តច្បាប់អន្តរជាតិទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួន”។ ដូច្នេះហើយទើបច្បាប់អន្តរជាតិអាចយកមកអនុវត្តបាន តែក្នុងករណីដែលការអនុវត្តដោយផ្ទាល់ត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយរដ្ឋធម្មនុញ្ញ ឬដោយការបញ្ចូលច្បាប់អន្តរជាតិ ទៅក្នុងប្រព័ន្ធច្បាប់ជាតិតែប៉ុណ្ណោះ។ សហមេធាវីការពារក្តីបានអះអាងបន្ថែមថា នៅពេលដែលអនុសញ្ញាមិនទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិនៅឡើយទេនោះ អនុសញ្ញានោះត្រូវតែជាអនុសញ្ញាដែលមានអានុភាពដោយខ្លួនឯង ទើបអាចយកមកអនុវត្តដោយផ្ទាល់បាន[៦១១]។ សហមេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា ដោយសារតែក្នុងអំឡុងពេលដែលបទល្មើសរងការចោទបានកើតឡើង ប្រទេសកម្ពុជាមិនមានច្បាប់ជាតិដែលនៅជាធរមានណាមួយសម្រាប់អនុវត្ត ហើយក៏មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាដែលអនុញ្ញាតឱ្យអនុវត្តនោះ ទើបអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាទីក្រុងហ្សឺណែវ មិនអាចប្រើជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ នៅក្នុងតុលាការក្នុងស្រុកកម្ពុជាបានឡើយ ដោយរួមបញ្ចូលទាំង អ.វ.ត.ក ផង ព្រោះការអនុវត្តបែបនេះជាការរំលោភទៅលើគោលការណ៍នីត្យានុកូលភាព ដោយសារតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ មិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែលតុលាការកម្ពុជាមានយុត្តាធិការទៅលើ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ[៦១២]។

២០៥. សហមេធាវីការពារក្តីបានលើកឡើងបន្តថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជាបានទេ ព្រោះប្រទេសកម្ពុជាអនុវត្តប្រព័ន្ធទ្វិកនិយម ក្នុងយន្តការរបស់ខ្លួនក្នុងការអនុវត្តច្បាប់អន្តរជាតិ នៅក្នុងប្រព័ន្ធច្បាប់ជាតិ[៦១៣]។ សហមេធាវីការពារក្តីបន្ថែម

[៦១០] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ១១០។

[៦១១] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១១១ ដល់១១៤។

[៦១២] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១១៥ ដល់១២០។

[៦១៣] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១២១ ដល់១២៥។

ថា ឋានៈ*អាជ្ញាបញ្ញា*នៃបទល្មើសអន្តរជាតិមិនអាចផ្លាស់ប្តូរការពិតដែលថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចអនុវត្តដោយផ្ទាល់ នៅក្នុងតុលាការកម្ពុជាបាននោះឡើយ[៤១៤]។

២០៦. ដោយលើកឡើងផ្ទុយមកវិញ សហមេធាវីការពារក្តីបានថ្លែងថា ទោះបីកម្ពុជាអាចអនុវត្តដោយផ្ទាល់នូវអនុសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏នៅមានលក្ខខណ្ឌតម្រូវបន្ថែមពីរទៀតដែលត្រូវបំពេញជាចាំបាច់ ដើម្បីឱ្យស្របនឹងគោលការណ៍នីត្យានុកូលភាពគឺ៖ ក) ជនត្រូវចោទត្រូវតែបានដឹងអំពីច្បាប់ដែលកំណត់អំពើដែលពាក់ព័ន្ធជាបទល្មើស និង ខ) ជនត្រូវចោទត្រូវតែអាចប្រមើលមើលដឹងយ៉ាងច្បាស់លាស់ថាអំពើរបស់ខ្លួនគឺប្រាកដជាតម្រូវឱ្យគាត់ទទួលខុសត្រូវព្រហ្មទណ្ឌ[៤១៥]។ យោងទៅលើកថាខណ្ឌ១៣០៥ ដល់១៣០៧ នៃដីកាដំណោះស្រាយ សហមេធាវីការពារក្តីសន្និដ្ឋានថា៖

> សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយយល់ឃើញថា លោក អៀង សារី ពិតជាបានដឹងយ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរ ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំ និងគាត់ពិតជាបានដឹងយ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ "តាមរយៈការជំនុំជម្រះនានាដែលបានធ្វើឡើង បន្ទាប់ពីសង្គ្រាមលោកលើកទី២ នៅទីក្រុង Nuremburg និងទីក្រុងតូក្យូ ជាដើម"។ ក.ស.ច.ស ក៏ភ័ន្តច្រឡំដោយយល់ឃើញថា៖
>
> > ក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងច្បាប់បង្កើត អ.វ.ត.ក ក៏មានទម្រង់នៃការទទួលខុសត្រូវមួយចំនួន ត្រូវបានទទួលស្គាល់ផងដែរ តាមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ដូចមានបញ្ជាក់ខាងក្រោមនេះ ហេតុដូច្នេះទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ ដល់ជនត្រូវចោទ។ ចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ដូចជាសហឧក្រិដ្ឋកម្មរួម ការញុះញង់ និងការទទួលខុសត្រូវថ្នាក់លើ ក៏ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិ ឆ្លងតាមការជំនុំជម្រះនានាដែលត្រូវបានរៀបចំឡើង បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះទម្រង់នៃការទទួលខុសត្រូវទាំងនេះ ត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

---

[៤១៤] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១២៦ ដល់១២៩។

[៤១៥] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ១៣០ ដល់១៣៥។

លោក អៀង សារី មិនអាចព្យាករណ៍ជាមុនបានទេថា រូបគាត់អាចនឹងត្រូវបានជំនុំជម្រះក្ដីដោយតុលាការជាតិពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងទម្រង់នៃការទទួលខុសត្រូវ ដែលគ្មានចែងក្នុងច្បាប់ជាតិរបស់កម្ពុជា នៅពេលដែលអង្គហេតុបានកើតឡើងឡើយ។ បទល្មើស និងទម្រង់នៃការទទួលខុសត្រូវទាំងនេះ មិនត្រូវបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់គាត់ឡើយ ព្រោះថាបទល្មើស និងទម្រង់នៃការទទួលខុសត្រូវទាំងនេះ អាចមានតែនៅក្នុងយុត្តិសាស្ត្រខ្លះៗ ក្រោយសង្គ្រាមលោកលើកទីពីរប៉ុណ្ណោះ[៤១៦]។

២០៧. សហមេធាវីការពារក្ដីអះអាងថា កង្វះលទ្ធភាពព្យាករណ៍ និងលទ្ធភាពផ្សព្វផ្សាយទូលំទូលាយអំពីទម្រង់នៃការទទួលខុសត្រូវទាំងនេះ ពិតជាមានប្រាកដមែន នៅពេលពិចារណាអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលជាទស្សនាទានមួយមិនទាន់ត្រូវបានកំណត់និយមន័យឲ្យបានច្បាស់លាស់គ្រប់គ្រាន់នៅឡើយទេ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ សហមេធាវីបានលើកឡើងថា បញ្ហានេះស្ដែងឡើងពីកង្វះភាពច្បាស់លាស់ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃ *ចេតនាប្រព្រឹត្តបទល្មើស* និងថាតើវាអាចអនុវត្តបានចំពោះជម្លោះមិនមែនអន្តរជាតិ និងចំពោះថ្នាក់លើជាជនស៊ីវិលដែរឬទេ[៤១៧]។

## សម្រង់កថាខណ្ឌមួយចំនួនពីដីកាដំណោះស្រាយ ដែលបានយោងសម្រាប់មូលដ្ឋាននេះនៃបណ្ដឹងឧទ្ធរណ៍៖

២០៨. កថាខណ្ឌ១៣០១ ដល់១៣០៧ នៃដីកាដំណោះស្រាយ ដែលស្ថិតនៅក្រោមចំណងជើង "យុត្តាធិការរបស់ អ.វ.ត.ក" រៀបរាប់៖

បញ្ហាដែលថា តើ អ.វ.ត.ក. ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះនោះទេ ដរាបណាគោលការណ៍ *មិនមានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង (nullum crimen sine lege)* ត្រូវបានគោរព។

អនុលោមតាមគោលការណ៍នេះ ដែលមានចែងនៅក្នុងមាត្រា ៣៣(២)(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលយោងទៅដល់មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខាន

---

[៤១៦] បណ្ដឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ១៣០ ដល់១៣១។

[៤១៧] បណ្ដឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ១៣៤

ណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅខណៈពេលប្រព្រឹត្តនោះឡើយ។ ដូច្នេះ ដើម្បីអាចឱ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិ ក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុល្យភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើស នៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ។ ប្រភពនៃច្បាប់អន្តរជាតិដែលអនុវត្តនោះ រួមមានច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិ ក៏ដូចជាគោលការណ៍ទូទៅនៃនីតិ ដែលត្រូវបានទទួលស្គាល់ដោយសហគមន៍នៃបណ្តាប្រជាជាតិនានាផងដែរ។ ជាងនេះទៀត ច្បាប់ទាំងនេះត្រូវតែមានការផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ នៅខណៈពេលដែលអង្គហេតុបានកើតឡើង ហើយជនជាប់ចោទត្រូវឋិតក្នុងសភាពដែលអាចព្យាករណ៍ជាមុនថា ពួកគេអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ពួកគេ នៅក្នុងបញ្ហានេះ ចរិតលក្ខណៈសាហាវយង់ឃ្នងនៃអំពើអាចត្រូវបានយកមកពិចារណា។

គោលការណ៍ទាំងអស់ ដែលបានរៀបរាប់ខាងលើនេះ ត្រូវអនុវត្តផងដែរចំពោះទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌផ្សេងៗទៀត។

ពាក់ព័ន្ធនឹងបញ្ហានៃភាពដែលអាចអនុវត្តដោយផ្ទាល់នៃច្បាប់អន្តរជាតិ នៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវរំលឹកឡើងវិញថា មាត្រា១ និងមាត្រា២ និងមាត្រា២៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក បានដាក់បញ្ចូលក្នុងច្បាប់កម្ពុជានូវការរំលោភបំពានច្បាប់អន្តរជាតិមួយចំនួន ដែលត្រូវឋិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ការបំផ្លិច-បំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ) ក៏ដូចជា ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវអនុវត្ត (ដោយបញ្ចូលផងដែរនូវរបបទោសបញ្ញត្តិ ដែលអនុលោមតាមគោលការណ៍ *មិនមានទោស ប្រសិនបើគ្មានច្បាប់ចែង* (*nulla poena sine lege*)។ ដោយយោងទៅលើបទប្បញ្ញត្តិទាំងនេះ បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬមិនអាចអនុវត្តដោយផ្ទាល់ នៅក្នុងប្រទេសកម្ពុជានឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. នោះឡើយ។

ម្យ៉ាងវិញទៀត បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដែលចែងអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងដែលបានកំណត់យ៉ាង

ច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានអនុភាពគតិយុត្តិចាប់បង្ខំតម្រូវឱ្យកម្ពុជាត្រូវតែគោរពតាមដូចមានបកស្រាយខាងក្រោមនេះ ក្នុងន័យនេះ បទប្បញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ ដែលអាចឱ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា ។

ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ ការកំណត់ថាអំពើនេះជាបទល្មើសដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ តាមរយៈការជំនុំជម្រះនានាដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅទីក្រុងនូរឹមប៊ឺក និងតូក្យូ ជាដើម។

ក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក. ក៏មានទម្រង់នៃការទទួលខុសត្រូវមួយចំនួនត្រូវបានទទួលស្គាល់ផងដែរ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដូចមានបញ្ជាក់ខាងក្រោមនេះ។ ហេតុដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយដល់ជនត្រូវចោទ។ ហើយចំពោះទម្រង់នៃការទទួលខុសត្រូវដែលនៅសេសសល់វិញ ដូចជា សហឧក្រិដ្ឋកម្មរួម (JCE) ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាក៏ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះនានាដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយជនត្រូវចោទ។

២០៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា កថាខណ្ឌនានានៃដីកាដំណោះស្រាយដែលបានរៀបរាប់ពីខាងលើ គឺឆ្លើយតបនឹងតម្រូវការនៃគោលការណ៍នីត្យានុកូលភាព ហើយឥទ្ធិពលរបស់វាចំពោះយុត្តាធិការរបស់ អ.វ.ត.ក ទាក់ទិនទៅនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិ គឺមានចែងក្នុងច្បាប់ អ.វ.ត.ក។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា “ទាំងបទល្មើស ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលបានកំណត់នៅក្នុងផ្នែកនេះក្នុងដីកាដំណោះស្រាយ គឺស្របទៅនឹងគោលការណ៍នីត្យានុកូលភាព”[៤១៨]។ ដោយសារការគោរពទៅតាមគោលការណ៍នីត្យានុកូលភាព គឺជាការតម្រូវជាមុនសម្រាប់ការបង្កើតនូវយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដូចមានចែងក្នុងច្បាប់ អ.វ.ត.ក ទើបការយល់ឃើញរបស់សហ

[៤១៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចៅក្រមស៊ើបអង្កេត រួមជាមួយនឹងខ្លឹមសារក្នុងកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ មានតម្លៃជាការបញ្ជាក់ឡើងវិញអំពីយុត្តាធិការ។

២១០. គោលការណ៍នីត្យានុកូលភាពត្រូវតែបំពេញ ក្នុងនាមជាព្រឹត្តិការណ៍នាំមុខដ៏សមហេតុផលមួយ សម្រាប់ការកំណត់ថាតើបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ បានកើតមានឡើងនៅពេលដែលអង្គហេតុបានកើតឡើងដែរឬអត់។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ភាពអាចប្រមើលដឹងថាជាបទល្មើស និងលក្ខខណ្ឌដឹងថាមានច្បាប់ចែង គឺជាសមាសធាតុនៃគោលការណ៍នីត្យានុកូលភាព។ អង្គបុរេជំនុំជម្រះ សូមផ្តល់នូវការវិភាគយ៉ាងល្អិតល្អន់ទៅលើការវាយតម្លៃពីភាពអាចប្រមើលដឹងថាជាបទល្មើស និងលក្ខខណ្ឌដឹងថាមានច្បាប់ចែង នៅក្នុងកថាខណ្ឌ ២២៩ ដល់២៣៧ ខាងក្រោម។ សហមេធាវីការពារក្តី អៀង សារី ស្នើឱ្យមានការពិចារណាទៅលើការយល់ដឹងជាលក្ខណៈអត្តនោម័តរបស់ អៀង សារី ទាក់ទងទៅនឹងស្ថានភាពនៃច្បាប់អន្តរជាតិ[៤១៩] តែសំណើបែបនេះទាមទារឱ្យមានការសម្រេចលើអង្គហេតុ ដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនោះទេ។

២១១. សារណាមួយទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នារបស់ អៀង សារី ស្តីពីកង្វះភាពច្បាស់លាស់ ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃ *ចេតនាប្រព្រឹត្តបទល្មើស* សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៤២០] បានលើកឡើងពីការពិចារណាយ៉ាងលម្អិត ពីសមាសធាតុឬគម្រោងរបស់ទម្រង់នៃការទទួលខុសត្រូវ ជាជាងលើកឡើងពីវត្តមានរបស់វាតែម្តង។ ហេតុដូច្នេះវាមិនស្ថិតនៅក្នុងវិសាលភាពវិធាន ៧៤(៣)(ក)នៃវិធានផ្ទៃក្នុង ដែលចែងពីការជំទាស់ទៅលើយុត្តាធិការនោះឡើយ។ ការសម្រេចពីវត្តមាននៃជម្លោះប្រដាប់អាវុធ គឺមានលក្ខណៈជាអង្គហេតុដូច្នេះហើយវាមិនស្ថិតនៅក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ដើម្បីធ្វើការពិចារណាទេ។

២១២. អង្គបុរេជំនុំជម្រះបានយល់ស្របជាមួយនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ១៣០១ នៃដីកាដំណោះស្រាយដែលចែងថា លក្ខណៈរបស់ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះ

---

[៤១៩] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ១៣០, ១៣១ និង១៣៥ ព្រមទាំងដីកាដំណោះស្រាយ កថាខណ្ឌ១៣០៥។

[៤២០] បណ្តឹងឧទ្ធរណ៍អៀង សារី កថាខណ្ឌ ១៣៤។

00661624



លើឧក្រិដ្ឋកម្ម ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ ដូចមានចែងក្នុងច្បាប់ អ.វ.ត.ក នោះទេ ព្រោះច្បាប់ អ.វ.ត.ក ផ្តល់នូវយុត្តាធិការទាំងអស់នេះដល់ អ.វ.ត.ក។ ច្បាប់ អ.វ.ត.ក ត្រូវបានតាក់តែងឡើងយ៉ាងប្រុងប្រយ័ត្ន ហើយបានចែងយ៉ាងច្បាស់ថា អ.វ.ត.ក អាចជំនុំជម្រះនូវបទឧក្រិដ្ឋ ព្រមទាំងទម្រង់នៃការទទួលខុសត្រូវទាំងអស់នោះបាន ក្នុងករណីដែលបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវទាំងនោះ មានចែងក្នុងច្បាប់ដែលនៅជាធរមាន ក្នុងពេលដែលអង្គហេតុបានកើតឡើង។ បើទោះបីជា អ.វ.ត.ក ជាតុលាការក្នុងស្រុកក៏ដោយ ក៏គ្មានអ្វីជាបញ្ហាចំពោះយុត្តាធិការដែរ ដរាបណាច្បាប់បង្កើត អ.វ.ត.ក នៅជាធរមាន ហើយ អ.វ.ត.ក បំពេញបានសព្វគ្រប់នូវរាល់តម្រូវការនានា។

២១៣. អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរួម[៤២១] រវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិ ហើយកម្ពុជាបានព្រមទទួលយកកិច្ចព្រមព្រៀង អ.វ.ត.ក មកអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា[៤២២]។ ច្បាប់ អ.វ.ត.ក បានចែងយ៉ាងច្បាស់ពីយុត្តាធិការរបស់អង្គជំនុំជម្រះ ក្នុងការអនុវត្តនូវសន្ធិសញ្ញានានាដែលកម្ពុជាបានទទួលស្គាល់ ព្រមទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិនានា ដរាបណាមានការគោរពតាមគោលការណ៍នីត្យានុកូលភាព[៤២៣]។ ដោយយោងយ៉ាងច្បាស់លាស់ទៅលើមាត្រា១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចំពោះករណីឧក្រិដ្ឋកម្មអន្តរជាតិ គឺគ្មានអ្វីគួរឱ្យសង្ស័យនោះឡើយដែលថា គោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងច្បាប់ អ.វ.ត.ក គឺជាគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលធ្វើឱ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋដែលមានលក្ខណៈជាបទឧក្រិដ្ឋជាតិ ឬអន្តរជាតិ នៅខណៈពេលដែលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្ត[៤២៤]។ ដោយសារតែគោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនបានតម្រូវថាបទឧក្រិដ្ឋអន្តរជាតិ ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ ចាំបាច់ត្រូវអនុវត្តដោយលក្ខន្តិកៈជាតិ ដើម្បីអាចឱ្យរកឃើញនូវពិរុទ្ធភាពរបស់ជនល្មើសនោះ លក្ខណៈជាប្រព័ន្ធឯកនិយម ឬក៏ទ្វិកនិយម នៃប្រព័ន្ធច្បាប់កម្ពុជានឹងមិនមានផលប៉ះពាល់ទៅលើសុពលភាពនៃច្បាប់ជាធរមាន នៅចំពោះមុខ អ.វ.ត.ក ឡើយ។ ដូច្នេះអង្គបុរេជំនុំជម្រះសូមឯកភាពជាមួយសហ-

---

[៤២១] កិច្ចព្រមព្រៀង។

[៤២២] មាត្រា៤៧ ស្ទួន(ថ្មី) នៃច្បាប់ អ.វ.ត.ក។

[៤២៣] មាត្រា៣៣(២) (ថ្មី) នៃច្បាប់ អ.វ.ត.ក។

[៤២៤] មាត្រា១៥(១) នៃ ICCPR។

ចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា[៤២៥] លើចំណុចដែលថា លក្ខណៈរបស់ អ.វ.ត.ក គឺមិនទាក់ទងជាមួយនឹងយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើភាពច្បាស់លាស់នៃច្បាប់ អ.វ.ត.ក។ ច្បាប់ អ.វ.ត.ក មិនបានផ្តល់សិទ្ធិដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាបានទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋអន្តរជាតិទាំងអស់នោះទេ។ នេះមិនចាំបាច់នោះឡើយ[៤២៦]។ រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែអាចធ្វើការជំនុំជម្រះលើបទល្មើសទាំងអស់នោះ ដែលបានកើតឡើងនៅក្នុងយុត្តាធិការដែនដីរបស់ខ្លួន ដែលជាការអនុវត្តជាមូលដ្ឋាននូវយុត្តាធិការរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាថែមទាំងមានកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ដើម្បីធ្វើការជំនុំជម្រះលើបទល្មើសបែបនេះទៀតផង[៤២៧]។ ជាជាងប្រើប្រាស់នូវរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ រាជរដ្ឋាភិបាលកម្ពុជា

---

[៤២៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៣៧។

[៤២៦] សូមមើលជាឧទាហរណ៍ *Kononov* សាលក្រមអង្គជំនុំជម្រះជាន់ខ្ពស់ (Grand Chamber Judgement) កថាខណ្ឌ ២០៧ (ករណីដែល ECtHR រំឭកថា ធម្មនុញ្ញ Nuremberg (IMT) មិនមែនជាច្បាប់ព្រហ្មទណ្ឌ ប្រតិសកម្មនោះឡើយ ដោយសារតែមានកិច្ចព្រមព្រៀងក្នុងលិទ្ធិសម័យទំនើបដែលច្បាប់អន្តរជាតិបានកំណត់រួចរាល់នូវនិយមន័យឧក្រិដ្ឋកម្មសង្គ្រាម ហើយតម្រូវឱ្យបុគ្គលនានា ត្រូវទទួលការជំនុំជម្រះទោស)។

[៤២៧] អនុសញ្ញាស្តីពីការរារាំង និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា១ និង ៥, អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬប្រព្រឹត្តិដោយសាហាវព្រៃផ្សៃ អមនុស្សធម៌ និងបន្ទាបបន្ថោក មាត្រា៤ និង៥ (កម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២), អនុសញ្ញាទី៤ ទាក់ទិននឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨ មាត្រា១៤៦ (“អនុសញ្ញាទី៤ ទីក្រុងហ្សឺណែវ”)។ ប្រទេសកម្ពុជាដែលបានផ្តល់សច្ចាប័នទៅលើ ICCPR និងបន្តមានកាតព្វកិច្ចធានាថា ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យគឺសំដៅដល់ការបង្កនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ត្រូវទទួលបាននូវការដោះស្រាយដោយប្រសិទ្ធិភាព។ មាត្រា២(៣) នៃ ICCPR បានចែងថា “រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា៖ (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះ *មានសិទ្ធិឱ្យមានការដោះស្រាយដោយប្រសិទ្ធិភាព* ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។” (គូសបញ្ជាក់បន្ថែម) ជាទូទៅកាតព្វកិច្ចទាំងនេះ តម្រូវឱ្យរដ្ឋធ្វើការជំនុំជម្រះ និងផ្តន្ទាទោសលើអ្នកប្រព្រឹត្តបទឧក្រិដ្ឋនេះ។ សូមមើល IACtHr, *រឿងក្តី Velázquez Rodriguez* “សេចក្តីសម្រេច និងសាលក្រម” ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ កថាខណ្ឌ ១៧៦ (“រដ្ឋមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតទៅលើគ្រប់ស្ថានការណ៍ទាំងអស់ដែលពាក់ព័ន្ធ និងការរំលោភបំពានលើសិទ្ធិដែលបានការពារដោយអនុសញ្ញា។ ករណីដែលក្បាលម៉ាស៊ីនរដ្ឋបានប្រព្រឹត្តនូវការរំលោភបំពាន ហើយបានរួចផុតពីការផ្តន្ទាទោស ឯជនរងគ្រោះមិនទទួលបាននូវការជួសជុល ព្រមទាំងផ្តល់នូវសិទ្ធិពេញលេញនោះទេ មានន័យថារដ្ឋមិនបានគោរពតាមតួនាទីរបស់ខ្លួនក្នុងការធានាដល់ការប្រើប្រាស់ដោយសេរី និងពេញលេញនូវសិទ្ធិរបស់ប្រជាជនដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន។ លក្ខណៈដូចគ្នានេះនឹងកើតឡើង ប្រសិនបើរដ្ឋអនុញ្ញាតឱ្យបុគ្គល ឬក្រុមឯកជនណាមួយ អនុវត្តដោយសេរី ដោយមានអភ័យឯកសិទ្ធិ ដែលអំពើរបស់ពួកគេធ្វើឱ្យប៉ះពាល់

បានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ក្នុងការបង្កើត អ.វ.ត.ក ឡើង ដោយសារតែតុលាការនេះមានជំនាញជាអន្តរជាតិហើយរាជរដ្ឋាភិបាលបានផ្តល់យុត្តាធិការរបស់ខ្លួនទៅតុលាការនេះ ដើម្បីជំនុំជម្រះទៅលើសំណុំរឿងទាំងនេះ។

២១៤. អនុលោមតាមច្បាប់ អ.វ.ត.ក, អ.វ.ត.ក ត្រូវតែអនុវត្តដោយផ្ទាល់នូវច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់ ក្នុងការកំណត់អំពើឧក្រិដ្ឋអន្តរជាតិសំខាន់ៗជាបទឧក្រិដ្ឋ និងក្នុងការអនុវត្តនូវយុត្តាធិការរបស់ខ្លួនទាក់ទិននឹងបទល្មើសទាំងនេះ ដោយអនុលោមទៅតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិនោះ។ នៅក្នុងការអនុវត្តច្បាប់នេះ កម្ពុជាបានធ្វើតាមវិធីសាស្ត្រមួយចំនួនដែលរដ្ឋជាសមាជិកបានអនុម័តយក ដោយគោរពទៅតាមភាសានៃអនុសញ្ញា ICCPR ព្រមទាំងតុលាការ ECtHR[៤២៨]។ វិធីសាស្ត្រដែលរដ្ឋជាសមាជិកបានអនុម័តយកនោះ រួមមានករណីលើកលែងចំពោះបទឧក្រិដ្ឋអន្តរជាតិមួយចំនួន នៅក្នុងការបង្កើតគោលការណ៍នីត្យានុកូលភាពក្នុងច្បាប់ជាតិ[៤២៩]។ បើ

---

ដល់សិទ្ធិដែលបានទទួលស្គាល់ដោយអនុសញ្ញា។" (គូសបញ្ជាក់បន្ថែម)។ *Kononov* សាលក្រមតុលាការជាន់ខ្ពស់ (Grand Chamber Judgement) កថាខណ្ឌ ២១៣ (តុលាការ ECtHR រកឃើញនៅខែឧសភា ឆ្នាំ១៩៤៤ ដែលមុនពេលមានការអនុម័តលើលិខិតុបករណ៍សិទ្ធិមនុស្សថា "រដ្ឋត្រូវបានអនុញ្ញាតិ (បើទោះមិនបានតម្រូវ) ឲ្យធ្វើការដាក់ទណ្ឌកម្មចំពោះបុគ្គលណាដែលប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ដោយរួមបញ្ចូលទាំងមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ")។

[៤២៨] មាត្រា៧ នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបាន អនុម័តិនៅទីក្រុងរ៉ូម កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ ដោយក្រុមប្រឹក្សាអឺរ៉ុប ("ECHR") មានចែងនូវបទបញ្ញត្តិប្រហាក់ប្រហែលគ្នានិងមាត្រា១៥ នៃ ICCPR ("១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអំពើអកម្មណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលទទួលស្គាល់ដោយប្រទេសដែលមានអារ្យធម៌រុងរឿង។")

[៤២៩] សូមមើលជាឧទាហរណ៍ មាត្រា៤២(១) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ របស់ប្រទេសប៉ូឡូញ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនេះ គោលការណ៍នីត្យានុកូលភាព "មិនត្រូវរារាំងការដាក់ទណ្ឌកម្ម ចំពោះអំពើណាមួយដែល ក្នុងពេលបានប្រព្រឹត្ត ត្រូវបានចាត់ទុកថាជាបទល្មើស តាមអត្ថន័យនៃច្បាប់អន្តរជាតិ"។ បទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះក៏មានចែងក្នុងមាត្រា១១(ឆ) នៃធម្មនុញ្ញប្រទេសកាណាដា ស្តីពីសិទ្ធិនិងសេរីភាព ដែលមានឋានៈប្រហាក់ប្រហែលនិងរដ្ឋធម្មនុញ្ញដែរ ហើយធម្មនុញ្ញនេះបានចែងថា "បុគ្គលទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទល្មើស ត្រូវមានសិទ្ធិរួចផុតពីពិរុទ្ធភាព ទាំងចំពោះអំពើសកម្ម និងអំពើអកម្ម វៀលែងតែក្នុងករណីដែលក្នុងពេលប្រព្រឹត្តអំពើសកម្ម ឬអំពើអកម្មនោះ អំពើនោះត្រូវបានចាត់ទុកថាជាបទល្មើស តាមច្បាប់ប្រទេសកាណាដា ឬច្បាប់អន្តរជាតិ ឬចាត់ទុកជាអំពើឧក្រិដ្ឋដោយយោងតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ។ យោងតាមរបាយការណ៍របស់គណៈកម្មការស៊ើបអង្កេតលើឧក្រិដ្ឋកម្មសង្គ្រាម (Deschenes Commission)

ទោះបីជាការនេះមិនបានឆ្លុះបញ្ចាំងពីការអនុវត្តមានលក្ខណៈដូចគ្នា ឬឋិតថេរក្តី ក៏តុលាការក្នុងស្រុកមួយចំនួនបានចេញសេចក្តីសម្រេច ដោយអនុវត្តបទដ្ឋានខុសៗគ្នា ទាក់ទិននឹងគោលការណ៍នីត្យានុកូលភាព សម្រាប់បទឧក្រិដ្ឋធម្មតា និងបទឧក្រិដ្ឋអន្តរជាតិ[៤៣០]។ ហេតុដូច្នេះ រដ្ឋជាច្រើនបាន

---

ការបកស្រាយនូវគោលការណ៍នីត្យានុកូលភាពនេះ ជំនួសឲ្យការចែងមិនច្បាស់លាស់នៃច្បាប់។ មើលផងដែរលើក្រមព្រហ្មទណ្ឌរបស់ប្រទេស Bosnia និង Herzegovina (មាត្រា ៣(២))។ ច្បាប់ដូចគ្នានេះដែរ គណៈវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត បានបកស្រាយនៅផ្នែក ៩.១ និង ៣១ នៃរដ្ឋធម្មនុញ្ញប្រទេសទីម័រខាងកើតថា អាចចោទប្រកាន់ និងដាក់ទោសបុគ្គលណាម្នាក់ ចំពោះអំពើសកម្ម ឬ អកម្មក្នុងខណៈពេលប្រព្រឹត្ត ដូចដែលមានចែងក្នុងមាត្រា ១៥(២) នៃ ICCPR ថា "ជាអំពើឧក្រិដ្ឋដោយផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ឲ្យសហគមន៍ប្រជាជាតិ"។ រឿងក្តីរដ្ឋអាជ្ញាទល់នឹង *Mondonca et al* សំណុំរឿងលេខ 18a/2001 , "សាលដីកាលើបណ្តឹងរបស់មេធាវី (Domingos Mendonca) ដែលតុលាការបង្គាប់រដ្ឋអាជ្ញាឲ្យកែប្រែលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ១៨។ សាលដីកានេះបានបដិសេធចោលនូវសេចក្តីសម្រេចពីមុនរបស់សាលាឧទ្ធរណ៍នៃប្រទេសទីម័រខាងកើត (*Armando dos Santos),* "សេចក្តីសម្រេចលើច្បាប់បន្ទាប់បន្សំជាធរមាន" ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ ទំព័រ១៤។

[៤៣០] សូមមើលជាឧទាហរណ៍ ក្នុងប្រទេសហុងគ្រី ការយល់ឃើញរបស់តុលាការធម្មនុញ្ញ ក្នុងឆ្នាំ១៩៩៣ ដែលយោងទៅលើមាត្រា ១៤(២) នៃ ICCPR និងមាត្រា ៧(២) នៃ ECHR ថា ការចោទប្រកាន់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានគ្រប់គ្រងដោយគោលការណ៍នីត្យានុកូលភាពជាតិឡើយ ( តុលាការធម្មនុញ្ញហុងគ្រី "សេចក្តីសម្រេច No. 53/1993 ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៣ ការបកប្រែជាភាសាអង់គ្លេស នៅក្នុង Sólyom and Brunner 2000, ទំព័រ២៧៣-២៨៣ (អង់គ្លេស) ត្រង់ ២៩៧, សូមមើលផងដែរ ការបកស្រាយដោយតុលាការប្រទេសអាហ្សង់ទីន លើគោលការណ៍នីត្យានុកូលភាព ក្នុងទម្រង់អន្តរជាតិ Argentina, Federal Court of Buenos Aires, *Videla*, សេចក្តីសម្រេចលើការឃុំឃាំងខ្លួនមុនពេលសវនាការ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលបានចង្អុលបង្ហាញថា គោលការណ៍នីត្យានុកូលភាព ដូចមានចែងក្នុងមាត្រា ១៥ នៃ ICCPR បានចងកាតព្វកិច្ចលើប្រទេសអាហ្សង់ទីន ហើយខ្លួនមិនអាចច្រានចោលនូវច្បាប់ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធយុត្តិធម៌អន្តរជាតិ ដែលមានអាទិភាពជាងច្បាប់ក្នុងស្រុក "បើទោះបីជាការនេះតម្រូវឲ្យផ្តល់សារៈសំខាន់ចំពោះគោលការណ៍នីត្យានុកូលភាព ខុសប្លែកពីការអនុវត្តជាទម្លាប់ដែលមានការឯកភាពគ្នា ដោយតុលាការក្នុងស្រុក និងរដ្ឋាភិបាលប្រទេសអាហ្សង់ទីនក៏ដោយ ហើយដែលការរក្សាបែបនេះមិនអាចធ្វើការកែប្រែលើបទប្បញ្ញត្តិផ្ទៃក្នុង ព្រមទាំងស្ថានទម្ងន់នៃកាតព្វកិច្ចដែលកើតឡើងពីប្រភពដទៃនៃបទដ្ឋានច្បាប់អន្តរជាតិឡើយ" ទំព័រ ៣៩ ដល់៤០ (អង់គ្លេស) តុលាការកំពូលអាហ្សង់ទីន *Arancibia Clavel, Enrique Lautaro s/ homicidio alificado y associación illićita y otros*, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ សេចក្តីសម្រេចភាគច្រើន បានបដិសេធថាមិនមានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ចាប់តាំងពីពេលដែលបញ្ហាដែលរងការចោទបានកើតឡើង ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិ គ្រប់គ្រងទៅលើទាំងលក្ខណៈឧក្រិដ្ឋនៃអំពើនានា ក៏ដូចជាការហាមឃាត់លើអាជ្ញាយុកាលកំណត់ កថាខណ្ឌ ២២, ២៣, ២៨ និងកថាខណ្ឌ ៣៣។ សេចក្តីសម្រេចទាំងពីរ ត្រូវបានដកស្រង់ក្នុង Ward N. Ferdinadusse, ពីសៀវភៅក្រោមចំណងជើងថា *Direct Application of International Criminal Law in National Courts*, TMC Asser Presse, 2006, ទំព័រ ៧៤ ដល់៧៥ (អង់គ្លេស)។ សូមមើលផងដែរ ការយល់ឃើញរបស់តុលាការធម្មនុញ្ញ ប្រទេសកូឡុំប៊ី ក្នុងសាលដីកា

ឆ្នាំ២០០២ ស្តីពីធម្មនុញ្ញភាព នៃលក្ខន្តិកទីក្រុងរ៉ូម ដែលចែងថា បទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព គឺមិនដូចគ្នានិងក្រមព្រហ្មទណ្ឌជាតិ និងអន្តរជាតិឡើយ (Colombia, Corte Constitcional, Sala Plena, *Sentencia C-578 (In re Corte Penal Internacional)* ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ នៅត្រង់៣១ Jurisprudencia y Doctrina នៅត្រង់២២៣១-២២៩២។ ក្នុង *Barbie* ឆ្នាំ១៩៨៤, តុលាការ French Court de Cassation បានបដិសេធនូវការជួសជុលវិសាមញ្ញមួយដែលចាប់ផ្តើមឡើងដោយ Barbie (*pourvoi*) ដោយយោងទៅលើមាត្រា ១៥(២) នៃ ICCPR និងមាត្រា ៧(២) នៃតុលាការ ECHR ដោយយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនរាប់បញ្ចូលក្នុងគោលការណ៍នីត្យានុកូលភាព ដូចមានចែងក្នុងច្បាប់ប្រទេសបារាំងនោះទេ។ (France, Cour de Cassation, *Barbie* (No. 2) ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៤ Bull. Crim. លេខ៣៤ ត្រង់ទំព័រ ៩២(អង់គ្លេស) បានដកស្រង់ ហើយយល់ស្របជាមួយសាលាឧទ្ធរណ៍ ("qu'en définitive; l'incrimination de crimes contre l'humanité est conforme aux principes généraux de droit reconnus par les nations civilisées; qu'à ce titre ces crimes échappent au principe de la non rétroactivité des lois de répression…")។ សូមមើលផងដែរ France, Tribunal de Grande Instance de Paris, Juge d'Instruction, *In re Javor*, "Ordonnance", ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៤ (ដែលចៅក្រមស៊ើបអង្កេតយល់ឃើញថា គោលការណ៍ជាសកល កំណត់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាជាឧក្រិដ្ឋកម្មអន្តរជាតិនោះ គឺមិនគ្រប់គ្រាន់សម្រាប់បង្កើតជាយុត្តាធិការសម្រាប់តុលាការបារាំងឡើយ) ហើយសំខាន់ជាងនេះទៅទៀតនៅក្នុង Aussaresses ឆ្នាំ២០០៣, ការច្រានចោលរបស់តុលាការ French Court de Cassation ចំពោះការអនុវត្តដោយផ្ទាល់នូវទំនៀមទម្លាប់ និងការជំនុំជម្រះទោស ចំពោះនាយឧត្តមសេនីយ៍បារាំងដែលបានធ្វើទារុណកម្ម ដោយផ្ទាល់ ព្រមទាំងការកាប់សម្លាប់ទៅលើជនស៊ីវិលក្នុងសង្គ្រាម Algerian ដោយផ្អែកលើមូលដ្ឋានដែលថា "វិធានទំនៀមទម្លាប់អន្តរជាតិមិនអាចជំនួស បទប្បញ្ញត្តិដែលមិនមាន សម្រាប់ការកំណត់អំពើមួយជាបទឧក្រិដ្ឋ ដែលបានប្តឹងដោយម្ចាស់បណ្តឹងរដ្ឋប្បវេណី ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" (France, Court de Cassation, *Aussaresses*, 17 June 2003, 108 RGDIP 754) សម្រាប់ឧទាហរណ៍នៃការអនុវត្តផ្ទុយពីនេះ សូមមើល Oslo District Court, *រដ្ឋអាជ្ញា តទល់និង. Misrad Repak*, Case No 08-018985MED-OTIR/08, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦ ដល់៩ (ដែលតុលាការបានច្រានចោលនូវបទចោទដែលទាក់ទងនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រោះក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត គឺមិនមានបទប្បញ្ញត្តិណាមួយក្នុងច្បាប់ប្រទេសន័រវេស បានកំណត់អំពើនោះជាបទល្មើស ដោយប្រើពាក្យដូចនឹងពាក្យដែលប្រើក្នុងច្បាប់ដែលពាក់ព័ន្ធនាក្នុងពេលបច្ចុប្បន្ន ហើយរដ្ឋធម្មនុញ្ញ ប្រទេសន័រវេស ហាមឃាត់មិនឱ្យអនុវត្តនូវប្រតិសកម្មលើច្បាប់) *Re Habre*, Appeal Decision, Cassation No 14, ILDC 164 (SN 2001), កថាខណ្ឌ ៣៣ (ដែលតុលាការបានរកឃើញថា ខ្លួនមិនអាចជំនុំជម្រះជនបរទេសដែលបានប្រព្រឹត្តអំពើទារុណកម្ម នៅក្រៅប្រទេស ក្នុងពេលដែលបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីការធ្វើទារុណកម្ម និងអំពើសាហាវព្រៃផ្សៃ អមនុស្សធម៌ ព្រមទាំងអំពើបន្ទាបបន្ថោក មិនទាន់បានបញ្ចូលក្នុងច្បាប់ជាតិ Senegalese។ តុលាការកំពូល ប្រទេសហូឡង់ *In re Bouterse*, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០១ ការបកប្រែជាភាសាអង់គ្លេស ពីឯកសារប្រចាំឆ្នាំរបស់ហូឡង់ ស្តីពីច្បាប់អន្តរជាតិ កថាខណ្ឌ ៤.៥ (តុលាការកំពូលប្រទេសហូឡង់ បានសម្រេចថា គោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងច្បាប់ហូឡង់ មិនមានការលើកលែងចំពោះឧក្រិដ្ឋកម្មអន្តរជាតិឡើយ) Australia, Federal Court, *Nulyarimma v. Thompson*, [1999] FCA 1192, កថាខណ្ឌ ២០ ដល់២៦ និង ៣២ (មតិភាគច្រើនចៅក្រមពីររូបបានសម្រេចថា ក្នុងករណីមិនមានច្បាប់ជាធរមានណាមួយ បទល្មើសប្រល័យពូជសាសន៍ នឹងមិនត្រូវទទួលស្គាល់ក្នុងតុលាការអូស្ត្រាលីនោះទេ ជាពិសេសវានឹងរំលោភទៅលើ គោលការណ៍នីត្យានុកូលភាព (កថាខណ្ឌ២៦)។ ចៅក្រមដែលខ្វែងយោបល់ Merkel បានពិចារណាថា ការអនុវត្តនូវឧក្រិដ្ឋកម្មនៃយុត្តាធិការសកល តាមច្បាប់អន្តរជាតិមិនបង្ហាញពីការរំលោភបំពានបែបនេះទេ ហើយចៅក្រមបានសង្កត់ធ្ងន់ថា អំពីតម្រូវការ

អនុវត្តច្បាប់អន្តរជាតិផ្ទាល់ ដោយផ្អែកលើសន្ធិសញ្ញា និង/ឬច្បាប់ប្រពៃណី ដោយច្បាប់នៅក្នុងប្រទេសគ្មានបទប្បញ្ញត្តិជាក់លាក់ណាមួយ ដែលកំណត់អំពើទាំងនោះថាជាឧក្រិដ្ឋកម្ម ឬក្នុងករណីខ្លះបញ្ចូលច្បាប់អន្តរជាតិជាទូទៅតែម្តង[៤៣១]។ វិធីសាស្ត្រនេះក៏ស្របជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ECtHR ក៏ដូចជារបស់តុលាការជាតិទាំងនោះដែរ ដោយវែកញែកឱ្យដាច់ពីគ្នាយ៉ាងច្បាស់រវាងបទឧក្រិដ្ឋអន្តរជាតិ និងបទឧក្រិដ្ឋធម្មតា[៤៣២]។ ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះ តុលាការ *មិនអចិន្ត្រៃយ៍* នានាក៏បានធ្វើការចោទប្រកាន់ទៅលើបទឧក្រិដ្ឋអន្តរជាតិ ដោយផ្អែកទៅលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់តែមួយគត់ ដោយស្ថិតក្រោមលក្ខខណ្ឌថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិត្រូវបានគោរព[៤៣៣]។ វិធីសាស្ត្រនេះទទួលស្គាល់នូវតួនាទីរបស់យុត្តាធិការជាតិ និងអន្តរជាតិ

---

សម្រាប់តុលាការជាតិ ដើម្បីពិចារណាលើការវិវឌ្ឍន៍នៃច្បាប់អន្តរជាតិ (កថាខណ្ឌ ១៦១ និង ១៧៨)៖ "វាជាការចម្លែកមួយដែលតុលាការក្រុងមិនអនុវត្តបន្តនូវតួនាទីដែលមានតាំងពីយូររបស់ខ្លួន ក្នុងការទទួលស្គាល់នូវការផ្លាស់ប្តូរ និងវិវឌ្ឍន៍នៃច្បាប់អន្តរជាតិតាមរយៈការអនុម័តលើច្បាប់ទាំងនោះ" (កថាខណ្ឌ ១៨១)។

[៤៣១] បន្ថែមពីលើឯកសារយោងដែលបានដកស្រង់ក្នុងជើងទំព័រខាងលើរួចហើយ សូមមើល Ward N. Ferdinadusse, *Direct Application of International Criminal Law in National Courts*, TMC Asser Presse, 2006, ទំព័រ ៨៥ (អង់គ្លេស)។

[៤៣២] តុលាការ ECtHR, *Naletilic តទល់នឹង Croatia*, Application no. 51891/99, សេចក្តីសម្រេចលើភាពអាចទទួលយកបាន ថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០០០។ សូមមើលផងដែរ៖ *Kononov តទល់នឹង Latvia,* Application no. 36376/04, សាលដីកាតុលាការជាន់ខ្ពស់ ថ្ងៃទី១០ ខែឧសភាឆ្នាំ២០១០, ("សាលដីកាតុលាការជាន់ខ្ពស់លើ *Kononov*"), កថាខណ្ឌ ១៨៥ និង ១៨៦។ (តុលាការ ECtHR បាន រលឹកថា "កថាខណ្ឌទាំងពីរនៃមាត្រា៧ ត្រូវបានភ្ជាប់ទំនាក់ទំនងទៅវិញទៅមក និងត្រូវបានបកស្រាយក្នុងលក្ខណៈស្របគ្នា" និងថា "*ឯកសារព្រាង* នៃអនុញ្ញាចែងថា គោលបំណងនៃកថាខណ្ឌទី២ ក្នុងមាត្រា៧ គឺចង់បញ្ជាក់ថា មាត្រា៧ មិនមានឥទ្ធិពលទៅលើច្បាប់នានា ដែលបានអនុម័តរួចហើយ ដើម្បីដាក់ទោស រួមទាំងឧក្រិដ្ឋកម្មសង្គ្រាមដទៃទៀតឡើយ លើកលែងតែក្នុងកាលៈទេសៈនាចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ។ ដូច្នេះហើយ មាត្រា៧ នេះមិនមានគោលបំណងចេញជាច្បាប់ ឬជាសាលក្រមដែលត្រឹមត្រូវ ជំនួសលើច្បាប់ ទាំងនោះទេ"។ តាមការយល់ឃើញរបស់តុលាការបង្ហាញថា ការចោទប្រកាន់របស់ដើមបណ្តឹង ចំពោះឧក្រិដ្ឋកម្មសង្គ្រាមបានផ្អែកលើច្បាប់អន្តរជាតិ ជាជាងច្បាប់ក្នុងស្រុក ហើយត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួន។

[៤៣៣] សូមមើល *រដ្ឋអាជ្ញា តទល់នឹង* *Hadzihasanovic et al.*, IT-01-47-AR72, "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់លើយុត្តាធិការ ទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៥, ៤៤ ដល់៤៦ និងកថាខណ្ឌ ៥៥។ អៀង ធីរិទ្ធ បានទទួលស្គាល់ក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថាតុលាការមិនអចិន្ត្រៃយ៍នានា អាចធ្វើការជំនុំជម្រះបុគ្គល ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់ (បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៤)។

ក្នុងការជំនុំជម្រះលើបទឧក្រិដ្ឋអន្តរជាតិសំខាន់ៗ ដោយធ្វើដំណើរយឺតៗ ឆ្លងកាត់ដំណើរការចងក្រងច្បាប់ ដែលតម្រូវឱ្យពឹងផ្អែកទៅលើច្បាប់អន្តរជាតិ[៤៣៤]។

២១៥. អង្គបុរេជំនុំជម្រះសូមរំឭកថា ខ្លួនបានសន្និដ្ឋានជាបន្តបន្ទាប់ថា អ.វ.ត.ក ជាតុលាការមានលក្ខណៈជាអន្តរជាតិ។ ដូច្នេះទើបនៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ក្នុងសំណុំរឿង០០១ ដោយបានពិចារណាទៅលើកម្រិតទំនាក់ទំនងរវាង អ.វ.ត.ក ជាមួយនឹងតុលាការជាតិកម្ពុជា ហើយដោយប្រើប្រាស់សេចក្តីណែនាំពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា អង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានដោយមានសំអាងហេតុថា អ.វ.ត.ក ជាតុលាការមានលក្ខណៈជាអន្តរជាតិ៖

> អ.វ.ត.ក មានលក្ខណៈជាច្រើន ដែលខុសប្លែកពីតុលាការដទៃទៀតនៅកម្ពុជា។ សមាសភាពរបស់អង្គជំនុំជម្រះ រួមមានចៅក្រមជាតិ និងចៅក្រមអន្តរជាតិ។ ចៅក្រមអន្តរជាតិមិនប្រាកដថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការតែងតាំងជាចៅក្រមក្នុងប្រព័ន្ធតុលាការជាតិកម្ពុជាឡើយ ដោយហេតុថាចៅក្រមអន្តរជាតិទាំងនោះ មិនធ្លាប់បានទទួលការបណ្តុះបណ្តាលទូទៅលើច្បាប់កម្ពុជា។ ប៉ុន្តែពួកគាត់ត្រូវបានតែងតាំងជាចៅក្រម ដោយសារពួកគាត់មាន "បទពិសោធន៍ច្រើនក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស"។ អ.វ.ត.ក បំពេញកិច្ចដោយខ្លួនឯងទាំងស្រុង តាំងពីពេលចាប់ផ្តើមកិច្ចការស៊ើបសួររហូតដល់ការសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងឡាយ។ ដូចនេះគ្មានតុលាការនៅក្រៅរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ណាមួយ មានសិទ្ធិសើរើលើសេចក្តីសម្រេចរបស់ អ.វ.ត.ក នោះទេ ហើយដូចគ្នានេះដែរ អ.វ.ត.ក ក៏មិនមានសិទ្ធិសើរើសេចក្តីសម្រេចរបស់តុលាការណាមួយ ដែលមិនស្ថិតក្នុងរចនាសម្ព័ន្ធរបស់ខ្លួនដែរ។ នៅក្នុងរចនាសម្ព័ន្ធ

---

[៤៣៤] សាលដីកាតុលាការជាន់ខ្ពស់ លើ *Kononov* កថាខណ្ឌ ២០៨ (តុលាការ ECtHR សូមរំឭកថា "ក្នុងអំឡុងពេលនៃការតាក់តែងច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម តុលាការយោធា និងតុលាការព្រហ្មទណ្ឌជាតិ ដែលមានយន្តការជាចម្បងគឺជំរុញការអនុវត្តច្បាប់ និងទំនៀមទម្លាប់សង្គ្រាម [...] ព្រមទាំងការជំនុំជម្រះជាអន្តរជាតិ តាមរយៈ IMTs គឺជាករណីលើកលែង"។ ដូច្នេះ "ក្នុងករណីដែលច្បាប់ជាតិមិនបានចែងពីលក្ខណៈពិសេស នៃឧក្រិដ្ឋកម្មសង្គ្រាម តុលាការជាតិអាចពឹងផ្អែកទៅលើច្បាប់អន្តរជាតិ ធ្វើជាមូលដ្ឋានសម្រាប់សំអាងហេតុរបស់ខ្លួន ដោយការនេះមិនបានរំលោភទៅលើគោលការណ៍ គ្មានបទល្មើសបើគ្មានច្បាប់ចែង (*nullum crimen* and *nulla poena sine lege*) ឡើយ។ សូមមើលផងដែរ៖ ផ្នែក១៣ នៃក្រម Lieber ដែលក្នុង១៨៦៣ បានចែងថា "បទល្មើសយោធា ដែលមិនស្ថិតនៅក្នុងលក្ខន្តិកៈ ត្រូវតែជំនុំជម្រះ ហើយដាក់ទណ្ឌកម្មតាមច្បាប់សង្គ្រាមទូទៅ"។

តុលាការព្រហ្មទណ្ឌកម្ពុជា បណ្តឹងឧទ្ធរណ៍ពីតុលាការយោធាត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ហើយបន្ទាប់មកទៅតុលាការកំពូល។

ក្នុងការអនុវត្តជាក់ស្តែង និងតាមផ្លូវច្បាប់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យដែរ នៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ។ ដូច្នេះ អ.វ.ត.ក គ្មានយុត្តាធិការក្នុងការវិនិច្ឆ័យលើចំណាត់ការរបស់ស្ថាប័នតុលាការផ្សេងឡើយ។ សហព្រះរាជអាជ្ញាបានជូនសំអាងថា កត្តាមួយចំនួន ដែលបានសង្ខេបនៅក្នុងរបាយការណ៍បង្ហាញពីឯករាជ្យភាពនេះ ដែលធ្វើឱ្យ អ.វ.ត.ក ក្លាយជាសាលាក្តីពិសេស និងមានលក្ខណៈអន្តរជាតិ។

នៅក្នុងការសន្និដ្ឋានរបស់ខ្លួន អង្គបុរេជំនុំជម្រះយោងលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ របស់តុលាការពិសេសនៃប្រទេសសៀរ៉ាឡេអូន នៅក្នុងរឿងក្តី Taylor ដែលអង្គបុរេជំនុំជម្រះបានធ្វើការពិចារណាថា តុលាការនេះជាតុលាការអន្តរជាតិ ដោយហេតុថា៖ តុលាការនេះបានបង្កើតឡើងដោយសន្ធិសញ្ញា។ ការបង្កើតតុលាការនេះ គឺជាការសម្តែងឆន្ទៈរបស់សហគមន៍អន្តរជាតិ ដែលជាផ្នែកមួយនៃយន្តការស្វែងរកយុត្តិធម៌អន្តរជាតិ ហើយមានយុត្តាធិការក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ[៤៣៥]។

២១៦. អង្គបុរេជំនុំជម្រះនៅរក្សាជំហររបស់ខ្លួនដដែល ក្នុងសេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចៅក្រមអង្គបុរេជំនុំជម្រះមួយរូប នៅក្នុងសំណុំរឿង អ.ប.ជ ០១៖

អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជា អ.វ.ត.ក ជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជាក៏ដោយ ក៏ អ.វ.ត.ក គឺជាតុលាការមួយដាច់ដោយឡែក និងឯករាជ្យ គ្មានការជាប់ពាក់ព័ន្ធជាមួយតុលាការផ្សេងទៀតនៅកម្ពុជាទេ។ ចៅក្រមនៅក្នុង អ.វ.ត.ក ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានការឯកភាពជាអន្តរជាតិ និងបានធ្វើសច្ចាប្រណិធានដាច់ដោយឡែក និងផ្សេងពីតុលាការដទៃទៀត។ ក្នុងបរិបទនេះ អ.វ.ត.ក គឺជាតុលាការមានលក្ខណៈអន្តរជាតិថ្មីមួយដែលអនុវត្តបទដ្ឋាន និងនិយាមអន្តរជាតិ[៤៣៦]។

[៤៣៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទកាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ C5/45 កថាខណ្ឌ ១៨ ដល់២០។

[៤៣៦] សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចៅក្រមជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន៍យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ C11/29 កថាខណ្ឌ ៣០។

២១៧. ក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្ម-រួមបានសម្រេចទទួលយកនូវវិធីសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍នានា ក្នុងការកំណត់ថាអ្វីដែលបង្កើតជាបណ្តឹងជំទាស់យុត្តាធិការដ៏ត្រឹមត្រូវមួយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា អ.វ.ត.ក "ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានឹងតុលាការមិន*អចិន្ត្រៃយ៍*នានា" ដែលផ្ទុយពីប្រព័ន្ធច្បាប់ស៊ីវិលជាតិ ដែលលក្ខខណ្ឌនានានៃលក្ខន្តិកៈទាក់ទិននឹងបទឧក្រិដ្ឋ ព្រមទាំងទម្រង់នៃការទទួលខុសត្រូវដែលអាចចោទប្រកាន់បានមានភាពទូលាយ ហើយច្បាប់ដែលនៅជាធរមានគឺមិនបានបញ្ជាក់លម្អិត (បើកចំហ) ហើយដែល "គោលការណ៍នីត្យានុកូលភាពតម្រូវឲ្យអង្គជំនុំជម្រះ អនុវត្តច្បាប់ជាធរមាន ចំពោះអំពើដែលចោទប្រកាន់ជនជាប់ចោទនៅពេលនោះ... [ហើយ] អង្គច្បាប់ត្រូវតែអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[៤៣៧]។

២១៨. សេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ ដូចបានដកស្រង់ខាងលើ គឺស្របជាមួយនឹងការវិភាគ ក៏ដូចជាសេចក្តីសន្និដ្ឋាននានា ដែលធ្វើឡើងដោយអង្គតុលាការនានា ដូចជាអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក៏ដូចជាសាលាឧទ្ធរណ៍របស់តុលាការពិសេសប្រទេសលីបង់។ ហេតុដូច្នេះទើបនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៩ លើសំណើសុំឲ្យដោះលែងជនជាប់ចោទ ឌុច ឲ្យនៅក្រៅឃុំ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា៖

> រចនាសម្ព័ន្ធរបស់ អ.វ.ត.ក គឺខុសគ្នាពីរចនាសម្ព័ន្ធតុលាការកម្ពុជាផ្សេងទៀត។ ខណៈដែលនីតិវិធីរបស់ខ្លួនត្រូវអនុវត្តតាមច្បាប់កម្ពុជា អ.វ.ត.ក ក៏មានសិទ្ធិអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួនឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ដែលពិចារណាទៅលើយន្តការពិសេស ដែលចាំបាច់ដើម្បីវិនិច្ឆ័យសេចក្តីទៅលើឧក្រិដ្ឋកម្មធំៗ។ អ.វ.ត.ក នេះមានមន្ត្រីតុលាការ បុគ្គលិកជាតិ និងអន្តរជាតិ ដែលមិនមានសមត្ថកិច្ចចូលរួម ឬធ្វើការវិនិច្ឆ័យសេចក្តីសម្រេច ដែលត្រូវធ្វើដោយតុលាការកម្ពុជាឡើយ។ លើសពីនេះទៀត ចៅក្រមកម្ពុជានៅ អ.វ.ត.ក មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិបន្ថែមពីលើសិទ្ធិដទៃទៀត ដែលចៅក្រមកម្ពុជាមាន[៤៣៨]។

---

[៤៣៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ២៣ និង២៤, (ដកស្រង់ នូវករណីរដ្ឋអាជ្ញាទល់នឹង *Milutinović* សំណុំរឿងលេខ IT-05-98, សេចក្តីសម្រេចលើបណ្តឹងរបស់ Dragoljub Ojdanić ប្តឹងជំទាស់ នឹងបញ្ហាយុត្តាធិការ-សហឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ១០)។

[៤៣៨] សេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ E39/5 កថាខណ្ឌ១១។

២១៩. ក្នុងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ សម្រាប់សំណុំរឿង០០១ ("សាលក្រមសំណុំរឿង០០១") បើទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនបានកត់សម្គាល់ដោយផ្ទាល់អំពីលក្ខណៈរបស់ អ.វ.ត.ក ថាជាតុលាការជាតិ ឬអន្តរជាតិ តែអង្គជំនុំជម្រះមួយនេះបានអនុវត្តនូវគោលការណ៍នីត្យានុកូលភាព ចំពោះបញ្ហាទាំងឡាយដែលស្ថិតនៅចំពោះមុខខ្លួន[៤៣៩]។

២២០. ក្នុងសេចក្ដីសម្រេចកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ថ្មីៗនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់បានថ្លែងថារាល់តុលាការ និងអង្គជំនុំជម្រះទាំងឡាយណាដែលបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋ និងអង្គការសហប្រជាជាតិ គឺជាតុលាការអន្តរជាតិ មិនមែនជាតុលាការដែលមានលក្ខណៈជាតិនោះឡើយ៖

> គ្រប់យ៉ាងគឺខុសប្លែកគ្នានៅកម្រិតអន្តរជាតិ។ ក្នុងផ្នែកនេះ មិនមានប្រព័ន្ធយុត្តិធម៌នោះទេ។ តុលាការ និងអង្គជំនុំជម្រះត្រូវបានបង្កើតឡើងដោយឯកឯងដោយរដ្ឋ ឬដោយអង្គការអន្តររដ្ឋាភិបាល ដូចជាអង្គការសហប្រជាជាតិ ឬក៏បង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរដ្ឋ និងអង្គការទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងទាំងនេះមិនបង្កើតឱ្យមានអង្គតុលាការដែលមានការទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនោះឡើយ។ ជាការពិត អង្គជំនុំជម្រះនីមួយៗ បានបង្កើតឱ្យមានជាអង្គភាពស្វយ័តឯករាជ្យ ឬក៏ជាអង្គភាពមួយដែលគេហៅថា "អង្គភាពដែលមិនទំនាក់ទំនងជាមួយផ្នែកខាងក្រៅ" ឬ "ប្រភេទមួយនៃអតិសុខុមប្រាណ ដែលមានកោសិកាតែមួយ (unicellular organism)")[៤៤០]។

២២១. ដោយមិនមានសំអាងហេតុរឹងមាំពីសហមេធាវីការពារក្ដី សម្រាប់ដាក់ជូនមកអង្គបុរេជំនុំជម្រះ ដើម្បីធ្វើការពិចារណាឡើងវិញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនលើលក្ខណៈរបស់ អ.វ.ត.ក ថាជាតុលាការអន្តរតូបនីយកម្មនោះ អង្គបុរេជំនុំជម្រះប្រកាសគាំទ្រការសន្និដ្ឋានពីពេលមុនរបស់ខ្លួន ដូចដែលបានរៀបរាប់រួចមកហើយ។ អង្គបុរេជំនុំជម្រះនឹងមិនពិចារណាសារណាបន្ថែមពីសហព្រះរាជអាជ្ញា ឬមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានេះទេ។

---

[៤៣៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក សម្រាប់សំណុំរឿង០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ E188 ("សាលក្រម សំណុំរឿង០០១") កថាខណ្ឌ២៦ ដល់៣៤ ។

[៤៤០] CH/AC/2010/02, "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះ លើយុត្តាធិការ និង គោលជំហរ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៥១។

២២២. លក្ខណៈពិសេស និងវិសាមញ្ញនៃ អ.វ.ត.ក ជាតុលាការអន្តរតួបនីយកម្មមួយ ដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងអង្គការសហប្រជាជាតិតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើការពិនិត្យមើលលើបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព ដែលត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក។ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលយ៉ាងផ្ចិតផ្ចង់ទៅលើលិខិតុបករណ៍ដែលមានស្រាប់ ព្រមទាំងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង។

២២៣. មាត្រា៣៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក បានចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

២២៤. មាត្រា១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) បានចែងថា៖

> ១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬ ការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។
>
> ២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។

២២៥. ទាំងនេះគឺជាបទប្បញ្ញត្តិដែលត្រូវបានយោងនៅក្នុងច្បាប់ អ.វ.ត.ក ទាក់ទិនទៅនឹងគោលការណ៍នីត្យានុកូលភាពដែលត្រូវអនុវត្តដោយអង្គជំនុំជម្រះនៃ អ.វ.ត.ក។ ច្បាប់ អ.វ.ត.ក មិនបានណែនាំឱ្យអង្គជំនុំជម្រះនានានៅ អ.វ.ត.ក ពិនិត្យមើលលើបទប្បញ្ញត្តិគតិយុត្តិផ្សេងទៀត ទាក់ទិននឹងចំណុចនេះឡើយ។ ហេតុដូច្នេះហើយទើបទឡ្ហីករណ៍នានាដែលសហមេធាវីការពារក្តីបានស្នើឡើង ទាក់ទិននឹងការអនុវត្ត

នូវគោលការណ៍នីត្យានុកូលភាព ក្រៅពីទឡ្ហីករណ៍ដែលបានដកស្រង់ខាងលើ[៤៤១] នឹងមិនត្រូវបានពិចារណាឡើយ។[៤៤២]

២២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តលើបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព ដែលត្រូវបំពេញនៅចំពោះមុខ អ.វ.ត.ក គឺ៖

១) អំពើឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ ចាំបាច់ត្រូវមានចែងក្នុងច្បាប់ អ.វ.ត.ក,

២) អំពើឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ ចាំបាច់ត្រូវមានក្នុង៖

ក) ច្បាប់ជាតិ ឬ

ខ) ច្បាប់អន្តរជាតិ ឬ

គ) ជាបទឧក្រិដ្ឋយោងទៅតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ក្នុងខណៈពេលដែលប្រព្រឹត្តនូវអំពើឧក្រិដ្ឋនោះ។

៣) ការផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ ចាំបាច់ត្រូវតែដូចគ្នា ឬស្រាលជាង (ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន) ទោសដែលត្រូវដាក់ ក្នុងពេលដែលប្រព្រឹត្តិបទល្មើសនោះ។

២២៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ទាក់ទិននឹងចំណុចទី(២) ខាងលើ ដើម្បីបំពេញតាមគោលការណ៍នីត្យានុកូលភាព នៅក្នុង អ.វ.ត.ក វាគឺជាការគ្រប់គ្រាន់ក្នុងការរកឱ្យឃើញថា អំពើឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវនោះ ស្ថិតក្នុងចំណុចណាមួយ ក្នុងចំណោមចំណុចរងទាំងបី ចំណុច (ក), ចំណុច (ខ) ឬចំណុច (គ)។ អង្គបុរេជំនុំជម្រះ ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងដែរ យល់ឃើញថា "ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺជាច្បាប់ជាតិដែលនៅជាធរមានក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ

---

[៤៤១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១០៦ ដល់ ១១០។

[៤៤២] អង្គបុរេជំនុំជម្រះបានច្រានចោលនូវទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នា ដែលលើកឡើងដោយសហមេធាវីការពារក្តី អៀង សារី ក្នុងសេចក្តីសម្រេចលើសហឧក្រិដ្ឋរួម រួចមកហើយ។ សូមមើលកថាខណ្ឌ ៤៥៖ "អង្គបុរេជំនុំជម្រះ មិនយល់ស្របជាមួយទឡ្ហីករណ៍ ដែលលើកឡើងដោយ អៀង សារី ដែលថា សហចៅក្រមស៊ើបអង្កេត គួរត្រូវអនុវត្តនូវលក្ខណៈវិនិច្ឆ័យដែលតឹងតែងជាងលក្ខណៈវិនិច្ឆ័យដែលត្រូវបានអនុវត្តនៅកម្រិតអន្តរជាតិ ហើយទាមទារឱ្យមានការចែងអំពីការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ក្នុងច្បាប់កម្ពុជា ព្រោះអ.វ.ត.ក ជា "តុលាការជាតិ"។

១៩៧៩"[៤៤៣]។ អង្គជំនុំជម្រះក៏យល់ឃើញថា ពាក្យ "ច្បាប់អន្តរជាតិ" នៅក្នុងមាត្រា១៥(១) នៃ ICCPR សំដៅលើទាំងច្បាប់សន្ធិសញ្ញាអន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៤៤៤]។ ប្រសិនបើរកឃើញថា បទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ មានចែងតែក្នុងច្បាប់សន្ធិសញ្ញា នោះលក្ខខណ្ឌតម្រូវដែលត្រូវបំពេញគឺ (១) សន្ធិសញ្ញានោះត្រូវចងកាតព្វកិច្ចនៅពេលដែលបទល្មើសដែលត្រូវចោទបានកើតឡើង និង (២) សន្ធិសញ្ញានោះមិនត្រូវមានលក្ខណៈប្រឆាំងគ្នា ឬខុសពីបទដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិទេ[៤៤៥]។ ការរកឃើញថារដ្ឋមួយមានកាតព្វកិច្ចគោរពអនុសញ្ញាជាក់លាក់ណាមួយ ហើយតុលាការនៃរដ្ឋនោះបានអនុវត្តនូវបញ្ញត្តិនៃអនុសញ្ញានោះ ដោយមិនគិតថាវាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឬអត់នោះ វានឹងនាំដល់ការសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពពិតជាត្រូវបានបំពេញហើយ[៤៤៦]។ ដើម្បីឱ្យសន្ធិសញ្ញាមួយអាចចងកាតព្វកិច្ចទៅលើរដ្ឋជាភាគី វាគឺជាការគ្រប់គ្រាន់ដែលគេគ្រាន់តែបង្ហាញថា រដ្ឋជាភាគីនោះបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានោះរួចហើយ[៤៤៧]។

២២៨. អង្គបុរេជំនុំជម្រះយល់ឃើញថា គោលការណ៍នីត្យានុកូលភាពដែលត្រូវអនុវត្តទាំងចំពោះ "បទល្មើសក៏ដូចជាទម្រង់នៃការទទួលខុសត្រូវ" ដូចដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយដែលចេញដោយ [សហចៅក្រមស៊ើបអង្កេត][៤៤៨] ហើយក៏កត់សម្គាល់ថា "វិសាលភាពនៃការអនុវត្តគោលការណ៍ [នីត្យានុកូលភាព ដូចមានចែងក្នុង ICCPR] គឺទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌទាំងអស់ ទាំងអំពើសកម្ម ក៏ដូចជាអំពើអកម្មដែរ"[៤៤៩]។

---

[៤៤៣] *សូមមើល* សាលក្រមសំណុំរឿង០០១ កថាខណ្ឌ ២៩។

[៤៤៤] *សូមមើល* សាលក្រមសំណុំរឿង០០១ កថាខណ្ឌ ៣០ និង Nowak, Manfred, *U.N. Covenant on Civil and Political Rights CCPR Commentary*, N.P.Engel, ទំព័រ ២៧៦ កថាខណ្ឌ ៥ ("បទវិចារណកថា ICCPR")។

[៤៤៥] *រដ្ឋអាជ្ញា តទល់ Tadić*, IT-94-1-AR72, "សេចក្តីសម្រេចលើសារណារបស់មេធាវីការពារក្តី ស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ លើបញ្ហាយុត្តាធិការ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៤៣, សាលក្រម សំណុំរឿង០០១ កថាខណ្ឌ ៣៣។

[៤៤៦] *រដ្ឋអាជ្ញា តទល់ Kordić និងអ្នកដទៃទៀត,* IT-95-14/2-A, "សាលក្រម" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤៤។

[៤៤៧] អនុសញ្ញាទីក្រុងវីយែនស្តីអំពីច្បាប់សន្ធិសញ្ញា ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ មាត្រា ១៤។

[៤៤៨] សាលក្រម សំណុំរឿង០០១ កថាខណ្ឌ ២៨។

[៤៤៩] សាលក្រម សំណុំរឿង០០១ កថាខណ្ឌ៤៧៩ និង បទវិចារណកថា CCPR ទំព័រ ២៧៦ កថាខណ្ឌ ៧។

២២៩. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់បន្តទៀតថា គោលការណ៍នីត្យានុកូលភាពដូចដែលមានចែងក្នុងដីកាដំណោះស្រាយ[៤៥០] ហើយដែលមិនមានការជំទាស់ពីភាគីនានានោះ ទាមទារឱ្យមានការគោរពតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង។ បញ្ហាចំពោះមុខគឺផ្តោតលើលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្ត ដើម្បីបំពេញឱ្យបាននូវតម្រូវការបែបនេះក្នុងដំណើរការនីតិវិធីនេះ ក៏ដូចជាសម្រាប់បណ្តឹងឧទ្ធរណ៍ក្នុងពេលនេះដែរ។ ការលើកឡើងរបស់សហមេធាវីទាក់ទិននឹងចំណុចនេះ ត្រូវបានសង្ខេបនៅក្នុងកថាខណ្ឌ..៤ និង..៥ ខាងលើ។ សហមេធាវីបានលើកឡើងថា ដើម្បីបំពេញឱ្យបាននូវលក្ខណៈវិនិច្ឆ័យនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង បទឧក្រិដ្ឋនោះត្រូវតែមានក្នុងច្បាប់ជាតិកម្ពុជា ហើយជនជាប់ចោទមិនអាចប្រមើលមើលដឹងលើបញ្ហានេះបានទេ ព្រោះថាចំណុចទាំងនោះអាចស្ថិតក្នុង "យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ខ្លះៗ"។ ផ្នែកដទៃនៃសារណាទាក់ទិនទៅនឹងទឡ្ហីករណ៍នេះ ត្រូវបានសង្ខេបក្នុងបណ្តាកថាខណ្ឌនានាដូចខាងក្រោម។

២៣០. ក្នុងចម្លើយតបរបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញា ដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY បានលើកឡើងថា៖

> តុលាការ ICTY បានអនុវត្តយ៉ាងស៊ីសង្វាក់គ្នានូវលក្ខណៈវិនិច្ឆ័យ "ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង" ដើម្បីកំណត់ថាតើគោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភដែរ ឬយ៉ាងណា។ តាមការពិសោធន៍នេះ ការកាត់សេចក្តីពុំមែនជាការរំលោភគោលការណ៍នីត្យានុកូលភាពឡើយ ប្រសិនបើច្បាប់ដែលបង្កើតមូលដ្ឋាននៃការកាត់សេចក្តី មានភាពអាចឱ្យជនជាប់ចោទដឹងគ្រប់គ្រាន់ ហើយការកាត់សេចក្តីអំពីការរំលោភច្បាប់ អាចឱ្យជនជាប់ចោទដឹងមុនគ្រប់គ្រាន់។ ប្រសិនបើគេបានបំពេញតាមលក្ខខណ្ឌទាំងនោះ ចារីដឹងខុសត្រូវម្នាក់អាចសម្របអំពើរបស់ខ្លួនឱ្យស្របតាមច្បាប់ ហើយការកាត់សេចក្តីគឺមានភាពត្រឹមត្រូវ។ ដើម្បីវាយតម្លៃអំពីលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងនេះ តុលាការ ICTY បានចែងនូវលក្ខណៈ

[៤៥០] សហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់បញ្ហានេះ ដូចមានចែងក្នុងកថាខណ្ឌ ១៣០២ នៃដីកាដំណោះស្រាយដែលចែងថា "ជាងនេះទៅទៀត ច្បាប់ទាំងនេះត្រូវតែមានការផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ នៅខណៈពេលដែលអង្គហេតុបានកើតឡើង ហើយជនជាប់ចោទត្រូវឋិតក្នុងសភាពដែលអាចព្យាករណ៍ជាមុនថា ពួកគេអាចនឹងត្រូវទទួលខុសត្រូវ"។

សម្គាល់មួយចំនួនដូចខាងក្រោម ដែលអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច បានលើកយកមកសំអាង៖

> ចំពោះការប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ ទង្វើបែបនេះគឺជាការប្រព្រឹត្តពិតប្រាកដរបស់ជនជាប់ចោទ។ គាត់ត្រូវតែអាចដឹងថា ការប្រព្រឹត្តនោះ គឺជាអំពើឧក្រិដ្ឋនៅក្នុងវិញ្ញាណដែលអាចដឹងជាទូទៅដោយគ្មានសំអាងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ។ ចំពោះការដឹងថាមានច្បាប់ចែងនៅក្នុងករណីតុលាការអន្តរជាតិ ដូចជាករណីតុលាការនេះជាដើម ការដឹងថាមានច្បាប់ចែងបានរួមបញ្ចូលទាំងបទប្បញ្ញត្តិច្បាប់ ដែលផ្អែកលើទំនៀមទម្លាប់ផងដែរ។

ការពិចារណាពាក់ព័ន្ធទៅនឹងការវាយតម្លៃលើលក្ខខណ្ឌតម្រូវនៃ ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង រួមមានដូចខាងក្រោម៖

> (១) ភាពគួរឱ្យរន្ធត់ និងភាពអសីលធម៌នៃអំពើណាមួយអាចរួមចំណែកក្នុងការច្រានចោលការអះអាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលអះអាងថាមិនបានដឹងពីភាពឧក្រិដ្ឋរបស់អំពើនោះ។
>
> (២) ការដែលថាឧក្រិដ្ឋកម្មណាមួយ ឬទម្រង់នៃការទទួលខុសត្រូវណាមួយមានលក្ខណៈជាទំនៀមទម្លាប់ គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់ថាលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងនេះ ត្រូវបានបំពេញ។

ការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈយោគយល់ ឬជំរុញដល់អំពើជាក់លាក់នានា នឹងមិនរាំងដល់ការកាត់សេចក្តី និងផ្តន្ទាទោសដល់ចារីបានទេ ដែលអំពើប្រព្រឹត្តិទាំងនោះរបស់គាត់គឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិនោះ។

នៅក្នុងសំណុំរឿង ឌុច អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គេអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលជនជាប់ចោទអាចត្រូវបានកាត់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា ច្បាប់ដែលចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ អាចឱ្យគេដឹងបានយ៉ាងគ្រប់គ្រាន់ថាមានចែង ដោយពិចារណាទៅលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ក្នុងចំណោមចំណុចផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើការទទួលស្គាល់បទល្មើសនៅក្នុងច្បាប់អន្តរជាតិ តាំងពីសម័យតុលាការ Nuremberg ក៏ដូចជាលក្ខណៈគួរឱ្យរន្ធត់នៃបទល្មើសដែលត្រូវបានចោទប្រកាន់ផងដែរ។ ជា

ការពិតចំណុចនេះមានភាពដូចគ្នា ចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទនៅក្នុងសំណុំរឿង០០២[៤៥១]។

២៣១. ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ច្បាប់ដែលចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងគ្រប់គ្រាន់ ដោយពិចារណាទៅលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមទៀតថា ការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាពគឺគ្មានព្រំដែនកំណត់ ទាំងក្នុងក្របខ័ណ្ឌពេលវេលា ទាំងក្របខ័ណ្ឌភូមិសាស្ត្រ ហើយជនជាប់ចោទបានដឹងពីបទឧក្រិដ្ឋដែលខ្លួនត្រូវបានចោទប្រកាន់ ដោយសារលក្ខណៈគួរឱ្យតក់ស្លុតនៃបទឧក្រិដ្ឋទាំងនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀតថា ក្រោយសង្គ្រាមលោកលើកចុងក្រោយ ជនជាប់ចោទបានរស់នៅប្រទេសបារាំង ដែលនៅទីនោះបណ្តាញសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត មានការចុះផ្សាយពីកិច្ចពិភាក្សារយៈពេលយូរ និងក្បោះក្បាយ អំពីសញ្ញាណស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ពួកគាត់បានបញ្ជាក់ជាឧទាហរណ៍ "នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ១៩៦០ សារព័ត៌មាន Humanité ដែលជាសារព័ត៌មានរបស់បក្សកុម្មុយនីស្តបារាំង បានដាក់ចំណងជើងអត្ថបទមួយចុះផ្សាយថា "ជនជម្លៀសពីរនាក់នៅក្នុងជំរំមរណៈរបស់អាល្លឺម៉ង់" ដោយមានអមដោយរូបភាពមួយចំនួន។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងបន្ថែមថា ក្នុងខ្សែភាពយន្តរឿង ការប្រឈមនឹងអំពើប្រល័យពូជសាសន៍ - ខៀវ សំផន និងប៉ុល ពត (Facing Genocide – Khieu Samphan and Pol Pot) របស់លោក David Aronwitsch និងលោក Staffan Lindberg ស្តែងឱ្យឃើញថា កាលពីឆ្នាំ ១៩៧៦ នាទីក្រុងប៉ារីស លោក សឹន សាន អតីតសមាជិករដ្ឋាភិបាលរបស់ព្រះអង្គម្ចាស់សីហនុ បានអំពាវនាវឱ្យលោក ខៀវ សំផន ត្រឡប់មករកផ្លូវត្រូវវិញ ដោយប្រកាសថា នយោបាយដែលគាត់ប្រកាន់យក មានលក្ខណៈអត្តឃាត និងមិនអាចយល់បាន ដោយសារវាចេញអំពីសំណាក់អ្នកស្នេហាជាតិខ្មែរ"។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ដោយសារជនជាប់ចោទទាំងនេះបានកាន់តំណែង នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ទើបពួកគេអាចដឹងអំពីព័ត៌មានដ៏ស៊ីជម្រៅ ស្តីអំពីច្បាប់ជាធរមាន និងអនុសញ្ញាអន្តរជាតិដែលអាចអនុវត្តបាន។ ការដឹងឮនេះកាន់តែច្បាស់ទៅទៀតដោយមូលហេតុថា នៅដើមឆ្នាំ១៩៧៨ សមាជិកនៃកម្ពុជាប្រជាធិបតេយ្យពុំបានរារែកក្នុងការសុំអន្តរាគមន៍ នៅមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីថ្កោលទោសការឈ្លានពាន និងការរំលោភបំពានខាងយោធា ពីសំណាក់វៀតណាម។ ដើម

[៤៥១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៥៦ ដល់ ១៥៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

បណ្តឹងរដ្ឋប្បវេណីបន្តបន្ថែមថា ជនជាប់ចោទ "សុទ្ធតែជាសមាជិកបក្សកុម្មុយនីស្ត ហើយបានតាមដានព័ត៌មានដោយចំណាប់អារម្មណ៍ខ្លាំង ដូចដែលសហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ ពួកគាត់តាមដានយ៉ាងជិតដិតលើសារព័ត៌មានអន្តរជាតិ ក៏ដូចជាមតិនានារបស់ប្រជាជនខ្មែរដែលរស់នៅបរទេស"។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អះអាងថា ជនជាប់ចោទមិនមែនជា "ប្រជាជនសាមញ្ញ" ទេ តែពួកគេជាសមាជិកនៃ "អាជ្ញាធរដឹកនាំរបស់កម្ពុជា" ហេតុដូច្នេះ ពួកគាត់អាចទទួលបាននូវព័ត៌មានជាច្រើនទាក់ទងជាពិសេសដល់ការជំនុំជម្រះសេចក្តីជាអន្តរជាតិល្បីៗ ដូចជាការជំនុំជម្រះនៅ Nuremberg និងទីក្រុងតូក្យូ ក៏ដូចជាការផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ ដើមបណ្តឹងរដ្ឋប្បវេណីទទូចទាមទារថា ជនជាប់ចោទមិនអាចថាមិនបានដឹងអំពីការផ្តន្ទាទោសជាឯកច្ឆន្ទ លើឧក្រិដ្ឋកម្មដ៏ឃោរឃៅដែលត្រូវបានប្រព្រឹត្តឡើង ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ហើយជាលទ្ធផលបង្កឱ្យមានប្រតិកម្មចំពោះឧក្រិដ្ឋកម្មទាំងនោះ ដែលប្រតិកម្មទាំងនេះកើតចេញពីសង្គម ក៏ដូចជាតុលាការនានា[៤៥២]។

២៣២. សហមេធាវីការពារក្តីបានលើកឡើង ក្នុងសារណាតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាថា៖

> នៅក្នុងកថាខណ្ឌ ១៥៦ ក.ស.ព អះអាងថា តុលាការ ICTY បានអនុវត្តយ៉ាងស៊ីសង្វាក់គ្នានូវលក្ខណៈវិនិច្ឆ័យ "ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង" ដើម្បីកំណត់ថា គោលការណ៍នីត្យានុកូលភាព ត្រូវបានរំលោភដែរឬយ៉ាងណា ហើយថាអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *ឌុច* អនុវត្តតាមវិធីសាស្ត្រនេះ។ អង្គបុរេជំនុំជម្រះមិនត្រូវយកយុត្តិសាស្ត្រតុលាការ ICTY មកអនុវត្ត ដោយគ្មានការវិភាគឯករាជ្យ ថាតើយុត្តិសាស្ត្រនេះ ត្រឹមត្រូវដែរឬយ៉ាងណានោះទេ។ សាលក្រម *ឌុច* មានទម្ងន់តិចតួច ទាក់ទិនទៅនឹងច្បាប់ដែលអាចអនុវត្តបាន ដោយសារតែបញ្ហានេះ ដូចគ្នាជាមួយនឹងបញ្ហាគតិយុត្តិផ្នែកយុត្តាធិការស្ទើរតែទាំងអស់ដទៃទៀត មិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី។
>
> ក្នុងកថាខណ្ឌ ១៥៧ ក.ស.ព អះអាងថា ការពិចារណាពាក់ព័ន្ធនឹងការវាយតម្លៃលើលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង រួមមាន៖ ភាពគួរឱ្យរន្ធត់ និងភាពអយុត្តិធម៌នៃអំពើមួយ និងការដែលថាឧក្រិដ្ឋកម្មណាមួយ ឬទម្រង់នៃការទទួលខុសត្រូវមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ក.ស.ព អះអាងថា ការអនុវត្តរបស់រដ្ឋដែលឃោគយល់ ឬជំរុញដល់អំពើមួយ នឹងមិនរារាំងដល់ការកាត់

[៤៥២] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

សេចក្តី និងផ្តន្ទាទោស ដល់ចារីបានទេ នៅពេលដែលអំពើទាំងនោះ គឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ។ ទាក់ទិនទៅនឹងភាពគួរឱ្យរន្ធត់ ឬភាពអសីលធម៌នៃអំពើមួយ វាអាចដូច្នេះមែន ប្រសិនបើជនជាប់ចោទប្រព្រឹត្តអំពើមួយដោយខ្លួនឯង ដែលជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលរូបគាត់អាចប្រមើលដឹងជាមុនបានថាអំពើនោះគឺជាបទឧក្រិដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ ដូចជា JCE និងការទទួលខុសត្រូវក្នុងការចេញបញ្ជា នោះវាកាន់តែមានការពិបាកថែមទៀតក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មនោះអាចប្រមើលមើលដឹងជាមុនបាន។

ប្រហែលជាមិនមានទស្សនាទានពង្រីកសញ្ញាណទំនៀមទម្លាប់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឱ្យលើសពីការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ ចំពោះអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់នោះឡើយ។ ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាការទទួលខុសត្រូវនៃការខកខានដែលជនល្មើសត្រូវផ្តន្ទាទោសចំពោះការ*មិនបាន*ប្រព្រឹត្ត។ ប៉ុន្តែវាមានន័យច្រើនជាងនេះទៀត។ ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាក់លាក់ មិនមែនដោយសារអំពើរបស់គាត់ស្ថិតនៅក្នុងនិយមន័យរបស់បទឧក្រិដ្ឋនោះទេ ប៉ុន្តែដោយសារគាត់ខកខានមិនបានទប់ស្កាត់ការប្រព្រឹត្តបទឧក្រិដ្ឋនោះ ពីសំណាក់អ្នកដទៃ។ អ្វីដែលសំខាន់នោះគឺថា ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាក់ស្តែងរបស់អ្នកនៅក្រោមបង្គាប់ មិនមែនចំពោះបទល្មើសដាច់ដោយឡែក ដែលត្រូវបានផ្តោតទៅលើសេចក្តីធ្វេសប្រហែលក្នុងករណីកិច្ចរបស់អ្នកចេញបញ្ជានោះទេ។

ដូច្នេះវាមិនគ្រប់គ្រាន់ទេក្នុងការបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌ នឹងអាចត្រូវបានប្រមើលមើលដឹងជាមុនបាន ដោយផ្អែកលើលក្ខណៈនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ។ អង្គបុរេជំនុំជម្រះគួរតែបន្តការអនុវត្តពីមុនៗរបស់ខ្លួននៃការសម្រេចថាតើជនជាប់ចោទពិតជាអាចប្រមើលមើលដឹងជាមុនអំពីការទទួលខុសត្រូវឬយ៉ាងណា ជាជាងគ្រាន់តែស្វះស្វែងរក ថាតើការទទួលខុសត្រូវមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬយ៉ាងណានោះ។

ក្នុងកថាខណ្ឌ ១៥៨ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច សម្រេចថាគេអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលឌុចអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់។ អង្គបុរេជំនុំជម្រះគួរតែមានការប្រុងប្រយ័ត្នក្នុងការផ្អែកទៅលើសាលក្រម ឌុច ទាក់ទិននឹងបញ្ហានេះ។ បញ្ហាទាំងនេះមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តីឡើយ។ អង្គបុរេជំនុំជម្រះ

ត្រូវតែកំណត់ថាតើបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានអនុវត្តនោះ គឺពិតជាអាចប្រមើលមើលដឹងជាមុនចំពោះលោក អៀង សារី ដែរឬទេ[៤៥៣]។

២៣៣. ក្នុងសារណាតបទៅនឹងសេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តីបានលើកឡើងថា ខ្លួនមិនជំទាស់ទៅនឹងអ្វីដែលថាចរិតលក្ខណៈឃោរឃៅនៃបទល្មើស ត្រូវបានពិចារណាថាជាកត្តាមួយ ដើម្បីកំណត់អំពីភាពអាចប្រមើលមើលឃើញជាមុនឡើយ។ ប៉ុន្តែ "អំពើអសីលធម៌ ឬលក្ខណៈឃោរឃៅនៃទង្វើមួយ មិនមែនជាកត្តាគ្រប់គ្រាន់ដើម្បីធានាឱ្យទង្វើនោះក្លាយជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"។ សហមេធាវីការពារក្តីបានជំទាស់ថា "ឋានៈតួនាទីរបស់ជនជាប់ចោទ ជាមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ មិនឈានដល់ការសន្និដ្ឋានថា គាត់គួរតែអាចប្រមើលមើលឃើញជាមុន នូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមិននៅជាធរមាននៅក្នុងច្បាប់កម្ពុជាក្នុងអំឡុងពេលនោះឡើយ" ហើយសហមេធាវីបន្ថែមថា"វាប្រហែលជាអាចទៅរួច បើសិនជាជនជាប់ចោទប្រព្រឹត្តដោយផ្ទាល់នូវអំពើមួយដែលមានលក្ខណៈជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើបំពារបំពានធ្ងន់ធ្ងរ ជននោះអាចប្រមើលមើលឃើញជាមុនថាទង្វើបែបនោះគឺជាបទល្មើស។ ប៉ុន្តែនៅពេលមានការជាប់ពាក់ព័ន្ធជាមួយទម្រង់នៃការទទួលខុសត្រូវដូចជា សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាមានការលំបាកក្រៃលែង ដើម្បីសន្មតថាការទទួលខុសត្រូវគឺអាចប្រមើលមើលឃើញជាមុនបាននោះ[៤៥៤]។

២៣៤. ទាក់ទិនទៅនឹងសារណារបស់ភាគីនានា ដែលស្នើអំពីការពឹងផ្អែក ឬការប្រុងប្រយ័ត្នក្នុងការពឹងផ្អែកទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១នោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្នុងករណីដែលខ្លួនយល់ថាសមស្រប អង្គបុរេជំនុំជម្រះនឹងពឹងផ្អែកទៅលើសាលក្រមនេះទាក់ទងទៅនឹងសេចក្តីសម្រេចក្នុងសាលក្រមនោះ ហើយអង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា សុពលភាពនៃសេចក្តីសម្រេចមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង មិនត្រូវបានភាគីនានាជំទាស់នោះឡើយ។

---

[៤៥៣] ចម្លើយតបរបស់អៀង សារី កថាខណ្ឌ៧៦ ដល់៧៨។

[៤៥៤] ចម្លើយតបរបស់អៀង សារីចំពោះសេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី២ កថាខណ្ឌ១៨ និង១៩។

២៣៥. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់បន្ថែមថា ខ្លួនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍នានាទាក់ទិនទៅនឹងភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង នៅក្នុងសាលដីកាលើកមុន លើបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងលើមូលដ្ឋានប្រហាក់ប្រហែលគ្នានេះ ហើយនៅក្នុងសាលដីកានោះ អង្គបុរេជំនុំជម្រះបានយល់ឃើញដូចខាងក្រោម៖

> អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាសេចក្តីសម្រេច ICTY មួយចំនួន បង្កប់ន័យថា ប្រសិនបើទម្រង់នៃការទទួលខុសត្រូវមួយ មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាពាក់ព័ន្ធ លក្ខខណ្ឌនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងលក្ខខណ្ឌដឹងថាមានច្បាប់ចែងអាចនឹងត្រូវបានសន្មតផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា វាកាន់តែច្បាស់លាស់ ប្រសិនបើយើងមិនត្រឹមតែរកឃើញថាតើ JCE មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាដែលពាក់ព័ន្ធ ដូច្នេះអាចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែយើងក៏ត្រូវរកឲ្យឃើញថាតើជនត្រូវចោទដឹងថាមានច្បាប់ចែង និងអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋដែរឬទេ។ ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលដឹងថាជាបទឧក្រិដ្ឋ ជនត្រូវចោទត្រូវតែអាចបង្ហាញថា អំពើនោះគឺជាអំពើព្រហ្មទណ្ឌ នៅក្នុងអារម្មណ៍ដែលអាចដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ។ ចំពោះលក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែង វាក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែលផ្អែកលើទំនៀមទម្លាប់ផងដែរ។ ផ្ទុយទៅនឹងអ្វីដែលអះអាងដោយដើមបណ្តឹងឧទ្ធរណ៍ បញ្ហាចោទថាតើ JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលបានទទួលស្គាល់ នៅក្នុងច្បាប់ជាតិដែរឬយ៉ាងណា បញ្ហាចោទនេះអាចមានលក្ខណៈពាក់ព័ន្ធ នៅពេលកំណត់ថាតើជនត្រូវចោទអាចប្រមើលមើលដឹងថាតើ ទង្វើដែលចោទប្រកាន់លើខ្លួនអាចនាំឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែរឬទេ។ ប៉ុន្តែវាមិនមានលក្ខខណ្ឌតម្រូវថា ក្រៅពីជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក JCE ក៏អាចផ្តន្ទាទោសបានតាមច្បាប់ជាតិដែរ[៤៥៥]។

២៣៦. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា លក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង ដូចបានរៀបរាប់ខាងលើ ក៏ស្របគ្នានឹងលក្ខខណ្ឌតម្រូវនានា ដែលបាន

---

[៤៥៥] សូមមើល សាលដីកាលើ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៥។ សូមមើលផងដែរ កថាខណ្ឌ ៤៣ និង ៤៣ នៃសាលដីកាមួយនេះ។

ចែងដោយតុលាការអន្តរជាតិ ដែលមានលក្ខណៈជាតុលាការតំបន់ ដូចជាតុលាការសិទ្ធមនុស្សអឺរ៉ុប (ECHR)[៤៥៦]។ គោលការណ៍នីត្យានុកូលភាពនៃ ECtHR មានចែងនៅក្នុងអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប[៤៥៧]។ ក្នុងរឿងក្តី *Kononov* តុលាការ ECtHR បានសម្រេចថា៖

> នៅពេលនិយាយពី "ច្បាប់" មាត្រា៧ និយាយទៅដល់ទស្សនាទានដូចគ្នាទៅនឹងអ្វីដែលអនុសញ្ញាបាននិយាយយោង នៅគ្រប់ពេលដែលប្រើប្រាស់ពាក្យនេះ។ នេះជាទស្សនាទានដែលរួមមានច្បាប់ជាលាយលក្ខណ៍អក្សរ និងច្បាប់ដែលមិនមានជាលាយលក្ខណ៍អក្សរ ហើយដែលផ្តោតទៅលើលក្ខខណ្ឌតម្រូវផ្នែកគុណភាព ដូចជាលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង។ ទាក់ទិនទៅនឹងភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង តុលាការសូមរំឭកថា បើទោះបីជាបទប្បញ្ញត្តិច្បាប់ត្រូវបានតាក់តែងយ៉ាងច្បាស់លាស់យ៉ាងណាក៏ដោយ ហើយទោះនៅក្នុងប្រព័ន្ធច្បាប់ណាក៏ដោយ រួមទាំងច្បាប់ព្រហ្មទណ្ឌ ក៏វាតែងតែមានសមាសធាតុនៃការបកស្រាយរបស់តុលាការដោយជៀសមិនផុត។ ជាចាំបាច់គឺតែងតែមានលក្ខខណ្ឌតម្រូវឱ្យមានការពន្យល់នូវចំណុចមន្ទិលសង្ស័យ ព្រមទាំងសម្រាប់ការសម្របសម្រួលទៅនឹងស្ថានភាពផ្លាស់ប្តូរនានា។ ជាការពិតនៅក្នុងរដ្ឋជាភាគីនៃអនុសញ្ញា ការវិវឌ្ឍន៍ទៅមុខនៃច្បាប់ព្រហ្មទណ្ឌ តាមរយៈការបង្កើតច្បាប់ដោយតុលាការ គឺជាផ្នែកដ៏សំខាន់ និងពុំអាចប្រកែកបានក្នុងប្រពៃណីនៃច្បាប់។ មាត្រា៧ នៃអនុសញ្ញាមិនអាចបកស្រាយថា ការបញ្ជាក់ទៅលើវិធាននានាទាក់ទិននឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ តាមរយៈការបកស្រាយរបស់តុលាការទៅតាមករណីនីមួយៗ ជាការល្មើសច្បាប់នោះឡើយ លើកលែងតែក្នុងករណីដែលការវិវឌ្ឍន៍នៃលទ្ធផល មិនស៊ីសង្វាក់ជាមួយនឹងលក្ខណៈនៃបទល្មើស ហើយភាពមិនស៊ីសង្វាក់គ្នានេះ អាចប្រមើលមើលដឹងតាមហេតុផល

---

[៤៥៦] អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនអាចស្វែងរក ការណែនាំចេញពីយុត្តិសាស្ត្រនៃតុលាការ ECHR ទាក់ទិនទៅនឹងគោលការណ៍នីត្យានុកូលភាព ព្រោះមាត្រា៧ របស់តុលាការ ECHR ត្រូវបានប្រើជាគំរូសម្រាប់សេចក្តីព្រៀង មាត្រា១៥ នៃ ICCPR (សូមមើលវិចារណកថា ICCPR ទំព័រ២៧៥) ហើយតាមរយៈការអានលើមាត្រាទាំងពីរនេះ គឺវាមានលក្ខណៈសឹងតែដូចគ្នាតែម្តង។

[៤៥៧] ECHR, មាត្រា 7; ECtHR, *Sunday Times* ***តទល់នឹង*** *United Kingdom*, ពាក្យស្នើសុំលេខ ៦៥៣៨/៧៤ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៧៩ កថាខណ្ឌ ៤៩; ECtHR, *X Ltd and Y* ***តទល់នឹង*** *United Kingdom*, ពាក្យស្នើសុំលេខ 8710/79, 1982 កថាខណ្ឌ ៩; ECtHR, *G* ***តទល់នឹង*** *Federal Republic of Germany*, ពាក្យស្នើសុំលេខ 13079/87, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៨៩, កថាខណ្ឌ ១; ECtHR, *Kokkinakis* ***តទល់នឹង*** *Greece*, ពាក្យស្នើសុំលេខ 14307/88, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣, កថាខណ្ឌ ៥២; ECtHR, *C.R.* ***តទល់នឹង.*** *United Kingdom*, ពាក្យស្នើសុំលេខ 87 Kb20190/92, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៣២ ដល់ ៣៤; ECtHR, *S.W.* ***តទល់នឹង*** *United Kingdom*, ពាក្យស្នើសុំលេខ 92 Kb20166/92, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៣៤ ដល់ ៣៦។

សមស្រប។(*Streletz, Kessler* និង *Krenz v. Germany* [GC], nos. 34044/96, 35532/97 និង 44801/98, § 50, ECHR 2001-II; *K.-H.W.* តទល់នឹង. *Germany* [GC], no. 37201/97, § 85, ECHR 2001-II (អត្ថបទដកស្រង់); *Jorgic* តទល់. *Germany*, no. 74613/01, §§ 101-109, 12 កក្កដា 2007; និង *Korbely v. Hungary* [GC], no. 9174/02, §§ 69-71, 19 កញ្ញា 2008)[៤៥៨]។

២៣៧. អង្គបុរេជំនុំជម្រះពិចារណាថា ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង នៅក្នុងដំណើការនីតិវិធីនាពេលនេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើល តែលើបញ្ហា ថាតើលក្ខណៈវិនិច្ឆ័យសត្យានុម័តត្រូវបានបំពេញដែរឬទេ ព្រោះការពិនិត្យមើលទៅលើ លក្ខណៈវិនិច្ឆ័យអត្តនោម័ត ទាមទារឲ្យមានការសម្រេចលើអង្គហេតុ ដែលការងារនេះមិនស្ថិតនៅ ក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះឡើយ។ លក្ខណៈវិនិច្ឆ័យសត្យានុម័តនៃភាពអាចប្រមើលដឹង ថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង គឺស្របទៅនឹងសេចក្តីសម្រេចនានា កន្លងមករបស់ អង្គបុរេជំនុំជម្រះ ក៏ដូចជាការបែងចែកតាមប្រព័ន្ធនូវដែនសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ និងដែន សមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងតាមរយៈវិធានផ្ទៃក្នុង។ ដោយមិនបានដាក់បញ្ចូលនូវអង្គ ហេតុទៅក្នុងសំណុំរឿងបច្ចុប្បន្ន ទើបអង្គបុរេជំនុំជម្រះគ្រាន់តែត្រូវពិនិត្យមើល ថាតើសហចៅក្រម ស៊ើបអង្កេតបានលើកជាភស្តុតាងឬអត់ ថាជនត្រូវចោទមានហេតុផលអាចដឹងពីស្ថានភាពនៃបញ្ញត្តិ ច្បាប់ទាក់ទងទៅនឹងបទឧក្រិដ្ឋ ព្រមទាំងទម្រង់នៃការទទួលខុសត្រូវដែលកំពុងចោទជាបញ្ហានៅក្នុង ពេលជាក់លាក់មួយនោះ។

២៣៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីឲ្យបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអាចបំពេញបាន នៅ អ.វ.ត.ក លក្ខខណ្ឌតម្រូវនៃអត្ថិភាពបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ មិនមែនជាអាជ្ញាបញ្ញានោះ ឡើយ តែលក្ខខណ្ឌតម្រូវការនេះមានលក្ខណៈជាលក្ខខណ្ឌដែលមានក៏បាន និងគ្មានក៏បាន។ គ្រាន់តែ រកឲ្យឃើញថាបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវនោះពិតជាមានអត្ថិភាពនៅក្នុងស្ថាប័នច្បាប់ ណាមួយ ដូចមានបង្ហាញក្នុងចំណុច (២) នៃកថាខណ្ឌ២២៦ ខាងលើគឺជាការគ្រប់គ្រាន់ណាស់ទៅ ហើយ។

---

[៤៥៨] ECtHR, *Kononov* តទល់នឹង *Latvia*, ពាក្យស្នើសុំលេខ 36376/04, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១៨៥ (មានការគូសបញ្ជាក់បន្ថែម)។

២៣៩. ដូចគ្នានឹងការពន្យល់នៅខាងក្រោម អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសង្ខេបរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទិនទៅនឹងគោលការណ៍នីត្យានុកូលភាព ដែលត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក ដែលមាននៅក្នុងកថាខណ្ឌ១៣០១ ដល់១៣០៤ នៃដីកាដំណោះស្រាយ គឺត្រឹមត្រូវ។

២៤០. ដោយកម្រិតកំណត់ត្រឹមតែបញ្ហាដែលបានលើកឡើងក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណានៅក្នុងកថាខណ្ឌជាបន្តបន្ទាប់ អំពីថាតើក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមានបានរកឃើញថា អំពើឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ ដែល អៀង សារី ត្រូវបានចោទប្រកាន់នោះ មាននៅក្នុងច្បាប់ ដែលស្ថិតក្រោមលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌទាំង៣ ដូចក្នុងចំណុច (២) នៃកថាខណ្ឌ ២២៦ ខាងលើដែរឬទេ។ អង្គបុរេជំនុំជម្រះក៏នឹងពិចារណាថាតើសហចៅក្រមស៊ើបអង្កេត មានបានបង្ហាញថា ជនជាប់ចោទមានហេតុផលនឹងអាចដឹងអំពីច្បាប់នៅពេលដែលអង្គហេតុបានកើតឡើងដែរឬទេ។

២៤១. ជាបឋម អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើប-អង្កេតបានចោទប្រកាន់ អៀង សារី លើ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជ-សាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ (“ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ”)។ អៀង សារី ត្រូវបានចោទប្រកាន់ជាមួយទម្រង់នៃការទទួលខុសត្រូវដែលរួមមាន៖ សហឧក្រិដ្ឋកម្មរួម ការរៀបចំផែនការ ការញុះញង់ឱ្យមានការប្រព្រឹត្ត ការបញ្ជា ឬការសមគំនិតដោយការជួយ និងជំរុញ (“ការរៀបចំផែនការនិងការញុះញង់ឱ្យមានការប្រព្រឹត្ត”) ព្រមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើ។

<u>ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖</u>

២៤២. កថាខណ្ឌ១៣១០ នៃដីកាដំណោះស្រាយ ចែងថា៖

> នៅពេលដែលប្រទេសកម្ពុជាចូលក្នុង “សហភាពបារាំង” ក្នុងឆ្នាំ ១៩៤៩ ប្រទេសកម្ពុជាបានទទួលនូវស្វ័យភាពអធិបតេយ្យគ្រប់គ្រាន់ ក្នុងការចូលជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិបានទទួលយកការផ្តល់សច្ចាប័នចូលជាសមាជិករបស់

កម្ពុជា ហើយក៏មិនមានការជំទាស់លើទិដ្ឋភាពគតិយុត្តិណាមួយផងដែរ។ អនុសញ្ញានេះបានទទួលនូវការផ្តល់សច្ចាប័នចូលជាសមាជិកចំនួន ២0 ដែលចាំបាច់ដល់ការចូលជាធរមាន នៅក្នុងឆ្នាំ ១៩៥១។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង។

២៤៣. អង្គបុរេជំនុំជម្រះបានពិនិត្យមើលលើប្រភពទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់សម្រាប់គាំទ្រដល់ការយល់ឃើញរបស់ខ្លួន ក្នុងកថាខណ្ឌ១៣១0 នៃដីកាដំណោះស្រាយនេះ ហើយអង្គបុរេជំនុំជម្រះយល់ឃើញថា ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មាននៅក្នុងច្បាប់ ក្នុងពេលដែលអង្គហេតុបានកើតឡើងនោះ គឺត្រឹមត្រូវ។ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាច្បាប់សន្ធិសញ្ញាដែលចងកាតព្វកិច្ចលើប្រទេសកម្ពុជាយ៉ាងជាក់ច្បាស់ ដោយសារការចូលជាសមាជិកនៃអនុសញ្ញានេះ នៅពេលដែលបទល្មើសដែលត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើងក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត បានបំពេញនូវលក្ខខណ្ឌមួយនៃលក្ខខណ្ឌមួយនានាសម្រាប់គោលការណ៍នីត្យានុកូលភាព ដូចបានរៀបរាប់ពីខាងលើ។

២៤៤. ទោះបីជាអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនត្រូវបានអនុវត្តក្នុងច្បាប់កម្ពុជា ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ក៏ដោយ ក៏អនុសញ្ញានេះត្រូវបានគ្របដណ្តប់ដោយគោលការណ៍ *កិច្ចព្រមព្រៀងត្រូវតែគោរព (pacta sunt servanda)* [៤៥៩]។ ដូចដែលក្រុមមេធាវី *Avocats San Frontiéres* បានកត់សម្គាល់ក្នុងសារណារបស់ពួកគាត់ថា មាត្រា២៧ នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីនីតិនៃកិច្ចព្រមព្រៀង បានហាមឃាត់ភាគីណាមួយ មិនឱ្យលើកឡើងពីបទប្បញ្ញត្តិនៃនីតិក្នុងស្រុករបស់ខ្លួន ដើម្បីដោះសារពីការមិនអនុវត្តអនុសញ្ញា[៤៦0]។ បន្ថែមពីលើនេះ លក្ខណៈ*អាជ្ញាបញ្ញា* នៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ គឺល្មមគ្រប់គ្រាន់សម្រាប់ធ្វើយុត្តិកម្មលើការចោទប្រកាន់ ដោយមិនចាំបាច់គិតពីបទប្បញ្ញត្តិជាក់លាក់ណា

---

[៤៥៩] មាត្រា ២៦ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា, "សន្ធិសញ្ញាទាំងឡាយណាដែលចូលជាធរមាន គឺត្រូវចងកាតព្វកិច្ចលើភាគីដែលជាសមាជិក ហើយភាគីទាំងនោះត្រូវគោរពតាមសន្ធិសញ្ញានោះ"។

[៤៦0] សេចក្តីសង្កេតរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី១ កថាខណ្ឌ១៥។

មួយនៃច្បាប់កម្ពុជានោះឡើយ[៤៦១]។ កត្តាទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ថាបុគ្គលទាំងឡាយអាចត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

២៤៥. ក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា សហមេធាវីការពារក្តីមិនបានជំទាស់ពីវត្តមាននៃច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ ប៉ុន្តែសហមេធាវីបែរជាលើកឡើងពីបញ្ហាដែលថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមានចែងក្នុងច្បាប់កម្ពុជា ហេតុដូច្នេះ អៀង សារី មិនអាចដឹងពីការទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍ ក្នុងពេលដែលអង្គហេតុបានកើតឡើងឡើយ។ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា បើទោះបីជាកម្ពុជាមិនបានអនុម័តច្បាប់ដែលផ្តល់អំណាចសម្រាប់ការអនុវត្ត ដែលជាកាតព្វកិច្ចរបស់ខ្លួន តាមមាត្រា៥ នៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដោយ ក៏ការនេះមិនបានធ្វើឲ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវនោះឡើយ[៤៦២]។ ការអនុម័តច្បាប់ដែលផ្តល់អំណាចសម្រាប់ការអនុវត្ត មិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ឲ្យអនុសញ្ញានេះមានសិទ្ធិចងកាតព្វកិច្ចលើរដ្ឋជាភាគីនោះទេ តែវាគ្រាន់តែជាកាតព្វកិច្ចមួយដែលរដ្ឋជាភាគីត្រូវបំពេញ ក្រោយពីបានអនុម័តនូវសន្ធិសញ្ញាមួយដែលបានចូលជាធរមានរួចហើយ តាមរយៈការដែលរដ្ឋនោះបានក្លាយជាភាគីនៃអនុសញ្ញានោះ។ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា វាគឺជាគោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់[៤៦៣] ដែលចែងថា៖

---

[៤៦១] សូមមើលជាឧទាហរណ៍របាយការណ៍ដែលមានចំណងជើងថា *Advisory Opinion on the Reservations to the Genocide Convention*, របាយការណ៍ ICJ, 1951 (n.114) 52 (ផ្តល់យោបល់ថា បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គួរត្រូវបានបកស្រាយថា "ចងកាតព្វកិច្ចចំពោះ [បណ្តារដ្ឋនានា] បើទោះបីជារដ្ឋទាំងនោះមិនបានទទួលស្គាល់ដោយចំហក៏ដោយ៖ អនុសញ្ញាបែបនេះ បង្កើតឲ្យមាននូវទំនៀមទម្លាប់ចងកាតព្វកិច្ច ឬក៏បង្កើតនូវគោលការណ៍ដែលរដ្ឋទាំងអស់ត្រូវគោរពតាម ដោយសារហេតុផលនៃការពឹងផ្អែកទៅវិញទៅមក និងដោយសារវត្តមាននៃអង្គការអន្តរជាតិ។

[៤៦២] អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រាV៖ ភាគីដែលចុះហត្ថលេខា ត្រូវអនុម័តច្បាប់ដែលចាំបាច់សម្រាប់ផ្តល់អំណាច ដល់បទប្បញ្ញត្តិនានានៃអនុសញ្ញានេះ ដោយយោងតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសខ្លួន ហើយជាពិសេសត្រូវដាក់ទណ្ឌកម្មដោយមានប្រសិទ្ធភាព ចំពោះបុគ្គលដែលមានពិរុទ្ធភាព លើបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬក៏អំពើនានាដូចមានចែងក្នុងមាត្រា III។

[៤៦៣] សូមមើលរឿងក្តីរដ្ឋអាជ្ញា *Attorney General of Israel v Eichmann* តុលាការកំពូលប្រទេសអ៊ីស្រាអែល (១៩៦២) បោះពុម្ពឡើងវិញក្នុង 36 *ILR* 28, ("សំណុំរឿង Eichmann"), ទំព័រ២៩៦ ដល់ ២៩៧ (អង់គ្លេស) និងអត្ថបទស្រាវជ្រាវរបស់ Machteld Boot, ក្រោមចំណងជើងថា "Genocide, crimes against humanity, war crimes: *nullum crimen sine lege* and the subject matter jurisdiction of the International Criminal Court, *School of Human Rights Research Series*, V. 12), 14។

ការដែលច្បាប់ក្នុងស្រុក មិនបានដាក់ទណ្ឌកម្មលើអំពើមួយដែលត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ តាមច្បាប់អន្តរជាតិ មិនមែនមានន័យថា បុគ្គលដែលបានប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការទទួលខុសត្រូវតាមច្បាប់អន្តរជាតិនោះឡើយ[៦៦៤]។

២៤៦. ចំណែកឯលក្ខខណ្ឌដទៃទៀតនៃគោលការណ៍នីត្យានុកូលភាពវិញ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងកថាខណ្ឌ ១៣០៥ នៃដីកាដំណោះស្រាយដែលថា ព្រោះអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "មានអានុភាពគតិយុត្តិចាប់បង្ខំតម្រូវឲ្យកម្ពុជាត្រូវតែគោរពតាម" ហើយ "បទប្បញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដែលអាចឲ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា" គឺជាការត្រឹមត្រូវ ហើយគោរពទៅតាមលក្ខណៈវិនិច្ឆ័យសត្យានុម័ត នៃភាពអាចដឹងថាមានច្បាប់ចែង។ អង្គហេតុដែលថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាបទល្មើស ក៏ផ្សព្វផ្សាយដល់ជនជាប់ចោទផងដែរ ព្រោះដោយសារតែលក្ខណៈជាទំនៀមទម្លាប់ ដែលមានស្រាប់នៅក្នុងវិធាន ដែលត្រូវបានប្រើប្រាស់ជាគោលក្នុងការតាក់តែង អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយក៏ដោយសារតែលក្ខណៈនៃសិទ្ធិដែលត្រូវបានគេរំលោភបំពាន។ ក្នុងស្ថានភាពនេះ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៤៦ ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលបានទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយបានយល់ស្របថា នេះជាការជូនដំណឹងដល់បុគ្គលគ្រប់រូបឲ្យបានដឹងថា ខ្លួននឹងត្រូវរងការចោទប្រកាន់ចំពោះបទល្មើសមួយនេះ ហើយបុគ្គលទាំងអស់មិនអាចលើកពីច្បាប់ក្នុងស្រុកដើម្បីការពារខ្លួនពីបទចោទបែបនេះឡើយ[៦៦៥]។ ក្នុងទស្សនៈអ្នកជំនាញរបស់ខ្លួន លើរក្សាទុកខ្លឹមសារអនុសញ្ញានេះ តុលាការយុត្តិធម៌អន្តរជាតិបានចែងថា៖

ចេតនាដើមរបស់អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បានបង្ហាញថា វាជាចេតនារបស់អង្គការសហប្រជាជាតិ ដើម្បីផ្តន្ទាទោស និងដាក់ទណ្ឌកម្ម លើអំពើប្រល័យពូជសាសន៍ ថាជា "បទឧក្រិដ្ឋតាមច្បាប់អន្តរជាតិ" ដែលបទឧក្រិដ្ឋនេះរួមមានការបដិសេធនូវសិទ្ធិរបស់មនុស្សជាតិទាំងមូល ដែលការបដិសេធនូវសិទ្ធិបែបនេះ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់

---

[៦៦៤] *គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញរបស់តុលាការ* Nuremberg *និងនៅក្នុងសាលក្រមរបស់តុលាការនេះ។* International Law Commission: 1950, ("គោលការណ៍ Nuremberg"), គោលការណ៍ II។

[៦៦៥] ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ UN G.A. Res. 96(I) អនុម័តនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦។

មនសិការមនុស្សជាតិ ហើយជាលទ្ធផលនាំដល់ការបាត់បង់យ៉ាងធំធេងដល់មនុស្សជាតិ ហើយការនេះផ្ទុយទៅនឹងច្បាប់សីលធម៌ ព្រមទាំងស្មារតី និងគោលបំណងនៃអង្គការសហប្រជាជាតិ។ ផលវិបាកជាដំបូង ដែលលេចឡើងពីទស្សនាទាននេះ គឺគោលការណ៍ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រទេសនានា ជាការចងកាតព្វកិច្ចចំពោះរដ្ឋ បើទោះជារដ្ឋនោះមិនមានកាតព្វកិច្ចផ្នែកអនុសញ្ញាក៏ដោយ[៤៦៦]។

២៤៧. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ព្រមទាំងសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) បន្ថែមពីលើអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាការជូនដំណឹងដល់បុគ្គលនានាថា អំពើប្រល័យពូជសាសន៍ ជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយអ្នករំលោភបំពាននឹងត្រូវទទួលការជំនុំជម្រះ បើទោះបីជាមិនមានច្បាប់ក្នុងស្រុកក៏ដោយ។ ការជូនដំណឹងនេះធ្វើឡើងតាំងពីជាងម្ភៃឆ្នាំ មុនពេលដែលបទល្មើសដែលរងការចោទប្រកាន់ ក្នុងសំណុំរឿងនេះត្រូវបានប្រព្រឹត្តឡើង។

២៤៨. បន្ថែមពីលើនេះទៀត និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជានិយមន័យមួយដែលមានលក្ខណៈជាសកល អាចប៉ាន់ស្មានបាន និងមិនប្រែប្រួល ហើយនិយមន័យនេះត្រូវបានកំណត់ដូចគ្នាក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏ដូចជាក្នុងច្បាប់ អ.វ.ត.ក។

២៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តដោយត្រឹមត្រូវនូវបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព ទាក់ទិនទៅនឹងបទចោទប្រល័យពូជសាសន៍។ ដូច្នេះមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះត្រូវបានបដិសេធចោល។

<u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

---

[៤៦៦] “ការរក្សាទុកអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើអំពើប្រល័យពូជសាសន៍ (ទស្សនៈអ្នកជំនាញ)”, *របាយការណ៍ ICJ* 16, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៥១ ដកស្រង់ក្នុងរបាយការណ៍ដែលមានចំណងជើងថា *Legality of the Threat or Use of Nuclear Weapons (Advisory Opinion), របាយការណ៍ ICJ* 226, ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣១។

២៥០. ក្នុងកថាខណ្ឌ ១៣១៣ នៃដីកាដំណោះស្រាយ៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចាត់ទុកជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង"។

២៥១. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា ក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីមិនបានជំទាស់ពីវត្តមាននៃច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងពេល ដែលអង្គហេតុបានកើតឡើងនោះទេ។ សហមេធាវីការពារក្តីបានជំទាស់ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការយល់ឃើញថា "ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងគ្រប់គ្រាន់" តាមរយៈការជំនុំជម្រះនានា ដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅទីក្រុង Nuremburg និងទីក្រុង តូក្យូ"[៤៦៧]។

២៥២. ក្នុងករណីនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងកថាខណ្ឌ ១៣០៦ នៃដីកាដំណោះស្រាយ ដែលថា "ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ ការកំណត់ថាអំពើនេះជាបទល្មើសដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ តាមរយៈការជំនុំជម្រះនានា ដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅទីក្រុង Nuremburg និងទីក្រុងតូក្យូ"។

២៥៣. ដោយមិនអនុវត្តនូវអង្គហេតុចំពោះសំណុំរឿងបច្ចុប្បន្ន អង្គបុរេជំនុំជម្រះគ្រាន់តែត្រូវធ្វើការពិនិត្យមើល ថាតើសហចៅក្រមស៊ើបអង្កេតបានលើកយកនូវភស្តុតាង ដែលបង្ហាញថាជនត្រូវចោទមានហេតុផលនឹងអាចដឹងអំពីស្ថានភាពនៃច្បាប់អន្តរជាតិ ទាក់ទិនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់ នៅក្នុងពេលដែលអង្គហេតុបានកើតឡើង។ ក្រោយពីបានអានកថាខណ្ឌ១៣០៦ និង ១៣១៣ នៃដីកាដំណោះស្រាយរួចមក អង្គបុរេជំនុំជម្រះបានយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបំពេញនូវលក្ខណៈវិនិច្ឆ័យបែបសត្យានុម័ត។ ដូច្នេះការត្រួតពិនិត្យទៅលើប្រភពព័ត៌មានដែលបានប្រើប្រាស់សម្រាប់គាំទ្រដល់កថាខណ្ឌ១៣១៣ នៃដីកាដំណោះស្រាយ បានបង្ហាញថាក្នុងឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានឯកភាពជាឯកច្ឆន្ទ លើគោលការណ៍

[៤៦៧] សូមមើលសេចក្តីសង្ខេប ទឡ្ហីករណ៍របស់សហមេធាវី ក្នុងកថាខណ្ឌ២០៦ ខាងលើ។

Nuremberg[៤៦៨] ហើយនៅក្នុងឆ្នាំ ១៩៥០ គណៈ កម្មការច្បាប់អន្តរជាតិ បានតាក់តែងគោលការណ៍ ដោយអនុលោមទៅតាមសេចក្តីណែនាំរបស់មហាសន្និបាតក្នុងឆ្នាំ១៩៤៧[៤៦៩]។ អង្គហេតុទាំងនេះ បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងគោលការណ៍ បានទទួលឋានៈជាច្បាប់ ទំនៀមទម្លាប់ ក្នុងអំឡុងឆ្នាំ ១៩៥០។ ការទទួលបានឋានៈនេះជាការបង្ហាញយ៉ាងប្រាកដថា លក្ខខណ្ឌ នៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង ត្រូវបាន បំពេញ[៤៧០]។ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា គោលការណ៍ទី I នៃគោលការណ៍ Nuremberg ចែងថា៖ "បុគ្គលណាដែលប្រព្រឹត្តអំពើដែលចាត់ទុកថាជាបទល្មើសតាមច្បាប់អន្តរជាតិ ត្រូវទទួល ខុសត្រូវចំពោះអំពើនោះ ហើយត្រូវទទួលទណ្ឌកម្ម"។ ជាងនេះទៅទៀត នាចុងឆ្នាំ ១៩៥០ មហា សន្និបាតអង្គការសហប្រជាជាតិ បានសម្រេចថាត្រូវផ្សព្វផ្សាយគោលការណ៍ Nuremberg ទៅឱ្យ រដ្ឋាភិបាលនៃរដ្ឋជាសមាជិក ដើម្បីធ្វើការផ្តល់មតិយោបល់ និងការសង្កេតនានា ដើម្បីជួយដល់ការ រៀបចំនូវសេចក្តីព្រាងនាអនាគតសម្រាប់ច្បាប់ស្តីពីបទល្មើសប្រឆាំងសន្តិសុខ និងសុវត្ថិភាពមនុស្ស ជាតិ[៤៧១]។ អង្គបុរេជំនុំជម្រះសូមធ្វើការកត់សម្គាល់ថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងគោលការណ៍ Nuremberg ដែលប្រហាក់ប្រហែលនឹងនិយមន័យដែលមានចែង ក្នុងច្បាប់ អ.វ.ត.ក នោះ គឺមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុង ឆ្នាំ ១៩៧៥។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងស្ថានការណ៍ដូចដែលបានរៀបរាប់ក្នុងដីកា ដំណោះស្រាយ រួមទាំងលក្ខណៈឃោរឃៅនៃបទល្មើស ប្រាកដជាធ្វើឱ្យបុគ្គលទាំងនោះបានដឹងថា ខ្លួនអាចត្រូវទទួលរងការចោទប្រកាន់ចំពោះបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២៥៤. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តដោយត្រឹមត្រូវនូវបទដ្ឋាននៃ គោលការណ៍នីត្យានុកូលភាព ទាក់ទិនទៅនឹងបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះត្រូវបានបដិសេធចោល។

---

[៤៦៨] ការឯកភាពលើគោលការណ៍ ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការ Nuremberg។ G.A. Res. 95 (I), U.N. GAOR, 1st Sess., pt. 2, ត្រង់ 1144, U.N. Doc. A/236, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[៤៦៩] ការបង្កើតនូវគោលការណ៍ដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការ, U.N. G.A. Res. 177(II), 123rd Pl. Mtg., ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧, ("ការបង្កើតគោលការណ៍ Nuremberg")។

[៤៧០] ការបង្កើតគោលការណ៍ Nuremberg។

[៤៧១] ការបង្កើតគោលការណ៍ Nuremberg U.N. G.A. Res. 488(v), 320th Pl. Mtg., ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៥០។

<u>ការបំពារបំពានធ្ងន់ធ្ងរ</u>

២៥៥. កថាខណ្ឌ១៣១៦ នៃដីកាដំណោះស្រាយបានចែងថា៖

> “ការបំពារបំពានធ្ងន់ធ្ងរ” លើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង។ អនុសញ្ញាទាំងនេះបានចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០។ ប្រទេសកម្ពុជាបានចូលជាសមាជិក នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ១៩៥៨ ក្នុងឋានៈជារដ្ឋអធិបតេយ្យ ហើយមិនមានការជំទាស់លើទិដ្ឋភាពគតិយុត្តិណាមួយ ទាក់ទងនឹងការចូលជាសមាជិកនេះឡើយ។

២៥៦. ក្រោយពីបានពិនិត្យមើលលើប្រភពដែលសហចៅក្រមស៊ើបអង្កេត បានប្រើប្រាស់សម្រាប់គាំទ្រដល់ការយល់ឃើញរបស់ខ្លួន ក្នុងកថាខណ្ឌ១៣១៦ នៃដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថាការបំពារបំពានធ្ងន់ធ្ងរមានចែងក្នុងច្បាប់ ក្នុងពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺត្រឹមត្រូវ។ អនុសញ្ញាទីក្រុងហ្សឺណែវគឺពិតជាច្បាប់សន្ធិសញ្ញា ដែលចងកាតព្វកិច្ចចំពោះកម្ពុជា ដោយសារកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញានេះ ហើយវាចងកាតព្វកិច្ចចំពោះកម្ពុជា ក្នុងពេលដែលបទល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត គឺគ្រប់គ្រាន់សម្រាប់ការបំពេញលក្ខខណ្ឌនៃគោលការណ៍នីត្យានុកូលភាព[៤៧២]។ អង្គបុរេជំនុំជម្រះក៏សូមកត់សម្គាល់បន្ថែមថា អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន មានចែងនូវបទប្បញ្ញត្តិយ៉ាងច្បាស់ដែលថា ការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញា បង្កើតជាយុត្តាធិការព្រហ្មទណ្ឌ ជាសកល និងចាំបាច់ ក្នុងចំណោមរដ្ឋដែលជាសមាជិក[៤៧៣]។ បន្ថែមពីលើនេះទៀត លក្ខណៈ*អាជ្ញាបញ្ញា* នៃបទឧក្រិដ្ឋ លើការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលត្រូវបានចោទប្រកាន់

---

[៤៧២] *សូមមើល* សេចក្ដីអង្កេតរបស់អង្គបុរេជំនុំជម្រះ ត្រង់កថាខណ្ឌ២៤៤ ខាងលើ ក្នុងសាលដីកានេះ។

[៤៧៣] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១២៩, អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៦។

ក្នុងដីកាដំណោះស្រាយ គឺមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើយុត្តិកម្មការជំនុំជម្រះ ដោយមិនចាំបាច់គិតដល់បទប្បញ្ញត្តិជាក់លាក់ណាមួយនៃច្បាប់ក្នុងស្រុករបស់កម្ពុជានោះឡើយ[៤៧៤]។

២៥៧. ពាក់ព័ន្ធនឹងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងវិញ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងកថាខណ្ឌ១៣០៥ នៃដីកាដំណោះស្រាយដែលថា ដោយសារតែការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញា "មានអានុភាពគតិយុត្តិចាប់បង្ខំតម្រូវឱ្យកម្ពុជាត្រូវតែគោរពតាម" និងថា "បទប្បញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដែលអាចឱ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា" គឺត្រឹមត្រូវ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុសញ្ញាទីក្រុងហ្សឺណែវ បានរារាំង ព្រមទាំងកំណត់នូវបណ្តាបទល្មើសនានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ក៏ដូចជាក្នុងដីកាដំណោះស្រាយ ថាជាបទល្មើសព្រហ្មទណ្ឌ[៤៧៥]។ ការណ៍ដែលថាការបំពារបំពានធ្ងន់ធ្ងរ គឺជាបទល្មើសព្រហ្មទណ្ឌ ត្រូវបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនជាប់ចោទ ដោយសារតែលក្ខណៈទំនៀមទម្លាប់ដែលមានស្រាប់នៃវិធាន ដែលត្រូវបានដកស្រង់យកមកតាក់តែងជាអនុសញ្ញាទីក្រុងហ្សឺណែវ ហើយដោយសារតែលក្ខណៈនៃសិទ្ធិដែលត្រូវបានរំលោភបំពាន។

២៥៨. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តដោយត្រឹមត្រូវនូវបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព ទាក់ទិនទៅនឹងបទចោទការបំពារបំពានធ្ងន់ធ្ងរ។ ដូច្នេះមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះត្រូវបានបដិសេធចោល។

<u>ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនានា</u>

២៥៩. កថាខណ្ឌ ១៣១៨ នៃដីកាដំណោះស្រាយបានចែងថា៖

[៤៧៤] សូមមើលជាឧទាហរណ៍សៀវភៅដែលមានចំណងជើងថា *Legality of the Threat or Use of Nuclear Weapons*, ទស្សនៈអ្នកជំនាញ, ICJ (ICJ Reports 1996), ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៧៩ (ចែងថា អនុសញ្ញាទីក្រុងហ្សឺណែវ "ត្រូវតែគោរពដោយរដ្ឋទាំងអស់បើទោះបីជារដ្ឋនោះ បាន ឬមិនបានផ្តល់សច្ចាប័ន លើអនុសញ្ញានេះក៏ដោយ [...]ព្រោះអនុសញ្ញានេះបង្កើតជាគោលការណ៍ មិនអាចបំពារបំពានបាន [Sic] នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។

[៤៧៥] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ១៣០, អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ១៤៧។

ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជាក្នុងពេលដែលអង្គហេតុបានកើតឡើង។ អនុលោមតាមមាត្រានេះ ជនសង្ស័យណាមួយដែលបានប្រព្រឹត្ត (រួមបញ្ចូលផងដែរនូវការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម/JCE៖ JCE I ឬ JCE II) បញ្ជាឲ្យប្រព្រឹត្ត ញុះញង់ឲ្យប្រព្រឹត្ត រៀបចំផែនការ ឬសមគំនិតដោយការជួយ ឬជំរុញ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មទាំងនោះ។

២៦០. ក្រោយពីបានពិនិត្យមើលលើប្រភពដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់សម្រាប់គាំទ្រដល់ការយល់ឃើញរបស់ខ្លួន ក្នុងកថាខណ្ឌ១៣១៨ នៃដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលថាគ្រប់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវ មានចែងក្នុងច្បាប់ ក្នុងពេលដែលបទល្មើសដែលរងការចោទត្រូវបានប្រព្រឹត្ត គឺជាការត្រឹមត្រូវ[៤៧៦]។

២៦១. ទាក់ទិននឹងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា កថាខណ្ឌទី១៣០៧ នៃដីកាដំណោះស្រាយបានចែងថា៖

> ក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក ក៏មានទម្រង់នៃការទទួលខុសត្រូវមួយចំនួនត្រូវបានទទួលស្គាល់ផងដែរ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដូចមានបញ្ជាក់ខាងក្រោមនេះ។ ហេតុដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ។ ហើយចំពោះទម្រង់នៃការទទួលខុសត្រូវដែលនៅសេសសល់វិញ ដូចជា សហឧក្រិដ្ឋកម្មរួម (JCE) ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាក៏ត្រូវបានទទួលស្គាល់ផងដែរ ដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះនានាដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយដល់ជនត្រូវចោទ។

[៤៧៦] សម្រាប់ព័ត៌មានបន្ថែម ស្តីពីការយល់ឃើញរបស់អង្គបុរេជំនុំជម្រះទៅលើបញ្ហានេះ សូមមើលផ្នែកពិភាក្សាលើអង្គសេចក្តីនៃមូលដ្ឋានទី១១ របស់បណ្តឹងឧទ្ធរណ៍ ដែលមាននៅផ្នែកខាងក្រោម ក្នុងសេចក្តីសម្រេចនេះ។

២៦២. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីមិនបានជំទាស់ពីវត្តមានទម្រង់នៃការទទួលខុសតាមផ្លូវច្បាប់ ក្នុងពេលដែលអង្គហេតុបានកើតឡើងនោះទេ។ សហមេធាវីការពារក្តីបានជំទាស់ថា "លោក អៀង សារី មិនអាចប្រមើលមើលដឹងថាគាត់អាចត្រូវគេជំនុំជម្រះទោសក្នុងតុលាការជាតិ [...] ចំពោះទម្រង់នៃការទទួលខុសត្រូវ ដែលមិនមានចែងក្នុងច្បាប់ជាតិនោះឡើយ ក្នុងពេលដែលអង្គហេតុបានកើតឡើង។ ទម្រង់ [...] នៃការទទួលខុសត្រូវទាំងនេះ មិនត្រូវបានផ្សព្វផ្សាយដល់លោក អៀង សារី នោះឡើយ ព្រោះទម្រង់ទាំងនេះមាននៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ខ្លះៗតែប៉ុណ្ណោះ"។

២៦៣. អង្គបុរេជំនុំជម្រះសូមអះអាងសាជាថ្មីថា ដើម្បីបំពេញបានតាមលក្ខណៈវិនិច្ឆ័យលើភាពអាចប្រមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែងនៅក្នុង អ.វ.ត.ក អង្គបុរេជំនុំជម្រះនឹងអនុវត្តនូវបទដ្ឋានអន្តរជាតិសម្រាប់គោលការណ៍នីត្យានុកូលភាព។ ដូច្នេះការពិតដែលថា ការយល់ដឹងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺពិតជាកត្តាចង្អុលបង្ហាញយ៉ាងសំខាន់សម្រាប់បញ្ហានេះ។ អង្គបុរេជំនុំជម្រះនឹងផ្តល់នូវសំអាងហេតុលម្អិតបន្ថែមទៀតចំពោះបញ្ហានេះ នៅក្នុងផ្នែកពិភាក្សាលើអង្គសេចក្តីនៃមូលដ្ឋានទី១១ របស់បណ្តឹងឧទ្ធរណ៍ក្នុងផ្នែកខាងក្រោម នៃសេចក្តីសម្រេចនេះ។

២៦៤. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តដោយត្រឹមត្រូវនូវបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព ចំពោះទម្រង់នៃការទទួលខុសត្រូវ។ ដូច្នេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះត្រូវបានបដិសេធចោល។

២៦៥. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានបដិសេធចោល។

### ៤. មូលដ្ឋានទីប្រាំ (បទល្មើសជាតិ)

#### <u>សេចក្តីសង្ខេបសារណានានា៖</u>

២៦៦. សហមេធាវីការពារក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយសម្រេចថា អ.វ.ត.ក មានយុត្តាធិការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក (បទល្មើសជាតិ)។ ការភ័ន្តច្រឡំដែលបានលើកឡើងដោយសហមេធាវីការពារក្តីរួមមាន៖

ក. ការអនុវត្តមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក រំលោភសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានសមភាពចំពោះមុខច្បាប់ ដែលធានាដោយមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា៧ នៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស ("UDHR") និងមាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយសារបទប្បញ្ញត្តិនេះអនុវត្តបាននៅពេលដែលឧក្រិដ្ឋកម្ម ត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក តែប៉ុណ្ណោះ។

ខ. ការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក រំលោភដល់គោលការណ៍អប្រតិសកម្មនៃច្បាប់ដែលមានចែងក្នុងមាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មាត្រា១១(២) នៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

គ. វាជាការភ័ន្តច្រឡំដែលសហចៅក្រមស៊ើបអង្កេតអនុវត្តមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ទោះបីមានការខ្វែងយោបល់គ្នាក្នុងចំណោមពួកគេគាត់ក៏ដោយ។

ឃ. សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអង្គហេតុ ដើម្បីគាំទ្រដល់ការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ទេ ហើយក៏ខកខានមិនបានបញ្ជាក់ ថាតើទម្រង់នៃការទទួលខុសត្រូវណាខ្លះដែលត្រូវយកមកអនុវត្ត ចំពោះឧក្រិដ្ឋកម្មដែលបានលើកមកនោះដែរ។

២៦៧. សហព្រះរាជអាជ្ញាបានឆ្លើយតបថា "ការពន្យារអាជ្ញាយុកាលមិនបានរំលោភដល់គោលការណ៍នីត្យានុកូលភាពទេ ដោយសារថា ឧក្រិដ្ឋកម្មដែល [...] អៀង សារី ត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក ដូចគ្នាបេះបិទនឹងអាជ្ញាយុកាលនៃបទឧក្រិដ្ឋដែលកើតឡើងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[៤៧៧]។ នៅគ្រប់ករណីទាំងអស់ ការកំណត់ជាបទល្មើសនូវឧក្រិដ្ឋកម្មទាំងនេះគឺជាគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ហេតុនេះ អនុលោមតាមមាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គោលការណ៍នីត្យានុកូលភាពមិនអាចរារាំងមិនឲ្យជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងនោះទេ[៤៧៨]។ សហព្រះរាជអាជ្ញាលើកឡើងថា ចិរវេលាអាជ្ញាយុកាលមិនបានផុតរលត់ទៅ នៅពេលមានការពន្យារជាលើកដំបូងនៅឆ្នាំ ២០០១ ដោយសារ

---

[៤៧៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ៨៧។ *សូមមើលផងដែរ* កថាខណ្ឌ៩០-៩៤។

[៤៧៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ៩៥-៩៧។

00661658



អាជ្ញាយុកាលត្រូវព្យួរ[៤៧៩] រហូតដល់ពេលមានការបង្កើតរដ្ឋកម្ពុជានៅឆ្នាំ ១៩៩៣[៤៨០] និងជាងនេះទៀត ប្រទេសកម្ពុជាមានកាតព្វកិច្ចជាអន្តរជាតិក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះ និងកាតព្វកិច្ចក្នុងការបង្កើតបញ្ញត្តិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានទៅលើអនុសញ្ញានានាស្តីពីអំពើទារុណកម្ម[៤៨១]។ សហព្រះរាជអាជ្ញាបានលើកឡើងថែមទៀតថា "សេចក្តីសម្រេចក្នុងជំនុំជម្រះ [អៀង សារី] នៅចំពោះមុខនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញ ស្របទៅនឹងសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់គាត់ ផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសមហេតុផល និងជាសត្យានុម័តដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ"[៤៨២] ហើយថា ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាក៏បានបញ្ជាក់រួចមកហើយនូវការពន្យារចិរវេលាអាជ្ញាយុកាលជាពិសេសនៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ដែលចែងពីសិទ្ធិស្មើគ្នាចំពោះមុខច្បាប់[៤៨៣]។

២៦៨. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមមេធាវីគ្មានព្រំដែនប្រទេសបារាំង) បានឆ្លើយតបស្របគ្នានឹងសហព្រះរាជអាជ្ញាដែរ ដោយលើកឡើងថា ចិរវេលាអាជ្ញាយុកាលត្រូវបានព្យួរទុករហូតដល់ឆ្នាំ ១៩៩៣ ហេតុនេះវាមិនទាន់ផុតកំណត់ទេនៅឆ្នាំ២០០១ នៅពេលដែលអាជ្ញាយុកាលត្រូវបានពន្យារ[៤៨៤] ហើយថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានរារាំងមិនឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូន អៀង សារី ទៅជំនុំជម្រះពីបទល្មើសជាតិទេ[៤៨៥]។ សហមេធាវីទាំងនោះបានបន្ថែមទៀតថា "ត្រូវបញ្ជូនជនជាប់ចោទទៅជំនុំជម្រះចំពោះបទល្មើសជាតិ ដើម្បី

---

[៤៧៩] ការព្យួរទុក ជាទ្រឹស្តីច្បាប់ដែលអនុញ្ញាតឱ្យមានការផ្អាក ឬពន្យារការអនុវត្តចិរវេលានៃអាជ្ញាយុកាល។

[៤៨០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ៨៧។ សូមមើលផងដែរ កថាខណ្ឌ ១០៧-១១៤។

[៤៨១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ៨៧។ សូមមើលផងដែរ កថាខណ្ឌ១១៩-១២១។

[៤៨២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ៨៨។ សូមមើលផងដែរ កថាខណ្ឌ១២៥-១៣០។

[៤៨៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ, កថាខណ្ឌ១០០-១០២។

[៤៨៤] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកទី១, កថាខណ្ឌ ៣៨-៣៩។

[៤៨៥] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកទី១, កថាខណ្ឌ ៤១។

បញ្ចៀសហានិភ័យ ក្នុងការដែលជនជាប់ចោទត្រូវបានលើកលែងការចោទប្រកាន់ទាំងអស់ដទៃទៀត ប្រឆាំងនឹងរូបគាត់នៅក្នុងដំណាក់កាលជំនុំជម្រះ”។[៤៨៦]

២៦៩. សហមេធាវីការពារក្តី អៀង សារី បានឆ្លើយតបថា “ដែនកំណត់នៃគោលការណ៍ជំនុំជម្រះទោស ប្រកបដោយយុត្តិធម៌ជាអន្តរជាតិ គឺទូលំទូលាយជាងអ្វីដែលមានបញ្ញាក់នៅក្នុងកតិកាសញ្ញាអន្តរ-ជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ” និងរួមទាំងការហាមឃាត់មិនឱ្យអនុវត្តប្រតិសកម្មនៃច្បាប់ ដែលជាផ្នែកនៃសិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[៤៨៧]។ សហមេធាវីការពារក្តីបានលើកឡើងថា ប្រទេសកម្ពុជាមិនមានតួនាទីច្បាស់លាស់ទេចំពោះករណីដែលថាតើថិរវេលាអាជ្ញាយុកាលអាច ឬមិនអាចត្រូវពន្យារពេល មុនផុតកំណត់នោះ[៤៨៨] ហើយថា ការប្រកាសរបស់ក្រុមប្រឹក្សាធម្មនុញ្ញមិនមានន័យថា អ.វ.ត.ក មានយុត្តាធិការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នោះដែរ[៤៨៩]។ ពួកគាត់យល់ឃើញបន្ថែមទៀតថា ថិរវេលាអាជ្ញាយុកាលមិនត្រូវបានព្យួរដោយអង្គនីតិបញ្ញត្តិកម្ពុជាទេ ហើយថា តាមពិតប្រព័ន្ធយុត្តិធម៌កម្ពុជាបាន “ដំណើរការ” ចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ[៤៩០]។ តាមទស្សនៈរបស់សហមេធាវីការពារក្តីយល់ឃើញថា “ពុំមានកាតព្វកិច្ចទំនៀមទម្លាប់អន្តរជាតិ មិនទទួលស្គាល់អាជ្ញាយុកាលឡើយ” ហើយបញ្ហានៅទីនេះគឺថាតើ “មានយុត្តាធិការដើម្បីជំនុំជម្រះបទល្មើសប្រហាក់ប្រហែលទៅនឹងបទល្មើសជាតិ ដោយផ្អែកលើមូលដ្ឋាននៃក្របខណ្ឌច្បាប់ជាតិ” ដែរឬទេ[៤៩១]។ ជាចុងក្រោយ សហមេធាវីការពារក្តីលើកឡើងថា បញ្ហាដែលទាក់ទិននឹងសិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់ “មិនមែនផ្អែកទៅលើ តើនរណាអាចត្រូវ

---

[៤៨៦] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកទី១, កថាខណ្ឌ ៤២។

[៤៨៧] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីការដំណោះស្រាយ, កថាខណ្ឌ ៤១។ សូមមើលផងដែរ កថាខណ្ឌ៤៣។

[៤៨៨] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីការដំណោះស្រាយ, កថាខណ្ឌ ៤៤។

[៤៨៩] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីការដំណោះស្រាយ, កថាខណ្ឌ ៤៨-៥១។

[៤៩០] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំង នឹងដីការដំណោះស្រាយ, កថាខណ្ឌ ៥៤-៥៧។

[៤៩១] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំង នឹងដីការដំណោះស្រាយ, កថសខណ្ឌ ៥៨-៥៩។

បានយកមកជំនុំជម្រះទោសនៅ អ.វ.ត.ក ឡើយ ប៉ុន្តែបញ្ហាគឺស្ថិតលើ តើច្បាប់អ្វីដែលត្រូវយកមកអនុវត្ត" ដោយយោងទៅលើអង្គហេតុដែលថា អ.វ.ត.ក កំពុងអនុវត្តច្បាប់ដែលលែងអនុវត្តបាននៅក្នុងតុលាការកម្ពុជា[៤៩២]។

២៧០. សហមេធាវីការពារក្តី អៀង សារី បានឆ្លើយតបទៅនឹងសេចក្តីសង្កេតដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយបានយោងជាសំខាន់ទៅលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាតបចំពោះសហព្រះរាជអាជ្ញា និងបានសង្កត់ធ្ងន់ថា "ប្រសិនបើច្បាប់មួយមកអនុវត្តដើម្បីចោទប្រកាន់មកលើជនជាប់ចោទម្នាក់ មិនមានអត្ថិភាព ឬពុំមានអត្ថិភាពតទៅទៀត ច្បាប់មិនត្រូវបានបង្កើត ឬមិនត្រូវមានប្រតិសកម្ម ដើម្បីបំពេញចន្លោះប្រហោងឡើយ"[៤៩៣]។

## ការពិភាក្សា

២៧១. ជាបឋម អង្គបុរេជំនុំជម្រះពិចារណាទៅលើទឡ្ហីករណ៍ទីបី ដែលបានលើកឡើងដោយសហមេធាវី ពោលគឺរកឱ្យឃើញថាតើ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយបញ្ជូន អៀង សារី ទៅជំនុំជម្រះទោសពីបទល្មើសជាតិឬទេ ទោះបីមានការខ្វែងយោបល់គ្នាក៏ដោយ មុនពេលសម្រេចថាតើការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នឹងរំលោភទៅលើគោលការណ៍នីត្យានុកូលភាព ឬសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសមភាពនៅចំពោះមុខច្បាប់ឬទេ និងចុងក្រោយ ថាតើដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានអះអាងពេញលេញឬទេ ពីអង្គហេតុ និងទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តចំពោះឧក្រិដ្ឋកម្មទាំងនេះ។

### ថាតើសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយបញ្ជូន អៀង សារី ទៅជំនុំជម្រះទោសពីបទល្មើសជាតិឬទេ ទោះបីមានការខ្វែងយោបល់គ្នាក៏ដោយ

២៧២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងដីកាដំណោះស្រាយ ផ្នែកដែលទាក់ទិននឹងបទល្មើសជាតិ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ពីអង្គហេតុទៅតាមលំដាប់លំដោយ ទាក់ទិននឹងការប្រព្រឹត្ត

[៤៩២] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំង នឹងដីការដំណោះស្រាយ, កថាខណ្ឌ ៦២-៦៣។

[៤៩៣] សារណាឆ្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីអង្កេតរួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី I, កថាខណ្ឌ ១៧។

ចំពោះបញ្ហានៅក្នុងសំណុំរឿង០០១ ដែលទទួលដោះស្រាយដោយអង្គជំនុំជម្រះនានានៃ អ.វ.ត.ក បានអនុម័តទៅតាមយោបល់ផ្សេងៗគ្នា។ សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ថា ដោយសារមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើន អង្គជំនុំជម្រះសាលាដំបូងមិនអាចកំណត់ថាមានពិរុទ្ធភាព ឬមិនមានពិរុទ្ធភាពចំពោះជនជាប់ចោទពីបទល្មើសទាំងនេះទេ ដោយសារចៅក្រមអន្តរ-ជាតិមិនអាចសន្និដ្ឋានថា ចិរវេលាអាជ្ញាយុកាលដែលអាចអនុវត្តបានចំពោះបទល្មើសជាតិ ត្រូវបានព្យួរទុក ឬមិនព្យួរទុក ចន្លោះពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ នោះទេ ហើយចៅក្រមទាំងនោះយល់ឃើញថា ការជំនុំជម្រះទោសពីបទល្មើសប្រភេទនេះលែងធ្វើបានទៀតហើយ ក្រោយពីមានការប្រកាសឱ្យប្រើមាត្រា៣ និង មាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ក្នុងឆ្នាំ ២០០១ និងឆ្នាំ ២០០៤[៤៥៤]។ នៅក្នុងស្ថានភាពបែបនេះ សហចៅក្រមស៊ើបអង្កេត ដែលទទួលសំណើពីសហព្រះរាជអាជ្ញាសុំឱ្យបញ្ជូនជនជាប់ចោទទៅជំនុំជម្រះទោសពីបទល្មើសជាតិ "កំពុងប្រឈមនឹងបញ្ហានីតិវិធីដែលមិនអាចដោះស្រាយបាន ដែលបញ្ហានេះមានជាប់ពាក់ព័ន្ធមួយផ្នែកទៅនឹងរចនាសម្ព័ន្ធចម្រុះរបស់ អ.វ.ត.ក"[៤៥៥]។ ហេតុនេះសហចៅក្រមស៊ើបអង្កេតអនុម័តយកវិធីសាស្ត្រដូចខាងក្រោម៖

សហចៅក្រមស៊ើបអង្កេតបានព្យាយាមតាក់តែងនូវគោលជំហររួមមួយ ស្តីអំពីបញ្ហានៃការកំណត់បទល្មើសត្រួតគ្នា ចំពោះអង្គហេតុតែមួយ និងបញ្ហាអាជ្ញាយុកាលចំពោះបទល្មើសជាតិ ក៏ដូចជាអំពីវិសាលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ ប៉ុន្តែការងារនេះមិនទទួលបានលទ្ធផលនោះឡើយ។ ដោយស្ថិតក្នុងស្ថានភាពលំបាកបែបនេះ និងដើម្បីចៀសវាងភាពទ័លច្រកនានា ដោយមិនចាំបាច់ឱ្យមានការប្រើប្រាស់នីតិវិធីនៃការដោះស្រាយការខ្វែងយោបល់ ដែលអាចនឹងប៉ះពាល់ដល់ដំណើរការតុលាការទាំងមូល និងដោយពិចារណាទៅលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការចេញសេចក្តីសម្រេចមួយក្នុងចិរវេលាសមស្រប ដូចមានចែងក្នុងវិធាន២១(៤) រួមទាំងការទន្ទឹងរង់ចាំអស់រយៈពេលជាយូររបស់ជនរងគ្រោះ ដែលចង់បានការស៊ើបសួរមួយដែលប្រព្រឹត្តទៅនៅក្នុងចិរវេលាមួយសមស្រប សហចៅក្រមស៊ើបអង្កេតបានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនីតិវិធី ដែលពាក់ព័ន្ធនឹងបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទាំងនោះ[៤៥៦]។

---

[៤៥៤] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧០។

[៤៥៥] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧៤។

[៤៥៦] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧៤។

២៧៣. សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា "តាមទិដ្ឋភាពនៃធាតុផ្សំបទល្មើសទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា ដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦"[៤៩៧]។

២៧៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតមិនយល់ស្របទៅតាមសំអាងហេតុតាមផ្លូវច្បាប់លើបញ្ហាថាតើ ជនជាប់ចោទគួរ ឬមិនគួរយកទៅជំនុំជម្រះចំពោះបទឧក្រិដ្ឋថ្នាក់ជាតិទេ។ ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេត "បានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា"[៤៩៨] និងបានយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានបញ្ជូនជនជាប់ចោទទៅជំនុំជម្រះពីបទឧក្រិដ្ឋថ្នាក់ជាតិ[៤៩៩]។ ការធ្វើបែបនេះ ដែលផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តីមិនបានបង្កើតជាការរំលោភដល់សិទ្ធិរបស់ជនជាប់ចោទដោយត្រូវសន្មតថាគ្មានទោស ឬការចេញសេចក្តីសម្រេចដែល *ហួសពីសិទ្ធិអំណាចរបស់ខ្លួន (ultra vires)*[៥០០] ដោយខកខានមិនបានអនុវត្តតាមនីតិវិធីនៃការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធាន៧២ នៃវិធានផ្ទៃក្នុងនោះឡើយ។ សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយដែលនៅចំពោះមុខ ហើយក្នុងករណីនេះ សេចក្តីសម្រេចនោះគឺថា "ការស៊ើបអង្កេតត្រូវតែបន្ត" ស្របទៅនឹងវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្តនៅក្នុងករណីបច្ចុប្បន្ននេះ។

២៧៥. អង្គបុរេជំនុំជម្រះរំឭកឡើងវិញថា ក្នុងករណីមានសំណើសុំបើកកិច្ចស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត និងមានបណ្តឹងឧទ្ធរណ៍មកអង្គបុរេជំនុំជម្រះនោះ រាល់ការចាត់វិធានការ ឬការទទួលយកសំណើសុំដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតតែមួយរូប នឹងត្រូវតំកល់។ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហ

---

[៤៩៧] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧៦។

[៤៩៨] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧៤។

[៤៩៩] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៧៦។

[៥០០] ពាក្យឡាតាំង ultra vires មានន័យជាភាសាអង់គ្លេសថា "មិនមានសមត្ថកិច្ច, ហួសពីដែនសមត្ថកិច្ចដែលច្បាប់អនុញ្ញាត" វចនានុក្រម Black's Law Dictionnary។

ចៅក្រមស៊ើបអង្កេតលើសំណើសុំឱ្យកោះហៅសាក្សី[៥០១] ដែលអង្គបុរេជំនុំជម្រះបានពិចារណា និងច្រានចោលសំណើនានាដែលបានធ្វើឡើងដោយជនត្រូវចោទ នួន ជា និង អៀង សារី ក្នុងការស្នើសុំយាងអតីតព្រះមហាក្សត្រកម្ពុជា និងអញ្ជើញមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលចំនួនប្រាំរូបមកស្តាប់ចម្លើយ មិនអាចផ្តល់ឱ្យបានសមរម្យទេ ប្រសិនបើសហចៅក្រមស៊ើបអង្កេតទាំងពីររូបមិនបានព្រមព្រៀងគ្នា។ ដោយសារមានតែចៅក្រមស៊ើបអង្កេតមួយរូបចុះហត្ថលេខាលើលិខិតយាង និងអញ្ជើញឥស្សរជនទាំងនោះមកផ្តល់សក្ខីកម្ម អង្គបុរេជំនុំជម្រះត្រូវតែពិចារណាថា តើគួរអនុញ្ញាតឱ្យមានសកម្មភាពបែបនេះឬទេ។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ខ្លួននឹងមិនពិចារណាលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតឡើយ ដោយសារវាមិនមែនជាកត្តាមួយរារាំងមិនឱ្យមានការបើកកិច្ចស៊ើបសួរទេ[៥០២]។

២៧៦. អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញបន្ថែមទៀតទៅលើសេចក្តីសម្រេច ដែលទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ទាក់ទិននឹងការដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរថ្មីចំនួនពីរ ទៅសហចៅក្រមស៊ើបអង្កេតសម្រាប់បើកកិច្ចស៊ើបសួរ។ អង្គបុរេជំនុំជម្រះយល់ឃើញថាវិសាលភាពនៃការពិនិត្យឡើងវិញនៅក្នុងករណីនោះ ត្រូវបានកំហិតត្រឹមការដោះស្រាយលើបញ្ហាជាក់លាក់នានា ដែលសហព្រះរាជអាជ្ញាមិនបានព្រមព្រៀងគ្នា[៥០៣]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ច្បាប់ជាធរមាននៅ អ.វ.ត.ក មានចែងពីការខ្វែងយោបល់គ្នាដែរ ហើយថា ក៏មានបញ្ញត្តិចែងពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាផងដែរ[៥០៤]។ ជាងនេះទៀត អង្គបុរេជំនុំជម្រះបានពិចារណាថា ច្បាប់ជាធរមាននៅ អ.វ.ត.ក "បង្ហាញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាមួយរូបអាចចាត់វិធានការ ដោយពុំចាំបាច់មានការព្រមព្រៀងពីសហព្រះរាជអាជ្ញាមួយរូបទៀតទេ ប្រសិនបើមិនមានសហព្រះរាជអាជ្ញាណាម្នាក់ស្នើសុំ

---

[៥០១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំឱ្យកោះហៅសាក្សី ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០១០ ឯកសារលេខ D314/1/8។

[៥០២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំឱ្យកោះហៅសាក្សី ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០១០ ឯកសារលេខ D314/1/8 កថាខណ្ឌ២៣។

[៥០៣] ការពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ("ការពិចារណាទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា") កថាខណ្ឌ២៥។

[៥០៤] ការពិចារណាទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា កថាខណ្ឌ១៦។

អង្គបុរេជំនុំជម្រះ ឱ្យសម្រេចលើការខ្វែងយោបល់នៅក្នុងពេលវេលាកំណត់នោះទេ"[៥០៥]។ ហេតុនេះ ការពិតដែលថាមានការខ្វែងយោបល់គ្នាមិនមែនមានន័យថា អនុសាសន៍របស់សហព្រះរាជអាជ្ញា មិនមានសុពលភាពនោះទេ។

២៧៧. ទោះបីទឡ្ហីករណ៍ដែលបានលើកឡើងដោយសហមេធាវីការពារក្តីត្រូវទទួលបរាជ័យក៏ដោយ ក៏ អង្គបុរេជំនុំជម្រះយល់ឃើញថា ស្ថានភាពដែលបានពណ៌នាខាងលើនាំឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាបង្គាប់ដែលមិនមានសំអាងហេតុត្រឹមត្រូវបែបនេះ។ ហេតុនេះ ទាក់ទិននឹងទឡ្ហីករណ៍ ដែលបានលើកឡើងដោយសហមេធាវីការពារក្តីនេះ អង្គបុរេជំនុំជម្រះត្រូវធ្វើការវិភាគរបស់ខ្លួនដើម្បី សម្រេចថាតើ អ.វ.ត.ក មានយុត្តាធិការទៅលើបទល្មើសជាតិឬទេ ទោះបីជាសហចៅក្រមស៊ើប អង្កេតមានការភ័ន្តច្រឡំ ដោយបញ្ជូនជនជាប់ចោទទៅជំនុំជម្រះទោសពីបទឧក្រិដ្ឋទាំងនេះ ក៏ដោយ។ ជាលទ្ធផល អង្គបុរេជំនុំជម្រះត្រូវផ្តល់នូវសំអាងហេតុរបស់ខ្លួន ចំពោះការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត។

<u>ថាតើការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នឹងរំលោភទៅលើគោលការណ៍អប្រតិសកម្មឬទេ</u>

២៧៨. អង្គបុរេជំនុំជម្រះរំឭកឡើងវិញថា បើតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិ ការក្នុងការជំនុំជម្រះទោសជនជាប់ចោទពីបទមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារ សាសនា តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៥០៦]។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅជាធរមានចំពោះយុត្តា-ធិការពេលវេលារបស់ អ.វ.ត.ក ក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[៥០៧]។ "មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ កំណត់ចិរវេលានៃអាជ្ញាយុកាលចំនួន ១០ឆ្នាំ ចំពោះបទឧក្រិដ្ឋ ០៥ឆ្នាំ ចំពោះបទមជ្ឈិម និង០១ឆ្នាំចំពោះបទលហុ។ អាជ្ញាយុកាលទាំង នេះចាប់ផ្តើមរាប់ពីពេលដែលប្រព្រឹត្តបទឧក្រិដ្ឋ និងត្រូវបានផ្តាច់ ដោយការផ្តើមកិច្ចស៊ើបសួររបស់

---

[៥០៥] ការពិចារណាទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា កថាខណ្ឌ១៦។

[៥០៦] មាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

[៥០៧] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ សេចក្តីសម្រេចស្តីពីអញ្ញត្តកម្មទាក់ទិននឹងចិរវេលានៃអាជ្ញាយុកាល ចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E187 ("សេចក្តី សម្រេចស្តីពីអញ្ញត្តកម្ម កម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ") កថាខណ្ឌ១២។

តុលាការ"[៥០៨]។ "ផ្អែកតាមការអានធម្មតាចំពោះមាត្រា១០៩ ដល់មាត្រា១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ [...] នៅក្នុងករណីដែលមិនមានកិច្ចស៊ើបសួរ ឬការចោទប្រកាន់ដែលផ្តាច់ចិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ"[៥០៩] ចិរវេលានៃអាជ្ញាយុកាលនឹងផុតរលត់ បន្ទាប់មានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពោលគឺចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៨៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៨៩[៥១០]។ ជាចុងក្រោយ "មាត្រា៣ និងមាត្រា៣ (ថ្មី) ដែលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០១ និងឆ្នាំ ២០០៤ ដំបូងបានបន្ថែមចិរវេលានៃអាជ្ញាយុកាល២០ឆ្នាំ និងក្រោយមកទៀតបានបន្ថែមចិរវេលានៃអាជ្ញាយុកាល៣០ឆ្នាំ។ សរុបទៅ ចិរវេលានៃអាជ្ញាយុកាលគឺ៤០ឆ្នាំ"[៥១១]។

២៧៩. តាមរយៈមាត្រា៣ និងមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក សភាជាតិកម្ពុជាបានពន្យារចិរវេលាអាជ្ញាយុកាលសម្រាប់បទល្មើសជាតិនានាដូចជា មនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលអាចអនុវត្តបានក្នុងអំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងពេលវេលារយៈពេល២០ឆ្នាំ ហើយក្រោយមកគឺ៣០ឆ្នាំ។ នីត្យានុកូលភាពនៃការពន្យារចិរវេលានេះតាមច្បាប់កម្ពុជា ត្រូវបានបញ្ជាក់ដោយក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១[៥១២]។

២៨០. ទាក់ទិននឹងច្បាប់កម្ពុជា អ.វ.ត.ក មិនមានអំណាចពិនិត្យឡើងវិញពីនីត្យានុកូលភាព ពីការពន្យារចិរវេលាអាជ្ញាយុកាលដែលបានសម្រេចដោយសភាជាតិ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

---

[៥០៨] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី, កថាខណ្ឌ១០។

[៥០៩] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ជើងទំព័រលេខ១៣ ("មាត្រា១១២-១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងថា កិច្ចស៊ើបសួរ និងការចោទប្រកាន់ ផ្តាច់ចិរវេលានៃអាជ្ញាយុកាល ដែលចិរវេលានេះចាប់ផ្តើមរាប់សាជាថ្មីចំនួន១០ឆ្នាំវិញ ក្រោយពីកិច្ចនៃការផ្តាច់ចុងក្រោយ (នៅក្នុងករណីបទឧក្រិដ្ឋ)")។

[៥១០] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, កថាខណ្ឌ១២។

[៥១១] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, កថា ខណ្ឌ ១៣។ មាត្រា៣៣ (ថ្មី) (២) នៃច្បាប់ អ.វ.ត.ក។

[៥១២] ក្រុមប្រឹក្សាធម្មនុញ្ញ សេចក្តីសម្រេចលេខ ០៤០/០០២/២០០១ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១។

ទេ[៥១៣]។ ហេតុនេះ ជាគោលការណ៍ មាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការដល់ អ.វ.ត.ក ទៅលើបទល្មើសជាតិ។ ទោះជាយ៉ាងណាក្តី ដូចបានសង្កត់ធ្ងន់ពីសំអាងហេតុក្នុងមូលដ្ឋានទីបីខាងលើរួចមកហើយគឺថា អ.វ.ត.ក "ត្រូវប្រតិបត្តិសមត្ថកិច្ចយុត្តាធិការរបស់ខ្លួនស្របទៅនឹងបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការតាមនីតិវិធីច្បាប់ ដូចបានចែងក្នុងមាត្រា១៤ និង១៥ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦"។ ហេតុនេះ ទាក់ទិននឹងទឡ្ហីករណ៍ដែលបានលើកឡើងដោយសហមេធាវី អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ ការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក រំលោភទៅលើគោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឬទេ។

២៨១. អង្គបុរេជំនុំជម្រះធ្លាប់បានយល់ឃើញពីមុនរួចមកហើយថា គោលការណ៍នីត្យានុកូលភាពត្រូវតែគោរព នៅពេលដែលបទល្មើសដែលត្រូវបានចោទប្រកាន់មានចែងនៅក្នុងច្បាប់ អ.វ.ត.ក ហើយដែលបទល្មើសទាំងនោះក៏មានចែងផងដែរនៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលបទល្មើសនោះបានប្រព្រឹត្ត។ នៅទីនេះ សហមេធាវីការពារក្តីទទួលស្គាល់ថា បទល្មើសដែលត្រូវបានចោទប្រកាន់រួមមាន មនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា ដែលមានចែងក្នុងមាត្រា៣(ថ្មី) ត្រូវបានកំណត់ថាជាបទល្មើសនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងមានការយល់ស្របថា ការជំនុំជម្រះទោសលើបទល្មើសទាំងនេះអាចប្រមើលមើលបានពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥១៤]។ សហមេធាវីការពារក្តីសន្និដ្ឋានថា "បញ្ហានៅត្រង់ថា លទ្ធភាពនៃការចោទប្រកាន់បទល្មើសទាំងនេះក្នុងរយៈពេលជាង ៣០ ឆ្នាំ ទៅអនាគត មិនបានចែងក្នុងច្បាប់កម្ពុជាក្នុងរយៈពេលដែលពាក់ព័ន្ធ" ទេ[៥១៥]។ បើតាមទស្សនៈរបស់ខ្លួន គោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងមាត្រា១៥(១)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហាមឃាត់មិន

[៥១៣] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតកត/កសចស (អបជ០១) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" អង្គបុរេជំនុំជម្រះ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ C5/45 (នៅពេលដែល អង្គបុរេជំនុំជម្រះសម្រេចថា "អ.វ.ត.ក គ្មានសិទ្ធិសើរើលើសេចក្តីសម្រេចរបស់តុលាការណាមួយដែលមិនស្ថិតក្នុងរចនាសម្ព័ន្ធរបស់ខ្លួនដែរ")។ សូមមើលផងដែរ យោបល់របស់ចៅក្រមកម្ពុជា នៅក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្តកម្មសម្រាប់បទល្មើសជាតិ កថាខណ្ឌ៣៨។

[៥១៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ១៥៩។

[៥១៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ១៥៩។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ឱ្យអនុវត្តច្បាប់បែបប្រតិសកម្ម ហេតុនេះវាជាការការពារប្រឆាំងនឹងការពន្យារអាជ្ញាយុកាល ដែលបានផុតកំណត់។ អាស្រ័យហេតុនេះ សហមេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះឱ្យពង្រីកន័យចង្អៀតនៃគោលការណ៍នីត្យានុកូលភាព ដែលបានកំណត់ខាងលើ ដើម្បីសន្និដ្ឋានថា អំឡុងពេលដែលឧក្រិដ្ឋកម្មមួយអាចយកទៅជំនុំជម្រះបាន លុះត្រាតែជនជាប់ចោទអាចប្រមើលមើល និងដឹងជាមុន នៅពេលប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[៥១៦]។

២៨២. ដូចបានកត់សម្គាល់ដោយចៅក្រមអន្តរជាតិអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ រួចមកហើយគឺថា តាមមាត្រា១៥(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គោលការណ៍នីត្យានុកូលភាពមិនបាន "សំដៅដោយផ្ទាល់ចំពោះថិរវេលាកំណត់ទេ។ ប្រភពនេះពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ នៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទិននឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬការលុបចោលអាជ្ញាយុកាលនោះទេ"[៥១៧]។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ECtHR បានពិចារណាថា ការដំណើរការបណ្តឹងអាជ្ញាចំពោះបទឧក្រិដ្ឋដែលបានក្លាយជាកម្មវត្ថុនៃអាជ្ញាយុកាលនោះ អាចនឹងរំលោភដល់គោលការណ៍នៃការអាចប្រមើលមើលដឹងជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងគោលការណ៍នីត្យានុកូលភាពចែងក្នុងមាត្រា១៥(១)[៥១៨]។ ទោះជាយ៉ាងណាក្តី ករណីនេះមិនបានកើតឡើងទេ ដែលថាមានការពន្យារថិរវេលាអាជ្ញាយុកាល មុនពេលផុតកំណត់នោះ[៥១៩]។ ការពិត សហមេធាវី

---

[៥១៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ១៦៤។ អង្គបុរេជំនុំជម្រះសូមរំឭកថា ខ្លួនបានទទួលដាច់ពីគ្នានូវបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលជំទាស់ផងដែរទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក លើបទល្មើសជាតិ ដោយផ្អែកលើមូលដ្ឋានថា ការពន្យារថិរវេលានៃអាជ្ញាយុកាលតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក រំលោភលើគោលការណ៍នីត្យានុកូលភាព តែត្រូវតែទៅលើន័យទូលាយរបស់វាជាជាងការទទួលយកជារួម មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រូវបានឆ្លើយតប នៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ទាក់ទិននឹងន័យចង្អៀតនៃគោលការណ៍នីត្យានុកូលភាព ដូចបានពណ៌នាក្នុងផ្នែកដែលពិភាក្សាលើអង្គសេចក្តីនៃមូលដ្ឋានទីបី នៃបណ្តឹងឧទ្ធរណ៍ខាងលើ នៅក្នុងសាលដីកានេះ។

[៥១៧] សេចក្តីសម្រេចស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ , កថាខណ្ឌ ៤២។

[៥១៨] ECtHR *រឿងក្តី Kononoតទល់នឹង ប្រទេស Latia* សំណើលេខ 36376/04 សាលក្រម (យោងទៅអង្គជំនុំជម្រះជាន់ខ្ពស់ Grand Chamber) ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ១៤៤-១៤៦។ អង្គជំនុំជម្រះជាន់ខ្ពស់ Grand Chamber មិនបានច្រានចោលសេចក្តីសន្និដ្ឋាននេះទេ៖ សាលក្រមចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ២២៨-២៣៣។

[៥១៩] ECtHR *រឿងក្តី Coëme និងអ្នកដទៃទៀត តទល់នឹង ប្រទេសប៊ែលហ្ស៊ិក* សំណើលេខ 32492/96, 32547/96, 32548/96, 33209/96 និង 33210/96 សាលក្រមចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០០ កថាខណ្ឌ១៤៩-១៥១។

ការពារក្តីមិនបានលើកឡើងថា ការពន្យារថិរវេលាបែបនេះនឹងរំលោភដល់គោលការណ៍នីត្យានុកូលភាពនោះទេ។ ដូចដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងរួចមកហើយ និងបានបកស្រាយបន្ថែមខាងក្រោម ការអនុវត្តជាក់ស្តែងនៃប្រព័ន្ធច្បាប់ជាតិបានគាំទ្របន្ថែមទៀតទៅលើជំហរដែលថា អាជ្ញាយុកាលអាចត្រូវពន្យារបាន មុនពេលផុតកំណត់[៥២០]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពន្យារថិរវេលាអាជ្ញាយុកាលមុនពេលផុតកំណត់ គឺជាបញ្ហាគោលនយោបាយថ្នាក់ជាតិ និងមិនពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាពនោះឡើយ។

២៨៣. អង្គបុរេជំនុំជម្រះនឹងងាកទៅពិនិត្យ ថាតើបទឧក្រិដ្ឋថ្នាក់ជាតិត្រូវបានរាំងដោយសារពេលវេលាកន្លងផុតឬទេ នៅពេលថិរវេលាអាជ្ញាយុកាលត្រូវបានពន្យារនៅឆ្នាំ ២០០១ ដោយសារសភាជាតិកម្ពុជាបានអនុម័តច្បាប់ អ.វ.ត.ក ។

២៨៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អាជ្ញាយុកាលរយៈពេល ១០ ឆ្នាំ ចំពោះបទឧក្រិដ្ឋថ្នាក់ជាតិដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានកន្លងហួសហើយ នៅពេលច្បាប់ អ.វ.ត.ក ត្រូវបានអនុម័តនៅឆ្នាំ២០០១។ ច្បាប់ អ.វ.ត.ក គ្រាន់តែមានចែងតែពីការពន្យារថិរវេលាអាជ្ញាយុកាលសម្រាប់អនាគតតែប៉ុណ្ណោះ ដោយមិនបានបញ្ជាក់ឱ្យបានច្បាស់ពីបញ្ហាថាតើ បទឧក្រិដ្ឋទាំងនោះត្រូវបានរាំងដោយសារផុតកំណត់នៅពេលពន្យារនោះ ហើយដែលច្បាប់នេះមានអានុភាពក្នុងការដំណើរការរឿងក្តីនោះឡើងវិញ បន្ទាប់ពីការផុតថិរវេលាអាជ្ញាយុកាល ឬមួយ ថាតើបញ្ញត្តិនោះត្រូវលុបចោលឬទេ។ ហេតុនេះ ដោយសារអង្គបុរេជំនុំជម្រះត្រូវឱ្យអនុវត្តតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នោះ អង្គបុរេជំនុំជម្រះនឹងត្រូវចេញសេចក្តីសម្រេចលើបញ្ហានេះ យោងតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងការធានាឱ្យមានការគោរពដល់គោលការណ៍នីត្យានុកូលភាព។

២៨៥. គោលការណ៍នៃអាជ្ញាយុកាល គឺដើម្បីកំណត់ពីថិរវេលាមួយសម្រាប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះ មានការសន្មតថា ស្ថាប័នតុលាការដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបាន[៥២១]។ ការអនុវត្តជាក់ស្តែងក្នុងប្រព័ន្ធច្បាប់តាមប្រទេសនានាបានបង្ហាញ

---

[៥២០] សេចក្តីសម្រេចស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ, កថាខណ្ឌ ១៧។

[៥២១] *សូមមើលឧទាហរណ៍* សាធារណរដ្ឋឆេក ច្បាប់ឆ្នាំ១៩៩៣ ស្តីពីអនីត្យានុកូលភាពនៃរបបកុម្មុយនីស្ត បកប្រែជាភាសាអង់គ្លេសនៅក្នុងសៀវភៅរបស់ N.J. Kritz, ដែលមានចំណងជើងថា *យុត្តិធម៌សម័យអន្តរកាល៖ របៀបប្រទេសដែលប្រកាន់*

ឧទាហរណ៍ជាច្រើនដែលថិរវេលាអាជ្ញាយុកាលត្រូវបានព្យួរទុក ដោយផ្អែកលើមូលដ្ឋានថា ស្ថាប័នតុលាការមិនបានដំណើរការ ដោយសារមានជម្លោះនៅតែបន្ត ឬដោយសារមានរបបផ្តាច់ការកំពុងគ្រប់គ្រងប្រទេស[៥២២]។ ការព្យួរថិរវេលាអាជ្ញាយុកាលនៅពេលស្ថាប័នតុលាការមិនដំណើរការក៏ត្រូវ

---

*របបប្រជាធិបតេយ្យថ្មីពិចារណាទៅលើរបបមុនៗ (Transitional Justice: How emerging democracies reckon with former regimes)* វិទ្យាស្ថានសារព័ត៌មានសន្តិភាពរបស់សហរដ្ឋអាមេរិក ឆ្នាំ ១៩៩៥ ក្បាលទី III ទំព័រ. (ដោយអះអាងថា "ថិរវេលានៃអាជ្ញាយុកាលសម្រាប់បទល្មើសមិនត្រូវរាប់បញ្ចូលអំឡុងពេលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៤៨ រហូតដល់ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៨៩ ទេ ដោយសារការចោទប្រកាន់ទោស ឬលើកលែងការចោទប្រកាន់មិនបានកើតឡើងទេ ដោយសារមូលហេតុនយោបាយមិនស្របទៅនឹងធាតុផ្សំជាមូលដ្ឋាននៃបញ្ញត្តិច្បាប់របស់ប្រទេសប្រជាធិបតេយ្យ") *រឿងក្តី Brown តទល់នឹង Hiatts* សំណុំរឿងលេខ 82 U. S. 177 (ឆ្នាំ ១៨៧២) (ដែលអះអាងថា "ក្នុងការប៉ះប៉ូវរយៈពេលមួយដែលមានការអះអាងពីសិទ្ធិធ្វើសកម្មភាព អាជ្ញាយុកាលត្រូវដំណើរការអនុលោមតាមគោលការណ៍ថា តុលាការរបស់ប្រទេសដែលបុគ្គលនោះត្រូវបានជំនុំជម្រះទោសរស់នៅ ឬទ្រព្យសម្បត្តិដែលប្រមូលបានតាំងនៅ ដែលអាជ្ញាយុកាលនោះមានការបើកទូលាយចំពោះបុគ្គលដែលសក្តិសមក្នុងអំឡុងពេលនោះ")។

[៥២២] ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២០ ខែ ធ្នូ ២០ ឆ្នាំ ១៩៤៥ 3 Official Gazette Control Council for Germany 50-55 (ឆ្នាំ ១៩៤៦) មាត្រា II(5) (ដែលចែងថា "នៅក្នុងការកាត់សេចក្តី ឬការជំនុំជម្រះទោសចំពោះបទល្មើសនៅទីនេះ ជនជាប់ចោទមិនមានសិទ្ធិទទួលបានការកំហិតអាជ្ញាយុកាលទាក់ទិននឹងរយៈពេលពីថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៣៣ រហូតដល់ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៤៥") ទិនានុប្បវត្តិផ្លូវការសម្រាប់តំបន់ដែលគ្រប់គ្រងដោយចក្រភពអង់គ្លេស *(Verordnungsblatt für die Britische Zone)* ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៤៧ ទំព័រ៦៥ មាត្រា ៣។ ("បញ្ញត្តិស្តីពីអាជ្ញាយុកាល ទាក់ទិននឹងថិរវេលាពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៣៣ រហូតដល់ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៤៥ មិនបានរារាំងមិនឱ្យមានការជំនុំជម្រះទោស និងការផ្តន្ទាទោសទេ។ ការគិតពីថិរវេលានៃអាជ្ញាយុកាលត្រូវបានព្យួរទុកនៅក្នុងអំឡុងពេលនេះ") ទិនានុប្បវត្តិផ្លូវការសម្រាប់តំបន់ដែលគ្រប់គ្រងដោយអាមេរិកាំង ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៤៦ រួមមានលក្ខន្តិកៈបួន ដែលមានបញ្ញត្តិដូចគ្នាបេះបិទស្តីពីថិរវេលាអាជ្ញាយុកាល នៅក្នុងមាត្រា២ (៣) នៃលក្ខន្តិកៈទាំងនោះ ("នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ (...) ដែលទាក់ទិននឹងឧក្រិដ្ឋមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ចុងចោទមិនមានសិទ្ធិទទួលបានប្រយោជន៍ពីអាជ្ញាយុកាលសម្រាប់រយៈពេលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៣៣ រហូតដល់ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៤៥ ទេ។ សម្រាប់រយៈពេលនោះ អាជ្ញាយុកាលត្រូវបានព្យួរទុក"។ ទិនានុប្បវត្តិផ្លូវការសម្រាប់តំបន់ដែលគ្រប់គ្រងដោយប្រទេសបារាំង ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៤៦ ទំព័រ១៥១ ("ជាផលវិបាកនៃវិធានការនានាដែលមានរៀបរាប់ក្នុងកថាខណ្ឌ៥ មិនមានកើតឡើង ឬត្រូវបានពន្យារពេល ឬ មិនបានកើតឡើង ឬត្រូវបានពន្យារពេល ដោយសារជនជាប់ចោទត្រូវបានការពារដោយ NSDAP ឬ ផ្នែកណាមួយនៃផ្នែកដែលគ្រប់គ្រងដោយពួកសម្ព័ន្ធមិត្ត ឬក្រុមដែលពាក់ព័ន្ធមិនបានរារាំងដល់ការជំនុំជម្រះពីបទព្រហ្មទណ្ឌទេ នៅពេលការផុតរលត់នៃថិរវេលាអាជ្ញាយុកាលដោយផ្អែកលើមូលដ្ឋានទាំងនេះ រហូតទាល់តែក្រឹត្យនេះចូលជាធរមាន ដោយចែងថាការជំនុំជម្រះពីបទព្រហ្មទណ្ឌ នឹងត្រូវបានធ្វើឡើងក្នុងរយៈពេលប្រាំមួយខែ ក្រោយពេលលក្ខន្តិកៈនេះចូលជាធរមាន")។ សហរដ្ឋអាមេរិក ច្បាប់មួយទាក់ទិននឹងអាជ្ញាយុកាលនៃបណ្តឹង នៅក្នុងករណីមួយចំនួន ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨៦៤ (ដោយអះអាងថា "ទោះបីបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងអាជ្ញា

បានចាត់ទុកជាការចាំបាច់ផងដែរ ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដោយសារតែឧក្រិដ្ឋកម្មនានាដូចជា ឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃយុត្តាធិការរបស់ អ.វ.ត.ក ជាដើម តាមរយៈការជំនុំជម្រះទោសចារីប្រព្រឹត្តបទល្មើសទាំងនោះ[៥២៣]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ស្របទៅនឹងការសម្រេចជាឯកច្ឆ័ន្ទរបស់

---

បានកើតឡើងក៏ដោយ ហើយបុគ្គលនោះមិនអាចត្រូវបានចាប់ខ្លួន ឬមិនអាចដំណើរការចាប់ផ្តើមបណ្តឹងនេះបាន ដោយសារមានឧបសគ្គតាមផ្លូវច្បាប់ ឬមានការអាក់ខានកិច្ចដំណើរការតាមផ្លូវតុលាការក៏ដោយ ក៏ពេលវេលាដែលចាប់ផ្តើមដំណើរការតាមផ្លូវច្បាប់ប្រឆាំងនឹងជននេះបាន មិនត្រូវបានចាត់ទុកជាភាគផ្នែកមួយនៃពេលវេលាដែលកំហិតដោយច្បាប់ក្នុងការចាប់ផ្តើមបណ្តឹងបែបនោះបានឡើយ" ត្រូវបានបង្កើតឡើងវិញ និងយកមកអនុវត្តនៅក្នុង *រឿងក្តី Stewart តទល់នឹង Kahn* សំណុំរឿងលេខ 78 U.S. 11 (ឆ្នាំ ១៨៧០) E9/8.5 តុលាការកំពូលសហរដ្ឋអាមេរិក *រឿងក្តី Hanger តទល់នឹង Abbott* សំណុំរឿងលេខ 73 U.S. 532, 1867 WL 11246, E9/7.14 (ដោយយល់ឃើញថា អាជ្ញាយុកាល (សម្រាប់បណ្តឹងរដ្ឋប្បវេណី) មិនបានរាប់ទេ នៅពេលដែលតុលាការនៅរដ្ឋ Arkansas ត្រូវបានផ្អាកដំណើរការ ដោយសារមានការបះបោររយៈពេលបីឆ្នាំ) តុលាការកំពូលសហរដ្ឋអាមេរិក *រឿងក្តី Brown តទល់នឹង Hiatts* សំណុំរឿងលេខ 82 U. S. 177 (ឆ្នាំ ១៨៧២)៣៤, តុលាការសាលាឧទ្ធរណ៍សហរដ្ឋអាមេរិក *រឿងក្តី Jean តទល់នឹង Dorelien* តុលាការមណ្ឌល១១ នៃសហរដ្ឋអាមេរិក លេខ 04-15666 ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៥ ("យើងកត់សម្គាល់ឃើញថា តុលាការទាំងអស់ដែលបានពិចារណាទៅលើសំណួរថាតើ សង្គ្រាមស៊ីវិល និងរបបផ្តាច់ការគាបសង្កត់គឺជា "ស្ថានភាពវិសាមញ្ញ" ដែលត្រូវព្យួរទុកអាជ្ញាយុកាលនៃ [ច្បាប់ស្តីពីការទាមទារសំណងរដ្ឋប្បវេណីដោយជនបរទេស (Alian Tort Claim Act)] និង [ច្បាប់ការពារជនរងគ្រោះពីការធ្វើទារុណកម្ម (Torture Victim Protection Act)] បានឆ្លើយតបជាវិជ្ជមានឬទេ")។ សាធារណរដ្ឋឆេក ច្បាប់ឆ្នាំ ១៩៩៣ ស្តីពីអនីត្យានុកូលភាពនៃរបបកុម្មុយ នីស្ត បកប្រែជាភាសាអង់គ្លេសនៅក្នុង N.J. Kritz, *យុត្តិធម៌សម័យអន្តរកាល៖ របៀបប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យថ្មីពិចារណាទៅលើរបបមុនៗ (Transitional Justice: How emerging democracies reckon with former regimes)* វិទ្យាស្ថានសារព័ត៌មានសន្តិភាពរបស់សហរដ្ឋអាមេរិក ឆ្នាំ១៩៩៥ ក្បាលទី III ទំព័រ៦២០។ តុលាការធម្មនុញ្ញឆេក សេចក្តីសម្រេចទៅលើច្បាប់ឆ្នាំ១៩៩៣ ស្តីពីអនីត្យានុកូលភាពនៃរបបកុម្មុយនីស្ត 21 December 1993 បកប្រែជាភាសាអង់គ្លេសនៅក្នុង N.J. Kritz, *យុត្តិធម៌សម័យអន្តរកាល៖ របៀបប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យថ្មីពិចារណាទៅលើរបបមុនៗ (Transitional Justice: How emerging democracies reckon with former regimes)* វិទ្យាស្ថានសារព័ត៌មានសន្តិភាពរបស់សហរដ្ឋអាមេរិក ឆ្នាំ ១៩៩៥ ក្បាលទី III ទំព័រ៦២០(បញ្ជាក់ឡើងវិញសុពលភាពនៃច្បាប់ ជាពិសេស ដោយផ្អែកទៅលើគោល ការណ៍នីត្យានុកូលភាព) ។ ប្រទេសហូឡង់ ក្រឹត្យច្បាប់ ១៩៤៣ ស្តីពីច្បាប់ព្រហ្មទណ្ឌ នៅក្នុងស្ថានភាពពិសេសដែលបានអនុម័ត នៅក្នុងឆ្នាំ ១៩៤៧ មាត្រា ២៧(ក) (ដែលបានព្យួរទុកចិរវេលាអាជ្ញាយុកាលជាប្រតិសកម្មចំពោះបទឧក្រិដ្ឋសង្គ្រាម ពីពេលដែលមានការប្រព្រឹត្ត រហូតដល់ពេលក្រឹត្យច្បាប់នេះចូលជាធរមាន)។

[៥២៣] មាត្រា២(៣) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា៖ (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះជននោះមានសិទ្ធិឲ្យ*មានការដោះស្រាយដោយស័ក្តិសិទ្ធិ* ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។" (គូសបញ្ជាក់បន្ថែម)។ IACtHR, *រឿងក្តី Myrna Mack Chang តទល់នឹង Guatemala*, សាលក្រម (អង្គសេចក្តី, សំណង និងតម្លៃ), ចុះថ្ងៃទី

អង្គជំនុំជម្រះសាលាដំបូងដែលថា ចិរវេលាអាជ្ញាយុកាលមិនយកមកពិចារណាទេ នៅពេលស្ថាប័នតុលាការមិនដំណើរការ[៥២៤]។

២៨៦. អង្គបុរេជំនុំជម្រះក៏បានយល់ស្របផងដែរ និងអនុម័តតាមការសន្និដ្ឋានដែលសម្រេចដោយសំឡេងភាគច្រើននៃចៅក្រមកម្ពុជាបីរូបនៃអង្គជំនុំជម្រះសាលាដំបូងដែលថា "ចាប់តាំងពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ ប្រព័ន្ធតុលាការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនមានដំណើរការទាល់តែសោះ" និង "រហូតមកទល់នឹងពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយរដ្ឋធម្ម-

---

២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣, កថាខណ្ឌ២៧៦-២៧៧ (អះអាងថា "រដ្ឋត្រូវធានាថា កិច្ចដំណើរការនីតិវិធីនៅក្នុងច្បាប់ជាតិ ក្នុងការស៊ើបសួរ និងផ្ដន្ទាទោសដល់បុគ្គលដែលទទួលខុសត្រូវចំពោះអង្គហេតុនៅក្នុងរឿងក្ដីនេះត្រូវមានសុពលភាព ហើយជាពិសេសកិច្ចដំណើរការនីតិវិធីនេះត្រូវចៀសផុតពីទស្សនាទានច្បាប់មួយចំនួនដូចជា ការលើកលែងទោស ការលុបបំបាត់បណ្ដឹង និងការបង្កើតនូវវិធានការនានាដើម្បីលុបបំបាត់ការទទួលខុសត្រូវនានា")។ IACtHR, រឿងក្ដី *Barrios Altos*, សាលក្រម, ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១, កថាខណ្ឌ៤១ (ដែលអះអាងថា "បញ្ញត្តិស្ដីពីអាជ្ញាយុកាល និងការបង្កើតវិធានការនានាដើម្បីលុបបំបាត់ការទទួលខុសត្រូវមិនអាចទទួលយកបានទេ ដោយសារថាបញ្ញត្តិមានចេតនារារាំងមិនឱ្យមានការស៊ើបសួរ និងផ្ដន្ទាទោសដល់បុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដូចជា អំពើទារុណកម្ម ការសម្លាប់មនុស្សក្រៅផ្លូវតុលាការ ដោយមិនការជំនុំជម្រះ ឬតាមអំពើចិត្ត និងការបាត់ខ្លួនដោយបង្ខំ ដែលការរំលោភសិទ្ធិទាំងនេះត្រូវបានហាមឃាត់ ដោយសារវាជាការរំលោភដល់សិទ្ធិជាសារវន្តដែលត្រូវបានទទួលស្គាល់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។ *សូមមើលផងដែរ* គណៈកម្មការសិទ្ធិមនុស្ស អនុគណៈកម្មការស្ដីពីការបង្ការនូវការរើសអើង និងការការពារដល់ជនជាតិភាគតិច, *គោលការណ៍ និងសេចក្ដីណែនាំជាមូលដ្ឋានស្ដីពីសិទ្ធិទទួលបានសំណងចំពោះជនរងគ្រោះ ពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងច្បាប់មនុស្សធម៌ ដែលរៀបរៀងដោយលោក Theo van Boven អនុលោមតាមសេចក្ដីសម្រេចរបស់អនុគណៈកម្មការលេខ 1995/1179*។ អ.ស.ប ឯកសារលេខ E/CN.4/Sub.2/1996/17 ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៦ ឧបសម្ព័ន្ធ កថាខណ្ឌ៩ ("អាជ្ញាយុកាលមិនត្រូវយកមកអនុវត្តនៅក្នុងអំឡុងពេលដែលមិនមានការដោះស្រាយឱ្យសមរម្យចំពោះការរំលោភច្បាប់ស្ដីពីសិទ្ធិមនុស្ស និងមនុស្សធម៌ទេ។ បណ្ដឹងទាមទារសំណងរដ្ឋប្បវេណី ទាក់ទិននឹងការជួសជុលចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ស្ដីពីសិទ្ធិមនុស្ស និងមនុស្សធម៌ មិនត្រូវក្លាយជាកម្មវត្ថុនៃអាជ្ញាយុកាលទេ")។ គណៈកម្មការសិទ្ធិមនុស្ស អនុគណៈកម្មការស្ដីពីការបង្ការនូវការរើសអើង និងការការពារដល់ជនជាតិភាគតិច, *សំណួរស្ដីពីនិទណ្ឌភាពរបស់ចារីដែលរំលោភសិទ្ធិមនុស្ស (ទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)៖ របាយការណ៍កែប្រែចុងក្រោយដែលរៀបរៀងដោយលោក Joinet អនុលោមតាមសេចក្ដីសម្រេចរបស់អនុគណៈកម្មការលេខ 1996/119*។ អ.ស.ប ឯកសារលេខ E/CN.4/Sub.2/1997/20/Rev.1 ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៧ ឧបសម្ព័ន្ធ១ គោលការណ៍២៤ ("អាជ្ញាយុកាល ពីការជំនុំជម្រះទោស ឬការផ្ដន្ទាទោស នៅក្នុងសំណុំរឿងព្រហ្មទណ្ឌមិនផុតរលត់ទេ នៅក្នុងរយៈពេលដែលមិនមានការដោះស្រាយឱ្យមានសមរម្យ")។

[៥២៤] សេចក្ដីសម្រេចស្ដីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ, កថាខណ្ឌ១៤, ១៦-១៧ (យោបល់របស់ចៅក្រមកម្ពុជាទាំងបីរូប) កថាខណ្ឌ២៧ និង២៨ (យោបល់របស់ចៅក្រមអន្តរជាតិទាំងពីររូប)។

នុញ្ញថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ បញ្ញាប្រវត្តិសាស្ត្រ និងបរិការណ៍បានរាំងយ៉ាងខ្លាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ"[៥២៥]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ចៅក្រមភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សមត្ថភាពតុលាការកម្ពុជាមានការខ្វះខាតច្រើនណាស់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ ដោយសារតែ "ការបំផ្លិចបំផ្លាញប្រព័ន្ធតុលាការទាំងស្រុងដោយរបបកម្ពុជាប្រជាធិបតេយ្យ" ដែលជនជាប់ចោទត្រូវបានចោទប្រកាន់គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបក្នុងចំណោមមេដឹកនាំផ្សេងទៀត និងបានទទួលស្គាល់ថា "ត្រូវការពេលវេលាយូរអង្វែង ដើម្បីបង្កើតប្រព័ន្ធតុលាការឡើងវិញ ដើម្បីបណ្តុះបណ្តាលមេធាវី រដ្ឋអាជ្ញា(ព្រះរាជអាជ្ញា) និងចៅក្រម"[៥២៦]។ ចៅក្រមទាំងនោះបានថ្លែងថា លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរដោយតុលាការជាតិ ចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ថាបានប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានអាក់ខានពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៩៣ ដោយសារសង្គ្រាមស៊ីវិលនៅបន្តដោយពួកខ្មែរក្រហម ដែលគ្រប់គ្រងទឹកដីកម្ពុជាមួយផ្នែក ហើយដែលសហគមន៍អន្តរជាតិនៅចាត់ទុកក្រុមនេះជាតំណាងមួយរបស់ខ្លួន ដែលជាការលំបាកក្នុងការស្វែងរកសន្តិភាព ស្របពេលដែលត្រូវនាំខ្លួនអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកជំនុំជម្រះទោស[៥២៧]។ អង្គបុរេជំនុំជម្រះយល់ស្រប និងអនុម័តយកសេចក្តីសន្និដ្ឋានរបស់ចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូង ដែលចៅក្រមគាត់មានយោបល់ថា "ថិរវេលានៃអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងបទល្មើសជាតិ [...] ចាប់ផ្តើមរាប់ ពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣"[៥២៨]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមថា ជនជាប់ចោទមិនអាចទទួលបានផលប្រយោជន៍ពីការកន្លងផុតនៃថិរវេលាទេ ដែលនៅពេលនោះគាត់ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវមួយផ្នែក ចំពោះការមិនមានដំណើរការរបស់តុលាការក្នុងការស៊ើបអង្កេត និងជំនុំជម្រះ។

[៥២៥] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ, កថាខណ្ឌ១៩, ២០។

[៥២៦] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ, កថាខណ្ឌ១៩។

[៥២៧] សេចក្តីសម្រេចស្តីពីអញ្ញត្តកម្មសម្រាប់បទល្មើសជាតិ កថាខណ្ឌ២០។ សហមេធាវីការពារក្តី អៀង សារី បានលើកឡើងថា ការផ្តាច់ខ្លួនរបស់ អៀង សារី មកចូលរួមជាមួយរាជរដ្ឋាភិបាលនាឆ្នាំ ១៩៩៦ គឺបានចូលរួមចំណែកយ៉ាងធំធេងក្នុងការបញ្ចប់សង្គ្រាមស៊ីវិល៖ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ៥៩។

[៥២៨] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ, កថាខណ្ឌ ២៥។

00661673



២៨៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ចិរវេលាអាជ្ញាយុកាល ១០ ឆ្នាំដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលចាប់ផ្ដើមរាប់ពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ មិនទាន់ផុតកំណត់នៅឡើយទេនៅឆ្នាំ ២០០១។ ហេតុនេះ ការពន្យារចិរវេលាដែលសភាជាតិបានអនុម័តនៅឆ្នាំ ២០០១ និងឆ្នាំ ២០០៤ រហូតដល់រយៈពេល ២០ ឆ្នាំ និងបន្ទាប់មករហូតដល់រយៈពេល ៣០ ឆ្នាំ មិនបានរំលោភដល់គោលការណ៍នីត្យានុកូលភាពទេ។

<u>ថាតើការអនុវត្តមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក រំលោភសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានសមភាពនៅចំពោះមុខច្បាប់ឬទេ</u>

២៨៨. អង្គបុរេជំនុំជម្រះមិនបានរកឃើញថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាក់ពីយុត្តាធិការទាក់ទិននឹងបទល្មើសជាតិតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជាការរំលោភដល់សិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានសមភាពនៅចំពោះមុខច្បាប់ទេ ដោយសារការពន្យារចិរវេលានៃអាជ្ញាយុកាលតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក អនុវត្តតែនៅពេលដែលបទល្មើសទាំងនោះត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក តែប៉ុណ្ណោះ[៥២៩]។

២៨៩. នៅក្នុងបរិបទដែលមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក អនុវត្តជាទូទៅចំពោះបុគ្គលគ្រប់រូបដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ឃើញថា ការជំទាស់របស់ អៀង សារី ចំពោះបញ្ហាយុត្តាធិការលើរឿងក្ដីរបស់ អ.វ.ត.ក ទាក់ទិននឹងបទឧក្រិដ្ឋថ្នាក់ជាតិតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយសំអាងថាវាជាការប្រព្រឹត្តមិនស្មើភាពគ្នា គឺការជំទាស់ទៅលើយុត្តាធិការចំពោះបុគ្គល និងពេលវេលាពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងនេះ។ បើតាមមាត្រា២ (ថ្មី) នៃច្បាប់ អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិការទៅលើ *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត* ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ [...] ដែលបានប្រព្រឹត្តក្នុងអំឡុង *ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"*[៥៣០]។ ហេតុនេះ សំណួរនៅចំពោះមុខអង្គបុរេជំនុំជម្រះគឺថាតើយុត្តាធិការដែលពិភាក្សានេះធ្វើឲ្យ អ.វ.ត.ក មិនគោរពតាមកាតព្វកិច្ចរបស់ខ្លួននៅក្នុងមាត្រា៣៣(ថ្មី) នៃច្បាប់

[៥២៩] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ១៥៥។

[៥៣០] មាត្រា២ (ថ្មី) នៃច្បាប់ អ.វ.ត.ក (គូសបញ្ជាក់បន្ថែម)។

អ.វ.ត.ក ដែលចែងថា ការអនុវត្តយុត្តាធិការដោយ អ.វ.ត.ក ត្រូវ "សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤" នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬយ៉ាងណា។ ពិសេសទៅទៀត ថាតើវាបានរំលោភដល់មាត្រា១៤(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលតម្រូវថា "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី"[៥៣១] ឬទេ និងថាតើវាជាការរើសអើងប្រឆាំងនឹងជនជាប់ចោទឬទេ។

២៩០. អង្គបុរេជំនុំជម្រះមិនបានយល់ឃើញបែបនេះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីគណៈកម្មាធិការសិទ្ធិមនុស្សបានសម្រេចថា "សមភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី [...] តម្រូវថា ក្នុងរឿងក្តីស្រដៀងគ្នា ត្រូវអនុវត្តតាមនីតិវិធីស្រដៀងគ្នា"[៥៣២] ក៏ដោយ ក៏អង្គជំនុំជម្រះមិនយល់ឃើញថា ក្នុងនាមជាតុលាការ"វិសាមញ្ញ" ឬ"ពិសេស" ដែលមានយុត្តាធិការមានកំណត់ ឬដោយជាក់លាក់នោះ បានរំលោភលើមាត្រា១៤(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៥៣៣] នោះទេ។ ផ្ទុយទៅវិញ ដូចតុលាការដទៃទៀតដែរ សំណួរដ៏សំខាន់នោះគឺ "ថាតើតុលាការទាំងនោះ បានធានាពីការអនុវត្តទៅតាមលក្ខខណ្ឌនៃសវនាការប្រកបដោយយុត្តិធម៌នៃមាត្រា១៤ ឬទេ"[៥៣៤]។ តាមការពិនិត្យទៅលើច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងនាំឲ្យមានការសន្និដ្ឋានថា អ.វ.ត.ក ពិតជាបានធានាដល់ការអនុវត្តត្រឹមត្រូវបែបនេះមែន។ ឧទាហរណ៍ ការធានាឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងមាត្រា១៤ ត្រូវបានចម្លងស្ទើរតែទាំងស្រុងនូវពាក្យពេចន៍នៅក្នុង មាត្រា៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក។ ជាងនេះទៀត ការធានាឲ្យមានការជំនុំជម្រះប្រកប

---

[៥៣១] មាត្រា១៤(១) នៃកតិកាសញ្ញាស្តីពិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[៥៣២] បទអត្ថាធិប្បាយទូទៅ លេខ. 32, កថាខណ្ឌ១៤។

[៥៣៣] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1 ""សាលដីកាលើសំណើរបស់មេធាវីការពារក្តី សុំដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ស្តីពីយុត្តាធិការ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ ("សាលដីកាក្នុងរឿងក្តី *Tadić* ស្តីពីយុត្តាធិការ"), កថាខណ្ឌ៤៥ (ទាញហេតុសំអាង បទអត្ថាធិប្បាយទូទៅ មាត្រា១៤, គណៈកម្មាធិការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៤៣ Supp. No. 40, ត្រង់កថាខណ្ឌ៤, អ.ស.ប ឯកសារលេខ A/43/40 (1988); រឿងក្តី *Cariboni* ***តទល់នឹង*** *Uruguay*, គណៈកម្មាធិការសិទ្ធិមនុស្ស 159/83. សម័យប្រជុំលើកទី៣៩ Supp. No. 40 អ.ស.ប ឯកសារលេខ A/39/40)។

[៥៣៤] សាលដីកាក្នុងរឿងក្តី *Tadić* ស្តីពីយុត្តាធិការ, កថាខណ្ឌ៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic*, សំណុំរឿងលេខ IT-99-37-PT, "សេចក្តីសម្រេចលើសំណើបឋម" អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ៩-១០។

ដោយយុត្តិធម៌ដទៃទៀត មានចែងក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង ជា "គោលការណ៍ជាសារវ័ន្ត" ដែលត្រូវអនុវត្តនៅ អ.វ.ត.ក ដើម្បីការពារផលប្រយោជន៍របស់ជនត្រូវចោទ។

២៩១. ជាងនេះទៀត មានមូលដ្ឋានដែលមានភាពសត្យានុម័ត និងសមស្របចំពោះសមត្ថកិច្ចយុត្តាធិការដែលមានកម្រិតកំណត់សម្រាប់ អ.វ.ត.ក ទៅលើបុគ្គល និងពេលវេលា ក្នុងនាមជា "អង្គជំនុំជម្រះវិសាមញ្ញ" នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ គណៈកម្មាធិការសិទ្ធិមនុស្សបានអះអាងថា បើតាមមាត្រា ១៤(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ប្រសិនបើ [...]គេត្រូវបង្ហាញពីមូលដ្ឋានដែលមានភាពសត្យានុម័ត និងសមស្រប ដើម្បីពន្យល់អំពីការកំណត់យកនីតិវិធីព្រហ្មទណ្ឌពិសេស ឬ តុលាការ ឬសាលាជម្រះក្តីដែលបានបង្កើតឡើងយ៉ាងពិសេស ដើម្បីសម្រេចលើរឿងក្តីក្នុងប្រភេទមួយចំនួន"[៩៣៥]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសម្រេចកំណត់ពីយុត្តាធិការរបស់ អ.វ.ត.ក មិនត្រូវបានធ្វើឡើងតាមអំពើចិត្ត ឬដោយរាជរដ្ឋាភិបាលកម្ពុជាតែម្នាក់ឯងទេ តែក៏បានផ្អែកលើអនុសាសន៍របស់ក្រុមជំនាញការ និងបានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផងដែរ។ សេចក្តីសម្រេចនោះស្របទៅនឹងគោលការណ៍ជាមូលដ្ឋានមួយ ដែលមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលថា បុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត ដែលធ្វើឱ្យមានអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវតែចាប់ឱ្យទទួលខុសត្រូវ។ ផ្អែកលើលក្ខណៈនៃឧក្រិដ្ឋកម្មទាំងនេះដែលតម្រូវឱ្យមានការជម្លៀសមនុស្ស ការរៀបចំផែនការ និងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំនោះ ក្នុងគោលបំណងឱ្យមានការផ្តន្ទាទោស និងធ្វើឱ្យរាងចាល វាជាការសមរម្យក្នុងការកំហិតយុត្តាធិការត្រឹមតែផ្តន្ទាទោសចំពោះមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះអំពើសាហាវឃោរឃៅដែលបានប្រព្រឹត្តនៅពេលវេលាមួយខ្លីជាក់លាក់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ វាជាសមរម្យដែលត្រូវបង្កើតតុលាការពិសេសដូច អ.វ.ត.ក ដើម្បីវិនិច្ឆ័យទោសដល់ចារីជាន់ខ្ពស់ ចំពោះឧក្រិដ្ឋកម្មប្រភេទនេះ ដែលប្រព័ន្ធតុលាការធម្មតាអាចមិនមានសមត្ថភាព ឬធនធាន ដើម្បីដំណើរការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងមិនលម្អៀងបាន ឬ ដោយសារអាចនឹងជាការប្រថុយប្រថានជាខ្លាំងដែលថា ការជំនុំជម្រះដោយតុលាការក្នុងស្រុកអាចនឹងធ្វើឱ្យមានអស្ថិរភាពក្រោយពេលមានជម្លោះនោះ។ ចុងក្រោយ ផ្អែកលើធនធានមានកម្រិតសម្រាប់ អ.វ.ត.ក នោះវាជាការសមរម្យដែលតុលាការនេះ

[៩៣៥] បទអត្ថាធិប្បាយទូទៅ លេខ. 32, កថាខណ្ឌ១៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ត្រូវខិតខំប្រើប្រាស់ធនធានតុលាការនេះ ក្នុងការជំនុំជម្រះទោសអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

២៩២. អង្គបុរេជំនុំជម្រះយល់ឃើញថា ច្បាប់ អ.វ.ត.ក រួមទាំងមាត្រា៣ (ថ្មី) អនុវត្តយ៉ាងស្មើភាពគ្នាចំពោះបុគ្គល ដែលស្របតាមលក្ខខណ្ឌដែលត្រូវបានបង្កើតឡើងដោយមានលក្ខណៈវិនិច្ឆ័យប្រកបដោយសត្យានុម័ត និងសមហេតុផល ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបុគ្គល និងពេលវេលា។ ហេតុនេះ ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីត្រូវច្រានចោល។

<u>**ថាតើ សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអង្គហេតុដែលគាំទ្រដល់ការអនុវត្តមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក និងខកខានមិនបានបញ្ជាក់ពីទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវអនុវត្តចំពោះបទល្មើសជាតិ ឬទេ**</u>

២៩៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានអះអាងឱ្យបានច្បាស់លាស់ពីអង្គហេតុ និងទម្រង់នៃការទទួលខុសត្រូវ ដែលប្រើប្រាស់ដើម្បីចោទប្រកាន់ពីបទឧក្រិដ្ឋថ្នាក់ជាតិដូចដែលពួកគេបានធ្វើចំពោះបទឧក្រិដ្ឋកម្រិតអន្តរជាតិ[៥៣៦] ទេ។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះនឹងមិនលើកពីបញ្ហានានាដែលទាក់ទិននឹងភាពខ្វះចន្លោះ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[៥៣៧] តែកំហិតការវិភាគរបស់ខ្លួនត្រឹមតែកំណត់ ថាតើកង្វះខាតភាពជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទិននឹងបទឧក្រិដ្ឋថ្នាក់ជាតិ នឹងរារាំង អ.វ.ត.ក មិនឱ្យអនុវត្តយុត្តាធិការរបស់ខ្លួនដែលនាំឱ្យមានការរារាំងមិនឱ្យនាំជនជាប់ចោទទៅជំនុំជម្រះពីបទឧក្រិដ្ឋទាំងនេះបានឬទេ។

២៩៤. សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលចោទប្រកាន់ជនជាប់ចោទពីបទល្មើសជាតិបង្ហាញថាសហចៅក្រមស៊ើបអង្កេតបានពិចារណាថា អំពើនានាដែលមានរៀបរាប់នៅក្នុង "ជំពូក

[៥៣៦] ចាប់ពីកថាខណ្ឌ១៣៣៦ ដល់១៥២០ នៃដីកាដំណោះស្រាយ សម្រាប់បទឧក្រិដ្ឋកម្មអន្តរជាតិ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់យ៉ាងពិស្តារ ពីមូលដ្ឋានអង្គហេតុដែលធ្វើឱ្យចៅក្រមទាំងនោះសន្និដ្ឋានថា ធាតុផ្សំតាមផ្លូវច្បាប់នៃបទឧក្រិដ្ឋអន្តរជាតិនីមួយៗពិតជាមានមែន។ នៅក្នុងផ្នែកស្តីពីទម្រង់នៃការទទួលខុសត្រូវ (កថាខណ្ឌ១៥២១-១៥៦៣) សហចៅក្រមស៊ើបអង្កេតបានរៀបរាប់យ៉ាងពិស្តារពីទម្រង់នៃការទទួលខុសត្រូវនីមួយៗ ដែលបទឧក្រិដ្ឋទាំងនោះត្រូវបានចោទប្រកាន់។

[៥៣៧] *សូមមើល* ផ្នែកនៃការទទួលយកបណ្តឹងឧទ្ធរណ៍ខាងលើ នៃសាលដីកានេះ។

៣៖ ការកំណត់ប្រភេទបទល្មើស" ផ្នែក "III. បទល្មើសប្រល័យពូជសាសន៍" "IV. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" និង "V. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ"[៥៣៨] អាចត្រូវបានកំណត់តាមផ្លូវច្បាប់ថាជាបទល្មើសមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា តាមមាត្រា២០៩, ២១០, ៥០០, ៥០១, ៥០៣ និង៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយថា មានភស្តុតាងគ្រប់គ្រាន់ដែលថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

២៩៥. បើតាមខ្លឹមសារនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជនជាប់ចោទបានទទួលដំណឹងពីអំពើនានាដែលគេត្រូវបានចោទប្រកាន់ តែមិនមានភាពច្បាស់លាស់ថាតើអង្គហេតុជាក់លាក់ណាមួយអាចត្រូវបានចាត់ទុកបទល្មើសជាតិនោះ។ ទម្រង់នៃការទទួលខុសត្រូវក៏មានស្ថានភាពនេះដូចគ្នាដែរ។ សហចៅក្រមស៊ើបអង្កេតបានអះអាងពីអង្គហេតុ ដែលគាំទ្រដល់សំអាងហេតុរបស់ខ្លួនថា មានភស្តុតាងគ្រប់គ្រាន់ដែលថា ជនជាប់ចោទបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់ ហើយក៏បានអះអាងថាផងដែរ ពីទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្ត ចំពោះបទល្មើសអន្តរជាតិនីមួយៗ[៥៣៩]។ ទោះជាយ៉ាងណាក្តី ពួកគាត់មិនបានអះអាងពីទម្រង់នៃការទទួលខុសត្រូវជាក់លាក់ដែលត្រូវអនុវត្តចំពោះបទល្មើសជាតិទេ។

២៩៦. បន្ទាប់ពីបានអានដីកាដំណោះស្រាយទាំងមូលរួចមក អង្គបុរេជំនុំជម្រះយល់ថា ការចោទប្រកាន់ពីបទឧក្រិដ្ឋថ្នាក់ជាតិគឺផ្អែកទៅលើអង្គហេតុនានា ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌទាក់ទិននឹងបទឧក្រិដ្ឋនានាដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរដល់អនុសញ្ញាទីក្រុងហ្សឺណែវ[៥៤០]។ ចំណុចនេះក៏ដូចគ្នាផងដែរចំពោះទម្រង់នៃការទទួលខុសត្រូវ[៥៤១]

---

[៥៣៨] ឆ្លើយតបទៅនឹងកថាខណ្ឌ១៣៣៦-១៥២០ នៃដីកាដំណោះស្រាយ។

[៥៣៩] ដីកាដំណោះស្រាយ កថាខណ្ឌ១៥២១-១៥៦៣។

[៥៤០] អង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីមនុស្សឃាតនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវចាត់ទុកដូចជាអង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ដោយការសម្លាប់ (ជនជាតិចាម និងជនជាតិវៀតណាម) ដែរ ដូចដែលមានរៀបរាប់ចន្លោះពីកថាខណ្ឌ១៣៣៦ ដល់១៣៤៩ មនុស្សឃាត និងការសម្លាប់ផ្តាច់ពូជ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានរៀបរាប់ពីកថាខណ្ឌ១៣៧៣ ដល់១៣៩០ និងមនុស្សឃាតដោយចេតនា ជាអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចដែលមានរៀបរាប់ពីកថាខណ្ឌ១៤៩១ ដល់១៤៩៧។ អង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីអំពើទារុណកម្មនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវចាត់ទុកដូចជាអង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីអំពើទារុណកម្ម ដូចមានរៀបរាប់ពី

ដោយពុំនិយាយដល់ទម្រង់នៃការទទួលខុសត្រូវតាមបទដ្ឋានអន្តរជាតិ ដែលហៅថា ជាការប្រព្រឹត្ត ឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមិនត្រូវយកមក អនុវត្តចំពោះបទឧក្រិដ្ឋថ្នាក់ជាតិទេ[៥៤២]។ ចំពោះអង្គហេតុនានាដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូន រឿងទៅជំនុំជម្រះដែលអាចកំណត់ជាបទឧក្រិដ្ឋនានាដូចជា មនុស្សឃាត ការធ្វើទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជាបញ្ហានៃការកំណត់ បទឧក្រិដ្ឋតាមផ្លូវច្បាប់ដែលត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង[៥៤៣] ហើយនៅក្នុងដំណាក់ កាលនេះ វាមិនមានផលប៉ះពាល់ទៅដល់យុត្តាធិការរបស់ អ.វ.ត.ក ក្នុងការបញ្ជូនជនជាប់ចោទទៅ ជំនុំជម្រះទាក់ទិននឹងឧក្រិដ្ឋកម្មទាំងនេះទេ។

---

កថាខណ្ឌ១៤០៨ ដល់១៤១៤ និងអំពើទារុណកម្ម ជាអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចដែល មានរៀបរាប់ពីកថាខណ្ឌ១៤៩៨ ដល់១៥០០។ អង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីការវាយប្រហារលើសាសនានៅក្នុង ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវចាត់ទុកដូចជាអង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីការវាយប្រហារលើសាសនា ជាឧក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិ ដូចមានរៀបរាប់ពីកថាខណ្ឌ១៤១៩ ដល់១៤២១។

[៥៤១] ក្រៅពីទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ ដោយការ សម្លាប់មនុស្ស មនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមនុស្សឃាតដោយចេតនា ជាអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅ លើអនុសញ្ញាទីក្រុងហ្សឺណែវ ការវាយប្រហារលើសាសនា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមទម្រង់នៃការទទួលខុសត្រូវៈ ការរៀបផែនការ ដូចមានរៀបរាប់ពីកថាខណ្ឌ១៥៤៤ ដល់១៥៤៥ ការញុះញង់ ដូចមានរៀបរាប់ពីកថាខណ្ឌ១៥៤៧ ដល់១៥៤៨ ការជួយនិងជំរុញ ដូចមានរៀបរាប់ពីកថាខណ្ឌ១៥៥០ ដល់១៥៥១ និងការបញ្ជា ដូចមានរៀបរាប់ពីកថាខណ្ឌ១៥៥៣ ដល់ ១៥៥៤។

[៥៤២] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ D97/13, កថាខណ្ឌ ២២ (ដែលសហចៅក្រមស៊ើបអង្កេតលើកឡើងថា "ទម្រង់នៃការទទួលខុស ត្រូវនៃឧក្រិដ្ឋកម្មអន្តរជាតិអាចត្រូវបានអនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ")។ នៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំ ជម្រះមិនបានច្រានចោលការសន្និដ្ឋាននេះទេៈ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើប អង្កេត ចំពោះ ការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារ D97/14/15, កថាខណ្ឌ១០២ (ដែលអង្គបុរេជំនុំជម្រះលើកឡើងថា "គ្មានទឡ្ហីករណ៍ណាមួយក្នុងចំណោមទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីនានា នៅ ក្នុងបណ្តឹងឧទ្ធរណ៍នេះបង្ហាញថា ដីកាដែលត្រូវបានជំទាស់ ភ័ន្តច្រឡំក្នុងការពិចារណាថា ទម្រង់ JCE ដែលជាទម្រង់នៃការទទួល ខុសត្រូវមួយដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយជា ជាងអនុវត្តចំពោះបទល្មើសជាតិនោះទេ")។

[៥៤៣] វិធាន៩៨(២) នៃវិធានផ្ទៃក្នុង (ដែលចែងថា អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូន រឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ)។



PRE-TRIAL ... E.C.C.C ... PRÉLIMINAIRE

២៩៧. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទីប្រាំត្រូវច្រានចោលទាំងស្រុង។

## ៥. មូលដ្ឋានទីប្រាំពីរ៖ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

២៩៨. នៅក្នុងផ្នែកស្តីពីការទទួលយកបណ្តឹងឧទ្ធរណ៍ខាងលើនៃសាលដីកានេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានរងនានាខាងក្រោមនៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍ បង្ហាញពីការជំទាស់ទៅនឹងយុត្តាធិការ៖ មូលដ្ឋានរងទី៣ ("ទឡ្ហីករណ៍ទៅលើ*ចំណងពាក់ព័ន្ធ*")[៥៤៤] មូលដ្ឋានរងទី១០ ("ទឡ្ហីករណ៍ទៅលើការដាក់ក្នុងមន្ទីរឃុំឃាំង")[៥៤៥] មូលដ្ឋានរងទី១១ ("ទឡ្ហីករណ៍ទៅលើអំពើទារុណកម្ម")[៥៤៦] មូលដ្ឋានរងទី១៤ ("ទឡ្ហីករណ៍ទៅលើការរំលោភលើផ្លូវភេទ")[៥៤៧] មូលដ្ឋានរងទី១៥ ("ទឡ្ហីករណ៍ទៅលើអំពើអមនុស្សធម៌ផ្សេងៗទៀត")[៥៤៨] មូលដ្ឋានរងទី១៦ ("ទឡ្ហីករណ៍ទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ")[៥៤៩] មូលដ្ឋានរងទី១៧ ("ទឡ្ហីករណ៍ទៅលើអំពើហិង្សាផ្លូវភេទ")[៥៥០] និង មូលដ្ឋានរងទី១៩ ("ទឡ្ហីករណ៍ទៅលើការបាត់ខ្លួនដោយបង្ខំ")[៥៥១]។

២៩៩. ទឡ្ហីករណ៍របស់សហមេធាវីការពារក្តី ទាក់ទិននឹងមូលដ្ឋានរងទាំងនេះត្រូវបានរៀបរាប់ដោយសង្ខេប នៅក្នុងផ្នែកស្តីពីការទទួលយកបណ្តឹងឧទ្ធរណ៍ខាងលើនៃសាលដីកានេះ។ នៅក្នុងកថាខណ្ឌបន្តទៅទៀត អង្គបុរេជំនុំជម្រះនឹងបង្ហាញសេចក្តីសង្ខេបពេញលេញលើសារណារបស់ភាគី ដោយរួមបញ្ចូលទាំងការពិភាក្សា និងសេចក្តីសន្និដ្ឋានទៅលើអង្គសេចក្តីនៃមូលដ្ឋានរងនីមួយៗ។

---

[៥៤៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៨-១៨៩។

[៥៤៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២០៥-២០៧។

[៥៤៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២០៨-២០៩។

[៥៤៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២១៨-២១៩។

[៥៤៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២០។

[៥៤៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២៣។

[៥៥០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២៥។

[៥៥១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២៣០។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

**i) មូលដ្ឋានរងទី៣ (*ចំណងពាក់ព័ន្ធ/ចំណងទាក់ទង*)**

**សារណានានា៖**

៣០០. សហមេធាវីការពារក្តី អៀង សារី អះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយពុំបានពន្យល់ "ថាចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក"។ សហមេធាវីការពារក្តីបានផ្តល់យោបល់ថា "ចំណងពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវដាក់ចូលទៅក្នុងនិយមន័យជាធរមាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីកុំឱ្យរំលោភគោលការណ៍នីត្យានុកូលភាព" ដូចដែលពួកគាត់បានលើកឡើងរួចមកហើយគឺថា ដោយសារ "ចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ ត្រូវបានចាត់ទុកជាលក្ខខណ្ឌគតិយុត្តិមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩" និង "ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧៩ មានភស្តុតាងតិចតួចស្តួចស្តើងណាស់ដែលបញ្ជាក់អំពីទម្លាប់អនុវត្តទូទៅរបស់រដ្ឋ និង *ទស្សនៈច្បាប់*[៥៥២] ដែលថា ចំណងពាក់ព័ន្ធនេះលែងជាធាតុផ្សំមួយចាំបាច់ទៀតហើយ"[៥៥៣]។

៣០១. នៅក្នុងចម្លើយតបរួមរបស់ខ្លួន សហព្រះរាជអាជ្ញាសន្និដ្ឋានថា "នៅមិនទាន់ច្បាស់លាស់ទេថាទំនាក់ទំនងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិធ្លាប់ត្រូវបានតម្រូវជាបញ្ហាសម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ" ដោយសារលក្ខខណ្ឌតម្រូវចំណងពាក់ព័ន្ធដែលមាននៅក្នុងធម្មនុញ្ញតុលាការ Nuremberg ពាក់ព័ន្ធតែចំពោះយុត្តាធិការដោយឡែករបស់តុលាការនោះ ដោយមិនបញ្ចូលធាតុផ្សំសំខាន់បន្ថែមទៀតទៅក្នុងឧក្រិដ្ឋកម្មនោះទេ[៥៥៤]។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅគ្រប់ករណីទាំងអស់ ការលុបបំបាត់យ៉ាងជាក់លាក់នូវទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើប្រល័យពូជសាសន៍ និងការប្រកាន់ពូជសាសន៍ (apartheid) គឺជា "ការចង្អុលបង្ហាញដ៏ជាក់លាក់មួយបញ្ជាក់ថា នេះជាច្បាប់ទំនៀម

---

[៥៥២] ពាក្យ *opinio juris* ជាភាសាឡាតាំង មានន័យជាភាសាអង់គ្លេសថា៖ "គោលការណ៍ដែលថា ចំពោះការប្រព្រឹត្តឬការអនុវត្តណាមួយដែលក្លាយជាវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវតែបង្ហាញថា បណ្តាប្រជាជាតិមានជំនឿថា ច្បាប់អន្តរជាតិ (មិនត្រឹមតែកាតព្វកិច្ចផ្នែកគុណធម៌ទេ) ទទួលស្គាល់នូវការប្រព្រឹត្ត ឬការអនុវត្តនោះ", វចនានុក្រម Black's Law Dictionary ។

[៥៥៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៨, ១៨៩។

[៥៥៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៧៦, ១៨១។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. PRELIMINAIRE

00661681



ទម្លាប់អន្តរជាតិក្នុងអំឡុងរយៈកាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩”[៥៥៥]។ សហព្រះរាជអាជ្ញាទទួចថា សេចក្តីសន្និដ្ឋាននេះត្រូវបានគាំទ្រដល់ការអនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់*[៥៥៦] ដែលមានចែងនៅក្នុងសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិរបស់គណៈកម្មការច្បាប់អន្តរជាតិឆ្នាំ១៩៥៤[៥៥៧] អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥៥៨] និងច្បាប់ជាតិដូចជាច្បាប់នៅប្រទេសអ៊ីស្រាអែល ១៩៥០[៥៥៩] ជាដើម។ ចុងក្រោយ សហព្រះរាជអាជ្ញាអះអាងថា ដោយមិនមានការជំទាស់ចំណុចនេះនៅក្នុងសំណុំរឿងលេខ០០១ ដើម្បីជាផលប្រយោជន៍នៃ “សង្គតិភាពនៃយុត្តិ

---

[៥៥៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨០។

[៥៥៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៣។

[៥៥៧] *សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ* របាយការណ៍ទីបីរបស់ J. Spiropoulos អ្នករាយការណ៍ពិសេស ឯកសារលេខ A/CN.4/85 បោះពុម្ពផ្សាយឡើងវិញនៅក្នុង *ទស្សនាវដ្តីប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ១៩៥៤ Vol. II* ទំព័រ១១២-១២១។ សូមមើលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា២(១១) ដោយលុបចោលនូវលក្ខខណ្ឌតម្រូវនៃ*ចំណងពាក់ព័ន្ធ*៖ “អំពើអមនុស្សធម៌ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ឬការធ្វើទុក្ខបុកម្នេញ ដែលបានប្រព្រឹត្តប្រឆាំងប្រជាជនស៊ីវិលនានា ដោយសារមូលហេតុសង្គម នយោបាយ ពូជសាសន៍ សាសនា ឬវប្បធម៌ ដោយអាជ្ញាធរនៃរដ្ឋណាមួយ ឬដោយបុគ្គលឯកជនដែលញុះញង់ ឬអនុញ្ញាតឱ្យការប្រើប្រាស់អំណាចបែបនោះ”។

[៥៥៨] *អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* (អនុម័តថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧០) សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 2391 (XXIII), U.N. GAOR សម័យប្រជុំលើកទី២៣ Supp. No. 18, at 40 ឯកសារ អ.ស.ប លេខ A/7218 (ឆ្នាំ ១៩៦៨) 754 U.N.T.S. 73 (អនុញ្ញាតឱ្យចុះហត្ថលេខានៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧០) មាត្រា១(ខ) “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទោះបីបានប្រព្រឹត្តក្នុងពេលមានសង្គ្រាមក្តី ក្នុងពេលសន្តិភាពក្តី”។

[៥៥៩] *ច្បាប់ស្តីពី (ការផ្តន្ទាទោសទៅលើ) ពួកណាហ្ស៊ី និងពួកសហការជាមួយណាហ្ស៊ី ឆ្នាំ ១៩៥០* (ប្រទេសអ៊ីស្រាអែល) មាត្រា១(ក)(២) និង(ខ)៖ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ត្រូវបានកំណត់និយមន័យស្រដៀងគ្នាទៅនឹងធម្មនុញ្ញ Nuremberg ដែរ ដោយលុបចោលនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ។ សូមមើលផងដែរ *ច្បាប់ស្តីពី (ការបង្ការ និងផ្តន្ទាទោស) បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឆ្នាំ ១៩៥០* (ប្រទេសអ៊ីស្រាអែល) មាត្រា៥។

សាស្ត្រគតិយុត្តិ" អង្គបុរេជំនុំជម្រះគួរអនុម័តតាមយុត្តិសាស្ត្រពីមុននៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅក្នុងករណីនោះ[៥៦០]។

៣០២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា គ្មានសេចក្តីអង្កេតដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីបញ្ហាទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធជាអន្តរជាតិ ដែលជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ[៥៦១]។

៣០៣. ជាការឆ្លើយតបវិញ សហមេធាវីការពារក្តី អៀង សារី បានអះអាងជាថ្មីថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានប្រភពចេញពីឧក្រិដ្ឋកម្មសង្គ្រាម ហើយថា ចំណុចនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ ដែលមាននៅក្នុងធម្មនុញ្ញNuremberg[៥៦២]។ សហមេធាវីការពារក្តីបានអះអាងថា ប្រភពឯកសារដែលសហព្រះរាជអាជ្ញាយកមកសំអាងមិនបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់ទេគឺ៖ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឥតរូបទេ ដោយសារអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានភាពខុសគ្នាតាមផ្លូវច្បាប់ អនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ (apartheid) ទើបតែចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦ ប៉ុណ្ណោះ ហើយក៏មិនទាន់បានចុះហត្ថលេខាដោយបណ្តាបស្ចិមប្រទេសដែរ សេចក្តីព្រាងរបស់គណៈកម្មការច្បាប់អន្តរជាតិឆ្នាំ ១៩៥៤ ធ្វើឡើងសំដៅទៅរកការវិវឌ្ឍន៍នៃច្បាប់អន្តរជាតិជាជាងការចងក្រងសេចក្តីព្រាងនោះ និងអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ "ទទួលបានការគាំទ្រតិចជាងពាក់កណ្តាលពីសំណាក់រដ្ឋ ដែលជាសមាជិកអង្គការសហប្រជាជាតិ"[៥៦៣]។

---

[៥៦០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៥។ សាលក្រមក្នុងសំណុំរឿង០០១ កថាខណ្ឌ២៩១-២៩២។

[៥៦១] សារណារួមឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ដែលជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត I, II និងIII។

[៥៦២] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៨៧។

[៥៦៣] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៨៨, ៩០។

00661683



<u>ការពិភាក្សា៖</u>

៣0៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីមិនបានយោងទៅលើកថាខណ្ឌជាក់លាក់នៃដីកាដំណោះស្រាយ ទាក់ទិននឹងទឡ្ហីករណ៍នេះទេ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា កថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយរួមមាន កថាខណ្ឌ១៣១៣-១៣១៥, ១៣៥0-១៤៧៨ និង ១៦១៣។ ក្រោយពីបានពិនិត្យកថាខណ្ឌទាំងនេះនៃដីកាដំណោះស្រាយរួចមក អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេត[៥៦៤] ចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ នៅក្នុងផ្នែកសំអាងហេតុនៃដីកាដំណោះស្រាយ នៅក្នុងផ្នែកទី៤ (ក) នៃជំពូក៣ ដែលមានចំណងជើងថា “ការកំណត់ប្រភេទបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ” សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ពី “ធាតុផ្សំរួម” នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារមានចែងនៅក្នុងកថាខណ្ឌទីពីរ នៃមាត្រា៥ នៃច្បាប់ អ.វ.ត.ក។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ផ្នែកនេះនៃដីកាដំណោះស្រាយមិនបានរៀបរាប់ពីធាតុផ្សំមួយនៃទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធទេ។

៣0៥. ក្រោយពីបានពិនិត្យមើលឡើងវិញទៅលើទឡ្ហីករណ៍របស់ភាគីទៅលើបញ្ហានេះ ដោយយល់ស្របជាមួយសហមេធាវីការពារក្តីដែលថា បញ្ហានេះទាក់ទិននឹងបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលយកមកអនុវត្តនៅ អ.វ.ត.ក ដោយបានពិចារណាយ៉ាងយកចិត្តទុកដាក់ពីផលប៉ះពាល់ដែលអាចកើតមានចំពោះករណីនេះ និងដោយបានពិនិត្យឡើងវិញទៅលើប្រភពច្បាប់ដែលពាក់ព័ន្ធ អង្គបុរេជំនុំជម្រះបានធ្វើការវាយតម្លៃដោយខ្លួនឯងថាតើ ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលដែលពាក់ព័ន្ធ រួមបញ្ចូលនូវការប្រព្រឹត្តដោយគ្មានទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធដែរឬទេ។

៣0៦. ដូចបានកត់សម្គាល់ខាងលើរួចមកហើយ អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងជាលើកដំបូងនៅក្នុងច្បាប់អន្តរជាតិ ក្នុងមាត្រា៦(គ) នៃធម្មនុញ្ញតុលាការ Nuremberg (IMT)។ នៅក្នុងនិយមន័យនោះមានបង្កប់ន័យនូវពាក្យថា លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធ ដែលចែងថា អំពើជាមូលដ្ឋានដែលបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង “ដោយការអនុវត្ត ឬដោយមានទំនាក់ទំនងជា

---

[៥៦៤] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១៣។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

មួយឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ"[៥៦៥]។ បញ្ញត្តិនេះបានឱ្យនិយមន័យលក្ខខណ្ឌតម្រូវមួយដែលថា មានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋសង្គ្រាម ដូចដែលមានចែងនៅក្នុងកថាខណ្ឌពីរខាងដើម នៃមាត្រាដដែលនេះ។ លក្ខខណ្ឌតម្រូវនេះក៏មានចែងផងដែរនៅក្នុងគោលការណ៍ Nuremberg[៥៦៦]។

៣០៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា យុត្តិសាស្ត្ររបស់តុលាការ ICTY បានសម្រេចថា លក្ខខណ្ឌតម្រូវជាក់លាក់នៃទំនាក់ទំនងនៅក្នុងធម្មនុញ្ញ Nuremberg និងគោលការណ៍ Nuremberg គឺជាការចែងយ៉ាងពិសេសសម្រាប់តុលាការនោះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុង *រឿងក្តី Tadić* បានសម្រេចថា ក្រៅពីបរិបទនៃតុលាការ Nuremberg "លក្ខខណ្ឌតម្រូវនេះមិនមានភាពតក្កវិទ្យា និងមិនមានមូលដ្ឋានច្បាប់"ទេ[៥៦៧]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "*មកទល់នឹងពេលនេះ* មានការបង្កើតនូវវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនតម្រូវឱ្យមានទំនាក់ទំនង ទៅនឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិទេ"។ តាមន័យទូទៅ អង្គបុរេជំនុំជម្រះសង្កេតឃើញថា គេត្រូវមានការប្រុងប្រយ័ត្នក្នុងការពឹងផ្អែកលើសំអាងហេតុរបស់តុលាការ ICTY នៅពេលពិភាក្សាពីសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសាររឿងក្តីនានាដែលតុលាការ ICTY ដោះស្រាយ ទាក់ទិននឹងពេលវេលាមួយដែលខុសពីពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក។ អង្គបុរេជំនុំជម្រះក៏ត្រូវតែសង្កេតផងដែរពីភាពខុសគ្នារវាងការពិភាក្សារបស់តុលាការ ICTY ទៅលើសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងគោលបំណងរកឱ្យឃើញពីនិយមន័យសុក្រឹត្យមួយនៃបទល្មើសមួយ ដែលផ្ទុយពីការពិភាក្សារបស់តុលាការ ICTY ទៅលើសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងគោលបំណងសម្រេចថាតើឧក្រិដ្ឋកម្មមួយ ដែលកើតមានក្នុងពេលជាក់លាក់មួយ។ ដើម្បីជាគោលបំណងនៃការពិនិត្យទៅលើបញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យទៅលើសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចំពោះវិសាលភាពដែលថា វាបានបង្កើត ឬមិនបានបង្កើតអត្ថិភាពនៃបទល្មើសមួយ ឬទម្រង់នៃការទទួលខុសត្រូវមួយនាពេលនោះ។

---

[៥៦៥] ធម្មនុញ្ញតុលាការ Nuremberg (IMT), មាត្រា៦(គ)។

[៥៦៦] គោលការណ៍ Nuremberg, គោលការណ៍ VI(គ)។.

[៥៦៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dusko Tadic* សំណុំរឿងលេខ IT-94-1-AR72 "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ១៤០។

៣០៨. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានដកស្រង់រឿងក្តី *Einsatzgruppen* ដើម្បីគាំទ្រដល់សំណើដែលថា ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងមិនបានបញ្ចូលទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធទេ[៥៦៨]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មិនបាននិយាយដល់យុត្តិសាស្ត្រក្រោយរបស់តុលាការយោធាអន្តរជាតិថាបានបញ្ជាក់សារជាថ្មីពីទំនាក់ទំនងនៃសង្គ្រាមទេ[៥៦៩]។ ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះសង្កេតឃើញថា បញ្ញត្តិនានាពីមុននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា បុព្វកថានៃសេចក្តីប្រកាសនៅទីក្រុង St. Petersburg នាឆ្នាំ១៨៦៨[៥៧០] និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩[៥៧១]

---

[៥៦៨] តុលាការយោធា Nuremberg ("NMT") *រឿងក្តីសហរដ្ឋអាមេរិក តទល់នឹង Otto Ohlendor និងអ្នកដទៃទៀត* សំណុំរឿងលេខ 9, NMT Vol. 4 ("រឿងក្តី *Einsatzgruppen*") ទំព័រ៤៩៩ (អង់គ្លេស)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dusko Tadić* សំណុំរឿងលេខ IT-94-1-T "សាលក្រមលើបណ្តឹងរបស់មេធាវីការពារក្តី ស្តីពីយុត្តាធិការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៥ កថាខណ្ឌ៧៩។

[៥៦៩] តុលាការយោធា Nuremberg *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Friedrich Flick និងអ្នកដទៃទៀត* សំណុំរឿងលេខ 5, NMT Vol. 6 ("រឿងក្តី *Flick*") ទំព័រ៨៣៖ "យើងជឿថា អំពើនានាដែលស្របទៅនឹងនិយមន័យនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងអាចផ្តន្ទាទោសបានតាមច្បាប់នោះ ដែលគេចាត់ទុកថាជាការកំណត់នូវតួនាទី ថាតើអំពើទាំងនោះមាន ឬមិនមានទំនាក់ទំនងជាឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម។ មិនមានការផ្តល់នូវសេចក្តីសន្និដ្ឋានណាមួយឡើយ នៅពេលមានការបាត់បង់នូវ ខ ដែលចែងថា "ក្នុងការអនុវត្ត ឬនៅក្នុងទំនាក់ទំនងជាមួយបទល្មើសដែលស្ថិតក្នុងយុត្តាធិការតុលាការ"" (គូសបញ្ជាក់បន្ថែម)។ ហេតុនេះ ការដកចេញនូវចំណងពាក់ព័ន្ធត្រូវបានគេចាត់ទុកថាមានទំនាក់ទំនងទៅនឹងការកំណត់ជាច្បាប់ក្នុងស្រុក នៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ តុលាការយោធា Nuremberg *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Ernst von Weizsaecker និងអ្នកដទៃទៀត* សំណុំរឿងលេខ 11, NMT Vol. 14 សូមមើលជាឧទាហរណ៍ ទំព័រ៦៥៤ (អង់គ្លេស) នៅពេលមានការពិចារណាថាតើ ចុងចោទបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ បណ្តាចៅក្រមទាំងនោះបានសម្រេចថា "ការប្រព្រឹត្តត្រូវបានបន្តជាផ្នែកមួយ និងជាជំនួយមួយដល់ការឈ្លានពានរបស់អាល្លឺម៉ង់ និងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព" សម្រាប់ឧទាហរណ៍មួយទៀតនៃការអនុវត្តនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ សូមមើលទំព័រ៦០៦ (អង់គ្លេស) ដែលចៅក្រមទាំងនោះបានសន្និដ្ឋានថា "ទោះជាយ៉ាងណាក្តី មិនមានភស្តុតាងដែលបង្ហាញថា ការប្រព្រឹត្តដែលបានចោទប្រកាន់នោះបានជួយជំរុញ ឬមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមទេ ...។ ហេតុនេះ វាមិនមែនជាបទល្មើសដែលទទួលស្គាល់ដោយតុលាការនេះទេ"។

[៥៧០] *សេចក្តីប្រកាសពីការលះបង់មិនប្រើប្រាស់នូវការបាញ់ផ្លោងអាវុធដែលបំផ្ទុះដែលមានទម្ងន់ក្រោម៤០០ក្រាម នៅពេលមានសង្គ្រាម* (អនុម័តថ្ងៃទី ២៩ ខែ វិច្ឆិកា/ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៨៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៨៦៨) បោះពុម្ពឡើងវិញនៅ D. Schindler and J. Toman (eds), សៀវភៅដែលមានចំណងជើងថា ច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ (*The Laws of*

និងឆ្នាំ ១៩០៧[៥៧២] ពិតជាមានចែងនៅក្នុងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម។ អង្គបុរេជំនុំជម្រះយល់ស្របថា អ្នកតាក់តែងសេចក្តីព្រាងធម្មនុញ្ញ Nuremberg បានធានាឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ដើម្បីបញ្ចៀសការចោទប្រកាន់ថា ការវិនិច្ឆ័យទោសចេញឆ្ងាយពីអ្វីដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញា[៥៧៣]។ អាស្រ័យហេតុនេះ នៅពេលបង្កើតដំបូង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធ។

៣០៩. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ឯកសារដែលមាន មិនបានបង្ហាញឱ្យបានច្បាស់លាស់ទេថាតើទំនាក់ទំនងនេះត្រូវបានកាត់ផ្តាច់ មុនពេល ឬក្នុងអំឡុងពេល នៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ អាស្រ័យហេតុនេះ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[៥៧៤] ត្រូវបានអនុម័តនៅក្នុងច្បាប់ជាតិជាពិសេសដោយមហាអំណាចសម្ព័ន្ធមិត្ត ក្នុងនាមប្រទេសអាល្លឺម៉ង់ អនុលោមតាម "អំណាចនីតិប្បញ្ញត្តិកំពូល" របស់មហាអំណាចទាំងនោះ[៥៧៥]។ ទោះបីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ត្រូវបានអនុម័តជាឯកច្ឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិក៏

---

*Armed Conflicts)*, បោះពុម្ពដោយ Martinus Nihjoff Publisher ឆ្នាំ ១៩៨៨ ទំព័រ១០២ (អង់គ្លេស)។ សូមមើល បុព្វកថា៖ "... អាស្រ័យហេតុនេះ ការប្រើប្រាស់អាវុធបែបនេះ *ផ្ទុយនឹងច្បាប់មនុស្សធម៌*" (គូសបញ្ជាក់បន្ថែម)។

[៥៧១] *អនុសញ្ញាទីក្រុងឡាអេ (II) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់ច្បាប់នេះ៖ បទប្បញ្ញត្តិទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* (អនុម័តថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ចូលជាធរមាននៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩០០) បុព្វកថា។

[៥៧២] *អនុសញ្ញាទីក្រុងឡាអេ (III) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់ច្បាប់នេះ៖ បទប្បញ្ញត្តិទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* (អនុម័តថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩១០) បុព្វកថា។

[៥៧៣] M. Bassiouni, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (*Crimes Against Humanity in International Criminal Law)*, Kluwer Law International, The Hague ឆ្នាំ ១៩៩៩ ទំព័រ ២៣-២៥, ២៩-៣០, ៤៣ (អង់គ្លេស)។

[៥៧៤] *ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង: ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* អនុម័តដោយក្រុមប្រឹក្សាសម្ព័ន្ធមិត្តគ្រប់គ្រងប្រទេសអាល្លឺម៉ង់ រួមមានចក្រភពអង់គ្លេស បារាំង សហរដ្ឋអាមេរិក និងសហភាពសូវៀត ក្រុងប៊ែរឡាំង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ ("ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង") មាត្រាII(១)(គ) ("មុនពេល និងអំឡុងពេលសង្គ្រាម" ត្រូវបានលុបចោល)។

[៥៧៥] សូមមើលផងដែរ M. Bassiouni, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (*Crimes Against Humanity in International Criminal Law*), Kluwer Law International, The Hague ឆ្នាំ ១៩៩៩ ទំព័រ៣៣ (អង់គ្លេស)។

ដោយ[៥៧៦] ក៏និយមន័យនៃពាក្យថា អំពើប្រល័យពូជសាសន៍នៅទីនេះ ពិតជាបានដកចេញយ៉ាងច្បាស់លាស់ពីនិយមន័យដើមរបស់វា ដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយតម្រូវឱ្យមាន "ចេតនាជាក់លាក់" ជាធាតុផ្សំមួយដែលមិនមានចែងនៅក្នុងធម្មនុញ្ញ Nuremberg ទេ[៥៧៧]។ អង្គបុរេជំនុំជម្រះយល់ស្របទៅនឹងទស្សនៈថា ទោះបីអំពើប្រល័យពូជសាសន៍ត្រូវបានចាត់ទុកជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ ១៩៤៨ ក៏ដោយ ក៏អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ "មិនបានផ្លាស់ប្តូរលក្ខខណ្ឌតម្រូវទូទៅនៃទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងអំពើប្រល័យពូជសាសន៍"។ គោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ដែលឆ្លុះបញ្ចាំងពីគោលការណ៍នៃច្បាប់អន្តរជាតិនាពេលនោះ បានបញ្ចូលចំណុចនេះទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មហាសន្និបាតអង្គការសហប្រជាជាតិមិនបានអនុម័តទទួលយក សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិរបស់គណៈកម្មការច្បាប់អន្តរជាតិទេឆ្នាំ ១៩៥៤[៥៧៨]។ មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសចំនួនត្រឹមតែ១៨ ប៉ុណ្ណោះ ក្នុងចំណោមប្រទេសសរុបចំនួន១៣៤ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីនៃអនុសញ្ញាស្តីពីអាជ្ញាយុ កាលឆ្នាំ ១៩៦៨[៥៧៩] ហើយមានតែរដ្ឋមួយបន្ថែមទៀតប៉ុណ្ណោះដែលផ្តល់សច្ចាប័នដល់លក្ខន្តិកៈនេះ ក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ទោះបីអង្គបុរេជំនុំជម្រះទទួលស្គាល់ថា ការអនុវត្តរបស់រដ្ឋមិនចាំបាច់មានលក្ខណៈដូចៗគ្នាដែលអាចចាត់ទុកជាការអនុវត្តទូទៅក៏ដោយ ក៏គេមិនអាចនិយាយបានថា អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ ស្របទៅនឹងកម្រិតនៃការទទួលយកមួយ ដើម្បីក្លាយជាការអនុវត្តជាទូទៅបានទេ។ ជាងនេះទៅទៀត នៅឆ្នាំ ១៩៦៨ អ្នកតំណាងដែលបានចូលរួមអនុម័តអនុសញ្ញាស្តីពីអាជ្ញាយុកាល ស្ទើរតែត្រូវបានបែងចែកស្មើគ្នារវាងអ្នកគាំទ្រមិនឱ្យបញ្ចូលទំនាក់ទំនងនៃជម្លោះប្រដាប់

---

[៥៧៦] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា១៖ "... នៅពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាមក្តី ..."។

[៥៧៧] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា២៖ "... ត្រូវបានធ្វើឡើងក្នុងបំណងបំផ្លាញទោះទាំងស្រុងក្តី ឬក៏ខ្លះៗក្តីដល់ប្រជាជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសន៍មួយ"។

[៥៧៨] សូមមើលការបដិសេធចោលរបស់មហាសន្និបាត៖ សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 897 (IX) ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤។

[៥៧៩] *អនុសញ្ញាស្តីពីការមិនអនុវត្តច្បាប់អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* (អនុម័តនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧០) សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2391 (XXIII), U.N. GAOR, 23d Sess., Supp. No. 18, at 40, U.N. Doc. A/7218 (ឆ្នាំ ១៩៦៨) 754 U.N.T.S. 73 មាត្រា១(ខ) "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះបីប្រព្រឹត្តនៅពេលមានសង្គ្រាម ឬនៅពេលមានសន្តិភាពក៏ដោយ"។

អាវុធ និងអ្នកប្រឆាំងនឹងទង្វើបែបនេះ[៥៨០]។ ស្របៀងគ្នានេះដែរ មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសត្រឹមតែ២៥ ប៉ុណ្ណោះ ដែលបានចុះហត្ថ លេខាផ្តល់សច្ចាប័ន ឬចូលជាភាគី នៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការប្រកាន់ពូជសាសន៍ ដោយមិនមានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ[៥៨១] ក្នុងចំណោមប្រទេសសរុប១៣៧ ដែលជាសមាជិកអង្គការសហប្រជាជាតិ និងមានប្រទេសចំនួន៣២ បន្ថែមទៀតដែលបានចុះហត្ថលេខាក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ក្នុងចំណោមប្រទេសជាសមាជិកបានកើនឡើងរហូតដល់ចំនួន១៤៨[៥៨២]។ ជាងនេះទៀត ដូចបានកត់សម្គាល់ទាក់ទិននឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ រួចមកហើយគឺថា ការដកចេញនូវលក្ខខណ្ឌនៃចំណងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធ ចំពោះការប្រកាន់ពូជសាសន៍មិនបានផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធមួយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ផ្សេងទេ។ បន្ថែមលើនេះទៀត បើតាមអ្វីដែលអង្គបុរេជំនុំជម្រះអាចស្វែងរកបានគឺថា មានឧទាហរណ៍មួយចំនួនតូចនៅក្នុងច្បាប់ជាតិ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនេះ។ ឧទាហរណ៍មួយនៃការមិនរាប់បញ្ចូលនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនៅក្នុងច្បាប់ជាតិ មាននៅក្នុងច្បាប់ប្រទេសអ៊ីស្រាអែលឆ្នាំ ១៩៥០ ដែលបង្ហាញពីលក្ខណៈពិសេសតែមួយគត់របស់វា។

៣១០. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីលិខិតុបករណ៍ទាំងនេះត្រូវបានវិនិច្ឆ័យដោយផលប៉ះពាល់រួមរបស់វាក្តី ហើយនៅពេលគេវិនិច្ឆ័យលិខិតុបករណ៍មួយៗដោយឡែកភាពមិនពេញលេញរបស់វា

---

[៥៨០] គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍សម័យប្រជុំលើកទី២៣ ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ ដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ កថាខណ្ឌ១៤៤-១៤៥ នៅក្នុងកំណត់ហេតុផ្លូវការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម សម័យប្រជុំលើកទី៤២ Supp. No. 6។

[៥៨១] *អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍* (ចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦) សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 3068 (XXVIII), 28 U.N. GAOR Supp. (No. 30) at 75, U.N. Doc. A/9030 (ឆ្នាំ ១៩៧៤) 1015 U.N.T.S. 243។ កំណត់សម្គាល់នៃបុព្វកថានៅក្នុងកថាខណ្ឌ៦ និង៧ នៅពេលដែលការប្រកាន់ពូជសាសន៍ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមាត្រា II នៅពេលដែល*ចំណងពាក់ព័ន្ធ* ត្រូវបានលុបចោល នៅក្នុងនិយមន័យនៃការប្រកាន់ពូជសាសន៍។

[៥៨២] អង្គការសហប្រជាជាតិ ឯកសារក្រោមចំណងជើងថា សន្ធិសញ្ញាពហុភាគីដែលមាននៅក្នុងមូលដ្ឋានទិន្នន័យសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ (*Multilateral Treaties Deposited with the Secretary-General Treaty Series* Database), "Status of Treaties" ជំពូកទី IV, 7។

ត្រូវបានកាត់បន្ថយក៏ដោយ ក៏មិនទាន់មានភាពច្បាស់លាស់ដែរ នៅពេលមានផលប៉ះពាល់ចំពោះការមិនរាប់បញ្ចូលក្នុងច្បាប់ទំនៀមទម្លាប់នោះ។ គេអាចនិយាយបានថា នៅឆ្នាំ ១៩៦៨ អ្នកតំណាងដែលបានចូលរួមអនុម័តអនុសញ្ញាស្តីពីអាជ្ញាយុកាល ស្ទើរតែត្រូវបានបែងចែកស្មើគ្នារវាងអ្នកគាំទ្រមិនឱ្យបញ្ចូលចំណងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធ និងអ្នកប្រឆាំងមិនឱ្យមានទង្វើបែបនេះ[៥៨៣]។ ជាថ្មីម្តងទៀត នៅឆ្នាំ ១៩៨៤ នៅពេលដែលគណៈកម្មការច្បាប់អន្តរជាតិបានផ្តល់អនុសាសន៍ឱ្យធ្វើការអនុម័តទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមិនមានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ ការពិភាក្សាដេញដោលគ្នារវាងអ្នកតំណាងពីរដ្ឋជាសមាជិកបានសម្តែងឱ្យឃើញថា អ្នកដែលគាំទ្រមិនឱ្យបញ្ចូលចំណងពាក់ព័ន្ធ គឺច្រើនជានិន្នាការមកពីសហគមន៍អន្តរជាតិ។ ទោះបីជាយ៉ាងណាក្តី ដោយសារមិនមានទម្លាប់អនុវត្តរបស់រដ្ឋច្បាស់លាស់ និង*ទស្សនៈច្បាប់*នោះ អង្គបុរេជំនុំជម្រះនៅតែមិនអាចកំណត់បានពីដំណាក់កាលដែលមានបញ្ហាចន្លោះពីឆ្នាំ ១៩៦៨ រហូតដល់ឆ្នាំ ១៩៨៤ នៅពេលដែលដំណាក់កាលអន្តរកាលបានកើតឡើង។ បើតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* ភាពមិនច្បាស់លាស់បែបនេះនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។

៣១១. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការ Nuremberg និង គោលការណ៍ Nuremberg បន្តអនុវត្តនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថា ចំណងទាក់ទំនងមួយទៅនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម នៅតែជាធាតុផ្សំមួយដ៏សំខាន់នៅឡើយ។ ទោះជាយ៉ាងណាក្តី វាជាការសមរម្យដែលត្រូវកត់សម្គាល់ថា ដោយសារឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានហាមឃាត់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិទាំងនៅក្នុងបរិបទជាតិ និងអន្តរជាតិនោះ ចំណងពាក់ព័ន្ធចាំបាច់ទៅនឹងជម្លោះប្រដាប់អាវុធ មិនតម្រូវឱ្យមានលក្ខណៈជាអន្តរជាតិនោះទេ[៥៨៤]។

---

[៥៨៣] គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍សម័យប្រជុំលើកទី២៣ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ - ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ កថាខណ្ឌ១៤៤-១៤៥ នៅក្នុងកំណត់ហេតុផ្លូវការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម សម័យប្រជុំលើកទី៤២ Supp. No. 6។

[៥៨៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dusko Tadić* សំណុំរឿងលេខ IT-94-1-T "សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ កថាខណ្ឌ៨២។

៣១២. មុននឹងឈានមកដល់សេចក្តីសន្និដ្ឋានបែបនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមរម្យដែលត្រូវកត់សម្គាល់ត្រង់ចំណុចនេះថា ចាប់ពីកថាខណ្ឌ១៥០ ដល់កថាខណ្ឌ១៥៥ នៃដីកាដំណោះស្រាយបានអះអាងថា មានជម្លោះប្រដាប់អាវុធជាអន្តរជាតិបានកើតឡើងសឹងតែភ្លាមៗ បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ("CPNLAF") បានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ ហើយថាជម្លោះប្រដាប់អាវុធនេះបានអូសបន្លាយយ៉ាងហោចណាស់រហូតដល់ពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញ នាថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ និងនៅពេលក្រោយៗមកទៀត។

៣១៣. សម្រាប់ហេតុផលទាំងអស់នេះ អង្គបុរេជំនុំជម្រះផ្តល់នូវមូលដ្ឋានរងនេះនៃមូលដ្ឋានទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍ ដូចដែលមានរៀបរាប់នៅក្នុងចំណុច៧(១) នៃបទបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍នេះ ដើម្បីបន្ថែម "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងបទល្មើសជាក់លាក់ និងជម្លោះប្រដាប់អាវុធ" ចំពោះលក្ខខណ្ឌតម្រូវ "ជាមូលដ្ឋាន" នៅក្នុងជំពូក IV(ក) នៃផ្នែកទី៣ នៃដីកាដំណោះស្រាយ។

**ii) មូលដ្ឋានរងទី១០ (ការដាក់ក្នុងមន្ទីរឃុំឃាំង)៖**

<u>សារណានានា៖</u>

៣១៤. សហមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍ និងជាថ្មីម្តងទៀតនៅក្នុងសារណាតបរបស់ខ្លួន ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាថា សហចៅក្រមស៊ើបអង្កេត "បានភ័ន្តច្រឡំដោយបានយល់ឃើញថា ការដាក់ក្នុងមន្ទីរឃុំឃាំង ថាជាអំពើដែលបានរៀបរាប់បង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ក្នុងចំណោមប្រការដទៃទៀត ដោយសារអំពើនេះមិនត្រូវបានរាប់បញ្ចូលឱ្យបានច្បាស់លាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុង *ធម្មនុញ្ញនៃតុលាការយោធាសម្រាប់ការកាត់សេចក្តីនៃឧក្រិដ្ឋកម្មសង្គ្រាមធំៗ* ដែលគេហៅថា ធម្មនុញ្ញតុលាការ Nuremberg ("ធម្មនុញ្ញតុលាការ Nuremberg (IMT)")[៥៨៥] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ

---

[៥៨៥] *ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ការកាត់ទោសនៃឧក្រិដ្ឋកម្មសង្គ្រាមធំៗ* ដែលមានភ្ជាប់ជាមួយកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ចុះថ្ងៃទី៨ ខែ សីហា ឆ្នាំ ១៩៤៥ 82 U.N.T.S. 280 ("ធម្មនុញ្ញ Nuremberg (IMT)")។

សម្រាប់ចុងបូព៌ា ដែលគេហៅថា ធម្មនុញ្ញតុលាការទីក្រុងតូក្យូ ("ធម្មនុញ្ញតុលាការទីក្រុងតូក្យូ (IMTFE)")[៥៨៦] ឬគោលការណ៍ Nuremberg ដែលត្រូវបានចងក្រងនោះទេ[៥៨៧]។

៣១៥. នៅក្នុងចម្លើយតបរួមរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍ថា ការហាមប្រាមទៅលើការដាក់ក្នុងមន្ទីរឃុំឃាំងដោយបំពាន ដំបូងកើតឡើងចេញពីច្បាប់ស្តីពីសង្គ្រាម ហើយត្រូវបានគាំទ្រដោយលិខិតុបករណ៍សិទ្ធិមនុស្ស[៥៨៨]។ ដោយសារមានភស្តុតាងថា អំពើនេះត្រូវបានកំណត់ជាបទល្មើសតាំងពីមុនឆ្នាំ ១៩៧៥ ម្ល៉េះ សហព្រះរាជអាជ្ញាបានបង្ហាញយ៉ាងច្បាស់នូវការបញ្ចូលបញ្ញត្តិនេះទៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[៥៨៩] និងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[៥៩០] និងពឹងផ្អែកលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ០០១[៥៩១] ទាក់ទិននឹងអំពើនេះ។ នៅក្នុងសារណារួមរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សំណើណាមួយជាក់លាក់ ស្តីពីបញ្ហានៃការដាក់ក្នុងមន្ទីរឃុំឃាំងទេ តែបានសន្និដ្ឋានជាទូទៅថា ការបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ស្របទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥៩២]។

---

[៥៨៦] *ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា* អនុម័តដោយបទបញ្ជាប្រតិបត្តិ ឧត្តមសេនីយ៍ Dougals MacArther អគ្គមេបញ្ជាការជាន់ខ្ពស់នៃមហាអំណាចសម្ព័ន្ធមិត្តប្រចាំប្រទេសជប៉ុន ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ ធ្វើវិសោធនកម្មនៅថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៤៦ ដែលគេហៅថា ធម្មនុញ្ញតុលាការទីក្រុងតូក្យូ ("ធម្មនុញ្ញតុលាការទីក្រុងតូក្យូ (IMTFE)")។

[៥៨៧] សូមមើល បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២០៥ និងជើងទំព័រលេខ៤៧៦ ដោយយោងទៅដល់កថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយ។ *សូមមើលផងដែរ* សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៩៥។

[៥៨៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៨។

[៥៨៩] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មាត្រា II(១)(គ)៖ "អំពើឃោរឃៅ និងបទល្មើសនានា រួមបញ្ចូលតែមិនកំណត់ត្រឹមតែ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស *ការដាក់ក្នុងមន្ទីរឃុំឃាំង* ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងៗទៀត ..." (គូសបញ្ជាក់បន្ថែម)។

[៥៩០] ក្រមព្រហ្មទណ្ឌ (ឆ្នាំ ១៩៥៦) មាត្រា២៤៨-២៥១។

[៥៩១] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៥២-៣៥៣។

[៥៩២] សារណារួមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី I កថាខណ្ឌ២០-២៨។ សារណារួមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី II កថាខណ្ឌ១៥។ សារណារួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី III ដែលបានសន្និដ្ឋាននៅកថាខណ្ឌ៨ ថា "សហមេធាវីតំណាងដើម

<u>ការពិភាក្សា៖</u>

៣១៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ អៀង សារី ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយចាត់ទុកការដាក់ក្នុងមន្ទីរឃុំឃាំង ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន[៥៩៣]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានយោងទៅកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយដូចខាងក្រោម៖

> តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល [...] ការដាក់ក្នុងមន្ទីរឃុំឃាំង [...]

៣១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងជាពិសេសនៅក្នុងមាត្រា៥ ថា "ការដាក់ក្នុងមន្ទីរឃុំឃាំង" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា សហមេធាវីការពារក្តីបានជំទាស់ថា ធម្មនុញ្ញ Nuremberg (IMT) និង ធម្មនុញ្ញទីក្រុងតូក្យូ (IMTFE) មិនបានចាត់ទុកការដាក់ក្នុងមន្ទីរឃុំឃាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៣១៨. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្នុងការអំណះអំណាងរបស់ខ្លួននៅក្នុងកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ប្រភពឯកសារគាំទ្រនានាដូចជា៖

> សាលក្រម សំណុំរឿងលេខ៖០០១/១៨ កក្កដា ២០០៧/អវតក/អជសដ កថាខណ្ឌ៣៤៧, ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [ឆ្នាំ ១៩៤៥] មាត្រាII(១)(គ), Greifelt និងអ្នកដទៃទៀត ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ការជំនុំជម្រះ [ឆ្នាំ ១៩៤៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ Vol. IV ទំព័រ៦០៩, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [ឆ្នាំ ១៩៦៦] មាត្រា៩[៥៩៤]។

---

បណ្តឹងរដ្ឋប្បវេណីយល់ឃើញថា រាល់ការលើកឡើងជាទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ [...] មិនអាចទទួលយកបាននោះទេ ហើយយើងខ្ញុំសូមប្រកាសការគាំទ្ររាល់ទឡ្ហីករណ៍ទាំងអស់របស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់ខ្លួន [...]"។

[៥៩៣] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១៣។

[៥៩៤] ដីកាដំណោះស្រាយ ជើងទំព័រលេខ៥១៩០។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

៣១៩. ទាក់ទិននឹងប្រភពឯកសារទាំងនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដំបូង នៅក្នុងសំណុំរឿងលេខ០០១ ឌុច មិនបានជំទាស់នឹងយុត្តាធិការរបស់ អ.វ.ត.ក លើការដាក់ក្នុងមន្ទីរឃុំឃាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ហើយថា នៅផ្នែកសម្រេចនៃសាលក្រមនៅក្នុងសំណុំរឿងលេខ ០០១ នោះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យ ដោយអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនទៅលើនិយមន័យនៃពាក្យថា ការដាក់ក្នុងមន្ទីរឃុំឃាំង ដោយមិនបានពិចារណាថាតើអំពើនេះត្រូវ ឬមិនត្រូវបានកំណត់ជាបទល្មើស តាមច្បាប់អន្តរជាតិមុនឆ្នាំ ១៩៧៥ នោះទេ[៩៩៥]។ អាស្រ័យហេតុនេះ ទោះបីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១ ជាជំនួយក្នុងការសម្រេចថានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏សាលក្រមនេះមិនជួយក្នុងសម្រេចថាតើអំពើនេះត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែរ។

៣២០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការឃុំខ្លួនជនស៊ីវិលមិនស្របច្បាប់ ត្រូវបានហាមឃាត់ថាជាបទល្មើសមួយនៅក្នុងច្បាប់សង្គ្រាម តាំងពីយូរមកហើយ។ ទោះបីការឃុំខ្លួនជនស៊ីវិល អាចមានយុត្តិកម្មនៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួនក៏ដោយ[៩៩៦] ក៏អនុសញ្ញាទីក្រុងហ្សឺណែវទី IV បានហាមឃាត់អំពើនេះនៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ នៅពេលដែលភាគីដែលចាប់ឃុំខ្លួនមនុស្សមិនអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា៤២ និង៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV។ ហេតុនេះ ច្បាប់សង្គ្រាមបានកំណត់ជាបទល្មើសនូវការឃុំខ្លួនជនស៊ីវិលមិនស្របច្បាប់នៅពេលដែល (i) បុគ្គលត្រូវបានឃុំខ្លួន*ដោយមិនមានមូលហេតុសមរម្យ* ដែលអាចជឿបានថា វាជាការចាំបាច់សម្រាប់សន្តិសុខរបស់ភាគីដែលឃុំខ្លួនមនុស្ស និង (ii) *នៅពេលការពារផ្នែកនីតិវិធី* ដែលតម្រូវដោយមាត្រា៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV មិនត្រូវបានអនុវត្ត ទាក់ទិននឹងជនស៊ីវិលដែលត្រូវបានឃុំខ្លួននោះ ទោះបីការឃុំខ្លួនដំបូងអាចមានយុត្តិកម្មក៏ដោយ[៩៩៧]។ ការពិត ក្រោយសង្គ្រាមលោកលើកទីពីរ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ត្រូវបានចោទប្រកាន់ថាជាបទឧក្រិដ្ឋសង្គ្រាម

---

[៩៩៥] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៤៧-៣៥១។

[៩៩៦] បានបញ្ជាក់ច្បាស់លាស់នៅក្នុងមាត្រា៤១ ៤២ និង៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV។

[៩៩៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordic និង Cerkez* សំណុំរឿងលេខ IT-95-14/2-T "សាលក្រម" ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ២៩១។

បន្ថែមទៅលើការចោទប្រកាន់ថាជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានបង្ហាញខាងក្រោម។

៣២១. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីការដាក់ក្នុងមន្ទីរឃុំឃាំងមិនត្រូវបានចែងយ៉ាងច្បាស់នៅក្នុងធម្មនុញ្ញ Nuremberg (IMT) និងធម្មនុញ្ញទីក្រុងតូក្យូ (IMTFE) ក៏ដោយ ក៏អំពើនេះមានចែងនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ដូចដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងដែរ។ យុត្តិសាស្ត្ររបស់តុលាការយោធា Nuremberg ("NMTs") នៅក្នុងតំបន់ដែលត្រួតត្រាដោយពួកសម្ព័ន្ធមិត្តដែលអនុវត្តច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង បង្ហាញឲ្យឃើញថា ចុងចោទត្រូវបានជំនុំជម្រះទោស និងផ្តន្ទាទោសពីការដាក់ក្នុងមន្ទីរឃុំឃាំង ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងករណីជាច្រើន ប្រការដែលគួរឲ្យកត់សម្គាល់គឺករណីដែលទាក់ទិននឹងជំរំប្រមូលផ្តុំ។ នៅក្នុងករណីភាគច្រើន ចុងចោទត្រូវបានជំនុំជម្រះទោសជាបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ហើយ NMTs បានពិចារណាជាទូទៅពីការចោទប្រកាន់ទោសរួមគ្នាតែម្តង ដោយបង្ហាញសញ្ញាណថា ការដាក់ក្នុងមន្ទីរឃុំឃាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចេញពីសញ្ញាណដែលមានលក្ខណៈច្បាស់លាស់ជាងមុននៅក្នុងច្បាប់សង្គ្រាម[៥៥៨]។

---

[៥៥៨] បន្ថែមទៅលើករណីនានាដែលនឹងពិភាក្សាខាងក្រោម *សូមមើលផងដែរ៖ រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Alfried Felix Alwyn Krupp von Bohlen und Halbach និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៤៨ ដែលបោះពុម្ពជាថ្មីនៅក្នុង *NMT Trials*, Vol IX, p. 1 ត្រង់ទំព័រ១៣៧៣ (ដែលចុងចោទត្រូវបានចោទប្រកាន់ពីបទ "ការដាក់ក្នុងមន្ទីរឃុំឃាំង" ក្រោមបទចោទទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលរួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅផ្នែក(គ)។ ផ្នែក(គ) នៃបទចោទទី៣ រួមមានអំណះអំណាងដូចតទៅ៖ មានការអះអាងទទួលស្គាល់ថា អំពើនានាដែលបានលើកយកមកសំអាងដែលបានបង្កើតជាការរំលោភដល់បទប្បញ្ញត្តិទាំងនេះ ក៏មានការរំលោភដល់ច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាម រំលោភដល់គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ដែលដកស្រង់ចេញពីច្បាប់ព្រហ្មទណ្ឌនានារបស់បណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់ និងពីអនុសញ្ញាអន្តរជាតិនានា ដោយឡែករំលោភដល់មាត្រាជាក់លាក់មួយចំនួននៃបញ្ញត្តិនៃទីក្រុងឡាអេស្តីពីសង្គ្រាមលើដីគោក ឆ្នាំ ១៩០៧ និងរំលោភដល់អនុសញ្ញាស្តីពីឈ្លើយសឹក និងសង្គ្រាម ទីក្រុងហ្សឺណែវ ឆ្នាំ ១៩២៩។ រាល់អំពើទាំងអស់ដែលលើកយកមកសំអាងដែលបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតឡើងក្នុងពេលសង្គ្រាម និងទាក់ទិននឹងសង្គ្រាម)។ ចុងចោទ Krupp, Loeser, Houdremont, Mueller, Janssen, Ihn, Eberhardt, Korschan, von Buelow, Lehmann និង Kupke ត្រូវបានរកឃើញពិរុទ្ធភាពនៅក្នុងបទចោទទី៣ (ទំព័រ១៤៤៩) (អង់គ្លេស)។

៣២២. នៅក្នុង*រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកដទៃទៀត* (“រឿងក្តី *Pohl*”) ចុងចោទត្រូវបានចោទប្រកាន់ពីបទចោទទី៣ ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបទចោទប្រកាន់មួយចំនួនត្រូវបានផ្តន្ទាទោស[៥៩៩] រួមមាន “ការដាក់ក្នុងមន្ទីរឃុំឃាំង” ផង ទាក់ទិននឹងអំពើនានាដែលបានប្រព្រឹត្តនៅក្នុងជំរំប្រមូលផ្តុំ និងជំរំធ្វើការ នៅទូទាំងប្រទេសអាល្លឺម៉ង់ និងនៅក្នុងតំបន់ដែលត្រួតត្រាដោយពួកណាហ្ស៊ី[៦០០]។ ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា នៅក្នុងរឿងក្តី *Pohl* ចុងចោទត្រូវបានចោទប្រកាន់ និងរកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះ “ការដាក់ក្នុងមន្ទីរឃុំឃាំង*ដោយខុសច្បាប់*” ឬ “ការឃុំខ្លួនមនុស្ស*មិនស្របច្បាប់*”[៦០១]

---

[៥៩៩] តុលាការយោធា Nuremberg *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ បោះពុម្ពសាជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* United States Government Printing Office ឆ្នាំ១៩៤៩-១៩៥២ (“*សវនាការ NMT*”) Vol. V ទំព័រ១៩៥ (“រឿងក្តី *Pohl*”)។ Phol, Frank, Loerner, Tschenstcher, Kiefer, Eirenschmalz, Sommer, Pook, Hohberg និង Baier ត្រូវបានផ្តន្ទាទោសទាំងអស់គ្នាក្រោមបទចោទទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[៦០០] បើតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានទទួលការគាំទ្រនៅក្នុងសេចក្តីសម្រេចរបស់តុលាការនេះ (ជាពិសេស សូមមើលទំព័រ១៣០៤) គឺថា៖ “គោលការណ៍ដែលត្រូវបានបង្កើតឡើងដោយ WVHA គឺការដាក់បន្ទុកដល់អ្នកទោសនៅក្នុងជំរំប្រមូលផ្តុំឱធ្វើការងារដ៏ច្រើន ដោយផ្គត់ផ្គង់មិនដិតដល់នូវរបបអាហារ សម្លៀកបំពាក់ ការស្នាក់អាស្រ័យ អនាម័យ សេវាផ្នែកពេទ្យ និងការវះកាត់ និងមធ្យោបាយចាំបាច់ ឬបរិក្ខារដទៃទៀត។ គេអាចដឹងយ៉ាងច្បាស់ថា គោលនយោបាយបែបនេះបណ្តាលឱ្យស្លាប់បាត់បង់ជីវិតមនុស្សរាប់ពាន់នាក់ ដោយសារជំងឺ ឬការបាក់កម្លាំងធ្ងន់ធ្ងរ។ សម្រាប់អ្នកទោសភាគច្រើន មិនត្រូវបានដោះលែងពីជំរំប្រមូលផ្តុំទេ លើកលែងតែមានការស្លាប់ ចំណែកឯផែនការសម្រាប់ធ្វើឱ្យការរស់នៅបានសមរម្យ ចំពោះអ្នកដែលមិនអាចធ្វើការកើតក៏គ្មានដែរ។ វិធីព្យាបាលអ្នកមានជំងឺគឺការសម្លាប់អ្នកទាំងនោះចោល។ ជាលទ្ធផលនៃគោលនយោបាយនេះ សាកសពមនុស្សស្លាប់មានចំនួនច្រើនហួសប្រមាណ” (ទំព័រ២០៥ (អង់គ្លេស) កថាខណ្ឌ១៦) ។ បទចោទទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានរៀបរាប់ថា៖ “ចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៣៩ ដល់ខែ មេសា ឆ្នាំ ១៩៤៥ ចុងចោទទាំងអស់នេះបានប្រព្រឹត្តដោយខុសច្បាប់ ដោយមានចេតនា និងបានដឹងជាមុន នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានកំណត់នៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ដែលក្នុងនោះពួកគេជា ចារី អ្នកសមគំនិត ដែលបានបញ្ជា ជំរុញ ចូលរួមដោយយល់ស្របជាមួយ និងមានការពាក់ព័ន្ធទៅនឹងផែនការ និងក្រុមដែលចូលរួមក្នុងការប្រព្រឹត្តអំពើសាហាវយង់ឃ្នង និងបទល្មើសនានា រួមបញ្ចូលតែមិនកំណត់ត្រឹមតែ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស *ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការធ្វើទារុណកម្ម* ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ និងសាសនា និងការប្រព្រឹត្តពុំគប្បី និងអំពើអមនុស្សធម៌ និងព្រហ្មទណ្ឌផ្សេងៗទៀត ប្រឆាំងនឹងមនុស្សរាប់ពាន់នាក់ [...]” (ទំព័រ២០៥ កថាខណ្ឌ២៤) (គូសបញ្ជាក់បន្ថែម)។

[៦០១] រឿងក្តី *Pohl* ទំព័រ៩៦២ និង ៩៦៤។

ដោយបង្ហាញថា ការដកហូតសិទ្ធិត្រូវបានធ្វើឡើងដោយបំពាន ក្នុងន័យថាច្បាប់មិនបានទទួលស្គាល់។ ភស្តុតាងដែលបានលើកឡើងនៅក្នុងរឿងក្តី *Pohl* ផ្តល់ជាគំនិតថា ការដាក់ក្នុងមន្ទីរឃុំឃាំងនឹងមិនស្របច្បាប់ នៅពេលការទទួលស្គាល់តាមផ្លូវច្បាប់ពីមុនអស់សុពលភាព តែបុគ្គលនោះមិនបានទទួលសេរីភាពរបស់ខ្លួនដូចដើមឡើងវិញឡើយ[៦០២]។

៣២៣. នៅក្នុងរឿងក្តី *សហរដ្ឋអាមេរិក តទល់នឹង Wilhelm List និងអ្នកដទៃទៀត* (“រឿងក្តី *ចាប់ពង្រត់*”) ចុងចោទបីនាក់ក៏ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោស[៦០៣]ផងដែរ ពីបទដាក់មន្ទីរឃុំឃាំងដោយខុសច្បាប់ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃបទចោទទី៤ ដូចតទៅ៖

> “ចុងចោទជាអាទិចារី ឬជាចារីបន្ទាប់បន្សំនៃអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការប្រព្រឹត្តគួឱ្យរន្ធត់ជាប្រព័ន្ធ *ការដាក់ឃុំឃាំងក្នុងជំរំប្រមូលផ្តុំ* ការងារដោយបង្ខំនៅកន្លែងសាងសង់មូលដ្ឋានយោធា និងការនិរទេសទៅធ្វើការងារបែបទាសករ ចំពោះប្រជាជនស៊ីវិលក្រិច យូហ្គោស្លាវី និងអាល់បានី ដោយកងទ័ពអាល្លឺម៉ង់ ដែលធ្វើសកម្មភាពតាមបញ្ជារបស់ចុងចោទ *ដែលប្រជាពលរដ្ឋមួយចំនួនធំដូចជា អ្នកប្រជាធិបតេយ្យ អ្នកជាតិនិយម ជនជាតិជ្វីហ្វ និងពួកជីបស៊ី (gypsies) ត្រូវបានចាប់ខ្លួន បញ្ចូលក្នុងជំរំប្រមូលផ្តុំ ត្រូវបានគេវាយដំ ធ្វើទារុណកម្ម ប្រព្រឹត្តមិនគប្បី* និងត្រូវបានគេយកទៅសម្លាប់ ខណៈដែលប្រជាពលរដ្ឋដទៃទៀតត្រូវបានគេកេណ្ឌដោយបង្ខំឱ្យទៅធ្វើការ នៅក្នុងរបប Reich និងតំបន់ដែលត្រួតត្រាដោយពួកណាហ្ស៊ី” [៦០៤]។

តុលាការបានសង្កត់ធ្ងន់នៅក្នុងសាលក្រមរបស់ខ្លួនថា “អំពើនានាដែលត្រូវបានចោទប្រកាន់នៅក្នុងបទចោទមួយក្នុងចំណោមបទចោទទាំងបួន ត្រូវបានអះអាងថាត្រូវបានប្រព្រឹត្តឡើងដោយចេតនា ដោយបានដឹងជាមុន និងដោយមិនស្របច្បាប់ និងបានបង្កើតជាការរំលោភដល់ *អនុសញ្ញាអន្តរជាតិ* បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧ ច្បាប់និងទំនៀមទម្លាប់សង្គ្រាម *គោលការណ៍ទូទៅនៃច្បាប់*

---

[៦០២] រឿងក្តី *Pohl* ទំព័រ (បើតាមសំបុត្រភស្តុតាងមួយដែលបានដកស្រង់នៅក្នុងសាលក្រម “បញ្ហាមួយរបស់ Pohl ត្រូវបានផ្ញើទៅជំរំប្រមូលផ្តុំ ដែលអនុញ្ញាតឱ្យមេបញ្ជាការជំរំអាចបង្ខាំងអ្នកទោសដែលត្រូវបានដោះលែងពីចោទប្រកាន់របស់ មន្ទីរសន្តិសុខធំរបស់ Reich បាន តែជាការសំខាន់សម្រាប់កម្លាំងការងារនៅក្នុងជំរំនោះ។ រយៈពេលនៃការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់នេះអាចពន្យារបានរហូតដល់ចប់សង្គ្រាម”)។

[៦០៣] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Wilhelm List និងអ្នកដទៃទៀត* ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៤៨ បោះពុម្ពជាថ្មីនៅក្នុង *NMT Trials*, Vol. XI (“រឿងក្តី *ចាប់ពង្រត់*”) Kuntze (ទំព័រ១២៨១) Rendulic (ទំព័រ១២៩៧) និង von Leyser (ទំព័រ១៣០៥) ត្រូវបានរកឃើញពិរុទ្ធភាពក្រោមបទចោទទី៤។

[៦០៤] រឿងក្តី *ចាប់ពង្រត់* ទំព័រ១២៣៤។

*ព្រហ្មទណ្ឌ* ដែលបានដកស្រង់ចេញពីច្បាប់ព្រហ្មទណ្ឌរបស់បណ្តាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់ និងត្រូវបានប្រកាស ទទួលស្គាល់ និងកំណត់ជាបទល្មើស ដោយមាត្រា II នៃច្បាប់លេខ១០ *របស់ក្រុមប្រឹក្សាគ្រប់គ្រង* ដែលត្រូវបានអនុម័តដោយអ្នកតំណាងសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សាធារណរដ្ឋបារាំង និងសហភាពសូវៀត"[៦០៥]។

៣២៤. ស្រដៀងគ្នានេះដែរ នៅក្នុង*សវនាការលើរឿងក្តី* Wilhelm Von Leeb *និងមនុស្សដប់បីនាក់ផ្សេងទៀត* ("រឿងក្តី*មេបញ្ជាការជាន់ខ្ពស់*") ចុងចោទ ដែលជាឧត្តមសេនីយ៍ជាន់ខ្ពស់ ១៤ នាក់ នៃពួក *Wehrmacht* អាល្លឺម៉ង់ និងអតីតសមាជិកមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពណាហ្ស៊ី ត្រូវបានផ្តន្ទាទោស ទាក់ទិននឹងការចូលរួមរបស់អ្នកទាំងនោះ *ក្នុងចំណោមប្រការផ្សេងទៀត* ទៅក្នុងការចាប់ខ្លួន និងការដាក់ក្នុងមន្ទីរឃុំឃាំងប្រជាជនស៊ីវិល ដែលបានធ្វើឡើងដោយកងទ័ពអាល្លឺម៉ង់ នៅក្នុងតំបន់ដែលត្រួតត្រាដោយពួកណាហ្ស៊ីក្នុងអំឡុងសម័យសង្គ្រាម។ ក្នុងការអនុវត្តតាមក្រឹត្យ Night and Fog Decree របស់ហ៊ីត្លែរ "លើកលែងអ្នកដែលនឹងត្រូវទទួលទោសប្រហារជីវិត មនុស្សដែលប្រព្រឹត្តបទល្មើសប្រឆាំងនឹងរបប Reich ឬកងទ័ពអាល្លឺម៉ង់នៅក្នុងតំបន់ដែលត្រួតត្រាដោយពួកណាហ្ស៊ី *នឹងត្រូវនាំខ្លួនដោយសម្ងាត់* ទៅប្រទេសអាល្លឺម៉ង់ និងបញ្ជូនទៅឱ្យកងកម្លាំង SIPO [Sicherheitspolizei (ប៉ូលីសសម្ងាត់)] និង កងកម្លាំង SD [Sicherheitsdienst (ក្រុមភ្នាក់ងារសម្ងាត់)] ដើម្បីធ្វើការជំនុំជម្រះទោស និងផ្តន្ទាទោសនៅប្រទេសអាល្លឺម៉ង់"[៦០៦]។ សាលក្រមបានអះអាងថា កងកម្លាំងប៉ូលីសសម្ងាត់ជាអ្នកជួយនាំមនុស្សដែលត្រូវគេចាប់ខ្លួនទៅជំរំប្រមូលផ្តុំ ដែលដំបូងត្រូវបានគេប្រើប្រាស់ជាកន្លែង *"ឃុំឃាំងមនុស្សដោយពុំមានការជំនុំជម្រះ* ចំពោះអ្នកដែលគេចាត់ទុកថាប្រឆាំងនឹងរដ្ឋាភិបាល ឬអ្នកដែលអាជ្ញាធរអាល្លឺម៉ង់ស្អប់ខ្ពើម" ហើយបន្ទាប់មកជំរំប្រមូលផ្តុំនេះត្រូវបានគេយកទៅប្រើប្រាស់ នៅក្នុងតំបន់ដែលត្រួតត្រាដោយពួកណាហ្ស៊ី ដើម្បីបំផ្លាញក្រុមប្រឆាំងទាំងអស់[៦០៧]។ ចុងចោទត្រូវបានចោទប្រកាន់ និងបានរកឃើញថាមានពិរុទ្ធភាពពីបទ "ដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានមូលហេតុ" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមបទចោទ

---

[៦០៥] រឿងក្តី *ចាប់ពង្រត់* ទំព័រ១២៣៤។

[៦០៦] *ការជំនុំជម្រះទោស Wilhelm Von Leeb និងមនុស្ស១៣នាក់ដទៃទៀត* ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៤៨ បោះពុម្ពជាថ្មីនៅក្នុង *NMT Trials*, Vols X – XI ("រឿងក្តី *មេបញ្ជាការជាន់ខ្ពស់*") ត្រង់ទំព័រ៤៨៦-៤៨៧ ដោយដកស្រង់ចេញពីសាលក្រមតុលាការ IMT ដែលត្រូវបានគាំទ្រនៅទំព័រ៥០១ (គូសបញ្ជាក់បន្ថែម)។

[៦០៧] រឿងក្តី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ៤៩៨ ដកស្រង់ចេញពីសាលក្រមតុលាការ IMT ដែលត្រូវបានគាំទ្រនៅទំព័រ៥០១ (គូសបញ្ជាក់បន្ថែម)។

ទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានចំណងជា "ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិល"[៦០៨]។

៣២៥. នៅក្នុង *រឿងក្ដី សហរដ្ឋអាមេរិក តទល់នឹង Greifelt និងអ្នកដទៃទៀត* ("រឿងក្ដី *RuSHA*") ចុងចោទត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោស[៦០៩] ពីបទដាក់ក្នុងមន្ទីរឃុំឃាំង ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមបទចោទទី១ ដូចតទៅ៖

> "១. ចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៣៩ ដល់ខែ មេសា ឆ្នាំ ១៩៤៥ រាល់ចុងចោទទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់នៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ដែលក្នុងនោះពួកគេជាចារី អ្នកសមគំនិត ដែលបានបញ្ជា បានជំរុញ បានចូលរួមព្រមព្រៀងជាមួយ បានជាប់ទាក់ទងទៅនឹងផែនការ និងការចូលរួមជាក្រុម និងជាសមាជិកអង្គការ ឬក្រុមដែលពាក់ព័ន្ធនឹង៖ អំពើឃោរឃៅ និងបទល្មើសនានា រួមទាំងតែមិនកំណត់ត្រឹមតែមនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ ការធ្វើឲ្យទៅជាទាសករ ការនិរទេស *ការដាក់ក្នុងមន្ទីរឃុំឃាំង* ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ ពូជសាសន៍ សាសនា និងអំពើអមនុស្សធម៌ និងឧក្រិដ្ឋដទៃទៀត ប្រឆាំងនឹងប្រជាជនស៊ីវិល រួមទាំងជនជាតិអាល្លឺម៉ង់ និងជនជាតិនៃប្រទេសដទៃទៀតផង និងប្រឆាំងនឹងអ្នកទោសសង្គ្រាមផង"។ (គូសបញ្ជាក់បន្ថែម)

៣២៦. ចុងចោទខ្លះទៀតក៏ត្រូវបានជំនុំជម្រះផងដែរពីអំពើនានា ដែលចាត់ទុកថាជាការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់នៅតុលាការយោធាអន្តរជាតិ (IMT)។ ទោះបី ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់មិនត្រូវបានរៀបរាប់ជាក់លាក់ ជាបទល្មើសនៅក្នុងបទចោទនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ តែវាជាផ្នែកនៃមូលដ្ឋានដែលចុងចោទត្រូវបានផ្ដន្ទាទោស ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដែលគួរឲ្យកត់សម្គាល់នោះគឺនៅក្នុងបរិបទជំរំប្រមូលផ្ដុំ ក្នុងគោលបំណងដើម្បី

---

[៦០៨] រឿងក្ដី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ២៧។ *សូមមើល* បទចោទទី៣៖ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សម្រាប់អំណះអំណាងពីអង្គហេតុរបស់រដ្ឋអាជ្ញា សូមមើលកថាខណ្ឌខាងក្រោម។

[៦០៩] *រឿងក្ដី សហរដ្ឋអាមេរិក តទល់នឹង Ulrich Greifelt និងអ្នកដទៃទៀត* ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៨ បោះពុម្ពជាថ្មីនៅក្នុង *NMT Trials*, Vols. IV – V ទំព័រ៥៩៩ ("រឿងក្ដី *RuSHA*")។ ចុងចោទ Greifelt (ទំព័រ១៥៥) Creutz (ទំព័រ១៥៥) Huebner (ទំព័រ១៥៨) Lorenz (ទំព័រ១៥៩) Brueckner (ទំព័រ១៦០) Hofmann (ទំព័រ១៦០) និង Hildebrandt (ទំព័រ១៦២) ត្រូវបានរកឃើញពិរុទ្ធភាពក្រោមបទចោទទី១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

“*ដាក់ក្នុងមន្ទីរឃុំឃាំងដោយពុំមានការជំនុំជម្រះ* ចំពោះជនគ្រប់រូបដែលប្រឆាំងនឹងរដ្ឋាភិបាល ឬអ្នកដែលអាជ្ញាធរអាល្លឺម៉ង់ស្អប់ខ្ពើម”[៦១០]។ ជាញឹកញយ សាលក្រមតុលាការ Nuremberg (IMT) បានភ្ជាប់ “ការដាក់ក្នុងមន្ទីរឃុំឃាំង” មានទំនាក់ទំនងទៅនឹងបទល្មើសនានាដូចជា “ការធ្វើឱ្យទៅជាទាសករ” និង “ការនិរទេស” នៅក្នុងបរិបទនៃជំរំប្រមូលផ្តុំ។ នៅពេលវិនិច្ឆ័យទោសទៅលើចុងចោទម្នាក់ៗពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តុលាការបានបង្ហាញអង្គហេតុនានាដាច់ដោយឡែកពីគ្នា ដែលបំបែកការចាប់ខ្លួនដោយបំពានពីការចាប់និរទេស និងការងារជាទាសករ[៦១១]។ Kaltenbrunner ជាប្រមុខ RSHA ត្រូវបានតុលាការ IMT ផ្តន្ទាទោសតាមបទចោទទី៤ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងចំណោមប្រការដទៃទៀត ដោយសារ

---

[៦១០] តុលាការយោធាអន្តរជាតិ (“IMT”) *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅតុលាការយោធាអន្តរជាតិ* “សាលក្រម” ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ បោះពុម្ពជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ* លេខាធិការដ្ឋាននៃតុលាការយោធាអន្តរជាតិ ឆ្នាំ ១៩៤៧ Vol. I ទំព័រ១៧១ (“សាលក្រមតុលាការ Nuremberg (IMT)”) “កិច្ចដំណើរការនីតិវិធី៖ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៤៦ - ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦” ទំព័រ៤៧៧ (គូសបញ្ជាក់បន្ថែម)។

[៦១១] *សូមមើល* សាលក្រមតុលាការ Nuremberg (IMT) Vol. 22។ សម្រាប់ Keitel តុលាការបានរកឃើញថា គាត់បានចុះហត្ថលេខាក្នុងក្រឹត្យមួយដែល “ឧក្រិដ្ឋកម្មនៃការតស៊ូប្រឆាំងកងទ័ពគ្រប់គ្រង នឹងត្រូវជំនុំជម្រះ និងផ្តន្ទាទោសប្រហារជីវិត បើពុំដូច្នោះទេ ត្រូវបញ្ជូនទៅឱ្យក្រុម Gestapo ដើម្បីដឹកយកទៅប្រទេសអាល្លឺម៉ង់” (ទំព័រ៥៣៥-៥៣៦)។ សម្រាប់ Rosenberg តុលាការបានរកឃើញថាគាត់ “បានដឹងពី [...] វិធីសាស្ត្រនៃ “ការជ្រើសរើសបុគ្គលិក” [...] គាត់បានផ្តល់ជាកូតានូវកម្លាំងពលកម្មរបស់គាត់ទៅឱ្យអ្នកគ្រប់គ្រងរដ្ឋបាល ដែលត្រូវបញ្ជូនទៅ Reich ដែលកូតាត្រូវតែបំពេញឱ្យបានតាមមធ្យោបាយចាំបាច់” (ទំព័រ៥៤១) (អង់គ្លេស)។ សម្រាប់ Frank តុលាការបានរកឃើញថា គាត់បាន “ប្រើប្រាស់កម្លាំងនគរបាលវាយឆ្មក់ ដើម្បីប្រមូលកម្លាំងពលកម្មតាមកូតា ដែលត្រូវនិរទេសទៅប្រទេសអាល្លឺម៉ង់” (ទំព័រ៥៤៣) (អង់គ្លេស)។ សម្រាប់ Frick តុលាការបានរកឃើញថា គាត់បានចុះហត្ថលេខាលើក្រឹត្យមួយ “ដែលដាក់ជនជាតិជ្វីហ្វ “នៅក្រៅច្បាប់” និងបានប្រគល់អ្នកទាំងនោះទៅឱ្យពួក Gestapo [ជាការដកហូតសេរីភាពអ្នកទាំងនោះដោយបំពាន]” (ទំព័រ៥៤៦) (អង់គ្លេស)។ សម្រាប់ Funk *សូមមើល* ទំព័រ៥៥២។ សម្រាប់ Sauckel តុលាការបានសង្កត់ធ្ងន់ពីលក្ខណៈមិនស្ម័គ្រចិត្តនៃ “ការជ្រើសរើសកម្លាំងពលកម្ម” (ទំព័រ៥៦៧) (អង់គ្លេស)។ សម្រាប់ Speer តុលាការបានរកឃើញថា “មានការអនុវត្តថា Speer ជាអ្នកបញ្ជូនទៅឱ្យ Sauckel នូវចំនួនកម្មករដែលត្រូវការ។ Sauckel ជាអ្នកចាំទទួលកម្មករ [...]។ Speer ដឹងនៅពេលគាត់កំណត់ចំនួនកម្មករដល់ Sauckel ថា ពួកគេនឹងត្រូវយកកម្លាំងកម្មករជាជនបរទេសមកប្រើប្រាស់ដោយការបង្ខិតបង្ខំ” (ទំព័រ៥៧៨) (អង់គ្លេស)។ សម្រាប់ Bormann តុលាការរកឃើញថាគាត់ “បានចុះហត្ថលេខាលើបទបញ្ជាឱ្យដកជនជាតិជ្វីហ្វពីការការពាររបស់តុលាការ ហើយដាក់ទៅក្រោមយុត្តាធិការដាច់ខាតរបស់ក្រុម Gestapo ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ Himmler [ជាការដកហូតសេរីភាពដោយបំពាន]” (ទំព័រ៥៨៦) (អង់គ្លេស)។

អំណាចរបស់គាត់ក្នុងការបញ្ជាឱ្យបញ្ជូនមនុស្ស និងការឃុំខ្លួនមនុស្សនៅក្នុងជំរំប្រមូលផ្តុំ[៦១២] និងការឃុំខ្លួនដោយមានការការពារ និងការដោះលែងចេញពីជំរំប្រមូលផ្តុំ[៦១៣]។

៣២៧. អាស្រ័យហេតុនេះ បើផ្អែកលើច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទីពីរ អង្គបុរេជំនុំជម្រះយល់ឃើញថា "ការដាក់ក្នុងមន្ទីរឃុំឃាំង" បានក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់អន្តរជាតិទៅហើយមកត្រឹមឆ្នាំ ១៩៧៥។

៣២៨. ដើម្បីឱ្យការវិភាគរបស់ខ្លួនបានពេញលេញ មុននឹងសម្រេចថាតើការចោទប្រកាន់ អៀង សារី ពីបទដាក់ក្នុងមន្ទីរឃុំឃាំង នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងរំលោភ ឬមិនរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះ គេត្រូវសម្រេចថាតើមានការគោរពដល់ធាតុផ្សំទាំងអស់នៃគោលការណ៍នីត្យានុកូលភាព ដូចដែលបានកំណត់ក្នុងការវិភាគរបស់ខ្លួននៅក្នុងមូលដ្ឋានទីបីខាងលើ ឬទេ។ ហេតុនេះ គេត្រូវពិនិត្យមើលថាតើ មាននិយមន័យគ្រប់គ្រាន់ឬទេចំពោះបទល្មើស "ការដាក់ក្នុងមន្ទីរឃុំឃាំង" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែល អៀង សារី អាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាជាបទឧក្រិដ្ឋ ដែលគាត់នឹងត្រូវជំនុំជម្រះទោសពីបទឧក្រិដ្ឋនេះ។

៣២៩. នៅពេលយោងទៅដល់ "ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់" "ការដាក់ក្នុងមន្ទីរឃុំឃាំងមិនស្របច្បាប់" "ការដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានការជំនុំជម្រះ" "ការដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានមូលហេតុ" យុត្តិសាស្ត្ររបស់តុលាការនានានៅក្រោយសង្គ្រាមលោកលើកទីពីរយោងទៅដល់ការដកហូតសេរីភាពរាងកាយ ដោយមិនស្របច្បាប់ ពោលគឺតាមទំនើងចិត្ត។

៣៣០. ស្របនឹងយុត្តិសាស្ត្រនេះដែរ លិខិតុបករណ៍នានាផ្នែកសិទ្ធិមនុស្សដែលត្រូវបានអនុម័តក្រោយសង្គ្រាមលោកលើកទីពីរ ទាំងនៅកម្រិតអន្តរជាតិ និងនៅថ្នាក់តំបន់ បានការពារសិទ្ធិបុគ្គលមិនដកហូតសេរីភាពរបស់ខ្លួនតាមទំនើងចិត្ត ដោយបញ្ជាក់ជាថ្មីថា សិទ្ធិក្នុងការមានសេរីភាពដែលមិន

[៦១២] សាលក្រមតុលាការ Nuremberg (IMT) Vol. 22 ទំព័រ៥៣៧ (អង់គ្លេស)។

[៦១៣] សាលក្រមតុលាការ Nuremberg (IMT) Vol. I ទំព័រ២៩១-២៩៣ (អង់គ្លេស)។

“ដាច់ខាត” អាចត្រូវបានកំហិតតាមតែតាមរយៈ “នីតិវិធីដែលបង្កើតដោយច្បាប់” ប៉ុណ្ណោះ[៦១៤]។ ការពិត លិខិតុបករណ៍អន្តរជាតិដែលត្រូវបានអនុម័តមុនឆ្នាំ ១៩៧៥ រួមមាន មាត្រា៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (ឆ្នាំ ១៩៤៨) បានចែងថា គ្មានជនណាម្នាក់ត្រូវបាន*ចាប់ខ្លួន ឃុំខ្លួន និរទេសខ្លួន ដោយបំពានបានឡើយ* មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ ១៩៦៦) ក៏បានតម្រូវស្រដៀងគ្នាដែរគឺថា គ្មានជនណាម្នាក់ត្រូវ*ចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ*។ មាត្រា II នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ (ឆ្នាំ ១៩៧៣) ដោយបានចែងថា “*ការចាប់ខ្លួនដោយបំពាន និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់* ចំពោះសមាជិកក្រុមជាតិពន្ធុណាមួយ ឬច្រើន” ជាអំពើដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍។ បទប្បញ្ញត្តិស្រដៀងគ្នានេះក៏មានចែងនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សនៅថ្នាក់តំបន់ផងដែរ[៦១៥]។

៣៣១. ទោះបីការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់មិនត្រូវបានកំណត់ជាបទល្មើសក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា លិខិតុបករណ៍ដែលអនុម័តដោយរដ្ឋភាគច្រើន ទាំងមុនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក រួមទាំងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរបង្ហាញថា ជនជាប់ចោទអាចដឹងថាមានច្បាប់ចែង និងដឹងថាអំពើរបស់ខ្លួនចំពោះការដាក់ក្នុងមន្ទីរឃុំឃាំងដោយបំពានគឺជាបទឧក្រិដ្ឋ និងអាចត្រូវទទួលខុសត្រូវបទឧក្រិដ្ឋនេះ។

៣៣២. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បទល្មើសដាក់ក្នុងមន្ទីរឃុំឃាំង គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រឹមតែមាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប៉ុណ្ណោះទេ តែអង្គបុរេជំនុំជម្រះយល់ឃើញថា សញ្ញាណនៃការដាក់ក្នុងមន្ទីរឃុំឃាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានន័យគ្រប់គ្រាន់ថា “ត្រូវបានដឹងជាទូទៅ”ដែលភ្ជាប់ជាមួយលក្ខណៈគួរឱ្យរន្ធត់នៃឧក្រិដ្ឋកម្ម

---

[៦១៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Knojelac* សំណុំរឿងលេខ IT-97-25-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ១០៩។

[៦១៥] ECHR (ឆ្នាំ ១៩៥០) បានចែងនៅក្នុងមាត្រា៥ ពីសិទ្ធិមានសេរីភាព និងសន្តិសុខ និងបានអះអាងថា គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួនបានទេ លើកលែងតែក្នុងករណីពិសេស ដូចមានចែងក្នុងអនុសញ្ញានេះ។ អនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស (ឆ្នាំ ១៩៦៩) (“ACHR”) បានចែងនៅក្នុងមាត្រា៧ ថា “គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពរាងកាយបានទេ” លើកលែងតែក្នុងករណីមួយចំនួន ហើយថា “គ្មានជនណាម្នាក់ក្លាយជាកម្មវត្ថុនៃការចាប់ខ្លួន ឬដាក់ក្នុងមន្ទីរឃុំឃាំងដោយបំពានបានទេ”។

នេះ ជាពិសេសនៅពេលប្រព្រឹត្តជាលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ដែលមិនអាចនិយាយថា ជនជាប់ចោទមិនបានដឹងពីលក្ខណៈឧក្រិដ្ឋនៃអំពើនេះ ឬថាមិនបានដឹងពីការការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើបែបនេះទេ។ ហេតុនេះ ជនជាប់ចោទអាចប្រមើលមើលឃើញ និងដឹងបានគ្រប់គ្រាន់ថាខ្លួនអាចនឹងត្រូវទទួលខុសត្រូវបទឧក្រិដ្ឋ ចំពោះការដាក់ក្នុងមន្ទីរឃុំឃាំងតាមអំពើចិត្តបែបនេះ ទៅលើប្រជាពលរដ្ឋកម្ពុជា ឬប្រជាពលរដ្ឋដទៃទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធបែបនេះ។

៣៣៣. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន បានសម្រេចត្រឹមត្រូវក្នុងការចោទប្រកាន់លើជនជាប់ចោទ ពីបទដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាប្រភេទមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដូច្នេះ អង្គបុរេជំនុំជម្រះច្រានចោលមូលដ្ឋានរងនេះ នៃមូលដ្ឋានទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍។

**<u>iii) មូលដ្ឋានរងទី១១ (ការធ្វើទារុណកម្ម)៖</u>**

<u>សារណានានា៖</u>

៣៣៤. សហមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍ និងជាថ្មីម្តងទៀតនៅក្នុងសារណាតបរបស់ខ្លួន ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាថា សហចៅក្រមស៊ើបអង្កេត "បានភ័ន្តច្រឡំដោយយល់ឃើញថា ការធ្វើទារុណកម្មគឺជាអំពើមួយត្រូវបានរៀបរាប់ ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដោយសារអំពើនេះមិនត្រូវបានរាប់បញ្ចូលឲ្យបានច្បាស់លាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *នៅក្នុងចំណោម* ធម្មនុញ្ញ Nuremberg ធម្មនុញ្ញទីក្រុងតូក្យូ ឬគោលការណ៍ Nuremberg ដែលត្រូវបានចងក្រងនោះទេ[៦១៦]។

---

[៦១៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២០៨។ សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៩៦។

៣៣៥. សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍នៅក្នុងចម្លើយតបរួមរបស់ខ្លួនថា ការធ្វើទារុណកម្មជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ[៦១៧] ដោយផ្អែកលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១[៦១៨] សេចក្ដីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៧៥ ស្ដីពីការធ្វើទារុណកម្ម[៦១៩] អនុសញ្ញាឆ្នាំ ១៩៨៤ ប្រឆាំងទារុណកម្ម[៦២០] យុត្តិសាស្ត្ររបស់តុលាការ ICTY[៦២១] និងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[៦២២]។ នៅក្នុងសារណារួមរបស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដល់ការសន្និដ្ឋានជាក់លាក់ទៅលើបញ្ហានៃការធ្វើទារុណកម្មទេ តែពាក្យពេចន៍ទូទៅដែលគេបានប្រើដើម្បីបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុម័តបញ្ចូលទៅក្នុងមាត្រា៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ស្របទៅនឹងពាក្យពេចន៍ដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

៣៣៦. នៅក្នុងសារណាតបរបស់ខ្លួនទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា អៀង សារី បានអះអាងថា សេចក្ដីប្រកាសស្ដីពីអំពើទារុណកម្ម "ពុំមែនជាសេចក្ដីប្រកាសនៃច្បាប់ទំនៀមទម្លាប់

---

[៦១៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៨៩។

[៦១៨] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៥២-៣៥៨។

[៦១៩] *សេចក្ដីប្រកាសស្ដីពីការការពារជនគ្រប់រូបមិនឱ្យទទួលរងនូវការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តដ៏ឃោរឃៅ បន្ទាបបន្ថោក ឬអមនុស្សធម៌ផ្សេងៗទៀត* សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 3452 (XXX), U.N. GAOR, 30th Sess., 2433rd Pl. Mtg. ឯកសារលេខ A/10408 ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧៥។

[៦២០] *អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្មយ៉ាងព្រៃផ្សៃ អមនុស្សធម៌ ឬបន្ទាបបន្ថោកផ្សេងៗទៀត* (អនុម័តនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧) សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 39/46, U.N. GAOR, 39th Sess., 93rd Pl. Mtg. ឯកសារលេខ A/39/708 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ("អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម")។

[៦២១] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Delalić សំណុំរឿងលេខ IT-96-21-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ៤៥៩ ("រឿងក្ដី Čelebići")។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Furundžija សំណុំរឿងលេខ IT-95-17/1-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ១១១។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Furundžija សំណុំរឿងលេខ IT-95-17/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ១៥១-១៥៣។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Krnojelac សំណុំរឿងលេខ IT-97-25-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ១៨២។

[៦២២] ក្រមព្រហ្មទណ្ឌ (ឆ្នាំ ១៩៥៦) មាត្រា៥០០។



អង្គជំនុំជម្រះ * PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

00661704



អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ" ហើយថា សេចក្តីប្រកាសនេះពុំមានអត្ថិភាពឡើយ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៦២៣]។

<u>ការពិភាក្សា៖</u>

៣៣៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ អៀង សារី ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយចាត់ទុកការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន[៦២៤]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានយោងទៅកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយ ដូចខាងក្រោម៖

> តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចតទៅ នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល [...] ការធ្វើទារុណកម្ម [...]

៣៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ច្បាប់ អ.វ.ត.ក ចែងជាពិសេសនៅក្នុងមាត្រា៥ ថា "ការធ្វើទារុណកម្ម" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា សហមេធាវីការពារក្តីបានជំទាស់ថា ធម្មនុញ្ញ Nuremberg (IMT) និងគោលការណ៍ Nuremberg មិនបានចាត់ទុកការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៣៣៩. ក្នុងការគាំទ្រដល់អំណះអំណាងរបស់ខ្លួននៅក្នុងកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ប្រភពឯកសារនានាដូចជា៖

> សាលក្រម សំណុំរឿងលេខ៖០០១/១៨ កក្កដា ២០០៧/អវតក/អជសង កថាខណ្ឌ៣៥២-៣៥៧, Karl Brandt និងអ្នកដទៃទៀត សវនាការតាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [ឆ្នាំ ១៩៤៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ Vol. I ទំព័រ៧, សេចក្តីណែនាំចំពោះអ្នកគ្រប់គ្រងកងទ័ពសហរដ្ឋអាមេរិកនៅសមរភូមិ (Lieber Code) [ឆ្នាំ ១៨៦៣], មាត្រា១៦ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [ឆ្នាំ ១៩៤៥] មាត្រា II(១)(គ), សេចក្តីប្រកាសស្តីពីការ

---

[៦២៣] សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៩៧។

[៦២៤] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១៣។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ការពារបុគ្គលគ្រប់រូបមិនឲ្យទទួលរងនូវការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ បន្ថាបបន្ថោកផ្សេងៗទៀត សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 3452 (XXX) ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧៥, អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម (ដែលអនុញ្ញាតឲ្យចុះហត្ថលេខាចូលជាភាគីនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤) 1465 UNTS 85, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [ឆ្នាំ ១៩៦៦] មាត្រា ៧[៦២៥]។

៣៤០. ទាក់ទិននឹងប្រភពឯកសារ ដែលសហចៅក្រមស៊ើបអង្កេតបានលើកយកមកសំអាងទាំងនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានដកស្រង់នៅក្នុងផ្នែកនេះនៃសាលក្រមរបស់ខ្លួន លើសំណុំរឿងលេខ០០១ ត្រូវបានសំដៅពីនិយមន័យនៃការធ្វើទារុណកម្មនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ តែមិនបានសម្រេច តាមឆន្ទានុសិទ្ធិរបស់ខ្លួន ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមាន ឬមិនមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ទេ[៦២៦]។

៣៤១. ទីពីរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការហាមឃាត់ការធ្វើទារុណកម្មកើតឡើងជាច្រើននៅក្នុងទិដ្ឋភាពនៃច្បាប់អន្តរជាតិ ហើយគេត្រូវយកចិត្តទុកដាក់ដើម្បីបញ្ចៀសពីការយកការទទួលខុសត្រូវចំពោះការធ្វើទារុណកម្មតាមច្បាប់សិទ្ធិមនុស្ស ឬឧក្រិដ្ឋកម្មសង្គ្រាម ទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមវិធីយកសទិសភាពតែមួយមុខ។ ទោះជាយ៉ាងណាក្តី ការលើកឡើងមកនិយាយសាជាថ្មីពីការធ្វើទារុណកម្ម ក្លាយជាប្រភពមួយដែលត្រួសត្រាយផ្លូវ និងបង្ហាញថា ជនជាប់ជាប់អាចប្រមើលមើលដឹងថាអំពើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ និងដឹងថាមានច្បាប់ចែងថា ការប្រព្រឹត្តដែលគេហាមឃាត់ទាំងនេះ អាចនឹងនាំឲ្យមានការជំនុំជម្រះទោសចំពោះរូបគាត់ពីបទព្រហ្មទណ្ឌនេះ។

៣៤២. ការធ្វើទារុណកម្មត្រូវបានហាមឃាត់ ជាយូរមកហើយ ដោយសារវាជាការរំលោភមួយដល់ច្បាប់សង្គ្រាម។ នៅឆ្នាំ១៨៦៣ មាត្រា១៦ នៃ Lieber Code បានចែងថា៖ "ភាពចាំបាច់ផ្នែកយោធា មិន

---

[៦២៥] ដីកាដំណោះស្រាយ ជើងទំព័រលេខ៥១៩១។

[៦២៦] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៥៣។

បានទទួលស្គាល់ឱ្យមានភាពសាហាវឃោរឃៅទេ ពោលគឺថា *ជាការធ្វើទុក្ខធ្វើបាប គ្រាន់តែដើម្បីធ្វើទុក្ខធ្វើបាប ឬគ្រាន់តែដើម្បីជាការសងសឹក* មិនចាំបាច់រហូតដល់មានពិការ ឬរងរបួសទេ លើកលែងតែក្នុងពេលប្រយុទ្ធគ្នា ហើយក៏មិនមែនជា*ការធ្វើទារុណកម្ម ដើម្បីឱ្យសារភាពដែរ*។ ក្រោយមក ការហាមឃាត់មិនឱ្យធ្វើទារុណកម្មមានចែងក្នុងមាត្រា៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ។ គណៈកម្មការកាកបាទក្រហមអន្តរជាតិ ("ICRC") បានអះអាងនៅក្នុងយោបល់របស់ខ្លួនទៅលើមាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV ថា តាមច្បាប់សង្គ្រាម ការធ្វើទារុណកម្ម "ត្រូវបានគេយល់ថាជាការធ្វើទុក្ខធ្វើបាបជនណាម្នាក់ ដើម្បីឱ្យជននោះ ឬជនណាម្នាក់ផ្សេងទៀតផ្តល់ចម្លើយសារភាព ឬផ្តល់ព័ត៌មាន [...]។ វាមិនត្រឹមតែជាការវាយប្រហារធម្មតាទៅលើបូរណភាពរាងកាយ ឬផ្លូវចិត្តរបស់ជនណាម្នាក់ទេ។ អ្វីដែលសំខាន់នោះគឺថា មិនមែនជាការឈឺចាប់នោះទេ តែគឺគោលបំណងដែលនៅពីក្រោយនៃការធ្វើទុក្ខធ្វើបាបនោះតែម្តង"[៦២៧]។ ទោះបីគេមិនបានដាក់ឈ្មោះជាក់លាក់ថាជាការធ្វើទារុណកម្មក៏ដោយ តែការធ្វើទុក្ខធ្វើបាប ដើម្បីសងសឹកក៏ត្រូវបានហាមឃាត់ដោយក្រម Lieber ដែរ ដូចដែលមាននៅក្នុងអត្ថបទសម្រង់ខាងលើ។ ការពិត ក្រោយសង្គ្រាមលោកលើកទីពីរមក ការធ្វើទារុណកម្មត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មសង្គ្រាម។

៣៤៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ ដូចដែលសហមេធាវីការពារក្តីបានជំទាស់រួចមកហើយគឺថា ការធ្វើទារុណកម្មមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងធម្មនុញ្ញ Nuremberg (IMT) ឬនៅក្នុងធម្មនុញ្ញតទីក្រុងតូក្យូ (IMTFE) ទេ។ តែទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះកត់សម្គាល់ ដូចដែលដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយរួចមកហើយគឺថា ការធ្វើទារុណកម្មមានចែងនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[៦២៨]។ ដូចគ្នានឹងការដាក់ក្នុងមន្ទីរឃុំឃាំងផងដែរគឺថា NMTs បានផ្តន្ទាទោសចុងចោទពីការធ្វើទារុណកម្ម ជាឧក្រិដ្ឋកម្មប្រឆាំង

---

៦២៧ Jean Pictet (ed.), *បទអត្ថាធិប្បាយ: អនុសញ្ញាហ្សឺណែវ IV ទាក់ទងទៅនឹងការការពារពលរដ្ឋស៊ីវិលក្នុងពេលសង្គ្រាម* ICRC ឆ្នាំ ១៩៥៨ ទំព័រ៥៩៨ (អង់គ្លេស)។

៦២៨ *ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* មាត្រា២(១)(គ)៖ "អំពើឃោរឃៅ និងបទល្មើសនានា រួមបញ្ចូលតែមិនកំណត់ត្រឹមតែ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង *ការធ្វើទារុណកម្ម* ការរំលោភលើផ្លូវភេទ ឬ អំពើអមនុស្សធម៌ដទៃទៀត [...]" (គូសបញ្ជាក់បន្ថែម)។

មនុស្សជាតិ ដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ជាពិសេសនៅក្នុងបរិបទនៃការសួរយកចម្លើយ និងការប្រព្រឹត្តកម្មឃោរឃៅនៅក្នុងជំរំប្រមូលផ្តុំ រួមទាំងការពិសោធន៍វេជ្ជសាស្ត្រផងដែរ[៦២៩]។

៣៤៤. ឧទាហរណ៍ នៅក្នុងរឿងក្តី *មេបញ្ជាការជាន់ខ្ពស់* ដែលបានពិភាក្សាខាងលើ ចុងចោទត្រូវបានជំនុំជម្រះទោស ហើយមួយចំនួនត្រូវបានផ្តន្ទាទោស ចំពោះតួនាទីរបស់ពួកគេនៅក្នុងការធ្វើទារុណកម្មទៅលើអ្នកដែលពួក Gestapo បានសួរចម្លើយ[៦៣០] និង/ឬអ្នកដែលត្រូវបានឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំរួមមានជនជាតិជ្វីហ្វ សូវៀត ជីបស៊ី (gypsies) និង ប៉ូឡូញ ដែលត្រូវបានគេចាត់ទុកថាជា "ពួកមានឋានៈទាបនៅក្នុងសង្គម" និងអ្នកដែល "បានទទួលអ្វីដែលពួកហ៊ីត្លែរនិយមហៅថា "ប្រព្រឹត្តកម្មពិសេស" ឬ "ការជម្រះបញ្ជី" ឬ "ដំណោះស្រាយចុងក្រោយ"[៦៣១]។ បើតាមបទចោទទី ៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុងចោទត្រូវបានចោទប្រកាន់ជាសំខាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅពេលដែលពួក Gestapo សួរចម្លើយ អំពើទារុណកម្មមួយចំនួននាំមាន*ការឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ* និងត្រូវបានប្រព្រឹត្ត*ដោយមានគោលបំណងដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព*។ ទាក់ទិននឹងទិដ្ឋភាពនេះ សាលក្រមនោះសម្រេចថា៖

> "នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៤២ តាមរយៈ Mueller ដែលជាប្រធាន Gestapo ប្រមុខ SIPO និង SD ចេញបទបញ្ជាឲ្យប្រើប្រាស់វិធីសាស្ត្រ "កម្រិតទីបី" នៃការសួរចម្លើយ នៅពេលដែលការស៊ើបអង្កេតបឋមបានបង្ហាញថា មនុស្សនោះអាចផ្តល់ព័ត៌មានស្តីពីបញ្ហាសំខាន់ៗបាន ដូចជា សកម្មភាពបង្កវិទ្ធង្សនា ទោះបីវាមិនមានគោលបំណងយកចម្លើយសារភាព ទាក់ទិននឹងបទល្មើសរបស់អ្នកជាប់ឃុំឃាំងនោះក៏ដោយ។
> បទបញ្ជានេះចែងថា៖
> [...] ទៅតាមកាលៈទេសៈ កម្រិតទីបីអាចរួមមានក្នុងចំណោមវិធីសាស្ត្រដទៃទៀតនៃការផ្តល់ចំណីអាហារធម្មតាបំផុត (នំប៉័ង និងទឹក) កន្លែងដេករឹង បន្ទប់ងងឹត ការមិនឲ្យដេក ការ

[៦២៩] បន្ថែមទៅលើករណីនានាដែលបានយោងខាងក្រោម *សូមមើល ក្នុងចំណោមនោះរួមមាន៖ រឿងក្តី United states តទល់នឹង Carl Krauch និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៤៨ បោះពុម្ពជាថ្មីនៅក្នុង *NMT Trials,* Vols VII-VIII ទំព័រ១ ("រឿងក្តី *I. G. Farben*")។ ចុងចោទត្រូវបានជំនុំជម្រះទោសក្រោមបទចោទទី៣ ដែលក្នុងចំណោមនោះរួមមាន ការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (Vol. VII ទំព័រ៥០-៥១) (អង់គ្លេស)។ សូមមើលផងដែរ Vol. VII ទំព័រ១១ (អង់គ្លេស)និង Vol. VIII ទំព័រ១១៦៧ (អង់គ្លេស)។ Krauch និង Meer ត្រូវបានរកឃើញពិរុទ្ធភាពតាមបទចោទទី៣ (Vol. VIII ទំព័រ១១៩០-១១៩១) (អង់គ្លេស)។

[៦៣០] រឿងក្តី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ៤៩០-៤៩៧ (អង់គ្លេស)។

[៦៣១] រឿងក្តី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ៤៩៥ (អង់គ្លេស)។



អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

ហ្វឹកហាត់អស់កម្លាំងពីខ្លួន និងមានការវាយនឹងដំបងផង (បើការវាយនោះលើសពីម្ភៃដំបង ត្រូវពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត)"[៦៣២]។

សាលក្រមនេះបានយោងបន្ថែមទៀតទៅលើបទបញ្ជាឱ្យប្រើប្រាស់ "វិធានការធ្ងន់ធ្ងរបំផុត" ដោយសារ "បទពិសោធន៍បង្ហាញថា មានតែការប្រើប្រាស់វិធីសាស្ត្រឃោរឃៅបំផុតទេ ទើបធ្វើឱ្យពួកសមាសភាពជាប់សង្ស័យនិយាយចេញមក។ វិធីសាស្ត្រទាំងនេះរួមមានការវាយគូថដដែលៗ ដោយទុយោកៅស៊ូ (rubber tubings) (ចំពោះស្ត្រី) ឬរំពាត់ធ្វើពីស្បែកគោ ឬដំបងក្លគោធ្វើពីកៅស៊ូ (rubber trancheons) (ចំពោះបុរស)"[៦៣៣]។

៣៤៥. នៅក្នុងរឿងក្ដី *ចាប់ពង្រត់* ចុងចោទត្រូវបានចោទប្រកាន់ ហើយមួយចំនួនត្រូវបានផ្ដន្ទាទោស[៦៣៤] ពីបទធ្វើទារុណកម្ម ជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមបទចោទទី១ និងទី៤ នៅក្នុងបរិបទនៃ "ការសងសឹក" ពោលគឺភ្ជាប់ជាមួយ *ការដាក់ទណ្ឌកម្ម*។ នៅក្នុងផ្នែករបស់វាដែលពាក់ព័ន្ធ បទចោទទី១ អះអាងថា "ជនមិនមែនអ្នកប្រយុទ្ធរាប់ពាន់នាក់ ត្រូវបានចាត់ទុកដោយបំពានថាជា "ពួកប្រឆាំង" "ពួកកុម្មុយនីស្ត" "ជនសង្ស័យថាជាកុម្មុយនីស្ត" "ជនសង្ស័យថាជាចោរព្រៃ" ត្រូវបានបំភិតបំភ័យ *ធ្វើទារុណកម្ម* និងសម្លាប់ ដោយការសងសឹក" សម្រាប់ការវាយប្រហារតាមផ្លូវច្បាប់ប្រឆាំងនឹងពួកយោធាអាល្លឺម៉ង់[៦៣៥]។ បទចោទទី៤ ត្រូវបានលើកយកមកពិភាក្សាខាងលើក្នុងផ្នែក ការដាក់ក្នុងមន្ទីរឃុំឃាំង[៦៣៦]។

៣៤៦. នៅក្នុងរឿងក្ដី *សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកដទៃទៀត* ("រឿងក្ដី *Einsatzgruppen*") ចុងចោទត្រូវបានចោទប្រកាន់តាមបទចោទទី១ នៃដីកាដំណោះស្រាយ និងត្រូវបានផ្ដន្ទាទោស ក្នុងចំណោមបទល្មើសដទៃទៀត ពីបទធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាផ្នែកមួយនៃកម្មវិធីប្រល័យពូជសាសន៍ជាប្រព័ន្ធ ក្នុងគោលបំណងបំផ្លិចបំផ្លាញ

---

[៦៣២] រឿងក្ដី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ៤៩៧ (អង់គ្លេស)។

[៦៣៣] រឿងក្ដី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ៥៩០-៥៩២ (អង់គ្លេស)។

[៦៣៤] រឿងក្ដី *ចាប់ពង្រត់*។ List, von Leyser, Felmy និង Lanz ត្រូវបានរកឃើញពិរុទ្ធភាពតាមបទចោទទី១ (ទំព័រ១២៧៤, ១៣០៥, ១៣០៩ និង១៣១៣ តាមលំដាប់)។ Kuntze និង Rendulic ត្រូវបានរកឃើញពិរុទ្ធភាពតាមបទចោទទី១ និងទី៤ (ទំព័រ១២៨១ និង ១២៩៧ តាមលំដាប់)។

[៦៣៥] រឿងក្ដី *ចាប់ពង្រត់* ទំព័រ១២៣៣ (អង់គ្លេស)។

[៦៣៦] គួរយកចិត្តទុកដាក់ទៅលើទំព័រ១២៣៤ នៃសាលក្រម ត្រូវបានដកស្រង់នៅក្នុងផ្នែកស្ដីពីការដាក់ក្នុងមន្ទីរឃុំឃាំងខាងលើ។

ប្រទេសដទៃ និងក្រុមជាតិពន្ធ ដោយការសម្លាប់រង្គាលផ្តាច់ពូជ។ នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ការធ្វើទារុណកម្មត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺ៖

> "*បទចោទទី១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តីនេះចោទប្រកាន់ចុងចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។* មិនមានឧក្រិដ្ឋកម្មប្រឆាំងប្រទេសណាមួយជាក់លាក់ទេ មានតែប្រឆាំងមនុស្សជាតិ។
>
> មនុស្សជាតិគឺជាអធិបតេយ្យភាពដែលត្រូវបានបំពារបំពាន ហើយតុលាការជាអ្នកសម្រេចពីមូលហេតុនៃការបំពារបំពាននោះ។ នេះមិនមែនជាទស្សនៈថ្មីផ្នែកគុណធម៌ទេ តែវាជាការបង្កើតថ្មីនៅក្នុងវិស័យច្បាប់តែប៉ុណ្ណោះ។ ហេតុនេះ វាជាពន្លឺមួយសម្រាប់បំភ្លឺនៅទីងងឹត និងបរិយាកាសអន្ធការនៃវាលពិឃាតទៅលើមនុស្សស្លូតត្រង់។
>
> មនុស្សឃាត *ការធ្វើទារុណកម្ម* ការដាក់ជាទាសករ និង *ឧក្រិដ្ឋកម្មស្រដៀងគ្នាដែលពីមុនត្រូវបានអនុវត្តតែក្នុងបណ្តាប្រជាជាតិដែលពាក់ព័ន្ធ តែពេលនេះក្លាយជាបញ្ញត្តិរបស់ប្រជាជាតិរួមទាំងមូល។* ហេតុនេះ គ្មានការបែងចែកអំពើមនុស្សឃាត ថាជាអំពើស្រាល ឬធ្ងន់ទៀតហើយ ដោយសារទង្វើនេះត្រូវបានប្រព្រឹត្តឡើងប្រឆាំងជាតិសាសន៍ទាំងមូល មិនត្រឹមតែចំពោះមនុស្សម្នាក់ទេ"[៦៣៧]។

៣៤៧. នៅក្នុងរឿងក្តី *សហរដ្ឋអាមេរិក តទល់នឹង* Karl Brandt *និងអ្នកដទៃទៀត* ("រឿងក្តី*គ្រូពេទ្យ*") Karl Brandt និងអ្នកដទៃទៀតត្រូវបានផ្តន្ទាទោសពីបទចោទទី២ និងទី៣ ពីបទថាបានចូលរួមនៅក្នុង "ផែនការ និងក្រុមដែលពាក់ព័ន្ធនឹងការធ្វើពិសោធន៍វេជ្ជសាស្ត្រ ដែលបានប្រព្រឹត្តចំពោះជន

---

[៦៣៧] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង* *Otto Ohlendorf* *និងអ្នកដទៃទៀត* ចុះថ្ងៃទី ៨ និង ៩ ខែ មេសា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vol. IV ទំព័រ៣ ("រឿងក្តី *Einsatzgruppen*") ត្រង់ទំព័រ៤០៩ (អង់គ្លេស)។ សាលក្រមក៏បានសង្កត់ធ្ងន់ផងដែរថា "ទោះបីសវនាការត្រូវបានធ្វើឡើងតែចំពោះបញ្ហាមនុស្សឃាតក៏ដោយ ក៏ចុងចោទត្រូវបានចោទប្រកាន់ផងដែរនៅក្នុងបទចោទទី១ និងទី២ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម ដែលរាប់បញ្ចូលតែមិនកំណត់ត្រឹមតែ អំពើសាហាវយង់ឃ្នង ការធ្វើឱ្យទៅជាទាសករ ការនិរទេស *ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម* និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល។ ហេតុនេះ ប្រសិនបើរកឃើញពិរុទ្ធភាពមែន សេចក្តីសន្និដ្ឋានបែបនោះមិនបានពឹងផ្អែកទៅលើបទចោទពីការធ្វើមនុស្សឃាតតែមួយនោះទេ តែក៏ផ្អែកលើអំពើទាំងអស់ដែលបានប្រព្រឹត្តនៅក្នុងវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ដោយមិនបានអះអាងឱ្យបានច្បាស់លាស់នៅក្នុងការវិនិច្ឆ័យលើករណីនីមួយៗ ការដាក់ទោសគឺផ្អែកទៅលើកំណត់ហេតុទាំងមូល" (ទំព័រ៥១០) (អង់គ្លេស)។ Haensch (ទំព័រ៥៥៤-៥៥៥) (អង់គ្លេស) Redetzky (ទំព័រ៥៧៦) (អង់គ្លេស)និង Schubert (ទំព័រ៥៨៤) (អង់គ្លេស) ត្រូវបានរកឃើញពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * PRÉLIMINAIRE

ជាតិនានាមិនមែនជនជាតិអាល្លឺម៉ង់ ផ្ទុយពីឆន្ទៈនៃជនជាតិទាំងនោះ និងក្នុងអំពើឃោរឃៅដទៃទៀត ដែលក្នុងនោះ*បានប្រព្រឹត្ត* អំពើមនុស្សឃាត អំពើយង់ឃ្នង អំពើសាហាវឃោរឃៅ *ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត*"[៦៣៨]។

៣៤៨. ស្រដៀងគ្នានេះដែរ ការធ្វើទារុណកម្មក៏ត្រូវបានជំនុំជម្រះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងរឿងក្តី *Pohl* នៅក្នុងបរិបទនៃការធ្វើពិសោធន៍វេជ្ជសាស្ត្រ ដែលត្រូវបានប្រព្រឹត្តចំពោះអ្នកជាប់ឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំ។ ជាថ្មីម្តងទៀត ទោះបីសាលក្រមមិនបានបញ្ជាក់ច្បាស់លាស់ពីអ្វីដែលត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្មនោះ ផ្នែក"ការធ្វើពិសោធន៍វេជ្ជសាស្ត្រ" នៃសាលក្រមនេះបានបង្ហាញពីអង្គហេតុដែលបង្ហាញពីអំពើដែលនាំឱ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរថា៖

> "ជំរំប្រមូលផ្តុំពោរពេញទៅដោយមនុស្ស សម្រាប់ការធ្វើពិសោធន៍យ៉ាងសាហាវឃោរឃៅទាំងនេះ ហើយអ្នកជាប់ឃុំឃាំងជាច្រើននាក់ត្រូវបាន*នាំយកទៅធ្វើពិសោធន៍ផ្នែកវិទ្យាសាស្ត្រដែលចៀសមិនផុតពីការធ្វើទារុណកម្ម* ហើយមានករណីរាប់ពាន់ដែលបង្ហាញពីពិការភាព ការខូចខាតរូបរាងកាយ និងការស្លាប់បាត់បង់ជីវិត។ អ្នកជាប់ឃុំឃាំងត្រូវបានគេដាក់នៅក្នុងអាងដែលមានសម្ពាធខ្យល់ថយចុះ នៅលើរយៈកម្ពស់ខ្ពស់។ តារាងបញ្ជាក់កម្រិតនៃប្រតិកម្មដែលកើតចេញពីអំពើហិង្សាចំពោះអ្នកទោសទាំងនោះ ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ។ ព័ត៌មានក្នុងតារាង*បង្ហាញយ៉ាងច្បាស់អំពីការឈឺចាប់ និងការរងទុក្ខធ្ងន់ធ្ងរ*។ យូរៗម្តង តារាងនោះបញ្ចប់ដោយឃ្លាថា "អ្នកជាប់ឃុំឃាំងស្លាប់នៅម៉ោង ៩:១៨ នាទី"។ អ្នកជាប់ឃុំឃាំងដទៃទៀតត្រូវបានសម្រាតសម្លៀកបំពាក់ចេញ រួចដាក់ក្នុងទឹកត្រជាក់ខ្លាំងដែលមានសីតុណ្ហភាពត្រជាក់រហូតដល់កកជាច្រើនម៉ោង ដោយមានការជ្រមុជចូលក្នុងអាងទឹកកកទៀតផង។ ដូចអ្វីដែលគេបានរំពឹងទុកគឺថា អ្នកជាប់ឃុំឃាំងទាំងនោះត្រូវកករហូតដល់ស្លាប់។ អ្នកជាប់ឃុំឃាំងដទៃទៀតត្រូវបានបង្ខំឱ្យផឹកទឹកសមុទ្រ រហូតទាល់តែអ្នកទាំងនោះផឹកទាល់តែហាល់។ អ្នកជាប់ឃុំឃាំងត្រូវបានគេចាក់បញ្ចូលមេរោគជំងឺគ្រុនផ្តាសាយធំ អាសន្នរោគ គ្រុនចាញ់ គ្រុនពោះវៀន និងអុតស្វាយ ដែលគេបង្កើតឡើង ហើយអ្នកជាប់ឃុំឃាំងរាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិតដោយសារការចាក់បញ្ចូលមេរោគទាំងនោះ។ គេបានរះជើងអ្នកជាប់ឃុំឃាំង ហើយជើងក៏រលួយដោយសារក្លិនស្អុយ។ ឧស្ម័នពុល ឧស្ម័នរលាកផ្លូវដង្ហើម ឧស្ម័នជាតិហ្វូស្ស័រ និងជាតិស៊ុលហ្វ័រ ត្រូវបានគេប្រើចំពោះអ្នកជាប់ឃុំឃាំង ដើម្បីបញ្ជាក់ថា សារធាតុគីមីទាំងនេះមានគ្រោះថ្នាក់ និងជាញ៉ាក់ពុលអាចបណ្តាលឱ្យស្លាប់ ដែលមិនមែនត្រឹមតែជា

[៦៣៨] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Karl Brandt និងអ្នកដទៃទៀត* សំណុំរឿងលេខ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vols I-II ទំព័រ៣ ("រឿងក្តី *គ្រូពេទ្យ*") នៅ Vol. II ទំព័រ១៩៨ (អង់គ្លេស)។

របកគំហើញផ្នែកវិទ្យាសាស្ត្រនៅក្នុងរឿងប្រលោមលោកនោះទេ។ នេះជាផ្នែកមួយនៃរបបគំហើញដែលគួរឱ្យរន្ធត់។ ជាមធ្យោបាយមួយឆ្ពោះទៅកាន់ "ដំណោះស្រាយចុងក្រោយចំពោះបញ្ហាជនជាតិជ្វីហ្វ" មានការបង្កើតជាកម្មវិធីធ្វើឱ្យជនជាតិជ្វីហ្វទាំងមូលលែងមានកូន ហើយមានវិធីសាស្ត្រនានាជាច្រើនត្រូវបានយកមកប្រើ ដើម្បីឱ្យការធ្វើឱ្យលែងមានកូននេះអាចសម្រេចបាន ដោយជនរងគ្រោះមិនបានដឹងអ្វីទាំងអស់។ ក្រៅពីនោះការក្រៀវមនុស្សក៏ត្រូវបានយកមកប្រើ"[៦៣៩]។

៣៤៩. ការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ត្រូវយុត្តាធិការនៃតុលាការថ្នាក់ជាតិយកទៅជំនុំជម្រះដែរ។ ឧទាហរណ៍ Takashi Sakai ត្រូវបានផ្តន្ទាទោសដោយតុលាការយោធាឧក្រិដ្ឋកម្មសង្គ្រាមនៃក្រសួងការពារជាតិចិន ដែលស្ថិតនៅក្រុងណានគីង (Nanking) ពីបទធ្វើទារុណកម្មជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៦៤០] តាមបទប្បញ្ញត្តិនៃវិធានគ្រប់គ្រងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចិន ដែលបានចូលជាធរមាននាពេលជំនុំជម្រះក្តីនោះ។ អនុលោមតាមមាត្រា១ នៃវិធាននេះ ច្បាប់អន្តរជាតិជាប្រភពសំខាន់នៃច្បាប់សារធាតុសម្រាប់តុលាការឧក្រិដ្ឋកម្មសង្គ្រាមចិន។ ដោយយោងទៅតាមបទល្មើសប្រឆាំងជនស៊ីវិល និងសមាជិកកងទ័ព ដែលជនជាប់ចោទត្រូវបានរកឃើញពិរុទ្ធភាពនោះ តុលាការនេះបានសម្រេចថា៖

> "ក្នុងការញុះញង់ ឬអនុញ្ញាតឱ្យអ្នកក្រោមបង្គាប់សម្លាប់អ្នកទោសសង្គ្រាម ទាហានដែលរបួស គិលានុបដ្ឋាយិកា និងវេជ្ជបណ្ឌិតនៃអង្គការកាកបាទក្រហម និងជនផ្សេងទៀតដែលមិនមែនជាយុទ្ធជន និងការអនុញ្ញាតឱ្យប្រព្រឹត្តការរំលោភលើផ្លូវភេទ ការឆក់ប្លន់ ការនិរទេស ការធ្វើទារុណកម្ម និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ជននេះបានរំលោភដល់អនុសញ្ញាទីក្រុងឡាអេ ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩២៩។ អំពើល្មើសទាំងនេះជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[៦៤១]។

---

[៦៣៩] រឿងក្តី *Pohl* ទំព័រ៩៧១ (អង់គ្លេស) (គូសបញ្ជាក់បន្ថែម)។

[៦៤០] តុលាការយោធាឧក្រិដ្ឋកម្មសង្គ្រាមនៃក្រសួងការពារជាតិចិន *ការជំនុំជម្រះទោស Takashi Sakai* ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៤៦ រាយការណ៍នៅក្នុងគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ *របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម (Law Reports of Trials of War Criminals)* ទីក្រុងឡុងដ៍ Vol. XIV ឆ្នាំ ១៩៤៩ ទំព័រ១ (អង់គ្លេស) ("*ការជំនុំជម្រះទោស Takashi Sakai*")។

[៦៤១] *ការជំនុំជម្រះទោស Takashi Sakai* ទំព័រ៧ (អង់គ្លេស)។

៣៥០. នៅតុលាការ IMT ចុងចោទខ្លះក៏ត្រូវបានជំនុំជម្រះទោសពីអំពើនានាដែលចាត់ទុកថាជាការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។ ទោះបីការធ្វើទារុណកម្មមិនត្រូវបានរៀបរាប់ជាក់លាក់ថាជាបទឧក្រិដ្ឋមួយក្នុងបទចោទនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏វាជាផ្នែកមួយនៃមូលដ្ឋានដែលចុងចោទត្រូវបានផ្តន្ទាទោស ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ ជាពិសេសនៅក្នុងបរិបទនៃជំរំប្រមូលផ្តុំ[៦៤២]។ ឧទាហរណ៍ នៅតុលាការ IMT Kaltenbrunner ត្រូវបានសម្រេចថាមានពិរុទ្ធភាពទាំងឧក្រិដ្ឋកម្មសង្គ្រាម ទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើមូលដ្ឋាននៃការបញ្ជា ក្នុងចំណោមនោះរួមមាន "វិធីសាស្ត្រនានាដែលរួមមានការធ្វើទារុណកម្ម និងការឃុំខ្លួននៅក្នុងជំរំប្រមូលផ្តុំ"[៦៤៣]។ តុលាការនេះក៏បានសម្រេចថា ការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើង "ដោយមិនគិតដល់លក្ខណៈមនុស្សធម៌ជាមូលដ្ឋាន" ទោះបីនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ[៦៤៤]។

៣៥១. ដោយផ្អែកលើច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ អង្គបុរេជំនុំជម្រះយល់ឃើញថា ការធ្វើទារុណកម្មត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។

៣៥២. បើត្រឡប់មកពិចារណាថាតើ បទល្មើសនៃការធ្វើទារុណកម្មត្រូវបានកំណត់និយមន័យពេញលេញឬទេនោះ អង្គបុរេជំនុំជម្រះរំឭកថា ការធ្វើទារុណកម្មត្រូវបានកំណត់និយមន័យដំបូងនៅក្នុងច្បាប់សង្គ្រាមដោយមានចែងនូវធាតុផ្សំដូចតទៅ៖ (i) អំពើដែលបណ្តាលឱ្យរងទុក្ខដល់រាងកាយ និងផ្លូវចិត្តរបស់បុគ្គលណាម្នាក់ (ii) ដោយមានគោលបំណងជាក់លាក់ ដូចជាដើម្បីទទួលបានការសារភាព ឬព័ត៌មានពីជននោះ ឬជនណាម្នាក់ផ្សេងទៀត។ ទាក់ទិននឹងធាតុផ្សំទី១ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សាលក្រមមួយចំនួនដែលបានពោលខាងលើ បានយោងជាពិសេសទៅដល់សញ្ញាណនៃការឈឺចាប់ និងការរងទុក្ខធ្ងន់ធ្ងរ ហើយថា នៅក្នុងករណីណាក៏ដោយ គ្រប់ករណីទាំងអស់ដែលបានដកស្រង់មកនេះយោងទៅដល់អង្គហេតុនានា ដែលបង្ហាញយ៉ាងច្បាស់ពីការរងទុក្ខផ្នែករាងកាយ ឬខាងផ្លូវចិត្ត។ ទាក់ទិននឹងធាតុផ្សំទី២វិញ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅ

---

[៦៤២] សាលក្រមតុលាការ Nuremberg (IMT) Vol. 22 ទំព័រ៤៧៧, ៤៨៩ និង ៤៩៥ (អង់គ្លេស)។

[៦៤៣] សាលក្រមតុលាការ Nuremberg (IMT) Vol. 22 ទំព័រ៥៣៧ (អង់គ្លេស)។

[៦៤៤] សាលក្រមតុលាការ Nuremberg (IMT) Vol. 1 ទំព័រ២២៧ (អង់គ្លេស)។

ក្នុងរឿងក្តី *មេបញ្ជាការជាន់ខ្ពស់* គេបានរកឃើញពីគោលបំណងជាក់លាក់នៃការទទួលបានព័ត៌មាន។ រឿងក្តី *ចាប់ពង្រត់* ក៏បានផ្តល់ជាយោបល់ផងដែរថា ការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើងដោយមានគោលបំណងជាក់លាក់ *ពោលគឺ* ជាការសងសឹក តែករណីដទៃទៀតមិនមានភាពច្បាស់លាស់ទេពីគោលបំណងដែលការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើង។ លិខិតុបករណ៍សិទ្ធិមនុស្សនានាដែលត្រូវបានអនុម័តក្រោយសង្គ្រាមលោកលើកទី២ បានកែប្រែនិយមន័យនៃការធ្វើទារុណកម្ម ដូចដែលគេយល់បានជាបឋមតាមច្បាប់សង្គ្រាម និងយុត្តិសាស្ត្រតុលាការក្រោយសង្គ្រាមលោក ដោយដកស្រង់នូវធាតុផ្សំពីរខាងលើយកមកកែលម្អ។ ដូចដែលបានអះអាងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *Furundzija* (ត្រង់កថាខណ្ឌ១៤៣) រួចមកហើយគឺថា "ការហាមឃាត់ការធ្វើទារុណកម្មដែលមានចែងក្នុងច្បាប់មនុស្សធម៌អន្តរជាតិទាក់ទិននឹងស្ថានភាពនៃជម្លោះប្រដាប់អាវុធ ត្រូវបានពង្រឹងដោយស្ថាប័ននៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស៖ វិធានទាំងនេះបានហាមឃាត់មិនឱ្យមានការធ្វើទារុណកម្ម ទាំងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធ និងនៅក្នុងពេលសន្តិភាព"[៦៤៥]។

៣៥៣. ការហាមឃាត់នៅឆ្នាំ ១៩៧៥ ដែលត្រូវបានចាត់ទុកជាភាពដាច់ខាតនោះ ត្រូវបានយកទៅបញ្ចូលនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សនានាជាច្រើន ទាំងក្នុងកម្រិតអន្តរជាតិ[៦៤៦] និងនៅថ្នាក់តំបន់[៦៤៧]។ ច្បាប់មានជាធរមានដែលពាក់ព័ន្ធសំខាន់ទៅនឹងការធ្វើទារុណកម្ម នៅសម័យ "កម្ពុជាប្រជាធិបតេយ្យ" គឺ សេចក្តីប្រកាសស្តីពីការការពារបុគ្គលគ្រប់រូបពីការធ្វើទារុណកម្ម និងអំពើសាហាវយង់ឃ្នងពីការប្រព្រឹត្តអមនុស្សធម៌ ឬការធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូរ ឬពីការដាក់ទោសទណ្ឌ ដែលបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣៤៥៣ (XXX) ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧៥ ("សេចក្តីប្រកាសស្តីពីបទទារុណកម្ម")[៦៤៨]។ សេចក្តីប្រកាសនេះបានចែងពីនិយមន័យក្នុងមាត្រា១ ថា៖

---

[៦៤៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundzija* សំណុំរឿងលេខ IT-95-17/1 "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ("សាលក្រមលើសំណុំរឿង *Furundzija*") កថាខណ្ឌ១៤៣។

[៦៤៦] មាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[៦៤៧] មាត្រា៧ នៃ ECHR មាត្រា៥(២) នៃ ACHR។

[៦៤៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 កថាខណ្ឌ៦៣។

"ក្នុងគោលបំណងនៃសេចក្តីប្រកាសនេះ ការធ្វើទារុណកម្ម មានន័យថាជា *អំពើទាំងឡាយ* ដែលមន្ត្រីសាធារណៈ ឬដោយមានការញុះញង់ពីមន្ត្រីនេះ *មានចេតនាធ្វើឱ្យបុគ្គលដទៃមានការឈឺចាប់ជាខ្លាំងខាងផ្លូវកាយ និងផ្លូវចិត្ត ក្នុងគោលបំណងមួយចំនួនដូចជាយកព័ត៌មាន ឬយកចម្លើយសារភាពពីជននោះ ឬតតិយជន ដាក់ទណ្ឌកម្មចំពោះអំពើដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យជននោះ ឬជនដទៃ។* ការធ្វើទារុណកម្ម មិនរួមបញ្ចូលការឈឺចុកចាប់ ដែលកើតឡើងពី ឬដែលមានជាប់ទាក់ទងជាមួយ ឬ ដោយចៃដន្យការដាក់ទណ្ឌកម្មស្របច្បាប់ ដែលវាស្របទៅនឹងវិធាននៃបទដ្ឋានអប្បរមានៃការប្រព្រឹត្តចំពោះទណ្ឌិត"។ (គូសបញ្ជាក់បន្ថែម)

៣៥៤. សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្ម ជាប្រភពនៃការបង្កើតអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ដែលត្រូវបានអនុម័តដោយមហាសន្និបាតនាថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤ (ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧) ដែលត្រូវបានគេចាត់ទុកថា ធ្លាប់បានចងក្រងជាច្បាប់ទំនៀមទម្លាប់មុនគេ[៦៤៥]។ ជាថ្មីម្តងទៀត ដោយផ្អែកលើធាតុផ្សំទាំងពីរខាងលើ អនុសញ្ញានេះបានកំណត់និយមន័យនៃការធ្វើទារុណកម្ម ដូចខាងក្រោម៖

"១. ដើម្បីគោលបំណងនៃអនុសញ្ញានេះ ពាក្យ "ទារុណកម្ម" មានន័យថា *អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី* ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ *ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ* បើការឈឺចាប់ ឬការរងទុក្ខបង្កឡើងដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្ម មិនបានរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតឬដែលមានជាប់ទាក់ទងជាមួយ ឬ ដោយចៃដន្យ ពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ។

២. មាត្រានេះមិនប៉ះពាល់ដល់លិខិតុបករណ៍អន្តរជាតិ ឬច្បាប់ជាតិទាំងឡាយដែលមាន ឬអាចមានបទប្បញ្ញត្តិអនុវត្តទូលំទូលាយជាងនេះឡើយ"។

---

[៦៤៥] សាលដីកាលើសំណុំរឿង *Furundzija* កថាខណ្ឌ១៦០-១៦១ ដូចដែលបានបញ្ជាក់នៅក្នុងបណ្តឹងឧទ្ធរណ៍លើសាលក្រមចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ១១១។ *រឿងក្តី តទល់នឹង* Kunarac *និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-23&23/1 "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ១៤៦។

៣៩៥. អង្គបុរេជំនុំជម្រះយល់ស្របថា សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្មបានចងក្រងច្បាប់ទំនៀមទម្លាប់មុនគេ និងយល់ឃើញថា ត្រឹមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មានភាពច្បាស់លាស់គ្រប់គ្រាន់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថា ការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចគ្នានឹងឧក្រិដ្ឋកម្មសង្គ្រាមដែរគឺថា វារួមមានធាតុផ្សំពីរគឺ i) បណ្តាលឲ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរដល់បុគ្គលនោះ (ទាំងផ្នែករាងកាយ ឬផ្លូវចិត្ត) ii) ដោយមានគោលបំណងជាក់លាក់ក្នុងការទទួលបានព័ត៌មាន ឬចម្លើយសារភាព ដោយការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ។ អង្គបុរេជំនុំជម្រះមិនមែនជាអ្នកសម្រេច ថាតើអនុសញ្ញាស្តីពីការធ្វើទារុណកម្មបាន ឬមិនបានបង្កើតជាការវិវឌ្ឍន៍នៃនិយមន័យនៃការធ្វើទារុណកម្ម ដោយការបន្ថែមនូវគោលបំណងដែលអាចនាំឲ្យមានការប្រព្រឹត្តអំពើទារុណកម្ម ឬដែលអាចនាំឲ្យមានការចងក្រងជាច្បាប់ទំនៀមទម្លាប់នោះទេ ដោយហេតុថា អង្គបុរេជំនុំជម្រះយល់ឃើញថា និយមន័យនៃការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានការយល់ដឹងយ៉ាងទូលំទូលាយ បានកើតមានឡើងត្រឹមឆ្នាំ ១៩៧៥ ហេតុនេះទង្វើបែបនេះត្រូវបានចាត់ទុកជាបទល្មើស ក្នុងន័យដែលមានការយល់ដឹងជាទូទៅ និងដែលអាចប្រមើលមើលបានចាប់ពីពេលនោះមក។ ចំណុចទាំងអម្បាលម៉ាណខាងលើ រួមទាំងលក្ខណៈសាហាវឃោរឃៅនៃឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ដែលត្រូវបានប្រព្រឹត្តយ៉ាងទូលំទូលាយ និងជាប្រព័ន្ធផងដែរ មិនអាចធ្វើឲ្យជនជាប់ចោទអាចប្រកែកថាខ្លួនមិនបានដឹងពីលក្ខណៈឧក្រិដ្ឋនៃអំពើទាំងនោះ ឬពីការទទួលខុសត្រូវព្រហ្មទណ្ឌនៃអំពើទាំងនោះឡើយ។

៣៩៦. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចោទប្រកាន់ជនជាប់ចោទពីការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ សហចៅក្រមស៊ើបអង្កេតមិនបានរំលោភដល់គោលការណ៍នីត្យានុកូលភាពទេ ហើយអង្គបុរេជំនុំជម្រះសម្រេចច្រានចោលមូលដ្ឋានរងនេះនៃមូលដ្ឋានទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍។

**<u>iv) មូលដ្ឋានរងទី១៤ ( ការរំលោភលើផ្លូវភេទ)៖</u>**

<u>សារណានានា៖</u>

៣៩៧. សហមេធាវីការពារក្តីបានលើកឡើងថា ក.ស.ច.ស បានភ័ន្តច្រឡំដោយសម្រេចថា ការរំលោភលើផ្លូវភេទគឺជាអំពើបង្កជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៦៥០]។ ដោយសារការរំលោភលើផ្លូវភេទមិនត្រូវ

[៦៥០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២១៨ ដោយយោងទៅដល់ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៤។

បានរាប់បញ្ចូលឲ្យបានច្បាស់លាស់ *នៅក្នុងចំណោម* ធម្មនុញ្ញតុលាការ Nuremberg ធម្មនុញ្ញតុលាការក្រុងតូក្យូ ឬគោលការណ៍ Nuremberg ដែលត្រូវបានចងក្រងនោះ សហមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍ និងជាថ្មីម្តងទៀតនៅក្នុងសារណាតបរបស់ខ្លួន ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាថា ការរំលោភផ្លូវភេទមិនត្រូវបានចែងជា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលមានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩" ទេ[៦៥១]។ សហមេធាវីការពារក្តីបានផ្តល់យោបល់ថា "អំពើរំលោភផ្លូវភេទអាចនឹងរំលោភបំពានមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន លុះត្រាតែ៖ ក. "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាប្រភេទមួយដែលអាចអនុវត្តបាន និង ខ. ការរំលោភផ្លូវភេទអាចបង្កឲ្យមាន"អំពើអមនុស្សធម៌ផ្សេងៗទៀត"ក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[៦៥២]។

៣៥៨. នៅក្នុងសារណាតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងសម្រេចយ៉ាងត្រឹមត្រូវថា ការរំលោភលើផ្លូវភេទពិតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៦៥៣] ហើយថា សាលក្រមរបស់តុលាការ ICTR ក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu* តំណាងនូវ "ការបញ្ជាក់សាជាថ្មីនាសម័យទំនើបចំពោះលក្ខណៈជាទំនៀមទម្លាប់ដែលមានស្រាប់ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់អន្តរជាតិ"[៦៥៤]។ សហព្រះរាជអាជ្ញាបានយោងបន្ថែមទៀតទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[៦៥៥] និងយុត្តិសាស្ត្ររបស់តុលាការ ICTY។ នៅក្នុងការសង្កេតរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់ការសន្និដ្ឋានជាក់លាក់ទៅលើបញ្ហានៃការរំលោភផ្លូវភេទទេ តែពាក្យពេចន៍ទូទៅដែលគេបានប្រើដើម្បីបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុម័តបញ្ចូលទៅ

---

[៦៥១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២១៨។ សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៩៨។

[៦៥២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២១៨។ សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៩៨។

[៦៥៣] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៦១។

[៦៥៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៩០។

[៦៥៥] ក្រមព្រហ្មទណ្ឌ (ឆ្នាំ ១៩៥៦) មាត្រា៤៤៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ស្របទៅនឹងពាក្យពេចន៍ដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

<u>ការពិភាក្សា៖</u>

៣៥៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតចោទប្រកាន់ជនជាប់ចោទពីបទ៖

> [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេស [... (ឆ) ការរំលោភលើផ្លូវភេទ ...] ផ្តន្ទាទោសដោយមាត្រា៥ [...] នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក]។

៣៦០. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តីយោងទៅដល់កថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយដូចតទៅ៖

> តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល [...] <u>ការរំលោភលើផ្លូវភេទ</u> [...]

៣៦១. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា "ធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការរំលោភផ្លូវភេទ នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[៦៥៦]។

៣៦២. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏បានប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនផងដែរក្នុងការចែងថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

---

[៦៥៦] ដីកាដំណោះស្រាយ កថាខណ្ឌ១៤៣០។

00661718



៣៦៣. នៅក្នុងផ្នែកសំអាងហេតុនៅក្នុងដីកាដំណោះស្រាយនោះ ទោះបីពួកគាត់យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមាននៅក្នុងច្បាប់អន្តរជាតិនៅពេលដែលពាក់ព័ន្ធក៏ដោយ[៦៥៧] ក៏សហចៅក្រមស៊ើបអង្កេតបានអះអាងនៅក្នុងកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយថា ការរំលោភលើផ្លូវភេទក៏ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៦៥៨]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្នុងការចេញសេចក្តីសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកទៅលើឯកសារយោងនានាដូចខាងក្រោម៖

> សាលក្រម សំណុំរឿងលេខ៖00១/១៨ កក្កដា ២00៧/អវតក/អជសជ កថាខណ្ឌ៣៦១, សេចក្តីណែនាំចំពោះអ្នកគ្រប់គ្រងកងទ័ពសហរដ្ឋអាមេរិកនៅសមរភូមិ (Lieber Code) [ឆ្នាំ ១៨៦៣] មាត្រា៤៤, ច្បាប់ស្តីពីសង្គ្រាមលើដីគោក (Oxford Manual) [ឆ្នាំ ១៨៨0] មាត្រា ៤៩, អនុសញ្ញាទី (II) និង (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់ច្បាប់នេះ៖ បទប្បញ្ញត្តិទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក (បទប្បញ្ញត្តិទីក្រុងឡាអេ) (អនុម័តនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ និង ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩0៧) បុព្វកថា (Martens Clause) មាត្រា៤៦, គណៈកម្មការស្តីពីការទទួលខុសត្រូវអ្នកបង្កសង្គ្រាម និងការអនុវត្តទោស៖ របាយការណ៍ដែលបានដាក់ជូនសន្និសីទសន្តិភាពបឋម (អនុម័តថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩), ច្បាប់លេខ១0 របស់ក្រុមប្រឹក្សាគ្រប់គ្រង [ឆ្នាំ ១៩៤៥] មាត្រា II(១)(គ), តុលាការយោធាអន្តរជាតិសម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះនៅចុងបូព៌ា [ឆ្នាំ ១៩៤៦] បុព្វកថា, សាលក្រមរបស់តុលាការ IMT Nuremburg (Nuremburg) [ថ្ងៃទី ៣១ ខែ មករា និងថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៤៦] Vol.VI pp.404-407, 565, សាលក្រមរបស់តុលាការយោធាអន្តរជាតិសម្រាប់ភូមិភាគចុងបូព៌ា (ទីក្រុងតូក្យូ) [ឆ្នាំ ១៩៤៨] ទំព័រ 1012-1019, 1023, 1180-1191 ពិសេសទំព័រ 1185-1186, រឿងក្តីប្រទេសស៊ីព្រុស តទល់នឹង ប្រទេសទួរគី សំណើរបស់គណៈកម្មការសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុបលេខ 6780/74 និងលេខ 6950/75 [ថ្ងៃទី ១0 ខែ កក្កដា ឆ្នាំ ១៩៧៦] (1982) 4 E.H.R.R ទំព័រ 482, 483[៦៥៩]។

---

[៦៥៧] ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៣ ដែលបានកត់សម្គាល់នៅក្នុងផ្នែកដែលពិភាក្សាលើអង្គសេចក្តីនៃមូលដ្ឋានទីបី នៃបណ្តឹងឧទ្ធរណ៍ខាងលើ នៅក្នុងដីកាសម្រេចនេះ គឺជាសំអាងហេតុដែលត្រឹមត្រូវ។

[៦៥៨] ដីកាដំណោះស្រាយ ជើងទំព័រលេខ៥១៩២។

[៦៥៩] ដីកាដំណោះស្រាយ ជើងទំព័រលេខ៥១៩២។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

៣៦៤. បន្ទាប់ពីបានពិនិត្យទៅលើឯកសារទាំងនេះ ដែលបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតរួចមក អង្គបុរេជំនុំជម្រះសង្កេតឃើញថា ប្រភពឯកសារទាំងនេះមិនបានគាំទ្រដោយផ្ទាល់ដោយសំណើដែលថា ការរំលោភលើផ្លូវភេទត្រឹមឆ្នាំ ១៩៧៥ ជា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ទេ ដោយសារថា ឯកសារទាំងនេះភាគច្រើនផ្តន្ទាទោសចំពោះអំពើនេះ និងម្តងម្កាល វាបង្ហាញពីស្ថានទម្ងន់តែប៉ុណ្ណោះ។ ដោយឡែក អង្គបុរេជំនុំជម្រះសូមធ្វើការសង្កេតដូចខាងក្រោម៖

១. អង្គជំនុំជម្រះសាលាដំបូង សម្រេចថា ឌុច ត្រឹមតែ "ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ [...] ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមមានបទល្មើស៖ [...] ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ)"[៦៦០]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងករណី ឌុច អង្គជំនុំជម្រះសាលាដំបូងមិនបានប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការផ្តោតជាសំខាន់ក្នុងការសម្រេចថាតើ ការរំលោភលើផ្លូវភេទពិតជាមាន ឬមិនមានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[៦៦១] ដែលគេអាចយល់បានថា ដោយសារ ឌុច ត្រឹមតែត្រូវបានគេរកឃើញថា មានការទទួលខុសត្រូវចំពោះករណីរំលោភលើផ្លូវភេទតែមួយប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់ក្នុងការកំណត់ថា វាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ដោយសារមិនមានធាតុផ្សំរួម "ដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ"។ ទោះជាយ៉ាងណាក្តី វាជាការគួរឲ្យចាប់អារម្មណ៍ដែលថា ទោះបីនៅក្នុងផ្នែក ២.៥.៣ នៃសាលក្រមនោះ[៦៦២] អង្គជំនុំជម្រះសាលាដំបូងបានប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកំណត់ថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏នៅក្នុងកថាខណ្ឌ៣៦១ នៃសាលក្រមនោះ គ្រាន់តែអះអាងថា ការរំលោភលើផ្លូវភេទ "ត្រូវបានហាមឃាត់ជាយូរយារណាស់មកហើយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយត្រូវបានចាត់ទុកថាជា "ការឈឺចាប់មួយក្នុងចំណោមការឈឺចាប់បំផុតដែលមនុស្សម្នាក់អាចប្រព្រឹត្តទៅលើមនុស្សម្នាក់ទៀត" ដែលបើតាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនគឺថា វា

---

[៦៦០] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៥៦៧។

[៦៦១] អង្គបុរេជំនុំជម្រះមិនចាំបាច់បង្កើតជាអង្គហេតុបែបនេះនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ០០១ ទេ ដោយសារក្នុងករណីនោះមេធាវីការពារក្តីមិនបានលើកជាសំណួរអ្វីទេ។

[៦៦២] សាលក្រមលើសំណុំរឿងលេខ០០១ "ច្បាប់និងសំអាងហេតុទាក់ទងនឹងបទល្មើសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" កថាខណ្ឌ៣៣០ ទំព័រ១៩៨។

មិនបានកំណត់ថាជាសំអាងហេតុដោយផ្ទាល់ថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។

២. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា មាត្រា៤៤ នៃ*សេចក្តីណែនាំចំពោះអ្នកគ្រប់គ្រងកងទ័ពសហរដ្ឋអាមេរិកនៅសមរភូមិ* ក៏បានចាត់ទុកថា ការរំលោភលើផ្លូវភេទជាបទឧក្រិដ្ឋមានស្ថានទម្ងន់ដែរ[៦៦៣]។ មាត្រា៤៩ នៃ*ច្បាប់ស្តីពីសង្គ្រាមលើដីគោក (Oxford Manual)* និងមាត្រា៤៦ នៃ*អនុសញ្ញាទី (II) និង (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់ច្បាប់នេះ៖ បទប្បញ្ញត្តិទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក ទីក្រុងឡាអេ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩* ក៏បានប្រើប្រាស់ពាក្យពេចន៍ស្រដៀងគ្នានេះដោយយោងទៅដល់ "ការគោរពដល់កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរបស់បុគ្គល ការផ្តន្ទាទោសដោយសារមូលហេតុសាសនា និងសេរីភាព"។ នៅទីនេះ អង្គបុរេជំនុំជម្រះក៏បានសង្កេតឃើញដែរថា ការរំលោភលើផ្លូវភេទក៏មិនត្រូវបានបញ្ជាក់ច្បាស់លាស់ទេ ទោះបីគេអាចសំដៅដល់សិទ្ធិនៃការរស់រានមានជីវិតរបស់បុគ្គលក៏ដោយ។ តាមអំណានដោយយកចិត្តទុកដាក់ចំពោះពាក្យពេចន៍[៦៦៤] ដែលបានប្រើប្រាស់នៅក្នុងបុព្វកថានៃអនុសញ្ញាឆ្នាំ ១៨៩៩ អាចបង្ហាញថា អំពើប្រឆាំងនឹងសិទ្ធិបុគ្គលអាចនឹងត្រូវបានបង្កើនទៅក្នុងកម្រិត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន តែមិនបាននិយាយច្បាស់លាស់បែបនេះទេ។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ការរំលោភលើផ្លូវភេទត្រូវបានទទួលស្គាល់ច្បាស់លាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែនៅក្នុង មាត្រា II(១)(គ) នៃ*ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* ប៉ុណ្ណោះ។

៤. បុព្វកថានៃ*តុលាការយោធាអន្តរជាតិសម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះនៅចុងបូព៌ា* អះអាងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានយោង និងកំណត់និយមន័យនៅក្នុងធម្មនុញ្ញរបស់

---

[៦៦៣] Lieber Code មាត្រា៤៤ ចាត់ទុកការរំលោភលើផ្លូវភេទត្រូវបានហាមឃាត់តាមបញ្ញត្តិជាទោសប្រហារជីវិត ជាពេលចាប់ផ្តើម ហើយបន្ទាប់មកបានចែងថា "ឬការផ្តន្ទាទោសធ្ងន់ធ្ងរដទៃទៀតអាចមានលក្ខណៈសមរម្យចំពោះស្ថានទម្ងន់នៃបទល្មើសនេះដែរ"។

[៦៦៤] បុព្វកថានៃអនុសញ្ញាឆ្នាំ ១៨៩៩ បានបញ្ចូល "ផលប្រយោជន៍សម្រាប់មនុស្សជាតិ" ផង និង "ច្បាប់មនុស្សជាតិ" ផង។

តុលាការនេះ[៦៦៥]។ បុព្វកថានេះក៏បានថែងបន្ថែមទៀតថា ការរំលោភលើផ្លូវភេទគឺជាការរំលោភច្បាប់អន្តរជាតិ និង "ទំនៀមទម្លាប់ដែលមានការទទួលស្គាល់ និងអនុសញ្ញាស្តីពីសង្គ្រាម"។ បុព្វកថានេះមិនបានភាពការពាក់ព័ន្ធជាក់លាក់រវាង ការរំលោភលើផ្លូវភេទ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៥. សាលក្រមរបស់តុលាការ Nuremberg (IMT) បានអះអាងពីអង្គហេតុ និងឧទាហរណ៍នានានៃការរំលោភលើផ្លូវភេទ ដោយមានការផ្តន្ទាទោសដោយប្រយោល តែមិនបានចេញសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់អ្វីទេ ទាក់ទិននឹងទស្សនៈដែលថាការរំលោភលើផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៦. សាលក្រមរបស់តុលាការយោធាអន្តរជាតិសម្រាប់ភូមិភាគចុងបូព៌ា[៦៦៦] យោងទៅដល់ព្រឹត្តិការណ៍រំលោភលើផ្លូវភេទនៅក្រុងណានគីង[៦៦៧] ដែលទាហានបានចូលរួមក្នុងអំពើរំលោភផ្លូវភេទច្រើនរាប់មិនអស់។ សាលក្រមនេះបានផ្តន្ទាទោសការរំលោភលើផ្លូវភេទដោយបានអះអាងថា "លក្ខណៈសាហាវព្រៃផ្សៃរបស់កងទ័ពជប៉ុនមិនអាចចាត់ទុកដូចជាអំពើរបស់ពួកយោធាដែលបានធ្វើជ្រុលជ្រួសតែមួយរយៈពេលខ្លីប៉ុណ្ណោះទេ នៅពេលមានការស៊ុំចុះចាញ់ទៅហើយ តែការរំលោភលើផ្លូវភេទ ការដុតបំផ្លាញគេហដ្ឋាន និងការសម្លាប់មនុស្សនៅតែបន្តប្រព្រឹត្តជាទ្រង់ទ្រាយធំ យ៉ាងហោចណាស់ក៏រយៈពេលប្រាំមួយសប្តាហ៍ បន្ទាប់ពីបានកាន់កាប់ទីក្រុងនេះ និងយ៉ាងហោចណាស់ក៏រយៈពេលបួនសប្តាហ៍ក្រោយពេល

---

[៦៦៥] តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា *រឿងក្តី សហរដ្ឋអាមេរិក និងអ្នកដទៃទៀត តទល់នឹង Araki និងអ្នកដទៃទៀត* "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" បោះពុម្ពសាជាថ្មីនៅក្នុង Neil Boister and Robert Cryer (eds), *Documents on the Tokyo International Military Tribunal: Charter, Indictment and Judgments,* Oxford University Press: ឆ្នាំ ២០០៨ ទំព័រ១៦ (អង់គ្លេស)។

[៦៦៦] តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា *រឿងក្តី សហរដ្ឋអាមេរិក និងអ្នកដទៃទៀត តទល់នឹង Araki និងអ្នកដទៃទៀត* "សាលក្រមដោយសំឡេងភាគច្រើន" បោះពុម្ពសាជាថ្មីនៅក្នុង Neil Boister and Robert Cryer (eds), *Documents on the Tokyo International Military Tribunal: Charter, Indictment and Judgments,* Oxford University Press: ឆ្នាំ ២០០៨។

[៦៦៧] តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា *រឿងក្តី សហរដ្ឋអាមេរិក និងអ្នកដទៃទៀត តទល់នឹង Araki និងអ្នកដទៃទៀត* "សាលក្រមដោយសំឡេងភាគច្រើន" បោះពុម្ពសាជាថ្មីនៅក្នុង Neil Boister and Robert Cryer (eds), *Documents on the Tokyo International Military Tribunal: Charter, Indictment and Judgments,* Oxford University Press: ឆ្នាំ ២០០៨ ទំព័រ៤៩, ៦០៥។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. CETC PRÉLIMINAIRE

00661722



Matsui និង Muto បានចូលទីក្រុងនេះ”[៦៦៨]។ ផ្នែកនេះនៃសាលក្រមមិនបានកំណត់ឱ្យបានច្បាស់លាស់ថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៧. នៅក្នុងរឿងក្តី *ប្រទេសសាយប្រ៊ីស តទល់នឹង ប្រទេសទួរគី* មានឧបទ្ទវហេតុនៃការរំលោភលើផ្លូវភេទដែលបង្កឡើងដោយពួកទាហានទួរគីបានបង្កើតជា “ការប្រព្រឹត្តបែបអមនុស្សធម៌” ដែលមានចែងក្នុងមាត្រា៣ នៃអនុសញ្ញាសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប។ ទោះបីក្នុងរឿងក្តី ការរំលោភលើផ្លូវភេទត្រូវបានផ្តន្ទាទោសក៏ដោយ តែមិនមានការកំណត់ថាវាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ[៦៦៩]។

៣៦៥. ទាក់ទិននឹងប្រភពឯកសារដែលសហចៅក្រមស៊ើបអង្កេតយកមកប្រើប្រាស់ អង្គបុរេជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះមិនបានគាំទ្រយ៉ាងពេញលេញដល់សំណើដែលថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ នោះទេ។ លើកលែងតែច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងចេញ មិនមានប្រភពឯកសារណាមួយបង្ហាញថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៣៦៦. ក្រៅពីការកំណត់យ៉ាងច្បាស់ពីការរំលោភលើផ្លូវភេទនៅក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គបុរេជំនុំជម្រះត្រូវធ្វើការវាយតម្លៃដោយខ្លួនឯង ដើម្បីសម្រេចថាតើ មានសំអាងហេតុណាមួយសមស្រប ដោយពិនិត្យមើលថាតើ ការពិត ការរំលោភលើផ្លូវភេទមាននៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ ឬយ៉ាងណា។

៣៦៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បទល្មើសរំលោភលើផ្លូវភេទត្រូវបានហាមឃាត់ពីយូរយារណាស់មកហើយ ដោយសារវាចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម ដែលមានចាប់តាំងពីយ៉ាងហោច

---

[៦៦៨] តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា *រឿងក្តី សហរដ្ឋអាមេរិក និងអ្នកដទៃទៀត តទល់នឹង Araki និងអ្នកដទៃទៀត* “សាលក្រមដោយសំឡេងភាគច្រើន” បោះពុម្ពសាជាថ្មីនៅក្នុង Neil Boister and Robert Cryer (eds), *Documents on the Tokyo International Military Tribunal: Charter, Indictment and Judgments,* Oxford University Press: ឆ្នាំ ២០០៨ ទំព័រ៥៩, ១៩២ (អង់គ្លេស)។

[៦៦៩] គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី ប្រទេសសាយប្រ៊ីស តទល់នឹង ប្រទេសទួរគី* (ឆ្នាំ ១៩៨២) សំណុំរឿងលេខ 4 EHRR 482 សំណើលេខ 6780/74 និង 6950/75 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៦ (“*រឿងក្តី ប្រទេសស៊ីប តទល់នឹង ប្រទេសទួរគី*”)។

00661723



ណាស់ក៏នៅពេលបង្កើតLieber Code ឆ្នាំ ១៨៦៣ ដែរ[៦៧០]។ បញ្ញត្តិ Oxford Manual ដែលត្រូវបានតាក់តែងសេចក្តីព្រាងដោយវិទ្យាស្ថានច្បាប់អន្តរជាតិនាឆ្នាំ ១៨៨០ ដែលចែងថា "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ" ដែលជាពាក្យសម្រាលក្នុងសតវត្សទី ១៩ ដែលសំដៅដល់ការហាមឃាត់មិនឱ្យមានការរំលោភលើផ្លូវភេទ[៦៧១] និងការវាយប្រហារផ្លូវភេទ ត្រូវតែគោរពនិងចាត់ទុកជាផ្នែកមួយនៃច្បាប់ និងទំនៀមទម្លាប់សង្គ្រាម[៦៧២]។ អនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩[៦៧៣] និងឆ្នាំ ១៩០៧[៦៧៤] បានកំណត់លក្ខខណ្ឌតម្រូវដូចៗគ្នា ហើយត្រូវបានពង្រឹងដោយការការពារទូទៅនៅក្នុង Martens Clause[៦៧៥]។ បន្ទាប់មក ការរំលោភលើផ្លូវភេទត្រូវបានហាមឃាត់ជាក់លាក់នៅក្នុងអនុ

---

[៦៧០] Lieber Code មាត្រា៤៤៖ "អំពើហិង្សាសាហាវព្រៃផ្សៃដែលបានប្រព្រឹត្តប្រឆាំងនឹងមនុស្សនៅក្នុងប្រទេសដែលត្រូវបានលុកលុយ ... រាល់ *ការរំលោភលើផ្លូវភេទ* ការធ្វើឱ្យរបួស ការធ្វើឱ្យពិការ ឬការសម្លាប់ប្រជាជនទាំងនោះ ត្រូវបានហាមឃាត់ដោយបញ្ញត្តិនៃទោសប្រហារជីវិត ឬការផ្តន្ទាទោសធ្ងន់ធ្ងរដទៃទៀតដែលអាចសមរម្យចំពោះស្ថានទម្ងន់នៃបទល្មើសនោះ" (គូសបញ្ជាក់បន្ថែម)។

[៦៧១] M. Bassiouni, *Crimes Against Humanity in International Criminal Law*, Kluwer Law International, The Hague: ឆ្នាំ ១៩៩៩ ទំព័រ៣៤៨ (អង់គ្លេស)។

[៦៧២] *ច្បាប់ស្តីពីសង្គ្រាមលើដីគោក* អនុម័តដោយវិទ្យាស្ថានច្បាប់អន្តរជាតិ Oxford ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៨៨០ ("Oxford Manual") មាត្រា៤៩៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅរបស់បុគ្គល រួមទាំងជំនឿ និងការគោរពប្រណិប័តន៍សាសនាត្រូវតែគោរព"។

[៦៧៣] *បទប្បញ្ញត្តិទីក្រុងឡាអេ ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញា (II) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ("បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩") មាត្រា៤៦៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅ និងទ្រព្យសម្បត្តិឯកជនរបស់បុគ្គល រួមទាំងជំនឿ និងការគោរពប្រណិប័តន៍សាសនាត្រូវតែគោរព"។

[៦៧៤] *បទប្បញ្ញត្តិទីក្រុងឡាអេ ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញា (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ("បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧") មាត្រា៤៦៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅរបស់បុគ្គល និងទ្រព្យសម្បត្តិឯកជន រួមទាំងជំនឿ និងការគោរពប្រណិប័តន៍សាសនាត្រូវតែគោរព"។

[៦៧៥] *អនុសញ្ញាទីក្រុងឡាអេ (II) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ បុព្វកថា។ *អនុសញ្ញាទីក្រុងឡាអេ (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ បុព្វកថា។

សញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[៦៧៦] ពិធីសារបន្ថែមទី I ឆ្នាំ ១៩៧៧[៦៧៧] និង ពិធីសារបន្ថែមទី II ឆ្នាំ ១៩៧៧[៦៧៨]។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម មុនឆ្នាំ ១៩៧៥។

៣៦៨. មុនឆ្នាំ ១៩៧៥ ការរំលោភលើផ្លូវភេទត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែ នៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ឧទាហរណ៍នៃការផ្តន្ទាទោសលើការរំលោភលើផ្លូវភេទ អនុលោមតាមច្បាប់នេះ មិនត្រូវបានផ្តល់ ទៅឲ្យអង្គជំនុំជម្រះនោះទេ ហើយយើងក៏មិនអាចរកឧទាហរណ៍បែបនេះបាននោះដែរ[៦៧៩]។ ភស្តុតាងនៃការរំលោភលើផ្លូវភេទត្រូវបានអានដោយរដ្ឋអាជ្ញាបារាំង និងសូវៀត ដើម្បីបញ្ចូលក្នុង កំណត់ហេតុនៅតុលាការ IMT[៦៨០] ទោះជាយ៉ាងណាក្តី មិនមានចំណុចណាមួយនៅក្នុងសាលក្រម តុលាការ Nuremberg (IMT) និយាយពីការរំលោភលើផ្លូវភេទ ហើយមិនមានចុងចោទត្រូវបាន

---

៦៧៦ *អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទិននឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម* ឯកសារលេខ 75 U.N.T.S. 287 (អនុញ្ញាតឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០) (""អនុសញ្ញាទីក្រុងហ្សឺណែវទី៤) មាត្រា២៧ (កថាខណ្ឌទីពីរ)។

៦៧៧ *ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងទាក់ទិនទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី I)* ឯកសារលេខ 1125 U.N.T.S. 3 (អនុម័តនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចូលជាធរមាននៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨) ("ពិធីសារបន្ថែមទី I") មាត្រា៧៦(១) (អនុម័តជាឯកច្ឆន្ទ)។

៦៧៨ *ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៤៩ និងទាក់ទិនទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារទី II)* ឯកសារលេខ 1125 U.N.T.S. 609 (អនុម័តនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចូលជាធរមាននៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨) ("ពិធីសារបន្ថែមទី II") មាត្រា៤(២)(ង) (អនុម័តជាឯកច្ឆន្ទ)។

៦៧៩ សម្រាប់ការលើកឡើងនូវបទល្មើសផ្លូវភេទដទៃទៀត សូមមើល៖ "រឿងក្តីគ្រូពេទ្យ" (*រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Karl Brandt និងអ្នកដទៃទៀត*) សំណុំរឿងលេខ១ NMT Vol. 2 (ការធ្វើមិនឲ្យមានកូន និងការក្រៀវ), "រឿងក្តី Pohl" (*រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកដទៃទៀត*) សំណុំរឿងលេខ៤ NMT Vol 5 (ភស្តុតាងនៃការពន្លូតកូនដោយបង្ខំ និង "កន្លែងសោភិនី" នៅក្នុងជំរំប្រមូលផ្តុំ), "រឿងក្តី RuSHA" (*រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Ulrich Greifelt និងអ្នកដទៃទៀត*) សំណុំរឿងលេខ៨ NMT Vols 4-5 (ការពន្លូតកូនដោយបង្ខំ ការធ្វើទុក្ខបុកម្នេញដោយសារភេទ និងឧក្រិដ្ឋកម្មលើការបន្តពូជ)។

៦៨០ សូមមើល តុលាការយោធាអន្តរជាតិ ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ ឆ្នាំ ១៩៤៦ Nuremberg: ឆ្នាំ ១៩៤៧ Vol 6 ប្រតិចារិក ថ្ងៃទី ៣១ ខែ មករា ទំព័រ៤០៤-៤០៧ Vol 7 ប្រតិចារិក ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៤៦ ទំព័រ ៤៥៦-៤៥៧ (អានជាភស្តុតាងនៅក្នុង "កំណត់ហេតុរបស់ Molotov" ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៤២)។

00661725



ផ្តន្ទាទោសពីបទល្មើសរំលោភលើផ្លូវភេទជាបទឧក្រិដ្ឋណាមួយឡើយ កុំថាឡើយដល់ទៅចាត់ទុកថាវាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[៦៨១]។ មហាសន្និបាតអង្គការសហប្រជាជាតិមិនបានទទួលស្គាល់ថា ការរំលោភលើផ្លូវភេទតែឯកឯងនោះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ នៅពេលដែលមហាសន្និបាតនេះបញ្ជាក់ទទួលស្គាល់នូវគោលការណ៍ Nuremberg នៃច្បាប់អន្តរជាតិនោះ។

៣៦៩. សហចៅក្រមស៊ើបអង្កេត[៦៨២] និងសហព្រះរាជអាជ្ញា[៦៨៣] មិនបានបង្ហាញប្រភពណាមួយដល់អង្គបុរេជំនុំជម្រះ ដែលចាត់ទុកការរំលោភលើផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាបទល្មើសមានលក្ខណៈទំនៀមទម្លាប់នៅមុនពេល ឬក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។

៣៧០. ប្រភពមួយទៀតនៃច្បាប់អន្តរជាតិគឺ "គោលការណ៍ទូទៅរបស់ច្បាប់ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់"[៦៨៤]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការរំលោភលើផ្លូវភេទស្ទើរតែត្រូវបានចាត់ទុកជាបទល្មើសជាសកលទៅហើយ នៅក្នុងច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិ ទោះបីមានការប្រើប្រាស់និយមន័យនៃពាក្យថារំលោភលើផ្លូវភេទនេះខុសៗគ្នាក៏ដោយ[៦៨៥]។ ការពិត អង្គជំនុំជម្រះនេះមិនអាចស្វែងរកឧទាហរណ៍មួយពីប្រព័ន្ធច្បាប់ណាមួយ

---

[៦៨១] សូមមើល សាលក្រមរបស់តុលាការ IMT និង Kelly Askin, "ការជំនុំជម្រះលើបទរំលោភផ្លូវភេទ ឧក្រិដ្ឋកម្មផ្សេងៗទៀតតាមច្បាប់អន្តរជាតិៈ ដំណើរការវិវត្តន៍ទៅមុខដោយវិសាមញ្ញ ឧបសគ្គដែលត្រូវប្រឈម" (Prosecuting Wartime Rape and Other Gender-Related Crimes under International Law: Extraordinary Advances, Enduring Obstacles), ដែលចេញផ្សាយនៅក្នុងទស្សនាវដ្តីស្រាវជ្រាវ *Berkeley Journal of International Law*,ឆ្នាំ ២00៣ ទំព័រ៣0១ (អង់គ្លេស)។

[៦៨២] ដីកាដំណោះស្រាយ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 ("ដីកាដំណោះស្រាយ") ជើងទំព័រលេខ២៥៧០ និង២៥៧១។

[៦៨៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ជើងទំព័រលេខ៤៨៥-៤៩៤។

[៦៨៤] លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ មាត្រា៣៨(១)(គ)។ *សូមមើល* ផងដែរ ផ្នែកដែលពិភាក្សាពីអង្គសេចក្តីនៃមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ខាងលើ នៅក្នុងដីកាសម្រេចនេះ។

[៦៨៥] សូមមើលជាឧទាហរណ៍៖ *ក្រមព្រហ្មទណ្ឌ* (ឆ្នាំ ១៩៥៦) មាត្រា៤៤៣ (កម្ពុជា), *ក្រមព្រហ្មទណ្ឌ* (ឆ្នាំ ១៨១០) មាត្រា ៣៣១-៣៣៣ (បារាំង), *ក្រមព្រហ្មទណ្ឌ* (ច្បាប់លេខ៤៥ ឆ្នាំ ១៩០៧) មាត្រា១៧៧-១៧៨ (ជប៉ុន), *ក្រមព្រហ្មទណ្ឌឥណ្ឌា* (ច្បាប់លេខ៤៥ ឆ្នាំ ១៨៦០) មាត្រា៣៧៥ (ឥណ្ឌា), *ក្រមព្រហ្មទណ្ឌ* (លេខ៥៨ ឆ្នាំ ១៩៣៧) មាត្រា២៦៧-២៦៨ (អេហ្ស៊ីប), *ក្រមព្រហ្មទណ្ឌ* (ច្បាប់លេខ២៩ ឆ្នាំ ១៩៦០) ផ្នែក៩៨ (ហ្គាណា), *ក្រមព្រហ្មទណ្ឌ RSFSR* (ឆ្នាំ ១៩៦០ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧២) មាត្រា១១៧ (សាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតនៃរុស្ស៊ី ស.ស.ស.ស), *Código Penal* (Decreto-Lei No. 2.848 de 1940) មាត្រា២១៣-២១៥ (ប្រេស៊ីល), *ច្បាប់ព្រហ្មទណ្ឌ* (ច្បាប់សាធារណៈលេខ៤៣ ឆ្នាំ

00661726



ដែលកំណត់ថា ការរំលោភលើផ្លូវភេទមិនមែនជាបទល្មើសនៅត្រឹមឆ្នាំ ១៩៧៥ នោះទេ។ ទោះបីជាយ៉ាងណាក្តី ការរំលោភផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានធាតុផ្សំសំខាន់ៗ ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវដែលជាផ្នែកមួយនៃ "ការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ"[៦៨៦]។ ការរំលោភលើផ្លូវភេទដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិកំណត់និយមន័យ មិនមានធាតុផ្សំបែបនេះទេ។ អង្គហេតុនានាដែលនាំឲ្យការរំលោភលើផ្លូវភេទក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចនឹងគាំទ្រដល់ការចោទប្រកាន់ទោសចំពោះការរំលោភផ្លូវភេទតាមច្បាប់ជាតិដែរ តែការរំលោភផ្លូវភេទនៅក្នុងច្បាប់ថ្នាក់ជាតិមិនបានគាំទ្រដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ដោយសារថា ព្រឹត្តិការណ៍ដាច់ដោយឡែកដែលមិនពាក់ព័ន្ធនឹងអំពើដែលគួរឲ្យរន្ធត់ធំៗ មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ។ នៅក្នុងបរិបទមួយទៀត អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាថាតើ បទល្មើសជាតិ និងបទល្មើសអន្តរជាតិអាចត្រូវបានចាត់ទុកថាមានន័យដូចគ្នាឬទេ។ អង្គបុរេជំនុំជម្រះបានបង្ហាញថា ដោយសារធាតុផ្សំនៃបទល្មើសទាំងពីរប្រភេទមិនដូចគ្នាបេះបិទនោះ បទល្មើសជាតិ និងបទល្មើសអន្តរជាតិត្រូវបានចាត់ទុកជាបទល្មើសដាច់ពីគ្នា[៦៨៧]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការរំលោភលើផ្លូវភេទតែឯកឯងមិនអាចបញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ដោយសារគោលការណ៍ទូទៅរបស់ច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់។ ដោយសារវាស៊ីសង្វាក់ជាមួយយុត្តាធិការរបស់តុលាការ ICTY នោះ គោលការណ៍ទាំងនេះ

---

១៩៦១) ផ្នែក១២៨ (ញូវហ្សេលែន), *ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌឆ្នាំ ១៨៩៩* ផ្នែក៣៤៩-៣៥០ (Queensland, អូស្ត្រាលី), *ក្រមព្រហ្មទណ្ឌរដ្ឋ California* (ឆ្នាំ ១៩៧៣) ផ្នែក ២៦១-
២៦៩ (California, សហរដ្ឋអាមេរិក), *ក្រមព្រហ្មទណ្ឌ* ឆ្នាំ ១៨៩២ 55-56 Vict., c. 29, ផ្នែក២២៦ (កាណាដា)។

[៦៨៦] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣០០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T "ទស្សនៈ និងសាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ៦៤៦-៦៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ៥៧៩។

[៦៨៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 សូមមើល កថាខណ្ឌ៧២ និង៨៤។

00661727



អាចត្រឹមតែជួយបញ្ជាក់ឲ្យបានច្បាស់ពី *កត្តាសត្យានុម័ត* និង *កត្តាអត្តនោម័ត* នៃការរំលោភលើផ្លូវភេទតែប៉ុណ្ណោះ នៅពេលដែលអត្ថិភាពនៃបទល្មើស ត្រូវបានបង្កើតឡើងរួចហើយ[៦៨៨]។

<u>សេចក្តីសន្និដ្ឋាន៖</u>

៣៧១. អង្គបុរេជំនុំជម្រះយល់ឃើញថា មកត្រឹម ឆ្នាំ ១៩៧៥ ការរំលោភលើផ្លូវភេទមិនមាននៅក្នុងច្បាប់អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុសម្ភារៈដែលមានរៀបរាប់ក្នុងដីកាដំណោះស្រាយទាក់ទិននឹងការរំលោភលើផ្លូវភេទ អាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទារុណកម្ម ឬជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ នៅក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហមេធាវីការពារក្តីនិយាយថា "ការរំលោភលើផ្លូវភេទអាចត្រឹមតែរំលោភដល់មាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប៉ុណ្ណោះ ប្រសិនបើ៖ ក."អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាប្រភេទមួយអាចអនុវត្តបាន និង ខ.ការរំលោភលើផ្លូវភេទបានបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩"។ អង្គបុរេជំនុំជម្រះសន្និដ្ឋាននៅក្នុងការពិភាក្សានូវមូលដ្ឋានរងទី១៥, ១៦, ១៧ និង ១៩ ខាងក្រោមថា មកត្រឹមឆ្នាំ ១៩៧៥ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលមាននៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា លើទម្រង់ករណីដែលទាក់ទិននឹងអត្ថិភាពនៃប្រភេទរងនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងច្បាប់មកត្រឹមឆ្នាំ ១៩៧៥ មិនគួរយកមកពិចារណាបន្ថែមទៀតទេ។

៣៧២. អាស្រ័យហេតុនេះ មូលដ្ឋានរងនេះ នៃបណ្តឹងឧទ្ធរណ៍ត្រូវបានទទួលស្គាល់ ហើយអង្គបុរេជំនុំជម្រះសម្រេចលុបការរំលោភលើផ្លូវភេទចេញពីកថាខណ្ឌ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ(ញ)) នៃដីកាដំណោះស្រាយ និងតម្កល់សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ១៤៣៣ នៃដីកាដំណោះស្រាយដែលថា អង្គហេតុនានាដែលចាត់ទុកការរំលោភលើ

[៦៨៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Furundžija សំណុំរឿងលេខ IT-95-17/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ១៧៧៖ "ការសម្រេចយកនិយមន័យនៃការរំលោភលើផ្លូវភេទ គឺផ្អែកលើគោលការណ៍ច្បាប់ព្រហ្មទណ្ឌនៃភាពជាក់លាក់ ... វាជាការចាំបាច់ដែលត្រូវមើលទៅលើគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌរួម នៃប្រព័ន្ធច្បាប់ធំៗនៅលើពិភពលោក"។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-23-T និង លេខ IT-96-23/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ៤៣៩-៤៦០។

ផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានចោទប្រកាន់នូវបទឧក្រិដ្ឋបែបនេះ។

v) **មូលដ្ឋានរងទី១៥ (អំពើអមនុស្សធម៌ផ្សេងៗទៀត) និងទី១៦ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ទី១៧ (អំពើហិង្សាផ្លូវភេទ) និងទី១៩ (ការបាត់ខ្លួនដោយបង្ខំ)៖**

សារណានានា៖

៣៧៣. សហមេធាវីការពារក្តីសន្និដ្ឋានថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនមែនជាបទល្មើសមូលដ្ឋានបង្កឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ ហើយថា អំពើទាំងនោះមិនត្រូវបាន "ប្រកាស" ឲ្យបានពេញលេញទេ[៦៨៩]។ បន្ទាប់មក សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំដោយយល់ឃើញថា ខ្លួនមានយុត្តាធិការទៅលើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការជម្លៀសប្រជាជនដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ដោយសារអំពើទាំងនេះមិនទាន់មានលក្ខណៈសម្បត្តិបែបនេះឡើយ មកត្រឹមឆ្នាំ ១៩៧៥[៦៩០]។

៣៧៤. សហព្រះរាជអាជ្ញាបានឆ្លើយតបដោយលើកជាទឡ្ហីករណ៍ថា ""អំពើអមនុស្សធម៌ផ្សេងៗទៀត" រួមមានបទល្មើសដែលនៅសេសសល់ផ្សេងទៀត ដែលបានបំណងចាត់ទុកអំពើនោះជាបទល្មើស នៅពេលដែលអំពើនោះបំពេញតាមលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌតម្រូវនៃបទល្មើសមួយក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតឡើយ"[៦៩១]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "មានការបង្កើតឡើងយ៉ាងល្អនៅក្នុងច្បាប់អន្តរជាតិថា អំពើណាមួយដែលត្រូវបានចាត់ទុកថាជា "អំពើអមនុស្សធម៌មួយទៀត" ប្រសិនបើអំពើនោះ "មានស្ថានទម្ងន់ស្រដៀងគ្នាគ្រប់គ្រាន់ ទៅនឹងបទល្មើសជាក់លាក់ដទៃទៀតដែលបានរៀបរាប់""។ សហព្រះ

---

[៦៨៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២០ ដោយយោងទៅដល់ ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៤។

[៦៩០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២០, ២២៣-២២៤ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ២២៥ (អំពើហិង្សាផ្លូវភេទ) ២២៦-២២៩ (ការជម្លៀសប្រជាជនដោយបង្ខំ) ២៣០-២៣១ (ការបាត់ខ្លួនដោយបង្ខំ) ចំណុចនីមួយៗយោងទៅដល់ ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៤។

[៦៩១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀងធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៩៨។

រាជអាជ្ញាអះអាងបញ្ជាក់បន្ថែមទៀតថា ការវាយតម្លៃទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនោះគឺមិនមែនជាបញ្ហាយុត្តាធិការ និងមិនអាចអនុញ្ញាតឲ្យមានការប្ដឹងជំទាស់ទៅអង្គបុរេជំនុំជម្រះបានទេ[៦៩២]។ នៅក្នុងសារណារបស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដល់ការសន្និដ្ឋានជាក់លាក់ទៅលើបញ្ហានៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទេ តែដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ... ១៧... ខាងលើរួចមកហើយគឺថា ពាក្យពេចន៍ទូទៅដែលគេបានប្រើដើម្បីបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុម័តបញ្ចូលទៅក្នុងមាត្រា៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ស្របទៅនឹងពាក្យពេចន៍ដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

៣៧៥. នៅក្នុងសារណាឆ្លើយតប សហមេធាវីការពារក្ដីសង្កត់ធ្ងន់អំពី "កង្វះភាពជាក់លាក់" នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" និងបានលើកជាទឡ្ហីករណ៍ថា ការខ្វះចំណុចជាក់លាក់នេះគឺជាដើមចមដែលនាំឲ្យមានការដកបទល្មើសនេះចេញពីយុត្តាធិការរបស់ អ.វ.ត.ក[៦៩៣]។

<u>ការពិភាក្សា៖</u>

៣៧៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ អៀង សារី ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយចាត់ទុកត្រឹមតែ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ប៉ុណ្ណោះ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៦៩៤]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្ដីបានយោងទៅដល់កថាខណ្ឌ ១៣១៤ នៃដីកាដំណោះស្រាយ ដែលមាននៅក្នុងផ្នែកសំអាងហេតុនៃដីកាដំណោះស្រាយ ដូចខាងក្រោម៖

> "តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល [...] និងអំពើអមនុស្សធម៌ផ្សេងៗទៀត *រួមមាន*

---

[៦៩២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៩៨។

[៦៩៣] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១០៥។

[៦៩៤] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១៣។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ”។

៣៧៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កថាខណ្ឌនេះនៃដីកាដំណោះស្រាយមានគោលបំណងជាសំខាន់គឺបកស្រាយពីអត្ថន័យ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រភេទរងនៃបទល្មើសនេះ ហើយថាបទល្មើសនេះរួមមាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ ជា “អំពើអមនុស្សធម៌ផ្សេងៗទៀត” ដោយមានប្រើពាក្យថា “*រួមបញ្ចូលទាំង*” ដើម្បីភ្ជាប់ឃ្លាទាំងពីរ។

៣៧៨. តាំងពីដំបូងមក ទាក់ទិននឹងទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយបានសម្រេចថា ខ្លួនមានយុត្តាធិការលើ “អំពើអមនុស្សធម៌ផ្សេងៗទៀត” មានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ អង្គបុរេជំនុំជម្រះយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុង*រឿងក្តី* *Blagojević* ថា “គេគួរសង្កត់ធ្ងន់ថា អំពើអមនុស្សធម៌ផ្សេងៗទៀត*តែឯកឯង*គឺជាបទឧក្រិដ្ឋមួយតាមច្បាប់អន្តរជាតិ”[៦៥៥]។ ការដាក់លក្ខខណ្ឌតម្រូវថា ប្រភេទរងនីមួយៗនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត” មានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលតាមច្បាប់អន្តរជាតិនោះ គឺមានន័យថាប្រភេទ “អំពើអមនុស្សធម៌ផ្សេងៗទៀត” លែងជាប្រភេទចាំបាច់ទៀតហើយ ពោលគឺ រាល់ការប្រព្រឹត្តមានន័យស្មើនឹងបទល្មើសដោយខ្លួនឯងរួចទៅហើយ ដោយមិនចាំបាច់ចាត់ទុកការប្រព្រឹត្តនោះថាជាបទល្មើស ដែលស្ថិតក្នុងប្រភេទ “អំពើអមនុស្សធម៌ផ្សេងៗ

[៦៥៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Blagojević* *និង* *Jokić* សំណុំរឿងលេខ IT-02-60-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង I ផ្នែក ក ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ៦២៤ (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Brima* *និងអ្នកដទៃទៀត* សំណុំរឿងលេខ “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ (“សាលក្រមសាលាដំបូងលើ*រឿងក្តី* *Brima*”) កថាខណ្ឌ៦៩៧-៦៩៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Brima* *និងអ្នកដទៃទៀត* សំណុំរឿងលេខ SCSL-2004-16-A “សាលដីកា” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ (“សាលដីកាសាលាឧទ្ធរណ៍លើ*រឿងក្តី* *Brima*”) កថាខណ្ឌ១៩៧-១៩៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kayeshima* *និង* *Ruzindana* សំណុំរឿងលេខ ICTR-95-1-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ៣១៥-៣១៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* សំណុំរឿងលេខ IT-97-24-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ៧១៩។

ទៀត" នោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព ត្រូវភ្ជាប់ជាមួយប្រភេទទាំងមូលនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" និងមិនត្រូវភ្ជាប់តែជាមួយប្រភេទរងនីមួយៗទេ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា ទឡ្ហីករណ៍របស់សហមេធាវីការពារក្តី ដែលទាក់ទិននឹងអត្ថិភាពនៃប្រភេទរងនីមួយៗ នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងច្បាប់ត្រឹមឆ្នាំ ១៩៧៥ មិនគួរយកមកពិចារណាបន្ថែមទៀតទេ។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតដែលចោទប្រកាន់ អៀង សារី យ៉ាងជាក់លាក់ ពី "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ គឺជាមូលហេតុដែលថាតើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" បង្កឲ្យមានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនៅក្នុងច្បាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ គួរតែយកមកពិចារណាឬទេ។

៣៧៩. ទាក់ទិននឹងទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនមានអត្ថិភាពជាបទល្មើសជាមូលដ្ឋាន ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថា អំពើទាំងនេះមិនមានចែងពេញលេញនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងការចេញសេចក្តីសម្រេចទាក់ទិននឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងកថាខណ្ឌ១៣១៤ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកទៅលើឯកសារយោងនានាដូចខាងក្រោម៖

> សំណុំរឿងលេខ៖០០១/១៨ កក្កដា ២០០៧/អវតក/អជសដ សាលក្រម កថាខណ្ឌ២៩៣ ៣៦៧និងបន្ទាប់, *សេចក្តីណែនាំចំពោះអ្នកគ្រប់គ្រងកងទ័ពជើងគោកសហរដ្ឋអាមេរិកនៅសមរភូមិ* (Lieber Code) [ឆ្នាំ ១៨៦៣] មាត្រា១៦ ២២ ៥៦, *អនុសញ្ញាទី (II) និង (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់ច្បាប់នេះ៖ បទប្បញ្ញត្តិទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក (បទប្បញ្ញត្តិទីក្រុងឡាអេ)* [ឆ្នាំ ១៨៩៩ និងឆ្នាំ ១៩០៧] បុព្វកថា (Martens Clause), *គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការអនុវត្តទោស៖ របាយការណ៍ដាក់ជូនសន្និសីទសន្តិភាពបឋម* (អនុម័តថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩), *លក្ខន្តិកៈតុលាការ Nuremburg* [ឆ្នាំ ១៩៤៥] មាត្រា៦(ខ) និង (គ), *ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* [ឆ្នាំ ១៩៤៥] មាត្រា II(១)(ខ) និង (គ), *បទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិក ទាក់ទិននឹងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ដែលត្រូវជាប់ចោទក្នុងតំបន់ប៉ាស៊ីហ្វិក I និង II* (ឆ្នាំ ១៩៤៥) បញ្ញត្តិ២(ខ)



PRE-TRIAL ... E.C.C.C. ... PRÉLIMINAIRE

និង ៥, *តុលាការយោធាអន្តរជាតិ* [ឆ្នាំ ១៩៤៥] ដីកាបញ្ជូនទៅជម្រះបទចោទទី៤ ផ្នែក (ក), *សាលក្រមតុលាការ Nuremburg (IMT)* [ឆ្នាំ ១៩៤៦] Vol.I ទំព័រ២២៧, *ធម្មនុញ្ញតុលាការអន្តរជាតិសម្រាប់ចុងបូព៌ា* [ឆ្នាំ ១៩៤៦] មាត្រា៥(គ), *សាលក្រមតុលាការយោធាអន្តរជាតិសម្រាប់ភូមិភាគចុងបូព៌ា* IMT (ក្រុងតូក្យូ) [ឆ្នាំ ១៩៤៨] ជំពូក VIII ទំព័រ១០០១, *គោលការណ៍នៃច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nuremburg និងសាលក្រមតុលាការនេះ* ព្រឹត្តិប័ត្ររបស់គណៈកម្មាធិការ ច្បាប់អន្តរជាតិ Vol.2 [ឆ្នាំ ១៩៥០] ទំព័រ៣៧៧ គោលការណ៍ VI(គ) ទំព័រ៣៧៧, *ព្រឹត្តិប័ត្រគណៈកម្មាធិការច្បាប់អន្តរជាតិ ឯកសារនៃកិច្ចប្រជុំលើកទី៣* Vol.2 [ឆ្នាំ ១៩៥១], *សេចក្តីព្រាងក្រមស្តីពីអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ* គណៈកម្មាធិការច្បាប់អន្តរជាតិ [ឆ្នាំ ១៩៥៤] មាត្រា២(១១), ព្រឹត្តិប័ត្រគណៈកម្មាធិការច្បាប់អន្តរជាតិ ឯកសារនៃកិច្ចប្រជុំលើកទី៦ Volume II [ឆ្នាំ ១៩៥៤], *រឿងក្តីគ្រូពេទ្យ* ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [ឆ្នាំ ១៩៤៧] សាលក្រម Vol.I ទំព័រ១៦ និង Vol.II ទំព័រ១៧៥-១៨០, *រឿងក្តីចៅក្រម* ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង អង្គជំនុំជម្រះ [ឆ្នាំ ១៩៤៧] សាលក្រម Vol.III ទំព័រ៣-៤ ២៣, *រឿងក្តីរដ្ឋមន្ត្រី* ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង អង្គជំនុំជម្រះ [ឆ្នាំ ១៩៤៩] សាលក្រម Vol.XIV ទំព័រ៤៦៧, *រឿងក្តីមេបញ្ជាការជាន់ខ្ពស់* ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង អង្គជំនុំជម្រះ[ឆ្នាំ ១៩៤៨] សាលក្រម Vol.X ទំព័រ២៧-២៩ ៣៦ ៤៦២, *រឿងក្តីចាប់ចំណាប់* ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង អង្គជំនុំជម្រះ[ឆ្នាំ ១៩៤៨] ដីកាបញ្ជូនទៅជម្រះ Vol.XI ទំព័រ៧៧០ សាលក្រម ទំព័រ១២៣២, សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស [ឆ្នាំ ១៩៤៨] មាត្រា ៥, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [ឆ្នាំ ១៩៦៦] (កម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៨០ ផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២) មាត្រា៤(២) ៧, *អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* [ឆ្នាំ ១៩៥០] មាត្រា៣ ១៥(២), *អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស* (អនុម័តថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៦៩ *ចូលជាធរមាន* នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨) មាត្រា៥(២) ២៧(២), *បទបញ្ញា និងបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិ* [ឆ្នាំ ១៩៥០] វិធាន៤, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 2547 XXIV* (ឆ្នាំ ១៩៦៩) កថាខណ្ឌ២-៣ និង៧, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 3103 XXVIII* (ឆ្នាំ ១៩៧៤) កថាខណ្ឌ ៤, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 34/93 H* (ឆ្នាំ ១៩៧៩) កថាខណ្ឌ១ និង៤, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 41/35*, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 3318 XXIX* (ឆ្នាំ ១៩៧៤) កថាខណ្ឌ៥, *សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 3452 XXX* (ឆ្នាំ

១៩៧៥) កថាខណ្ឌ២, *រឿងក្តី* *Corfu Channel* *(អង្គសេចក្តី)* ICJ [ឆ្នាំ ១៩៤៩] សាលក្រម ទំព័រ២២ កថាខណ្ឌ២១៥, *របាយការណ៍រឿងក្តីប្រទេសក្រិច* ECHR [ឆ្នាំ ១៩៦៩] ផ្នែក ខ ជំពូក IV(B)(VI) ផ្នែក ក កថាខណ្ឌ៣៤ ផ្នែក គ កថាខណ្ឌ១៦-១៧ និងផ្នែកឃ កថាខណ្ឌ ២១"[៦៥៦]។

៣៨០. ទាក់ទិននឹងឯកសារយោងដែលបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេត ដូចដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយរួចមកហើយដែរ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ឯកសារយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ០០១ គាំទ្រដល់សេចក្តីសន្និដ្ឋានថា សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មាននៅក្នុងច្បាប់ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់តាំងពីឆ្នាំ ១៩៤៥ មក រួមមាន មាត្រា៦(គ) នៃធម្មនុញ្ញតុលាការ Nuremberg មាត្រា៥(គ) នៃធម្មនុញ្ញតុលាការទីក្រុងតូក្យូ និង មាត្រា II នៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ ឯកសារយោងដទៃដែលបានរៀបរាប់នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ០០១ ដូចដែលបានដកស្រង់នៅក្នុងកថាខណ្ឌនេះនៃដីកាដំណោះស្រាយ ទំនងជាត្រូវបានយកមកប្រើប្រាស់ដើម្បីស្វែងរកនូវអត្ថន័យនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" និងគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា ការហាមឃាត់ប្រឆាំងនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" *ពេលនេះត្រូវបាន*[៦៥៧] បញ្ចូលទៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិក្នុងចំនួនដ៏ច្រើន និងបានបង្កើតជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៦៥៨]។

៣៨១. នៅឆ្នាំ ១៩៤៥ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមថា ធម្មនុញ្ញតុលាការ Nuremberg ត្រូវបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងទីក្រុងឡុងដ៍រវាងប្រទេសបារាំង សហភាពសូវៀត ចក្រភពអង់គ្លេស

---

[៦៥៦] ដីកាដំណោះស្រាយ ជើងទំព័រលេខ៥១៩៤។

[៦៥៧] មិនចាំបាច់ទេ មុនឆ្នាំ ១៩៧៥។

[៦៥៨] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៦៧ ដែលដកស្រង់នៅក្នុងជើងទំព័រលេខ៦៧៤ នូវសាលក្រមសាលាដំបូងលើ *រឿងក្តី* *Celebici* កថាខណ្ឌ៥១៧។ *រឿងក្តី* *រដ្ឋអាជ្ញា* *តទល់នឹង* *Brima* *និងអ្នកដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL (សំណុំរឿងលេខ SCSL-04-16-A) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("សាលដីកាសាលាឧទ្ធរណ៍លើ *រឿងក្តី* *Brima*") កថាខណ្ឌ១៨៣។

និងសហរដ្ឋអាមេរិក[៦៩៩] និងថា នៅចុងឆ្នាំ ១៩៤៥ មានរដ្ឋចំនួន១៩ ផ្សេងទៀត ក៏បានចូលជាសមាជិកហត្ថលេខីចំពោះធម្មនុញ្ញនេះផងដែរ[៧០០]។ ហេតុនេះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ផ្អែកលើច្បាប់សន្ធិសញ្ញា ដែលសំដៅដល់ភស្តុតាងនៃ *ទស្សនៈច្បាប់* របស់រដ្ឋជាហត្ថលេខីទាំងនោះ។ ការបញ្ចូល "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទៅក្នុងមាត្រា៥(គ) នៃធម្មនុញ្ញតុលាការទីក្រុងតូក្យូ[៧០១] និងមាត្រា II(១)(គ) នៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[៧០២] ជាឧទាហរណ៍បញ្ជាក់ពីការអនុវត្តរបស់រដ្ឋ។

៣៨២. សហចៅក្រមស៊ើបអង្កេតក៏បានពឹងផ្អែកផងដែរទៅលើគោលការណ៍ Nuremberg ដែលបានទទួលស្គាល់គោលការណ៍នៃច្បាប់អន្តរជាតិដែលមាននៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងសាលក្រមនៃតុលាការនេះ ហើយបានរៀបរាប់យ៉ាងច្បាស់លាស់[៧០៣]ថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។ អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ពីលក្ខណៈជាទំនៀមទម្លាប់នៃគោលការណ៍ទាំងនេះ ដែលត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តជាឯកច្ឆន្ទនៅឆ្នាំ ១៩៤៦[៧០៤] ហើយគណៈកម្មការច្បាប់អន្តរជាតិចងក្រងគោលការណ៍នេះ នៅឆ្នាំ ១៩៥០[៧០៥] អនុ

---

[៦៩៩] *កិច្ចព្រមព្រៀងលើការជំនុំជម្រះទោស និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃអាក្ស៊ីស៍នៅអឺរ៉ុប* ឯកសារលេខ 82 U.N.T.C. 280 (ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥) ("កិច្ចព្រមព្រៀងទីក្រុងឡុងដ៍")។

[៧០០] ប្រទេសអូស្ត្រាលី បែលហ្ស៊ិក ឆេកូស្លូវ៉ាគី ដាណឺម៉ាក អេត្យូពី ក្រិច ហៃទី ហុងឌូរ៉ាស់ ឥណ្ឌា លុចសំបួរ ហូឡង់ ញូវហ្សេលែន ណ័រវេ ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉ូឡូញ អ៊ុយរ៉ាហ្គាយ វេណេហ្ស៊ុយអេឡា និងយូហ្គោស្លាវី៖ គណៈកម្មការកាកបាទក្រហមអន្តរជាតិ "ច្បាប់មនុស្សធម៌អន្តរជាតិ ភាគីរដ្ឋជាសមាជិក/ហត្ថលេខី៖ កិច្ចព្រមព្រៀងលើការជំនុំជម្រះទោស និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃអាក្ស៊ីស៍នៅអឺរ៉ុប និងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ក្រុងឡុងដ៍ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥" (ឆ្នាំ ២០០៥) http://www.icrc.org/ihl.nsf/WebSign?ReadForm&id=350&ps=P។

[៧០១] ធម្មនុញ្ញទីក្រុងតូក្យូ (IMTFE) មាត្រា៥(គ) (ភាពខុសគ្នាតែមួយគត់នៅក្នុងពាក្យពេចន៍ដែលប្រើប្រាស់នោះគឺ ការលុបសាសនាចេញពីមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញ និងការដាក់បញ្ចូលនូវ ការទទួលខុសត្រូវនៃ "ផែនការរួម" ឬ "ការសមគំនិត")។

[៧០២] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មាត្រាII(១)(គ) ("មុន ឬអំឡុងពេលមានសង្គ្រាម" ត្រូវបានលុបចោល ហើយអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានសង្កត់ធ្ងន់ដោយប្រើឃ្លាថា "រួមបញ្ចូលតែមិនកំណត់ត្រឹមតែ")។

[៧០៣] គោលការណ៍ Nuremberg, គោលការណ៍ VI (គ)។

[៧០៤] ការបញ្ជាក់ពីគោលការណ៍នានានៃច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nuremberg សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 95 (I), U.N. GAOR, 1st Sess., pt. 2 ត្រង់ទំព័រ១១៨៤ ឯកសារលេខ A/236 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។



PRE-TRIAL CHAMBER E.C.C.C. E.T.C. CHAMBRE PRÉLIMINAIRE

លោមតាមសេចក្ដីណែនាំរបស់មហាសន្និបាតឆ្នាំ ១៩៤៧[៧០៦]។ ការគាំទ្រជាឯកច្ឆន្ទដោយសហគមន៍អន្តរជាតិនៅឆ្នាំ ១៩៤៦ ចំពោះធម្មនុញ្ញតុលាការ Nuremberg និងសាលក្រមនៃតុលាការនេះ បង្ហាញយ៉ាងច្បាស់ថា នៅពេលនោះ ការកំណត់ជាបទល្មើសនូវការប្រព្រឹត្ត "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ក្លាយជាវិធានទំនៀមទម្លាប់នៃច្បាប់អន្តរជាតិ។

៣៨៣. និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតត្រូវបានចងក្រងតាមគោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg គឺដកស្រង់ចេញពីបុព្វកថានៃសេចក្ដីប្រកាសនៅទីក្រុង St. Petersburg នៅឆ្នាំ ១៨៦៨ និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩ និង ឆ្នាំ ១៩០៧ ដែលបានអំពាវនាវឱ្យ "ប្រើប្រាស់ទំនៀមទម្លាប់ដែលបានបង្កើតឡើងដោយប្រជាជនដែលមានអារ្យធម៌ខ្ពង់ខ្ពស់ ពីច្បាប់មនុស្សធម៌ និងការបង្គាប់បញ្ជានៃមនសិការសាធារណៈ"[៧០៧] ជាការការពារបន្ទាប់បន្សំប្រឆាំងនឹងអំពើដែលមិនត្រូវបានហាមឃាត់ជាក់លាក់ នៅក្នុងអត្ថបទនៃអនុសញ្ញាទីក្រុងឡាអេទេ[៧០៨]។ ទោះបីគោលការណ៍ VI(គ) បានចែងពីអំពើជាក់លាក់ដែលបង្កើតជា ឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់មនុស្សជាតិក៏ដោយ តែគោលការណ៍បានចែងរៀបរាប់ជាច្រើនចំណុច និងបានរួមបញ្ចូល "អំពើ

---

[៧០៥] គណៈកម្មការច្បាប់អន្តរជាតិ: *គោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់នៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការនេះ (Principles of International Law Recognized in the Charter of the Nuremberg Tribunal and in the Judgment of the Tribunal)* គណៈកម្មការច្បាប់អន្តរជាតិ៖ ឆ្នាំ ១៩៥០ http://untreaty.un.org/ilc/texts/instruments/english/draft%20articles/7_1_1950.pdf

[៧០៦] ការបង្កើតជាគោលការណ៍ដែលទទួលស្គាល់នៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងនៅក្នុងសាលក្រមនៃតុលាការនេះ សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 177(II), 123rd Pl. Mtg. ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧។

[៧០៧] អនុសញ្ញាទីក្រុងឡាអេទី IV ឆ្នាំ ១៨៩៩ បុព្វកថា។ សូមមើលផងដែរ អនុសញ្ញាទីក្រុងឡាអេទី II ឆ្នាំ ១៩០៧ បុព្វកថា។

[៧០៨] សូមមើលផងដែរ *ICRC Commentary on the IVth Geneva Convention Relative to the Protection of Civilian Persons in Time of War* ក្រុងហ្សឺណែវ ឆ្នាំ ១៩៥៨ បោះពុម្ពសាជាថ្មីនៅឆ្នាំ ១៩៩៤ ទំព័រ៣៩ (ទាក់ទិននឹង "ការប្រព្រឹត្តបែបអមនុស្សធម៌" នៅក្នុងមាត្រា៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ឯកសារនេះបានអះអាងថា៖ "ទោះជាមានការយកចិត្តក្នុងការកំណត់ពីទម្រង់ផ្សេងៗនៃការធ្វើបាបក៏ដោយ ក៏គេមិនអាចប្រមើលមើលបានដឹងអស់ពីអ្នកដែលនឹងធ្វើទារុណកម្មនាពេលអនាគត ដែលធ្វើតាមចិត្តខ្លួនដែរ ហើយប្រសិនបើបញ្ជីនោះកាន់តែមានភាពជាក់លាក់ និងពេញលេញពេក នោះកាន់តែធ្វើឱ្យមានការកំហិតកាន់តែតឹងរ៉ឹងទេ")។

អមនុស្សធម៌ផ្សេងៗទៀត” ជាប្រភេទដែលនោះសេសសល់[៧០៩] ដើម្បីបញ្ចៀសមិនឱ្យមានការផ្លាស់ប្តូរច្បាប់មនុស្សធម៌ទេ នៅក្នុងស្មារតីនៃ Martens Clause។

៣៨៤. ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងលក្ខខណ្ឌនៃភាពអាចដឹងថាមានច្បាប់ចែងទាក់ទិននឹង “អំពើអមនុស្សធម៌ផ្សេងៗទៀត” សហមេធាវីការពារក្តី អៀង សារី សន្និដ្ឋានថា ការបកស្រាយមិនស៊ីសង្វាក់គ្នានៃប្រភេទ “អំពើអមនុស្សធម៌ផ្សេងៗទៀត” បង្ហាញនូវកង្វះនូវភាពជាក់លាក់ ហេតុនេះហើយ វារំលោភដល់គោលការណ៍នីត្យានុកូលភាព[៧១០]។ សហមេធាវីការពារក្តីបានយោងទៅដល់យុត្តិសាស្ត្រតុលាការ ICTY ដែលមានភាពចម្រូងចម្រាស់[៧១១]។ ទោះបីអង្គបុរេជំនុំជម្រះមិនអាចដឹងពីរបៀបដែលច្បាប់យុត្តិសាស្ត្រពីដើមទសវត្សរ៍ឆ្នាំ ២០០០ អាចនឹងត្រូវបាននាំអោយមានការភ័ន្តច្រឡំនៅក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក៏ដោយ ក៏អង្គបុរេជំនុំជម្រះពិចារណាឃើញថា អាចនឹងស្របតាមលក្ខខណ្ឌតម្រូវនៃលក្ខណៈពិសេស នៅពេលដែលនិយមន័យនៃបទល្មើសអនុញ្ញាតឱ្យបុគ្គលសម្រេចបានជាមុនថាតើ ការប្រព្រឹត្តជាក់លាក់ នឹង ឬនឹងមិនស្ថិតក្នុងវង្វាស់វង្វាល់នៃបទល្មើសនោះឬទេ។ ចំពោះសំអាងហេតុជាក់លាក់ ចំណុចនេះជាបញ្ហាជាពិសេស នៅក្នុងករណីនៃប្រភេទដែលនៅសេសសល់នៃបទល្មើសដែលជា “អំពើអមនុស្សធម៌ផ្សេងៗទៀត” នេះ[៧១២]។

---

[៧០៩] សាលក្រមលើសំណុំរឿងលេខ០០១ កថាខណ្ឌ៣៦៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-16-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ៥៦៣។

[៧១០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២២០។

[៧១១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ជើងទំព័រលេខ៥២៣ ផ្អែកពី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-16-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ (“សាលក្រមលើ *រឿងក្តី Kupreškić*”) កថាខណ្ឌ៥៦៦ ជាមួយនឹង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-T “សាលក្រម” អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ៧២១។ តែគួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានច្រានចោលនូវគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូង និងបានយល់ស្របតាម *Kupreškić*៖ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* សំណុំរឿងលេខ IT-97-24-A “សាលដីកា” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ៣១៣-៣១៨។

[៧១២] សាលក្រមសាលាដំបូងលើ *រឿងក្តី Kupreškić* កថាខណ្ឌ៥៦៣។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៣៨៥. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានចែងច្បាស់លាស់ពីនិយមន័យនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទេ ហើយអង្គបុរេជំនុំជម្រះក៏មិនបានរកឃើញនូវឧទាហរណ៍ណាមួយស្តីពីនិយមន័យច្បាស់លាស់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងច្បាប់ជាតិ ឬនៅក្នុងទំនៀមទម្លាប់មុនឆ្នាំ ១៩៧៥ ដែរ។ ដើម្បីឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យបែបសត្យានុម័ត ចំពោះលក្ខខណ្ឌនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងលក្ខខណ្ឌនៃភាពអាចដឹងថាមានច្បាប់ចែងបាននេះ គេត្រូវរកឱ្យឃើញយ៉ាងពេញលេញថា សញ្ញាណនៃអំពើឧក្រិដ្ឋមានភាពច្បាស់លាស់នៅក្នុងន័យថា "មានការយល់ដឹងជាទូទៅ" ដោយមិនចាំបាច់យោងទៅដល់ច្បាប់ដែលមានចែងជាលាយលក្ខណ៍អក្សរទេ។ សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានចែងនៅក្នុងច្បាប់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមុនឆ្នាំ ១៩៧៥។ និយមន័យច្បាស់លាស់នៃអំពើនេះមានចែងជាលើកដំបូងនៅក្នុងច្បាប់ គឺនៅក្នុងមាត្រា៧ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ (លក្ខន្តិកៈ ICC) ដែលចែងថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជា "*អំពើនៃលក្ខណៈស្រដៀងគ្នាមួយ* [ទៅលើអំពើនានាដែលមានរៀបរាប់នៅក្នុងមាត្រា៧(១) ពីចំណុច (ក) ដល់ (ញ) *ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបកាយ ឬដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ*]"[៧១៣]។ អំពើមួយចំនួនដែលមានរៀបរាប់នៅក្នុងមាត្រា៧(១) ពីចំណុច(ក) ដល់(ឈ) នៅក្នុងលក្ខន្តិកៈ ICC ដែលដូចបេះបិទទៅនឹងអំពើដែលមានរៀបរាប់នៅក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ។

៣៨៦. និយមន័យជាក់លាក់ដំបូងនៃសញ្ញាណរបស់ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងលក្ខន្តិកៈ ICC មិនមានបញ្ចូលនិយមន័យ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលមានការយល់ដឹងជាទូទៅនោះទេ គឺវាគ្រាន់តែបញ្ជាក់ពីធាតុផ្សំសត្យានុម័តនៃបទល្មើសជាមូលដ្ឋានមួយចំនួនតែប៉ុណ្ណោះ ដោយបង្ហាញសញ្ញាណជាក់លាក់ថា ពីមុន និយមន័យបែបនេះគ្រាន់តែមានលក្ខណៈប្រយោលតែប៉ុណ្ណោះ ហើយនេះអាចសម្រេចបាន តាមវិធីនៃការបកស្រាយមួយគត់[៧១៤]។ ដូចដែលបានលើកឡើងខាងលើរួចមកហើយ អង្គបុរេជំនុំជម្រះយល់ថា អាចមានភាពខុសគ្នារវាងនិយមន័យនៅក្នុងលក្ខន្តិកៈ ICC និងនិយមន័យដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ ១៩៧៥។ ការពិត

---

[៧១៣] លក្ខន្តិកៈទីក្រុងរ៉ូម។

[៧១៤] សូមមើលផងដែរ Antonio Cassese, *International Criminal Law*, Oxford University Press, ឆ្នាំ ២០០៣ ទំព័រ៩១។

ប្រភពខ្លះនៃនិយមន័យបែបនេះគេអាចរកឃើញ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទីពីរ។

៣៨៧. អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា ការពិភាក្សាជាបន្តពីធាតុផ្សំនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបានលេចឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទីពីរ ជាការចាំបាច់ដើម្បីបង្ហាញ ថាតើបទល្មើសនោះមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ត្រឹមឆ្នាំ ១៩៧៥ ឬយ៉ាងណា។

៣៨៨. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងធម្មនុញ្ញតុលាការ Nuremberg ធម្មនុញ្ញទីក្រុងតូក្យូ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg បានចែងនូវអំពើជាក់លាក់ដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទាំង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ផងដែរ។ ពាក្យថា "ផ្សេងៗទៀត" ទាញចេញពី *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* នៃវិធានក្នុងការបកស្រាយ ដែលក្នុងន័យនោះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចត្រឹមតែរួមបញ្ចូលអំពើនានាដែលមានភាព "អមនុស្សធម៌" និងមាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងអំពើដែលមានចែងជាក់លាក់ពោលគឺ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងការនិរទេស[៧១៥]។

៣៨៩. ក្នុងការសន្និដ្ឋានថាទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មានភាពពាក់ព័ន្ធក្នុងការសម្រេចពីខ្លឹមសារនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា វាមិនរំលោភដល់វិធានប្រឆាំងនឹងគោលការណ៍

---

[៧១៥] តុលាការយោធា Nuremberg *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Friedrich និងអ្នកដទៃទៀត* NMT Vol. 6 ("រឿងក្តី Flick") ទំព័រ១២១៥, *Ternek Elsa* (តុលាការក្រុង Tel Aviv ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៥១) 5 Pesakim Mehoziim (ឆ្នាំ ១៩៥១-២) ទំព័រ១៤២-១៥២ (Hebrew), 18 ILR 1951 ទំព័រ៥៤០ (អត្ថបទសង្ខេបជាភាសាអង់គ្លេស កត់សម្គាល់ពីការរៀបរាប់ខុសថាជា "Tarnek"), *Enigster Yehezkel Ben Alish* (តុលាការក្រុង Tel Aviv ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៥២) 5 Pesakim Mehoziim (ឆ្នាំ១៩៥១-២) ទំព័រ ១៥២-១៨០ (Hebrew); ILR 18 ទំព័រ៥៤១-៥៤២ (អត្ថបទសង្ខេបជាភាសាអង់គ្លេស), សូមមើល *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreskic និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-16-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ៥៦៤៖ "វិធានដែលអាចយកទៅបកស្រាយបាននេះ មិនមានភាពច្បាស់លាស់ទេ ហើយវាមានលក្ខណៈទូទៅពេក ក្នុងការចែងពីវិធានការសុវត្ថិភាពសម្រេចការងាររបស់តុលាការ"។

00661739



សទិសភាព ដែលមាននៅក្នុងយុត្តាធិការផ្នែករដ្ឋប្បវេណីទេ[៧១៦]។ ចំពោះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ការយកបទល្មើសមួយតាមរយៈសទិសភាពមកអនុវត្តចំពោះការប្រព្រឹត្តដែលមិនមានចែងក្នុងច្បាប់ *(គោលការណ៍ analogia lexis)* ខុសប្លែកពីការយកប្រភេទរងមួយនៅក្នុងបទល្មើសមួយតាមរយៈសទិសភាព មកអនុវត្តចំពោះប្រភេទរងមួយទៀតនៅក្នុងបទល្មើសនោះ ក្នុងគោលបំណងបញ្ជាក់ឱ្យបានច្បាស់ពីនិយមន័យនៃប្រភេទរងមួយទៀតនោះ។ នៅក្នុងយន្តការទីពីរនេះ ប្រសិនបើការប្រព្រឹត្តដែលកំពុងពិភាក្សានោះ ស្ថិតទៅក្នុងនិយមន័យរបស់បទល្មើសនោះ ហេតុនេះការពិតវាជាការប្រព្រឹត្តដែល*មានចែងក្នុងច្បាប់* ហេតុនេះសំអាងហេតុនៃវិធានប្រឆាំងនឹងគោលការណ៍សទិសភាពមិនត្រូវយកមកអនុវត្តទេ[៧១៧]។ ភាពខុសគ្នានេះមិនអាចចៀសវាងបានទេ នៅពេលដែលត្រូវពិចារណាបន្ថែមទៀតថា ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងជាក់លាក់ជាបទល្មើសមួយសេសសល់ ដើម្បីបញ្ចៀសនូវភាពចន្លោះប្រហោងនៅក្នុងច្បាប់ ហើយថាពាក្យនេះមិនមានន័យទេ ប្រសិនបើមិនយក *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មកអនុវត្ត។

៣៩០. បណ្តាចៅក្រមដែលចេញយុត្តិសាស្ត្រនៃតុលាការ NMT បានប្រើប្រាស់ទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)*[៧១៨] ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាតើ ការដកហូតយកទ្រព្យសម្បត្តិត្រូវស្ថិតនៅក្នុងនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអំពើដែលមិនបានកំណត់ដោយច្បាប់។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Flick* និងបន្ទាប់មកគឺនៅក្នុងរឿងក្តី *I. G. Farben* តុលាការបានសម្រេចថា បទល្មើសដែលមានចែងនៅក្នុងបញ្ញត្តិ

---

[៧១៦] សូមមើល បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ កថាខណ្ឌ៤៩-៥១ ដែលបានលើកជាទឡ្ហីករណ៍សំអាងថា "អំពើហិង្សាផ្លូវភេទ" និង "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអាចកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" តាមបែបសទិសភាព ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានការទទួលស្គាល់នោះទេ"។

[៧១៧] មានអ្នកធ្វើអត្ថាធិប្បាយផ្នែកច្បាប់ ជាច្រើនបានចាត់ទុក *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* ជាករណីលើកលែងមួយប្រឆាំងនឹងវិធាននៃសទិសភាព។ សូមមើលជាឧទាហរណ៍ Antonio Cassese, *International Criminal Law*, Oxford University Press, ឆ្នាំ ២០០៣ ទំព័រ១៥៣-១៥៦។

[៧១៨] អត្ថន័យជាភាសាអង់គ្លេសនៃពាក្យឡាតាំង *ejusdem generis* គឺមានន័យថា៖ "ជាគោលការណ៍នៃការចងក្រងបញ្ចូលគ្នា នៅពេលដែលពាក្យពេចន៍ ឬឃ្លាមួយដែលមានន័យទូទៅមានភ្ជាប់នូវភាពជាក់លាក់មួយចំនួនបែបនេះ ពាក្យ ឬឃ្លាដែលមានន័យទូទៅនោះនឹងត្រូវយកទៅបកស្រាយ ដើម្បីបញ្ចូលតែភាពជាក់លាក់មួយចំនួនដែលមានប្រភេទដូចគ្នាតែប៉ុណ្ណោះ" វចនានុក្រម Black's Law Dictionary។

ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រងគឺជាបទល្មើសទាំងអស់ ដែលប្រឆាំងនឹងមនុស្ស ហើយហេតុនេះ "ត្រូវតែចាត់ទុកថាបានបញ្ចូលត្រឹមតែការប៉ះពាល់ទៅដល់ជីវិត និងសេរីភាពរបស់មនុស្សដែលត្រូវគេសង្កត់សង្កិនតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី អ្វីដែលគួរឱ្យបន្ទោស ការដកហូតយកទ្រព្យសម្បត្តិឧស្សាហកម្មចាំបាច់ មិនស្ថិតនៅក្នុងប្រភេទនេះទេ"[៧១៩]។ នៅក្នុង *រឿងក្តី Eichmann* តុលាការកំពូលអ៊ីស្រាអែលបានសម្រេចថា "ការបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត" អាចចាត់ទុកជាអំពើអមនុស្សធម៌មួយទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល ដែលកំណត់ដោយពួកណាហ្ស៊ី និងច្បាប់ (ការផ្តន្ទាទោស) ស្តីពីអ្នកសហការណាហ្ស៊ី ផ្នែក១(ក) ដែលបង្កើតឡើងវិញនូវ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញ Nuremberg (IMT)[៧២០]។ តុលាការកំពូលនេះក៏បានសម្រេចផងដែរថា ការរឹបអូសទ្រព្យសម្បត្តិអាចត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌មួយ នៅក្នុងន័យនៃនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅពេលដែល ក្នុងចំណោមចំណុចដទៃទៀត "វាមានទំនាក់ទំនងទៅនឹងអំពើហិង្សាដទៃទៀតដែលកំណត់ដោយច្បាប់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬដែលជាលទ្ធផលណាមួយនៃអំពើណាមួយនៃអំពើទាំងនោះ មានន័យ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបង្អត់អាហារ ឬ ការនិរទេសប្រជាជនស៊ីវិល ដែលការរឹបអូសទ្រព្យសម្បត្តិគឺត្រឹមតែជាផ្នែកមួយនៃដំណើរការទូទៅប៉ុណ្ណោះ"[៧២១]។ ក្នុងរឿងក្តីនោះ Eichmann ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទរឹបអូសទ្រព្យសម្បត្តិរបស់ជនជាតិជ្វីហ្វ ដែលជាផ្នែកមួយនៃនីតិវិធីនៃការបំបរបង់មនុស្ស ដែលតុលាការកំពូលនេះសម្រេចថា ត្រូវបានចាត់ទុកជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត[៧២២]។ នៅក្នុងរឿងក្តី *រដ្ឋមន្ត្រី* តុលាការចាត់ទុកការរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួន ខុសប្លែកពីទ្រព្យសម្បត្តិឧស្សាហកម្ម និងបានពិចារណាថា ការរឹបអូសទ្រព្យ

---

[៧១៩] រឿងក្តី *Flick,* Vol. VI ទំព័រ១២១៥ ត្រូវបានគាំទ្រនៅក្នុង *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Carl Krauch និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials,* Vols VII-VIII ទំព័រ១ ("រឿងក្តី *I. G. Farben*") Vol. VIII ទំព័រ១១៣០។

[៧២០] រឿងក្តី *Eichmann* កថាខណ្ឌ២០៤។

[៧២១] រឿងក្តី *Eichmann* កថាខណ្ឌ២០៤។

[៧២២] រឿងក្តី *Eichmann* កថាខណ្ឌ២០៤-២០៥។ សូមមើលផងដែរ រឿងក្តី *រដ្ឋមន្ត្រី* ដោយយោងទៅរឿងក្តី *Eichmann,* Vol. XIV ទំព័រ៨៩០-៨៩១ (ដែលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ Schwerin von Krosigk ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ចំពោះការផ្ទេរទ្រព្យសម្បត្តិរបស់ជនជាតិជ្វីហ្វ នៅពេលបណ្តេញពួកគេចេញពីលំនៅដ្ឋាន)។

សម្បត្តិចាត់ទុកជាអំពើអមនុស្សធម៌មួយ ដែលនៅពេលប្រព្រឹត្តអំពើនោះ *វាជាផ្នែកមួយនៃអំពើគួរឱ្យរន្ធត់ទ្រង់ទ្រាយធំ* ប្រឆាំងនឹងប្រជាជនស៊ីវិល ឬ *នៅពេលដែលវាមានទំនាក់ទំនងទៅនឹងអំពើហិង្សា ផ្សេងៗទៀត* ដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៧២៣]។

៣៩១. បន្ថែមលើការប្រើប្រាស់ទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* ដែលទាក់ទិននឹងអំពើដែលបានកំណត់នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា និយមន័យនេះក៏មានភាពច្បាស់លាស់ផងដែរ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ Nuremberg ដែលថា ក្នុងការទាក់ទងជាប្រចាំជាមួយឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមគ្នា តុលាការទាំងនេះបានពឹងផ្អែកលើវិសាលភាពឧក្រិដ្ឋកម្មសង្គ្រាម ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដើម្បីបញ្ជាក់ពីខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ ឬប្រជាជនស៊ីវិល នៅក្នុងទឹកដីដែលកាន់កាប់ដោយពួកណាហ្ស៊ី។

៣៩២. នៅក្នុងរឿងក្តី *ចៅក្រម* តុលាការបានកត់សម្គាល់ថា "យុត្តាធិការ" របស់តុលាការទាំងនោះ "ក្នុងការជំនុំជម្រះបុគ្គលដែលត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំហិតវិសាលភាពទាំងនិយមន័យ និងការពន្យល់ ដូចដែលមានចែងនៅក្នុង [ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង]"[៧២៤]។ តុលាការនេះបានពិចារណាទៅលើចំណុចនេះជាសំខាន់ថា បញ្ញត្តិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានប្រើប្រាស់ពាក្យថា *"ប្រឆាំងប្រជាជនស៊ីវិលណាក៏ដោយ"* ជំនួសឱ្យពាក្យថា "ប្រឆាំងជនស៊ីវិលណាម្នាក់"[៧២៥] ដោយសន្និដ្ឋានថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងក្នុង [ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង] ត្រូវតែយល់ឱ្យបានច្បាស់ថា វាមិនរាប់បញ្ចូលករណីអំពើសាហាវឃោរឃៅ ឬការធ្វើទុក្ខបុកម្នេញតែមួយដាច់ដោយឡែកនោះទេ"[៧២៦]។ នៅក្នុង

---

[៧២៣] "រឿងក្តី *រដ្ឋមន្ត្រី*" (*រឿងក្តីសហរដ្ឋអាមេរិក តទល់នឹង Ernst von Weizsaecker និងអ្នកដទៃទៀត*) សំណុំរឿងលេខ១១ NMT Vol. 14 ទំព័រ៣៤៤, ៩៨១។ សូមមើលផងដែរ ការបកស្រាយនៅក្នុង *រឿងក្តី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អ៊ីស្រាអែល តទល់នឹង Eichmann* (តុលាការអ៊ីស្រាអែលក្រុង ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៦១) 36 ILR 5 (ឆ្នាំ ១៩៦២) កថាខណ្ឌ២០៤។

[៧២៤] តុលាការយោធា Nuremberg *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Josef Altstoetter និងអ្នកដទៃទៀត* សំណុំរឿងលេខ៣ ("រឿងក្តី *ចៅក្រម*") ទំព័រ៩៧៣។

[៧២៥] រឿងក្តី *ចៅក្រម* ទំព័រ៩៧៣។

[៧២៦] រឿងក្តី *ចៅក្រម* ទំព័រ៩៨២។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

រឿងក្តី *ចៅក្រម* ចុងចោទត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទ "ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ និងអំពើព្រៃផ្សៃ អំពើសាហាវឃោរឃៅ និងអំពើអមនុស្សធម៌ផ្សេងៗទៀតប្រឆាំងនឹងមនុស្សរាប់ពាន់នាក់" ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[៧២៧]។ ក្នុងករណីនោះ នៅពេលដែលឆ្លើយទៅនឹងបញ្ហាដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាការរំលោភច្បាប់អន្តរជាតិ ចៅក្រមទាំងនោះបានអះអាងថា "ជាសង្ខេប ការចោទប្រកាន់ទោសគឺសំដៅដល់ការចូលរួមផ្នែកមនសិការទៅក្នុងប្រព័ន្ធនៃអំពើសាហាវឃោរឃៅ និងអយុត្តិធម៌ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងទូទាំងប្រទេស *ក្នុងការរំលោភដល់ច្បាប់ស្តីពីសង្គ្រាម និងច្បាប់ស្តីពីមនុស្សធម៌*"[៧២៨]។

៣៩៣. នៅក្នុងរឿងក្តី *គ្រូពេទ្យ* ឧក្រិដ្ឋកម្មសង្គ្រាមស្តីពីការប្រព្រឹត្ត "ការពិសោធន៍វេជ្ជសាស្ត្រ" ដោយគ្មានការព្រមព្រៀង[៧២៩] ប្រឆាំងនឹងប្រជាជនដែលមិនមែនជាជនជាតិអាល្លឺម៉ង់ និងកងកម្លាំងប្រដាប់អាវុធ ក៏ត្រូវបានចោទប្រកាន់ និងរកឃើញពិរុទ្ធភាពផងដែរ ដើម្បីបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់[៧៣០]។

៣៩៤. នៅក្នុងរឿងក្តីរដ្ឋមន្ត្រី ចុងចោទត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសតាមបទចោទទី៥ ពីបទ៖

---

[៧២៧] រឿងក្តី *ចៅក្រម* ទំព័រ៣-៤, ១៩, ២៣។

[៧២៨] រឿងក្តី *ចៅក្រម* ទំព័រ៩៨៥។

[៧២៩] *អនុសញ្ញាសម្រាប់កែលម្អលក្ខខណ្ឌរបស់អ្នកជំងឺ និងអ្នករបួសនៅក្នុងកងកម្លាំងប្រដាប់អាវុធនៅទីសមរភូមិ* ឯកសារលេខ 75 U.N.T.S. 31 (អនុញ្ញាតឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥0) ("អនុសញ្ញាទីក្រុងហ្សឺណែវទី១") មាត្រា១២។ *អនុសញ្ញាទីក្រុងហ្សឺណែវសម្រាប់កែលម្អលក្ខខណ្ឌសមាជិកកងកម្លាំងប្រដាប់អាវុធដែលមានរបួស ជំងឺ និងលិចនាវានៅសមុទ្រ* ឯកសារលេខ 75 U.N.T.S. 85 (អនុញ្ញាតឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥0) ("អនុសញ្ញាទីក្រុងហ្សឺណែវទី២") មាត្រា១២។ *អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងទៅនឹងការប្រព្រឹត្តចំពោះអ្នកទោសសង្គ្រាម* ឯកសារលេខ 75 U.N.T.S. 135 (អនុញ្ញាតឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥0) ("អនុសញ្ញាទីក្រុងហ្សឺណែវទី៣") មាត្រា១៣។ *អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម* ឯកសារលេខ 75 U.N.T.S. 287 (អនុញ្ញាតឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥0) ("អនុសញ្ញាទីក្រុងហ្សឺណែវទី៤") មាត្រា៣២។

[៧៣០] "រឿងក្តីគ្រូពេទ្យ" (*រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Karl Brandt និងអ្នកដទៃទៀត*) សំណុំរឿងលេខ១ NMT Vol. 1 ទំព័រ១៦ Vol. 2 ទំព័រ១៧៤-១៨0, ១៩៨។

ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពួកគេបានចូលរួមក្នុងអំពើឃោរឃៅ និងបទល្មើស រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់ចំណាប់ខ្មាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ និងអំពើឧក្រិដ្ឋផ្សេងៗទៀត ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ និងសមាជិកនៃប្រជាជនស៊ីវិលនៃបណ្តាប្រទេស និងទឹកដីដែលស្ថិតក្រោមការកាន់កាប់បែបប្រទូស្តរ៉ាយ ឬដែលបានត្រួតត្រាតាមវិធីផ្សេងទៀតដោយប្រទេសអាល្លឺម៉ង់ [...][៧៣១]។

៣៩៥. អាស្រ័យហេតុនេះ ដោយសារ ត្រឹមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មានចែងពី ធាតុផ្សំ *រួម* និងធាតុផ្សំ *សត្យានុម័ត* អង្គបុរេជំនុំជម្រះយល់ឃើញថា បទល្មើសសកម្ម ឬអកម្មមួយដែលរងការជំទាស់បានបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មួយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលអំពើនោះមាន*លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា* ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ឬការនិរទេសដែល៖ ១) វាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅនឹងជីវិត ឬសេរីភាពរបស់មនុស្ស រួមមាន*ការធ្វើបាបដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់រាយកាយ និងផ្លូវចិត្តទៅលើមនុស្ស* ឬ ២) *មានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិណាមួយដែលបានរៀបរាប់* តាមវិធីផ្សេងទៀត។ នៅក្នុងទិដ្ឋភាពនេះ គេអាចប្រមើលមើលជាមុនថា អំពើនានាត្រូវបានហាមឃាត់ដោយបញ្ញត្តិអន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ *ដោយផ្អែកលើមូលដ្ឋានអមនុស្សធម៌ ក៏នឹងត្រូវបានហាមឃាត់ស្រដៀងគ្នានេះដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ*។ និយមន័យនៃពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទំនងជាសំដៅដល់អំពើនានាដែលនឹងត្រូវចាត់ទុកជាការរំលោភធ្ងន់ធ្ងរ ឬការបំពារបំពានធ្ងន់ធ្ងរ *ដែលក្នុងចំណោមនោះ* មាន បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩ បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩ និង អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលចែងថា អំពើទាំងនោះស្របទៅនឹងលក្ខខណ្ឌតម្រូវជាក់លាក់ដទៃទៀតនៅក្នុងលិខិតុបករណ៍ទាំងនេះ។

---

[៧៣១] រឿងក្តី *វល្លមន្ត្រី* ទំព័រ៤៦៧-៦៨។ សូមមើលផងដែរ រឿងក្តី *មេបញ្ជាការជាន់ខ្ពស់* Vol. X ទំព័រ២៩, ៣៦ Vol. XI ទំព័រ ៤៦៣-៤៦៥។ រឿងក្តី *ចាប់ពង្រត់* Vol. XI ទំព័រ៧៦៥-៧៦៦, ៧៦៩-៧០, ១២៣៣-៣៤, ២៦២ និងបន្ទាប់។

៣៩៦. ផ្អែកទៅលើអំណះអំណាងដែលមានពីមុនៗ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទោះបីត្រឹមឆ្នាំ ១៩៧៥ មិនទាន់មានការកំណត់ច្បាស់លាស់ ឬពេញលេញ ពីធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមការយល់ឃើញរបស់យើងនាសម័យបច្ចុប្បន្នក៏ដោយ ក៏គោលការណ៍ដែលថា បុគ្គលម្នាក់អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទល្មើសដែលមាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានរៀបរាប់ដទៃទៀត ដែលត្រូវបានបង្កើតឡើង និងមានការយល់ដឹងជាទូទៅដែរ។

៣៩៧. ទាក់ទិននឹងបញ្ហាចុងក្រោយដែលថាតើ សហចៅក្រមស៊ើបអង្កេតមាន ឬមិនមានការភ័ន្តច្រឡំក្នុងការចោទប្រកាន់ទោសពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ តាមនិយមន័យ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបានរៀបរាប់ពីមុននោះ អង្គបុរេជំនុំជម្រះ យល់ឃើញថា ចំណុចនេះបានបង្កើតឲ្យមានបញ្ហាលាយឡំគ្នារវាងអង្គច្បាប់ និងអង្គហេតុ។ ក្នុងទិដ្ឋភាពនេះ វាមិនមែនជាបញ្ហាផ្នែកយុត្តាធិការដែលត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះអនុលោមតាមវិធាន៧៤(៣)(ក)ទេ តែវាជាបញ្ហាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចនៅក្នុងសវនាការ។

៣៩៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនត្រឹមតែមានចែងក្នុងច្បាប់ត្រឹមឆ្នាំ ១៩៧៥ ប៉ុណ្ណោះទេ តែ អៀង សារី ក៏អាចដឹងលក្ខខណ្ឌនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងលក្ខខណ្ឌនៃភាពអាចដឹងថាមានច្បាប់ចែងដែលថា ខ្លួនអាចនឹងត្រូវទទួលការចោទប្រកាន់ទោសពីបទល្មើសទាំងនោះដែលបានប្រព្រឹត្តក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ អាស្រ័យហេតុនេះ មូលដ្ឋានរងទី១៥, ១៦, ១៧ និង១៩ នៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោល។

### ៦) មូលដ្ឋានទីដប់មួយ (ការទទួលខុសត្រូវរបស់ថ្នាក់លើ)៖

<u>សេចក្តីសង្ខេបទឡ្ហីករណ៍នានា៖</u>

<u>ទឡ្ហីករណ៍របស់សហមេធាវីការពារក្តី អៀង សារី លើបណ្តឹងឧទ្ធរណ៍៖</u>

៣៩៩. សហមេធាវីការពារក្តី អៀង សារី អះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតភ័ន្តច្រឡំក្នុងការយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយហេតុថា ការទទួលខុសត្រូវរបស់ថ្នាក់លើពុំមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ[៧៣២]។ សហមេធាវីការពារក្តីជំទាស់ថា ក) ច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ មិនកំណត់ច្បាស់លាស់អំពីធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើទេ[៧៣៣] ខ) ទម្លាប់អនុវត្តរបស់រដ្ឋមិនបានបង្ហាញថា ទំនៀមទម្លាប់មានអត្ថិភាពឡើយមុនឆ្នាំ ១៩៧៥[៧៣៤] និង គ) ពិធីសារបន្ថែមទី១ នៃអនុសញ្ញាទីក្រុង ហ្សឺណែវ មិនបានបញ្ចូលទៅក្នុងទម្លាប់អន្តរជាតិទេ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ[៧៣៥]។

៤០០. សហមេធាវីការពារក្តីកត់សម្គាល់ថា គ្មានអត្ថបទច្បាប់បង្កើតតុលាការក្រោយសង្គ្រាមលោកលើកទីពីរ មានចែងនូវបទប្បញ្ញត្តិដែលបានចែងអំពីទម្រង់នៃការទទួលខុសត្រូវនេះទេ[៧៣៦]។ សហមេធាវីលើកទឡ្ហីករណ៍ថា ទោះបីជាតុលាការទាំងនេះបានភ្ជាប់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើយ៉ាងណាក៏ដោយ ក៏ការជំនុំជម្រះក្តីទាំងនេះមានតម្លៃមានដែនកំណត់នៅក្នុងការវាយតម្លៃអំពីអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារតែ "សេចក្តីសម្រេចគឺខ្លី និងមានការបញ្ជាក់សំអាងហេតុផលមានកម្រិតបើសិនជាមាន"[៧៣៧] ហើយសេចក្តីសម្រេចនីមួយៗ បង្ហាញនូវទិដ្ឋភាពជាច្រើនដែលមិនស៊ីសង្វាក់គ្នាស្តីពីធាតុផ្សំអត្តនោម័តដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ឲ្យមានទំនួលខុសត្រូវ[៧៣៨]។

---

[៧៣២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៣។

[៧៣៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៥-២៩២។

[៧៣៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៩៣-២៩៧។

[៧៣៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៩៨-៣០២។

[៧៣៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៦ យោងទៅលើធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ Nuremberg ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ និងធម្មនុញ្ញតុលាការ IMTFE ទីក្រុងតូក្យូ និងដកស្រង់ Greg R. Vetter *ការទទួលខុសត្រូវរបស់ថ្នាក់លើនៃថ្នាក់លើដែលមិនមែនជាយោធានៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ*, 25 Yale J. Int'l L. 89, 105-06 (2000)

[៧៣៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៧។

[៧៣៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៨-២៩១។

៤០១. សហមេធាវីការពារក្តីអះអាងថា រដ្ឋភាគច្រើនពុំបានដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើទៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួនឡើយ ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៧៣៩] ហើយថា បទប្បញ្ញត្តិទាំងនោះដែលមានមក "មិនស្របគ្នាសមល្មម នឹងអាចយកជាមូលដ្ឋាននៃទម្លាប់អនុវត្តរបស់រដ្ឋដែលមានទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែលជាតម្រូវការក្នុងការស្វែងរកច្បាប់ទំនៀម ទម្លាប់អន្តរជាតិបានទេ"[៧៤០]។

៤០២. សហមេធាវីការពារក្តីកត់សម្គាល់ថា មាត្រា៨៦ និងមាត្រា៨៧ នៃពិធីសារបន្ថែមទី១ ដែលចូលជាធរមានក្នុងឆ្នាំ១៩៧៧ បង្ហាញជាលើកដំបូងថា ទោសព្រហ្មទណ្ឌចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានកំណត់នៅក្នុងច្បាប់អន្តរជាតិ[៧៤១] ហើយថាការរៀបចំពិធីសារទាំងនោះ ផ្តល់នូវភស្តុតាងបន្ថែម ថាពិតជាមិនមានការព្រមព្រៀងគ្រប់គ្រាន់នៅក្នុងសហគមន៍អន្តរជាតិ ទាក់ទិននឹងធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីបង្កើតបានជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៧៤២]។ សហមេធាវីការពារក្តីលើកឡើងទៀតថា ពិធីសារបន្ថែមទី១ ពុំចងកាតព្វកិច្ចលើប្រទេសកម្ពុជាឡើយនៅពេលដែលពិធីសារនេះចូលជាធរមាន[៧៤៣] ហើយថា នៅពេលដែលពិធីសារនេះបានចូលជាធរមានពិធីសារនេះ គ្រាន់តែដាក់កាតព្វកិច្ចទៅលើរដ្ឋប៉ុណ្ណោះ និងពុំបានចែងឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ[៧៤៤]។ សហមេធាវីការពារក្តីបន្ថែមទៀតថា ពាក្យពេចន៍នៃមាត្រា៨៧ នៃពិធីសារបន្ថែមទី១ បញ្ចូលការទទួលខុសត្រូវសម្រាប់មេបញ្ជាការយោធាប៉ុណ្ណោះ[៧៤៥]

---

[៧៣៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ជើងទំព័រ ៧១៣ កំណត់សម្គាល់ "ប្រទេសមួយចំនួនតូចដែលបង្កើតជាច្បាប់សម្រាប់អនុវត្តទៅការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានបញ្ជាក់ក្នុងតារាង *មូលដ្ឋានទិន្នន័យនៃការអនុវត្តច្បាប់ជាតិ នៅលើគេហទំព័ររបស់* តុលាការព្រហ្មទណ្ឌអន្តរជាតិ (National Implementing Legislation Database on the ICC website) *អាចរកបាននៅឯគេហទំព័រ* http://iccdb.webfactional.com/data/keyword/569/។

[៧៤០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៩៣-២៩៦។

[៧៤១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៨។

[៧៤២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៩៩-៣០០។ បណ្តឹងឧទ្ធរណ៍បញ្ជាក់ថា ការពិតដែលថា មាត្រា៨៦ ត្រូវបានធ្វើសេចក្តីព្រាងឡើងវិញចំនួន ៥ដង បង្ហាញថា អ្វីដែលបានព្រមព្រៀងគ្នានោះ គឺជាការស្រុះស្រួលគ្នារវាងរដ្ឋនិងរដ្ឋ ពុំមែនជាការឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមានឡើយ។

[៧៤៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣០០។ បណ្តឹងឧទ្ធរណ៍កត់សម្គាល់ថា មានតែរដ្ឋចំនួនបីប៉ុណ្ណោះដែលផ្តល់សច្ចាប័នលើពិធីសារបន្ថែម ត្រឹមឆ្នាំ១៩៧៨ ហើយថា ប្រទេសកម្ពុជាពុំបានចុះហត្ថលេខាលើពិធីសារបន្ថែមនេះទេ។

[៧៤៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣០១-៣០២។

[៧៤៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣១៥។

ហើយថា របាយការណ៍ចុងក្រោយ ឆ្នាំ១៩៩៤ របស់គណៈកម្មការជំនាញស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ មានទស្សនៈនេះដូចគ្នា ដោយបានបញ្ជាក់ថា "ករណីតាមច្បាប់ភាគច្រើនដែលពិចារណាទៅដល់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនេះ គឺមានការពាក់ព័ន្ធទៅនឹងជនជាប់ចោទជាយោធា ឬជាកងជីវពល"[៧៤៦]។ សហមេធាវីការពារក្តីជំទាស់ថា មិនមានទម្លាប់អនុវត្តរបស់រដ្ឋយ៉ាងទូលំទូលាយ និងស៊ីសង្វាក់គ្នា នៅត្រឹមឆ្នាំ ១៩៧៥-១៩៧៩ ក្នុងការដាក់បន្ទុកនូវការទទួលខុសត្រូវព្រហ្មទណ្ឌដល់ថ្នាក់លើដែលជាជនស៊ីវិល ចំពោះអំពើដែលប្រព្រឹត្តដោយអ្នកក្រោមឱវាទរបស់ខ្លួនឡើយ[៧៤៧]។

<u>ចម្លើយតបរបស់សហព្រះរាជអាជ្ញា និងកំណត់សម្គាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី៖</u>

៤០៣. នៅក្នុងចម្លើយតបទៅនឹងការលើកឡើងរបស់ អៀង សារី សហព្រះរាជអាជ្ញាអះអាងថា ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលអាចអនុវត្តបាននៅ អ.វ.ត.ក ពីព្រោះវាបានបំពេញបុរេលក្ខខណ្ឌចំនួនបួន ដែលបានកំណត់ដោយអង្គជំនុំជម្រះនេះនៅក្នុងសេចក្តីសម្រេចអំពីសហឧក្រិដ្ឋកម្មរួមដែលទម្រង់នៃការទទួលខុសត្រូវ ត្រូវតែបំពេញឱ្យបានដើម្បីឱ្យស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយបុរេលក្ខខណ្ឌទាំងបួននេះរួមមាន៖ ១) វាត្រូវតែមានចែងនៅក្នុង [ច្បាប់ អ.វ.ត.ក] ទោះចែងច្បាស់ក្តី ឬប្រយោលក្តី ២) វាត្រូវមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលពាក់ព័ន្ធ ៣) ច្បាប់ដែលមានចែងអំពីទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចដឹងឱ្យបានគ្រប់គ្រាន់ នៅពេលពាក់ព័ន្ធចំពោះបុគ្គលដែលបានធ្វើអំពើនោះ។ ៤) ជននោះត្រូវតែអាចប្រមើលដឹងជាមុនថា គាត់នឹងត្រូវដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនប្រសិនបើរកឃើញ[៧៤៨]។

---

[៧៤៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣១៥។ ដកស្រង់របាយការណ៍ចុងក្រោយរបស់គណៈកម្មការជំនាញការ ដែលបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ 780 (1992) UN Doc. S/1994/647 ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៤ ទំព័រ ១៦។

[៧៤៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣១៤។

[៧៤៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១០ ដកស្រង់ សាលដីកាស្តីពី JCE កថាខណ្ឌ ៤៣។

៤០៤. សហព្រះរាជអាជ្ញាលើកឡើងថា បុរេលក្ខខណ្ឌទីមួយត្រូវបានបំពេញ ពីព្រោះមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ចែងយ៉ាងច្បាស់អំពីការអនុវត្តចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ[៧៤៩]។ ទាក់ទិននឹង បុរេលក្ខខណ្ឌទីពីរ សហព្រះរាជអាជ្ញាលើកឡើងថា ត្រឹមឆ្នាំ ១៩៧៥ ទ្រឹស្តីនៃការទទួលខុសត្រូវ របស់ថ្នាក់លើ "ត្រូវបានកំណត់យ៉ាងម៉ឺងម៉ាត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[៧៥០]។ ចំណុចនេះ ដែលត្រូវបានជំទាស់ ត្រូវបានបង្ហាញឡើងតាមរយៈ "សិទ្ធិអំណាចដ៏ក្រាស់ក្រែល" រួមមានលិខិតុប ករណ៍អន្តរជាតិដែលសំដៅទៅលើការបញ្ហាប្រកបដោយការទទួលខុសត្រូវ[៧៥១] និងក្រោយមកទៀត សំដៅទៅលើការ ទទួលខុសត្រូវរបស់ថ្នាក់លើ[៧៥២] ច្បាប់ជាតិ[៧៥៣] និងសៀវភៅក្បួនយោធាជាតិ[៧៥៤] និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី១[៧៥៥] និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោក លើកទី២[៧៥៦]។ សហព្រះរាជអាជ្ញាលើកទទួលស្គាល់ករណីថា ពិធីសារបន្ថែមទី១ បានធ្វើឲ្យច្បាប់ទំនៀម

---

[៧៤៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២១២-២១៣។

[៧៥០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២១៤។

[៧៥១] អនុសញ្ញាទីក្រុងឡាអេ (IV) ស្តីអំពីច្បាប់ និងទម្លាប់សង្គ្រាមជើងគោក និងឧបសម្ពន្ធ៖ បទបញ្ញា ស្តីពីច្បាប់ និងទម្លាប់ សង្គ្រាមជើងគោក ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ១៩០៧ U.S.T.S. 539, មាត្រា១។ អនុសញ្ញាទីក្រុងហ្សឺណែវ (III) ទាក់ទិន នឹងការប្រព្រឹត្តលើឈ្លើយសឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ 75 U.N.T.S. 135 មាត្រា ១៨, ៣៣។

[៧៥២] គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កើតសង្គ្រាម និង ស្តីពីការអនុវត្តការដាក់ទណ្ឌកម្ម – របាយការណ៍ត្រូវបាន ដាក់ បង្ហាញនៅសន្និសីទសន្តិភាពបឋម ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩១៩ ដែលបានបោះពុម្ពឡើងវិញក្នុង Violations of the Laws and Customs of War 24 (1919)។ សន្ធិសញ្ញា Versailles ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩១៩ មាត្រា ២២៨។

[៧៥៣] Ordonnance du 28 août 1944 relative à la répression des crimes de guerre, Art. 4 (1944) (France)។ ច្បាប់ស្តីពី ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម ថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៤៦ មាត្រា ៩ ឆ្នាំ ១៩៤៦ (ប្រទេសចិន) ឆ្នាំ១៩៥០។ Loi du 2 août 1947 sur la repression des crimes de guerre, Grand-Duché de Luxembourg, Art. 3, 1947 (Luxemburg) ។ ច្បាប់ ខែកក្កដា ឆ្នាំ១៩៤៧ មាត្រា 27(a)(3)(1947) ការធ្វើវិសោធនកម្មក្រឹត្យច្បាប់ព្រហ្មទណ្ឌវិសាមញ្ញ ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៤៣ (ប្រទេសហូឡង់)។

[៧៥៤] ច្បាប់ស្តីអំពីឧក្រិដ្ឋកម្មសង្គ្រាម ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៤៦ បទបញ្ញា 10(4) – 10(5) (ប្រទេសកាណាដា)។ បញ្ជាការ ដ្ឋានកងទ័ពជើងគោកអាមេរិក (U.S. Department of the Army) សៀវភៅក្បួនយោធា 27-10៖ ច្បាប់សង្គ្រាមជើងគោក ឆ្នាំ១៩៥៦ កថាខណ្ឌ ៥០១។

[៧៥៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ត្រង់កថាខណ្ឌ ២១៨ កត់សម្គាល់រឿងក្តីតុលាការកំពូលអាល្លឺម៉ង់៖ សាលក្រមនៅក្នុង រឿងក្តី Emil Muller ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩២១ បោះពុម្ពឡើងវិញនៅក្នុង 16 Am. J. Int'l L. 684, 1922 ទំព័រ 691។

[៧៥៦] ការជំនុំជម្រះក្តីឧត្តមសេនីយ៍ *Tomoyuki Yamashita* រឿងក្តីលេខ២១ សាលក្រមរបស់គណៈកម្មការយោធាសហរដ្ឋ អាមេរិកទីក្រុង Manila ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៥ ដូចដែលបានបោះពុម្ពឡើង វិញនៅក្នុង*របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម* បានជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋកម្ម

00661749



ទម្លាប់អន្តរជាតិស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមានអត្ថិភាពតាំងពីមុនៗមក ក្លាយជាក្រម ដោយកត់សម្គាល់ថា អង្គហេតុនេះក៏ត្រូវបានទទួលស្គាល់ផងដែរ ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY[៧៥៧]។

៤០៥. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍បន្ថែមទៀតថា ការអនុវត្តនូវគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក គឺជាការបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវអំពីការអាចព្យាករណ៍ទុក ជាមុនបាន និងការដឹងថាមានច្បាប់ចែង[៧៥៨]។ សហព្រះរាជអាជ្ញាលើកឡើងថា តាមស្មារតីនៃឋានៈនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៧៥៩] និងការដឹងឮអំពីការផ្តន្ទាទោសដែលគាំទ្រដោយទ្រឹស្តីនេះ ក្រោយសង្គ្រាមលោកលើកទី២[៧៦០] បុគ្គលម្នាក់ដែលស្ថិតក្នុងមុខតំណែងរបស់ អៀង សារី ដែលទទួលបានការអប់រំខ្ពស់ ជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យដែលធ្លាប់បានធ្វើដំណើរយ៉ាងច្រើន "ពិតជាមានសមត្ថភាព និងមធ្យោបាយដែលអាចឲ្យឈានទៅធ្វើសេចក្តីសន្និដ្ឋានដោយសមហេតុផលបានថា សកម្មភាព និងការខកខាន

---

សង្គ្រាមអង្គការសហប្រជាជាតិ Vol IV, London: HMSO, 1948, ទំព័រ 1-2; *re Hirota*, សាលក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ ("ការជំនុំជម្រះក្តីនៅ Tokyo") ទំព័រ 1179-80។ រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង *Brandt* នៅក្នុងការជំនុំជម្រះក្តីពីរដង លើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ឆ្នាំ១៩៤៩ ("រឿងក្តីទាក់ទងនឹងគ្រូពេទ្យ") ទំព័រ 1, 207, 212។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Pohl* នៅក្នុងការជំនុំជម្រះក្តី ៥ដងលើឧក្រិដ្ឋ ជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ឆ្នាំ១៩៤៩ ("សេចក្តីសម្រេចលើ រឿងក្តី Pohl") ទំព័រ 193, 1159-1163 ។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Toyoda* តុលាការឧក្រិដ្ឋកម្មសង្គ្រាម ទីក្រុងតូក្យូ (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៤៩) បោះពុម្ពឡើងវិញនូវផ្នែកពាក់ព័ន្ធនៅក្នុង William H. Parks *ការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម* 62 M.L.Rev. 1, 1973 ទំព័រ 72។ *រឿងក្តីប្រទេសបារាំង ទល់នឹង Roechling* នៅក្នុងការជំនុំជម្រះក្តី១៤ដង លើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាNuremberg ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ឧបសម្ព័ន្ធ B ឆ្នាំ១៩៥២ ទំព័រ 1061, 1139-43។

[៧៥៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២៨-២៣០ កត់សម្គាល់សេចក្តីសម្រេចនៅក្នុងរឿងក្តី *Hadžihasanović*, កថាខណ្ឌ ២៩ និងនៅក្នុងសាលក្រមលើរឿងក្តី *Čelebići* កថាខណ្ឌ ១៩៥។

[៧៥៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣២-២៣៧។

[៧៥៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣៣។

[៧៦០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៣៤។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ទាំងនេះ អាចនឹងធ្វើឱ្យគាត់ទទួលទោសព្រហ្មទណ្ឌ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ"[៧៦១]។

៤០៦. ទាក់ទិននឹងបញ្ហាថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តប្រឆាំងនឹងថ្នាក់លើជាជនស៊ីវិលដែរ ឬ យ៉ាងណានោះ សហព្រះរាជអាជ្ញាលើកឡើងថា គោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែល ត្រូវបាន "អនុវត្តយ៉ាងរលូនមកហើយចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៥០ មកនោះ" រកឃើញថា ថ្នាក់លើ ទាំងផ្នែកយោធា និងទាំងផ្នែកស៊ីវិល ដែលមានការត្រួតត្រាដ៏មានប្រសិទ្ធភាពទៅលើអ្នកក្រោមបង្គាប់របស់ខ្លួន គឺសុទ្ធតែអាចត្រូវចាប់បង្ខំឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានា ដែលអ្នកក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្ត[៧៦២]។ សហព្រះរាជអាជ្ញាបានលើកឡើងទៀតថា យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើជាជនស៊ីវិល គឺមានលក្ខណៈជាការណែនាំ ដោយសារតែលក្ខន្តិកៈរបស់តុលាការទាំងនេះ ឆ្លុះបញ្ចាំងនូវមាត្រា២៩ នៃច្បាប់ អ.វ.ត.ក និងដោយសារតែពុំមានការអភិវឌ្ឍដ៏គួរឱ្យកត់សម្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទិននឹងបញ្ហានេះឡើយ នៅចន្លោះទសវត្សរ៍ឆ្នាំ ១៩៧០ និង ទសវត្សរ៍ឆ្នាំ ១៩៩០[៧៦៣]។

កំណត់សម្គាល់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

៤០៧. នៅក្នុងកំណត់សម្គាល់ទី១ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គេបានលើកឡើងថា ការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាព នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីព្រោះគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ មានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ នៅក្នុងមាត្រា ១ នៃអនុសញ្ញាទីក្រុងឡាអេ ទាក់ទងនឹងច្បាប់ និងទម្លាប់ស្តីពីសង្គ្រាមដើងគោក ("អនុសញ្ញាទីក្រុងឡាអេ (ទី៤)") ក៏ដូចជានៅក្នុងមាត្រា ៤៣(១) នៃពិធីសារបន្ថែម១[៧៦៤] ផងដែរ។ កំណត់សម្គាល់ទី២ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនពិចារណាអំពីទឡ្ហីករណ៍

[៧៦១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៣៥។

[៧៦២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣៩។

[៧៦៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤០។

[៧៦៤] កំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥១, ៥២ និង ៥៤។

របស់ អៀង សារី ទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ[៧៦៥] ខណៈពេលដែលនៅក្នុងកំណត់សម្គាល់ទី៣ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការលើកឡើងថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "គាំទ្រទឡ្ហីករណ៍ទាំងអស់ដែលបានបង្ហាញដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា [...]"[៧៦៦]។

៤០៨. កំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានលើកឡើងផងដែរថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មានអត្ថិភាពចំពោះថ្នាក់លើណាដែលមានការទទួលខុសត្រូវផ្ទាល់ លើអ្នកក្រោមបង្គាប់[៧៦៧]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើដែលកាន់មុខងារស៊ីវិល[៧៦៨] ហើយថាមន្ត្រីស៊ីវិលមួយចំនួនត្រូវបានដាក់ឱ្យទទួលខុសត្រូវ តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងដំណើរការជំនុំជម្រះក្តីទីក្រុងតូក្យូ[៧៦៩]។

<u>សារណាតបរបស់សហមេធាវីការពារក្តី៖</u>

៤០៩. នៅក្នុងសារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តី អៀង សារី លើកឡើងថា ទម្រង់នៃទទួលខុសត្រូវរបស់ថ្នាក់លើដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺពុំគ្រប់គ្រាន់ទេ។ ដោយសារតែ អ.វ.ត.ក ជាតុលាការជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវតែមានអត្ថិភាពផងដែរនៅក្នុងច្បាប់ជាតិកម្ពុជា ដើម្បីអាចឱ្យអនុវត្តបាន[៧៧០]។

៤១០. សហមេធាវីការពារក្តីអះអាងម្តងទៀតថា ការទទួលខុសត្រូវរបស់ថ្នាក់លើ ពុំមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ ដោយលើកទឡ្ហីករណ៍ថា

---

[៧៦៥] កំណត់សម្គាល់ទី២ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[៧៦៦] កំណត់សម្គាល់ទី៣ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៨។

[៧៦៧] កំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥៦-៥៧។

[៧៦៨] កំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥៨។

[៧៦៩] កំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥៩។

[៧៧០] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១២-១១៣។



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

ការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានចងក្រងជាច្បាប់លើកដំបូងនៅក្នុងច្បាប់អន្តរជាតិ ជាមួយនឹងពិធីសារបន្ថែមទី១ ក្នុងឆ្នាំ១៩៧៧ ហើយនៅពេលនោះពុំទាន់មានការទទួលស្គាល់ទូលំទូលាយភ្លាមៗនៅឡើយទេ[៧៧១]។ ការលើកយកគោលការណ៍បញ្ញាប្រកបដោយទំនួលខុសត្រូវមកធ្វើជាសំអាងកន្លងមកត្រូវបានបញ្ជាក់ថា មិនពាក់ព័ន្ធឡើយ[៧៧២]។ នៅក្នុងសារណាតប សហមេធាវីការពារក្ដីបានបន្តជំទាស់ទៅនឹងភាពពាក់ព័ន្ធ ឬភាពអាចទុកចិត្តបាននៃប្រភពជាច្រើនក្នុងចំណោមប្រភពទាំងអស់ដែលសហព្រះរាជអាជ្ញាបានយកមកធ្វើជាសំអាង ដើម្បីបង្ហាញថា ការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាព ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពោលគឺអត្ថិភាពនៃការបញ្ញាប្រកបដោយការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៧៧៣] គណៈកម្មការអន្តរជាតិស្តីពីទំនួលខុសត្រូវរបស់ស្ថាបនិកសង្គ្រាម និងស្ដីពីការពង្រឹងការអនុវត្តទោស ដែលបានបង្កើតឡើងក្នុងអំឡុងសន្និសីទសន្តិភាពឆ្នាំ១៩១៩[៧៧៤] សន្ធិសញ្ញាក្រុង Versailles[៧៧៥] ការអនុវត្តដែលត្រូវបានចោទប្រកាន់នូវច្បាប់អន្តរជាតិ ដោយតុលាការកំពូលអាល្លឺម៉ង់នៅក្នុងរយៈកាលចន្លោះសង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២[៧៧៦] សាលក្រមនានាក្រោយសង្គ្រាមលោកលើកទី២[៧៧៧] ច្បាប់ជាតិដែលដាក់បញ្ចូលការទទួលខុសត្រូវរបស់ថ្នាក់លើ[៧៧៨] និងការផ្អែកទៅលើសំអាងហេតុចេញពីសាលក្រមនានារបស់តុលាការ ICTY[៧៧៩]។

៤១១. ពាក់ព័ន្ធទៅនឹងភាពអាចដឹងជាមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង សហមេធាវីការពារក្ដីលើកឡើងថា វាមិនគ្រប់គ្រាន់ទេក្នុងការសំអាងលើអត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីលើកឡើងថាការអនុវត្តទម្រង់នៃការទទួល

---

[៧៧១] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៣។

[៧៧២] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៣។

[៧៧៣] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៤។

[៧៧៤] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៥។

[៧៧៥] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៦។

[៧៧៦] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៧។

[៧៧៧] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១១៩។

[៧៧៨] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២០។

[៧៧៩] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២២។

00661753



ខុសត្រូវអាចដឹង ជាមុនថាជាបទឧក្រិដ្ឋ[៧៨០]។ ក្រោយមកទៀត សហមេធាវីការពារក្តីអះអាងថា "លោក អៀង សារី ពុំអាចដឹងជាមុនបានឡើយ អំពីគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ដោយហេតុថាគោលការណ៍ នេះពុំមានចែងនៅក្នុងច្បាប់ជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលជាពេលពាក់ព័ន្ធនោះទេ"[៧៨១]។ សហមេធាវីការពារក្តីបានលើកឡើងថែមទៀតថា មនុស្សដែលពុំមានវិជ្ជាជីវៈជាមេធាវីដូចជាលោក អៀង សារី ទំនងជាពុំបានដឹងអំពីការយកគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយតុលាការក្រោយសង្គ្រាមលោកលើកទី២នោះទេ[៧៨២]។ សហមេធាវីការពារក្តីលើកឡើងថា ការពុំអាចដឹងព័ត៌មានបាននៅក្នុងប្រទេសកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ បានរារាំងលោក អៀង សារី មិនឱ្យដឹងថា ទំនួលខុសត្រូវរបស់ថ្នាក់លើគឺជាទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលមួយ ដែលមានសុពលភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងថា វាអាចអនុវត្តបានចំពោះ លោក អៀង សារី ដែលជាជនស៊ីវិល[៧៨៣]។

៤១២. នៅក្នុងសារណាតបរបស់ខ្លួនទៅនឹងកំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តី អៀង សារី លើកឡើងថា អនុសញ្ញាទីក្រុងឡាអេ (IV) ព្រមទាំងមាត្រា ៤៣(១) នៃពិធីសារបន្ថែមទី១ គ្រាន់តែចែងអំពីគោលការណ៍នៃការទទួលខុសត្រូវ ចំពោះការបង្កាប់បញ្ជាប៉ុណ្ណោះ ដែលពុំអាចស្មើគ្នានឹងការទទួលខុសត្រូវរបស់ថ្នាក់លើឡើយ[៧៨៤]។ សហមេធាវីការពារក្តីបន្ថែមទៀតថា លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវបានដកស្រង់នៅក្នុងកំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំមានអានុភាពទៅលើបញ្ហាថាតើទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាព នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ដែរឬយ៉ាងណានោះទេ[៧៨៥]។

[៧៨០] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២៣។

[៧៨១] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២៤។

[៧៨២] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២៤។

[៧៨៣] សារណាតបរបស់ អៀង សារី កថាខណ្ឌ ១២៦-១២៧។

[៧៨៤] សារណាតបរបស់ អៀង សារី ទៅនឹងកំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២១។

[៧៨៥] សារណាតបរបស់ អៀង សារី ទៅនឹងកំណត់សម្គាល់ទី១ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៤។

ការពិភាក្សា៖

៤១៣. សហមេធាវីការពារក្ដីលើកនូវបញ្ហាចំពោះការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ដែលថាការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្ដីគ្រាន់តែយោងទៅលើកថាខណ្ឌ ១៣១៩ និង ១៥៥៨ នៃដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ផ្នែកដទៃទៀតនៃដីកាដំណោះស្រាយ ដែលទាក់ទិនទៅនឹងទឡ្ហីករណ៍ទាំងនេះ ប៉ុន្តែមិនត្រូវបានសហមេធាវីការពារក្ដីយោងទៅលើនៅក្នុងបណ្ដឹងឧទ្ធរណ៍ គឺកថាខណ្ឌ ១៣០៧ និង ១៣១៨។

៤១៤. នៅក្នុងការធ្វើសេចក្ដីបញ្ជាក់របស់សហចៅក្រមស៊ើបអង្កេតក្នុងកថាខណ្ឌ១៣០៧ នៃដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដោយសារតែ "ការទទួលខុសត្រូវរបស់ថ្នាក់លើក៏ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះនានាដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់នោះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ" សហចៅក្រមស៊ើបអង្កេតប្រើជា ប្រភពគាំទ្រនូវសាលក្រមសំណុំរឿង ០០១ របស់អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក កថាខណ្ឌ ៣២, ២៩៥ និង ៤០៧ និងរឿងក្ដី *Milutinovic និងអ្នកផ្សេងទៀត* សេចក្ដីសម្រេច [ឆ្នាំ២០០៣] របស់តុលាការ ICTY លើញត្តិជំទាស់នឹងយុត្តាធិការរបស់ Dragoljob Ojdanic – សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤២។

៤១៥. ក្នុងការធ្វើសេចក្ដីបញ្ជាក់របស់សហចៅក្រមស៊ើបអង្កេតដែលថា "ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង" ក្នុងកថាខណ្ឌ ១៣១៨ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតប្រើជាប្រភពគាំទ្រនូវសាលក្រមសំណុំរឿង ០០១ របស់អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក ត្រង់កថាខណ្ឌ ៤៧២ និងកថាខណ្ឌបន្តបន្ទាប់ទៀត។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

៤១៦. លើសពីនេះទៀត ក្នុងការធ្វើសេចក្ដីបញ្ជាក់របស់សហចៅក្រមស៊ើបអង្កេតដែលថា“ទម្រង់នៃការទទួលខុសត្រូវនេះ ក៏អនុវត្តផងដែរចំពោះថ្នាក់លើក្នុងស្ថាប័នស៊ីវិល ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយថ្នាក់ក្រោមបង្គាប់របស់ខ្លួន” ក្នុងកថាខណ្ឌ ១៣១៩ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតប្រើជាប្រភពគាំទ្រនូវរឿងក្ដី *Pohl* និង រឿងក្ដី*គ្រូពេទ្យ (Medical Case)*[៧៨៦]។ ចំពោះសេចក្ដីបញ្ជាក់របស់ពួកគាត់នៅក្នុងកថាខណ្ឌ ១៥៥៨ នៃដីកាដំណោះស្រាយ “ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ថ្នាក់លើអនុវត្តទៅលើថ្នាក់លើទាំងផ្នែកយោធា ទាំងផ្នែកស៊ីវិល ហើយការលើកឡើងអំពីឋានានុក្រមជាផ្លូវការពុំចាំបាច់ឡើយ ក្នុងការចាត់ទុកបុគ្គលណាម្នាក់ថាជាអ្នកទទួលខុសត្រូវក្នុងឋានៈជាថ្នាក់លើនោះ” សហចៅក្រមស៊ើបអង្កេតប្រើជាប្រភពនូវសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR នៅក្នុងរឿងក្ដី *Nahimana និងអ្នកផ្សេងទៀត*[៧៨៧]។

៤១៧. ពាក់ព័ន្ធនឹងប្រភពទាំងនេះ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកប្រើដើម្បីគាំទ្រដល់សេចក្ដីបញ្ជាក់របស់ខ្លួននៅក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយដែលបានបញ្ជាក់ជូនខាងលើ ជាដំបូង ទាក់ទិននឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ២៣៤ ខាងលើ “អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គបុរេជំនុំជម្រះអាចផ្អែកទៅលើសំអាងហេតុទាំងនោះ នៅពេលណាដែលខ្លួនយល់ថាសមស្រប ហើយថា សុពលភាពនៃសំអាងហេតុខ្លះ ក្នុងចំណោមសំអាងហេតុទាំងនោះរបស់អង្គជំនុំជម្រះសាលាដំបូង ពុំត្រូវបានជំទាស់ឡើយ”។

៤១៨. ដោយបានពិនិត្យអំពីប្រភពនានាដែលបានគាំទ្រដល់ការលើកឡើងថា “ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជាក្នុងពេលដែលអង្គហេតុបានកើតឡើង” អង្គបុរេជំនុំជម្រះឯកភាពតាមសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងកថាខណ្ឌ ៤៧៦ និង៤៧៧ នៃសាលក្រមនៅក្នុងសំណុំរឿង ០០១ ថា ៖ ១) តុលាការ Nuremberg យល់ឃើញថា ការខកខានរបស់ថ្នាក់លើក្នុងការអនុវត្ត

[៧៨៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩ ជើងទំព័រ ៥២២៣។

[៧៨៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៨ ជើងទំព័រ ៥៣០២។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

តួនាទីរបស់ខ្លួន ដើម្បីគ្រប់គ្រងអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ អាចនាំឱ្យមានការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ ២) ថា ដូចបានដកស្រង់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ ទោះបីជាពិធីសារបន្ថែមទី១ ត្រូវបានអនុម័តនៅឆ្នាំ ១៩៧៧ មាត្រា៨៦ និង៨៧ គ្រាន់តែធ្វើការប្រកាសអំពីគោលជំហរដែលមានប៉ុណ្ណោះ មិនមែនបង្កើតវានោះទេ និង ៣) យុត្តិសាស្ត្ររបស់តុលាការ Nuremberg ក៏បានបង្ហាញថា ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនត្រូវបានកំណត់ចំពោះតែមេបញ្ជាការយោធាប៉ុណ្ណោះទេ។

៤១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា មាត្រា២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានកំណត់ដូចខាងក្រោម ៖

> ប្រការដែលថាសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់ និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះចារីទាំងនេះ។

៤២០. ម្យ៉ាងវិញទៀត ដោយផ្អែកទៅលើមាត្រា ២៩(ថ្មី) អនុលោមតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ខ្លួន ធាតុផ្សំចំនួនបីត្រូវតែបង្ហាញ។ ទីមួយ "ត្រូវតែមានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់រវាងជនជាប់ចោទជាមួយនឹងជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ" ដោយមានការត្រួតពិនិត្យ និងការបញ្ជា ឬការត្រួតពិនិត្យ និងអំណាចដ៏មានប្រសិទ្ធភាព។ ទីពីរ "ជនជាប់ចោទត្រូវតែបានដឹង និងមានហេតុផលដឹងថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្ត" ដែលសំដៅទៅលើ*ធាតុផ្សំអត្តនោម័ត*នៃការដឹងពិតប្រាកដ ឬការដឹងតាមការសន្និត។ និងទីបី "ជនជាប់ចោទខកខានមិនបាន

ចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកដែលបាន ប្រព្រឹត្តឧក្រិដ្ឋកម្មនោះ" ដែលសំដៅទៅលើ *ធាតុផ្សំសត្យានុម័ត* តាមរយៈធាតុផ្សំនៃការខកខាន[៧៨៨]។

៤២១. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការវិវឌ្ឍន៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាម ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្រោមបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាព អវិជ្ជមានដោយសារព្រឹត្តការណ៍នានាក្រោយសង្គ្រាមលោកលើកទីមួយ។ ជាដំបូង នៅក្នុងរបាយ ការណ៍ឆ្នាំ ១៩១៩ របស់គណៈកម្មាការស្តីពីការទទួលខុសត្រូវរបស់ស្ថាបនិកសង្គ្រាម និងស្តីពីការ អនុវត្តការដាក់ទណ្ឌកម្ម ដែលត្រូវបានបង្កើតឡើងដោយសន្និសីទស្តីពីសន្តិភាពបឋម ក្នុងគោល បំណងកំណត់អំពីទោសទណ្ឌទាក់ទិននឹងសង្គ្រាម គណៈកម្មការបានផ្តល់នូវការយល់ឃើញយ៉ាង ច្បាស់លាស់ ចំពោះទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងការផ្តល់ជាយោបល់ថា បទចោទ ទាំងឡាយ គួរតែត្រូវបាននាំយកមកជំនុំជម្រះនៅចំពោះមុខតុលាការអន្តរជាតិ៖

> ប្រឆាំងនឹងអ្នកមានអំណាចទាំងអស់ ផ្នែកស៊ីវិល ឬយោធា ដែលជាសមាជិករបស់ប្រទេស សត្រូវ ទោះបីជាមានតួនាទីខ្ពស់យ៉ាងណាក៏ដោយ ដោយមិនមានការបែងចែកខុសគ្នាអំពីឋានៈ ឡើយ រួមទាំងប្រមុខរដ្ឋ ដែលបានបញ្ជា ឬ *បានដឹង និងមានអំណាចក្នុងការធ្វើអន្តរាគមន៍ នៅ តែពុំបានទប់ស្កាត់ ឬចាត់វិធានការដើម្បីទប់ស្កាត់ បញ្ចប់ ឬបង្ក្រាបទៅលើការរំលោភ ច្បាប់ ឬទម្លាប់សង្គ្រាម* (មានការយល់ថា ពុំមានការនៅស្ងៀមបែបនេះណាមួយឡើយដែល គួរតែបង្កើតបានជាការការពារខ្លួនសម្រាប់ចារីពិតប្រាកដ)[៧៨៩]។

៤២២. ទោះបីជាការជំនុំជម្រះទោសដោយតុលាការអន្តរជាតិលើបុគ្គលទាំងឡាយមកពីប្រទេសអាល្លឺម៉ង់ និងសម្ព័ន្ធមិត្តរបស់ខ្លួន អនុលោមតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពុំដែលកើតមាន ឡើងយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់បានយល់ព្រមជំនុំជម្រះទោសបុគ្គលដប់ពីរ នាក់ នៅចំពោះមុខតុលាការកំពូល Reich នៅ Leipzing ពីបទឧក្រិដ្ឋកម្មសង្គ្រាម[៧៩០]។ នៅក្នុង រឿងក្តីមួយក្នុងចំណោមរឿងក្តីទាំងនេះ ទាក់ទិននឹង Emil Müller ដែលជាអនុសេនីយ៍ឯកនៅក្នុង

---

[៧៨៨] សាលក្រមរឿងក្តី ០០១ កថាខណ្ឌ ៥៣៨។

[៧៨៩] បោះពុម្ពឡើងវិញនៅក្នុង *American Journal of International Law* វ៉ុល១៤ លេខ១ ទំព័រ 95-154 (ខែមករា-ខែមេសា ឆ្នាំ១៩២០) ទំព័រ ១២១ (សេចក្តីបញ្ជាក់បន្ថែម)។

[៧៩០] James F. Willis, *Prologue to Nuremberg: The Politics and Diplomacy of Punishing War Criminals of the First World War*, 1982 ទំព័រ 142។

កងទ័ពបម្រុងរបស់ Karlsruhe តុលាការកំពូលបានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវលើការធ្វើបាបអ្នកទោសពីសំណាក់អ្នកក្រោមបង្គាប់ដោយផ្អែកលើមូលដ្ឋានថា គាត់បានឃើញផ្ទាល់ភ្នែកនូវការធ្វើបាបនោះ ហើយពុំបានចាត់វិធានការនៅពេលក្រោយមកទៀត។ តុលាការសន្និដ្ឋានថា Müller យ៉ាងហោចណាស់បានអត់ទ្រាំ និងយល់ព្រមឱ្យមានការធ្វើបាបដ៏ឃោរឃៅនេះ ទោះបីជាអំពើនេះមិនត្រូវបាន ធ្វើឡើងតាមបញ្ជារបស់គាត់ក៏ដោយ"[៧៩១]។ ចំណែកឯទាក់ទិននឹងឧប្បត្តិហេតុមួយទៀត អំពីការធ្វើបាបអ្នកទោសពីសំណាក់អ្នកក្រោមបង្គាប់ តុលាការពុំបានរកឃើញថា Müller ជាអ្នកទទួលខុសត្រូវឡើយ ពីព្រោះវា "មិនច្បាស់ថាតើការធ្វើបាបនេះពុំបានកើតឡើងមុនពេលជនជាប់ចោទបានដឹងអំពីការធ្វើបាបនេះ ឬមុនពេលដែលជនជាប់ចោទអាចការពារកុំឱ្យមានអំពើនេះ ឬយ៉ាងណានោះឡើយ។ ដូច្នេះ ករណីនៃការអនុញ្ញាតដោយចេតនាឱ្យមានអំពើបែបនេះ នៅពេលដែលគាត់អាចការពារបានកុំឱ្យមានអំពើនេះ [...] មិនអាចត្រូវបានបង្កើតឡើងនៅទីនេះទេ"[៧៩២]។

៤២៣. ទោះបីជាយ៉ាងណាក៏ដោយ មានតែក្រោយពេលសង្គ្រាមលោកលើកទី២រួចប៉ុណ្ណោះ ទើបការកាត់សេចក្តីជាអន្តរជាតិដែលផ្អែកលើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានធ្វើឡើងពិតប្រាកដ។ ទោះជាទ្រឹស្តីនេះមិនត្រូវបានចែងច្បាស់លាស់ ក្រោមធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិនៅ Nuremberg ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា នៅទីក្រុងតូក្យូ ("IMTFE") ឬ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត ("ច្បាប់គ្រប់គ្រងរបស់ក្រុមប្រឹក្សា") ពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្តីនៅក្នុងតំបន់កាន់កាប់របស់អាល្លឺម៉ង់ រឿងក្តីមួយចំនួនរបស់ថ្នាក់លើអាល្លឺម៉ង់ និងជប៉ុនដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការ IMTFE ហើយគណៈកម្មការ ឬតុលាការយោធាសម្ព័ន្ធមិត្តបានបញ្ជាក់ច្បាស់ និងបានអនុវត្តទ្រឹស្តីនេះ។

៤២៤. ទីមួយ នៅក្នុងការជំនុំជម្រះក្តីឧត្តមសេនីយ៍ជប៉ុន Tomoyuki Yamashita ក្នុងឆ្នាំ១៩៤៥ "ដែលជានាយទាហានមានបទពិសោធន៍ច្រើនឆ្នាំ ដែលមានភារកិច្ចក្នុងការគ្រប់គ្រងទាហាន និងចេញបញ្ជាដ៏

[៧៩១] សាលក្រមនៅក្នុងរឿងក្តី Emil Müller ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩២១ បោះពុម្ពឡើងវិញ នៅក្នុង 16 *American Journal of International Law* 684, 1922 ("សាលក្រមលើរឿងក្តី Emil Müller") ទំព័រ ៦៩១។

[៧៩២] សាលក្រមលើរឿងក្តី Emil Müller ទំព័រ ៦៩១។

ទូលំទូលាយនៅក្នុងកងទ័ពអធិរាជជប៉ុន"[៧៩៣] ក្នុងវិសាលភាពដ៏ទូលាយនៅចំពោះមុខគណៈកម្មការយោធាអាមេរិក ឧត្តមសេនីយ៍ Yamashita ត្រូវបានចោទប្រកាន់ពី ៖

> ការមិនយកចិត្តទុកដាក់ និងការខកខានដោយខុសច្បាប់ពុំបានបំពេញតួនាទីរបស់គាត់ជាមេបញ្ជាការ ដើម្បីត្រួតពិនិត្យលើអំពើនានារបស់អ្នកក្រោមបង្គាប់របស់គាត់ ដោយអនុញ្ញាតឱ្យអ្នកក្រោមបង្គាប់គាត់ប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ ខ្លឹមសារនៃរឿងក្តីសម្រាប់អយ្យការគឺថាជនជាប់ចោទបានដឹង ឬប្រាកដជាបានដឹងអំពីអំពើនោះ និងបានអនុញ្ញាតឱ្យមានឧក្រិដ្ឋកម្មទូទៅដែលប្រព្រឹត្តនៅក្នុងប្រទេសហ្វីលីពីន ពីសំណាក់កងទ័ពនៅក្រោមបញ្ជារបស់គាត់ (ដែលរួមមាន អំពើមនុស្សឃាត អំពើលួចប្លន់ ការបំផ្លិចបំផ្លាញ ការរំលោភលើផ្លូវភេទ ការពុំផ្តល់នូវគ្រឿងចាំបាច់សម្រាប់ឈ្លើយសឹក និងការបាញ់សម្លាប់ទ័ពព្រៃដោយពុំមានការជំនុំជម្រះទោស) [...][៧៩៤]។

៤២៥. ទោះបីជាភស្តុតាងដែលបានដាក់ជូន មានលក្ខណៈមិនស៊ីសង្វាក់គ្នា ឬមិនច្បាស់លាស់ ទាក់ទិននឹងការដឹងរបស់ឧត្តមសេនីយ៍ Yamashita អំពីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់ ឬការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកក្រោមបង្គាប់ទាំងនោះ នៅពេលវេលាដែលពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏មានភស្តុតាងដ៏ច្រើននៅចំពោះមុខគណៈកម្មការដែលថា បទល្មើស "មានច្រើន និងទូទៅ នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា"[៧៩៥] ហើយត្រូវបានប្រព្រឹត្តឡើង "ដោយកងទ័ពជប៉ុនក្រោមបញ្ជារបស់ [ឧត្តមសេនីយ៍ Yamashita]"[៧៩៦]។ ដូច្នេះ គណៈកម្មការបានសម្រេចថា "នៅពេលដែលអំពើមនុស្សឃាត និងអំពើរំលោភលើផ្លូវភេទ និងអំពើសងសឹក និងអំពើសាហាវយង់ឃ្នង គឺជាបទល្មើសមានលក្ខណៈទូទៅ និងពុំមានការខិតខំប្រឹងប្រែងប្រកបដោយប្រសិទ្ធភាពពីសំណាក់មេបញ្ជាការដើម្បីរកឱ្យឃើញ និងត្រួតពិនិត្យទៅលើអំពើឧក្រិដ្ឋទាំងនោះ មេបញ្ជាការនោះអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ ទោះជាការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ចំពោះអំពើខុសច្បាប់របស់កងទ័ពរបស់គាត់ ដោយផ្អែកលើលក្ខណៈរបស់ពួកគេ និងកាលៈទេសៈនៅជុំវិញពួកគេ"[៧៩៧]។ ដូច្នេះ គណៈកម្មការបានផ្តន្ទាទោសឧត្តមសេនីយ៍ Yamashita ដោយផ្អែកលើមូល

---

[៧៩៣] សាលក្រមលើរឿងក្តី *Yamashita* ទំព័រ ៣៥។

[៧៩៤] សាលក្រមលើរឿងក្តី *Yamashita* ទំព័រ ១។

[៧៩៥] សាលក្រមលើរឿងក្តី *Yamashita* ទំព័រ២។

[៧៩៦] សាលក្រមលើរឿងក្តី *Yamashita* ទំព័រ ៣៥។

[៧៩៧] សាលក្រមលើរឿងក្តី *Yamashita* ទំព័រ ៣៥។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

ដ្ឋានថា "អំពើសាហាវឃោរឃៅមួយចំនួន និងបទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃកងកម្លាំងប្រដាប់អាវុធជប៉ុនក្រោមបញ្ជារបស់រូបលោក" និង "ក្នុងអំឡុងរយៈដែលបានលើកឡើងនោះ លោកពុំបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើកងទ័ពរបស់លោកដូចដែលកាលៈទេសៈបានតម្រូវឡើយ"[៧៩៨]។

៤២៦. នៅក្នុងការឆ្លើយតបទៅកាន់បណ្ដឹងទាមទារ លើដីកាបង្គាប់ឱ្យនាំខ្លួនមកតុលាការក្នុងនាមឧត្ដមសេនីយ៍ Yamashita តុលាការកំពូលសហរដ្ឋអាមេរិកបានគាំទ្រសំអាងហេតុរបស់គណៈកម្មការយោធាដោយសម្រេចថា បទប្បញ្ញត្តិមួយចំនួននៃច្បាប់អន្តរជាតិ "ពិតជាបានដាក់ទៅលើម្ចាស់បណ្ដឹងទាមទារ ដែលនៅពេលនោះជាអ្នកគ្រប់គ្រងកងកម្លាំងយោធាប្រទេសហ្វីលីពីន និងក៏ជាមេបញ្ជាការកងកម្លាំងជប៉ុនផងដែរ នូវភារកិច្ចស្រប (វិជ្ជមាន)មួយដើម្បីចាត់វិធានការដូច្នេះ *ដោយហេតុថាវាស្ថិតក្នុងអំណាចរបស់គាត់* និងសមស្របនៅក្នុងកាលៈទេសៈទាំងនេះ ដើម្បីការពារឈ្លើយសឹក និងប្រជាជនស៊ីវិល។ ដូច្នេះ ភារកិច្ចជាមេបញ្ជាការកាលពីមុននេះ ត្រូវបានទទួលស្គាល់ ហើយការប្រព្រឹត្តល្មើសភារកិច្ចនេះ ត្រូវបានដាក់ទោសទណ្ឌដោយតុលាការយោធាផ្ទាល់ខ្លួនរបស់យើង[៧៩៩]។

៤២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីជាសេចក្ដីបញ្ជាក់ និងការអនុវត្តធាតុផ្សំជាក់លាក់នៃទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពីសំណាក់ចៅក្រមនៅក្នុងរឿងក្ដីនេះមានភាពចម្រូងចម្រាស ជាពិសេសទាក់ទិននឹងបទដ្ឋានធាតុផ្សំអត្តនោម័តដែលតម្រូវឱ្យមាន រួមទាំងការធ្វេសប្រហែស ឬសូម្បីតែ បទដ្ឋានការទទួលខុសត្រូវដ៏តឹងរ៉ឹង និងការខកខានពុំបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ឧត្ដមសេនីយ៍ Yamashita ទៅលើកងទ័ពរបស់គាត់យ៉ាងណាក៏ដោយ ក៏វាពុំមានមន្ទិលឡើយថា រឿងក្ដី *Yamashita* គឺជាយុត្តិសាស្ត្រសម្រាប់សញ្ញាណដែលថា ថ្នាក់លើអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ទាក់ទិននឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយ

---

[៧៩៨] សាលក្រមលើរឿងក្ដី *Yamashita* ទំព័រ ៣៥។

[៧៩៩] *In re Yamashita* តុលាការកំពូលសហរដ្ឋអាមេរិក សាលក្រមចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ១៩៤៦, 327 US 1, 66 S.Ct. 340, 90 L.Ed. 499 (1946) បោះពុម្ពឡើងវិញ ផ្នែកខ្លះ នៅក្នុងរបាយការណ៍ច្បាប់ស្ដីពីការជំនុំជម្រះក្ដីឧក្រិដ្ឋជនសង្គ្រាម ដែលបានជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ វ៉ុល IV, London: HMSO, 1948 ទំព័រ ៤៣-៤៤ (សេចក្ដី បញ្ជាក់បន្ថែម)។



PRE-TRIAL CHAMBER · E.C.C.C. · C.E.T.C. · PRÉLIMINAIRE

អ្នកក្រោមបង្គាប់។ លើសពីនេះទៀត យោបល់ជំទាស់នៅក្នុងរឿងក្តីរបស់តុលាការកំពូល "បានរួមចំណែកច្រើនជាងសេចក្តីសម្រេចតាមមតិភាគច្រើន ក្នុងការប្រែក្លាយទស្សនាទាននេះឱ្យទៅជាទម្រង់ដែលមានលក្ខណៈជាទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[៨០០]។

៤២៨. ទីពីរ រឿងក្តីជាច្រើនក្នុងចំណោមរឿងក្តីទាំងដប់ពីរដែលត្រូវបានយកមកជំនុំជម្រះ និងសម្រេចក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ចាប់ពីខែ តុលា ឆ្នាំ ១៩៤៦-ខែ មេសា ឆ្នាំ ១៩៤៩ នៅចំពោះមុខតុលាការយោធា Nuremberg "តុលាការ Nurmberg" នៅក្នុងតំបន់កាន់កាប់ដោយសហរដ្ឋអាមេរិកក្នុងប្រទេសអាល្លឺម៉ង់ បានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ប្រហែលជារឿងក្តីដែលល្បីល្បាញជាងគេបំផុតនោះគឺរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Wilhelm von Leeb និង អ្នកផ្សេងទៀត* ("High Command Case")[៨០១] ដែលពាក់ព័ន្ធនឹងការចោទប្រកាន់នាយទាហានជាន់ខ្ពស់ ១៤នាក់ នៅក្នុងកងទ័ពអាល្លឺម៉ង់ ក្នុងចំណោមការចោទប្រកាន់ដទៃទៀត ចំពោះឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងក្រុមដែលចូលប្រឡូកក្នុងសង្គ្រាម និងឈ្លើយសឹក (បទចោទទីពីរ) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងជនស៊ីវិល (បទចោទទីបី) ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៨០២]។

៤២៩. ចុងចោទដប់នាក់ក្នុងចំណោមចុងចោទទាំងអស់ត្រូវបានរកឃើញថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងខណៈដែលចុងចោទនាំមុខ គឺសេនាប្រមុខ von Leeb ត្រូវបានផ្តន្ទាទោស តែចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ[៨០៣]។ សេនាប្រមុខ von Leeb ត្រូវបានផ្តន្ទាទោសយ៉ាងជាក់លាក់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាថ្នាក់លើផ្នែក

---

[៨០០] Guénaël Mettraux ច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ (*The Law of Command Responsibility)* Oxford, 2009 ទំព័រ ៧-៨។

[៨០១] *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Wilhelm von Leeb* និងអ្នកផ្សេងទៀត ក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuernberg ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ វ៉ុល* X និង XI ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ១៩៥១ ("*High Command Case*")។

[៨០២] *High Command Case* វ៉ុល X ទំព័រ ១០។ វ៉ុល XI ទំព័រ ៤៦៣-៤៦៥។

[៨០៣] *High Command Case* វ៉ុល XI ទំព័រ ៥៦០-៥៦១។ ចុងចោទផ្សេងទៀតបានធ្វើអត្តឃាតមុនពេលការជំនុំជម្រះក្តីត្រូវបានផ្អាកដំណើរការ។



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · PRÉLIMINAIRE

យោធា[៨០៤]។ នៅពេលដែលបញ្ជាក់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ តុលាការបានបញ្ជាក់ដូចខាងក្រោម ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័ត* និង*ធាតុផ្សំសត្យានុម័ត* ៖

> ភាពនៅក្រោមបង្គាប់ផ្នែកយោធាគឺជាកត្តាទូទៅ ប៉ុន្តែពុំមែនជាកត្តាចុងក្រោយគ្មានមន្ទិលក្នុងការកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ អំណាចទាំងផ្នែករដ្ឋបាល និងយោធារបស់មេបញ្ជាការម្នាក់ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់មានការជាប់ពាក់ព័ន្ធគ្នា ប៉ុន្តែពុំមានវិសាលភាពស្មើគ្នាឡើយ។ សង្គ្រាមសម័យទំនើប ដូចជាសង្គ្រាមចុងក្រោយ នាំឱ្យមានវិធានការដ៏ធំនៃវិមជ្ឈការ។ មេបញ្ជាការជាន់ខ្ពស់មិនអាចត្រូវដឹងឱ្យបានពេញលេញរៀងរាល់ពេលអំពីសេចក្តីពិស្តារ នៃប្រតិបត្តិការយោធារបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួនឡើយ ហើយពិតណាស់ ពុំដឹងអំពីគ្រប់វិធានការរដ្ឋបាលឡើយ។ គាត់មានសិទ្ធិក្នុងការសន្មតថា សេចក្តីពិស្តារដែលត្រូវបានប្រគល់ទៅឱ្យអ្នកក្រោមបង្គាប់ដែលមានការទទួលខុសត្រូវ នឹងត្រូវបានអនុវត្តដោយស្របច្បាប់។ ប្រធានាធិបតីសហរដ្ឋអាមេរិកគឺជាអគ្គមេបញ្ជាការនៃកងកម្លាំងយោធារបស់ខ្លួន។ ការប្រព្រឹត្តបទឧក្រិដ្ឋដែលធ្វើឡើងដោយកងកម្លាំងទាំងអស់នោះ មិនអាចត្រូវបានចោទប្រកាន់ចំពោះគាត់តាមទ្រឹស្តីអំពីភាពនៅក្រោមបង្គាប់នោះបានទេ។ ដូចគ្នាទៅនឹងមេបញ្ជាការជាន់ខ្ពស់ដទៃទៀតដែរនៅក្នុងខ្សែសង្វាក់របស់ថ្នាក់លើ។ ពិរុទ្ធភាពមិនទាក់ទិនទៅនឹងគ្រប់បុគ្គលទាំងអស់ នៅក្នុងខ្សែសង្វាក់របស់ថ្នាក់លើដែលចេញមកពីអង្គហេតុតែមួយប៉ុណ្ណោះឡើយ។ ត្រូវតែមានការធ្វេសប្រហែសផ្ទាល់ខ្លួន។ រឿងនេះអាចកើតឡើងបានតែនៅពេលដែលការប្រព្រឹត្តអាចពាក់ព័ន្ធចំពោះរូបគាត់ ឬនៅពេលដែលការខកខានមិនបានគ្រប់គ្រងអ្នកនៅក្រោមបង្គាប់ឱ្យបានត្រឹមត្រូវ គឺជាការធ្វេសប្រហែសទាក់ទិននឹងបទឧក្រិដ្ឋរបស់គាត់តែប៉ុណ្ណោះ។ នៅក្នុងករណីចុងក្រោយគេនេះ វាត្រូវតែជាការធ្វេសប្រហែសផ្ទាល់ខ្លួនដែលស្មើនឹងការមិនអើពើ ចំពោះអំពើមិនប្រព្រឹត្តសមរម្យ អសីលធម៌របស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន ដែលរាប់ទុកថាជាការត្រូវរ៉ូវគ្នា។ ការបកស្រាយច្បាប់អន្តរជាតិផ្សេងទៀត នឹងហួសឆ្ងាយពីគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ ដោយប្រជាជាតិដែលមានអារ្យធម៌ [...]។ មេបញ្ជាការដែលត្រូតត្រា ត្រូវតែមានការដឹងអំពីបទល្មើសទាំងនេះ [ប្រព្រឹត្តឡើងដោយកងទ័ពរបស់គាត់] និងត្រូវរ៉ូវគ្នា ឬចូលរួម ឬមិនអើពើជ្រៀតជ្រែកក្នុងការប្រព្រឹត្តរបស់ពួកគេ និង [...] បទល្មើសដែលត្រូវបានប្រព្រឹត្តត្រូវតែមានលក្ខណៈឧក្រិដ្ឋយ៉ាងច្បាស់ក្រឡែត[៨០៥]។

[៨០៤] *High Command Case* វ៉ុល XI ទំព័រ ៥៦០-៥៦១។

[805] *High Command Case* វ៉ុល XI *ទំព័រ ៥៤៣-៥៤៥*។

៤៣០. ទាក់ទិនទៅនឹងលក្ខណៈតម្រូវនៃទំនាក់ទំនងថ្នាក់លើនិងអ្នកក្រោមបង្គាប់ តុលាការបានកំណត់នូវទម្រង់នៃលក្ខខណ្ឌនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នៅពេលបដិសេធទ្រឹស្តីរបស់អយ្យការដែលថា មេបញ្ជាការនៅសមរភូមិដែលទទួលខុសត្រូវជាផ្លូវការចំពោះទឹកដីដែលបានកាន់កាប់ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវយ៉ាងតឹងរ៉ឹង ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់នៅក្នុងទឹកដីនោះ ដោយសារតែសកម្មភាពរបស់អាជ្ញាធរ Reich និងអាជ្ញាធរយោធាជាន់ខ្ពស់[៨០៦]។ តុលាការយល់ឃើញថា នៅពេលដែលអំណាចបែបនេះ ត្រូវបានចោទប្រកាន់ថាបានដកចេញពីមេបញ្ជាការ តុលាការនឹងពិនិត្យលើកត្តាអត្តនោម័ត និងកត្តាសត្យានុម័ត នៅក្នុងការពិចារណាអំពីសុពលភាពនៃការការពារខ្លួន[៨០៧]។

៤៣១. រឿងក្តីមួយទៀតរបស់តុលាការ NMT បានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើយ៉ាងជាក់លាក់ គឺរឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Wilhelm List និងអ្នកផ្សេងទៀត* (*"Hostage Case"*)[៨០៨] ដែលពាក់ព័ន្ធនឹងសេនាប្រមុខ និងឧត្តមសេនីយ៍ជាន់ខ្ពស់នានា ដែលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងប្រឆាំងនឹងជន

---

[806] តុលាការបានបញ្ជាក់ថា ៖ "ទាក់ទិននឹងការទទួលខុសត្រូវរបស់មេបញ្ជាការសមរភូមិ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់នៃការបញ្ជារបស់គាត់ ជាពិសេស ប្រឆាំងទៅនឹងប្រជាជនស៊ីវិល មានការទទូចពីអយ្យការថា អនុលោមតាមអនុសញ្ញាទីក្រុងឡាអេ មេបញ្ជាការយោធានៃទឹកដីដែលត្រូវបានកាន់កាប់ គឺទទួលខុសត្រូវដោយខ្លួនឯងនៅក្នុងតំបន់នៃការកាន់កាប់របស់គាត់ ដោយពុំគិតអំពីបញ្ជា បទបញ្ជា និងច្បាប់របស់ថ្នាក់លើគាត់ ដែលកម្រិតអំណាចរបស់គាត់ឡើយ និងដោយពុំគិតអំពីអង្គហេតុដែលថាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើង គឺដោយសារតែសកម្មភាពរបស់រដ្ឋ ឬអាជ្ញាធរយោធាថ្នាក់លើដែលគាត់ពុំបានផ្តួចផ្តើម ឬដែលគាត់ពុំបានចូលរួមនោះឡើយ [...] ។ តុលាការនេះយល់ឃើញថា [...] គេមិនអាចនិយាយបានថាគាត់អនុវត្តអំណាចដែលជនស៊ីវិលត្រូវស្ថិតនៅក្រោមកងទ័ពដែលចូលលុកលុយរបស់គាត់ឡើយ ដែលក្នុងខណៈនោះដែរ រដ្ឋដែលគាត់តំណាងនោះ អាចចូលមកគ្រប់គ្រងតំបន់ដែលគាត់កាន់កាប់ ហើយយកប្រជាជនជាគោលដៅនៃអំពើមនុស្សឃាត និងការប្រព្រឹត្តអមនុស្សធម៌ដទៃទៀត។ [...] ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកដទៃទៀតនៃរឿងក្តីនេះ យើងយល់ឃើញថា មេបញ្ជាការដែលកំពុងត្រួតត្រា ប្រាកដជាដឹងអំពីបទល្មើសទាំងនេះ និងត្រូវរ៉ូវគ្នា ឬចូលរួម ឬក៏មិនអើពើជ្រៀតជ្រែត នៅក្នុងការប្រព្រឹត្តបទល្មើសទាំងនោះដែលនាំឱ្យមានទោសព្រហ្មទណ្ឌ ហើយថា បទល្មើសដែលត្រូវបានប្រព្រឹត្តត្រូវតែមានលក្ខណៈព្រហ្មទណ្ឌយ៉ាងច្បាស់ក្រឡែត"។ *High Command* Case វ៉ុល XI ទំព័រ 544-545។

[៨០៧] *High Command Case វ៉ុល* XI ទំព័រ 548-549 ។

[៨០៨] រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង *Wilhelm List* និងអ្នកផ្សេងទៀត នៅក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuernberg ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ វ៉ុល* XI ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ ១៩៥១ (*"Hostage Case"*)។

00661764



ស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹក[៨០៩] "ពីសំណាក់កងទ័ពនៃកងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់ក្រោមការបញ្ជានិងសមត្ថកិច្ច ការទទួលខុសត្រូវនិងការប្រព្រឹត្តអនុលោមតាមបទបញ្ជាដែលត្រូវបានចេញអនុវត្ត និងផ្សព្វផ្សាយ"[៨១០] ដោយចុងចោទ។ តុលាការបានសម្រេចថា "ក្នុងការកំណត់អំពីពិរុទ្ធភាព ឬនិរទោសនៃចុងចោទនីមួយៗក្នុងចំណោមចុងចោទទាំងនេះ យើងត្រូវតម្រូវឱ្យមានភស្តុតាងអំពីអំពើសកម្ម ឬអកម្មយ៉ាងច្បាស់ក្រឡែត ដែលចេតនាពិរុទ្ធអាចត្រូវបានយោងទៅលើអំពើនោះ មុនពេលសាលក្រមផ្តន្ទាទោស នឹងត្រូវបានប្រកាស"[៨១១]។ ឧត្តមសេនីយ៍ List ត្រូវបានរកឃើញថាមានពិរុទ្ធភាព ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមបទចោទទីមួយ និងទីបី នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទិនទៅនឹងអំពើមនុស្សឃាត និងអំពើធ្វើបាប ដែលត្រូវបានធ្វើឡើងប្រឆាំងនឹងជនស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹករាប់ពាន់នាក់ ពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់ នៅពេលដែលគាត់ជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធនៅប៉ែកអាគ្នេយ៍ក្នុងទឹកដី ដែលត្រូវបានកាន់កាប់នៃប្រទេសយ៉ូហ្គោស្លាវី ប្រទេសក្រិក និងប្រទេសអាល់បានី[៨១២]។ តុលាការរកឃើញថា ភស្តុតាងបានបង្ហាញថា ទាក់ទិននឹងលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័ត* និង*ធាតុផ្សំសត្យានុម័ត* នៃការទទួលខុសត្រូវរបស់ថ្នាក់លើ៖

> របាយការណ៍ដែលធ្វើឡើងជូនចំពោះចុងចោទ List ដែលជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប៉ែកអាគ្នេយ៍ ចោទប្រកាន់គាត់អំពីការដឹងនូវការសម្លាប់ប្រជាជនស្លូតត្រង់រាប់ពាន់នាក់ដោយខុសច្បាប់ ជាការសងសឹងចំពោះអំពើរបស់សមាជិកដែលមិនត្រូវបានស្គាល់អត្តសញ្ញាណ ដែលតាមផ្លូវច្បាប់ មិនត្រូវបានស្ថិតនៅក្រោមការដាក់ទោសទណ្ឌបែបនោះឡើយ។ គាត់មិនដែលថ្កោលទោសអំពើបែបនោះថាខុសច្បាប់ឡើយ។ គាត់មិនដែលហៅអ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះ អំពើយង់ឃ្នង និងអមនុស្សធម៌មកធ្វើការបញ្ជាក់ឡើយ។ ការខកខានពុំបានបញ្ឈប់ការសម្លាប់ដោយ ខុសច្បាប់ទាំងនេះ និងចាត់វិធានការគ្រប់គ្រាន់ដើម្បីទប់ស្កាត់កុំឱ្យអំពើទាំងនេះកើតឡើងម្តងទៀត គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើកាតព្វកិច្ច និងដាក់នូវការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជំនួសឱ្យការចាត់វិធានការដ៏ត្រឹមត្រូវ គាត់បានអនុញ្ញាតដោយសេចក្តីពេញចិត្តឱ្យប្រជាជនស្លូតត្រង់រាប់ពាន់នាក់ស្លាប់ នៅចំពោះមុខក្រុមប្រហារជីវិតរបស់កងកម្លាំងប្រដាប់អាវុធ Wehrmacht និងអង្គភាពយោធាដទៃទៀតដែលប្រតិបត្តិការនៅក្នុង

---

[៨០៩] *Hostage* Case ទំព័រ 765-776, 1233-1234 ។

[៨១០] *Hostage* Case ទំព័រ 765-766 ។

[៨១១] *Hostage* Case ទំព័រ 765-766 ។

[៨១២] *Hostage* Case ទំព័រ 1274 ។

ដែនដីនោះ[៨១៣]។

៤៣២. តុលាការបានបដិសេធការការពារខ្លួនដែលថា គាត់ពុំបានដឹងអំពីរបាយការណ៍ទាំងនេះ ដោយផ្អែកលើមូលដ្ឋានថា "របាយការណ៍ជូនចំពោះឧត្តមសេនីយ៍បញ្ជាការ ត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍ពិសេសរបស់ពួកគាត់។ ការខកខានណាមួយពុំបានដឹងអំពីខ្លឹមសារនៃរបាយការណ៍បែបនោះ ឬការខកខានពុំបានស្នើសុំឱ្យមានរបាយការណ៍បន្ថែម នៅពេលដែលមានកង្វះខាតបង្ហាញឡើងនៅចំពោះមុខរបស់ពួកគាត់ គឺជាសេចក្តីធ្វេសប្រហែសក្នុងករណីកិច្ចដែលគាត់មិនអាចយកមកប្រើដើម្បីជួយខ្លួនគាត់បានឡើយ"[៨១៤]។ លើសពីនេះទៀត ទាក់ទិននឹងលក្ខខណ្ឌថ្នាក់លើ/អ្នកក្រោមបង្គាប់ ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ តុលាការពុំទទួលយកទឡ្ហីករណ៍របស់គាត់ដែលថា ការសម្លាប់ជាច្រើនត្រូវបានធ្វើឡើងដោយអង្គភាពយោធា ដែលជាយុទ្ធសាស្ត្រពុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់[៨១៥]។ តុលាការកត់សម្គាល់ថា "ឧត្តមសេនីយ៍បញ្ជាការលើទឹកដីដែលត្រូវបានកាន់កាប់ ត្រូវបានចោទប្រកាន់អំពីការខកខានក្នុងការបំពេញភារកិច្ចរក្សាសន្តិភាព និងសណ្តាប់ធ្នាប់ ការដាក់ទោសទណ្ឌលើបទឧក្រិដ្ឋ និងការពារអាយុជីវិត និងទ្រព្យសម្បត្តិនៅក្នុងតំបន់ក្រោមការបញ្ជារបស់គាត់។ ការទទួលខុសត្រូវរបស់គាត់មានវិសាលភាពគ្របដណ្តប់លើតំបន់នានាដែលស្ថិតនៅក្រោមការបញ្ជារបស់គាត់"[៨១៦]។ ដូច្នេះ តុលាការយល់ឃើញថា អំណាចរបស់ឧត្តមសេនីយ៍ List មានជាប់មកជាមួយនៅក្នុងតួនាទីនោះ ហើយ "ការទទួលខុសត្រូវជាបឋមចំពោះការទប់ស្កាត់ និងការដាក់ទោសទណ្ឌ ចំពោះបទឧក្រិដ្ឋស្ថិតនៅលើឧត្តមសេនីយ៍បញ្ជាការរូបនេះ។ នេះគឺជាការទទួលខុសត្រូវមួយដែលគាត់មិនអាចគេចផុត ដោយគ្រាន់តែការបដិសេធថាគាត់មិនមានអំណាចលើចារី"[៨១៧] នោះទេ។

៤៣៣. ស្រដៀងគ្នានេះដែរ ឧត្តមសេនីយ៍ Walter Kuntze ដែលទទួលតួនាទីជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប៉ែកអាគ្នេយ៍ពីឧត្តមសេនីយ៍ List ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយ ទីបី និង

---

[៨១៣] *Hostage* Case ទំព័រ 1271-1272 ។

[៨១៤] *Hostage* Case ទំព័រ 1271 ។

[៨១៥] *Hostage* Case ទំព័រ 1272 ។

[៨១៦] *Hostage* Case ទំព័រ 1271 ។

[៨១៧] *Hostage* Case ទំព័រ 1272 ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ទីបួន ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹករាប់ពាន់នាក់ពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់[៨១៨]។ តុលាការសម្រេចថា គាត់ទទួលខុសត្រូវក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះការប្រមូលផ្តុំជនជាតិ Jews និង Gypsies នៅក្នុងជំរំប្រមូលផ្តុំ និងការសម្លាប់ជនជាតិទាំងនោះ នៅពេលដែលតុលាការរកឃើញថា ៖

> ភស្តុតាងបង្ហាញនូវការប្រមូលផ្តុំជនជាតិ Jews នៅក្នុងជំរំប្រមូលផ្តុំ និងការសម្លាប់ជនជាតិ Jews និងជនជាតិ Gypsies មួយក្រុមធំភ្លាមៗបន្ទាប់ពីចុងចោទបានកាន់តួនាទីជាបញ្ជាការនៅប៉ែកអាគ្នេយ៍ពីសំណាក់អង្គភាពស្ថិតក្រោមបង្គាប់គាត់។ កំណត់ហេតុពុំបានបង្ហាញថាចុងចោទ Kuntze បានបញ្ជាឲ្យបាញ់សម្លាប់ជនជាតិ Jews ឬផ្ទេរពួកគេទៅជំរំប្រមូលផ្តុំឡើយ។ ភស្តុតាងបង្ហាញថា គាត់បានដឹងតាមរយៈរបាយការណ៍ថា អង្គភាពក្រោមបង្គាប់គាត់បានបាញ់សម្លាប់ជនជាតិ Jews និង Gypsies មួយក្រុមធំ ដូចដែលបានបញ្ជាក់ពីខាងលើ។ គាត់ពិតជាបានដឹងថា កង ទ័ពក្រោមបង្គាប់របស់គាត់ បានប្រមូល និងដឹកជញ្ជូនជនជាតិ Jews ទៅកាន់ជំរំប្រមូលផ្តុំ។ នៅក្នុងរបាយការណ៍ពុំមានបង្ហាញថា ចុងចោទ Kuntze បានចាត់វិធានការបញ្ឈប់អំពើខុសច្បាប់បែបនេះឡើយ។ វាច្បាស់ណាស់ដែលថា គាត់ពុំជំទាស់នឹងការអនុវត្តរបស់ពួកគេឡើយ នៅពេលដែលគាត់មានភារកិច្ចធ្វើអន្តរាគមន៍ដើម្បីទប់ស្កាត់កុំឲ្យអំពើទាំងនេះកើតឡើងជាថ្មីទៀត។ យើងយល់ថាការទទួលខុសត្រូវរបស់គាត់ ចំពោះអំពើខុសច្បាប់ទាំងនេះបានបង្ហាញយ៉ាងគ្រប់គ្រាន់តាម រយៈរបាយការណ៍[៨១៩]។

៤៣៨. លើសពីនេះទៀត មេបញ្ជាការនៃកងទ័ពបម្រុង LXIX (LXIX Reserve Corps) នៅក្នុងប្រទេសក្រូអាស៊ីប៉ែកខាងជើង ឧត្តមសេនីយ៍ Ernst Dehner ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះការសម្លាប់ចំណាប់ខ្មាំងស៊ីវិលរាប់ពាន់នាក់ដោយខុសច្បាប់ និងការសងសឹកប្រឆាំងនឹងអ្នកទោសស៊ីវិល ដែលធ្វើឡើងដោយអ្នកក្រោមបង្គាប់ផ្ទាល់របស់គាត់ដែលអំពើទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៨២០]។ តុលាការរកឃើញថា "កំណត់ហេតុបង្ហាញថាចុងចោទនេះបានដឹងច្បាស់អំពីអំពើទាំងនេះ។ [...] តាមរយៈការពិនិត្យភស្តុតាងបង្ហាញឲ្យយើងឃើញថា ការអនុវត្តការសម្លាប់ចំណាប់ខ្មាំង និងការសងសឹក

---

[៨១៨] *Hostage* Case ទំព័រ 1281 ។

[៨១៩] *Hostage* Case ទំព័រ 1279-1280 ។

[៨២០] *Hostage* Case ទំព័រ 1297, 1299 ។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00661767



អ្នកទោស គឺមិនអាចគ្រប់គ្រងបាន នីត្យានុកូលភាពមិនត្រូវបានគេអើពើ ហើយអំពើតាមតែទំនើងចិត្តបានក្លាយជាគោលនយោបាយដែលត្រូវបានគេទទួលយក។ ចុងចោទគឺជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការអនុញ្ញាតឬការអត់ធ្មត់ចំពោះអំពើបែបនេះនៅលើផ្នែកនៃមេបញ្ជាការក្រោមបង្គាប់របស់គាត់"[៨២១]។ ក្នុងការឆ្លើយតបទៅនឹងការការពារខ្លួនរបស់ឧត្តមសេនីយ៍ Dehner ដែលថា មេបញ្ជាការតំបន់ដែលជាអ្នកទទួលខុសត្រូវចំពោះការចេញបញ្ជាឱ្យប្រព្រឹត្តអំពើទាំងឡាយនោះ តុលាការយល់ស្រប ប៉ុន្តែតុលាការយល់ឃើញថា "មេបញ្ជាការថ្នាក់លើក៏ទទួលខុសត្រូវផងដែរ ប្រសិនបើគាត់ចេញបញ្ជាអនុញ្ញាត ឬត្រូវរ៉ូវគ្នានៅក្នុងអំពើឧក្រិដ្ឋបែបនោះ។ ភារកិច្ច និងកាតព្វកិច្ចរបស់គាត់គឺទប់ស្កាត់នូវអំពើបែបនេះ ឬប្រសិនបើអំពើបែបនេះត្រូវបានប្រព្រឹត្តរួចហើយ គឺត្រូវចាត់វិធានការដើម្បីទប់ស្កាត់ កុំឱ្យអំពើនោះកើតឡើងជាថ្មីទៀត"[៨២២]។

៤៣៥. ដូចគ្នានេះដែរ ឧត្តមសេនីយ៍ Hubert Lanz ត្រូវបានផ្តន្ទាទោស ចំពោះការខកខានពុំបានទប់ស្កាត់នូវការសងសឹកដោយខុសច្បាប់ប្រឆាំងនឹងជនស៊ីវិលស្លូតត្រង់ ដែលជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមបទចោទទីមួយ ដែលត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់[៨២៣]។ តុលាការសម្រេចថា ៖

> ចុងចោទនិយាយថាជាមេបញ្ជាការកលយុទ្ធ គាត់មានការមមាញឹកយ៉ាងខ្លាំងមិនបានចាប់អារម្មណ៍ទៅលើបញ្ហានៃការសងសឹកឡើយ។ នេះគឺជាការដោះសារដែលពុំគួរឱ្យជឿឡើយ។ ការសម្លាប់ប្រជាជនស្លូតត្រង់ដោយខុសច្បាប់ គឺជាបញ្ហាមួយដែលទាមទារនូវការចាត់ចែងប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័សពីសំណាក់នាយទាហានឋានៈខ្ពស់បំផុតនៃកងទ័ព។ ចុងចោទនេះ ដោយបានដឹងយ៉ាងច្បាស់អំពីអ្វីដែលកំពុងកើតឡើង ពុំបានធ្វើអ្វីទាល់តែសោះអំពីបញ្ហានេះ។ ពុំឃើញមានបទបញ្ជាណាមួយ ដែលបញ្ជាក់ពីគោលបំណងក្នុងការដាក់ចំណាប់ខ្មាំង និងការអនុវត្តការសងសឹកនៅក្នុងវិធានសង្គ្រាមឡើយ។ ចុងចោទពុំបានសូម្បីតែអះអាងថា គាត់បានធ្វើឡើយ។ ក្នុងនាមជាមេបញ្ជាការកងទ័ព XXII Corps គាត់មានកាតព្វកិច្ចចាត់វិធានការ ហើយនៅពេលដែលគាត់ពុំបានចាត់វិធានការ និងបានអនុញ្ញាតឱ្យមានការសម្លាប់ដោយខុសច្បាប់ និងអមនុស្សធម៌ទាំងនេះកើតឡើងបន្តទៀតនោះ គាត់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

---

[៨២១] *Hostage* Case ទំព័រ 1299 ។

[៨២២] *Hostage* Case ទំព័រ 1298 ។

[៨២៣] *Hostage* Case ទំព័រ 1313 ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៤៣៦. ចុងក្រោយ ឧត្តមសេនីយ៍ Wilhelm Speidal ជាមេបញ្ជាការយោធានៅប្រទេសក្រិកប៉ែកខាងត្បូង ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយ ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះការអនុវត្តការសម្លាប់ចំណាប់ខ្មាំង និងការសម្លាប់សងសឹកដោយខុសច្បាប់ ប្រឆាំងនឹងប្រជាជនស៊ីវិលពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់[៨២៤]។ តុលាការយល់ឃើញថា "មេបញ្ជាការយោធានៅប្រទេសក្រិក អាច*ត្រួតត្រា*ទៅលើការអនុវត្តការសងសឹក និងចំណាប់ខ្មាំង តាមរយៈបញ្ជាការដ្ឋានអនុតំបន់នានា ដែលស្ថិតក្រោមបញ្ជារបស់គាត់មិនអាចត្រូវបានចោទជាបញ្ហាទេ"[៨២៥]។ លើសពីនេះទៀត តុលាការយល់ឃើញថា ភស្តុតាងបានបង្ហាញថាឧត្តមសេនីយ៍ Speidal បានដឹងអំពីអំពើទាំងនេះ និងបានអនុញ្ញាតឲ្យអំពើទាំងនេះកើតមានឡើង[៨២៦]។

៤៣៧. រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Karl Brandt និងអ្នកផ្សេងទៀត* (*"Medical Case"*)[៨២៧] គឺជារឿងក្តីមួយទៀតរបស់តុលាការ NMT ដែលបានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទោះបីជាយ៉ាងណាក៏ដោយ និយាយដោយជាក់ច្បាស់ទៅ មិនដូចជារឿងក្តីទាក់ទងនឹង*បញ្ជាការជាន់ខ្ពស់* (*High Command Case*) និងរឿងក្តី*ចំណាប់ខ្មាំង* (*Hostage Case*) ឡើយ ទ្រឹស្តីនេះត្រូវបានយកមកអនុវត្តចំពោះចុងចោទ Karl Brandt ដែលពុំមែនជាថ្នាក់លើផ្នែកយោធា។ ក្នុងឆ្នាំ ១៩៣៤ គាត់គឺជាគ្រូពេទ្យផ្ទាល់ខ្លួនរបស់ Hitler និងជាសមាជិកម្នាក់របស់ Allgemeigne SS។ ក្នុងឆ្នាំ១៩៤០ គាត់ត្រូវបានផ្ទេរទៅក្រុមប្រដាប់អាវុធរបស់កងទ័ព SS ដែលជាកងកម្លាំងប្រដាប់អាវុធ Waffen SS ដែលកិច្ចការប្រតិបត្តិនានាស្មើគ្នាទៅនឹងកិច្ចការប្រតិបត្តិរបស់កងទ័ព ទោះបីជាវាពុំមែនជាផ្នែកនៃកងទ័ពអាល្លឺម៉ង់ ក៏ដោយ[៨២៨]។ តាមរយៈក្រឹត្យដែលចេញដោយ Hilter នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៤៤ Brandt បាន ក្លាយជាអគ្គាធិការសម្រាប់សេវាសុខភាព និងវេជ្ជសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់ "ដែលផ្តល់អំណាចឲ្យគាត់ចេញសេចក្តីណែនាំទៅកាន់គ្រប់សេវាផ្នែកវេជ្ជសាស្ត្រទាំងអស់របស់រដ្ឋ បក្ស និងកងកម្លាំង ប្រដាប់អាវុធអាល្លឺម៉ង់ (Wehrmacht) ទាក់ទិននឹង

---

[៨២៤] *Hostage* Case ទំព័រ 1317 ។

[៨២៥] *Hostage* Case ទំព័រ 1314 ។

[៨២៦] *Hostage* Case ទំព័រ 1315-1316 ។

[៨២៧] រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង *Wilhelm List* និងអ្នកផ្សេងទៀត នៅក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuernberg* *ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ វ៉ុល* XI ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ១៩៥១ (*"Hostage Case"*)។

[៨២៨] *Medical* Case វ៉ុល II ទំព័រ 190 ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

បញ្ហាវេជ្ជសាស្ត្រ" ទាំងស៊ីវិល និងយោធា[៨២៩]។ តុលាការយល់ឃើញថា ក្រៅពីទស្សនកិច្ចរបស់គាត់ទៅកាន់ជំរំប្រមូលផ្តុំ Brandt បានដឹងអំពីការធ្វើពិសោធន៍សារធាតុ sulfanilamide ទៅលើមនុស្ស នៅ Ravensbrueck អស់រយៈពេលប្រហែលមួយឆ្នាំ មុនខែ សីហា ឆ្នាំ ១៩៤៣ នៅកិច្ចប្រជុំមួយដែលធ្វើឡើងក្នុងខែ ឧសភា ឆ្នាំ ១៩៤៣ ដែលនៅទីនោះរបាយការណ៍ស្តីពីការធ្វើពិសោធន៍ត្រូវបានធ្វើឡើង[៨៣០]។ នៅពេលនោះ៖

> នៅក្នុងវិស័យវេជ្ជសាស្ត្រ Karl Brandt បានកាន់មុខតំណែងមួយដ៏ខ្ពស់ជាងគេបំផុតនៅក្រោម Hitler ដោយផ្ទាល់។ គាត់ស្ថិតនៅក្នុងមុខតំណែងមួយដែលត្រូវធ្វើអន្តរាគមន៍ទៅសមត្ថកិច្ចនានាលើរាល់បញ្ហាដែលទាក់ទិននឹងវេជ្ជសាស្ត្រ។ តាមពិត មុខតំណែងបែបនោះ ហាក់ដូចជាតួនាទី ដែលមានលក្ខណៈវិជ្ជាមានរបស់គាត់។ វាពុំបង្ហាញឱ្យឃើញថា នៅគ្រប់ពេលទាំងអស់ គាត់បានចាត់វិធានការណាមួយ ដើម្បីពិនិត្យមើលការពិសោធន៍ផ្នែកវេជ្ជសាស្ត្រលើមនុស្សឡើយ។ [...] ក្នុងការកាន់កាប់មុខតំណែងដែលគាត់បាន និងកំពុងមានតួនាទីជាគ្រូពេទ្យមួយរូប ដែលមានសមត្ថភាព និងបទពិសោធន៍ ភារកិច្ចគឺស្ថិតលើរូបគាត់ដែលត្រូវធ្វើការស៊ើបអង្កេតមួយចំនួនឱ្យបានគ្រប់គ្រាន់ ទាក់ទិននឹងការស្រាវជ្រាវពិសោធន៍ផ្នែកវេជ្ជសាស្ត្រដែលរូបគាត់បានដឹងដោយមិនបាច់សង្ស័យទេថា បាននិងកំពុងតែបន្តធ្វើនៅក្នុងជំរំប្រមូលផ្តុំ[៨៣១]។

៤៣៨. ដូច្នេះ តុលាការសន្និដ្ឋានថា ៖

> យើងយល់ឃើញថា Karl Brandt *បានទទួលខុសត្រូវ* បានជួយនិងជំរុញ បានចូលរួមដោយយល់ព្រម និងពាក់ព័ន្ធជាមួយនឹងផែនការ និងសហកម្ម ដែលទាក់ទិននឹងការធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានធ្វើឡើងទៅលើអ្នកដែលមិនមែនជាជនជាតិអាល្លឺម៉ង់ ដោយពុំមានការយល់ព្រមពីពួកគាត់ និងនៅក្នុងអំពើឃោរឃៅដទៃផ្សេងៗទៀត ដែលនៅក្នុងអំឡុងពេលនោះ អំពើមនុស្សឃាត ភាពសាហាវយង់ឃ្នង ភាពព្រៃផ្សៃ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត ត្រូវបានប្រព្រឹត្តឡើង។ ក្នុងវិសាលភាពដែលអំពើឧក្រិដ្ឋទាំងនេះ ពុំបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម អំពើឧក្រិដ្ឋបែបនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៨៣២]។

---

[៨២៩] *Medical* Case, វ៉ុល II ទំព័រ 191-192។

[៨៣០] *Medical* Case, វ៉ុល II ទំព័រ 193 ។

[៨៣១] *Medical* Case, វ៉ុល II ទំព័រ 193-194 ។

[៨៣២] *Medical* Case, វ៉ុល II ទំព័រ 198 (សេចក្តីបញ្ជាក់បន្ថែម) ។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៤៣៩. ស្រដៀងគ្នានេះដែរ សហចុងចោទរបស់ Brandt គឺឈ្មោះ Oskar Schroeder ត្រូវបានផ្តន្ទាទោសក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងឈ្លើយសឹក និងជនស៊ីវិលដែលពុំមែនជនជាតិអាល្លឺម៉ង់ ដោយសារតែការធ្វើពិសោធន៍ត្រាំ ក្នុងទឹកកកត្រជាក់ ដែលត្រូវបានគេធ្វើឡើងក្នុងឆ្នាំ១៩៤២ នៅជំរំប្រមូលផ្តុំ Dachau ដើម្បីផលប្រយោជន៍របស់កងទ័ពអាកាស (Luftwaffe)។ តុលាការរកឃើញថា នៅពេលដែលគាត់បានក្លាយជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃ Luftwaffe គាត់បានដឹងពិតប្រាកដអំពីការពិសោធន៍ ដែលបណ្តាលឱ្យអ្នកដែលជាកម្មវត្ថុសម្រាប់ការពិសោធន៍ ដែលពុំមែនជាជនជាតិអាល្លឺម៉ង់មានការឈឺចាប់ និងស្លាប់ជាច្រើននាក់។ គាត់ក៏បានដឹងថា ការស្រាវជ្រាវវ៉ាក់សាំងសម្រាប់ជំងឺគ្រុនសន្និ ត្រូវបានប្រើទៅលើអ្នក ដែលជាកម្មវត្ថុសម្រាប់ការពិសោធន៍ដែលពុំមែនជាជនជាតិអាល្លឺម៉ង់នៅជំរំប្រមូលផ្តុំ Natzweiler និង Schirmeck ក្នុងឆ្នាំ១៩៤២-១៩៤៣ ហើយគាត់បានដឹងតាមរយៈរបាយការណ៍ដែលផ្ញើជូនគាត់ដែលថាបណ្តាលឱ្យមានការស្លាប់ ប៉ុន្តែគាត់ពុំបានស៊ើបសួរទៅលើចំណុចនេះឡើយ[៨៣៣]។ តុលាការបានផ្តន្ទាទោសគាត់ចំពោះការធ្វើពិសោធន៍ទាំងនេះ ដែលធ្វើឡើងដោយអ្នកក្រោមបង្គាប់ ដោយយល់ឃើញថា “ច្បាប់សង្គ្រាមដាក់ទៅលើនាយទាហានដែលកាន់តួនាទីក្នុងការបញ្ជា ដែលមានភារកិច្ចវិជ្ជមានក្នុងការចាត់វិធានការនានាដែលស្ថិតក្នុងអំណាចរបស់គាត់ និងសមស្របចំពោះកាលៈទេសៈ ដើម្បីគ្រប់គ្រងអ្នកទាំងឡាយណាដែលស្ថិតក្រោមបញ្ជារបស់គាត់ ដើម្បីទប់ស្កាត់អំពើទាំងឡាយដែលរំលោភលើច្បាប់សង្គ្រាម”[៨៣៤]។

៤៤០. សហចុងចោទម្នាក់ទៀត ឈ្មោះ Sigfried Handloser ក៏ត្រូវបានផ្តន្ទាទោសផងដែរ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិលអាល្លឺម៉ង់ និងជនស៊ីវិលដែលពុំមែនជាជនជាតិអាល្លឺម៉ង់ និងឈ្លើយសឹក នៅក្នុងតួនាទីរបស់គាត់ជាថ្នាក់លើផ្នែកយោធា[៨៣៥]។ តុលាការយល់ឃើញថា Handloser បានដឹងពិតប្រាកដអំពីការពិសោធន៍ត្រាំក្នុងទឹកកកត្រជាក់ និងការពិសោធន៍សារធាតុ Sulfanimide ដែលត្រូវបានធ្វើឡើងទៅលើអ្នកទោស

---

[៨៣៣] *Medical* Case វ៉ុល II ទំព័រ 211-213 ។

[៨៣៤] *Medical* Case វ៉ុល II ទំព័រ 212 ។

[៨៣៥] ជាពិសេស “ជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃ Wehrmacht ដែលកាន់តួនាទីជាថ្នាក់លើគ្រប់គ្រងសេវាវេជ្ជសាស្ត្រកងទ័ព និងជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃកងទ័ពជើងទឹក និង Luftwaffe និងស្ថាប័នចំណុះមួយចំនួនទៀត ដែលពាក់ព័ន្ធនឹង Wehrmacht។ តារាងក៏បានបង្ហាញអំពីអំណាចរបស់គាត់ទៅលើប្រធានការិយាល័យផ្នែកសេវាវេជ្ជសាស្ត្រនៃ Waffen SS និងផ្នែកនានានៃ Waffen SS នៅពេលបញ្ចូលជាមួយនឹង Wehrmacht.” *Medical* Case វ៉ុល II, ទំព័រ 212 ។

ដោយពុំមានការយល់ព្រមពីពួកគាត់ ហើយដែលបានបណ្ដាលឱ្យពួកគាត់ស្លាប់។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ពុំបានព្យាយាមធ្វើការស៊ើបអង្កេត ឬគ្រប់គ្រងលើអ្នកក្រោមបង្គាប់របស់គាត់ដែលកំពុងអនុវត្តការពិសោធន៍នោះឡើយ[៨៣៦]។ ដោយដកស្រង់យុត្តិសាស្ត្ររឿងក្ដី *Yamashita* ចៅក្រមបានសម្រេចថា ៖

> ទាក់ទិននឹងការទទួលខុសត្រូវរបស់ Handloser ចំពោះការធ្វើពិសោធន៍ដោយខុសច្បាប់ទៅលើមនុស្ស ភស្តុតាងបង្ហាញថា ដោយដឹងអំពីការយកអ្នកដែលពុំមែនជាជនជាតិអាល្លឺម៉ង់ មកធ្វើជាកម្មវត្ថុសម្រាប់ការពិសោធន៍មនុស្សជារឿយៗ គាត់ពុំបានអនុវត្តកម្រិតក្នុងការគ្រប់គ្រងឱ្យបានត្រឹមត្រូវទៅលើអ្នកដែលនៅក្រោមបង្គាប់របស់គាត់ឡើយ ដែលជាប់ពាក់ព័ន្ធនឹងការពិសោធន៍ផ្នែកវេជ្ជសាស្ត្រដែលស្ថិតនៅក្នុងផ្នែកសមត្ថកិច្ចជាផ្លូវការរបស់គាត់។ នេះគឺជាភារកិច្ចមួយដែលត្រូវបានប្រគល់ឱ្យគាត់ទទួលខុសត្រូវ ដោយយោងលើតួនាទីផ្លូវការរបស់គាត់។ ប្រសិនបើគាត់បានអនុវត្តការទទួលខុសត្រូវរបស់គាត់ អ្នកដែលពុំមែនជាជនជាតិអាល្លឺម៉ង់យ៉ាងច្រើន ប្រាកដជាបានរួចផុតពីអំពើមនុស្សឃាត។ នៅក្នុងកម្រិតណាមួយនោះ ឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តដោយអំណាចរបស់គាត់ ឬដោយអ្នកក្រោមអំណាចរបស់គាត់ពុំមែនជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។ ឧក្រិដ្ឋកម្មទាំងនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៨៣៧]។

៤៤១. ទីបួន នៅក្នុងរឿងក្ដី*សហរដ្ឋអាមេរិក ទល់នឹង* *Ernst von Weizsaecker* ***និងអ្នកផ្សេងទៀត*** *("Ministries Case")*[៨៣៨] Gottlob Berger ដែលជាប្រធានទីស្នាក់ការកណ្ដាល SS (Main Office SS) ចាប់ពីឆ្នាំ ១៩៤០ ដល់ឆ្នាំ ១៩៤៥ និងជាភ្នាក់ងារទំនាក់ទំនងក្រសួងរបស់ Himmler សម្រាប់ទឹកដីប៉ែកខាងកើត ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយអង្គភាព Dirlewanger ដែល*ជាក់ស្ដែង* ស្ថិតក្រោមបង្គាប់របស់គាត់[៨៣៩]។

---

[៨៣៦] *Medical* Case វ៉ុល II, ទំព័រ 206។

[៨៣៧] *Medical* Case វ៉ុល II, ទំព័រ 206 ។

[៨៣៨] រឿងក្ដីសហរដ្ឋអាមេរិក ទល់នឹង *Ernst von Weizsaecker* និងអ្នកផ្សេងទៀត នៅក្នុងការជំនុំជម្រះក្ដីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuernberg* ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ វ៉ុល XII-XIV ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ ១៩៥១ ("*Ministries* Case") ។

[៨៣៩] នៅសមរភូមិ អង្គភាពមិនស្ថិតនៅក្រោមការបង្គាប់បញ្ជាផ្នែកកលយុទ្ធរបស់គាត់ទេ។ អង្គភាពនោះត្រូវបានរៀបចំឡើងដោយរូបគាត់ និងបណ្ដុះបណ្ដាលដោយបុគ្គលដែលគាត់បានជ្រើសរើស។ វាជាគំនិតរបស់គាត់។ អង្គភាព និងមេបញ្ជាការរបស់អង្គភាពនេះស្ថិតក្រោមការការពាររបស់គាត់។ គាត់ជារឿយៗបានទទួលព័ត៌មានអំពីទង្វើដែលគ្មានអារ្យធម៌ និងសាហាវឃោរឃៅរបស់អង្គភាពនេះ ដែលគាត់មិនត្រឹមតែបានអនុញ្ញាតឱ្យបន្តសកម្មភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានព្យាយាមធ្វើយុត្តិកម្ម

ដូចគ្នានឹង Karl Brandt ដែរ និយាយឱ្យចំទៅគាត់ពុំមែនជាថ្នាក់លើផ្នែកយោធាឡើយ។ គាត់ជាឧត្តមសេនីយ៍ឯក នៅក្នុងកងទ័ព Waffen SS ហើយលើសពីនេះទៀត គាត់ក៏កាន់តួនាទីមួយចំនួនទៀតនៅក្នុងរដ្ឋាភិបាលផងដែរ[៨៤០]។

៤៤២. ទីប្រាំ នៅក្នុងរឿងក្ដីគណៈកម្មាធិការរដ្ឋាភិបាលនៃតុលាការទូទៅរបស់រដ្ឋាភិបាលយោធាសម្រាប់តំបន់ដែលត្រួតត្រាដោយប្រទេសបារាំងនៅក្នុង *ប្រទេសអាល្លឺម៉ង់ទល់នឹង Roechling* ("រឿងក្ដី Roechling") ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៤៩[៨៤១] ឧស្សាហករជនជាតិអាល្លឺម៉ង់ឈ្មោះ Hermann Roechling និងvon Gemmingen-Hornberg ត្រូវបានដាក់ឱ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មសង្គ្រាម ចំពោះការប្រព្រឹត្តអមនុស្សធម៌ពីសំណាក់នគរបាលសន្តិសុខផ្ទៃក្នុងអាល្លឺម៉ង់(Gestapo) ទៅលើនិរទេសជនបរទេស និងកម្មករដែលជាឈ្លើយសឹក នៅក្នុងរោងចក្ររបស់ពួកគាត់ តាមរយៈប្រព័ន្ធវិន័យដែលត្រូវបានបង្កើតឡើងដោយមានការយល់ព្រមជាមុនពីពួកឧស្សាហករ[៨៤២]។ ទោះបីជាតុលាការបញ្ជាក់ថា ថ្នាក់លើជាជនស៊ីវិលពីរនាក់នេះ "បានអនុញ្ញាត" និង "បានជំរុញ" នូវអត្ថិភាព និងអភិវឌ្ឍន៍បន្ថែមទៀតនៃប្រព័ន្ធ នៃការប្រព្រឹត្តអមនុស្សធម៌នេះ នៅក្នុងរោងចក្ររបស់ពួកគាត់

---

ផងដែរ។ គាត់បានខិតខំប្រឹងប្រែងដើម្បីឱ្យមានការផ្ទេរ ឬបំបែកអង្គភាពនេះ ដោយបានស្នើឱ្យមានការដំឡើងឋានន្តរស័ក្តមេបញ្ជាការអង្គភាពនេះ និងបានជួយការពារគាត់។ គោលបំណងមួយក្នុងចំណោមគោលបំណងនានា ដែលកងពលតូចត្រូវបានបង្កើតឡើង គឺដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា អង្គភាពនេះបានប្រព្រឹត្តដូច្នេះ ដល់កម្រិតមួយដែលបានធ្វើឱ្យមានការភ័យខ្លាច និងរន្ធត់ដល់ស្នងការរបស់ Nazi និងក្រសួងសម្រាប់ទឹកដីប៉ែកខាងកើតរបស់ Rosenberg ដែលស្ទើរតែមិនអាចត្រូវបានចោទប្រកាន់ដោយយុត្តិធម៌អំពីការអត់អោនដល់ជនជាតិជ្វីហ្វ និងប្រជាជននៃទឹកដីប៉ែកខាងកើតត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ ការទទួលខុសត្រូវរបស់ Berger មានលក្ខណៈច្បាស់ក្រឡែត។ គាត់មានពិរុទ្ធភាពទាក់ទិនទៅនឹងបញ្ហានានា ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ពាក់ព័ន្ធនឹងសកម្មភាពរបស់អង្គភាព Dirlewanger ហើយយើងយល់ឃើញបែបនេះ។ *Ministries Case* វ៉ុល XIV ទំព័រ ៥៤៥-៥៤៦។

[៨៤០] *Ministries* Case, វ៉ុល XII ទំព័រ 17-18 ។

[៨៤១] គណៈកម្មាធិការរដ្ឋាភិបាលនៃតុលាការទូទៅរបស់រដ្ឋាភិបាលយោធាសម្រាប់តំបន់ ដែលត្រួតត្រាដោយប្រទេសបារាំងនៅក្នុង *ប្រទេសអាល្លឺម៉ង់ ទល់នឹង Roechling* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសាលក្រមរបស់តុលាការទូទៅរបស់រដ្ឋាភិបាលយោធាសម្រាប់តំបន់ដែលត្រួតត្រាដោយប្រទេសបារាំងនៅក្នុងប្រទេសអាល្លឺម៉ង់ បោះពុម្ពឡើងវិញនៅក្នុងការជំនុំជម្រះក្ដីឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា *Nuremberg ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០* វ៉ុល XIV ឧបសម្ព័ន្ធ B ("រឿងក្ដី *Roechling*")។

[៨៤២] *រឿងក្ដី Roechling* ទំព័រ 1135, 1140។

យ៉ាងណាក៏ដោយ[៨៤៣] អំពើពិរុទ្ធរបស់ Hermann Roechling ក៏ស្ថិតនៅក្នុងពាក្យនៃការខក ខានផងដែរ ក្នុងនាមជាថ្នាក់លើ។ តុលាការយល់ឃើញថា ដោយពិចារណាលើតួនាទី និងអំណាច របស់គាត់ វាគឺជា៖

ភារកិច្ចរបស់គាត់ក្នុងការទទួលព័ត៌មានអំពីការប្រព្រឹត្តមកលើនិរទេសជន។ ការពិតដែលគាត់ ពុំបានខ្វល់អំពីជោគវាសនារបស់និរទេសជនទាំងនះ កាន់តែបង្កើនការទទួលខុសត្រូវរបស់គាត់ ថែមទៀត។ នៅក្នុងការកាន់តួនាទីពីររបស់គាត់ ជាប្រធានរោងចក្រ Voelklingen និងជា ប្រធាននៃ Reich Association Iron គាត់មានអំណាចគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមន៍ និង បន្ថយកុំឱ្យមានការរំលោភបំពានធ្ងន់ធ្ងរ ទោះបីជាគាត់ពុំអាចបញ្ឈប់អំពើរំលោភបំពានទាំងនោះ បានទាំងស្រុងក៏ដោយ។ សាលក្រមដែលត្រូវបានជំទាស់ បង្ហាញដោយមានសុពលភាពថា សាក្សីជាច្រើនបានអះអាងថា Hermann Roechling មានឱកាសជាច្រើនលើកក្នុងការត្រួត ពិនិត្យទៅលើផ្នែកដែលពាក់ព័ន្ធចំពោះរូបគាត់ដើម្បីឱ្យដឹងប្រាកដអំពីជោគវាសនា ដែលត្រូវ បានកំណត់ទៅលើបុគ្គលិករបស់គាត់។ តាមរយៈឯកសណ្ឋានអ្នកទោសនៅក្នុងអំឡុងដែល គាត់ចុះពិនិត្យទាំងនោះ គាត់មិនអាចបដិសេធថា គាត់មិនបានដឹងអំពីអំពើរំលោភបំពានទាំង នោះបានទេ[៨៤៤]។

៨៤៣. ស្រដៀងគ្នានេះដែរ ទាក់ទិននឹង von Gemmingen-Hornberg តុលាការបញ្ជាក់ថាគាត់៖

គឺជាប្រធានគណៈនាយក Stahlwerke Roechling។ លើសពីនេះទៀត គាត់បានកាន់តួនាទីជា អ្នកគ្រប់គ្រងផ្នែកការងារ គឺថាជាអ្នកតំណាងផ្នែកការងារនៅក្នុងការពិភាក្សាចរចាជាមួយនឹង អាជ្ញាធរនានា ដែលមានសមត្ថកិច្ចពិសេសដើម្បីដោះស្រាយបញ្ហានានាទាក់ទិននឹងការងារ។ ផ្នែក សមត្ថកិច្ចរបស់គាត់ក៏រួមបញ្ចូលផងដែរ នូវទំនាក់ទំនងជាមួយនឹង Gestapo ទាក់ទិននឹង ប៉ូលីសផ្នែកការងារ។ Von Gemmingen-Hornberg អះអាងថា គាត់ពុំមានសមត្ថភាពក្នុង ការផ្លាស់ប្តូរស្ថានភាពដែលគាត់បានដឹងនោះឡើយ ដោយសារតែកម្មករដែលត្រូវបាននិរទេស ទាំងនោះស្ថិតនៅក្រោមអំណាចរបស់ Gestapo និងសហជីពជាតិសង្គមនិយមអាល្លឺម៉ង់ (German Labor Front)។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីខ្ពស់ដែលគាត់កាន់បានផ្តល់ ឱ្យគាត់នូវអំណាចគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមន៍ និងដើម្បីធានាធ្វើឱ្យមានលក្ខណៈប្រសើរក្នុង ការប្រព្រឹត្តចំពោះនិរទេសជន ដែលត្រូវបានផ្តន្ទាទោសទាំងនោះ[៨៤៥]។

---

[៨៤៣] រឿងក្តី *Roechling* ទំព័រ 1136, 1140 ។

[៨៤៤] រឿងក្តី *Roechling* ទំព័រ 1136 ។

[៨៤៥] រឿងក្តី *Roechling* ទំព័រ 1136។



អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

៤៤៤. ទីប្រាំមួយ សាលក្រមតុលាការយោធាអន្តរជាតិតូក្យូ ឆ្នាំ១៩៤៩ បញ្ជាក់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្រោមជំពូក II ដែលមានចំណងជើងថា "ច្បាប់" ទាក់ទិនទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងអ្នកទោស និងយកវាមកអនុវត្តលើនាយទាហាន ឬនាយទាហានជើងទឹក ដែលបញ្ជាទៅលើអង្គភាពយោធានានាដែលមានអ្នកទោសនៅក្នុងដៃរបស់ពួកគាត់ មន្ត្រីទាំងឡាយក្នុងនាយកដ្ឋាននានាដែលទទួលខុសត្រូវចំពោះសុខុមាលភាពរបស់អ្នកទោស និងមន្ត្រីនានា មិនថាផ្នែកស៊ីវិល យោធា ឬជើងទឹកឡើយដែលមានការត្រួតត្រាលើអ្នកទោសដោយផ្ទាល់[៨៤៦]។ ទោះបីជាសាលក្រមពុំបានសំដៅឱ្យបានច្បាស់លាស់ទៅលើ "ការទទួលខុសត្រូវរបស់ថ្នាក់លើ" នៅពេលដែលសាលក្រមនេះរៀបរាប់អំពីច្បាប់ជាធរមានទាក់ទិននឹងបញ្ហានេះយ៉ាងណាក៏ដោយ ក៏ពាក្យពេចន៍ដែលប្រើនោះ អនុលោមតាមធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្តីដែលមាននៅក្នុងច្បាប់ អ.វ.ត.ក។ សាលក្រមបញ្ជាក់ថា មន្ត្រីទាំងអស់ដោយផ្អែកលើតួនាទីរបស់ពួកខ្លួន មានភារកិច្ចទប់ស្កាត់មិនឱ្យមានការធ្វើបាបលើអ្នកទោស តាមរយៈ "ការបង្កើត និងការពារនូវដំណើរការ ប្រព័ន្ធមួយដ៏មានប្រសិទ្ធភាព និងនិរន្តរភាពដែលសមស្របសម្រាប់គោលបំណងទាំងនេះ[៨៤៧]។ នៅពេលដែលប្រព័ន្ធនោះត្រូវបានបង្កើតឡើង មន្ត្រីទាំងនោះមិនទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងអ្នកទោសនោះទេ លើកលែងតែ ៖

> (១) *ពួកគាត់បានដឹង*ថាបទឧក្រិដ្ឋបែបនោះត្រូវបានកំពុងប្រព្រឹត្តឡើង និងដោយបានដឹងបែបនេះ *ហើយពួកគាត់ខកខានពុំបានចាត់វិធានការ ដែលស្ថិតនៅក្នុងអំណាចរបស់ពួកគាត់ ដើម្បីទប់ស្កាត់*នូវការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះនៅពេលអនាគត ឬ (២) ពួកគេទទួលខុសត្រូវចំពោះការខកខានពុំបានដឹងបែបនេះ។ *ប្រសិនបើបុគ្គលនោះបានដឹង ឬគួរបានដឹង* ប៉ុន្តែដោយសារការធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ *គាត់មិនត្រូវបានអភ័យទោសចំពោះការមិនចាត់វិធានការនោះឡើយ ប្រសិនបើការិយាល័យរបស់គាត់តម្រូវ ឬអនុញ្ញាតឱ្យគាត់ចាត់វិធានការដើម្បីទប់ស្កាត់នូវបទឧក្រិដ្ឋទាំង នោះ*[៨៤៨]។

---

[៨៤៦] តុលាការយោធាអន្តរជាតិសម្រាប់តូក្យូ (តុលាការ IMTFE) *សហរដ្ឋអាមេរិក និងអ្នកផ្សេងទៀត ទល់នឹង Araki និងអ្នកផ្សេងទៀត* "សាលក្រមសំឡេងភាគច្រើន" ថ្ងៃទី ០៤-១២ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញនៅក្នុង Neil Boister and Robert Cryer (eds), *Documents on the Tokyo International Military Tribunal: Charter, Indictment and Judgments*, Oxford, 2008 ("សាលក្រមតុលាការ IMTFE") ទំព័រ 48443-48444។

[៨៤៧] សាលក្រមតុលាការ IMTFE ទំព័រ 48444។

[៨៤៨] សាលក្រមតុលាការ IMTFE ទំព័រ 48444 -48445 (សេចក្តីបញ្ជាក់បន្ថែម)។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00661775



៤៤៥. លើសពីនេះទៀត ទាក់ទិនទៅនឹង ជាពិសេស មេបញ្ជាការកងទ័ពជើងគោក ឬជើងទឹក សាលក្រម តុលាការយោធាអន្តរជាតិចុងបូព៌ា បញ្ជាក់ថា៖

> ប្រសិនបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តប្រឆាំងនឹងអ្នកទោស ក្រោមការត្រួតត្រារបស់ពួកគាត់ *ដែលពួកគាត់បានដឹង ឬគួរបានដឹងជាមុនអំពីភាពអាចកើតមានឡើងនៃបទឧក្រិដ្ឋនោះ* ពួកគាត់ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនោះ។ ឧទាហរណ៍ ប្រសិនបើមានការបង្ហាញថា*ស្ថិតនៅក្នុងអង្គភាពក្រោមការបញ្ជារបស់គាត់* ឧក្រិដ្ឋកម្មសង្គ្រាមដែលមានចែងក្នុងអនុសញ្ញាត្រូវបានប្រព្រឹត្តឡើង *ដោយគាត់បានដឹង ឬគួរបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ* មេបញ្ជាការ*ដែលពុំបានចាត់វិធានការគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ការកើតឡើងនូវឧក្រិដ្ឋកម្មនោះនៅពេលអនាគតនឹងត្រូវ*ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលមាននៅពេលខាងមុខនោះ[៨៤៩]។

៤៤៦. លើសពីនេះទៀត អនុលោមតាមជំពូក X នៃសាលក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ដែលមានចំណងជើងថា "ផ្នែកសំអាងហេតុស្តីពីបទចោទនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចៅក្រមបានអនុវត្តគោលការណ៍ដែលបានចែងក្រោមជំពូក II ទៅលើជនជាប់ចោទដែលជាថ្នាក់លើ នៅពេលធ្វើការសម្រេចអំពីពិរុទ្ធភាពជាលក្ខណៈបុគ្គល ក្រោមបទចោទទី៥៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ បទចោទទី៥៥ បានចោទប្រកាន់ជនជាប់ចោទ "អំពីការមិនគោរពភារកិច្ចស្របច្បាប់របស់ពួកគាត់តាមរយៈការិយាល័យរបស់ពួកគាត់ ក្នុងការចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីធានាឲ្យមានការគោរពច្បាប់ និងទប់ស្កាត់ការរំលោភបំពានច្បាប់ និងទំនៀមទម្លាប់សង្គ្រាម"[៨៥០]។ ដូច្នេះ ចៅក្រមបានផ្តន្ទាទោសឧត្តមសេនីយ៍ Iwane Matsui ដែលជាអគ្គមេបញ្ជាការនៃកងទ័ពប្រចាំប្រទេសចិនប៉ែកកណ្តាល ក្រោមបទចោទទី៥៥ ពាក់ព័ន្ធនឹងអំពើឃោរឃៅដែលកងទ័ពរបស់គាត់បានប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិល ក្នុងអំឡុងពេលការសម្លាប់រង្គាលទ្រង់ទ្រាយធំនៅ "Rape of Nanking"។ ចៅក្រមបានរកឃើញថា Matsui បានទទួលរបាយការណ៍អំពីអំពើឃោរឃៅ និងបានធ្វើការត្រួតពិនិត្យដោយផ្ទាល់ខ្លួនគាត់។ ដូច្នេះ តុលាការ"យល់ឃើញថា Matsui បានដឹងអំពីអ្វីដែលកំពុងកើតឡើង"[៨៥១]។ ទោះបីជាយ៉ាងណាក៏ដោយ "គាត់ពុំបានចាត់វិធានការអ្វីទាំងអស់ ឬពុំមានអ្វីដែលមានប្រសិទ្ធភាពក្នុងការសម្រាលនូវភាពរន្ធត់ទាំងនេះឡើយ [. . .]។ *គាត់មានអំណាច* ដោយគាត់មានភារកិច្ច ដើម្បីត្រួតត្រាកងទ័ពរបស់គាត់ និងដើម្បីការពារពលរដ្ឋទីក្រុង Nanking

[៨៤៩] សាលក្រមតុលាការ IMTFE ទំព័រ 48446។

[៨៥០] សាលក្រមតុលាការ IMTFE ទំព័រ 48424។

[៨៥១] សាលក្រមតុលាការ IMTFE ទំព័រ 49815។

00661776



ដែលទទួលភ័ព្វអាក្រក់។ គាត់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការខកខានពុំបានអនុវត្តភារកិច្ចរបស់គាត់"[៨៩២]។

៨៤៧. ចៅក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ក៏បានរកឃើញផងដែរថា សេនាប្រមុខ Shunroku Hata មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពដែលត្រូវបានបញ្ជូនឲ្យមកធ្វើសង្គ្រាមក្នុងប្រទេសចិនក្នុងឆ្នាំ ១៩៣៨ និងឆ្នាំ ១៩៤១-១៩៤៤ ដោយបានបញ្ជាក់ថា៖

> អំពើឃោរឃៅត្រូវបានប្រព្រឹត្តឡើងជាទ្រង់ទ្រាយធំ ដោយកងទ័ពក្រោមការបញ្ជារបស់គាត់ និងរីករាលដាលអស់រយៈពេលយ៉ាងយូរ។ Hata បានដឹងអំពីអំពើទាំងនេះ និងពុំបានចាត់វិធានការដើម្បីទប់ស្កាត់កុំឲ្យអំពើទាំងនេះកើតឡើងជាថ្មីទៀតឡើយ ឬក៏គាត់មិនអើពើ និងពុំបានចាត់វិធានការដើម្បីឲ្យដឹងថាតើបទបញ្ជាក្នុងការប្រព្រឹត្តប្រកបដោយមនុស្សធម៌លើឈ្លើយសឹក និងជនស៊ីវិល ត្រូវបានគោរពដែរឬយ៉ាងណាឡើយ។ នៅក្នុងករណីណាក៏ដោយ គាត់រំលោភបំពានលើភារកិច្ចរបស់គាត់ ដូចដែលត្រូវបានចោទប្រកាន់ក្រោមបទចោទទី៥៥[៨៩៣]។

៨៤៨. ស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងឧត្តមសេនីយ៍ Heitarō Kimura ដែលជាមេបញ្ជាការកងទ័ពប្រចាំក្នុងប្រទេសភូមា ចាប់ពីឆ្នាំ ១៩៤៤ រហូតដល់ពេលចុះចាញ់កងទ័ពសម្ព័ន្ធមិត្ត ចៅក្រមបានផ្តន្ទាទោសគាត់ក្រោមបទចោទទី៥៥ ពីព្រោះគាត់ត្រូវបានរកឃើញថា បានដឹងអំពីការធ្វើបាបអ្នកទោស ហើយនៅពេលដែលគាត់បានកាន់តួនាទីជាបញ្ជាការកងទ័ពប្រចាំក្នុងប្រទេសភូមា គាត់ពុំបានចាត់វិធានការដាក់វិន័យឲ្យមានប្រសិទ្ធភាព ដើម្បីបញ្ឈប់នូវបទឧក្រិដ្ឋទាំងឡាយឡើយ។ ចៅក្រមយល់ឃើញថា៖

> ភារកិច្ចរបស់មេបញ្ជាការកងទ័ពនៅក្នុងកាលៈទេសៈបែបនេះ មិនត្រូវបានបំពេញតាមរយៈការគ្រាន់តែចេញបទបញ្ជាធម្មតាៗប៉ុណ្ណោះទេ [...] ។ ភារកិច្ចរបស់គាត់គឺត្រូវចាត់វិធានការ និងចេញបទបញ្ជានានា ដែលនឹងទប់ស្កាត់កុំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមបែបនេះលើកក្រោយទៀត និងដើម្បីធ្វើឲ្យគាត់ប្រាកដថា បទបញ្ជាបែបនេះកំពុងតែត្រូវបានអនុវត្ត។ គាត់មិនបានបំពេញភារកិច្ចនេះឡើយ។ ដូច្នេះ គាត់មានចេតនាមិនគោរពភារកិច្ចស្របច្បាប់របស់គាត់ក្នុងការចាត់វិធានការឲ្យបានគ្រប់គ្រាន់ ដើម្បីទប់ស្កាត់នូវការរំលោភបំពានលើច្បាប់

---

[៨៩២] សាលក្រមតុលាការ IMTFE ទំព័រ 49815-49816។ (សេចក្តីបញ្ជាក់បន្ថែម)

[៨៩៣] សាលក្រមតុលាការ IMTFE ទំព័រ 49784។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

សង្គ្រាម[៨៥៤]។

៤៤៩. លើសពីនេះទៀត នៅក្នុងការសម្រេចឲ្យជនជាប់ចោទឧត្តមនាវីឯក Takasumi Oka រួចខ្លួនពីបទចោទ ក្រោមបទចោទទី៥៥ អំពីការទទួលខុសត្រូវចំពោះការធ្វើបាបឈ្លើយសឹក នៅពេលដែលគាត់ជាប្រធានការិយាល័យផ្នែកកងទ័ពជើងទឹក ចាប់ពីខែតុលា ឆ្នាំ ១៩៤០ ដល់ខែ កក្កដា ឆ្នាំ ១៩៤៤ ដែលទទួលបន្ទុកយ៉ាងសំខាន់ចំពោះកិច្ចការគ្រប់គ្រងប្រព័ន្ធដែលពាក់ព័ន្ធជាមួយឈ្លើយសឹក ចៅក្រមបានយកធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត នៅក្នុងការសម្រេចបែបនេះ។ ចៅក្រមរកឃើញថា "មានភស្តុតាងខ្លះបង្ហាញថា Oka បានដឹង ឬគួរបានដឹងថា ឧក្រិដ្ឋកម្មសង្គ្រាមកំពុងត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលិកទ័ពជើងទឹក ប្រឆាំងនឹងឈ្លើយសឹកដែលសុខុមាលភាពរបស់ឈ្លើយសឹកទាំងនោះ គឺជាការទទួលខុសត្រូវរបស់អង្គភាពគាត់ ប៉ុន្តែភស្តុតាងនេះពុំបានឈានទៅដល់កម្រិតនៃបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលធ្វើយុត្តិកម្មចំពោះការផ្តន្ទាទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ[៨៥៥]។

៤៥០. ដូចគ្នានឹងមន្ត្រីយោធាដែរ មន្ត្រីរបស់រដ្ឋាភិបាលជាច្រើននាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសនៅក្រោមបទចោទទី៥៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ ដែលពួកគាត់ជាមន្ត្រីស៊ីវិល ឬក៏មានតួនាទីទាំងផ្នែកយោធា និងទាំងផ្នែកស៊ីវិល។ Kōki Hirota ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុង "ការសម្លាប់រង្គាលក្នុងទីក្រុង Nanjing" នៅចុងទសវត្សរ៍ឆ្នាំ១៩៣០ ដែលក្នុងអំឡុងពេលនោះ គាត់គឺជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស។ តុលាការ IMTFE បានរកឃើញថា គាត់បានដឹងយ៉ាងច្បាស់អំពីព្រឹត្តការណ៍នោះ ពីព្រោះគាត់បានទទួលរបាយការណ៍ជាច្រើនពីប្រភពបរទេសស្តីអំពីអំពើឃោរឃៅនានា ហើយគាត់បានលើកយកបញ្ហានៃការប្រឆាំងជំទាស់របស់អន្តរជាតិទាក់ទិននឹងទីក្រុង Nanjing មកពិភាក្សានៅចំពោះមុខគណៈរដ្ឋមន្ត្រី[៨៥៦]។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានសម្រេចថា គាត់មិនគួរផ្អែកតែទៅលើការអះអាងបញ្ជាក់ពីក្រសួងការពារជាតិ ដែលថាពួកគាត់នឹងមិនបន្តសកម្មភាពទៀតនោះឡើយ[៨៥៧]

[៨៥៤] សាលក្រមតុលាការ IMTFE ទំព័រ 49809។

[៨៥៥] សាលក្រមតុលាការ IMTFE ទំព័រ 49822។

[៨៥៦] សាលក្រមតុលាការ IMTFE ទំព័រ 49791។

[៨៥៧] សាលក្រមតុលាការ IMTFE ទំព័រ 49791។

ហើយតុលាការ "យល់ឃើញថា Hirota ធ្វេសប្រហែស នៅក្នុងភារកិច្ចរបស់គាត់ដោយមិនបានទទូចនៅចំពោះមុខគណៈរដ្ឋមន្ត្រីឱ្យចាត់វិធានការជាបន្ទាន់ដើម្បីបញ្ឈប់អំពើឃោរឃៅឡើយ។ ការខកខានពុំបានចាត់វិធានការណាមួយ ដែលនៅមានសម្រាប់គាត់ នឹងនាំឱ្យគាត់ទទួលបានលទ្ធផលដូចគ្នា"[៨៥៨]។

៨៥១. លើសពីនេះទៀត Mamoru Shigemitsu ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម ទាក់ទិននឹងការធ្វើបាបអ្នកទោស និងអ្នកជាប់ឃុំឃាំងជាជនស៊ីវិល ក្នុងអំឡុងអាណត្តិរបស់គាត់ជារដ្ឋមន្ត្រីការបរទេស។ ស្រដៀងគ្នាទៅនឹងករណី Hirota ដែរ តុលាការ IMTFE បានរកឃើញថា គាត់បានទទួលព័ត៌មានពីរដ្ឋាភិបាលបរទេសស្តីអំពីការធ្វើបាបនេះ ចាប់ពីឆ្នាំ១៩៤៣ ដល់ឆ្នាំ១៩៤៥[៨៥៩]។ តុលាការសម្រេចថា គាត់ ៖

> ពុំបានចាត់វិធានការគ្រប់គ្រាន់ដើម្បីស៊ើបអង្កេតទៅលើបញ្ហានោះឡើយ ក្នុងនាមជាសមាជិកម្នាក់របស់រដ្ឋាភិបាល ទោះបីជាគាត់មានការទទួលខុសត្រូវជាទូទៅចំពោះសុខុមាលភាពរបស់អ្នកទោសយ៉ាងណាក៏ដោយ។ គាត់គួរតែបានចាត់វិធានការដោះស្រាយបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយតាមដែលគាត់អាចធ្វើបាន ដើម្បីរំដោះខ្លួនគាត់ឱ្យរួចផុតពីការទទួលខុសត្រូវ ដែលគេសង្ស័យថាជាបន្ទុករបស់គាត់ ហើយប្រសិនបើក្នុងករណីចាំបាច់គាត់ត្រូវលាលែងចេញពីតំណែងនោះ[៨៦០]។

៨៥២. ករណីមួយទៀត នាយករដ្ឋមន្ត្រីឧត្តមសេនីយ៍ Kuniaki Koiso ត្រូវបានដាក់ឱ្យទទួលខុសត្រូវក្រោមបទចោទទី៥៥ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងឈ្លើយសឹក។ តុលាការកត់សម្គាល់ថា នៅពេលដែលឧត្តមសេនីយ៍ Koiso ធ្វើជានាយករដ្ឋមន្ត្រីចាប់ពីឆ្នាំ ១៩៤៤ ដល់ឆ្នាំ ១៩៤៥ ការធ្វើបាបអ្នកទោសមានលក្ខណៈរីករាលដាលយ៉ាងខ្លាំង រហូតដល់កម្រិតមួយ "មិនគួរឱ្យជឿ" បានឡើយថា គាត់មិនបានដឹងអំពីអំពើនោះ[៨៦១]។ លើសពីនេះទៀត តុលាការរកឃើញថា បន្ទាប់ពីកិច្ចប្រជុំមួយក្នុងឆ្នាំ ១៩៤៤ ដែលរដ្ឋមន្ត្រីការបរទេសបានធ្វើសេចក្តីរាយការណ៍ស្តីពីព័ត៌មានដែលទទួលបានពីប្រភពនានា អំពីការធ្វើបាបអ្នកទោសពីសំណាក់ប្រទេសជប៉ុន

---

[៨៥៨] សាលក្រមតុលាការ IMTFE ទំព័រ 49471។

[៨៥៩] សាលក្រមតុលាការ IMTFE ទំព័រ 49829-49830។

[៨៦០] សាលក្រមតុលាការ IMTFE ទំព័រ 49831។

[៨៦១] សាលក្រមតុលាការ IMTFE ទំព័រ 49813។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

"Koiso នៅបន្តធ្វើជានាយករដ្ឋមន្ត្រីរយៈពេលប្រាំមួយខែ ដែលក្នុងអំឡុងពេលនោះការប្រព្រឹត្តមកលើអ្នកទោស និងអ្នកជាប់ឃុំឃាំងពីសំណាក់ជនជាតិជប៉ុន ពុំបានបង្ហាញឱ្យឃើញនូវលក្ខណៈល្អប្រសើរអ្វីឡើយ។ ប្រការនេះ គឺជាការមិនគោរពភារកិច្ចដោយចេតនា"[៨៦២]។

៤៩៣. មានការកត់សម្គាល់ថា តុលាការ IMTFE បានពិចារណាលើបទចោទប្រឆាំងនឹងមន្ត្រីស៊ីវិលជាន់ខ្ពស់ផងទៃទៀត ក្រោមបទចោទទី៥៥ និងបានសម្រេចឱ្យពួកគាត់រួចខ្លួនពីបទចោទក្នុងនាមជាថ្នាក់លើ។ ឧទាហរណ៍ Hiranuma Kiichirō ដែលជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ ១៩៣៩ និងក្រោយមកជារដ្ឋមន្ត្រីសន្តិសុខសង្គមនៃព្រះបរមរាជវាំងនៃប្រទេសជប៉ុន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមក្រោមបទចោទទី៥៥។ គាត់ត្រូវបានសម្រេចឱ្យរួចខ្លួនពីបទចោទ ដោយសារតែតុលាការយល់ឃើញថា ពុំមានភស្តុតាងដែលភ្ជាប់រូបគាត់ដោយផ្ទាល់ទៅនឹងបទឧក្រិដ្ឋឡើយ[៨៦៣]។ ឧទាហរណ៍មួយទៀត គឺ Kōichi Kido ដែលជា មន្ត្រីជាន់ខ្ពស់នៃបរមរាជវាំង ចាប់ពីឆ្នាំ១៩៤០ ដល់ឆ្នាំ១៩៤៥ ដែលត្រូវបានសម្រេចឱ្យរួចខ្លួនពីការចោទប្រកាន់ក្រោមបទចោទទី៥៥ ពីព្រោះទោះបីជាគាត់ត្រូវបានរកឃើញថាជាសមាជិកម្នាក់របស់គណៈរដ្ឋមន្ត្រីក្នុងអំឡុងពេលការសម្លាប់រង្គាលក្នុងទីក្រុង Nanjing យ៉ាងណាក៏ដោយ "ក៏មិនមានភស្តុតាងគ្រប់គ្រាន់ឡើយដើម្បីភ្ជាប់រូបគាត់ទៅនឹងការទទួលខុសត្រូវ ចំពោះការខកខានពុំបានទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាម"[៨៦៤]។

៤៩៤. ក្នុងការពិចារណាជាពិសេសលើសាលក្រមរឿងក្តី *Yamashita* អង្គបុរេជំនុំជម្រះកត់សម្គាល់ថា រូបភាពនៃធាតុផ្សំរបស់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលចៅក្រមបានគូសបញ្ជាក់នៅក្នុងជំពូក II នៃសាលក្រមរបស់តុលាការ IMTFE ឬការអនុវត្តរូបភាពនៃធាតុផ្សំទាំងនោះនៅក្នុងជំពូក X ទៅលើជនជាប់ចោទជាក់លាក់ ពុំមានការអភិវឌ្ឍដូចនិយមន័យនៃទ្រឹស្តីនាពេលបច្ចុប្បន្នដែលមាននៅក្នុងយុត្តិសាស្ត្រអន្តរជាតិឡើយ។ នេះគឺជាការពិត ទាក់ទិននឹងលក្ខខណ្ឌនៃទំនាក់ទំនងថ្នាក់លើ និងអ្នកក្រោមបង្គាប់ដែលមានការត្រួតត្រាប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅក្នុងបរិបទថ្នាក់លើដែលពុំមែនជាយោធា នៅពេលដែលសាលក្រមពុំបានបញ្ជាក់នូវសំអាងហេតុឱ្យបានច្បាស់ដែលបង្ហាញអំពីទំនាក់ទំនងបែបនោះ ប៉ុន្តែទំនងជាធ្វើការសន្និដ្ឋាន ដោយផ្អែកលើតួនាទីខ្ពស់របស់ជន

---

[៨៦២] សាលក្រមតុលាការ IMTFE ទំព័រ 49813។

[៨៦៣] សាលក្រមតុលាការ IMTFE ទំព័រ 49787។

[៨៦៤] សាលក្រមតុលាការ IMTFE ទំព័រ 49805-49806។

ជាប់ចោទ ហើយគ្រាន់តែយោងទៅលើ "*[ការ]*ខកខានពុំបានចាត់វិធានការដែល*ស្ថិតក្នុងអំណាចរបស់ពួកគាត់* ដើម្បីទប់ស្កាត់" នៅក្នុងជំពូក II។ ដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាថា តុលាការ IMTFE មិនមែនជាតុលាការដែលត្រូវយកមកធ្វើជាសំអាងចុងក្រោយឡើយ ទាក់ទិនទៅនឹងថា តើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពង្រីកវិសាលភាពទៅដល់ថ្នាក់លើដែលពុំមែនជាយោធាឬយ៉ាងណា ពីព្រោះតុលាការនេះពុំបានបញ្ជាក់សំអាងហេតុដែលទាក់ទិននឹងចំណុចសំខាន់នៃទ្រឹស្តីថាតើមានទំនាក់ទំនងថ្នាក់លើនិងអ្នកក្រោមបង្គាប់ *ជាក់ស្តែង* ឬ*ស្របច្បាប់* ដែរឬទេ រវាងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកយោធាដែលជាប់ពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ។

៤៥៥. ចំពោះថ្នាក់លើជាយោធា សាលក្រមសំដៅយ៉ាងច្បាស់ទៅលើ "អង្គភាពក្រោម [...] ការបញ្ជា" ប៉ុន្តែជាថ្មីម្តងទៀត សាលក្រមហាក់ដូចជាធ្វើការសន្និដ្ឋានអំពីការត្រួតត្រា ដែលមានប្រសិទ្ធភាពដោយផ្អែកទៅលើទំនាក់ទំនង*ស្របច្បាប់ (de jure)* លើកលែងតែរឿងក្តីឧត្តមសេនីយ៍ Matsui។ លើសពីនេះទៀត "ការខកខានពុំបានដាក់ទោសទណ្ឌ" *ធាតុផ្សំសត្យានុម័ត* មិនត្រូវបានបញ្ចូលឱ្យបានច្បាស់លាស់ នៅក្នុងនិយមន័យឡើយ ទោះបីជាការខកខានពុំបានចាត់ "វិធានការគ្រប់គ្រាន់ដើម្បីទប់ស្កាត់កុំឱ្យបទឧក្រិដ្ឋបែបនោះកើតឡើងជាថ្មីទៀតនៅពេលអនាគត" អាចត្រូវបានគេបកស្រាយ ដើម្បីបញ្ចូលជាការដាក់ទោសទណ្ឌយ៉ាងណាក៏ដោយ។ ជាចុងក្រោយ ស្រដៀងគ្នាទៅនឹងរឿងក្តី *Yamashita* ដែរ *ធាតុផ្សំអត្តនោម័ត*ដែលតម្រូវឱ្យមាន រួមបញ្ចូលយ៉ាងទូលំទូលាយនូវបទដ្ឋាននៃការធ្វេសប្រហែស បន្ថែមទៅលើការដឹងពិតប្រាកដនិងតាមការសន្មត។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា សាលក្រមរបស់តុលាការ IMTFE នៅពេលអានសាលក្រមទាំងមូលបញ្ជាក់យ៉ាងគ្រប់គ្រាន់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល នៅក្នុងផ្នែកសម្រេចសេចក្តី និងផ្នែកច្បាប់ជាធរមានរបស់សាលក្រមនេះ។

៤៥៦. ចុងក្រោយ នៅក្នុងការជំនុំជម្រះទោសឧត្តមនាវីឯក Soemu Toyoda ក្នុងឆ្នាំ ១៩៤៨-១៩៤៩ ដែលគាត់ជាអតីតអគ្គមេបញ្ជាការកងនាវារួមជប៉ុន (Japanese Combined Fleet) កងទ័ពជើងទឹករួម (Combined Naval Forces) និងបញ្ជាការដ្ឋានអមកងទ័ពជើងទឹក (Naval Escort Command) ចាប់ពីថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៤៤ ដល់ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៤៥ ដែលជាការជំនុំជម្រះក្តីមួយ ក្នុងចំណោមការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមដ៏ធំចុងក្រោយ ដែលត្រូវបានបញ្ចប់ក្រោយ

សង្គ្រាមលោកលើកទីពីរ តុលាការយោធាអាមេរិក/អូស្ត្រាលីបានលើកនូវបញ្ហានៃការទទួលខុសត្រូវរបស់ថ្នាក់លើ បន្ទាប់ពីពិនិត្យឡើងវិញនូវការជំនុំជម្រះក្តីអន្តរជាតិដទៃទៀតមុនតុលាការនេះ។ តុលាការបានកំណត់ធាតុផ្សំសំខាន់នៃទ្រឹស្តី ដូចខាងក្រោម ៖

> ១. ថា អំពើឃោរឃៅត្រូវបានប្រព្រឹត្តឡើងពិតប្រាកដ ២. ការដឹងអំពីការប្រព្រឹត្តអំពើឃោរឃៅ។ ការដឹងនេះអាច ៖ ក. ពិតប្រាកដ [...] ឬ ខ. តាមការសន្និត [...] ៣. អំណាចបញ្ជា។ គឺថាត្រូវតែមានការបង្ហាញថាជនជាប់ចោទមានអំណាចពិតប្រាកដលើអ្នកប្រព្រឹត្តបទល្មើស ក្នុងការចេញបញ្ជាដល់ពួកគេកុំឱ្យប្រព្រឹត្តអំពើខុសច្បាប់ និងដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើស។ ៤. ការ ខកខានពុំបានចាត់វិធានការសមស្របដែលស្ថិតក្នុងអំណាចរបស់គាត់ ដើម្បីត្រួតត្រាកងទ័ពក្រោមបញ្ជារបស់គាត់ និងដើម្បីទប់ស្កាត់នូវអំពើទាំងឡាយ ដែលជាការរំលោភច្បាប់សង្គ្រាម។ ៥. ការខកខានពុំបានដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើស[៨៦៥]។

៤៩៧. នៅក្នុងការសម្រេចឱ្យឧត្តមនាវីឯក Toyoda រួចខ្លួនពីបទចោទអំពីអំពើឃោរឃៅដែលប្រព្រឹត្តដោយបុគ្គលិកទ័ពជើងទឹក តុលាការបានកត់សម្គាល់ថា ៖

> ពិរុទ្ធភាពរបស់គាត់មិនអាច [គ្រាន់តែ] ត្រូវបានកំណត់តាមរយៈថាតើ គាត់មានការបញ្ជាផ្នែកប្រតិបត្តិការ ការបញ្ជាផ្នែករដ្ឋបាល ឬទាំងពីរផ្នែកប៉ុណ្ណោះទេ។ ប្រសិនបើគាត់បានដឹង ឬគួរបានដឹង តាមរយៈការយកចិត្តទុកដាក់ដ៏សមហេតុផលនូវការប្រព្រឹត្តអំពើឃោរឃៅពីសំណាក់កងទ័ពរបស់គាត់ ហើយប្រសិនបើគាត់ពុំបានចាត់វិធានការគ្រប់យ៉ាងក្រោមអំណាច និងសមត្ថភាពរបស់គាត់នៅក្នុងកាលៈទេសៈជាធរមាន ដើម្បីទប់ស្កាត់កុំឱ្យអំពើឃោរឃៅទាំងនោះកើតឡើងជាថ្មីទៀត និងដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើសទាំងនោះ គឺគាត់ធ្វេសប្រហែសក្នុងភារកិច្ចរបស់គាត់[៨៦៦]។

៤៩៨. ផ្អែកលើមូលដ្ឋានដែលបានលើកឡើងពីខាងលើ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើដូចដែលបានបញ្ជាក់ច្បាស់ក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។ ទោះបីជាការបញ្ជាក់ច្បាស់អំពីធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្តីមិនមែនតែងតែច្បាស់លាស់ ឬពេញលេញ តាមការយល់អំពីធាតុផ្សំទាំងនោះនាពេលបច្ចុប្បន្ន ហើយការអនុវត្តធាតុផ្សំទាំងអស់នោះ ចំពោះអង្គហេតុជាក់លាក់នៅក្នុងរឿងក្តី

[៨៦៥] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Soemu Toyoda* ប្រតិចារឹកផ្លូវការនៃកំណត់ហេតុសវនាការ 5005, 5006។

[៨៦៦] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Soemu Toyoda* ប្រតិចារឹកផ្លូវការនៃកំណត់ហេតុសវនាការ 5005, 5006។

ក្រោយសង្គ្រាមលោកលើកទី២ ជួនកាលមិនស៊ីសង្វាក់គ្នា និងមិនពេញលេញយ៉ាងណាក៏ដោយ គោលការណ៍ដែលថាថ្នាក់លើអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តឡើង ដោយអ្នកនៅក្រោមបង្គាប់ ប្រសិនបើមានទំនាក់ទំនងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ដោយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ធាតុផ្សំអត្តនោម័តនៃការដឹងពិតប្រាកដ ឬដឹងតាមការសន្មត និងធាតុផ្សំសត្យានុម័តនៃការខកខានត្រូវបានបង្ហាញឡើង។

៤៥៩. លើសពីនេះទៀត ទិដ្ឋភាពទូទៅនេះបង្ហាញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានយល់ឃើញថា មិនកំណត់តែចំពោះមេបញ្ជាការយោធាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានគ្របដណ្តប់ដល់ថ្នាក់លើដែលមិនមែនជាយោធាផងដែរ។ ហេតុដូច្នេះ យុត្តិសាស្ត្រនេះបង្ហាញថា លក្ខណៈពិតប្រាកដនៃតួនាទី ឬមុខងាររបស់នរណាម្នាក់ដែលជាថ្នាក់លើ និងបញ្ហាថាតើ *តាមផ្លូវច្បាប់ (de jure)* ឬ *តាមហេតុការណ៍ពិត (de facto)* មិនសូវមានលក្ខណៈសំខាន់ស្មើនឹងកម្រិតនៃការបញ្ជា ឬការអនុញ្ញាតដែលបានធ្វើលើអ្នកនៅក្រោមបង្គាប់ឡើយ។ ដូចនេះ បញ្ហានេះគឺសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់អំពីតួនាទីពិតប្រាកដ និងអំពីកម្រិតនៃការគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរចនាសម្ព័ន្ធនៃរបបខ្មែរក្រហមស្របតាមអង្គហេតុនៃរឿងក្តីនេះ ហើយផ្អែកលើមូលដ្ឋាននេះ ថាតើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តចំពោះជនជាប់ចោទទាំងនោះ ឬមិនអនុវត្ត។

៤៦០. ហេតុដូច្នេះ ផ្អែកលើមូលដ្ឋានដែលបានលើកឡើងពីខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹង អៀង សារី មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ដោយគិតអំពីយុត្តិសាស្ត្រអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២ ដែលបានលើកឡើងខាងលើ និងលក្ខណៈធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនានា អៀង សារី អាចដឹងជាមុនថាជាបទឧក្រិដ្ឋ និងអាចដឹងថាមានច្បាប់ចែងថា ខ្លួនអាចនឹងត្រូវបានផ្តន្ទាទោសក្នុងនាមជាថ្នាក់លើម្នាក់មិនថាជាយោធា ឬមិនមែនជាយោធានោះទេ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួនពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ ហេតុនេះ មូលដ្ឋានទី១១ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ត្រូវបានបដិសេធ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

## ខ. សំអាងហេតុសម្រាប់ការឃុំខ្លួន÷

៨៦១. នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសំអាងហេតុចំពោះសេចក្ដីសម្រេចរបស់ខ្លួននៅក្នុងចំណុចទី១១ នៃសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍[៨៦៧]។ សំអាងហេតុទាំងនេះមានដូចខាងក្រោម ៖

"**ការរក្សាការឃុំខ្លួនបណ្ដោះអាសន្នជនជាប់ចោទ ÷ សំអាងហេតុ**

៤. អនុលោមតាមអនុវិធាន៦៨(២) នៅពេលបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនថាលក្ខណៈនៃបណ្ដឹងឧទ្ធរណ៍នោះយ៉ាងណាទេ "អានុភាពនៃដីកាឃុំខ្លួន ឬដីកាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តរហូតដល់មានសេចក្ដីសម្រេចពីអង្គបុរេជំនុំជម្រះ"។

៥. ជាបន្ថែមទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដែលជាកម្មវត្ថុនៃការចេញសេចក្ដីសម្រេចនេះ ជនជាប់ចោទបានដាក់បណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែកមួយ ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្ដោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ("បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្ដោះអាសន្នត្រូវបានបដិសេធចោលនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ដោយហេតុនោះ អង្គបុរេជំនុំជម្រះបានប្រកាសសេចក្ដីសម្រេចជាស្ថាពរលើបណ្ដឹងឧទ្ធរណ៍នេះ និងបានប្រកាសឱ្យបានដឹងជាមុនថា សេចក្ដីសម្រេចដែលមានសំអាងហេតុចំពោះបណ្ដឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមពេលវេលាសមស្រប។ សំអាងហេតុទាំងឡាយសម្រាប់សេចក្ដីសម្រេចនេះ ត្រូវបានផ្ដល់រួចហើយក្នុងថ្ងៃនេះ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានពន្យល់ហេតុដែលបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្ដោះអាសន្នបានខកខានបង្ហាញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅក្នុងការចេញដីកាសម្រេចរបស់ខ្លួន ដើម្បីរក្សាជនជាប់ចោទនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានកាលៈទេសៈពិសេសណាមួយ ចាប់តាំងពីការចេញដីកាដំណោះស្រាយដោយសហចៅក្រមស៊ើបអង្កេត ក្រៅពីការអះអាងលើការបញ្ជូនរឿងទៅជំនុំជម្រះពីអង្គបុរេជំនុំជម្រះ ដែលធ្វើឱ្យរឹងមាំពីមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយវាក៏ធ្វើឱ្យរឹងមាំផងដែរពីភាពចាំបាច់ ដើម្បីរក្សាគាត់ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បី

---

[៨៦៧] សំអាងហេតុសម្រាប់ការបន្តឃុំខ្លួន។

ធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុដែលផ្តល់ឲ្យដោយសហចៅក្រមស៊ើបអង្កេត ដើម្បីបង្គាប់ថា ជនជាប់ចោទនៅតែស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដែលអង្គជំនុំជម្រះយកតាមមានយុត្តិកម្មថា អង្គជំនុំជម្រះបង្គាប់ថា ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នត្រូវបានបង្គាប់ឲ្យបន្តចិរវេលារហូតដល់ពេល ដែលជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៦៨(៣)[៨៦៨]។

៤៦២. អាស្រ័យហេតុនេះ ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះបានសម្រេច ដូចដែលបានប្រកាសនៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១១។

អនុលោមតាមវិធានផ្ទៃក្នុង ៧៧(១៣) សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **ន័យ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

**សរ ចំន្នរ៉ាត** **Entela JOSIFI**

[៨៦៨] សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៤-៦។